

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ទីឃនិកាយ បញ្ចមភាគ
# បាដិកវគ្គ
# ១៨

បាដិកសូត្រ ឧទុម្ពរិកសូត្រ

ចក្កវត្តិសូត្រ អគ្គញ្ញសូត្រ សម្បសាទនីយសូត្រ

និង បាសាទិកសូត្រ

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៥០៣

# សុត្តន្តបិដកេ ទីឃនិកាយស្ស

## បញ្ចមោ ភាគោ

---

## បាដិកវគ្គោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### បាដិកសុត្តំ(១) បឋមំ

(១) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា មល្លេសុ វិហរតិ អនុបិយំ នាម មល្លានំ និគមោ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អនុបិយំ បិណ្ឌាយ បាវិសិ ។ អថខោ ភគវតោ ឯតទហោសិ អតិប្បគោ ខោ តាវ អនុបិយាយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន ភគ្គវគោត្តស្ស បរិព្វាជកស្ស អារាមោ យេន ភគ្គវគោត្តោ បរិព្វាជកោ តេនុបសង្កមេយ្យន្តិ ។ អថខោ ភគវា យេន ភគ្គវគោត្តស្ស បរិព្វាជកស្ស អារាមោ យេន ភគ្គវគោត្តោ បរិព្វាជកោ តេនុបសង្កមិ ។

---

១ ខ. បាដិកសុត្តំ ។ ម. បាថិកសុត្តំ ។

# សុត្តន្តបិដក ទីឃនិកាយ

## បញ្ចមភាគ

---

## បាដិកវគ្គ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

### បាដិកសូត្រ ទី ១

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យ ១ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអនុប្បិយនិគម របស់ពួកមល្លជន ក្នុងមល្លជនបទ ។ គ្រានោះឯង វេលាព្រឹកព្រហាម ព្រះមានព្រះភាគ ទ្រង់ស្បង់ទ្រង់បាត្រចីវរ ទ្រង់ពុទ្ធដំណើរចូលទៅបិណ្ឌបាត ក្នុងអនុប្បិយនិគម ។ ពេលនោះឯង ព្រះមានព្រះភាគ មានព្រះតម្រិះយ៉ាងនេះថា ការចូលទៅបិណ្ឌបាត ក្នុងអនុប្បិយនិគម ក៏នៅព្រឹកពេកណាស់ បើដូច្នោះគួរតែតថាគតចូលទៅរកបរិព្វាជក ជាភគ្គវគោត្រ ក្នុងអារាមនៃបរិព្វាជក ជាភគ្គវគោត្រសិន ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចូលទៅរកបរិព្វាជក ជាភគ្គវគោត្រ ក្នុងអារាមនៃបរិព្វាជក ជាភគ្គវគោត្រ ។

អថខោ ភគ្គវគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច
ឯតុ ខោ ភន្តេ ភគវា ស្វាគតំ(១) ភន្តេ ភគវតោ ចិរស្សំ
ខោ ភន្តេ ភគវា ឥមំ បរិយាយមកាសិ យទិទំ ឥធាគ-
មនាយ និសីទតុ ភន្តេ ភគវា ឥទមាសនំ បញ្ញត្តន្តិ ។
និសីទិ ភគវា បញ្ញត្តេ អាសនេ ។ ភគ្គវគោត្តោបិ ខោ
បរិព្វាជកោ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភគ្គវគោត្តោ បរិព្វា-
ជកោ ភគវន្តំ ឯតទវោច បុរិមានិ ភន្តេ ទិវសានិ បុរិមត-
រានិ សុនក្ខត្តោ លិច្ឆវិបុត្តោ យេនាហំ តេនុបសង្កមិ
ឧបសង្កមិត្វា មំ ឯតទវោច បច្ចក្ខាតោទានិ មយា ភគ្គវ
ភគវា នទានាហំ ភគ្គវ ភគវន្តំ ឧទ្ទិស្ស វិហរាមីតិ កច្ចិ ឯ-
តំ ភន្តេ តថេវ យថា សុនក្ខត្តោ លិច្ឆវិបុត្តោ អវចាតិ ។

១ ឱ. សាគតំ ។

ពេលនោះឯង ភគ្គវគោត្របរិព្វាជក បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ស្តេចមក បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ស្តេចមកល្អហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ធ្វើនូវបរិយាយនេះ ដើម្បីនិមន្តមកក្នុងទីនេះ អស់កាលយូរហើយ[១] បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានបុណ្យស្តេចគង់ នេះឯងជាអាសនៈ ដែលខ្ញុំព្រះអង្គក្រាលបម្រុងទុក ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈ ដែលបរិព្វាជកបានក្រាលទុក ។ ចំណែកខាង ភគ្គវគោត្របរិព្វាជក បានកាន់យកអាសនៈដ៏ទាបមួយ អង្គុយក្នុងទីសមគួរ ។ លុះភគ្គវគោត្របរិព្វាជក អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន កាលពីថ្ងៃមុន យូរថ្ងៃណាស់មកហើយ លិច្ឆវីបុត្រឈ្មោះសុនក្ខត្តៈ បានចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏និយាយនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រអ្នកជាភគ្គវគោត្រ ឥឡូវនេះ ខ្ញុំបោះបង់ព្រះមានព្រះភាគហើយ បពិត្រអ្នកជាភគ្គវគោត្រ ឥឡូវនេះ ខ្ញុំមិនបាននៅពឹងផ្អែក នឹងព្រះមានព្រះភាគទេ បពិត្រព្រះអង្គដ៏ចំរើន សុនក្ខត្តលិច្ឆវីបុត្រ បានក្រាបទូលព្រះអង្គយ៉ាងនុ៎ះមែនឬទេ ។

---

១ បានសេចក្តីថា ព្រះអង្គខាននិមន្តមក ក្នុងទីនេះយូរណាស់ហើយ ។

## បាដិកសុត្តេ សុនក្ខត្តវត្ថុ ភគវតោ បច្ចក្ខានកថា

តថេវ ខោ ឯតំ ភគ្គវ យថា សុនក្ខត្តោ លិច្ឆវិបុត្តោ អវច បុរិមានិ ភគ្គវ ទិវសានិ បុរិមតរានិ សុនក្ខត្តោ លិច្ឆវិបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ មំ ឯតទវោច បច្ចក្ខាមិទានាហំ ភន្តេ ភគវន្តំ នទានាហំ ភន្តេ ភគវន្តំ ឧទ្ទិស្ស វិហរិស្សាមីតិ ។ ឯវំ វុត្តេ អហំ ភគ្គវ សុនក្ខត្តំ លិច្ឆវិបុត្តំ ឯតទវោចំ អបិ នុ តាហំ(១) សុនក្ខត្ត ឯវំ អវចំ(២) ឯហិ ត្វំ សុនក្ខត្ត មមំ ឧទ្ទិស្ស វិហរាហីតិ ។ នោ ហេតំ ភន្តេ ។ ត្វំ វា បន មំ ឯវំ អវច អហំ ភន្តេ ភគវន្តំ ឧទ្ទិស្ស វិហរិស្សាមីតិ ។ នោ ហេតំ ភន្តេ ។

---

១ ម. អបិ នូនាហំ ។ ២ ឯវំ អវចន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ព្រះមានព្រះភាគត្រាស់តបថា ម្នាលភគ្គវគោត្រ សុនក្ខត្តលិច្ឆវិបុត្រ បាននិយាយពាក្យនុ៎ះ យ៉ាងនោះមែន ម្នាលភគ្គវគោត្រ កាលពីថ្ងៃមុនយូរថ្ងៃណាស់មកហើយ សុនក្ខត្តលិច្ឆវិបុត្របានចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីដ៏សមគួរ ។ ម្នាលភគ្គវគោត្រ លុះសុនក្ខត្តលិច្ឆវិបុត្រអង្គុយក្នុងទីដ៏សមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គសូមលាព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គនឹងលែងនៅពឹងផ្អែក នឹងព្រះមានព្រះភាគហើយ ។ ម្នាលភគ្គវគោត្រ កាលសុនក្ខត្តលិច្ឆវិបុត្រ និយាយយ៉ាងនេះហើយ តថាគតក៏បាននិយាយទៅនឹងសុនក្ខត្តលិច្ឆវិបុត្រ យ៉ាងនេះវិញថា ម្នាលសុនក្ខត្តៈ ចុះតថាគតមានបាននិយាយនឹងអ្នកយ៉ាងនេះថា នែសុនក្ខត្តៈ អ្នកចូរមកនៅពឹងផ្អែកនឹងតថាគតចុះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គនឹងបានមានព្រះបន្ទូលយ៉ាងនុ៎ះ នឹងខ្ញុំព្រះអង្គក៏ទេដែរ ។ តថាគតបានសួរតទៅទៀតថា ចុះអ្នកបាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែក នឹងព្រះមានព្រះភាគដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងបានក្រាបទូលយ៉ាងនុ៎ះ ចំពោះព្រះអង្គក៏ទេ ។

ឥតិ កិរ សុនក្ខត្ត នេវាហន្តំ វទាមិ ឯហិ ត្វំ សុនក្ខត្ត មមំ ឧទ្ទិស្ស វិហរាហីតិ នបិ កិរ មំ ត្វំ វទេសិ អហំ ភន្តេ ភគវន្តំ ឧទ្ទិស្ស វិហរិស្សាមីតិ ឯវំ សន្តេ មោឃបុរិស កោ សន្តោ កំ បច្ចាចិក្ខសិ(១) បស្ស មោឃបុរិស យាវញ្ច តេ ឥទំ អបរទ្ធំ ។

(២) ន ហិ បន មេ ភន្តេ ភគវា ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករោតីតិ ។ អបិ នុ តាហំ សុនក្ខត្ត ឯវំ អវចំ ឯហិ ត្វំ សុនក្ខត្ត មមំ ឧទ្ទិស្ស វិហរាហិ អហំ តេ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សាមីតិ ។ នោ ហេតំ ភន្តេ ។

---

១ កត្ថចិ ពោត្ថកេ បច្ចាចិក្ខសីតិ បាឋោ ទិស្សតិ ។

តថាគតបាននិយាយទៀតថា នែសុនក្ខត្ត: តថាគតក៏ឥតបាននិយាយនឹងអ្នកថា ម្នាលសុនក្ខត្ត: អ្នកចូរមកនៅពឹងផ្អែក នឹងតថាគតចុះ ដូច្នេះទេ ចំណែកអ្នក ក៏មិនបាននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែក នឹងព្រះមានព្រះភាគ ដូច្នេះដែរ ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះមានហើយ អ្នកឯងជាអ្នកជាទុក្ខ ពោលលាអ្នកណា ម្នាលមោឃបុរស ចូរអ្នកមើលចុះ អំពើនេះ ជាកំហុសរបស់អ្នកហើយ ។

(២) សុនក្ខត្តលិច្ឆវីបុត្រ បាននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ព្រោះព្រះមានព្រះភាគ មិនដែលបានធ្វើឥទ្ធិបាដិហារិយ៍[1] ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស[2]ឲ្យដល់ខ្ញុំព្រះអង្គសោះ ។ តថាគតក៏បាននិយាយថា ម្នាលសុនក្ខត្ត: ចុះតថាគតបាននិយាយនឹងអ្នកយ៉ាងនេះថា ម្នាលសុនក្ខត្ត: ចូរអ្នកមកនៅពឹងផ្អែក នឹងតថាគតចុះ តថាគតនឹងធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សឲ្យដល់អ្នកដូច្នេះដែរឬ ។ សុនក្ខត្តលិច្ឆវីបុត្រ ក៏ឆ្លើយតបមកថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គនឹងបានមានព្រះបន្ទូលយ៉ាងនុ៎ះ នឹងខ្ញុំព្រះអង្គក៏ទេ ។

---

១ បាដិហារិយ៍កើតអំពីឫទ្ធិ ហៅថាឥទ្ធិបាដិហារិយ៍ ។ ២ សីល ៥ និងសីល ១០ ឈ្មោះថា ជាធម៌របស់មនុស្ស ។ អដ្ឋកថា ។

ត្វំ វា បន(១) មំ ឯវំ អវច អហំ ភន្តេ ភគវន្តំ ឧទ្ទិស្ស វិហរិស្សាមិ ភគវា មេ ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ករិស្សតីតិ ។ នោ ហេតំ ភន្តេ ។ ឥតិ កិរ សុនក្ខត្ត នេវាហំ វទាមិ ឯហិ ត្វំ សុនក្ខត្ត មមំ ឧទ្ទិស្ស វិហរាហិ អហន្តេ ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ករិស្សាមីតិ នបិ កិរ មំ ត្វំ វទេសិ អហំ ភន្តេ ភគវន្តំ ឧទ្ទិស្ស វិហរិស្សាមិ ភគវា មេ ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ករិស្សតីតិ ឯវំ សន្តេ មោឃបុរិស កោ សន្តោ កំ បច្ចាចិក្ខសិ ។ តំ កឹ មញ្ញសិ សុនក្ខត្ត កតេ វា ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយេ អកតេ វា ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយេ យស្សត្ថាយ មយា ធម្មោ ទេសិតោ

---

១ ត្វញ្ច បនាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

តថាគតក៏សួរទៅទៀតថា ចុះអ្នកបាននិយាយនឹងតថាគត យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែក នឹងព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស ឲ្យដល់ខ្ញុំដូច្នេះដែរឬ ។ សុនក្ខត្តលិច្ឆវីបុត្រក៏ឆ្លើយតបថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបាននិយាយយ៉ាងនោះ នឹងព្រះអង្គក៏ទេ ។ តថាគតក៏និយាយទៅទៀតថា ម្នាលសុនក្ខត្ត: តថាគតក៏ឥតបាននិយាយនឹងអ្នកថា ម្នាលសុនក្ខត្ត: អ្នកចូរមកនៅពឹងផ្អែក នឹងតថាគតចុះ តថាគតនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស ឲ្យដល់អ្នកដូច្នេះទេ ចំណែកខាងអ្នក ក៏មិននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែក នឹងព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស ឲ្យដល់ខ្ញុំព្រះអង្គដូច្នេះដែរ ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះមានហើយ អ្នកឯងជាអ្នកជាទុក្ខ ពោលលាអ្នកណា ។ ម្នាលសុនក្ខត្ត: អ្នកសំគាល់សេចក្តីនោះថាដូចម្តេច កាលបើតថាគតធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សក្តី កាលបើតថាគតមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សក្តី ធម៌ដែលតថាគតបានសំដែងហើយ ដើម្បីជាប្រយោជន៍

សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ ។ កតេ វា ភន្តេ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយេ អកតេ វា ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយេ យស្សត្ថាយ ភគវតា ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ ។ ឥតិ កិរ សុនក្ខត្ត កតេ វា ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយេ អកតេ វា ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយេ យស្សត្ថាយ មយា ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ(១) ។ តត្រ សុនក្ខត្ត កឹ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ កតំ ករិស្សតិ បស្ស មោឃបុរិស យាវញ្ច តេ ឥទំ អបរទ្ធំ ។

---

១ ឱ. ម. សម្មាទុក្ខក្ខយាយ ។

ឲ្យអស់ទៅនៃទុក្ខណា ធម៌នោះ តែងដឹកនាំបុគ្គលអ្នកធ្វើតាម ឲ្យអស់ទៅនៃទុក្ខនោះ ដោយប្រពៃ ។ សុនក្ខត្តលិច្ឆវិបុត្រឆ្លើយតបថា បពិត្រព្រះអង្គដ៏ចំរើន កាលបើព្រះអង្គធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សក្តី កាលបើព្រះអង្គមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សក្តី ធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ដើម្បីប្រយោជន៍ឲ្យអស់ទៅនៃទុក្ខណា ធម៌នោះ តែងដឹកនាំបុគ្គលអ្នកធ្វើតាម ឲ្យអស់ទៅនៃទុក្ខនោះ ដោយប្រពៃ ។ តថាគតនិយាយថា ម្នាលសុនក្ខត្ត: កាលបើតថាគតធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សក្តី កាលបើតថាគតមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សក្តី ធម៌ដែលតថាគតបានសំដែងហើយ ដើម្បីឲ្យអស់ទៅនៃទុក្ខណា ធម៌នោះ តែងដឹកនាំបុគ្គលអ្នកធ្វើតាម ឲ្យអស់ទៅនៃទុក្ខនោះ ដោយប្រពៃ ។ ម្នាលសុនក្ខត្ត: កាលបើធម៌ដែលតថាគត បានសំដែងហើយនោះ ប្រព្រឹត្តទៅដើម្បីឲ្យអស់ទៅនៃទុក្ខ ដោយប្រពៃ យ៉ាងនេះហើយ ទឹងចាំបាច់ធ្វើឥទ្ធិបាដិហារិយ៍ ដែលជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សធ្វើអ្វី ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះជាកំហុសរបស់អ្នក ។

## បាដិកសុត្តំ សុនក្ខត្តវត្ថុ អគ្គញ្ញកថា

(៣) ន ហិ បន មេ ភន្តេ ភគវា អគ្គញ្ញំ បញ្ញបេតីតិ(១) ។ កឹ នុ តាហំ សុនក្ខត្ត ឯវំ វទាមិ ឯហិ ត្វំ សុនក្ខត្ត មមំ ឧទ្ទិស្ស វិហរាហិ អហន្តេ អគ្គញ្ញំ បញ្ញបេស្សាមីតិ ។ នោ ហេតំ ភន្តេ ។ ត្វំ វា បន មំ ឯវំ វទេសិ អហំ ភន្តេ ភគវន្តំ ឧទ្ទិស្ស វិហរិស្សាមិ ភគវា មេ អគ្គញ្ញំ បញ្ញបេស្សតីតិ ។ នោ ហេតំ ភន្តេ ។ ឥតិ កិរ សុនក្ខត្ត នេវាហន្តំ វទាមិ ឯហិ ត្វំ សុនក្ខត្ត មមំ ឧទ្ទិស្ស វិហរាហិ អហន្តេ អគ្គញ្ញំ បញ្ញបេស្សាមីតិ នបិ កិរ មំ ត្វំ វទេសិ អហំ ភន្តេ ភគវន្តំ ឧទ្ទិស្ស វិហរិស្សាមិ ភគវា មេ អគ្គញ្ញំ បញ្ញបេស្សតីតិ ឯវំ សន្តេ មោឃបុរិស

---

១ ម. បញ្ញាបេតីតិ ។

(៣) សុនក្ខត្តលិច្ឆវីបុត្រ និយាយទៀតថា បពិត្រព្រះអង្គដ៏ចំរើន ព្រោះព្រះមានព្រះភាគ មិនបានបញ្ញត្តនូវច្បាប់ទំលាប់[១] ដល់ខ្ញុំព្រះអង្គសោះ ។ តថាគតក៏និយាយទៅវិញថា ម្នាលសុនក្ខត្តៈ ចុះតថាគតបានពោលនឹងអ្នកយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកចូរមកនៅពឹងផ្អែកនឹងតថាគតចុះ តថាគតនឹងបញ្ញត្តនូវច្បាប់ទំលាប់ដល់អ្នក ដូច្នេះដែរឬ ។ សុនក្ខត្តលិច្ឆវីបុត្រឆ្លើយថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គនឹងបានមានព្រះបន្ទូលយ៉ាងនោះ នឹងខ្ញុំព្រះអង្គក៏ទេ ។ តថាគតនិយាយទៀតថា ចុះអ្នកបាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែកនឹងព្រះមានព្រះភាគ ព្រះមានព្រះភាគ នឹងបញ្ញត្តនូវច្បាប់ទំលាប់ដល់ខ្ញុំព្រះអង្គដូច្នេះដែរឬទេ ។ សុនក្ខត្តលិច្ឆវីបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងបានពោលយ៉ាងនោះ នឹងព្រះអង្គក៏ទេ ។ តថាគតនិយាយថា នែសុនក្ខត្តៈ តថាគតឥតបាននិយាយនឹងអ្នកថា ម្នាលសុនក្ខត្តៈ អ្នកចូរមកនៅពឹងផ្អែកនឹងតថាគតចុះ តថាគតនឹងបញ្ញត្តនូវច្បាប់ទំលាប់ដល់អ្នក ដូច្នេះទេ ចំណែកខាងអ្នកក៏មិននិយាយនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងនៅពឹងផ្អែកនឹងព្រះមានព្រះភាគ ព្រះមានព្រះភាគ នឹងបញ្ញត្តនូវច្បាប់ទំលាប់ដល់ខ្ញុំព្រះអង្គ ដូច្នេះដែរ ម្នាលមោឃបុរស

---

[១] អដ្ឋកថា ថា លោកបញ្ញត្តិថា ច្បាប់ដ៏ប្រសើរ ដែលបុគ្គលគួរចេះដឹង ។

កោ សន្តោ កំ បច្ចាចិក្ខសិ ។ តំ កឹ មញ្ញសិ សុនក្ខត្ត បញ្ញត្តេ វា អគ្គញ្ញេ អប្បញ្ញត្តេ វា អគ្គញ្ញេ យស្សត្ថាយ មយា ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ ។ បញ្ញត្តេ វា ភន្តេ អគ្គញ្ញេ អប្បញ្ញត្តេ វា អគ្គញ្ញេ យស្សត្ថាយ ភគវតា ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ ។ ឥតិ កិរ សុនក្ខត្ត បញ្ញត្តេ វា អគ្គញ្ញេ អប្បញ្ញត្តេ វា អគ្គញ្ញេ យស្សត្ថាយ មយា ធម្មោ ទេសិតោ សោ និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយាតិ[1] ។ តត្រ សុនក្ខត្ត

១ ឱ. ម. សម្មាទុក្ខក្ខយាយ ។

កាលបើហេតុយ៉ាងនេះមានហើយ អ្នកឯងជាអ្នកជាទុក្ខ ពោលលាអ្នកណា ៗ ម្នាលសុនក្ខត្តៈ អ្នកសំគាល់សេចក្ដីនោះថាដូចម្ដេច កាលបើតថាគតបញ្ញត្តនូវច្បាប់ទំលាប់ក្ដី មិនបានបញ្ញត្តនូវច្បាប់ទំលាប់ក្ដី ធម៌ដែលតថាគត បានសំដែងហើយ ដើម្បីប្រយោជន៍ឲ្យអស់ទៅ នៃទុក្ខណា ធម៌នោះតែងដឹកនាំបុគ្គលអ្នកប្រព្រឹត្តតាម ឲ្យអស់ទៅ នៃទុក្ខនោះដោយប្រពៃ បានឬទេ ៗ សុនក្ខត្តលិច្ឆវីបុត្រ ទូលតបថា បពិត្រព្រះអង្គដ៏ចំរើន កាលបើព្រះអង្គបញ្ញត្ត នូវច្បាប់ទំលាប់ក្ដី មិនបានបញ្ញត្ត នូវច្បាប់ទំលាប់ក្ដី ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដើម្បីប្រយោជន៍ឲ្យអស់ទៅនៃទុក្ខណា ធម៌នោះ តែងដឹកនាំបុគ្គលអ្នកប្រព្រឹត្តតាមធម៌ ឲ្យអស់ទៅនៃទុក្ខនោះដោយប្រពៃបានមែន ៗ តថាគតនិយាយថា ម្នាលសុនក្ខត្តៈ កាលបើតថាគតបញ្ញត្តនូវច្បាប់ទំលាប់ក្ដី មិនបានបញ្ញត្តនូវច្បាប់ទំលាប់ក្ដី ធម៌ដែលតថាគតបានសំដែងហើយ ដើម្បីប្រយោជន៍ឲ្យអស់ទៅនៃទុក្ខណា ធម៌នោះ គង់នឹងដឹកនាំបុគ្គល អ្នកប្រព្រឹត្តតាមធម៌ ឲ្យអស់ទៅនៃទុក្ខនោះដោយប្រពៃទេតើ ៗ ម្នាលសុនក្ខត្តៈ

កឹ អគ្គញ្ញំ បញ្ញត្តំ[១] ការិស្សតិ បស្ស មោឃបុរិស យាវញ្ច តេ ឥទំ អបរទ្ធំ ។ អនេកបរិយាយេន ខោ តេ សុនក្ខត្ត មម វណ្ណោ ភាសិតោ វជ្ជិគាមេ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ឥតិ ខោ តេ សុនក្ខត្ត អនេកបរិយាយេន មម វណ្ណោ ភាសិតោ វជ្ជិគាមេ ។ អនេកបរិយាយេន ខោ តេ សុនក្ខត្ត ធម្មស្ស វណ្ណោ ភាសិតោ វជ្ជិគាមេ

---

១ ម. បញ្ញត្តំ អគ្គញ្ញំ ។

កាលបើធម៌ដែលតថាគតសំដែងហើយនោះ ប្រព្រឹត្តទៅដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃ យ៉ាងនេះហើយ ទីងចាំបាច់បញ្ញត្តច្បាប់ទំលាប់ធ្វើអ្វី ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះជាកំហុសរបស់អ្នកឯង ៗ ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណ នៃតថាគតក្នុងវជ្ជិគ្រាម ដោយអនេកបរិយាយថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ ដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹងនិងក្រិត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានព្រះដំណើរល្អ ស្តេចទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀតដូច្នេះ ៗ ម្នាលសុនក្ខត្តៈ អ្នកឯងបានពោលសរសើរគុណរបស់តថាគតក្នុងវជ្ជិគ្រាម ដោយអនេកបរិយាយដូច្នេះឯង ៗ ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណនៃព្រះធម៌ ក្នុងវជ្ជិគ្រាមដោយអនេកបរិយាយថា

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ឥតិ ខោ តេ សុនក្ខត្ត អនេកបរិយាយេន ធម្មស្ស វណ្ណោ កថិតោ វិត្ថារេន ។ អនេកបរិយាយេន ខោ តេ សុនក្ខត្ត សង្ឃស្ស វណ្ណោ កថិតោ វិត្ថារេន សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ

ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ព្រះនវលោកុត្តរធម៌ជាធម៌ដែលព្រះអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងច្បាស់ដោយខ្លួនឯង ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណនៃព្រះធម៌ក្នុងវេជ្ជិគ្រាម ដោយអនេកបរិយាយដូច្នេះឯង ។ ម្នាលសុនក្ខត្តៈ អ្នកបានពោលសរសើរគុណនៃព្រះសង្ឃក្នុងវេជ្ជិ-គ្រាមដោយអនេកបរិយាយថា ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដោយប្រពៃ ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដោយត្រង់ ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដើម្បីព្រះនិព្វាន ពួកសាវ័ករបស់ព្រះមានព្រះភាគ លោកប្រតិបត្តិដោយសមគួរ ពួកសាវ័កទាំងនេះ បើរាប់ជាគូបាន ៤ គូ បើរាប់រៀងគ្នាជាបុរសបុគ្គលបាន ៨ ពួកសាវ័ករបស់ព្រះមានព្រះភាគនេះ លោកគួរទទួលនូវចតុ-ប្បច្ច័យដែលគេនាំមកអំពីចម្ងាយហើយបូជា លោកគួរទទួលនូវអាគន្តុក-ទាន លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា លោកគួរដល់អញ្ជលីកម្ម លោកជាបុញ្ញក្ខេត្ត នៃសត្វលោក

ឥតិ ខោ តេ សុនក្ខត្ត អនេកបរិយាយេន សង្ឃស្ស វណ្ណោ ភាសិតោ វជ្ជិគាមេ ។ អារោចយាមិ ខោ តេ សុនក្ខត្ត បដិវេទយាមិ ខោ តេ សុនក្ខត្ត ភវិស្សន្តិ ខោ តេ សុនក្ខត្ត វត្តារោ នោ វិសហិ សុនក្ខត្តោ លិច្ឆវិបុត្តោ សមណេ គោតមេ ព្រហ្មចរិយំ ចរិតុំ សោ អវិសហន្តោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តោតិ ឥតិ ខោ តេ សុនក្ខត្ត ភវិស្សន្តិ វត្តារោតិ ។ ឯវំបិ(១) ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ មយា វុច្ចមានោ អបក្កមេវ ឥមស្មា ធម្មវិនយា យថា តំ អាបាយិកោ នេរយិកោ ។

(៤) ឯកមិទាហំ ភគ្គវ សមយំ ថូលូសុ វិហារាមិ ឧត្តរកា នាម ថូលូនំ និគមោ ។ អថខ្វាហំ(២) ភគ្គវ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សុនក្ខត្តេន លិច្ឆវិបុត្តេន បច្ឆាសមណេន ឧត្តរកំ បិណ្ឌាយ បាវិសិំ ។ តេន ខោ បន សមយេន

---

១ ម. ឯវំ ។ ២ ឧ. អថខោហំ ។

រកខេត្តដទៃក្រៅលែងជាងគ្មាន ម្នាលសុនក្ខត្តៈអ្នកបានពោលសរសើរគុណនៃព្រះសង្ឃ ក្នុងវជ្ជិគ្រាមដោយអនេកបរិយាយដូច្នេះឯង ។ ម្នាលសុនក្ខត្តៈ តថាគតនឹងប្រាប់ដល់អ្នកឯង ម្នាលសុនក្ខត្តៈ តថាគតនឹងពន្យល់ឲ្យអ្នកដឹង ម្នាលសុនក្ខត្តៈ មុខជានឹងមានអ្នកផងស្តីឲ្យអ្នកថា សុនក្ខត្តលិច្ឆវិបុត្រ មិនអាចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់នៃព្រះសមណគោតមបានឡើយ លុះដល់គាត់មិនអាច (នឹងប្រព្រឹត្តព្រហ្មចរិយធម៌) ក៏ពោលលាសិក្ខា ហើយនឹងត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ម្នាលសុនក្ខត្តៈ ខ្លួនអ្នកមុខជានឹងមានអ្នកផងស្តីឲ្យយ៉ាងដូច្នេះមិនខាន ។ ម្នាលភគ្គវៈ សុនក្ខត្តលិច្ឆវិបុត្រ លុះដល់តថាគតស្តីថាឲ្យយ៉ាងនេះ ក៏គេចចេញចាកធម្មវិន័យនេះបាត់ទៅ ដូចសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

(៤) ម្នាលភគ្គវៈ សម័យមួយ តថាគតទៅក្នុងឧត្តរកានិគមរបស់ពួកជនថូលូ ក្នុងថូលូជនបទឯណោះ ។ ម្នាលភគ្គវៈ ក្នុងបុព្វណ្ហសម័យ តថាគតស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ មានសុនក្ខត្តលិច្ឆវិបុត្រជាបច្ឆាសមណៈ ដើរចូលទៅបិណ្ឌបាតក្នុងឧត្តរកានិគម ។ ក៏សម័យនោះឯង

អចេលោ កោរក្ខត្តិយោ កុក្កុរវត្តិកោ ចតុក្កុណ្ឌិកោ ឆមានិកិណ្ណំ ភក្ខសំ មុខេនេវ ខាទតិ មុខេនេវ ភុញ្ជតិ ។ អទ្ទសា ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ អចេលំ កោរក្ខត្តិយំ កុក្កុរវត្តិកំ ចតុក្កុណ្ឌិកំ (១) ឆមានិកិណ្ណំ ភក្ខសំ មុខេនេវ ខាទន្តំ មុខេនេវ ភុញ្ជន្តំ ។ ទិស្វានស្ស ឯតទហោសិ សាធុរូបោ វត ភោ អយំ សមណោ ចតុក្កុណ្ឌិកោ ឆមានិកិណ្ណំ ភក្ខសំ មុខេនេវ ខាទតិ មុខេនេវ ភុញ្ជតីតិ ។ អថខ្វាហំ ភគ្គវ សុនក្ខត្តស្ស លិច្ឆវិបុត្តស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សុនក្ខត្តំ លិច្ឆវិបុត្តំ ឯតទវោចំ ត្វំបិ នាម មោឃបុរិស សក្យបុត្តិយោ (២) បដិជានិស្សសីតិ ។ កឹ បន មំ ភន្តេ ភគវា ឯវមាហ ត្វំបិ នាម មោឃបុរិស សក្យបុត្តិយោ (៣) បដិជានិស្សសីតិ ។ ននុ តេ សុនក្ខត្ត ឥមំ អចេលំ កោរក្ខត្តិយំ

១ ឱ. ចតុក្កុណ្ឌិកំ ។ ២-៣ សមណោ សក្យបុត្តិយោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

មានអចេលម្នាក់ ជាកោរខត្តិយៈ(១) សមាទានកុក្កុរវត្ត គឺប្រព្រឹត្តដូចសុនខ ដើរវារដើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្ស្យាហារដែលគេចាក់ចោលលើផែនដី ៗ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្របានឃើញអចេលកោរខត្តិយៈ សមាទានកុក្កុរវត្ត ដើរវារដើង ៤ កំពុងយកមាត់ត្រ-បាក់ស៊ី យកមាត់ស៊ីនូវភក្ស្យាហារ ដែលគេចាក់ចោលលើផែនដី ៗ លុះសុនក្ខត្តលិច្ឆវិបុត្រនោះ បានឃើញហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អើហ្ន៎ សមណៈជាព្រះអរហន្តល្អពេកណាស់ ដើរវារដើង ៤ យកមាត់ត្រ-បាក់ស៊ី យកមាត់ស៊ីនូវភក្ស្យាហារ ដែលគេចាក់ចោលលើផែនដី ៗ ម្នាលភគ្គវៈ លំដាប់នោះឯង តថាគតបានដឹងច្បាស់នូវសេចក្តីត្រិះរិះ ក្នុងចិត្តនៃសុនក្ខត្តលិច្ឆវិបុត្រ ដោយចិត្ត (របស់តថាគត) ហើយបាននិយាយនឹងសុនក្ខត្តលិច្ឆវិបុត្រយ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើប្តេជ្ញាខ្លួនថាជាសក្យបុត្តិយ៍សោះឡើយ ៗ សុនក្ខត្តលិច្ឆវិបុត្រនិយាយថា បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុដូចម្តេច បានជាព្រះមានព្រះភាគ ទ្រង់បន្ទោសខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើនឹងប្តេជ្ញាខ្លួនថាជាសក្យបុត្តិយ៍សោះឡើយ ៗ តថាគតក៏និយាយត្រឡប់ទៅវិញថា ម្នាលសុនក្ខត្តៈ ចុះអ្នកបានឃើញអចេលកោរខត្តិយៈនេះសមាទានកុក្កុរវត្ត

---

១ អដ្ឋកថា ថា ជាជាតិក្សត្រមានបណ្ដារូបមូលក្នុង ។

កុក្កុរវត្តិកំ ចតុក្កោណ្ឌិកំ ឆមានិកិណ្ណំ ភក្ខសំ មុខេនេវ ខាទន្តំ មុខេនេវ ភុញ្ជន្តំ ។ ទិស្វា-នស្ស ឯតទហោសិ សាធុរូបោ វត ភោ អយំ សមណោ ចតុក្កោណ្ឌិកោ ឆមានិកិណ្ណំ ភក្ខសំ មុខេនេវ ខាទតិ មុខេនេវ ភុញ្ជតីតិ(១) ។ ឯវំ សន្តេ(២) កឹ បន ភន្តេ ភគវា អរហត្តស្ស មច្ឆរាយ-តីតិ ។ ន ខោ អហំ មោឃបុរិស អរហត្តស្ស មច្ឆ-រាយាមិ អបិច តុយ្ហេវេតំ(៣) បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តំ បជហ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយ យំ ខោ បនេតំ សុនក្ខត្ត មញ្ញសិ អចេលោ កោ-រក្ខត្តិយោ(៤) សាធុរូបោ អយំ សមណោតិ(៥) សោ សត្តមំ ទិវសំ(៦) អលសកេន កាលំ ករិស្សតិ កា-លង្កតោ ច កាលកញ្ជិកា នាម(៧) អសុរា សព្វនិ-ហីនោ អសុរកាយោ តត្រ ឧប្បជ្ជិស្សតិ កាលង្ក-តញ្ច នំ វីរណត្ថម្ភកេ(៨) សុសានេ ឆឌ្ឌេស្សន្តិ ។

---

១ ឱ. ភុញ្ជតិ ។ ២ ឱ. ម. ភន្តេ ។ ៣ ម. តុយ្ហេវតំ ។ ៤ ឱ. ម. អចេលំ កោរក្ខត្តិយំ ។ ៥ ម. សាធុរូបោ អយំ សមណោតិ ។ ៦ ឱ. សោ សត្តមទិវសំ ។ ៧ ឱ. កាលកញ្ជា នាម ។ ៨ ឱ. ម. ពីរណត្ថម្ភកេ ។

ដើរវារដើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ។ លុះអ្នកឃើញហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា អើហ្ន៎ សមណៈជាព្រះអរហន្តល្អពេកណាស់ ដើរវារដើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ដូច្នេះមែនឬទេ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុយ៉ាងនេះមានហើយ ហេតុអ្វីក៏ព្រះមានព្រះភាគ កំណាញ់ព្រះអរហត្តម៉្លេះ ។ តថាគតនិយាយតបថា ម្នាលមោឃបុរស តថាគតមិនមែនកំណាញ់ព្រះអរហត្តទេ តែថាទិដ្ឋិអាក្រក់យ៉ាងនេះកើតឡើងដល់អ្នកហើយ ចូរអ្នកលះបង់ទិដ្ឋិអាក្រក់នោះចេញ ទិដ្ឋិអាក្រក់ដែលប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ជាទុក្ខអស់កាលដ៏យូរ កុំបីមានដល់អ្នកឡើយ ម្នាលសុនក្ខត្តៈ អ្នកសំគាល់នូវអចេលកោរខត្តិយៈណា ថាជាព្រះអរហន្តជាសមណៈល្អដូច្នេះ ឯអចេលនោះនឹងធ្វើមរណកាលដោយអលសកព្យាធិ(១) ក្នុងថ្ងៃទី ៧ ពុំខាន លុះដល់គាត់ធ្វើមរណកាលទៅហើយ នឹងទៅកើតក្នុងពួកអសុរឈ្មោះកាលកញ្ជិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ចំណែកខាងជនទាំងឡាយ នឹងនាំយកអចេលដែលធ្វើមរណកាលហើយនោះ ទៅចោលក្នុងព្រៃស្មសាន ដែលមានដើមស្បូវរណ្តាស ។

---

១ អដ្ឋកថា ថា ជម្ងឺដែលកើតអំពីសេចក្តីខ្ជិលច្រអូស ។

អាកង្ខមានោ ច ត្វំ សុនក្ខត្ត អចេលំ កោរក្ខត្តិយំ ឧបសង្កមិត្វា បុច្ឆេយ្យាសិ ជានាសិ អាវុសោ កោរក្ខត្តិយ អត្តនោ គតិន្តិ(១) ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យន្តេ អចេលោ កោរក្ខត្តិយោ ព្យាករិស្សតិ ជានាមិ អាវុសោ សុនក្ខត្ត អត្តនោ គតឹ កាលកញ្ជិកា នាម អសុរា សព្វនិហីនោ អសុរកាយោ តត្រម្ហិ ឧប្បន្នោតិ(២) ។ អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ យេន អចេលោ កោរក្ខត្តិយោ តេនុបសង្កមិ ឧបសង្កមិត្វា អចេលំ កោរក្ខត្តិយំ ឯតទវោច ព្យាកតោ ខោសិ អាវុសោ កោរក្ខត្តិយ សមណេន គោតមេន អចេលោ កោរក្ខត្តិយោ សត្តមំ ទិវសំ អលសកេន កាលំ ករិស្សតិ កាលកតោ ច កាលកញ្ជិកា នាម អសុរា សព្វនិហីនោ អសុរកាយោ តត្រ ឧប្បជ្ជិស្សតិ កាលកតញ្ច នំ វីរណត្ថម្ពកេ សុសានេ ឆឌ្ឌេស្សន្តីតិ យេន ត្វំ អាវុសោ កោរក្ខត្តិយ មត្តំ មត្តំ ច ភត្តំ ភុញ្ជេយ្យាសិ

១ ខ. គតីតិ ។ ២ ឧបបន្នោតីតិ កត្ថចិ ពោត្ថកេ ទិស្សតិ ។

ម្នាលសុនក្ខត្តៈ បើអ្នកចង់ដឹង គប្បីចូលទៅរកអចេលកោរខត្តិយៈហើយ សួរថា នែអាវុសោកោរខត្តិយៈ អ្នកដឹងគតិរបស់ខ្លួនដែរឬទេ ម្នាលសុនក្ខត្តៈ ហេតុនេះមានជាប្រាកដ គឺអចេលកោរខត្តិយៈ មុខជានឹងប្រាប់អ្នកថា នែអាវុសោសុនក្ខត្តៈ ខ្ញុំដឹងគតិរបស់ខ្ញុំថា ខ្ញុំឯងលុះធ្វើមរណកាលទៅ នឹងទៅកើតក្នុងពួកអសុរឈ្មោះកាលកញ្ជិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ។ ម្នាលភគ្គវៈ សម័យនោះឯង សុនក្ខត្តលិច្ឆវិបុត្រ បានចូលទៅរកអចេលកោរខត្តិយៈ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងអចេលកោរខត្តិយៈ យ៉ាងនេះថា ម្នាលអាវុសោកោរខត្តិយៈ ព្រះសមណគោតម ទ្រង់បានព្យាករឲ្យអ្នកថា អចេលកោរខត្តិយៈនឹងធ្វើមរណកាលដោយអលសកព្យាធិក្នុងថ្ងៃទី ៧ លុះដល់ធ្វើមរណកាលទៅហើយនឹងទៅកើតក្នុងពួកអសុរឈ្មោះកាលកញ្ជិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ជនទាំងឡាយនឹងនាំយកអចេល ដែលធ្វើមរណកាលហើយនោះ ទៅចោលឯព្រៃស្មសានដែលមានដើមស្បូវរណ្តាស ម្នាលអាវុសោកោរខត្តិយៈ ព្រោះហេតុនោះគួរអ្នកបរិភោគភត្តាហារឲ្យល្មម ៗ

មត្តំ មត្តំ ច ខាទីយំ បិវេយ្យាសិ យថា សមណស្ស គោតមស្ស មិច្ឆា អស្ស វចនន្តិ ៗ អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ (១) ឯកទ្វីហិ កាយ សត្ត រត្តិន្ទិវានិ គណេសិ យថា តំ តថាគតស្ស អសទ្ទហមានោ ៗ អថខោ ភគ្គវ អចេលោ កោរក្ខត្តិយោ សត្តមំ ទិវសំ អលសកេន កាលមកាសិ កាលកតោ ច កាលកញ្ជា នាម អសុរា សព្វនិហីនោ អសុរកាយោ តត្រ ឧប្បជ្ជិ កាលកតញ្ច នំ វីរណត្ថម្ភកេ សុសានេ ឆឌ្ឌេសុំ ៗ អស្សោសិ ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ (២) អចេលោ កិរ (៣) កោរក្ខត្តិយោ អលសកេន កាលកតោ វីរណត្ថម្ភកេ សុសានេ ឆឌ្ឌិតោតិ ៗ អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ យេន វីរណត្ថម្ភកំ សុសានំ យេន អចេលោ កោរក្ខត្តិយោ តេនុបសង្កមិ ឧបសង្កមិត្វា អចេលំ កោរក្ខត្តិយំ តិក្ខត្តុំ បាណិនា អាកោដេសិ

---

១ - ២ ឱ. លិច្ឆវីបុត្តោតិ ន ទិស្សតិ ។ ៣ ឱ. កិរសទ្ទោ នត្ថិ ។

គួរផឹកទឹកឲ្យល្ហម ៗ ពាក្យរបស់ព្រះសមណគោតម ត្រឡប់ទៅជាពាក្យខុសវិញយ៉ាងណា (អ្នកគប្បីធ្វើយ៉ាងនោះ) ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រមិនជឿពាក្យតថាគត ហើយក៏រាប់តាំងអំពី ១ ថ្ងៃ ២ ថ្ងៃ រហូតដល់៧យប់ ៧ ថ្ងៃ ។ ម្នាលភគ្គវៈ លំដាប់នោះឯង អចេលកោរក្ខត្តិយៈ ក៏បានធ្វើមរណកាលដោយអលសកព្យាធិ ក្នុងថ្ងៃទី ៧ (នោះមែន) លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងពួកអសុរ ឈ្មោះកាលកញ្ជិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ពួកមហាជនក៏នាំគ្នាយកអចេលដែលធ្វើមរណកាលហើយនោះ ទៅចោលក្នុងព្រៃស្មសានដែលមានដើមស្បូវវណ្ណាស ។ ម្នាលភគ្គវៈ សុនក្ខត្តលិច្ឆវិបុត្រ បានឮដំណឹងថា អចេលកោរក្ខត្តិយៈបានធ្វើមរណកាល ដោយអលសកព្យាធិ ពួកមនុស្សបាននាំយកទៅចោល ឯព្រៃស្មសាន ដែលមានដើមស្បូវវណ្ណាស ។ ម្នាលភគ្គវៈ លំដាប់នោះឯង សុនក្ខត្តលិច្ឆវិបុត្រ ក៏ដើរចូលទៅរកអចេលកោរក្ខត្តិយៈ ក្នុងព្រៃស្មសាន ដែលមានដើមស្បូវវណ្ណាស លុះចូលទៅដល់ហើយ ក៏យកដៃទះសាកសពអចេលកោរក្ខត្តិយៈ ៣ ដង

ជានាសិ អាវុសោ កោរក្ខត្តិយ អត្តនោ គតិន្តិ ។ អថខោ ភគ្គវ អចេលោ កោរក្ខត្តិយោ បាណិនា បិដ្ឋឹ បរិបុញ្ជន្តោ(១) វុដ្ឋាសិ ជានាមិ អាវុសោ សុនក្ខត្ត អត្តនោ គតឹ កាលកញ្ជិកា នាម អសុរា សព្វនិហីនោ អសុរកាយោ តត្រម្ហិ ឧប្បន្នោតិ វត្វា តត្ថេវ ឧត្តានោ បរិបតិ(២) ។ អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អហំ ភគ្គវ សុនក្ខត្តំ លិច្ឆវិបុត្តំ ឯតទវោចំ តំ កឹ មញ្ញសិ សុនក្ខត្ត យថេវ តេ អហំ អចេលំ កោរក្ខត្តិយំ អារព្ភ ព្យាកាសឹ តថេវ តំ វិបាកំ នោ(៣) អញ្ញថា វាតិ ។

---

១ ឱ. បរិបុញ្ឆន្តោ ។ ២ ឱ. បបតិ ។ ៣ ឱ. ម. ហោតិ ឥត្ថំ ។

សួរថា ម្នាលអាវុសោកោរក្ខត្តិយៈ អ្នកដឹងគតិរបស់ខ្លួនឬទេ ។ ម្នាលភគ្គវៈ សម័យនោះឯង សាកសពអចេលកោរក្ខត្តិយៈ យកដៃរោសខ្នងក្រោកឡើងប្រាប់ថា ម្នាលអាវុសោសុនក្ខត្តៈ ខ្ញុំដឹងគតិរបស់ខ្ញុំថា ខ្ញុំបានមកកើត ក្នុងពួកអសុរ ឈ្មោះកាលកញ្ជិកៈហើយ ជាអសុរកាយថោកទាបជាងគេទាំងអស់[1] ដូច្នេះរួចហើយ ក៏ដួលដេកផ្ងារស្រទាំងក្នុងទីនោះទៅវិញ ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រ ក៏ចូលមករកតថាគត លុះចូលមកដល់ហើយក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ តថាគត ក៏សួរយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច តថាគតបានព្យាករណ៍ នូវអចេលកោរក្ខត្តិយៈប្រាប់អ្នកយ៉ាងណាមិញ វិបាកនោះក៏ពិតដូច្នោះមែន មិនបានទៅជាខុសវិញទេឬ ។ សុនក្ខត្តលិច្ឆវិបុត្រ ក៏ទូលតបមកវិញថា

---

១ អដ្ឋកថា ថា សាកសពអចេលកោរក្ខត្តិយៈដែលស្លាប់ហើយត្រឡប់ក្រោកឡើង និយាយតបមកនឹងសុនក្ខត្តលិច្ឆវិបុត្រវិញបាននេះ ក៏ដោយអានុភាពរបស់ព្រះពុទ្ធជាម្ចាស់ ។ មានដំណាលថា ព្រះមានព្រះភាគបាននាំយកអចេលកោរក្ខត្តិយៈ ពីកំណើតអសុរកាយមកបញ្ចូលក្នុងរូបខ្មោចអចេលនោះ ឲ្យនិយាយកើត ព្រោះហេតុនោះ បានជាខ្មោចអចេលកោរក្ខត្តិយៈនិយាយបាន ។

## បាដិកសុត្តេ ឥទ្ធិប្បាដិហារិយកតាកតកថា

យទេវ មេ ភន្តេ ភគវា អវេចសិ កោរក្ខត្តិយំ អារព្ភ ព្យាកាសិ តថេវ តំ វិបាកំ នោ អញ្ញថាតិ ។ តំ កិំ មញ្ញសិ សុនក្ខត្ត យទិ ឯវំ សន្តេ កតំ វា ហោតិ ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ អកតំ វាតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ កតំ ហោតិ ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ នោ អកតន្តិ ។ ឯវំបិ ខោ មំ ត្វំ មោឃបុរិស ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ករោន្តំ ឯវំ វទេសិ ន ហិ បន មេ ភន្តេ ភគវា ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ករោតីតិ បស្ស មោឃបុរិស យាវញ្ច តេ ឥទំ អបរទ្ធំ ។ ឯវំបិ ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ មយា វុច្ចមានោ អបក្កមេវ ឥមស្មា ធម្មវិនយា យថា តំ អាបាយិកោ នេរយិកោ ។

បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ប្រារព្ធព្យាករណ៍ នូវអចេលកោរក្ខត្តិយៈ ប្រាប់ខ្ញុំព្រះអង្គ យ៉ាងណា វិបាកនោះក៏ពិតដូច្នោះមែន មិនមែនផ្សេងទេ ។ តថាគតសួរថា ម្នាលសុនក្ខត្តៈ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច បើហេតុយ៉ាងនេះមានហើយ តើតថាគតឈ្មោះថាបានធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរ ក្រៃលែងជាងធម៌របស់មនុស្សហើយ ឬមិនមែនបានធ្វើទេ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុយ៉ាងនេះមានហើយ ឈ្មោះថាព្រះអង្គបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ពិតមែនហើយ មិនមែនថាព្រះអង្គមិនធ្វើទេ ។ តថាគតនិយាយតបថា ម្នាលមោឃបុរស កាលបើដូច្នោះមែន (ចុះដូចម្តេច) ក៏អ្នកនិយាយនឹងតថាគត ដែលជាអ្នកធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ពិតជាមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ដល់ខ្ញុំព្រះអង្គទេ ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះជាកំហុសរបស់អ្នក ។ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្រ កាលតថាគតស្តីឲ្យយ៉ាងនេះ ក៏គេចចេញចាកធម្មវិន័យនេះបាត់ទៅ ដូចជាសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

(៨) ឯកមិទាហំ ភគ្គវ សមយំ វេសាលិយំ វិហារាមិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន អចេលោ កឡារមដ្ឋកោ[១] វេសាលិយំ បដិវសតិ លាភគ្គប្បត្តោ ចេវ យសគ្គប្បត្តោ ច វជ្ជិគាមេ ។ តស្ស សត្ត វតបទានិ សមត្តានិ សមាទិន្នានិ ហោន្តិ យាវជីវំ អចេលោ អស្សំ ន វត្ថំ បរិទហេយ្យំ យាវជីវំ ព្រហ្មចារី អស្សំ ន មេថុនំ ធម្មំ បដិសេវេយ្យំ យាវជីវំ សុរាមំសេនេវ យាបេយ្យំ ន ឱទនកុម្មាសំ ភុញ្ជេយ្យំ បុរត្ថិមេន វេសាលឹ[២] ឧទេនំ នាម ចេតិយំ តំ នាតិក្កមេយ្យំ ទក្ខិណេន វេសាលឹ គោតមកំ នាម ចេតិយំ តំ នាតិក្កមេយ្យំ បច្ឆិមេន វេសាលឹ សត្តម្ពំ នាម ចេតិយំ តំ នាតិក្កមេយ្យំ ឧត្តរេន វេសាលឹ ពហុបុត្តកន្នាម[៣] ចេតិយំ តំ នាតិក្កមេយ្យន្តិ ។ សោ ឥមេសំ សត្តន្នំ វតបទានំ សមាទានហេតុ លាភគ្គប្បត្តោ ចេវ យសគ្គប្បត្តោ ច វជ្ជិគាមេ ។

---

១ ឱ. កឡុរមត្តុកោ ។ ម. កឡារមដ្ដកោ ។ ២ ម. ឯវំ ។ ឱ. វេសាលិយំ ។
៣ ឱ. ម. ពហុបុត្តំ នាម ។

(៤) ម្នាលភគ្គវៈ សម័យមួយ តថាគតឋិតនៅក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ជិតក្រុងវេសាលី ។ សម័យនោះឯង មានអចេលម្នាក់ ឈ្មោះកឡារមដ្ឋកៈ(១) នៅអាស្រ័យក្នុងក្រុងវេសាលី ជាអ្នកបានលាភនឹងយសដ៏ប្រសើរ ក្នុងវជ្ជិគ្រាម ។ ចំណែកវត្តទាំង ៧ អចេលនោះក៏បានសមាទានសព្វគ្រប់ថា អាត្មាអញគួរជាអ្នកអាក្រាត មិនត្រូវស្លៀកដណ្តប់សំពត់ដរាបដល់អស់ជីវិត ១ អាត្មាអញគួរប្រព្រឹត្តធម៌ដ៏ប្រសើរ មិនត្រូវសេពមេថុនធម្មដរាបដល់អស់ជីវិត ១ អាត្មាអញគួរចិញ្ចឹមជីវិតដោយសុរានឹងសាច់តែម្យ៉ាង មិនត្រូវបរិភោគបាយនឹងនំដរាបដល់អស់ជីវិត ១ អាត្មាអញមិនត្រូវបោះបង់ចោលនូវឧទេនចេតិយ ខាងកើតក្រុងវេសាលី ១ អាត្មាអញមិនត្រូវបោះបង់ចោលនូវគោតមកចេតិយ ខាងត្បូងក្រុងវេសាលី ១ អាត្មាអញមិនត្រូវបោះបង់ចោលនូវសត្តម្ពចេតិយ ខាងលិចក្រុងវេសាលី ១ អាត្មាអញមិនត្រូវបោះបង់ចោល នូវពហុបុត្តកចេតិយ ខាងជើងក្រុងវេសាលី ១ ព្រោះហេតុដែលប្រព្រឹត្តសមាទាន នូវចំណែកវត្តទាំង ៧ នេះហើយ ទើបអចេលនោះបាននូវលាភនឹងយសដ៏ប្រសើរក្នុងវជ្ជិគ្រាម ។

---

១ អដ្ឋកថា ថា ជាអ្នកដុសខាត់ធ្មេញដែលលៀនចេញមកក្រៅ ។

## បាដិកសុត្តេ សុនក្ខត្តស្ស បញ្ហា

អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ យេន អចេលោ កឡារមជ្ឈកោ តេនុបសង្កមិ ឧបសង្កមិត្វា អចេលំ កឡារមជ្ឈកំ បញ្ហំ អបុច្ឆិ ។ តស្ស អចេលោ កឡារមជ្ឈកោ បញ្ហំ បុដ្ឋោ ន សំបាយាសិ អសំបាយន្តោ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាត្វាកាសិ ។ អថខោ ភគ្គវ សុនក្ខត្តស្ស លិច្ឆវិបុត្តស្ស ឯតទហោសិ សាធុរូបំ វត ភោ អរហន្តំ សមណំ អាសាទិយិម្ហសេ[១] មា វត នោ កោ[២] អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អហំ ភគ្គវ សុនក្ខត្តំ លិច្ឆវិបុត្តំ ឯតទវោចំ ត្វំបិ នាម មោឃបុរិស សក្យបុត្តិយោ[៣] បដិជានិស្សសីតិ ។ កឹ បន មំ ភន្តេ ភគវា ឯវមាហ ត្វំបិ នាម

---

១ ខ. ម. អាសាទិម្ហសេ ។ ២ ខ. ម. កោតិ នត្ថិ ។ ៣ ម. សមណោ សក្យបុត្តិយោ ។

## បាដិកសូត្រ ប្រស្នារបស់សុនក្ខត្តលិច្ឆវីបុត្រ

ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវីបុត្របានចូលទៅរកអចេលកឡារមដ្ឋកៈ លុះចូលទៅដល់ហើយ ក៏សួរប្រស្នានឹងអចេលកឡារមដ្ឋកៈ ។ លុះសុនក្ខត្តលិច្ឆវីបុត្រនោះសួរប្រស្នាយ៉ាងនោះហើយ អចេលកឡារមដ្ឋកៈក៏ឆ្លើយដោះស្រាយប្រស្នានោះមិនរួច កាលបើឆ្លើយមិនរួចហើយក៏ធ្វើនូវសេចក្ដីក្រេវក្រោធផង ប្រទូស្ដផង សេចក្ដីមិនត្រេកអរផង ឲ្យប្រាកដឡើង ។ ម្នាលភគ្គវៈ លំដាប់នោះឯង សុនក្ខត្តលិច្ឆវីបុត្រមានសេចក្ដីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញបានដេញដោលនូវអរហន្តសមណៈ មានសភាពដ៏ល្អ ធ្វើដូចម្ដេចហ្ន៎ អំពើដែលប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលជាយូរអង្វែង កុំបីមានដល់អាត្មាអញឡើយ ។ ម្នាលភគ្គវៈ លំដាប់នោះ សុនក្ខត្តលិច្ឆវីបុត្របានចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ក្រាបថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវីត្រ អង្គុយក្នុងទីសមគួរហើយ តថាគតក៏បានពោលពាក្យនេះថា ម្នាលមោឃបុរស អ្នកមិនសមបើមកប្ដេជ្ញាខ្លួនថាជាសក្យបុត្តិយ៍សោះឡើយ ។ សុនក្ខត្តលិច្ឆវីបុត្តបាននិយាយថា បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុអ្វីបានជាព្រះមានព្រះភាគ ទ្រង់បន្ទោសខ្ញុំ

មោឃបុរិស សក្យបុត្តិយោ(១) បដិជានិស្សសីតិ ។ ឥង្ឃ ត្វំ សុនក្ខត្ត អចេលំ កឡារមដ្ឋកំ(២) ឧបសង្កមិត្វា បញ្ហំ អបុច្ឆិ តស្ស តេ អចេលោ កឡារមដ្ឋកោ បញ្ហំ បុដ្ឋោ ន សំបាយាសិ អសំបាយន្តោ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាត្វាកាសិ តស្ស តេ ឯតទហោសិ សាធុរូបំ វត ភោ អរហន្តំ សមណំ អាសាទិយិម្ហសេ មា វត នោ ភោ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ កឹ បន ភន្តេ ភគវា អរហត្តស្ស មច្ឆរាយតីតិ ។ ន ខោ អហំ(៣) មោឃបុរិស អរហត្តស្ស មច្ឆរាយាមិ អបិច តុយ្ហេវេតំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តំ បជហ

---

១ ម. សមណោ សក្យបុត្តិយោ ។ ២ ឱ. កន្ទរមសុកំ ។ ម. កឡារមដ្ឋកំ ។
៣ ឱ. ន ខោ ហំ ។

ព្រះអង្គយ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើមកបដិញ្ញាខ្លួនថាជា
សក្យបុត្តិយ៍សោះឡើយ ។ តថាគតក៏ត្រឡប់និយាយទៅវិញទៀតថា
ម្នាលសុនក្ខត្ត: ក្រែងអ្នកបានចូលទៅរកអចេលកឡារមដ្ឋក: ហើយសួរ
ប្រស្នា ឯអចេលកឡារមដ្ឋក: លុះដល់អ្នកសួរប្រស្នាហើយ ក៏រក
ឆ្លើយដោះប្រស្នាមិនរួច កាលបើឆ្លើយដោះប្រស្នាមិនរួចហើយ ក៏បាន
ធ្វើនូវសេចក្តីក្រេវក្រោធផង ប្រទូស្តផង សេចក្តីមិនត្រេកអរផង ឲ្យ
ប្រាកដឡើង អ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញបាន
ដេញដោលនូវព្រះអរហន្តសមណ: ដែលមានសភាពដ៏ល្អ ធ្វើដូចម្តេចហ្ន៎
អំពើដែលប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាល
ជាយូរអង្វែង កុំបីមានដល់អាត្មាអញឡើយ ដូច្នេះមែនឬ ។ ឯសុនក្ខត្ត-
លិច្ឆវិបុត្រ ក៏ត្រឡប់ទូលតបថា ព្រះករុណា ព្រះអង្គ បពិត្រព្រះអង្គ
ដ៏ចំរើន ចុះព្រះមានព្រះភាគ ទ្រង់កំណាញ់ព្រះអរហត្តឬអ្វី ។ តថាគត
និយាយថា ម្នាលមោឃបុរស តថាគតមិនមែនកំណាញ់ព្រះអរហត្តទេ
តែទិដ្ឋិអាក្រក់យ៉ាងនេះ កើតឡើងដល់អ្នកទេតើ អ្នកចូរលះបង់នូវទិដ្ឋិ

ម. តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ យំ ខោ បនេតំ សុនក្ខត្ត មញ្ញសិ អចេលំ កឡារមដ្ឋកំ សាធុរូបោ អរហំ សមណោតិ(១) សោ នចិរស្សេវ បរិហិតោ សានុចរិកោ(២) វិចរន្តោ ឱទនកុម្មាសំ ភុញ្ជមានោ សព្វានេវ វេសាលិយានិ ចេតិយានិ សមតិក្កមិត្វា យសា និហីនោ(៣) កាលំ ករិស្សតីតិ ។ អថខោ ភគ្គវ អចេលោ កឡារមដ្ឋកោ នចិរស្សេវ បរិហិតោ សានុចរិកោ វិចរន្តោ ឱទនកុម្មាសំ ភុញ្ជមានោ សព្វានេវ វេសាលិយានិ ចេតិយានិ សមតិក្កមិត្វា យសា និហីនោ(៤) កាលមកាសិ ។ អស្សោសិ ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ អចេលោ កិរ កឡារមដ្ឋកោ បរិហិតោ សានុចរិកោ វិចរន្តោ ឱទនកុម្មាសំ ភុញ្ជមានោ សព្វានេវ វេសាលិយានិ ចេតិយានិ សមតិក្កមិត្វា យសា និហីនោ កាលំ កតោតិ ។ អថខោ ភគ្គវ

---

១ ឱ. សាធុរូបោ អយំ សមណោតិ ។ ២ ឱ. សានុចរិយោ ។ ៣-៤ ឱ. និក្កិណ្ណោ ។ ម. តិកិណ្ណោ ។

អាក្រក់នោះចេញ ទិដ្ឋិអាក្រក់ដែលប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ជាទុក្ខអស់កាលដ៏យូរ ក៏មិនមានដល់អ្នកឡើយ ។ តថាគតនិយាយទៀតថា ម្នាលសុនក្ខត្តៈ អ្នកឯងសំគាល់នូវអចេលកឡារមដ្ឋកៈណា ថាជាអរហន្ត-សមណៈមានសភាពដ៏ប្រសើរដូច្នេះ មិនយូរប៉ុន្មាន អចេលនោះ មុខជានឹងត្រឡប់ទៅជាអ្នកស្លៀកសំពត់មានប្រពន្ធកូន បរិភោគបាយនឹងនំ លះបង់ចោលនូវចេតិយទាំងអស់ ដែលមាននៅជិតក្រុងវេសាលី នឹងសាប-សូន្យចាកយសហើយធ្វើមរណកាលទៅ ។ ម្នាលភគ្គវៈ លំដាប់នោះឯង អចេលកឡារមដ្ឋកៈ មិនយូរប៉ុន្មាន ត្រឡប់ទៅជាអ្នកស្លៀកសំពត់ មានប្រពន្ធកូន បរិភោគបាយនឹងនំ លះបង់នូវចេតិយទាំងអស់ដែលមាននៅជិតក្រុងវេសាលី ជាអ្នកសាបសូន្យចាកយស ហើយធ្វើមរណកាលទៅដូច្នោះមែន ។ ម្នាលភគ្គវៈ សុនក្ខត្តលិច្ឆវីបុត្រ បានឮដំណឹងថា អចេលកឡា-រមដ្ឋកៈ ត្រឡប់ទៅជាអ្នកស្លៀកសំពត់ មានប្រពន្ធកូនបរិភោគបាយនឹងនំ លះបង់ចោលនូវចេតិយទាំងអស់ ដែលមាននៅជិតក្រុងវេសាលី សាបសូន្យចាកយសហើយធ្វើមរណកាលទៅដែរ ។ ម្នាលភគ្គវៈ គ្រានោះឯង

សុនក្ខត្តោ លិច្ឆវិបុត្តោ(១) យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អហំ ភគ្គវ សុនក្ខត្តំ លិច្ឆវិបុត្តំ ឯតទវោចំ តំ កឹ មញ្ញសិ សុនក្ខត្ត យថេវ តេ អហំ អចេលំ កឡារមដ្ដកំ អារព្ភ ព្យាកាសឹ តថេវ តំ វិបាកំ នោ អញ្ញថា វាតិ ។ យថេវ មេ ភន្តេ ភគវា អចេលំ កឡារមដ្ដកំ អារព្ភ ព្យាកាសិ តថេវ តំ វិបាកំ នោ អញ្ញថាតិ ។ តំ កឹ មញ្ញសិ សុនក្ខត្ត យទិ ឯវំ សន្តេ កតំ វា ហោតិ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ អកតំ វាតិ ។ អថ ខោ(២) ភន្តេ ឯវំ សន្តេ កតំ ហោតិ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ នោ អកតន្តិ ។

---

១ ឱ. លិច្ឆវិបុត្តោតិ នត្ថិ ។ ២ ឱ. ម. អទ្ធា ខោ ។

សុនក្ខត្តលិច្ឆវិបុត្រចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវិបុត្រអង្គុយក្នុងទីសមគួរហើយ តថាគតក៏បានសួរយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច តថាគត បានព្យាករណ៍នូវអចេលកឡារមដ្ឋកៈ ប្រាប់អ្នកយ៉ាងណា វិបាកនោះក៏ពិតដូច្នោះមែន មិនមែនទៅជាផ្សេងវិញទេឬ ។ ឯសុនក្ខត្តលិច្ឆវិបុត្រ បានឆ្លើយតបថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ព្យាករណ៍នូវអចេលកឡារមដ្ឋកៈ ប្រាប់ខ្ញុំព្រះអង្គយ៉ាងណា វិបាកនោះក៏ពិតដូច្នោះមែន មិនមែនទៅជាផ្សេងវិញទេ ។ តថាគត ក៏និយាយថា ម្នាលសុនក្ខត្តៈ អ្នកសំគាល់សេចក្តីនោះ ថាដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ តើឈ្មោះថាតថាគតបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សហើយ ឬថាមិនបានធ្វើទេ ។ សុនក្ខត្តលិច្ឆវិបុត្រក៏ទូលតបថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុយ៉ាងនេះមានហើយ ឈ្មោះថាព្រះអង្គបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សពិតមែនហើយ មិនមែនថាព្រះអង្គមិនធ្វើទេ ។

ឯវំបិ ខោ មំ ត្វំ មោឃបុរិស ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ការោន្តំ ឯវំ វទេសិ ន ហិ បន មេ កត្តេ កតេវា ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយេ ការោតីតិ បស្ស មោឃបុរិស យាវញ្ច តេ ឥទំ អបរទ្ធន្តិ ។ ឯវំបិ ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ មយា វុច្ចមានោ អបក្កមេវ ឥមស្មា ធម្មវិនយា យថា តំ អាបាយិកោ នេរយិកោ ។

(២) ឯកមិទាហំ ភគ្គវ សមយំ វេសាលិយំ វិហរាមិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន អចេលោ បាថិកបុត្តោ វេសាលិយំ បដិវសតិ លាភគ្គប្បត្តោ ចេវ យសគ្គប្បត្តោ ច វជ្ជិគាមេ ។ សោ វេសាលិយំ បរិសតិ ឯវំ វាចំ ភាសតិ សមណោបិ គោតមោ ញាណវាទោ អហំបិ ញាណវាទោ ញាណវាទោ ខោ បន ញាណវាទេន អរហតិ ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ទស្សេតុំ សមណោ គោតមោ

តថាគតពោលថា ម្នាលមោឃបុរស កាលបើហេតុយ៉ាងនោះទេ ចុះដូចម្ដេចក៏អ្នកនិយាយនឹងតថាគត ដែលជាអ្នកធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ដល់ខ្ញុំព្រះអង្គសោះ ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះ ជាកំហុសរបស់អ្នកហើយ ។ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្រ កាលបើតថាគតស្ដីថាឲ្យយ៉ាងនេះ ក៏គេចចេញចាកធម្មវិន័យនេះបាត់ទៅ ដូចជាសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

(៦) ម្នាលភគ្គវៈ សម័យមួយ តថាគតឋិតនៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលីឯណោះ ។ សម័យនោះឯង អចេល-បាដិកបុត្រ នៅអាស្រ័យក្នុងក្រុងវេសាលី ជាអ្នកបានលាភនឹងយសដ៏ប្រសើរ ក្នុងវជ្ជីគ្រាម ។ អចេលបាដិកបុត្រនោះពោលពាក្យក្នុងកណ្ដាលបរិសទ្យ ក្នុងក្រុងវេសាលីយ៉ាងនេះថា ព្រះសមណគោតមជាញាណវាទ (អ្នកពោលដោយប្រាជ្ញា)ឯយើងក៏ជាញាណវាទដែរ អ្នកដែលជាញាណ-វាទ នឹងអ្នកដែលជាញាណវាទដូចគ្នា គួរនឹងសំដែងឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សតគ្នា តែព្រះសមណគោតម

ឧបឌ្ឍបថំ អាគច្ឆេយ្យ អហំបិ(១) ឧបឌ្ឍបថំ គច្ឆេយ្យំ តេ តត្ថ ឧភោបិ(២) ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករេយ្យាម ឯកញ្ចេ សមណោ គោតមោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតិ ទ្វាហំ ករិស្សាមិ ទ្វេ ចេ សមណោ គោតមោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយានិ ករិស្សតិ ចត្តារហំ ករិស្សាមិ ចត្តារិ ចេ សមណោ គោតមោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយានិ ករិស្សតិ អដ្ឋាហំ ករិស្សាមិ ។ ឥតិ យាវតកំ យាវតកំ សមណោ គោតមោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតិ តទ្ទិគុណំ តទ្ទិគុណាហំ(៣) ករិស្សាមីតិ ។ ឥតិ ខោ(៤) ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ មំ ឯតទវោច អចេលោ ភន្តេ បាដិកបុត្តោ វេសាលិយំ បដិវសតិ ញាតក្ខប្បត្តោ ចេវ យសក្ខប្បត្តោ ច វជ្ជិគាមេ

---

១ ឱ. អហំ ប ។ ២ ឱ. ឧភោ ។ ៣ តំ ទិគុណំ តំ ទិគុណាហន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៤ ឱ. ម. អថខោ ។

គួរមកកាន់ទីពាក់កណ្ដាលផ្លូវ ឯយើងក៏គួរទៅដល់ទីពាក់កណ្ដាលផ្លូវដែរ ហើយយើងទាំងពីរនាក់នោះ នឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ក្នុងទីដែលជួបគ្នានោះ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សបាន ១ យើងអាចនឹងធ្វើបានពីរ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបានពីរ យើងអាចនឹងធ្វើបាន ៤ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្សបាន ៤ យើងអាចនឹងធ្វើបាន ៨ ៗ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបានប៉ុន្មាន ៗ យើងអាចនឹងធ្វើឲ្យបានជាទ្វេគុណ ៗ ជាងនោះ ៗ ទៅទៀតបាន ដោយប្រការដូច្នេះឯង ។ ម្នាលភគ្គវៈ ព្រោះហេតុនោះឯង បានជាសុនក្ខត្តលិច្ឆវិបុត្រចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ ក៏បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រនៅអាស្រ័យក្នុងក្រុងវេសាលី ជាអ្នកបានលាភនិងយសដ៏ប្រសើរ ក្នុងវជ្ជិគ្រាម

សោ វេសាលិយំ បរិសតិ ឯវំ វាចំ ភាសតិ សមណោបិ គោតមោ ញាណវាទោ អហំបិ ញាណវាទោ ញាណវាទោ ខោ បន ញាណវាទេន អរហតិ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ទស្សេតុំ សមណោ គោតមោ(១) ឧបឌ្ឍបថំ អាគច្ឆេយ្យ អហំបិ ឧបឌ្ឍបថំ គច្ឆេយ្យំ តេ តត្ថ ឧភោបិ(២) ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករេយ្យាម ឯកញ្ចេ សមណោ គោតមោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតិ ទ្វាហំ ករិស្សាមិ ។ សង្ខិត្តំ ។ តទ្ទិគុណំ តទ្ទិគុណាហំ ករិស្សាមីតិ(៣) ។ ឯវំ វុត្តេ អហំ ភគ្គវ សុនក្ខត្តំ លិច្ឆវិបុត្តំ ឯតទវោចំ អភព្វោ ខោ សុនក្ខត្ត អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា មម សម្មុខីភាវំ អាគន្តុំ សចេបិស្ស

---

១ ឱ. សមណោ ប គោតមោ ។ ២ ឱ. ឧភោ ។ ៣ ឱ. ករិស្សតិ .. ។ បេ ។ ... តទ្ទិគុណំ តទ្ទិគុណាហំ ករិស្សាមីតិ ។

អចេលបាដិកបុត្រនោះ ក៏ពោលពាក្យក្នុងកណ្ដាលបរិស័ទ ក្នុងវេសាលី យ៉ាងនេះថា ព្រះសមណគោតមជាញាណវាទ ឯយើងក៏ជាញាណវាទដែរ អ្នកដែលជាញាណវាទនឹងអ្នកដែលជាញាណវាទដូចគ្នា គួរនឹងសំដែងឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សតគ្នា. តែព្រះសមណគោតមគួរមកកាន់ទីពាក់កណ្ដាលផ្លូវ ឯយើងក៏គួរទៅកាន់ទីពាក់កណ្ដាលផ្លូវដែរ ហើយយើងទាំងពីរនាក់នោះ នឹងធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស ក្នុងទីដែលជួបគ្នានោះ បើព្រះសមណគោតមនឹងធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបាន ១ យើងអាចនឹងធ្វើបាន ២ ៗ សេចក្ដីបំព្រួញ ៗ យើងអាចនឹងធ្វើឲ្យជាទ្វេគុណ ៗ ជាងនោះ ៗ ទៅទៀតបាន ៗ ម្នាលភគ្គវៈ កាលបើសុនក្ខត្តលិច្ឆវិបុត្រពោលពាក្យយ៉ាងនេះហើយ តថាគតក៏និយាយនឹងសុនក្ខត្តលិច្ឆវិបុត្រយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេក៏មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតឡើយ បើប្រសិនជាអចេល-

ឯវមស្ស អហំ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ រក្ខិតេតំ ភន្តេ ភគវា វាចំ រក្ខិតេតំ សុគតោ វាចន្តិ ។ កឹ បន មំ ត្វំ សុនក្ខត្ត ឯវំ វទេសិ រក្ខិតេតំ ភន្តេ ភគវា វាចំ រក្ខិតេតំ សុគតោ វាចន្តិ ។ ភគវតា-បស្ស(១) ភន្តេ ឯសា វាចា ឯកំសេន ឱធារិតា(២) អភេញ្ញា អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា មម សម្មុខីភាវំ អាគន្តុំ សចេបិស្ស ឯវមស្ស អហំ តំ វាចំ អប្បហា-យ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ អចេលោ ច ភន្តេ បាដិកបុត្តោ

១ ឱ. ម. ភគវតាបស្ស ។ ២ ឱ. ម. ឱភាទិតា ។

បាដិកបុត្រនោះតាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះមុខ នៃព្រះសមណគោតមដូច្នេះ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះ(១) ។ សុនក្ខត្តលិច្ឆវិបុត្រក៏និយាយទៀតថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគរក្សានូវវាចានុះ សូមព្រះសុគតរក្សានូវវាចានុះ ។ តថាគតនិយាយថា ម្នាលសុនក្ខត្ត: ព្រោះហេតុអ្វីបានជាអ្នកនិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគរក្សានូវវាចានុះ សូមព្រះសុគតរក្សាវាចានុះ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគបានពោលនូវវាចានុះ ដោយដាច់ខាតដូច្នេះថា អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ បើប្រសិនជាអចេលបាដិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់នូវវាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះមុខ នៃព្រះសមណគោតមដូច្នេះ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះ ។ បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើអចេលបាដិកបុត្រនឹងមក

---

១អដ្ឋកថា ថា ក្បាលគប្បីធ្លាក់ចុះអំពីក ដូចជាផ្លែត្នោតទុំជ្រុះអំពីទង ឬគប្បីបែកចេញជា ៧ ភាគ ។

វិប្បប្បេន ភគវតោ សម្មុខីភាវំ អាគច្ឆេយ្យំ តេនស្ស ភគវ-តោ មុសាតិ ។ អបិ នុ សុនក្ខត្ត តថាគតោ តំ វាចំ ភាសេយ្យ យា សា វាចា ទ្វយគាមិនីតិ ។ កឹ បន ភន្តេ ភគវតា អចេលោ ញាតិកបុត្តោ ចេតសា ចេតោ បរិច្ច វិទិតោ អញ្ញោ អចេលោ ញាតិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា មម សម្មុខីភាវំ អាគច្ឆេយ្យ សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ ឧទាហុ ទេវតា ភគវតោ(១) ឯតមត្ថំ អារោចេសុំ អញ្ញោ ភន្តេ អចេលោ ញាតិកបុត្តោ តំ វាចំ អប្បហាយ ។ បេ ។

---

១ ម. គហិតស្ស ។

កាន់ទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដោយរូបប្លែក(១)បាន ពាក្យរបស់ព្រះមានព្រះភាគនោះ នឹងត្រឡប់ទៅ ជាពាក្យមុសាវិញ ។ តថាគតក៏និយាយទៀតថា ម្នាលសុនក្ខត្តៈ វាចាណា មានដំណើរបែកជា ២ ផ្លូវ តថាគតគប្បីពោលវាចានោះដែរឬទេ ។ សុនក្ខត្តលិច្ឆវិបុត្រក៏ទូលតបថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់បានកំណត់ជ្រាបចិត្តរបស់អចេលបាដិកបុត្រ ដោយព្រះហឫទ័យរបស់ព្រះអង្គ ថា អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ បើប្រសិន ជាអចេលបាដិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះ ហើយគប្បីទៅកាន់ទីចំពោះមុខ នៃព្រះសមណគោតម ដូច្នេះ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះដូច្នេះឬ ឬក៏ទេវតាទាំងឡាយមកក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រ បើមិនលះបង់វាចានោះមិនគួរនឹង ។ បេ ។

---

១ អដ្ឋកថា ថា រូបដែលកំបាំងបាត់មើលមិនឃើញ ឬរូបប្លែកមានរូបសីហៈនិងខ្លាជាដើម ។

មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ ចេតសា ចេតោ បរិច្ច វិទិតោ ចេវ មេ សុនក្ខត្ត អចេលោ បាដិកបុត្តោ អភព្វោ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ ។ បេ ។ មុទ្ធាបិ តស្ស វិបតេយ្យាតិ ទេវតាបិ មម ឯតមត្ថំ អារោចេសុំ អភព្វោ ភន្តេ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ ។ បេ ។ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ អជិតោបិ នាម លិច្ឆវីនំ សេនាបតិ អធុនា កាលកតោ តាវតឹសកាយំ ឧបបន្នោ(១) សោបិ មំ ឧបសង្កមិត្វា ឯវមារោចេសិ អលជ្ជី ភន្តេ អចេលោ បាដិកបុត្តោ មុសាវាទី ភន្តេ អចេលោ បាដិកបុត្តោ មំបិ ភន្តេ អចេលោ បាដិកបុត្តោ ព្យាកាសិ វជ្ជិគាមេ អជិតោ លិច្ឆវីនំ សេនាបតិ មហានិរយំ ឧបបន្នោតិ ន ខោ បនាហំ ភន្តេ មហានិរយំ ឧបបន្នោ

---

១ ឱ. ឧប្បន្នោ ។

ក្បាលរបស់អចេលបាដិកបុត្រនោះមុខជានឹងធ្លាក់ចុះ ។ តថាគតពោលថា ម្នាលសុនក្ខត្ត៖ តថាគតបានកំណត់ដឹងចិត្តរបស់អចេលបាដិកបុត្រដោយចិត្តរបស់តថាគតថា អចេលបាដិកបុត្របើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនគួរនឹង ។បេ។ ក្បាលរបស់អចេលបាដិកបុត្រនោះមុខជានឹងធ្លាក់ចុះដូច្នេះផង ទាំងពួកទេវតាក៏ប្រាប់ដំណើរនុ៎ះដល់តថាគតថា បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនគួរនឹង ។បេ។ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះដូច្នេះផង ។ មិនតែប៉ុណ្ណោះ បុរសឈ្មោះអជិត ជាសេនាបតីរបស់ពួកស្តេចលិច្ឆវី ទើបនឹងធ្វើមរណកាលថ្មីៗ ទៅកើតក្នុងពួកទេវតាជាន់តាវត្តិង្ស ឯអជិតសេនាបតីនោះ ក៏ចូលមករកតថាគត ហើយប្រាប់យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រឥតមានសេចក្តីអៀនខ្មាស បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រ តែងពោលពាក្យកុហក បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រ បានទាយឲ្យខ្ញុំព្រះអង្គថា អជិតសេនាបតីរបស់ពួកស្តេចលិច្ឆវីកើតក្នុងវជ្ជិគ្រាម ទៅកើតក្នុងមហានរកដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនមែនទៅកើតក្នុងមហានរកឡើយ

តាវត្តឹសកាយំ (១) ឧបបន្នោ អលជ្ជី ភន្តេ អចេលោ បាដិកបុត្តោ មុសាវាទី ភន្តេ អចេលោ បាដិកបុត្តោ អភព្វោ ច (២) ភន្តេ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ ។ បេ ។ មុទ្ធាបិ តស្ស វិបតេយ្យាតិ ឥតិ ហោ សុនក្ខត្ត ចេតសា ចេតោ បរិច្ច វិទិតោ ចេវ មេ អចេលោ បាដិកបុត្តោ អភព្វោ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា មម សម្មុ-ខីភាវំ អាគន្តុំ សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិ-និស្សជ្ជិត្វា សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ទេវតាបិ មេ ឯតមត្ថំ អារោចេសុំ អភព្វោ ភន្តេ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា ភគវតោ សម្មុខីភាវំ អាគន្តុំ

---

១ ឱ. តាវត្តឹសម្ពិ កាយំ ។ ម. តាវត្តឹសកាយេហិ ។ ២ ឱ. បសត្ថោ ន វិស្សជិ ។

បានទៅកើត ក្នុងពួកទេវតាជាន់តាវត្តិង្សទេតើ បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រ ឥតមានសេចក្ដីអៀនខ្មាសទេ បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រតែងពោលពាក្យកុហក បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្របើមិនលះបង់វាចានោះ មិនគួរនឹង ។ បេ ។ ក្បាលរបស់អចេលបាដិកបុត្រនោះមុខជានឹងធ្លាក់ចុះមិនខាន ។ ម្នាលសុនក្ខត្ត: តថាគតបានកំណត់ដឹងចិត្តរបស់អចេលបាដិកបុត្រ ដោយចិត្តថា អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតឡើយ បើប្រសិនជាអចេលបាដិកបុត្រតាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណគោតមដូច្នេះ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះដូច្នេះផង ទាំងពួកទេវតាក៏ប្រាប់ដំណើរនុះដល់តថាគតថា បពិត្រព្រះអង្គដ៏ចំរើន អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះ

សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា សមណស្ស គោតមស្ស សម្មុខីភាវំ អាគច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ ឯសោ (១) ខោ បនាហំ សុនក្ខត្ត វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន អចេលស្ស បាដិកបុត្តស្ស អារាមោ តេនុបសង្កមី (២) ទិវាវិហារាយ យស្សទានិ ត្វំ សុនក្ខត្ត ឥច្ឆសិ តស្ស អារោចេហីតិ ។

(៧) អថខោ ស្វាហំ (៣) ភគ្គវ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរំ អាទាយ វេសាលិយំ បិណ្ឌាយ បាវិសឹ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន អចេលស្ស បាដិកបុត្តស្ស អារាមោ តេនុបសង្កមឹ ទិវាវិហារាយ ។ អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ តរមានរូបោ វេសាលឹ បវិសិត្វា យេន អភិញ្ញាតា អភិញ្ញាតា លិច្ឆវី តេនុបសង្កមិ ឧបសង្កមិត្វា អភិញ្ញាតេ អភិញ្ញាតេ

១ ឱ. សោ ។ ២ ឱ. ម. តេនុបសង្កមិស្សាមិ ។ ៣ ឱ. អថខោហំ ។ ម. អថខ្វាហំ ។

ព្រះភក្ត្រ នៃព្រះមានព្រះភាគបានឡើយ បើប្រសិនជាអចេលបាដិកបុត្រនោះតាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រព្រះសមណគោតម ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះដូចេះផង ។ ម្នាលសុនក្ខត្ត៖ ចំណែកខាងតថាគតត្រេចទៅដើម្បីបិណ្ឌបាតក្នុងក្រុងវេសាលី លុះដល់វេលាបច្ឆាភត្ត តថាគតត្រឡប់ពីបិណ្ឌបាតមក ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីទៅសម្រាកក្នុងវេលាថ្ងៃ ម្នាលសុនក្ខត្ត៖ ឥឡូវនេះ អ្នកចង់ប្រាប់នូវរឿងណា អ្នកចូរប្រាប់នូវរឿងនោះមកចុះ ។

(៧) ម្នាលភគ្គវៈ គ្រានោះឯង តថាគតស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងវេលាព្រឹកព្រហាម ចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី លុះចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលីហើយ ត្រឡប់ពីបិណ្ឌបាតមកវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីទៅសម្រាកក្នុងវេលាថ្ងៃ ។ ម្នាលភគ្គវៈ លំដាប់នោះឯង សុនក្ខត្តលិច្ឆវីបុត្រ ជាអ្នកចូលទៅកាន់ក្រុងវេសាលី ដោយប្រញាប់ប្រញាល់ហើយ ក៏ចូលទៅរកពួកលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ លុះចូលទៅដល់ហើយ ក៏និយាយនឹងពួកលិច្ឆវីដែល

លិច្ឆវី ឯតទវោច ឯសាវុសោ ភគវា វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន អចេលស្ស បាដិកបុត្តស្ស អារាមោ តេនុប-សង្កមិ ទិវា វិហារាយ អភិក្កមថាយស្មន្តោ អ-ភិក្កមថាយស្មន្តោ សាធុរូបានំ សមណានំ ឧត្តរិម-នុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតីតិ ។ អថខោ ភគ្គវ អភិញ្ញាតានំ អភិញ្ញាតានំ លិច្ឆវីនំ ឯតទហោសិ សាធុរូបានំ កិរ ភោ សមណានំ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតិ ហន្ទ វត ភោ គច្ឆាមាតិ ។ យេន ច អភិញ្ញាតា អភិញ្ញាតា ព្រាហ្មណមហាសាលា គហបតិនេចយិកា នានាតិត្ថិយស្សមណព្រាហ្មណា[១] តេនុបសង្កមិ ឧបសង្កមិត្វា អភិញ្ញាតេ អភិញ្ញាតេ នានាតិត្ថិយេស្សមណព្រាហ្មណេ ឯតទវោច ឯសាវុសោ

---

១ ឱ. ម នានាតិត្ថិយា សមណព្រាហ្មណា ។

មានកេរ្តិ៍ឈ្មោះប្រាកដជាងគេ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគនុ៎ះ ទ្រង់ពុទ្ធដំណើរទៅបិណ្ឌបាត ក្នុងក្រុងវេសាលី ព្រះអង្គត្រឡប់ពីបិណ្ឌបាតមកវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីនៅសម្រាក ក្នុងវេលាថ្ងៃ បពិត្រអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរអញ្ជើញទៅ បពិត្រអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរអញ្ជើញទៅ ដ្បិតឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែង ជាងធម៌របស់មនុស្ស នៃសមណៈទាំងឡាយ មានសភាពដ៏ល្អ មុខជានឹងមានមិនខាន ៗ ម្នាលភគ្គវៈ គ្រានោះឯង ពួកលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏ប្រឹក្សាគ្នាដូច្នេះថា ម្នាលគ្នាយើង បានឮថាឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស របស់សមណៈទាំងឡាយមានសភាពដ៏ល្អ មុខជានឹងមានមិនខាន ម្នាលគ្នាយើង បើដូច្នោះមានតែយើងទាំងឡាយ នាំគ្នាទៅមើល ៗ ឯសុនក្ខត្តលិច្ឆវីបុត្រ ក៏ដើរចូលទៅរកពួកព្រាហ្មណមហាសាល និងគហបតី អ្នកសន្សំទ្រព្យ សមណព្រាហ្មណ៍ដែលមានលទ្ធិផ្សេង ៗ មានកេរ្តិ៍ឈ្មោះប្រាកដជាងគេ លុះចូលទៅដល់ហើយ បាននិយាយទៅនឹងសមណព្រាហ្មណ៍ ដែលមានលទ្ធិផ្សេង ៗ មានកេរ្តិ៍ឈ្មោះប្រាកដ

ភគវ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន អចេលស្ស បាដិកបុត្តស្ស អារាមោ តេនុបសង្កមិំ ទិវាវិហារាយ អភិក្កមថាយស្មន្តោ អភិក្កមថាយស្មន្តោ សាធុរូបានំ សមណានំ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតីតិ ។ អថខោ ភគ្គវ អភិញ្ញាតានំ អភិញ្ញាតានំ នានាតិត្ថិយសមណព្រាហ្មណានំ ឯតទហោសិ សាធុរូបានំ កិរ ភោ សមណានំ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករិស្សតិ ហន្ទ វត ភោ គច្ឆាមាតិ ។ អថខោ ភគ្គវ អភិញ្ញាតា អភិញ្ញាតា លិច្ឆវី អភិញ្ញាតា អភិញ្ញាតា ច ព្រាហ្មណមហាសាលា គហបតិនេចយិកា នានាតិត្ថិយសមណព្រាហ្មណា យេន អចេលស្ស បាដិកបុត្តស្ស អារាមោ តេនុបសង្កមឹសុ ។ សា ឯសា ភគ្គវ បរិសា ហោតិ អនេ-

ជាងគេដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគនុ៎ះ ទ្រង់ពុទ្ធដំណើរទៅបិណ្ឌបាតក្នុងក្រុងវេសាលី ព្រះអង្គត្រឡប់ពីបិណ្ឌបាតមកវិញក្នុងវេលាក្រោយភត្ត ក៏ចូលសំដៅទៅត្រង់អារាមរបស់អចេលបាដិកបុត្រ ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ នែអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរអញ្ជើញទៅ នែអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរអញ្ជើញទៅ ដ្បិតឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស នៃសមណៈទាំងឡាយ មានសភាពដ៏ល្អ មុខជានឹងមានមិនខាន ។ ម្នាលភគ្គវៈ លំដាប់នោះឯង ពួកសមណព្រាហ្មណ៍ ដែលមានលទ្ធិផ្សេង ៗ មានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏ប្រឹក្សាគ្នាដូច្នេះថា ម្នាលគ្នាយើង បានឮថា ឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស នៃសមណៈទាំងឡាយ មានសភាពដ៏ល្អ មុខជានឹងមានមិនខាន ម្នាលគ្នាយើង បើដូច្នោះ មានតែពួកយើងនាំគ្នាទៅមើល ។ ម្នាលភគ្គវៈ លំដាប់នោះឯង ពួកលិច្ឆវី ដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ នឹងពួកព្រាហ្មណមហាសាល នឹងគហបតីអ្នកសន្សំទ្រព្យ នឹងពួកសមណព្រាហ្មណ៍មានលទ្ធិផ្សេង ៗ សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ បាននាំគ្នាចូលទៅកាន់អារាម របស់អចេល-បាដិកបុត្រ ។ ម្នាលភគ្គវៈ បរិសទ្យនោះ មានប្រមាណច្រើនរយ

បាដិកសុត្ត អចេលបាដិកបុត្តភយឆម្ភិតត្តលោមហំសកថា

ការសតា អនេកសហស្សា ។ អស្សោសិ ខោ ភគ្គវ អចេលោ បាដិកបុត្តោ អភិក្កន្តា កិរ អភិញ្ញាតា អភិញ្ញាតា លិច្ឆវី អភិក្កន្តា អភិញ្ញាតា អភិញ្ញាតា ច ព្រាហ្មណមហាសាលា គហបតិនេចយិកា នានាតិត្ថិយសមណព្រាហ្មណា សមណោបិ គោតមោ មយ្ហំ អារាមេ ទិវាវិហារំ និសិន្នោតិ ។ សុត្វានស្ស ភយំ ឆម្ភិតត្តំ លោមហំសោ ឧទបាទិ ។ អថខោ ភគ្គវ អចេលោ បាដិកបុត្តោ ភីតោ សំវិគ្គោ លោមហដ្ឋជាតោ(១) យេន តិន្ទុកខាណុបរិព្វាជការាមោ(២) តេនុបសង្កមិ ។ អស្សោសិ ខោ ភគ្គវ សា បរិសា អចេលោ កិរ បាដិកបុត្តោ ភីតោ សំវិគ្គោ លោមហដ្ឋជាតោ យេន តិន្ទុកខាណុបរិព្វាជការាមោ តេនុបសង្កន្តោតិ ។ អថខោ ភគ្គវ សា បរិសា អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ ភោ បុរិស យេន តិន្ទុកខាណុបរិព្វាជការាមោ យេន អចេលោ បាដិកបុត្តោ តេនុបសង្កម ឧប-

---

១ កត្ថចិ បោត្ថកេ លោមហំសជាតោតិ បាឋោ ទិស្សតិ ។ ២ ឱ. តិណ្ឌុកខាណុបរិព្វាជការាមោ ។

ច្រើនពាន់នាក់ ។ ម្នាលភគ្គវៈ អចេលបាដិកបុត្រ បានឮដំណឹងថា ពួកស្ដេចលិច្ឆវី សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដផងគេ បានមកហើយ ពួកព្រាហ្មណមហាសាលនឹងគហបតីអ្នកសន្សំទ្រព្យ នឹងសមណព្រាហ្មណ៍មានលទ្ធិផ្សេង ៗ សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដផងគេ ក៏បានមកដែរ ព្រះសមណគោតម ក៏គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អាត្មាអញ ។ អចេលបាដិកបុត្រនោះ លុះឮដំណឹងហើយក៏កើតភ័យរន្ធត់ព្រឺព្រួចអស់ទាំងរោម ។ ម្នាលភគ្គវៈ លំដាប់នោះឯង លុះអចេលបាដិកបុត្រ កើតមានភ័យតក់ស្លុតព្រឺព្រួចរោមហើយ ក៏ចូលទៅឯតិណ្ឌុកខានុបរិព្វាជការាម(១) ។ ម្នាលភគ្គវៈ បរិសទ្យនោះបានឮដំណឹងថា អចេលបាដិកបុត្រ កើតមានភ័យតក់ស្លុតព្រឺព្រួចរោមហើយ ក៏ចូលទៅឯតិណ្ឌុកខានុបរិព្វាជការាម ។ ម្នាលភគ្គវៈ វេលានោះឯង បរិសទ្យនោះហៅបុរសម្នាក់មកថា នែបុរសដ៏ចំរើន អ្នកចូរមកនេះ អ្នកចូលទៅរកអចេលបាដិកបុត្រ ក្នុងតិណ្ឌុកខានុបរិព្វាជការាម លុះចូលទៅដល់ហើយ

---

១ អារាមរបស់បរិព្វាជកដែលគេកំណត់ដោយជង្គត់ដើមដង្កោឬទន្លាប់ ។

សង្កមិត្វា អចេលំ ថាដិកបុត្តំ ឯវំ វទេហិ អភិក្កមាវុ-
សោ ថាដិកបុត្ត អភិក្កន្តា អភិញ្ញាតា អភិញ្ញាតា
លិច្ឆវី អភិក្កន្តា អភិញ្ញាតា អភិញ្ញាតា ច ព្រាហ្មណ-
មហាសាលា គហបតិនេចយិកា នានាតិត្ថិយសមណ-
ព្រាហ្មណា សមណោបិ គោតមោ អាយស្មតោ
អារាមេ ទិវាវិហារំ និសិន្នោ ភាសិតា ខោ បន តេ
ឯសាវុសោ ថាដិកបុត្ត វេសាលិយំ បរិសតិ វាចា
សមណោបិ គោតមោ ញាណវាទោ អហំបិ ញា-
ណវាទោ ញាណវាទោ ខោ បន ញាណវាទេន
អរហតិ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ទស្សេ-
តុំ សមណោ គោតមោ ឧបឌ្ឍបថំ អាគច្ឆេយ្យ
អហំបិ(១) ឧបឌ្ឍបថំ គច្ឆេយ្យំ តេ តត្ថ ឧភោបិ(២) ឧត្ត-
រិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករេយ្យាម ឯកញ្ចេ(៣)
សមណោ គោតមោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ
ករិស្សតិ ទ្វាហំ ករិស្សាមិ ទ្វេ ចេ សមណោ គោត-
មោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយានិ ករិស្សតិ
ចត្តារាហំ ករិស្សាមិ ចត្តារិ ចេ សមណោ គោតមោ

---

១ ឱ. អហំ ។ ២ ឱ. ឧភោ ។ ៣ ម. ឯកំ ចេ ។

ចូរនិយាយនឹងអចេលបាដិកបុត្រ យ៉ាងនេះថា នែអាវុសោបាដិកបុត្រ ចូរអ្នកត្រឡប់ទៅវិញ ព្រោះពួកស្តេចលិច្ឆវី សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ បាននាំគ្នាមកហើយ ពួកព្រាហ្មណមហាសាល ពួកគហបតីអ្នកសន្សំទ្រព្យ នឹងពួកសមណព្រាហ្មណ៍មានលទ្ធិផ្សេង ៗ សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏បាននាំគ្នាមកដែរ ទាំងព្រះសមណគោតមសោត ក៏នៅគង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អ្នកមានអាយុ នែអាវុសោបាដិកបុត្រ ចំណែកអ្នកបានពោលវាចានេះ ក្នុងកណ្តាលបរិសទ្យក្នុងក្រុងវេសាលីថា សមណគោតមជាញាណវាទ យើងក៏ជាញាណវាទដែរ ចំណែកបុគ្គលជាញាណវាទ គួរសំដែងឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស មួយអន្លើដោយបុគ្គលជាញាណវាទដូចគ្នា ព្រះសមណគោតម គួរមកកាន់ទីពាក់កណ្តាលផ្លូវ ឯយើងក៏គួរទៅកាន់ទីពាក់កណ្តាលផ្លូវដែរ យើងទាំងពីរនាក់នោះនឹងធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរ ក្រៃលែងជាងធម៌របស់មនុស្ស ក្នុងទីដែលជួបគ្នានោះ បើព្រះសមណគោតម នឹងធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបាន ១ យើងអាចនឹងធ្វើបាន ២ បើព្រះសមណគោតម នឹងធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សបាន ២ យើងអាចនឹងធ្វើបាន ៤ បើព្រះសមណគោតម

ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយានិ ករិស្សតិ អដ្ឋាហំ ករិស្សាមិ ឥតិ យាវតកំ យាវតកំ សមណោ គោតមោ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយានិ ករិស្សតិ តទ្ទិគុណំ តទ្ទិគុណាហំ ករិស្សាមីតិ អតិក្កមយេវ[1] ខោ អាវុសោ បាដិកបុត្ត ឧបឌ្ឍបថំ សព្វប្បឋមំយេវ អាគន្ត្វា សមណោ គោតមោ អាយស្មតោ អារាមេ ទិវាវិហារំ និសិន្នោតិ ។ ឯវំ ភោតិ ខោ ភគ្គវ សោ បុរិសោ តស្សា បរិសាយ បដិស្សុត្វា យេន តិន្ទុកខាណុបរិព្វាជការាមោ យេន អចេលោ បាដិកបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អចេលំ បាដិកបុត្តំ ឯតទវោច អតិក្កមាវុសោ បាដិកបុត្ត អភិក្កន្តា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី អភិក្កន្តា អភិញ្ញាតា អភិញ្ញាតា ព្រាហ្មណមហាសាលា ។ បេ ។ អតិក្កមយេវ អាវុសោ[2]

---

១ ម. អភិក្កមស្សេវ ។ ២ ឧ. លិច្ឆវី... ។ បេ ។... សមណោ គោតមោ អាយស្មតោ អារាមេ ទិវាវិហារំ និសិន្នោ ។ ភាសិតា ខោ បន តេ ឯសាវុសោ បាដិកបុត្ត វេសាលិយំ បរិសតិ វាចា សមណោបិ គោតមោ ញាណវាទោ អហម្បិ ញាណវាទោ...។ បេ ។... តទ្ទិគុណំ តទ្ទិគុណាហំ ករិស្សាមីតិ ។ អតិក្កមយេវ ខោ អាវុសោតិ ទិស្សតិ ។

នឹងធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ ដ៏ប្រសើរក្រៃលែងជាងធម៌ របស់មនុស្ស បាន ៤ យើងអាចនឹងធ្វើបាន ៨ បើព្រះសមណគោតម នឹងធ្វើឥទ្ធិបាដិហា-រិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស បានប៉ុន្មានៗ យើងអាចនឹងធ្វើឲ្យបានជាទ្វេគុណៗ ជាងនោះៗ ទៅទៀតដូច្នេះឯង ម្នាលអាវុសោបាដិកបុត្រ អ្នកចូរត្រឡប់ទៅកាន់ទីពាក់កណ្តាលផ្លូវចុះ ព្រះសមណ-គោតម ទ្រង់ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយ គង់សម្រាកនៅវេលាថ្ងៃ ក្នុងអារាមរបស់អ្នកមានអាយុ ៗ ម្នាលភគ្គវៈ បុរសនោះទទួលពាក្យបរិសទ្យនោះថា អើអ្នកដ៏ចំរើន ហើយក៏ចូលទៅរកអចេល-បាដិកបុត្រ ក្នុងតិណ្ឌុកខាណុបរិព្វាជការាម លុះចូលទៅដល់ហើយ បាននិយាយនឹងអចេលបាដិកបុត្រ យ៉ាងនេះថា ម្នាលអាវុសោបាដិកបុត្រ អ្នកចូរត្រឡប់ទៅវិញ ព្រោះពួកស្តេចលិច្ឆវី សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រា-កដជាងគេ បាននាំគ្នាមកហើយ ពួកព្រាហ្មណមហាសាលសុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ក៏បាននាំគ្នាមកដែរ ។ បេ ។ ម្នាលអាវុសោ

បាដិកបុត្ត ឧបឌ្ឍបដំ សព្វព្យាមិយេវ អាគន្ត្វា សមណោ គោតមោ អាយស្មតោ អារាមេ ទិវាវិហារំ និសិន្នោតិ ។ ឯវំ វុត្តេ ភគ្គវ អចេលោ បាដិកបុត្តោ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុំ ។ អថខោ សោ ភគ្គវ បុរិសោ អចេលំ បាដិកបុត្តំ ឯតទវោច កឹសុ នាម តេ អាវុសោ បាដិកបុត្ត បាវឡាសុ នាម តេ បីឋកស្មឹ អល្លីនា បីឋកំសុ នាម តេ បាវឡាសុ(១) អល្លីនំ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បសិ ន សក្កោសិ អាសនាបិ វុដ្ឋាតុន្តិ ។ ឯវំបិ ខោ ភគ្គវ វុច្ចមានោ អចេលោ បាដិកបុត្តោ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុំ ។ យទា ខោ សោ ភគ្គវ បុរិសោ អញ្ញាសិ បរាភូតរូបោ អយំ អចេលោ បាដិកបុត្តោ អាយាមិ អាវុសោ

---

១ ម. ភវត្ត សោ ១ បាវឡាយន្តិ បទេន ភវិតព្វំ ។

បាដិកបុត្រ អ្នកចូរទៅកាន់ទីពាក់កណ្តាលផ្លូវ ព្រះសមណគោតម ទ្រង់ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយ គង់សម្រាកព្រះអង្គនៅវេលាថ្ងៃក្នុងអារាមរបស់អ្នកមានអាយុ ។ ម្នាលភគ្គវៈ កាលបើបុរសនោះនិយាយយ៉ាងនេះហើយ អចេលបាដិកបុត្រឆ្លើយថា ម្នាលអ្នកមានអាយុ ខ្ញុំនឹងទៅ ម្នាលអ្នកមានអាយុ ខ្ញុំនឹងទៅ ហើយក៏អង្គុយជ្រប់នៅត្រង់ទីនោះឯង មិនអាចក្រោកចាកអាសនៈបានឡើយ ។ ម្នាលភគ្គវៈ ទើបបុរសនោះនិយាយនឹងអចេលបាដិកបុត្រ យ៉ាងនេះថា ម្នាលអាវុសោបាដិកបុត្រ គូទអ្នកជាប់នៅនឹងតាំងរបស់អ្នកឬ ឬតាំងជាប់ស្អិតនៅនឹងគូទរបស់អ្នក បានជាអ្នកគ្រាន់តែនិយាយថា ម្នាលអ្នកមានអាយុ ខ្ញុំនឹងទៅ ម្នាលអ្នកមានអាយុ ខ្ញុំនឹងទៅ ដូច្នេះហើយក៏នៅតែអង្គុយសំកុកត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបាន ។ ម្នាលភគ្គវៈ អចេលបាដិកបុត្រ បើទុកជាបុរសនោះនិយាយយ៉ាងនេះ ក៏នៅតែនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោ ខ្ញុំនឹងទៅដូច្នេះហើយក៏នៅតែអង្គុយជ្រប់ ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលណាបុរសនោះដឹងថា អចេល-បាដិកបុត្រនេះបរាជ័យហើយនៅតែនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ

អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុំ អថ តំ បរិសំ អាគន្ត្វា ឯវមារោចេសិ បរាភូតរូបោ ភោ អយំ(១) អចេលោ បាដិកបុត្តោ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុន្តិ ។ ឯវំ វុត្តេ អហំ ភគ្គវ តំ បរិសំ ឯតទវោចំ អភព្វោ ខោ អាវុសោ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា មម សម្មុខីភាវំ អាគន្តុំ សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។

បឋមភាណវារំ និដ្ឋិតំ ។

---

១ ឱ. ភោ អយន្តិ ន ទិស្សតិ ។

ម្នាលអាវុសោ ទំនឹងទៅ ដូច្នេះហើយក៏នៅតែអង្គុយជ្រប់ ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ កាលនោះ បុរសនោះក៏ត្រឡប់មកកាន់បរិសទ្យនោះវិញ ហើយប្រាប់យ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អចេលបាដិកបុត្រនេះ បរាជ័យហើយ ក៏នៅតែនិយាយថា ម្នាលអាវុសោ ទំនឹងទៅ ម្នាលអាវុសោ ទំនឹងទៅ ដូច្នេះហើយក៏នៅតែអង្គុយជ្រប់ ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលបើបុរសនោះ និយាយយ៉ាងនេះហើយ តថាគតបាននិយាយនឹងបរិសទ្យនោះដូច្នេះថា ម្នាលអ្នកមានអាយុ អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតឡើយ ប្រសិនបើជាអចេលបាដិកបុត្រនោះ តាំងចិត្តយ៉ាងនេះថា កាត្តាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញឡើយ ហើយទៅកាន់ទីចំពោះព្រះភក្ត្រ នៃព្រះសមណគោតមឲ្យបានដូច្នេះ ក្បាលរបស់អចេលបាដិបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន ។

ចប់ បឋមភាណវារៈ ។

(៨) អថខោ ភគ្គវ អញ្ញតរោ លិច្ឆវិមហាមត្តោ ឧដ្ឋាយាសនា តំ បរិសំ ឯតទវោច តេនហិ ភោ មុហុត្តំ តាវ អាគមេថ យាវាហំ គច្ឆាមិ អប្បេវនាម អហំបិ សក្កុណេយ្យំ អចេលំ បាដិកបុត្តំ ឥមំ បរិសំ អានេតុន្តិ ។ អថខោ សោ ភគ្គវ លិច្ឆវិមហាមត្តោ យេន តិន្ទុកខាណុបរិព្វាជការាមោ យេន អចេលោ បាដិកបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អចេលំ បាដិកបុត្តំ ឯតទវោច អភិក្កមាវុសោ បាដិកបុត្ត អភិក្កន្តំ តេ សេយ្យោ អភិក្កន្តា អភិញ្ញាតា អភិញ្ញាតា ច ។ សន្និន្តិ(១) ។ សមណោបិ គោតមោ អាយស្មតោ អារាមេ ទិវាវិហារំ និសិន្នោ ភាសិតា ខោ បន តេ ឯសាវុសោ បាដិកបុត្ត វេសាលិយំ បរិសតិ វាចា សមណោបិ គោតមោ ញាណវាទោ អហំបិ ញាណវាទោ ។ បេ ។ តទ្ទិគុណំ តទ្ទិគុណាហំ ករិស្សាមីតិ អភិក្កមយេវ(២) ខោ អាវុសោ បាដិកបុត្ត

១ ឱ. អយំ បាឋោ ន ទិស្សតិ ។ ២ ម. អភិក្កមស្សេវ ។

(៨) ម្នាលភគ្គវៈ លំដាប់នោះឯង លិច្ឆវីមហាមាត្រម្នាក់ក្រោកចាកអាសនៈ ហើយនិយាយនឹងបរិសទ្យនោះយ៉ាងនេះថា នែអ្នកដ៏ចំរើន បើដូច្នោះអ្នកទាំងឡាយ ចូរនៅចាំមួយរំពេចសិន ទំរាំខ្ញុំទៅ ក្រែងជួនជាខ្ញុំអាចនាំអចេលបាដិកបុត្រ មកកាន់បរិសទ្យនេះបាន ។ ម្នាលភគ្គវៈ ទើបលិច្ឆវីមហាមាត្រនោះ ចូលទៅរកអចេលបាដិកបុត្រ ក្នុងតិណ្ឌុកខានុបរិព្វាជការាម លុះចូលទៅដល់ហើយ បាននិយាយនឹងអចេលបាដិកបុត្រយ៉ាងនេះថា ម្នាលអាវុសោបាដិកបុត្រ ចូរអ្នកត្រឡប់ទៅវិញ ការដែលអ្នកត្រឡប់ទៅវិញប្រសើរជាង ព្រោះពួកជនដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ បាននាំគ្នាទៅអស់ហើយ ។ សេចក្តីបំប្រួញ ។ ទាំងព្រះសមណគោតមសោត ក៏គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អ្នកមានអាយុ ម្នាលអាវុសោបាដិកបុត្រ ឯអ្នកក៏បាននិយាយសំដីនេះក្នុងកណ្តាលបរិសទ្យ ក្នុងក្រុងវេសាលីថា ព្រះសមណគោតមជាញាណវាទ ឯយើងក៏ជាញាណវាទដែរ ។ បេ ។ យើងអាចនឹងធ្វើឲ្យជាទ្វេគុណ ៗ ជាងនោះ ៗ ទៀតបានដូច្នេះ ម្នាលអាវុសោបាដិកបុត្រ

## បាដិកសុត្តេ អចេលបាដិកបុត្តស្ស បរាភូតរូបកថា

ឧបឌ្ឍបថំ សព្វបឋមំយេវ អាគន្ត្វា សមណោបិ[១] គោ-
តមោ អាយស្មតោ អារាមេ ទិវាវិហារំ និសិន្នោ ភាសិតា
ខោ បនេសា អាវុសោ[២] បាដិកបុត្ត សមណេន
គោតមេន បរិសតិ វាចា អភព្វោ អចេលោ បាដិក-
បុត្តោ តំ វាចំ អប្បហាយ ។ បេ ។ មុទ្ធាបិ តស្ស
វិបតេយ្យាតិ អភិក្កមាវុសោ បាដិកបុត្ត អភិក្កមេនេវ
តេ ជយំ ករិស្សាម សមណស្ស គោតមស្ស បរាជ-
យន្តិ ។ ឯវំ វុត្តេ ភគ្គវ អចេលោ បាដិកបុត្តោ អាយាមិ
អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ
ន សក្កោតិ អាសនាបិ វុដ្ឋាតុំ ។ អថខោ សោ
ភគ្គវ លិច្ឆវិមហាមត្តោ អចេលំ បាដិកបុត្តំ ឯតទវោច
កឹសុ នាម តេ អាវុសោ បាដិកបុត្ត បាវឡាសុ នាម
តេ បីឋកស្មឹ អល្លីនា បីឋកំ សុ នាម តេ បាវឡាសុ
អល្លីនំ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា
តត្ថេវ សំសប្បសិ ន សក្កោសិ អាសនាបិ វុដ្ឋាតុន្តិ ។

---

១ ឱ. សមណោ ។ ២ ឱ. ខោ បន តេ ឯសាវុសោ ។

ចូរអ្នកត្រឡប់ទៅកាន់ទីពាក់កណ្ដាលផ្លូវចុះ ព្រះសមណគោតម ទ្រង់ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយគង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អ្នកមានអាយុ ម្នាលអាវុសោបាដិកបុត្រ មួយវិញទៀត ព្រះសមណគោតមបានត្រាស់ព្រះវាចានេះ ក្នុងកណ្ដាលបរិសទ្យថា អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ ។ បេ ។ ក្បាលរបស់អចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខានឡើយ នែអាវុសោបាដិកបុត្រ អ្នកចូរត្រឡប់ទៅវិញចុះ យើងនឹងឲ្យជ័យជំនះដល់អ្នក នឹងឲ្យព្រះសមណគោតមចាញ់វិញ ព្រោះការដែលអ្នកហ៊ានត្រឡប់ទៅវិញប៉ុណ្ណោះ ។ ម្នាលភគ្គវៈ កាលបើលិច្ឆវីមហាមាត្រនោះនិយាយយ៉ាងនេះហើយ អចេលបាដិកបុត្រក៏និយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោ ខ្ញុំនឹងទៅដូច្នេះ ហើយក៏នៅអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ ម្នាលភគ្គវៈ ទើបលិច្ឆវីមហាមាត្រនោះនិយាយនឹងអចេលបាដិកបុត្រយ៉ាងនេះថា នែអាវុសោបាដិកបុត្រ គូថអ្នកជាប់ស្អិតនៅនឹងតាំងរបស់អ្នកឬ ឬតាំងជាប់ស្អិតនៅនឹងគូថរបស់អ្នក បានជាអ្នកនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោ ខ្ញុំនឹងទៅដូច្នេះ ហើយក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែលមិនអាចក្រោកចាកអាសនៈបានឡើយ ។

ឯវំ ខោ ភគ្គវ វុច្ចមានោ អចេលោ បាដិកបុត្តោ អា-
យាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំ-
សប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុំ ។ យទា ខោ
ភគ្គវ(១) លិច្ឆវិមហាមត្តោ អញ្ញាសិ បរាភូតរូបោ អយំ
អចេលោ បាដិកបុត្តោ អាយាមិ អាវុសោ អាយាមិ
អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាស-
នាបិ វុដ្ឋាតុន្តិ អថ តំ បរិសំ អាគន្ត្វា ឯវំ អារោចេសិ
បរាភូតរូបោ អយំ(២) អចេលោ បាដិកបុត្តោ អាយាមិ
អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ
ន សក្កោតិ អាសនាបិ វុដ្ឋាតុន្តិ ។ ឯវំ វុត្តេ អហំ
ភគ្គវ តំ បរិសំ ឯតទវោចំ អភព្វោ ខោ អាវុសោ
អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ
ចិត្តំ អប្បហាយ ។ បេ ។ សចេបិស្ស ឯវមស្ស
អហន្តំ វាចំ អប្បហាយ ។ បេ ។ សមណស្ស
គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស
វិបតេយ្យាតិ សចេបាយស្មន្តានំ លិច្ឆវីនំ ឯវមស្ស

---

១ ឱ. ម. យទា ខោ សោ ភគ្គវ ។ ២ ឱ. ម. សោ ។

ម្នាលភគ្គវៈ អចេលបាដិកបុត្រ បើទុកជាលិច្ឆវីមហាមាត្រនិយាយយ៉ាងនេះក្តី ក៏នៅតែនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោ ខ្ញុំនឹងទៅដូច្នេះ ហើយក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលណាលិច្ឆវីមហាមាត្របានដឹងច្បាស់ថា អចេលបាដិកបុត្រនេះបរាជ័យហើយ ក៏នៅតែនិយាយថា ម្នាលអាវុសោ ខ្ញុំនឹងទៅ ម្នាលអាវុសោ ខ្ញុំនឹងទៅដូច្នេះ ហើយក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយដូច្នេះហើយ ទើបត្រឡប់មកកាន់បរិស័ទនោះវិញ ប្រាប់យ៉ាងនេះថា អចេល-បាដិកបុត្រនេះបរាជ័យហើយក៏នៅតែនិយាយថា នែអាវុសោ ខ្ញុំនឹងទៅ នែអាវុសោ ខ្ញុំនឹងទៅ ដូច្នេះហើយ ក៏នៅតែអង្គុយជ្រប់ ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលបើលិច្ឆវីមហាមាត្រនិយាយយ៉ាងនេះហើយ តថាគតក៏និយាយនឹងបរិស័ទនោះដូច្នេះថា ម្នាលអាវុសោទាំងឡាយ អចេលបាដិកបុត្របើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនគួរ ។បេ។ ប្រសិនបើអចេលបាដិកបុត្រនោះគាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ ។បេ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណគោតមដូច្នេះ ក្បាលអចេល-បាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន ទោះបីពួកលិច្ឆវីដ៏មានអាយុ

បយំ អចេលំ បាដិកបុត្តំ យាហិ វរត្តាហិ ពន្ធិត្វា គោយុត្តេហិ អាវិញ្ឆេយ្យាមាតិ(១) តា វរត្តា ឆិជ្ជេរុំ(២) បាដិកបុត្តោ វា អភព្វោ បន(៣) អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ ។ បេ ។ សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ ។ បេ ។ សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។

(៩) អថខោ ភគ្គវ ជាលិយោ ទារុបត្តិកន្តេវាសី ឧដ្ឋាយាសនា តំ បរិសំ ឯតទវោច តេនហិ ភោ មុហុត្តំ តាវ អាគមេថ យាវាហំ គច្ឆាមិ អប្បេវនាមាហំ(៤) សក្កុណេយ្យំ អចេលំ បាដិកបុត្តំ អានេតុន្តិ(៥) ។ អថខោ ភគ្គវ ជាលិយោ ទារុបត្តិកន្តេវាសី យេន តិណ្ឌុកខាណុបរិព្វាជការាមោ យេន អចេលោ បាដិកបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អចេលំ បាដិកបុត្តំ ឯតទវោច អភិក្កមាវុសោ

---

១ ឱ. អាវិញ្ឆេយ្យាមាតិ ។ ២ ម. ឆិជ្ជេយ្យុំ ។ ៣ ម. បន តិ ន ទិស្សតិ ។
៤ ឱ. អប្បេវនាម អហម្បិ ។ ៥ ឱ. អចេលំ បាដិកបុត្តំ ឥមំ បរិសំ អានេតុន្តិ ។

គិតគ្នាថា បើទុកជាយើងទាំងឡាយ ចងអចេលបាដិកបុត្រ ដោយខ្សែព្រ័ត្រណា ហើយបង្អូសមក ដោយគោច្រើនទឹមដូច្នេះ ខ្សែព្រ័ត្រនោះនឹងដាច់ ឬខ្លួនអចេលបាដិកបុត្រឯងនឹងដាច់ ឯអចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនគួរ ។ល។ ប្រសិនបើអចេលបាដិកបុត្រនោះ គាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ ។ល។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណគោតម ដូច្នេះ ក្បាលអចេលបាដិកបុត្រនោះមុខជានឹងធ្លាក់ចុះមិនខាន ។

(៩) ម្នាលភគ្គវៈ លំដាប់នោះឯង ជាលិយបព្វជិតជាសិស្សរបស់ទារុបត្តិកបព្វជិត[១] ក្រោកចាកអាសនៈហើយនិយាយនឹងបរិសទ្យនោះយ៉ាងនេះថា នែអ្នកដ៏ចំរើន បើដូច្នោះអ្នកទាំងឡាយចូររង់ចាំមួយរំពេចសិន ទំរាំខ្ញុំទៅ ក្រែងចួនជាខ្ញុំអាចនាំអចេលបាដិកបុត្រមកបាន ។ ម្នាលភគ្គវៈ គ្រានោះឯង ជាលិយបព្វជិតជាសិស្សរបស់ទារុបត្តិកបព្វជិត បានចូលទៅរកអចេលបាដិកបុត្រ ក្នុងតិណ្ឌុកខានុបរិព្វាជការាម លុះចូលទៅដល់ហើយ បាននិយាយនឹងអចេលបាដិកបុត្រយ៉ាងនេះថា នែ

---

១ អ្នកបួសប្រើប្រាស់ភាត្រឈើ ។

បាដិកបុត្ត អភិក្កន្តំ តេ សេយ្យោ អភិក្កន្តា អភិញ្ញាតា អភិញ្ញាតា ច លិច្ឆវី ។ បេ ។ សមណោបិ គោតមោ អាយស្មតោ អារាមេ ទិវាវិហារំ និសិន្នោ ភាសិតា ខោ បន តេ អាវុសោ បាដិកបុត្ត វេសាលិយំ បរិសតិ វាចា សមណោបិ គោតមោ ញាណវាទោ ។ បេ ។ តទ្ទិគុណំ តទ្ទិគុណាហំ ករិស្សាមីតិ អភិក្កមាយេវ អាវុសោ បាដិកបុត្ត ឧបឌ្ឍបថំ សព្វបឋមំយេវ អាគន្ត្វា សមណោ គោតមោ អាយស្មតោ អារាមេ ទិវាវិហារំ និសិន្នោ ភាសិតា ខោ បន តេ អាវុសោ បាដិកបុត្ត សមណេន គោតមេន បរិសតិ វាចា អភព្វោ ខោ អាវុសោ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ ។ បេ ។ សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ ។ បេ ។ សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ សចេបាយស្មន្តានំ[1] លិច្ឆវីនំ ឯវមស្ស មយំ អចេលំ បាដិកបុត្តំ យោហិ វរត្តាហិ ពន្ធិត្វា

១ ឱ. សចេ អាយស្មន្តានំ ។

អាវុសោ បាដិកបុត្រ អ្នកចូរត្រឡប់ទៅវិញចុះ ការដែលអ្នកត្រឡប់ទៅវិញប្រសើរជាង ព្រោះពួកស្តេចលិច្ឆវី សុទ្ធតែមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ បាននាំគ្នាមកហើយ ។ បេ ។ ទាំងព្រះសមណគោតមក៏គង់សម្រាកព្រះអង្គនៅវេលាថ្ងៃ ក្នុងអារាមរបស់អ្នកមានអាយុ នៃអាវុសោបាដិកបុត្រ ឯអ្នកសោតក៏បាននិយាយសំដីនេះក្នុងកណ្តាលបរិសទ្យក្នុងក្រុងវេសាលីថា ព្រះសមណគោតម ជាញាណវាទ ។ បេ ។ យើងអាចនឹងធ្វើឲ្យជាទ្វេគុណ ៗ ជាងនេះទៅទៀត នៃអាវុសោបាដិកបុត្រ អ្នកចូរទៅកាន់ទីពាក់កណ្តាលផ្លូវចុះ ព្រះសមណគោតមទ្រង់ពុទ្ធដំណើរមកដល់មុនគេទាំងអស់ហើយ គង់សម្រាកព្រះអង្គនៅវេលាថ្ងៃក្នុងអារាមរបស់អ្នកមានអាយុ ម្នាលអាវុសោបាដិកបុត្រ មួយវិញទៀត ព្រះសមណគោតម បានត្រាស់ព្រះវាចានេះចំពោះរូបអ្នកក្នុងកណ្តាលបរិសទ្យថា នៃអាវុសោទាំងឡាយ អចេលបាដិកបុត្រមិនលះបង់វាចានោះ មិនគួរ ។បេ។ ប្រសិនជាអចេលបាដិកបុត្រនោះតាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ ។ បេ ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណគោតមដូច្នេះ ក្បាលអចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន ប្រសិនបើពួកលិច្ឆវីដ៏មានអាយុគិតគ្នាយ៉ាងនេះថា បើទុកជាយើងទាំងឡាយចងអចេលបាដិកបុត្រ ដោយខ្សែព្រ័ត្រណា ហើយ

គោយុត្តេហិ អាវិញ្ឆេយ្យាមាតិ តា វរត្តា ឆិជ្ជេរំ បាដិក-បុត្តោ វា អភព្វោ បន អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋិំ អប្បដិ-និស្សជ្ជិត្វា មម សម្មុខីភាវំ អាគន្តុំ សចេបិស្ស ឯវ-មស្ស អហន្តំ វាចំ អប្បហាយ ។ បេ ។ សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិប-តេយ្យាតិ អភិក្កមាវុសោ បាដិកបុត្ត អភិក្កមនមេវ តេ ជយំ ករិស្សាម សមណស្ស គោតមស្ស បរាជ-យន្តិ ។ ឯវំ វុត្តេ ភគ្គវ អចេលោ បាដិកបុត្តោ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុំ ។ អថខោ ភគ្គវ ជាលិ-យោ ទារុបត្តិកន្តេវាសី អចេលំ បាដិកបុត្តំ ឯតទវោច កិំសុ នាម តេ អាវុសោ បាដិកបុត្ត បាវឡាសុ នាម តេ បីឋកស្មឹ អល្លីនា បីឋកំសុ នាម តេ បាវឡាសុ អល្លីនំ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បសិ ន សក្កោសិ អាសនាបិ វុដ្ឋាតុន្តិ ។

បន្ទួសមកដោយគោប្រើនទឹមដូច្នេះ ខ្សែព្រ័ត្រទាំងនោះ នឹងដាច់ ឬខ្លួនអចេលបាដិកបុត្រឯងនឹងដាច់ ឯអចេលបាដិកបុត្របើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ ប្រសិនបើជាអចេលបាដិកបុត្រនោះតាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ ។បេ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្ត្រនៃព្រះសមណគោតមដូច្នេះ ក្បាលអចេលបាដិកបុត្រនោះមុខជានឹងធ្លាក់ចុះមិនខាន នែអាវុសោបាដិកបុត្រ អ្នកចូរត្រឡប់ទៅវិញចុះ យើងនឹងឲ្យជ័យជំនះដល់អ្នក នឹងឲ្យព្រះសមណគោតមចាញ់ ព្រោះការដែលអ្នកត្រឡប់ទៅវិញប៉ុណ្ណោះ ។ នែភគ្គវៈ កាលបើជាលិយៈនិយាយយ៉ាងនេះហើយ អចេលបាដិកបុត្រនៅតែនិយាយថា នែអាវុសោ ខ្ញុំនឹងទៅ នែអាវុសោ ខ្ញុំនឹងទៅ ដូច្នេះហើយក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ នែភគ្គវៈ គ្រានោះ ជាលិយៈជាសិស្សនៃទារុបត្តិកៈ បាននិយាយនឹងអចេលបាដិកបុត្រយ៉ាងនេះថា នែអាវុសោបាដិកបុត្រ គូថអ្នកជាប់ស្អិតនៅនឹងតាំងរបស់អ្នកឬ ឬតាំងជាប់ស្អិតនៅនឹងគូថរបស់អ្នក បានជាអ្នកនិយាយថា នែអាវុសោ ខ្ញុំនឹងទៅ នែអាវុសោ ខ្ញុំនឹងទៅ ដូច្នេះហើយក៏នៅតែអង្គុយជ្រប់ត្រង់ទីនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។

ឯវំបិ ខោ ភគ្គវ វុត្តមានោ អចេលោ បាថិកបុត្តោ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុំ ។ យទា ខោ ភគ្គវ ជាលិយោ ទារុបត្តិកន្តេវាសី អញ្ញាសិ បរាភូតរូបោ អយំ អចេលោ បាថិកបុត្តោ អាយាមិ អាវុសោ អាយាមិ អាវុសោតិ វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុន្តិ អថ នំ ឯតទវោច ភូតបុព្វំ អាវុសោ បាថិកបុត្ត សីហស្ស មិគរញ្ញោ ឯតទហោសិ យន្នូនាហំ អញ្ញតរំ វនសណ្ឌំ និស្សាយ អាសយំ កប្បេយ្យំ តត្រាសយំ កប្បេត្វា សាយណ្ហសមយំ អាសយា និក្ខមេយ្យំ អាសយា និក្ខមិត្វា វិជម្ភេយ្យំ វិជម្ភិត្វា(១) សមន្តា ចតុទ្ទិសា អនុវិលោកេយ្យំ សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទេយ្យំ តិក្ខត្តុំ សីហនាទំ នទិត្វា គោចរាយ បក្កមេយ្យំ សោ វរំ វរំ មិគសង្ឃំ(២) វធិត្វា

---

១ ម. វិជម្ភេត្វា ។ ២ ម. មិគសង្ឃេ ។

នែភគ្គវៈ អចេលបាដិកបុត្រ សូម្បីជាលិយៈស្ដីថាឲ្យយ៉ាងនេះ ក៏នៅតែនិយាយថា នែអាវុសោ ខ្ញុំនឹងទៅ នែអាវុសោ ខ្ញុំនឹងទៅ ហើយក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ នែភគ្គវៈ កាលណាជាលិយៈជាសិស្សទារុបត្តិកៈបានដឹងច្បាស់ថា អចេលបាដិកបុត្រនេះបរាជ័យហើយ ក៏នៅតែនិយាយថា នែអាវុសោ ខ្ញុំនឹងទៅ នែអាវុសោ ខ្ញុំនឹងទៅដូច្នេះ ហើយក៏នៅតែអង្គុយជ្រប់ត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ដូច្នេះហើយ ទើបនិយាយនឹងអចេលបាដិកបុត្រនោះយ៉ាងនេះថា នែអាវុសោបាដិកបុត្រ កាលពីព្រេងនាយមក មានសីហមិគរាជមួយ មានសេចក្ដីត្រិះរិះយ៉ាងនេះថា គួរតែអាត្មាអញនៅអាស្រ័យនឹងដងព្រៃមួយ ក៏សម្រេចការដេក លុះសម្រេចការដេកក្នុងដងព្រៃនោះហើយ ក្នុងវេលាសាយណ្ហសម័យ ត្រូវចេញពីទីដេក លុះចេញពីទីដេកហើយ ត្រូវមិតតពត់កាយ លុះមិតតពត់កាយហើយ ត្រូវក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញ លុះក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញហើយ ត្រូវបន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងហើយ ត្រូវចេញទៅរកចំណី អាត្មាអញនោះត្រូវសំឡាប់ហ្វូងម្រឹគដ៏ធំ ៗ ហើយ

មុទុមំសានិ មុទុមំសានិ ភក្ខយិត្វា តមេវ អាសយំ អជ្ឈុបេយ្យន្តិ ។ អថខោ សោ សីហោ(១) មិគរាជា អញ្ញតរំ វនសណ្ឌំ និស្សាយ អាសយំ កប្បេសិ តត្រាសយំ កប្បេត្វា សាយណ្ហសមយំ អាសយា និក្ខមិ អាសយា និក្ខមិត្វា វិជម្ភិ វិជម្ភិត្វា សមន្តា ចតុទ្ទិសា អនុវិលោកេសិ សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទិ តិក្ខត្តុំ សីហនាទំ នទិត្វា គោចរាយ បក្កាមិ សោ វរំ វរំ មិគសង្ឃំ វធិត្វា មុទុមំសានិ មុទុមំសានិ ភក្ខយិត្វា តមេវ អាសយំ អជ្ឈុបេសិ ។ តស្សេវ ខោ អាតុរោ ចាដិគាបុត្ត សីហស្ស មិគរញ្ញោ វិឃាសសំវទ្ធោ(២) ជរសិគាលោ និត្តោ ចេវ ពលវា ច ។ អថខោ អាតុរោ តស្ស ជរសិគាលស្ស ឯតទហោសិ កោ ចាហំ កោ សីហោ មិគរាជា យន្នូនាហំបិ អញ្ញតរំ វនសណ្ឌំ និស្សាយ អាសយំ កប្បេយ្យំ តត្រាសយំ កប្បេត្វា សាយណ្ហសមយំ អាសយា និក្ខមេយ្យំ

---

១ ឱ. សោ អាតុរោ សីហោ ។ ២ ឱ. វិឃាសេ សំវទ្ធោ ។

បរិភោគសាច់ដែលឆ្ងាញ់ៗ ហើយត្រឡប់ចូលទៅកាន់ទីដេកនោះដដែលវិញ ។ គ្រានោះឯង សីហមិគរាជនោះ អាស្រ័យនឹងដងព្រៃមួយសម្រេចការដេក លុះសម្រេចការដេកក្នុងដងព្រៃនោះហើយ ក្នុងវេលាសាយណ្ហសម័យ ក៏ចេញពីទីដេក លុះចេញពីទីដេកហើយ បិតពត់ខ្លួន លុះមិតពត់ខ្លួនហើយ ក្រឡេកមើលទិសទាំង ៤ ដោយជុំវិញ លុះក្រឡេកមើលទិសទាំង ៤ ដោយជុំវិញហើយ បន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងហើយ ទើបចេញទៅរកចំណី សីហមិគរាជនោះសម្លាប់ហ្វូងម្រឹគដ៏ធំៗ ហើយបរិភោគសាច់ដែលឆ្ងាញ់ៗ រួចត្រឡប់ចូលទៅកាន់ទីដេកនោះដដែលវិញ ។ នៃករុសោបាដិកបុត្រ មានចចកចាស់មួយ ស៊ីសាច់រំពារបស់សីហមិគរាជនោះឯង ហើយចំរើន (សាច់ឈាម)ធាត់ធំមានកំឡាំងឡើង ៗ ម្នាលករុសោ លំដាប់នោះឯង ចចកចាស់នោះ មានគំនិតយ៉ាងនេះថា អញដូចម្ដេច សីហមិគរាជ ដូចម្ដេច គួរតែអញឯងអាស្រ័យនឹងដងព្រៃមួយ សម្រេចការដេក លុះសម្រេចការដេកក្នុងដងព្រៃនោះហើយ ក្នុងវេលាសាយណ្ហសម័យ ត្រូវចេញពីទីដេក

អាសយា និក្ខមិត្វា វិជម្ភេយ្យំ វិជម្ភិត្វា សមន្តា ចតុទ្ទិសា អនុវិលោកេយ្យំ សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទេយ្យំ តិក្ខត្តុំ សីហនាទំ នទិត្វា គោចរាយ បក្កមេយ្យំ សោ វរំ វរំ មិគសង្ឃំ វធិត្វា មុទុំសានិ មុទុំសានិ ភក្ខយិត្វា តមេវ អាសយំ អជ្ឈុបេយ្យន្តិ ។ អថខោ សោ អាវុសោ ជរសិគាលោ អញ្ញតរំ វនសណ្ឌំ និស្សាយ អាសយំ កប្បេសិ តត្រាសយំ កប្បេត្វា សាយណ្ហសមយំ អាសយា និក្ខមិ អាសយា និក្ខមិត្វា វិជម្ភិ វិជម្ភិត្វា សមន្តា ចតុទ្ទិសា អនុវិលោកេសិ សមន្តា ចតុទ្ទិសា អនុវិលោកេត្វា តិក្ខត្តុំ សីហនាទំ នទិស្សាមីតិ សិគាលកំ(១) អនទិ ភេរណ្ឌកំយេវ អនទិ កេ ច ឆវេ សិគាលេ កេ បន សីហនាទេតិ ។ ឯវមេវ ខោ ត្វំ អាវុសោ សុនក្ខត្ត សុគតាបទានេសុ ជីវមានោ សុគតាតិរិត្តានិ ភុញ្ជមានោ តថាគតេ អរហន្តេ

១ ឱ ម. សិគាលកំយេវ ។

លុះចេញពីទីដេកហើយ ត្រូវមិតតពត់ខ្លួន លុះមិតតពត់ខ្លួនរួចហើយ ត្រូវក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញ លុះក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញហើយ ត្រូវបន្លឺសីហនាទ ៣ ដង លុះបន្លឺសីហនាទ ៣ ដងហើយ ត្រូវចេញទៅរកចំណី អាត្មាអញសម្លាប់ហ្វូងម្រឹគធំ ៗ ហើយបរិភោគសាច់ដែលឆ្ងាញ់ ៗ ហើយត្រឡប់ចូលទៅកាន់ទីដេកនោះ ដដែលវិញ ។ ម្នាលអាវុសោ ទើបចចកចាស់នោះ អាស្រ័យដងព្រៃមួយ សម្រេចការដេក លុះសម្រេចការដេក ក្នុងដងព្រៃនោះហើយ ក្នុងវេលាសាយណ្ហសម័យ ក៏ចេញចាកទីដេក លុះចេញចាកទីដេកហើយ ក៏មិតតពត់ខ្លួន លុះមិតតពត់ខ្លួនហើយ ក៏ក្រឡេកមើលទៅទិសទាំង៤ ដោយជុំវិញ លុះក្រឡេកមើលទៅទិសទាំង ៤ ដោយជុំវិញហើយក៏គិតថា អញនឹងបន្លឺសីហនាទ៣ដង ដូច្នេះហើយស្រែកជាសម្រែកចចក ស្រែកសម្រែកដ៏ពន្ទឹកថា ចចកអាក្រក់ដូចម្ដេចទៅ ចំណែកសីហនាទដូចម្ដេចទៅ ។ នែអាវុសោ បាដិកបុត្រ អ្នកក៏ដូចគ្នានឹងចចកចាស់នោះដែរ រស់នៅក្នុងសុគតាបទាន ( ត្រៃសិក្ខា ជាសាសនារបស់ព្រះសុគត ) បរិភោគភោជនជាសំណល់សល់អំពីព្រះសុគត ហើយតតាំងនឹងព្រះតថាគតជាអរហន្ត

សម្មាសម្ពុទ្ធេ អាសាទេតុំ មញ្ញសិ កេ ច ឆវេ បាដិកបុត្តេ កា ច តថាគតានំ អរហន្តានំ សម្មាសម្ពុទ្ធានំ អាសាទនាតិ ។ យតោ ខោ ភគ្គវ ជាលិយោ ទារុបត្តិកន្តេវាសី ឥមិនាបិ ឱបម្មេន នេវ អសក្ខិ អចលំ បាដិកបុត្តំ តម្ហា អាសនា ចាវេតុំ ។ អថ នំ ឯតទវោច

សីហោតិ អត្តាន សមេក្ខិយាន(១)
អមញ្ញិ(២) កោត្ថុ មិគរាជាហមស្មិ
តថេវ(៣) សោ សិគាលកំ អនទិ
កេ ច ឆវេ សិគាលេ កេ បន សីហនាទេតិ ។

(១០) ឯវមេវ ខោ ត្វំ អាវុសោ បាដិកបុត្ត សុគតាបទានេសុ ជីវមានោ សុគតាតិរិត្តានិ ភុញ្ជមានោ តថាគតេ អរហន្តេ សម្មាសម្ពុទ្ធេ អាសាទេតុំ មញ្ញសិ កេ ច ឆវេ បាដិកបុត្តេ កា ច តថាគតានំ អរហន្តានំ សម្មាសម្ពុទ្ធានំ អាសាទនាតិ ។ យតោ ខោ ភគ្គវ ជាលិយោ

---

១ ឱ. ប. អត្តានំ សមេក្ខិយានំ ។ ២ ឱ. មញ្ញិ ។ ៣ ឱ. ម. តថេវ ។

សម្មាសម្ពុទ្ធថា បាដិកបុត្រអាក្រក់ដូចម្តេច ការតតាំង (បាដិហារិយ៍) របស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដូចម្តេច ។ ម្នាលភគ្គវៈ កាលណា ជាលិយៈជាសិស្សទារុបត្តិកៈ មិនអាចឲ្យអចេលបាដិកបុត្រ ឃ្លាតចាក អាសនៈនោះ ដោយពាក្យប្រៀបផ្ទឹមនេះហើយ ។ ទើបនិយាយនឹង អចេលបាដិកបុត្រនោះ យ៉ាងនេះថា

ចចកសំគាល់ខ្លួនថាជាសីហរាជ បានសំគាល់ខ្លួនទៀតថា
អាត្មាអញជាមិគរាជ ចចកនោះ បន្ទឺនូវសំរែកចចកនោះថា
សំរែកចចកអាក្រក់ដូចម្តេចទៅ ចំណែកខាងសីហនាទ
ដូចម្តេចទៅ ។

(១០) ម្នាលអាវុសោបាដិកបុត្រ អ្នកក៏ដូច្នោះដែរ រស់នៅ ក្នុងសុគតាបទាន (ត្រៃសិក្ខា ជាសាសនារបស់ព្រះសុគត) បរិភោគ ភោជនជាសំណល់អំពីព្រះសុគតហើយ តតាំងនឹងព្រះតថាគតជាអរហន្ត សម្មាសម្ពុទ្ធថា បាដិកបុត្រលាមកដូចម្តេចទៅ ការតតាំងរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធដូចម្តេចទៅ ។ ម្នាលភគ្គវៈ កាលណាជាលិយៈ

ទារុបត្តិកន្តេវាសី ឥមិនាបិ ឱបម្មេន នេវ អសក្ខិ អចេលំ បាដិកបុត្តំ តម្ហា អាសនា ចាវេតុំ ។ អថ នំ ឯតទវោច

សុញ្ញំ អនុបកាមិនំ(១) អត្តានំ
វិឃាសេ សមេក្ខិយ
យាវ អត្តា ន(២) បស្សតិ កោត្ថុ
តាវ ព្យគ្ឃោតិ មញ្ញតិ
ឯវមេវ(៣) សោ សិង្គាលកំ អនទិ
កោ ច ឆវេ សិង្គាលេ កោ បន សីហនាទេតិ ។

(១១) ឯវមេវ ខោ ត្វំ អាវុសោ បាដិកបុត្ត សុគតាបទានេសុ ជីវមានោ សុគតាតិរិត្តានិ ភុញ្ជមានោ តថាគតេ អរហន្តេ សម្មាសម្ពុទ្ធេ អាសាទេតព្វំ មញ្ញសិ កោ ច ឆវេ បាដិកបុត្តេ កា ច តថាគតានំ អរហន្តានំ សម្មាសម្ពុទ្ធានំ អាសាទនាតិ ។ យតោ ខោ ភគ្គវ ជាលិយោ ទារុបត្តិកន្តេវាសី ឥមិនាបិ ឱបម្មេន នេវ អសក្ខិ អចេលំ បាដិកបុត្តំ តម្ហា អាសនា ចាវេតុំ ។ អថ នំ ឯតទវោច

---

១ ឱ ម អញ្ញំ អនុចង្កមនំ ។ ២ ឱ ម. អត្តានំ ។ ៣ ឱ. ម. តថេវ ។

ជាសិស្សទារុបត្តិកៈ មិនអាចឲ្យអចេលបាដិកបុត្រ ឃ្លាតចាកអាសនៈនោះ ដោយពាក្យឧបមានេះហើយ ។ ទើបនិយាយនឹងអចេលបាដិកបុត្រ នោះយ៉ាងនេះ ក្នុងកាលនោះថា

ចចកដើរទៅកាន់ទីស្ងាត់ បានឃើញស្រមោលខ្លួនដែលធ្លុះ
ចូលទៅក្នុងទឹកសំណល់ (ក្នុងត្រពាំង) មិនបានឃើញ
ខ្លួនច្បាស់ដរាបណា ក៏សំគាល់នូវស្រមោលនោះថាជាខ្លាធំ
ដរាបនោះ ចចកនោះ បន្លឺនូវសម្រែករបស់ចចកនោះឯងថា
សម្រែកចចកអាក្រក់ដូចម្តេចទៅ ចំណែកខាងសីហនាទដូច
ម្តេចទៅ ។

(១១) នែអាវុសោបាដិកបុត្រ អ្នកក៏ដូច្នោះដែរ រស់នៅក្នុងសុគតាបទាន (ត្រៃសិក្ខាជាសាសនារបស់ព្រះសុគត) បរិភោគភោជនជាសំណល់អំពីព្រះសុគត ក៏តតាំងនឹងព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធថា បាដិកបុត្រ អាក្រក់ដូចម្តេចទៅ ការតតាំង របស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធដូចម្តេចទៅ ។ ម្នាលភគ្គវៈ កាលណាជាលិយៈ ជាសិស្សទារុបត្តិកៈ មិនអាចឲ្យអចេលបាដិកបុត្រ ឃ្លាតចាកអាសនៈនោះបានដោយពាក្យឧបមានេះហើយ ។ ទើបនិយាយនឹងអចេលបាដិកបុត្ត នោះយ៉ាងនេះថា

បាដិកសុត្តេ សីហមិគរាជនិងសិគាលោបម្មគាថា

ភុត្វាន ភេកេ(១) ខលមូសិកាយោ
កដសីសុ ខិត្តានិ ច កុណបានិ(២)
មហាវនេ សុញ្ញវនេ វិវឌ្ឍោ
អមញ្ញិ កោត្ថុ មិគរាជាហមស្មិ
តថេវ សោ សិគាលកំ អនទិ
កេ ច ឆវេ សិគាលេ កេ បន សីហនាទេតិ ។

(១២) ឯវមេវ ខោ ត្វំ អាវុសោ បាដិកបុត្ត សុគតាបទានេសុ ជីវមានោ សុគតាតិរិត្តានិ ភុញ្ជមានោ តថាគតេ អរហន្តេ សម្មាសម្ពុទ្ធេ អាសាទេតព្វំ មញ្ញសិ កេ ច ឆវេ បាដិកបុត្តេ កា ច តថាគតានំ អរហន្តានំ សម្មាសម្ពុទ្ធានំ អាសាទនាតិ ។ យតោ ខោ ភគ្គវ ជាលិយោ ទារុបត្តិកន្តេវាសី ឥមិនាបិ ឱបម្មេន នេវ អសក្ខិ អចេលំ បាដិកបុត្តំ តម្ហា អាសនា ចាវេតុំ ។ អថ តំ បរិសំ អាគន្ត្វា ឯវមារោចេសិ បរាភូតរូបោ ភោ អចេលោ បាដិកបុត្តោ អាយាមិ អាវុសោ អាយាមិ អាវុសោតិ

១ ម. ភិង្គេ ។ ២ ឱ. ម កោណបានិ ។

ចចកស៊ីកង្កែបទាំងឡាយក្នុងរណ្តៅផង ស៊ីកណ្ដុរទាំងឡាយក្នុងទីលានផង ស៊ីសាកសពទាំងឡាយដែលគេចោលក្នុងព្រៃស្មសានផង បានចំរើនធំឡើងក្នុងព្រៃធំជាព្រៃស្ងាត់ ក៏សំគាល់ខ្លួនថា អាត្មាអញជាមិគរាជ ចចកនោះក៏បន្លឺ នូវសម្រែកចចកយ៉ាងនោះឯដែលថា សម្រែកចចកអាក្រក់ដូចម្តេចទៅ បំណែកខាងសីហនាទតើដូចម្តេចទៅ ៗ

(១២) នៃអាវុសោ បាដិកបុត្រ អ្នកក៏ដូច្នោះដែរ រស់នៅក្នុងសុគតាបទាន (ត្រៃសិក្ខាជាសាសនារបស់ព្រះសុគត) បរិភោគភោជនជាសំណល់អំពីព្រះសុគត ក៏តតាំងនឹងព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ថា បាដិកបុត្រអាក្រក់ដូចម្តេចទៅ ការតតាំងរបស់ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធដូចម្តេចទៅ ៗ ម្នាលភគ្គវៈ កាលណាជាលិយៈជាសិស្សទារុបត្តិកៈ មិនអាចឲ្យអចេលបាដិកបុត្រ ឃ្លាតចាកអាសនៈនោះបាន ដោយពាក្យឧបមានេះហើយ ៗ ទើបត្រឡប់មករកបរិសទ្យនោះវិញ ហើយប្រាប់យ៉ាងនេះថា អស់លោកដ៏ចំរើន អចេលបាដិកបុត្របរាជ័យហើយ គ្រាន់តែនិយាយថា នៃអាវុសោ ខ្ញុំនឹងទៅ នៃអាវុសោ ខ្ញុំនឹងទៅ

វត្វា តត្ថេវ សំសប្បតិ ន សក្កោតិ អាសនាបិ វុដ្ឋាតុម្បិ ។ ឯវំ វុត្តេ អហំ ភគ្គវ តំ បរិសំ ឯតទវោចំ អភព្វោ ខោ អាវុសោ អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា មម សម្មុខីភាវំ អាគន្តុំ សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ តំ ចិត្តំ អប្បហាយ តំ ទិដ្ឋឹ អប្បដិនិស្សជ្ជិត្វា សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ សចេបាយស្មន្តានំ លិច្ឆវីនំ ឯវមស្ស មយំ អចេលំ បាដិកបុត្តំ យាហិ(១) វរត្តាហិ ពន្ធិត្វា គោយុត្តេហិ អាវិញ្ឆេយ្យាមាតិ តា វរត្តា ឆិជ្ជេរំ(២) បាដិកបុត្តោ វា អភព្វោ បន អចេលោ បាដិកបុត្តោ តំ វាចំ អប្បហាយ ។ បេ ។ មម សម្មុខីភាវំ អាគន្តុំ សចេបិស្ស ឯវមស្ស អហន្តំ វាចំ អប្បហាយ ។ បេ ។ សមណស្ស គោតមស្ស សម្មុខីភាវំ គច្ឆេយ្យន្តិ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។

---

១ ឱ. យោហីតិ ន ទិស្សតិ ។ ២ ម. ឆិជ្ជេយ្យុំ ។

ដូច្នេះហើយក៏អង្គុយជ្រប់នៅត្រង់កន្លែងនោះដដែល មិនអាចក្រោកចាកអាសនៈបានឡើយ ។ ម្នាលភគ្គវៈ កាលបើជាលិយៈនិយាយយ៉ាងនេះហើយ តថាគតបាននិយាយនឹងបរិសទ្យនោះយ៉ាងនេះថា នែអាវុសោទាំងឡាយ អចេលបាដិកបុត្រ បើមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញទេ មិនគួរនឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ បើប្រសិនជាអចេលបាដិកបុត្រនោះ គាំងចិត្តយ៉ាងនេះថា អាត្មាអញមិនលះបង់វាចានោះ មិនលះបង់ចិត្តនោះ មិនលះបង់ទិដ្ឋិនោះចេញ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្រ្ត នៃព្រះសមណគោតមដូច្នេះ ក្បាលអចេលបាដិកបុត្រនោះ មុខជានឹងធ្លាក់ចុះមិនខាន ទោះបីពួកលិច្ឆវីដ៏មានអាយុគិតគ្នាយ៉ាងនេះថា យើងត្រូវចងនូវអចេលបាដិកបុត្រដោយខ្សែព្រ័ត្រណា ហើយបង្អូសមកដោយគោច្រើននឹមដូច្នេះ ខ្សែព្រ័ត្រទាំងនោះនឹងដាច់ ឬខ្លួនបាដិកបុត្រឯងនឹងដាច់ ឯអចេលបាដិកបុត្របើមិនលះបង់វាចានោះ មិនគួរ ។ បេ ។ នឹងមកកាន់ទីចំពោះមុខតថាគតបានឡើយ ទោះបីអចេលបាដិកបុត្រនោះ គាំងចិត្តយ៉ាងនេះថា អញមិនលះបង់វាចានោះ ។ បេ ។ ហើយគប្បីទៅកាន់ទីចំពោះព្រះភក្រ្តព្រះសមណគោតមដូច្នេះ ក្បាលអចេលបាដិកបុត្រនោះ នឹងធ្លាក់ចុះមិនខាន ។

អថខ្វាហំ(១) ភគ្គវ តំ បរិសំ ធម្មិយា កថាយ សន្ទស្សេសឹ សមាទបេសឹ សមុត្តេជេសឹ សម្បហំសេសឹ តំ បរិសំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា មហាពន្ធនា មោក្ខំ ករិត្វា ចតុរាសីតិបាណសហស្សានិ មហាវិទុគ្គា ឧទ្ធរិត្វា តេជោធាតុំ សមាបជ្ជិត្វា សត្តតាលំ វេហាសំ អព្ភុគ្គន្ត្វា អញ្ញំ សត្តតាលំបិ អច្ចឹ(២) អភិនិម្មិនិត្វា ជលិត្វា ធូមាយិត្វា(៣) មហាវនេ កូដាគារសាលាយំ បច្ចុដ្ឋាសឹ ។ អថខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អហំ ភគ្គវ សុនក្ខត្តំ លិច្ឆវិបុត្តំ ឯតទវោចំ តំ កឹ មញ្ញសិ សុនក្ខត្ត យថេវ តេ អហំ អចេលំ បាដិកបុត្តំ អារព្ភ ព្យាកាសឹ តថេវ តំ វិបាកំ ហោ អញ្ញថាតិ(៤) ។

១ ឱ. អថ ខោហំ ។ ២ ឱ. អច្ចី ។ ម. អច្ចី ។ ៣ ឱ. ជលេត្វា ធូមាយេត្វា ។ ម. បជ្ជលិត្វា . . . ។ ៤ ម. តំ វិបាកំ អញ្ញថា ភតិ ។

ម្នាលភគ្គវៈ លំដាប់នោះតថាគត បានញុំាងបរិសទ្យនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា លុះញុំាងបរិសទ្យនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ធ្វើឲ្យរួចចាកចំណងធំ ហើយស្រង់សត្វទាំង ៨ ហ្មឺន៤ពាន់អំពីអន្លង់ធំ (ឱឃៈទាំង៤) រួចហើយចូលតេជោធាតុ ហោះទៅកាន់វេហាស៍កំពស់ប្រមាណ ៧ ដើមត្នោត ទាំងបាននិម្មិតភ្លើងដទៃកំពស់ប្រមាណ ៧ ដើមត្នោតឲ្យភ្លឺរន្ទាល បញ្ចេញផ្សែង មកប្រាកដ ក្នុងកូដាគារសាលានាព្រៃមហាវ័ន ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវីបុត្រ បានចូលមករកតថាគត លុះចូលមកដល់ហើយក៏ថ្វាយបង្គំតថាគតរួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ កាលសុនក្ខត្តលិច្ឆវីបុត្រអង្គុយក្នុងទីសមគួរហើយ តថាគតបានសួរយ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច តថាគតបានប្រារព្ធព្យាករណ៍ នូវអចេលបាដិកបុត្រ ប្រាប់អ្នកយ៉ាងណា ផលវិបាកនោះក៏ពិតដូច្នោះមែន មិនបានទៅជាដទៃវិញទេឬ ។

យថេវ មេ ភន្តេ ភគវា អចេលំ បាដិកបុត្តំ អារព្ភ ព្យាកាសិ តថេវ តំ វិបាកំ នោ អញ្ញថាតិ ។ តំ កឹ មញ្ញសិ សុនក្ខត្ត យទិ ឯវំ សន្តេ កតំ វា ហោតិ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ អកតំ វាតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ កតំ ហោតិ ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ នោ អកតន្តិ ។ ឯវំបិ ខោ មំ ត្វំ មោឃបុរិស ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករោន្តំ ឯវំ វទេសិ ន ហិ បន មេ ភន្តេ ភគវា ឧត្តរិមនុស្សធម្មា ឥទ្ធិបាដិហារិយំ ករោតីតិ ។ បស្ស មោឃបុរិស យាវញ្ច តេ ឥទំ អបរទ្ធន្តិ ។ ឯវំបិ ខោ ភគ្គវ សុនក្ខត្តោ លិច្ឆវិបុត្តោ មយា វុច្ចមានោ អបក្កមេវ ឥមស្មា ធម្មវិនយា យថា តំ អាបាយិកោ នេរយិកោ ។

សុនក្ខត្តលិច្ឆវិបុត្រឆ្លើយថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ប្រារព្ធព្យាករណ៍នូវអចេលបាដិកបុត្រ ប្រាប់ខ្ញុំព្រះអង្គយ៉ាងណា ផលវិបាកនោះក៏ពិតដូច្នោះមែន មិនមែនទៅជាដទៃវិញទេ ។ តថាគតសួរថា ម្នាលសុនក្ខត្តៈ អ្នកសំគាល់សេចក្ដីនោះជាដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ តើតថាគតឈ្មោះថាបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ឬមិនបានធ្វើទេ ។ សុនក្ខត្តលិច្ឆវិបុត្រឆ្លើយតបថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុយ៉ាងនេះមានហើយ ឈ្មោះថាព្រះអង្គបានធ្វើ នូវឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សពិតមែនហើយ មិនមែនជាព្រះអង្គមិនបានធ្វើទេ ។ តថាគតតបថា ម្នាលមោឃបុរស កាលបើមានហេតុយ៉ាងនេះហើយ អ្នកនៅតែនិយាយនឹងតថាគត ដែលជាអ្នកធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ មិនធ្វើឥទ្ធិបាដិហារិយ៍ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ដល់ខ្ញុំព្រះអង្គទេ ។ តថាគតពោលថា ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះជាសេចក្ដីខុសរបស់អ្នក ។ ម្នាលភគ្គវៈ ឯសុនក្ខត្តលិច្ឆវិបុត្រ កាលដែលតថាគតស្ដីឲ្យយ៉ាងនេះហើយ ក៏គេចចេញចាកធម្មវិន័យនេះ ដូចជាសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

(១៣) អគ្គញ្ញញ្ចាហំ ភគ្គវ បជានាមិ តតោ ច ឧត្តរិតរំ បជានាមិ តញ្ច បជានំ(១) ន បរាមសាមិ អបរាមសតោ ច(២) មេ បច្ចត្តញ្ញេវ និព្វុតិ វិទិតា យទភិជានំ តថាគតោ នោ អនយំ អាបជ្ជតិ ។ សន្តិ ភគ្គវ ឯកេ សមណព្រាហ្មណា ឥស្សរកុត្តំ ព្រហ្មកុត្តំ អាចរិយកំ អគ្គញ្ញំ បញ្ញបេន្តិ ត្យាហំ(៣) ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ឥស្សរកុត្តំ ព្រហ្មកុត្តំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ច មេ ឯវំ បុដ្ឋា អាមាតិ(៤) បដិជានន្តិ ត្យាហំ ឯវំ វទាមិ កថំវិហិតកំ បន តុម្ហេ អាយស្មន្តោ ឥស្សរកុត្តំ ព្រហ្មកុត្តំ អាចរិយកំ

១ ឱ. ម. បជានាមិ តញ្ច បជានាមិ តតោ ច ឧត្តរិតរំ បជានាមិ តញ្ច បជានំ ។
២ ឱ. វិសេត្វា ន ទិស្សតិ ។ ម. ប ។ ៣ ឱ. តេហំ ។ ៤ ឱ. អាមោតិ ។

(១៣) ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទំលាប់ផង ដឹងច្បាស់នូវគុណវិសេសដ៏លើសលប់ជាងនោះទៅទៀតផង(១) កាលដែលតថាគតដឹងច្បាស់នូវធម៌នោះហើយ ក៏មិនបានប្រកាន់ខុស (ដោយអំណាចតណ្ហា ទិដ្ឋិ និងមានះ) ទេ ។ លុះតថាគតមិនបានប្រកាន់ខុស ( នូវធម៌នោះហើយ) ទើបដឹងច្បាស់នូវសេចក្តីរលត់ ( កិលេស ) ចំពោះខ្លួនឯង កាលបើតថាគតដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្តីវិនាសឡើយ ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវច្បាប់ទំលាប់ជាអាចារ្យវាទដែលព្រះឥសូរគាត់តែងហើយ ដែលព្រះព្រហ្មគាត់តែងហើយ តថាគតបានចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះហើយសួរយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំងឡាយ ឮថាអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទំលាប់ជាអាចារ្យវាទ ដែលព្រះឥសូរគាត់តែងហើយ ដែលព្រះព្រហ្មគាត់តែងហើយពិតមែនឬ ។ ចំណែកខាងសមណព្រាហ្មណ៍ទាំងនោះ លុះដល់តថាគតសួរយ៉ាងនេះហើយ ក៏ប្រាប់ថា ព្រះករុណាដូច្នេះ ទើបតថាគត សួរសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្ត នូវច្បាប់ទំលាប់ជាអាចារ្យវាទ ដែលព្រះឥសូរគាត់តែងហើយ ដែលព្រះព្រហ្មគាត់តែង

១ អដ្ឋកថាថា ដឹងច្បាស់តាំងពី សីល សមាធិ (បញ្ញា) រហូតដល់សព្វញ្ញុតញ្ញាណ ដែលជាគុណដ៏លើសលប់ ជាងច្បាប់ទំលាប់នោះទៅទៀត ។

អត្តញ្ញំ បញ្ញាបេថាតិ ។ តេ មយា បុដ្ឋា ន សំបាយន្តិ
អសំបាយន្តា មមញ្ញេវ បដិបុច្ឆន្តិ តេសាហំ បុដ្ឋោ
ព្យាករោមិ ហោតិ ខោ សោ អាវុសោ សមយោ
យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន
អយំ លោកោ សំវដ្ដតិ សំវដ្ដមានេ លោកេ យេភុយ្យេន
សត្តា អាភស្សរសំវត្តនិកា ហោន្តិ តេ តត្ថ ហោន្តិ
មនោមយា បីតិភក្ខា សយំបភា អន្តលិក្ខចរា
សុភដ្ឋាយិនោ ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ ។ ហោតិ ខោ
សោ អាវុសោ សមយោ យំ កទាចិ ករហចិ
ទីឃស្ស អទ្ធុនោ អច្ចយេន អយំ លោកោ វិវដ្ដតិ
វិវដ្ដមានេ លោកេ សុញ្ញំ ព្រហ្មវិមានំ បាតុភវតិ អថ
អញ្ញតរោ សត្តោ អាយុក្ខយា វា បុញ្ញក្ខយា វា
អាភស្សរកាយា ចវិត្វា សុញ្ញំ ព្រហ្មវិមានំ ឧបបជ្ជតិ

ហើយ តើមានប្រការដូចម្តេចខ្លះ ។ សមណព្រាហ្មណ៍ទាំងឡាយនោះ លុះតថាគតសួរហើយ ក៏រកឆ្លើយដោះមិនរួច កាលបើឆ្លើយដោះមិនរួច ហើយ ទើបត្រឡប់សួរមកតថាគតវិញ លុះសមណព្រាហ្មណ៍ទាំងឡាយនោះ សួរតថាគតហើយ តថាគតក៏ព្យាករថា ម្នាលអាវុសោទាំងឡាយ មានសម័យដែលលោកនេះវិនាសទៅម្តងៗ ដោយកន្លងកាលយូរទៅពុំខាន កាលដែលលោកវិនាសទៅ ពួកសត្វ ច្រើនទៅកើតក្នុងអាភស្សរព្រហ្ម ពួកសត្វដែលទៅកើតក្នុងអាភស្សរព្រហ្មនោះ ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីភ្លឺដោយខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅអស់កាលយូរអង្វែង(១) ។ ម្នាលអាវុសោទាំងឡាយ មានសម័យដែលត្រូវលោកនេះកើតឡើងវិញម្តងៗ ដោយកន្លងកាលយូរទៅពុំខាន កាលដែលលោកនេះ កើតឡើង វិមាននៃព្រហ្មដែលសូន្យស្ងាត់គ្មានសត្វ ក៏កើតឡើងប្រាកដ គ្រានោះឯង មានសត្វម្នាក់ច្យុតចាកពួកអាភស្សរព្រហ្ម ព្រោះអស់អាយុ ឬអស់បុណ្យ ហើយទៅកើតក្នុងវិមាននៃព្រហ្មដែលសូន្យស្ងាត់ (នោះ) លុះសត្វនោះ

---

១ ក្នុងព្រហ្មជាលសុត្តវណ្ណនា មានសេចក្តីពន្យល់ថា អស់ ៨ កប្បយ៉ាងច្រើន ។

សោ តត្ថ ហោតិ មនោមយោ បីតិភក្ខោ សយំបភោ
អន្តលិក្ខចរោ សុភដ្ឋាយី ចិរំ ទីឃមទ្ធានំ តិដ្ឋតិ
តស្ស តត្ថ ឯកកស្ស ទីឃរត្តំ និវុសិតត្តា អនភិរតិ
បរិតស្សនា ឧប្បជ្ជតិ អហោ វត អញ្ញេបិ សត្តា ឥត្ថត្តំ
អាគច្ឆេយ្យុន្តិ ។ អថ ខោ អញ្ញេបិ សត្តា អាយុក្ខយា
វា បុញ្ញក្ខយា វា អាភស្សរកាយា ចវិត្វា សុញ្ញំ
ព្រហ្មវិមានំ ឧបបជ្ជន្តិ តស្ស សត្តស្ស សហព្យតំ
តេបិ តត្ថ ហោន្តិ មនោមយា បីតិភក្ខា សយំបភា
អន្តលិក្ខចរា សុភដ្ឋាយិនោ ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ ។
តត្រាវុសោ យោ សោ សត្តោ បឋមំ ឧបបន្នោ តស្ស
ឯវំ ហោតិ អហមស្មិ ព្រហ្មា មហាព្រហ្មា អភិភូ អនភិ-
ភូតោ អញ្ញទត្ថុទសោ វសវត្តី ឥស្សរោ កត្តា និម្មិតា (១)

---

១ ខ. និម្មាតា ។

បានទៅកើតក្នុងវិមាននោះ ក៏ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីក្នុងខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅអស់កាលយូរអង្វែង(១) សត្វម្នាក់នោះ ដែលទៅកើតក្នុងវិមាននោះតែម្នាក់ឯង នៅអស់កាលជាយូរអង្វែងទៅ ក៏មានសេចក្តីប្រាថ្នា សេចក្តីអន្ទះអន្ទែងដោយតណ្ហា កើតឡើងដូច្នេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យបានពួកសត្វដទៃ មកកាន់អត្តភាពជាព្រហ្មនេះផង ៗ លំដាប់នោះឯង ពួកសត្វដទៃច្យុតចាកពួកអាភស្សរព្រហ្ម ព្រោះអស់អាយុឬបុណ្យ ហើយមកកើតក្នុងព្រហ្មវិមាន ដែលសូន្យជាមួយនឹងសត្វនោះដែរ ឯសត្វទាំងនោះលុះកើតក្នុងព្រហ្មវិមាននោះហើយ ក៏ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីក្នុងខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅអស់កាលជាយូរអង្វែង ៗ ម្នាលអាវុសោទាំងឡាយ បណ្តាសត្វទាំងនោះ សត្វណាបានទៅកើតជាដំបូង សត្វនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញជាព្រហ្ម ជាមហាព្រហ្ម គ្របសង្កត់នូវសត្វឯទៀត ៗ បាន សត្វឯទៀត ៗ មិនអាចគ្របសង្កត់ លើអាត្មាអញបានឡើយ អាត្មាអញជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចខ្លួន ជាធំ (ក្នុងលោក) ជាអ្នកសាងលោក

១ ក្នុងព្រហ្មជាលសុត្តវណ្ណនា មានសេចក្តីពន្យល់ថាឋិតនៅអស់ ១ កល្ប ឬកន្លះកល្ប ។

សេដ្ឋោ សជ្ជិតា (១) វសី បិតា ភូតភព្យានំ មយា ឥមេ សត្តា និម្មិតា ។ តំ កិស្ស ហេតុ ។ មមញ្ហិ (២) បុព្វេ ឯតទហោសិ អហោ វត អញ្ញេបិ សត្តា ឥត្ថត្តំ អាគច្ឆេយ្យុន្តិ ឥតិ មមញ្ច (៣) មនោបណិធិ ឥមេ ច សត្តា ឥត្ថត្តំ អាគតាតិ ។ យេបិ តេ សត្តា បច្ឆា ឧបបន្នា តេសំបិ ឯវំ ហោតិ អយំ ខោ ភវំ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មាតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានំ ឥមិនា មយំ ភោតា ព្រហ្មុនា និម្មិតា ។ តំ កិស្ស ហេតុ ។ ឥមញ្ហិ (៤) មយំ អទ្ទសាម បឋមំ (៥) ឧបបន្នំ មយំ បនម្ហា បច្ឆា ឧបបន្នាតិ ។ តត្រាវុសោ យោ សោ សត្តោ បឋមំ ឧបបន្នោ សោ ទីឃាយុកតរោ ច ហោតិ

---

១ សញ្ជិតា ។ ២ ឱ. មមំ ហិ ។ ៣ ម. មមបិ ។ ៤ ឱ. ឥមំ ហិ ។ ៥ ឱ. ឥធ បឋមំ ។

តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកចាត់ចែង[១]លោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់ពួកភូតនិងភព្យៈ[២] សត្វទាំងនេះសុទ្ធតែអាត្មាអញតាក់តែងហើយ ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថាអាត្មាអញមានគំនិតក្នុងកាលពីដើមមកដូច្នេះថា ធ្វើដូចម្តេចហ្ន៎ឲ្យបានពួកសត្វឯទៀតមកកាន់អត្តភាពជាព្រហ្មនេះផង ពួកសត្វទាំងនេះមកកាន់អត្តភាពជាព្រហ្មត្រូវតាមសេចក្តីប្រាថ្នា របស់អាត្មាអញដូច្នោះឯង ។ ពួកសត្វទាំងឡាយណាដែលមកកើតជាខាងក្រោយ សត្វទាំងនោះក៏មានសេចក្តីយល់ឃើញយ៉ាងនេះថា ព្រហ្មដ៏ចំរើននេះ ជាមហាព្រហ្ម គ្របសង្កត់នូវសត្វឯទៀតៗបាន សត្វឯទៀត ៗ មិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួងឲ្យលុះនៅក្នុងអំណាចខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកចាត់ចែងលោក ជាអ្នកស្ទាត់ជំនាញ ជាបិតានៃពួកភូតនិងភព្យៈ យើងទាំងឡាយ គឺព្រហ្មដ៏ចំរើននេះឯង បានតាក់តែងហើយ ។ ដំណើរនោះព្រោះហេតុដូចម្តេច ។ ព្រោះថាយើងបានឃើញព្រហ្មនេះ មកកើតក្នុងទីនេះមុន ចំណែកយើងមកកើតខាងក្រោយទេ ។ ម្នាលអាវុសោ បណ្តាសត្វទាំងនោះ សត្វណាបានទៅកើតមុនគេ សត្វនោះឯងមានអាយុវែង

---

១ ជាអ្នកចែករំលែកសត្វលោក ឲ្យឈ្មោះថាក្សត្រ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ជាដើម ។

២ សត្វដែលប្រសូតចេញមកហើយ ហៅថា ភូត សត្វដែលនៅក្នុងស្រោមស៊ុត ឬនៅក្នុងផ្ទៃ ហៅថា ភព្យៈ ។

បាថិកសុត្តេ មហាព្រហ្មាទិកថា

វណ្ណវន្តតរោ ច មហេសក្ខតរោ ច ។ យេ បន តេ សត្តា បច្ឆា ឧបបន្នា តេ អប្បាយុកតរា ច ហោន្តិ ទុព្វណ្ណតរា ច អប្បេសក្ខតរា ច ។ ឋានំ ខោ បនេតំ ភគ្គវ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ ស-មានោ អគារស្មា អនគារិយំ បព្វជតិ អគារស្មា អន-គារិយំ បព្វជិតោ សមានោ អាតប្បមន្វាយ បធាន-មន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាម-នសិការមន្វាយ តថារូបំ ចេតោសមាធិំ ផុសតិ យ-ថាសមាហិតេ ចិត្តេ តំ បុព្វេនិវាសំ អនុស្សរតិ តតោ បរំ នានុស្សរតិ ។ សោ ឯវមាហ យោ ខោ សោ ភវំ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ

ជាងគេផង មានសម្បុរល្អជាងគេផង មានសក្តិធំជាងគេផង ។ ចំណែកខាងពួកសត្វណា ដែលទៅកើតខាងក្រោយគេ ពួកសត្វនោះ មានអាយុក៏តិចជាងគេផង មានសម្បុរអន់ជាងគេផង មានសក្តិតូចជាងគេផង ។ ម្នាលអាវុសោទាំងឡាយ ហេតុនុ៎ះ តែងមានជាប្រាកដ ត្រង់ថាសត្វណាមួយ ច្យុតចាកពួកព្រហ្មនោះ មកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្សនេះ ហើយក៏ចេញចាកផ្ទះបួសទៅកាន់ផ្នួស លុះបានចេញចាកផ្ទះបួសទៅកាន់ផ្នួស ហើយក៏អាស្រ័យនូវព្យាយាម ជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវព្យាយាម ជាគ្រឿងតំកល់មាំ អាស្រ័យនូវព្យាយាម ជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្តីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ល្អ ក៏បានចេតោសមាធិតាមបែបនៃចិត្តរបស់ព្រះយោគី ដែលតាំងនៅខ្ជាប់ខ្ជួន ដោយសមាធិហើយរលឹកនូវខន្ធដែលសត្វអាស្រ័យនៅហើយ ក្នុងកាលមុននោះ កំណត់ត្រឹមតែអត្តភាពជាព្រហ្មនោះប៉ុណ្ណោះ មិនអាចរលឹកឃើញ នូវខន្ធហួសអំពើនោះបានឡើយ ។ សត្វនោះឯងនិយាយយ៉ាងនេះថា ព្រហ្មដ៏ចំរើនណា ជាមហាព្រហ្ម គ្របសង្កត់នូវសត្វឯទៀត ៗ សត្វឯទៀត ៗ មិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើជន

វសវត្តី ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជិតា វសី បិតា ភូតភព្យានំ ។ យេន មយំ ភោតា ព្រហ្មុនា និម្មិតា សោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតិ ។ យេ បន មយំ អហុម្ហា តេន ភោតា ព្រហ្មុនា និម្មិតា តេ មយំ អនិច្ចា អទ្ធុវា អសស្សតា[1] អប្បាយុកា ចវនធម្មា ឥត្ថត្តំ អាគតាតិ ។ ឯវំវិហិតកំ កោ[2] តុម្ហេ អាយស្មន្តោ ឥស្សរកុត្តំ ព្រហ្មកុត្តំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ឯវមាហំសុ ឯវំ ខោ នោ អាវុសោ គោតម សុតំ យថេវាយស្មា គោតមោ អាហាតិ ។ អគ្គញ្ញញ្ចាហំ ភគ្គវ បជានាមិ ។ សន្ធិត្តិ ។ យទភិជានំ តថាគតោ នោ អនយំ អាបជ្ជតិ ។

១ ឱ. អសស្សតាតិ ន ទិស្សតិ ។ ២ ម. នោ ។

ទាំងពួងឲ្យលុះក្នុងអំណាចខ្លួន ជាធំស្រះក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចម្បងជាងសត្វលោក ជាអ្នកចាត់ចែងលោក ជាអ្នកស្ទាត់ជំនាញ ជាបិតារបស់ពួកភូតនិងភព្យៈ ៗ ព្រហ្មដ៏ចំរើនណា ជាអ្នកតាក់តែងនូវយើងទាំងឡាយ ព្រហ្មនោះឯងជាអ្នកទៀងទាត់ ឋិតថេរ មានអាយុវែង មានសេចក្ដីមិនប្រែប្រួលជាធម្មតា តែងឋិតនៅដូចជាសស្សតិវត្ថុ យ៉ាងនោះឯង ៗ ចំណែកយើងទាំងឡាយណា ដែលព្រហ្មដ៏ចំរើននោះ បានតាក់តែងហើយ យើងទាំងឡាយនោះ ជាអ្នកមិនទៀងទាត់ឋិតថេរទេ មានអាយុខ្លី មានកិរិយាច្យុតជាធម្មតា ទើបបានមកកាន់អត្តភាពជាមនុស្សនេះ ៗ តថាគត សួរសមណព្រាហ្មណ៍ទាំងនោះថា ម្នាលអ្នកមានអាយុដ៏ចំរើនទាំងឡាយ អ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទំលាប់ ជាអាចរិយកទ ដែលព្រះឥស្សរ តាក់តែងហើយ ព្រះព្រហ្មតាក់តែងហើយ មានប្រការយ៉ាងនេះឬ ៗ ពួកសមណព្រាហ្មណ៍ទាំងនោះ បានឆ្លើយតបយ៉ាងនេះថា នែអាវុសោគោតម ព្រះគោតមមានអាយុ ពោលយ៉ាងណា យើងទាំងឡាយក៏បានឮមកយ៉ាងនោះដែរ ៗ ម្នាលភគ្គវៈ តថាគត ដឹងច្បាស់នូវច្បាប់ទំលាប់ផង ៗ សេចក្ដីបំប្រួញ ៗ កាលដែលតថាគត បានដឹងច្បាស់នូវសេចក្ដីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្ដីវិនាសឡើយ ៗ

(១៤) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ខិឌ្ឌាបទោសិកំ(១) អាចរិយកំ អគ្គញ្ញំ បញ្ញបេន្តិ តេសាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ខិឌ្ឌាបទោសិកំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ច មេ ឯវំ បុដ្ឋា អាមាតិ(២) បដិជានន្តិ ត្យាហំ ឯវំ វទាមិ កថំវិហិតកំ បន(៣) តុម្ហេ អាយស្មន្តោ ខិឌ្ឌាបទោសិកំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ មយា បុដ្ឋា ន សម្បាយន្តិ អសម្បាយន្តា មមំយេវ(៤) បដិបុច្ឆន្តិ តេសាហំ បុដ្ឋោ ព្យាករោមិ សន្តាវុសោ ខិឌ្ឌាបទោសិកា នាម ទេវា តេ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នា វិហរន្តិ តេសំ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នានំ វិហា-

---

១ ឱ. ខិឌ្ឌាបទូសិកំ ។ ២ ឱ. អាមោតិ ។ ៣ ម. នោ បន ។ ៤ ឱ. មមញ្ញេវ ។

(១៤) ម្នាលភគ្គវៈ មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវច្បាប់ទំលាប់ជាអាចរិយកៈ មានទេវតាឈ្មោះខិឌ្ឌាបទោសិកាជាមូល (អ្នកវិនាសខ្លួនព្រោះល្បែង) តថាគត ក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ បានឮថាពួកអ្នកបញ្ញត្តនូវច្បាប់ទំលាប់ ជាអាចរិយកៈ មានទេវតាឈ្មោះខិឌ្ឌាបទោសិកាជាមូលពិតមែនឬ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយក៏ប្រាប់ថា ព្រះករុណា ព្រះអង្គដូច្នេះ ទើបតថាគត សួរសមណព្រាហ្មណ៍ទាំងនោះទៀតយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទំលាប់ ជាអាចរិយកៈ មានទេវតាឈ្មោះខិឌ្ឌាបទោសិកាជាមូល តើមានប្រការដូចម្តេចខ្លះ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរហើយក៏ឆ្លើយមិនរួច កាលបើឆ្លើយមិនរួចក៏ត្រឡប់សួរមកតថាគតវិញ លុះសមណព្រាហ្មណ៍ទាំងនោះ សួរតថាគតហើយ តថាគតក៏ព្យាករថា ម្នាលអាវុសោទាំងឡាយ មានពួកទេវតាឈ្មោះខិឌ្ឌាបទោសិកា ទេវតាទាំងនោះជាអ្នកខ្វល់ខ្វាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយនឹងល្បែងជាធម្មតា ហួសវេលា កាលទេវតាទាំងនោះកំពុងតែខ្វល់ខ្វាយ ក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយនឹងល្បែង

រតំ សតិ សម្មុស្សតិ សតិយា សម្មោសាយ (១) តេ ទេវា តម្ហា កាយា ចវន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ អគារស្មា អនគារិយំ បព្វជតិ អគារស្មា អនគារិយំ បព្វជិតោ សមានោ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ តំ បុព្វេនិវាសំ អនុស្សរតិ តតោ បរំ នានុស្សរតិ ។ សោ ឯវមាហ យេ ខោ តេ ភោន្តោ ទេវា ន ខិឌ្ឌាបទោសិកា តេ ន អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នា វិហរន្តិ តេសំ នាតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នានំ វិហរតំ

---

១ ខ. ម. សម្មោសា ។

ជាធម្មតា ហួសវេលាហើយ សតិក៏ភ្លេចវង្វេងទៅ (ខានបរិភោគអាហារ) កាលបើសតិភ្លេចវង្វេងហើយ ទេវតាទាំងនោះ ក៏ច្យុតចាកកាយនោះមក ។ ម្នាលអាវុសោទាំងឡាយ ហេតុនោះតែងមានប្រាកដ ត្រង់ថា សត្វណាមួយ ច្យុតចាកកាយនោះ បានមកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្សនេះហើយ ក៏ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះ ចូលទៅកាន់ផ្នួសហើយ ក៏អាស្រ័យនូវព្យាយាម ជាគ្រឿងដុតកំដៅ (កិលេស) អាស្រ័យនូវព្យាយាម ជាគ្រឿងតម្កល់មាំ អាស្រ័យនូវព្យាយាម ជាគ្រឿងប្រកប អាស្រ័យនូវសេចក្តីមិនធ្វេសប្រហែស អាស្រ័យនូវការធ្វើទុកក្នុងចិត្តដោយល្អ ក៏បាននូវចេតោសមាធិ តាមបែបនៃចិត្តរបស់ព្រះយោគី ដែលតាំងនៅខ្ជាប់ខ្ជួន ដោយសមាធិ ហើយរលឹកឃើញនូវខន្ធ ដែលសត្វអាស្រ័យនៅហើយក្នុងកាលមុននោះ កំណត់ត្រឹមតែអត្តភាពជាព្រហ្មនោះប៉ុណ្ណោះ មិនអាចរលឹកឃើញនូវខន្ធហួសអំពីនោះទៅបានឡើយ ។ សត្វនោះឯងនិយាយយ៉ាងនេះថា ទេវតាទាំងឡាយដ៏ចំរើនណា មិនមែនឈ្មោះខិឌ្ឌាបទោសិកា ទេវតាទាំងនោះ ជាអ្នកមិនខ្វល់ខ្វាយ ក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយនឹងល្បែង ជាធម្មតាហួសវេលាឡើយ កាលដែលទេវតាទាំងនោះ មិនខ្វល់ខ្វាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយនឹងល្បែង ជាធម្មតាហួសវេលាទេ

សតិ ន(១) សម្មុស្សតិ សតិយា អសម្មោសាយ តេ ទេវា តម្ហា កាយា ន ចវន្តិ និច្ចា ធុវា សស្សតា ទីឃាយុកា(២) អវិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សន្តិ ។ យេ បន មយំ អហុម្ហា ខិឌ្ឌាបទោសិកា តេ មយំ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នា វិហរិម្ហា តេសន្នោ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នានំ វិហរតំ សតិ សម្មុស្សតិ សតិយា សម្មោសាយ តេ(៣) មយំ តម្ហា កាយា ចុតា អនិច្ចា អធុវា អសស្សតា អប្បាយុកា ចវនធម្មា ឥត្ថត្តំ អាគតា-តិ ។ ឯវំវិហិតកំ បន(៤) តុម្ហេ អាយស្មន្តោ ខិឌ្ឌា-បទោសិកំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ឯវមាហំសុ ឯវំ ខោ នោ អាវុសោ គោតម សុតំ យថេវាយស្មា គោតមោ អាហាតិ ។ អគ្គញ្ញញ្ចា-ហំ ភគ្គវ បជានាមិ ។ បេ ។ យថាភិជានំ តថាគតោ នោ អនយំ អាបជ្ជតិ ។

---

១ ម. ន សតិ ។ ២ ខ. ទីឃាយុកាតិ ន ទិស្សតិ ។ ៣ ខ. សម្មោសា ឯវំ ។
៤ ខ. ភោ ។ ម. នោ ។

សតិក៏មិនភ្លេចវង្វេង កាលបើសតិមិនភ្លេចវង្វេងហើយ ទេវតាទាំងនោះ ក៏មិនច្យុតចាកកាយនោះឡើយ ជាទេវតាទៀងទាត់ឋិតថេរ មានអាយុវែង មានសេចក្តីមិនប្រែប្រួលជាធម្មតា តែងឋិតនៅដូចជាសស្សតតែ ៗ ចំណែកយើងទាំងឡាយណាជាខិឌ្ឌាបទោសិកា យើងទាំងនោះជាអ្នកខ្វល់ខ្វាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយ នឹងល្បែងជាធម្មតាហួសវេលា កាលដែលយើងទាំងនោះ កំពុងខ្វល់ខ្វាយក្នុងសេចក្តីត្រេកអរ ក្នុងការសើចសប្បាយនឹងល្បែង ជាធម្មតាហួសវេលាហើយ សតិក៏ភ្លេចវង្វេងទៅ កាលបើសតិភ្លេចវង្វេងហើយ ពួកយើងទាំងនោះ ក៏ច្យុតចាកកាយនោះ ជាទេវតាមិនទៀងទាត់ មិនឋិតថេរ មានអាយុតិច មានកិរិយាច្យុតជាធម្មតា បានជាមកកាន់អត្តភាពជាមនុស្សនេះ ៗ តថាគត សួរសមណព្រាហ្មណ៍ទាំងនោះថា នៃអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទំលាប់ ជាអាចរិយកំ មានទេវតាឈ្មោះខិឌ្ឌាបទោសិកាជាមូល មានប្រការយ៉ាងនេះឬ ៗ សមណព្រាហ្មណ៍ទាំងនោះបានឆ្លើយតបយ៉ាងនេះថា ម្នាលអាវុសោគោតម ព្រះគោតមមានអាយុ ពោលយ៉ាងណា យើងទាំងឡាយក៏បានឮមក យ៉ាងនោះដែរ ៗ ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទំលាប់ផង ៗ បេ ៗ កាលដែលតថាគត ដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ មិនដល់នូវសេចក្តីវិនាសឡើយ ៗ

(១៤) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា មនោបទោសិកំ អាចរិយកំ អគ្គញ្ញំ បញ្ញបេន្តិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ មនោបទោសិកំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ច មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ ត្យាហំ ឯវំ វទាមិ កថំវិហិតកំ បន[១] តុម្ហេ អាយស្មន្តោ មនោបទោសិកំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ មយា បុដ្ឋា ន សំបាយន្តិ អសំបាយន្តា មមញ្ញេវ បដិបុច្ឆន្តិ តេសាហំ បុដ្ឋោ ព្យាករោមិ សន្តាវុសោ មនោបទោសិកា នាម ទេវា តេ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តិ តេ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តា អញ្ញមញ្ញម្ហិ ចិត្តានិ បទោសេន្តិ តេ អញ្ញមញ្ញំ បទុដ្ឋចិត្តា កិលន្តកាយា

---

១ ម. កោ បន ។

(១៩) ម្នាលភគ្គវៈ មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវច្បាប់ទំលាប់ជាអាចារិយវាទ មានទេវតាឈ្មោះមនោបទោសិកាជាមូល (អ្នកវិនាសខូចព្រោះចិត្ត) តថាគតបានចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ ឮថាអ្នកទាំងឡាយ បញ្ញត្តនូវច្បាប់ទំលាប់ ជាអាចារិយវាទ មានទេវតាឈ្មោះមនោបទោសិកាជាមូល ពិតមែនឬ ។ ឯសមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ ដូច្នេះ ទើបតថាគតសួរសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះទៀតថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទំលាប់ ជាអាចារិយវាទ មានទេវតាឈ្មោះមនោបទោសិកាជាមូល តើមានប្រការដូចម្តេចខ្លះ ។ សមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរហើយ ក៏ឆ្លើយដោះមិនរួច កាលបើឆ្លើយដោះមិនរួចហើយ ក៏ត្រឡប់សួរមកតថាគតវិញ លុះសមណ-ព្រាហ្មណ៍ទាំងនោះ សួរមកតថាគត ៗ ក៏ព្យាករថា ម្នាលអាវុសោទាំងឡាយ មានពួកទេវតាឈ្មោះមនោបទោសិកា ពួកទេវតាទាំងនោះសំឡក់រិះគន់គ្នានឹងគ្នាហួសវេលា កាលពួកទេវតាទាំងនោះ សំឡក់រិះគន់គ្នានឹងគ្នាហួសវេលាហើយ ក៏ធ្វើចិត្តឲ្យប្រទូស្តដល់គ្នានឹងគ្នាទៀត ទេវតាទាំងឡាយនោះ លុះមានចិត្តប្រទូស្តដល់គ្នានឹងគ្នាហើយ ក៏លំបាកកាយ

កិលន្តចិត្តា តេ ទេវា តម្ហា កាយា ចវន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ អគារស្មា អនគារិយំ បព្វជតិ អគារស្មា អនគារិយំ បព្វជិតោ សមានោ អាតប្ប-មន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ តំ បុព្វេនិវាសំ អនុស្សរតិ តតោ បរំ នានុស្សរតិ ។ សោ ឯវមាហ យេ ខោ តេ ភោន្តោ ទេវា ន មនោបទោសិកា តេ អតិវេលំ អញ្ញមញ្ញំ ន ឧបនិជ្ឈាយន្តិ[១] តេ អតិវេលំ អញ្ញ-មញ្ញំ ន ឧបនិជ្ឈាយន្តា[២] អញ្ញមញ្ញម្ហិ ចិត្តានិ ន បទោសេន្តិ តេ អញ្ញមញ្ញំ អបទុដ្ឋចិត្តា អកិលន្ត-កាយា អកិលន្តចិត្តា តេ ទេវា[៣] តម្ហា កាយា ន ចវន្តិ និច្ចា ធុវា សស្សតា ទីឃាយុកា[៤] អ-វិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សន្តិ ។

---

១ ឱ. នាតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តិ ។ ២ ឱ. ន តិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តា ។ ឞ. អតិវេលំ អញ្ញមញ្ញំ អនុបនិជ្ឈាយន្តា ។ ៣ ម. តេ ទេវាតិ នត្ថិ ។ ៤ ឱ. ទីឃាយុកាតិ ន ទិស្សតិ ។

លំបាកចិត្ត ទេវតាទាំងនោះក៏ច្យុតចាកកាយនោះមក ម្នាលអាវុសោ ហេតុនោះ តែងមានប្រាកដ ត្រង់ថា សត្វណាមួយ ច្យុតចាកកាយនោះហើយមកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្សហើយក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយក៏អាស្រ័យនូវព្យាយាមជាគ្រឿងដុតកំដៅ ( កិលេស ) ។ បេ ។ ក៏បាននូវចេតោសមាធិ តាមបែបនៃចិត្តរបស់យោគី ដែលតាំងនៅខ្ជាប់ខ្ជួនដោយសមាធិ ក៏រលឹកឃើញនូវខន្ធដែលសត្វអាស្រ័យនៅហើយ ក្នុងកាលមុននោះកំណត់ត្រឹមតែអត្តភាព ជាព្រហ្មនោះប៉ុណ្ណោះ មិនអាចរលឹកឃើញនូវខន្ធហួសពីនោះទៅទៀតបានឡើយ ។ សត្វនោះបាននិយាយយ៉ាងនេះថា ពួកទេវតាដ៏ចំរើនណា ដែលមិនមែនឈ្មោះថា មនោបទោសិកាទេ ទេវតាទាំងនោះមិនសំឡក់រិះគន់គ្នានឹងគ្នាហួសវេលា ហើយក៏មិនបានធ្វើចិត្តឲ្យប្រទូស្តដល់គ្នានឹងគ្នា ទេវតាទាំងនោះលុះមានចិត្តមិនបានប្រទូស្តដល់គ្នានឹងគ្នាហើយក៏មិនលំបាកកាយ មិនលំបាកចិត្ត ទេវតាទាំងនោះក៏មិនច្យុតចាកកាយនោះឡើយ ជាទេវតាទៀងទាត់ ឋិតថេរ មានអាយុវែង មានសេចក្តីមិនប្រែប្រួលជាធម្មតា តែងតាំងនៅដូចជាសស្សតិវត្ថុ ។

យេ បន មយំ អហុម្ហា មនោបទោសិកា តេ មយំ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយិម្ហា តេ មយំ អតិ-វេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តា អញ្ញមញ្ញម្ហិ ចិត្តានិ បទោសយិម្ហា (១) តេ មយំ អញ្ញមញ្ញំ បទុដ្ឋចិត្តា កិលន្តកាយា កិលន្តចិត្តា ឯវំ មយំ (២) តម្ហា កាយា ចុតា អនិច្ចា អធុវា អសស្សតា (៣) អប្បាយុកា ចវនធម្មា ឥត្ថត្តំ អាគតាតិ ។ ឯវំវិហិតកំ បន (៤) តុម្ហេ អាយស្មន្តោ មនោបទោសិកំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ឯវមាហំសុ ឯវំ ខោ នោ អាវុសោ គោតម សុតំ យថេវាយស្មា គោតមោ អាហាតិ ។ អគ្គញ្ញញ្ចាហំ ភគ្គវ បជានាមិ ។ បេ ។ យថាបដិបន្នំ តថាគតោ នោ អនយំ អាបជ្ជតិ ។

---

១ ឱ. បទូសិម្ហ ។ ២ ម. ឯវំ មយាគ្គំ ឥត្ថិ ។ ៣ ឱ. អសស្សតាតិ ឯ វិស្សតិ ។
៤ ឱ. ភោ ។

ចំណែកយើងទាំងឡាយណា ឈ្មោះថា មនោបទោសិកាទេវតា យើងទាំងនោះបានសំឡក់រិះគន់គ្នានឹងគ្នាហួសវេលា កាលដែលយើងទាំងនោះសំឡក់រិះគន់គ្នានឹងគ្នាហួសវេលាហើយ ក៏បានធ្វើចិត្តឲ្យប្រទូស្តដល់គ្នានឹងគ្នាទៀត លុះដល់យើងទាំងនោះ មានចិត្តប្រទូស្តដល់គ្នានឹងគ្នាហើយ ក៏លំបាកកាយលំបាកចិត្ត យើងទាំងឡាយក៏ច្យុតចាកកាយនោះ ដោយអាការយ៉ាងនេះឯង ជាទេវតាមិនទៀងទាត់ មិនឋិតថេរ មានអាយុតិច មានការច្យុតជាធម្មតា បានជាមកកាន់អត្តភាពជាមនុស្សនេះ ។ តថាគតសួរពួកសមណព្រាហ្មណ៍ទាំងនោះថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តនូវច្បាប់ទំលាប់ជាអាចរិយកៈ មានទេវតាឈ្មោះមនោបទោសិកាជាមូល មានប្រការយ៉ាងនេះឬ ។ សមណព្រាហ្មណ៍ទាំងនោះបានឆ្លើយតបយ៉ាងនេះថា ម្នាលអាវុសោគោតម ព្រះគោតមមានអាយុពោលយ៉ាងណា យើងទាំងឡាយក៏បានឮមកយ៉ាងនោះដែរ ។ ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទំលាប់ផង ។ បេ ។ កាលដែលតថាគតដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្តីវិនាសឡើយ ។

## បាដិកសុត្តេ អធិច្ចសមុប្បន្នគ្គញ្ញបញ្ញត្តិកថា

(១៦) សន្តិ ភគ្គវ ឯកេ សមណព្រាហ្មណា អធិច្ចសមុប្បន្នំ អាចរិយកំ អគ្គញ្ញំ បញ្ញបេន្តិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ អធិច្ចសមុប្បន្នំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ច មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ ត្យាហំ ឯវំ វទាមិ កថំវិហិតកំ បន តុម្ហេ អាយស្មន្តោ អធិច្ចសមុប្បន្នំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ [១] មយា បុដ្ឋា ន សំបាយន្តិ អសំបាយន្តា មមំយេវ បដិបុច្ឆន្តិ តេសាហំ បុដ្ឋោ ព្យាករោមិ សន្តាវុសោ អសញ្ញសត្តា នាម [២] ទេវា សញ្ញុប្បាទា ច បន តេ ទេវា តម្ហា កាយា ចវន្តិ ។ ឋានំ ខោ បនេតំ អាវុសោ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ

---

១ ឱ. បស្សេត្វ ន វិស្សជ្ជតិ ។ ២ ឱ. អសញ្ញសត្តា នាម ។

(១៦) ម្នាលភគ្គវៈ មានសមណព្រាហ្មណ៍ពួកមួយ បញ្ញត្តច្បាប់ទំលាប់ជាអាចារ្យកៈ ដែលកើតឡើងដោយមិនអាស្រ័យហេតុ តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា នែអ្នកមានអាយុទាំងឡាយ ឮថា អ្នកទាំងឡាយ បញ្ញត្តច្បាប់ទំលាប់ ជាអាចារ្យកៈ ដែលកើតឡើងដោយមិនអាស្រ័យហេតុ ពិតមែនឬ ។ ឯសមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គដ៏ចំរើន ហើយទើបតថាគត សួរយ៉ាងនេះទៅសមណ-ព្រាហ្មណ៍ទាំងនោះទៀតថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយ បញ្ញត្តនូវច្បាប់ទំលាប់ ជាអាចារ្យកៈ ដែលកើតឡើង ដោយមិនអាស្រ័យហេតុ តើមានប្រការដូចម្តេចខ្លះ ។ ឯសមណព្រាហ្មណ៍ទាំងនោះ លុះតថាគតសួរហើយ ក៏ឆ្លើយដោះមិនរួច កាលបើឆ្លើយដោះមិនរួចហើយ ក៏ត្រឡប់សួរមកតថាគតវិញ លុះសមណព្រាហ្មណ៍ទាំងនោះសួរ តថាគតក៏ព្យាករថា ម្នាលអាវុសោទាំងឡាយ មានទេវតាឈ្មោះអសញ្ញីសត្វ គឺសត្វមិនមានសញ្ញា ទេវតាទាំងនោះ លុះមានសញ្ញាកើតឡើងហើយ ក៏ច្យុតចាកកាយនោះ ។ ម្នាលអាវុសោទាំងឡាយ ហេតុនោះតែងមានប្រាកដ ត្រង់ថា សត្វណាមួយ ច្យុតចាកកាយនោះ ហើយមកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្ស

អគារស្មា អនគារិយំ បព្វជតិ អគារស្មា អនគារិយំ បព្វជិតោ សមានោ អាតប្បមន្វាយ បធានមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ តំ សញ្ញុប្បាទំ អនុស្សរតិ តតោ បរំ នានុស្សរតិ ។ សោ ឯវមាហ អធិច្ចសមុប្បន្នោ អត្តា ច លោកោ ច តំ កិស្ស ហេតុ អហំ ហិ បុព្វេ នាហោសឹ សោម្ហិ ឯតរហិ អហុត្វា សន្តតាយ បរិណតោតិ ។ ឯវំវាទិនោ[១] តុម្ហេ អាយស្មន្តោ អធិច្ចសមុប្បន្នំ អាចរិយកំ អគ្គញ្ញំ បញ្ញបេថាតិ ។ តេ ឯវមាហំសុ ឯវំ ខោ អាវុសោ គោតម សុតំ យថេវាយស្មា គោតមោ អាហាតិ ។ អគ្គញ្ញញ្ចាហំ ភគ្គវ បជានាមិ តញ្ច បជានាមិ តតោ ច ឧត្តរិតរំ បជានាមិ តញ្ច បជានំ

១ ម. ភោ ។

នេះហើយ ក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ អាស្រ័យនូវព្យាយាមជាគ្រឿងដុតកំដៅ (កិលេស) អាស្រ័យនូវព្យាយាមជាគ្រឿងដំកល់មាំ ។ បេ ។ ក៏បាននូវចេតោសមាធិ តាមបែបនៃចិត្តរបស់យោគី ដែលតាំងនៅខ្ជាប់ខ្ជួន ដោយសមាធិហើយក៏រលឹកឃើញត្រឹមកំណត់កាល ដែលមានសញ្ញាកើតឡើងហើយនោះ មិនអាចរលឹកឃើញ ឲ្យហួសពីនោះបានឡើយ ។ សត្វនោះក៏និយាយយ៉ាងនេះថា ខ្លួននឹងលោកកើតឡើង ដោយមិនអាស្រ័យហេតុ ការពោលដូច្នេះ តើព្រោះហេតុអ្វី ព្រោះថា អាត្មាអញក្នុងកាលមុននោះក៏មិនបានកើតជាសត្វអ្វីទេ កើតតែក្នុងកាលឥឡូវនេះឯង តទៅមុខទៀតក៏មិនបានកើតដែរ ត្រឡប់ទៅជាស្ងប់ស្ងាប់ ។ តថាគតសួរសមណព្រាហ្មណ៍ទាំងនោះថា នែអ្នកមានអាយុទាំងឡាយ ចុះអ្នកទាំងឡាយបញ្ញត្តច្បាប់ទំលាប់ ជាអាចរិយកៈ ដែលកើតឡើង ដោយមិនអាស្រ័យហេតុ មានប្រការយ៉ាងនេះឬ ។ សមណព្រាហ្មណ៍ទាំងនោះបានឆ្លើយតបយ៉ាងនេះថា នែអាវុសោគោតម ព្រះគោតមមានអាយុពោលយ៉ាងណា យើងទាំងឡាយក៏បានឮមកយ៉ាងនោះដែរ ។ ម្នាលភគ្គវៈ តថាគតដឹងច្បាស់នូវច្បាប់ទំលាប់ផង ដឹងច្បាស់នូវគុណវិសេសលើសលុបជាងនោះផង កាលដែលតថាគតដឹងច្បាស់នូវធម៌នោះហើយ

ន បញ្ញាបេមិ ។ អបញ្ញាបេន្តោ ច មេ បច្ចត្តញ្ញេវ[១] និព្វុតិ វិទិតា យថាភិជានំ តថាគតោ នោ អនយំ អាបជ្ជតិ ។

(១៧) ឯវំវាទឹ ខោ មំ ភគ្គវ ឯកេ សមណព្រាហ្មណា អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខន្តិ វិបរីតោ សមណោ គោតមោ ភិក្ខវោ ច សមណោ គោតមោ ឯវមាហ យស្មឹ សមយេ សុភំ វិមោក្ខំ ឧបសម្បជ្ជ វិហរតិ សព្វំ តស្មឹ សមយេ អសុភន្តេវ សញ្ជានាតីតិ ។ ន ខោ បនាហំ ភគ្គវ ឯវំ វទាមិ យស្មឹ សមយេ សុភំ វិមោក្ខំ ឧបសម្បជ្ជ វិហរតិ សព្វំ តស្មឹ សមយេ អសុភន្តេវ សញ្ជានាតីតិ ។ ឯវញ្ច ខោ អហំ ភគ្គវ វទាមិ យស្មឹ សមយេ សុភំ វិមោក្ខំ ឧបសម្បជ្ជ វិហរតិ សុភន្តេវ តស្មឹ សមយេ សញ្ជានាតីតិ ។

---

១ ឱ ម. បច្ចត្តំយេវ ។

ក៏មិនបានប្រកាន់ខុសឡើយ ។ កាលតថាគត មិនបានប្រកាន់ខុស ហើយ ទើបដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសចំពោះខ្លួនឯង កាលដែល តថាគត ដឹងច្បាស់នូវសេចក្តីរលត់នៃកិលេសហើយ ក៏មិនដល់នូវសេចក្តី វិនាសឡើយ ។

(១៧) ម្នាលភគ្គវៈ សមណព្រាហ្មណ៍ពួកមួយ ពោលបង្កាច់ តថាគត ដែលមានវាទៈយ៉ាងនេះ ជាអ្នកប្រាប់យ៉ាងនេះ ដោយពាក្យ មិនមាន ជាពាក្យទទេ ជាពាក្យកុហកមិនពិតថា ព្រះសមណគោតមនឹង ពួកភិក្ខុមានសេចក្តីសំគាល់ខុស ព្រោះព្រះសមណគោតម និយាយយ៉ាង នេះថា សម័យណា យោគីបានដល់នូវសុភវិមោក្ខ (វណ្ណកសិណ) សម័យនោះយោគី រមែងដឹងច្បាស់នូវរបស់ទាំងពួងដែលល្អក្តី មិនល្អក្តី ថាជារបស់មិនល្អតែមួយយ៉ាង ។ ម្នាលភគ្គវៈ តថាគតឥតបានពោល យ៉ាងនេះថា សម័យណា យោគីបានដល់នូវសុភវិមោក្ខ សម័យនោះ យោគី រមែងដឹងច្បាស់នូវរបស់ទាំងពួង ដែលល្អក្តី មិនល្អក្តី ថាជា របស់មិនល្អតែមួយយ៉ាងដូច្នេះឡើយ ។ ម្នាលភគ្គវៈ តថាគតតែងនិ-យាយយ៉ាងនេះថា សម័យណា យោគីបានដល់នូវសុភវិមោក្ខ សម័យ នោះយោគី រមែងដឹងច្បាស់ថាជារបស់ល្អតែមួយយ៉ាងដូច្នេះទេតើ ។

តេ ច(១) វិបរិតា យេ ភគវន្តំ វិបរិតត្តា ទហន្តិ ភិក្ខវេ ច ឯវំបសន្នោ អហំ ភន្តេ ភគវតិ(២) បហោតិ ច(៣) មេ ភគវា តថា ធម្មំ ទេសេតុំ យថា អហំ សុភំ វិមោក្ខំ ឧបសម្បជ្ជ វិហរេយ្យន្តិ ។ ទុក្ករំ ខោ ឯតំ ភគ្គវ តយា អញ្ញទិដ្ឋិកេន អញ្ញក្ខន្តិកេន អញ្ញរុចិកេន អញ្ញត្រ អាយោគេន អញ្ញត្រ អាចរិយកេន សុភំ វិមោក្ខំ ឧបសម្បជ្ជ វិហរិតុំ ឥង្ឃ ត្វំ ភគ្គវ យោ ច តេ អយំ មយិ បសាទោ តមេវ ត្វំ សាធុកំ អនុរក្ខាហិ ។ សចេ ភន្តេ មយា ទុក្ករំ អញ្ញទិដ្ឋិកេន អញ្ញក្ខន្តិកេន អញ្ញរុចិកេន អញ្ញត្រ អាយោគេន អញ្ញត្រ អាចរិយកេន

---

១ ឱ. តេ ច ភន្តេ ។ ២ ឱ. អហំ ភគវតិ ។ ៣ ឱ. បហោតេ ន វិស្សតិ ។

ភគ្គវគោត្របរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន សមណព្រាហ្មណ៍ទាំងឡាយណា ដុតកំដៅព្រះមានព្រះភាគ ទាំងពួកភិក្ខុថា ជាអ្នកមានសេចក្តីសំគាល់ខុស សមណព្រាហ្មណ៍ទាំងឡាយនោះ ជាបុគ្គលមានសេចក្តីសំគាល់ខុសវិញទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាបុគ្គលជ្រះថ្លាចំពោះព្រះមានព្រះភាគ ដោយប្រការដូច្នេះ ដ្បិតព្រះមានព្រះភាគ អាចសំដែងធម៌ប្រោសខ្ញុំព្រះអង្គ ដោយអាការដែលធ្វើខ្ញុំព្រះអង្គឲ្យបានដល់នូវសុភវិមោក្ខបាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភគ្គវៈ ការដែលអ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីដទៃ មានអាចារ្យក្នុងទីដទៃ កម្រនឹងបានដល់នូវសុភវិមោក្ខនុះ ក្រៃពេក ម្នាលភគ្គវៈ ណ្ហើយចុះ សេចក្តីជ្រះថ្លាណា របស់អ្នកចំពោះតថាគត ចូរអ្នកពេញចិត្តរក្សាតែសេចក្តីជ្រះថ្លានោះឲ្យល្អចុះ ។ ភគ្គវគោត្របរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន បើខ្ញុំព្រះអង្គមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីដទៃ មានអាចារ្យក្នុងទីដទៃ

សុភំ វិមោក្ខំ ឧបសម្បជ្ជ វិហរិតុំ យោ ច មេ អយំ កណ្ដេ កតវតិ បសាទោ តមេកហំ សាធុកាមធុ-រត្តិសញ្ញមីតិ(១) ។ ឥទមេវច កតក ។ អត្ថមេទោ កត្តវេគោត្តោ បរិញ្ញាជគោ កតវេគោ កាសិតំ អភិ-ឆន្ទិតិ ។

ជាតិកសុត្តំ បឋមំ (២) និដ្ឋិតំ ។

---

១ ឱ. សាធុកំ អតុរត្តិសញ្ញមីតិ ។ ២ ឱ. ជាតិកសុត្តំ បឋមំ ។ ម. ជាតិកសុត្តំ បឋមំ សមត្តំ ។

## ពាលិកសូត្រ ពោលអំពីសុភវិមោក្ខ

កម្រនឹងបានដល់ នូវសុភវិមោក្ខនុ៎ះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីជ្រះថ្លាណា របស់ខ្ញុំព្រះអង្គ ចំពោះព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រុងរក្សាតែសេចក្តីជ្រះថ្លានោះឯងឲ្យប្រពៃ ។ ព្រះមានព្រះភាគ បានត្រាស់សំដែងសេចក្តីនេះចប់ហើយ ។ ភគ្គវគោត្របរិព្វាជក ក៏មានចិត្តរីករាយត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ពាលិកសូត្រ ទី ១ ។

# ឧទុម្ពរិកសុត្តំ ទុតិយំ

(១៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន និគ្រោធោ បរិព្វាជកោ ឧទុម្ពរិកាយ បរិព្វាជការាមេ បដិវសតិ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ តឹសមត្តេហិ បរិព្វាជកសតេហិ ។ អថខោ សន្ធានោ គហបតិ ទិវាទិវស្ស រាជគហា និក្ខមិ ភគវន្តំ ទស្សនាយ ។ អថខោ សន្ធានស្ស គហបតិស្ស ឯតទហោសិ អកាលោ ខោ តាវ ភគវន្តំ ទស្សនាយ បដិសល្លីនោ ភគវា មនោភាវនីយានំបិ ភិក្ខូនំ អសមយោ ទស្សនាយ បដិសល្លីនា មនោភាវនីយា ភិក្ខូ យន្នូនាហំ យេន ឧទុម្ពរិកាយ បរិព្វាជការាមោ យេន និគ្រោធោ បរិព្វាជកោ តេនុបសង្កមេយ្យន្តិ ។ អថខោ សន្ធានោ គហបតិ យេន ឧទុម្ពរិកាយ បរិព្វាជការាមោ យេន និគ្រោធោ បរិព្វាជកោ តេនុបសង្កមិ ។

# ឧទុម្ពរិកសូត្រ ទី ២

[១៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង បរិព្វាជកឈ្មោះនិគ្រោធ នៅអាស្រ័យក្នុងបរិព្វាជការាម ជារបស់នាងទេវីឈ្មោះឧទុម្ពរិកា ជាមួយនឹងបរិព្វាជកបរិស័ទ ជាច្រើន ប្រមាណ ៣០០០ នាក់ ។ គ្រានោះឯង គហបតីឈ្មោះសន្ធាន បានចេញអំពីក្រុងរាជគ្រឹះ ដើម្បីគាល់ព្រះមានព្រះភាគ ក្នុងវេលាថ្ងៃជ្រេពីត្រង់ ។ គ្រានោះ សន្ធានគហបតី មានសេចក្តីត្រិះរិះដូច្នេះថា កាលនេះជាកាលមិនគួរនឹងទៅគាល់ព្រះមានព្រះភាគនៅឡើយ (ព្រោះថា) ព្រះមានព្រះភាគ ទ្រង់កំពុងសម្ងំនៅ(១) ទាំងមិនមែនជាសម័យ ដើម្បីជួបភិក្ខុទាំងឡាយ ដែលជាអ្នកចម្រើនចិត្ត(២) ព្រោះពួកភិក្ខុជាអ្នកចម្រើនចិត្ត ក៏កំពុងនៅសម្ងំដែរ បើដូច្នោះគួរតែអាត្មាអញ ចូលទៅរកនិគ្រោធបរិព្វាជក ឯបរិព្វាជការាម របស់ព្រះនាងឧទុម្ពរិកាទេវី (សិនចុះ) ។ ទើបសន្ធានគហបតីចូលទៅរកនិគ្រោធបរិព្វាជក ឯបរិព្វាជការាម របស់នាងឧទុម្ពរិកាទេវី ។

---

១ អដ្ឋកថា ថា សំដៅដល់ការចូលទៅក្នុងឈាន ។ ២ ព្រោះដល់ការនៃការធ្វើឲ្យពេញចិត្ត ។

## ឧទុម្ពរិកសុត្ត និគ្រោធបរិព្វាជកវត្ថុ

(១៩) តេន ខោ បន សមយេន និគ្រោធោ បរិព្វាជកោ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ និសិន្នោ ហោតិ ឧន្នាទិនិយា ឧច្ចាសទ្ទមហាសទ្ទាយ អនេកវិហិតំ តិរច្ឆានកថំ កថេន្តិយា សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ ជនបទកថំ នគរកថំ(១) ឥត្ថីកថំ បុរិសកថំ សុរាបានកថំ(២) វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំកថំ សមុទ្ទក្ខាយិកំកថំ ឥតិភវាភវកថំ ឥតិ វា ។ អទ្ទសា ខោ និគ្រោធោ បរិព្វាជកោ សន្ធានំ គហបតឹ ទូរតោវ អាគច្ឆន្តំ ទិស្វាន សកំ បរិសំ សណ្ឋាបេសិ(៣) អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ អយំ សមណស្ស គោតមស្ស សាវកោ

---

១ ឱ. ម. នគរកថំ ជនបទកថំ ។ ២ ឱ. ម. សូរកថំ ។ ៣ ឱ. សណ្ឋាបេតិ ។

## ឧទុម្ពរិកសូត្រ រឿងនិគ្រោធបរិព្វាជក

(១៩) សម័យនោះឯង និគ្រោធបរិព្វាជក កំពុងអង្គុយជាមួយនឹងបរិព្វាជកបរិស័ទ្យជាច្រើន ដែលកំពុងតឹកកងរំពង មានសំឡេងហ៊ោសំឡេងខ្លាំង និយាយតិរច្ឆានកថាមានប្រការផ្សេង ៗ គឺនិយាយពីស្ដេច និយាយពីចោរ និយាយពីមហាមាត្រ និយាយពីសេនា និយាយពីភ័យ និយាយពីចំបាំង និយាយពីបាយ និយាយពីទឹក និយាយពីសំពត់ និយាយពីទីដេក និយាយពីកម្រងផ្កា និយាយពីគ្រឿងក្រអូប និយាយពីញាតិ និយាយពីយាន និយាយពីស្រុក និយាយពីនិគម និយាយពីជនបទ និយាយពីក្រុង និយាយពីស្ត្រី និយាយពីបុរស និយាយពីការផឹកសុរា និយាយពីច្រកល្ហក និយាយពីកំពង់ទឹក និយាយពីបុព្វប្រេត និយាយពីរឿងផ្សេង ៗ ដែលឥតប្រយោជន៍ និយាយរឿងលោក (និយាយរឿងក្អែកសកុកក្រហមជាដើម) និយាយពីសមុទ្រ និយាយពីសេចក្ដីចំរើននឹងសេចក្ដីសាបសូន្យ ដែលជាហេតុឥតប្រយោជន៍ជាដូច្នេះខ្លះ ដូច្នោះខ្លះ ៗ និគ្រោធបរិព្វាជក បានឃើញសន្ធានគហបតិ កំពុងដើរមកពីចម្ងាយក៏ហាមបរិស័ទ្យរបស់ខ្លួនថា ពួកអ្នកដ៏ចំរើនចូរមានសំឡេងតិច ៗ ពួកអ្នកដ៏ចំរើនកុំនិយាយគ្នាឡើយ នេះជាសាវ័ករបស់ព្រះសមណគោតម

អាគច្ឆតិ សន្ធានោ គហបតិ យាវតា ខោ បន សមណស្ស គោតមស្ស សាវកា គិហី ឱទាតវសនា រាជគហេ បដិវសន្តិ អយំ តេសំ អញ្ញតរោ សន្ធានោ គហបតិ អប្បសទ្ទកាមា ខោ បនាយស្មន្តោ អប្បសទ្ទស្ស វណ្ណវាទិនោ(១) អប្បេវនាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ ឯវំ វុត្តេ តេ បរិព្វាជកា តុណ្ហី អហេសុំ ។

(២០) អថខោ សន្ធានោ គហបតិ យេន និគ្រោធោ បរិព្វាជកោ តេនុបសង្កមិ ឧបសង្កមិត្វា និគ្រោធេន បរិព្វាជកេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សន្ធានោ គហបតិ និគ្រោធំ បរិព្វាជកំ ឯតទវោច អញ្ញថា ខោ ឥមេ ភោន្តោ អញ្ញតិត្ថិយា បរិព្វាជកា សង្គម្ម សមាគម្ម ឧន្នាទិនោ ឧច្ចាសទ្ទមហាសទ្ទា អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា(២) វិហរន្តិ សេយ្យថីទំ រាជកថំ

---

១ ឱ. បរនេតេ អាយស្មន្តោ អប្បសទ្ទវិនីតា អប្បសទ្ទវណ្ណវាទិនោ ។ ២ ឱ. កថេន្តា ។

ឈ្មោះសន្ធានគហបតិកំពុងដើរមក មួយទៀតពួកគ្រហស្ថជាសាវ័ករបស់ព្រះសមណគោតម ជាមនុស្សមានសំលៀកបំពាក់ស នៅអាស្រ័យក្នុងក្រុងរាជគ្រឹះ សន្ធានគហបតិនេះក៏ជាសាវ័ក ១ ក្នុងពួកសាវ័កទាំងនោះដែរ ពួកលោកមានអាយុ សុទ្ធតែត្រូវការមនុស្សមានសំឡេងតិច សរសើរតែមនុស្សមានសំឡេងតិច ៗ ធ្វើម្តេចឲ្យគេដឹងនូវបរិសទ្យ ដែលមានសំ-ឡេងតិច ហើយសំគាល់នូវទី ដែលគេត្រូវចូលមករក ។ កាលបើនិគ្រោធបរិព្វាជកនិយាយ យ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នានៅស្ងៀម ។

(២០) លំដាប់នោះ សន្ធានគហបតិ បានចូលទៅរកនិគ្រោធបរិព្វាជក លុះចូលទៅដល់ហើយ ក៏បានរាក់ទាក់ជាមួយនឹងនិគ្រោធ-បរិព្វាជក បញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសន្ធានគហបតិអង្គុយក្នុងទីសមគួរហើយ បាននិយាយពាក្យនេះទៅនឹងនិគ្រោធបរិព្វាជកថា លោកដ៏ចំរើនទាំងឡាយពួកបរិព្វាជកជាអន្យតិរ្ថិយនេះ ជួបជុំសមាគមគ្នាហើយ តែងមានសំឡេងហ៊ោ សំឡេងខ្លាំង ប្រកបតិរច្ឆានកថាច្រើនយ៉ាង គឺ និយាយពីស្តេច

ចោរកថំ ។ បេ ។ ឥតិភវាភវកថំ ឥតិ វា អញ្ញថា ខោ បន(១) សោ ភគវា អរញ្ញេ វនបត្ថានិ បន្តានិ សេនាសនានិ បដិសេវតិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានីតិ ។ ឯវំ វុត្តេ និគ្រោធោ បរិព្វាជកោ សន្ធានំ គហបតឹ ឯតទវោច យគ្ឃេ គហបតិ ជានេយ្យាសិ កេន សមណោ គោតមោ សទ្ធឹ សល្លបតិ កេន សាកច្ឆំ សមាបជ្ជតិ កេន បញ្ញាវេយ្យត្តិយំ សមាបជ្ជតិ(២) សុញ្ញាគារហតា សមណស្ស គោតមស្ស បញ្ញា អបរិសាវចរោ សមណោ គោតមោ នាលំ សល្លាបាយ សោ អន្តមន្តានេវ(៣) សេវតិ សេយ្យថាបិ នាម គោកាណា បរិយន្តចារិនី អន្តមន្តានេវ សេវតិ ឯវមេវ សុញ្ញាគារហតា សមណស្ស គោតមស្ស បញ្ញា

១ ឱ. ប បន ។ ២ ឱ. ម. អាបជ្ជតិ ។ ៣ ឱ. ម. អន្តមន្តានេវ ។

និយាយពីចោរ ៗ បេ ៗ និយាយពីសេចក្តីចំរើននិងសេចក្តីសាបសូន្យ ដែលជាហេតុឥតប្រយោជន៍ថាដូច្នេះខ្លះ ដូច្នោះខ្លះ ឯព្រះមានព្រះភាគ ព្រះអង្គនោះ ដោយឡែក គឺទ្រង់សេពសេនាសនៈដ៏ស្ងាត់ តាំងនៅ ក្នុងព្រៃស្រោង ជាសេនាសនៈមានសំឡេងស្ងឹកគឹកកងតិច ប្រាសចាក ពាក្យសំដីរបស់អ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស គួរដល់ ការលាក់ខ្លួនពួនអាត្មាបាន ៗ កាលបើសន្ធានគហបតិនិយាយយ៉ាងនេះ ហើយ និគ្រោធបរិព្វាជកក៏និយាយពាក្យនេះ ទៅនឹងសន្ធានគហបតិថា នែគហបតិ ដូចជាយើងរះគន់ អ្នកឯងត្រូវដឹងថា ព្រះសមណគោតម ចរចាជាមួយនឹងអ្នកណាបាន ប្រទះសាកច្ឆាជាមួយនឹងអ្នកណា ល្បងនូវ ភាពវាងវៃដោយប្រាជ្ញាជាមួយនឹងអ្នកណា (ដូចម្តេចបាន) ព្រោះប្រាជ្ញា របស់ព្រះសមណគោតម បាត់វិនាសក្នុងផ្ទះស្ងាត់អស់ទៅហើយ ព្រះ សមណគោតមជាបុគ្គលមិនហ៊ានចុះកាន់បរិសទ្យ មិនអាចធ្វើការចរចានឹង អ្នកដទៃបានទេ បានជាលោកតែងអាស្រ័យនៅតែក្នុងសេនាសនៈដ៏ស្ងាត់ ប៉ុណ្ណោះ ដូចមេគោខ្វាក់ភ្នែកម្ខាង តែងត្រាច់ទៅតែក្នុងទីជុំវិញ គប់រក តែទីស្ងាត់ប៉ុណ្ណោះ(១) ដូចម្តេចមិញ ប្រាជ្ញារបស់ព្រះសមណគោតម

---

១ អដ្ឋកថា ថា មេគោខ្វាក់ម្ខាងចូលចិត្តរកស៊ីខាងៗ ព្រៃ ព្រោះខ្លាចក្រែងស្លឹកឈើមែកឈើឬបន្លាប៉ះលើ មិនហ៊ាននៅក្នុងហ្វូង ព្រោះខ្លាចក្រែងប៉ះស្នែង ប៉ះត្រចៀកឬកន្ទុយពួកគោដូចគ្នា ។

អបរិសាវចរោ សមណោ គោតមោ នាលំ សល្លាបាយ សោ អន្តមន្តានេវ សេវតិ ឥង្ឃ គហបតិ សមណោ គោតមោ ឥមំ បរិសំ អាគច្ឆេយ្យ ឯកបញ្ហេនេវ នំ សំសាទេយ្យាម(១) តុច្ឆកុម្ភីវ នំ មញ្ញេ ឱរោធេយ្យាមាតិ ។

[២១] អស្សោសិ ខោ ភគវា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ សន្ធានស្ស គហបតិស្ស និគ្រោធេន បរិព្វាជកេន សទ្ធឹ ឥមំ កថាសល្លាបំ ។ អថខោ ភគវា គិជ្ឈកូដា បព្វតា ឱរោហិត្វា យេន សុមាគធាយ តីរេ មោរនិវាបោ តេនុបសង្កមិ ឧបសង្កមិត្វា សុមាគធាយ តីរេ មោរនិវាបេ អព្ភោកាសេ ចង្កមតិ(២) ។ អទ្ទសា ខោ និគ្រោធោ បរិព្វាជកោ ភគវន្តំ សុមាគធាយ តីរេ មោរនិវាបេ អព្ភោកាសេ ចង្កមន្តំ ទិស្វា(៣) សកំ បរិសំ សណ្ឋាបេសិ អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមករិត្ថ អយំ សមណោ គោតមោ សុមាគធាយ តីរេ មោរនិវាបេ អព្ភោកាសេ ចង្កមតិ

១ ម. សំហរេយ្យាម ។ ២ ទី ម. ចង្កមិ ។ ៣ ម. ទិស្វាន ។

ក៏វិនាសបាត់ទៅក្នុងផ្ទះស្ងាត់ហើយ ព្រះសមណគោតម មិនហ៊ានចូលមកកាន់បរិសទ្យ មិនគួរនឹងនិយាយសំណេះសំណាលបានទេ លោកតែងអាស្រ័យនៅតែក្នុងសេនាសនៈដ៏ស្ងាត់ដូច្នោះឯង នៃអ្នកគហបតិ ល្បងមើលចុះ បើព្រះសមណគោតមគប្បីមករកបរិសទ្យនេះ ពួកយើងគួរសាកសួរលោកមួយប្រស្នាល្បងមើលដែរ ពួកយើងត្រូវចាប់បង្វិលព្រះសមណ-គោតមនោះ ឲ្យដូចជាគេចាប់បង្វិលឆ្នាំងទទេ (មិនខាន) ។

[៤១] ព្រះមានព្រះភាគ ទ្រង់ជ្រាបពាក្យឆ្លើយឆ្លងនេះ របស់សន្ធានគហបតីនឹងនិគ្រោធបរិព្វាជក ដោយសោតធាតុដូចជាទិព្វដ៏បរិ-សុទ្ធ កន្លងបង់នូវសោតធាតុរបស់មនុស្សសាមញ្ញ ។ លំដាប់នោះ ព្រះមានព្រះភាគស្តេចចុះ អំពីភ្នំគិជ្ឈកូដ ហើយចូលទៅឯមោរនិវាបស្ថាន (កន្លែងសម្រាប់ឲ្យចំណីដល់សត្វក្ងោក) ក្បែរឆ្នេរស្រះ ឈ្មោះសុមាគធា លុះចូលទៅដល់ហើយ ក៏ទ្រង់ចង្ក្រមក្នុងទីវាលទៀបមោរនិវាបស្ថាន ក្បែរឆ្នេរស្រះឈ្មោះសុមាគធា ។ លុះនិគ្រោធបរិព្វាជក បានឃើញព្រះមានព្រះភាគ ទ្រង់ចង្ក្រមក្នុងទីវាលជិតមោរនិវាបស្ថាន ទៀបឆ្នេរស្រះសុមាគធាហើយ ក៏បញ្ឈប់បរិសទ្យរបស់ខ្លួនថា សូមអ្នកដ៏ចម្រើនទាំងឡាយមានសំឡេងតិច ៗ សូមអ្នកទាំងឡាយកុំជជែកគ្នាឡើយ នេះព្រះសមណ-គោតម កំពុងចង្ក្រមក្នុងទីវាលជិតមោរនិវាបស្ថាន ក្បែរឆ្នេរស្រះសុមាគធា

អប្បសទ្ទកាមោ ខោ បន សោ អាយស្មា អប្បសទ្ទស្ស វណ្ណវាទី អប្បេវនាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យ សចេ សមណោ គោតមោ ឥមំ បរិសំ អាគច្ឆេយ្យ ឥមន្តំ បញ្ហំ បុច្ឆេយ្យាម គោ នាម សោ ភន្តេ ភគវតោ ធម្មោ យេន ភគវា សាវកេ វិនេតិ យេន ភគវតា សាវកា វិនីតា អស្សាសប្បត្តា បដិជានន្តិ អជ្ឈាសយំ អាទិព្រហ្មចរិយន្តិ ។ ឯវំ វុត្តេ តេ បរិព្វាជកា តុណ្ហី អហេសុំ ។

(២២) អថខោ ភគវា យេន និគ្រោធោ បរិព្វាជកោ តេនុបសង្កមិ ។ អថខោ និគ្រោធោ បរិព្វាជកោ ភគវន្តំ ឯតទវោច ឯតុ ខោ ភន្តេ ភគវា ស្វាគតំ(១) ភន្តេ ភគវតោ ចិរស្សំ ខោ ភន្តេ ភគវា ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទតុ ភន្តេ ភគវា

១ ឱ សាគតំ ។

ដ្បិតលោកដ៏មានអាយុនោះ ត្រូវការតែបុគ្គលមានសំឡេងតិច ៗ សរសើរតែមនុស្សមានសំឡេងតិច ៗ ធ្វើដូចម្តេចឲ្យលោកជ្រាបថា បរិសទ្យមានសំឡេងតិចហើយ គប្បីសំគាល់នូវកិច្ចដែលលោកគួរចូលមករក (យើង) បើព្រះសមណគោតម គប្បីមករកបរិសទ្យនេះ (មែន) ពួកយើងត្រូវសួរប្រស្នានេះនឹងលោកថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ទូន្មានពួកសាវ័កដោយធម៌ណា ពួកសាវ័កដែលព្រះមានព្រះភាគ ទ្រង់ទូន្មានដោយធម៌ណាហើយ ដល់នូវសេចក្តីត្រេកអរ បានបំពេញអរិយមគ្គ ជាព្រហ្មចរិយធម៌ដើម ជាធម៌ឲ្យកើតនិស្ស័យដ៏ឧត្តម ធម៌របស់ព្រះមានព្រះភាគនោះ តើឈ្មោះដូចម្តេច ។ កាលបើនិគ្រោធបរិព្វាជកនិយាយយ៉ាងនេះហើយ បរិព្វាជកទាំងនោះ ក៏នាំគ្នានៅស្ងៀម ។

(២២) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចូលទៅត្រង់កន្លែងដែលនិគ្រោធបរិព្វាជកនៅ ។ ទើបនិគ្រោធបរិព្វាជកក្រាបទូលសេចក្តីនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ស្តេចចូលមក បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គស្តេចមកប្រពៃហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គបានធ្វើបរិយាយនេះ ដើម្បីមកកន៍ទីនេះយូរយាណាស់ហើយ សូមព្រះអង្គស្តេចគង់ចុះ បពិត្រព្រះ

ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ភគវា បញ្ញត្តេ អាស-
នេ ។ និគ្រោធោបិ ខោ បរិព្វាជកោ អញ្ញតរំ នីចំ
អាសនំ(១) គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ
និសិន្នំ ខោ និគ្រោធំ បរិព្វាជកំ ភគវា ឯតទវោច
កាយ នុត្ថ និគ្រោធ ឯតរហិ កថាយ សន្និសិន្នា
កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឯវំ
វុត្តេ និគ្រោធោ បរិព្វាជកោ ភគវន្តំ ឯតទវោ-
ច ឥធ មយំ ភន្តេ អទ្ទសាម ភគវន្តំ សុមា-
គធាយ តីរេ មោរនិវាបេ អព្ភោកាសេ ចង្កមន្តំ
ទិស្វា ឯវំ អវោចុម្ហា សចេ សមណោ គោតមោ
ឥមំ បរិសំ អាគច្ឆេយ្យ ឥមន្តំ បញ្ហំ បុច្ឆេយ្យាម កោ
នាម សោ ភន្តេ ភគវតោ ធម្មោ យេន ភគវា
សាវកេ វិនេតិ យេន ភគវតា សាវកា វិនីតា អស្សា-
សប្បត្តា បដិជានន្តិ អជ្ឈាសយំ អាទិព្រហ្មចរិយន្តិ
អយំ ខោ នោ ភន្តេ អន្តរាកថា វិប្បកតា អថ ភគវា

១ ម. នីចាសនំ ។

អង្គដ៏ចំរើន នេះអាសនៈដែលខ្ញុំព្រះអង្គ បានក្រាលទុកស្រេចហើយ ។ ព្រះមានព្រះភាគស្តេចគង់លើអាសនៈ ដែលគេក្រាលទុកស្រេចហើយ ។ ចំណែកឯ និគ្រោធបរិព្វាជក ក៏កាន់យកអាសនៈទាបមួយ ហើយអង្គុយក្នុងទីសមគួរ ។ ព្រះមានព្រះភាគ បានត្រាស់សួរសេចក្តីនេះ នឹងនិគ្រោធបរិព្វាជក ដែលអង្គុយក្នុងទីសមគួរ យ៉ាងនេះថា ម្នាលនិគ្រោធ អម្បាញ់មិញនេះ អ្នកអង្គុយប្រជុំគ្នានិយាយរឿងអ្វី សំដីដូចម្តេច ដែលពួកអ្នកឈប់បង្អង់ទាំងពាក់កណ្តាល ។ កាលបើ ព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះហើយ និគ្រោធបរិព្វាជក ក្រាបទូលសេចក្តីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គ ក្នុងទីនេះ បានឃើញព្រះមានព្រះភាគ ស្តេចកំពុងចង្រ្កមក្នុងទីវាល ទៀបមោរនិវាបស្ពានក្បែរឆ្នេរស្រះសុមាគធា លុះឃើញហើយ បាននាំគ្នានិយាយយ៉ាងនេះថា បើព្រះសមណគោតម គប្បីមកកាន់បរិសទ្យនេះ (មែន) ពួកយើងត្រូវសួរប្រស្នានេះ ចំពោះព្រះអង្គថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ទូន្មានពួកសាវ័កដោយធម៌ណា ពួកសាវ័កដែលព្រះមានព្រះភាគ ទ្រង់ទូន្មានដោយធម៌ណាហើយ ដល់នូវសេចក្តីត្រេកអរ បានបំពេញអាទិព្រហ្មចរិយធម៌ដើម ដែលឲ្យកើតនិស្ស័យដ៏ឧត្តម ធម៌របស់ព្រះមានព្រះភាគនោះ តើឈ្មោះដូចម្តេច

## ឧទុម្ពរិកសុត្តេ តបោជិគុច្ឆាវាទាទិកថា

អធុប្បត្តោតិ ។ ទុជ្ជានំ ខោ បនេតំ និគ្រោធ តយា អញ្ញទិដ្ឋិកេន អញ្ញខន្តិកេន អញ្ញរុចិកេន អញ្ញត្រ អាយោគេន អញ្ញត្រ អាចរិយកេន យេនាហំ សាវកេ វិនេមិ យេន មយា សាវកា វិនីតា អស្សាសប្បត្តា បដិជានន្តិ អជ្ឈាសយំ អាទិព្រហ្មចរិយន្តិ ឥង្ឃ ត្វំ និគ្រោធ សកេ អាចរិយកេ អធិជិគុច្ឆេ(១) បញ្ហំ បុច្ឆ កថំ សន្តា នុ ខោ ភន្តេ តបោជិគុច្ឆា បរិបុណ្ណា ហោតិ កថំ អបរិបុណ្ណាតិ ។ ឯវំ វុត្តេ តេ បរិព្វាជកា ឧន្នាទិនោ ឧច្ចាសទ្ទមហាសទ្ទា អហេសុំ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ សមណស្ស គោតមស្ស ម-ហិទ្ធិកតា មហានុភាវតា(២) យត្រ ហិ នាម សកវាទំ ឋបេស្សតិ បរវាទេន បវារេស្សតីតិ ។

---

១ ឱ. ម. អធិជេគុច្ឆេ ។ ២ ម. មហានុភាវកតា ។

### ឧទុម្ពរិកសូត្រ ពោលអំពីតបោជិគុច្ឆវាទជាដើម

បពិត្រព្រះអង្គដ៏ចម្រើន សំដីនេះឯងដែលពួកខ្ញុំព្រះអង្គ ឈប់បង្អង់ទាំងពាក់កណ្តាល ក៏ទទួលព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ តថាគតទូន្មានពួកសាវ័ក ដោយធម៌ណា ពួកសាវ័កដែលតថាគតទូន្មានហើយ ដោយធម៌ណា ដល់នូវសេចក្តីគាប់ចិត្ត បានបំពេញអរិយមគ្គជាព្រហ្មចរិយធម៌ ដើម ដែលឲ្យកើតនិស្ស័យដ៏ឧត្តម អ្នកឯងដែលមានទិដ្ឋិដោយឡែក មានសេចក្តីពេញចិត្តដោយឡែក មានសេចក្តីគាប់ចិត្តដោយឡែក មិនងាយនឹងដឹងធម៌នោះទេ វៀរលែងតែអ្នកមានព្យាយាមជាគ្រឿងប្រកបខ្ជាំង វៀរលែងតែអ្នកបានរៀនក្នុងសំណាក់អាចារ្យ (នោះទើបដឹងបាន) ម្នាលនិគ្រោធ អញ្ជើញអ្នកសួរប្រស្នាក្នុងការខ្ពើមបាប ជាអាចារិយវាទរបស់ខ្លួននឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ដូចម្តេចឈ្មោះថាបរិបូណ៌ ដូចម្តេចឈ្មោះថាមិនបរិបូណ៌ ។ កាលបើព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នាបន្លឺមានសំឡេងហោ សំឡេងខ្លាំងថា នែអ្នកដ៏ចម្រើន គួរអស្ចារ្យណាស់តើ នែអ្នកដ៏ចម្រើន ហេតុមិនដែលមានហ្ន៎ ព្រះសមណគោតម ព្រះអង្គមានបុទ្ធិច្រើន មានអានុភាពខ្លាំង ព្រោះទ្រង់បញ្ឈប់វាទៈរបស់ព្រះអង្គ ទ្រង់បណ្តោយឲ្យអ្នកដទៃនិយាយវិញ ។

(២៣) អថខោ និគ្រោធោ បរិព្វាជកោ តេ បរិព្វាជកេ អប្បសទ្ទេ កត្វា ភគវន្តំ ឯតទវោច មយំ ខោ ភន្តេ តបោជិគុច្ឆវាទា តបោជិគុច្ឆំ អល្លីនា(១) វិហរាម កថំសន្តា នុ ខោ ភន្តេ តបោជិគុច្ឆា បរិបុណ្ណា ហោតិ កថំ អបរិបុណ្ណាតិ ។ ឥធ និគ្រោធ តបស្សី អចេលកោ ហោតិ មុត្តាចារោ ហត្ថាវលេខនោ(២) ន ឯហិភទ្ទន្តិកោ ន តិដ្ឋភទ្ទន្តិកោ ន អភិហតំ(៣) ន ឧទ្ទិស្សកតំ ន និមន្តនំ សាទិយតិ សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោបិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ

---

១ ឱ. តបោជិគុច្ឆា វាទា តបោជិគុច្ឆា សារា តបោជិគុច្ឆា អល្លីនា ។ ម. តបោជិគុច្ឆំ សារោទា តបោជិគុច្ឆំ អល្លីនា ។ ២ ឱ. ម. ហត្ថាបលេខនោ ។ ៣ ឱ. នាភិហតំ ។ ម. ន អភិហដំ ។

(២៣) លំដាប់នោះឯង និគ្រោធបរិព្វាជក ធ្វើពួកបរិព្វាជកទាំងនោះ ឲ្យមានសំឡេងតិចហើយ បានទូលសួរសេចក្ដីនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គជាតបោជិគុច្ឆវាទ (អ្នកពោលប្រកាន់ការខ្ពើមបាប ដោយព្យាយាមជាគ្រឿងដុតកិលេស) ជាអ្នកមិនរួញរាទឹងតបោជិគុច្ឆវត្ត បពិត្រព្រះអង្គដ៏ចំរើន ការខ្ពើមបាបដោយព្យាយាមជាគ្រឿងដុតកិលេស ដូចម្ដេចទើបឈ្មោះថាបរិបូណ៌ ដូចម្ដេចឈ្មោះថាមិនបរិបូណ៌ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ មនុស្សបំពេញព្យាយាមជាគ្រឿងដុតកិលេសក្នុងលោកនេះ ជាអ្នកអាក្រាតកាយ មានមារយាទល្អលះបង់ហើយ ប្រកាន់ហត្ថាវលេខនបដិបត្តិ(១) ជាអ្នកប្រកាន់វត្តដែលគេនិមន្តថា លោកដ៏ចំរើន សូមចូលមកទទួលភត្តហើយមិនចូលមក ប្រកាន់វត្តដែលគេនិមន្តថា លោកដ៏ចម្រើនចូរឈរចាំសិនហើយមិនឈរចាំ មិនត្រេកអរនឹងភិក្ខាដែលគេនាំមកមុនបំផុត មិនត្រេកអរនឹងភិក្ខាដែលគេធ្វើចំពោះខ្លួន មិនត្រេកអរនឹងការនិមន្ត មិនទទួលភិក្ខាដែលគេដួសឲ្យពីឆ្នាំង មិនទទួលភិក្ខាដែលគេដួសឲ្យពីកញ្ឆេ មិនទទួលភិក្ខាដែលគេកន្លងធរណីទ្វារនាំមក មិនទទួលភិក្ខាដែលគេកន្លងត្បាល់នាំមក

---

១ អដ្ឋកថា ថាសំដៅដល់ការបរិភោគលិទ្ធដៃ ឬថាវិលោបខ្ទោបង់ឧច្ចារៈហើយ ជូតជម្រះស្អាតនឹងដៃ ។ មហាសីហនាទសូត្រ ។

## ឧទុម្ពរិកសុត្តេ តបោជិគុច្ឆវាទកថា

ន មុសលមន្តរំ ន ទណ្ឌមន្តរំ ន ទ្វិន្នំ(១) ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សង្កិត្តីសុ ន យត្ថ សា ឧបដ្ឋិតា(២) ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ ។ សោ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ ទ្វាគារិកោ វា ហោតិ ទ្វាលោបិកោ សត្តាគារិកោ វា ហោតិ សត្តាលោបិកោ ឯកិស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ សត្តហិបិ ទត្តីហិ យាបេតិ ឯកាហិកំបិ អាហារំ អាហារេតិ ទ្វីហិកំបិ អាហារំ អាហារេតិ សត្តហិកំបិ(៣) អាហារំ អាហារេតិ ឥតិ ឯវរូបំ អទ្ធមាសិកំ(៤) បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។ សោ សាកភក្ខោ វា ហោតិ សាមាកភក្ខោ វា ហោតិ

---

១ ឧ. ន ឯឡកមន្តរំ ន ឧទុក្ខលមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ។ ម. ន ឯឡកមន្តរំ ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ។ ២ ឧ. ម. ឧបដ្ឋិតោ ។ ៣ ឧ. ម. សត្តាហិកំបិ ។ ៤ ឧ. អទ្ធមាសិកម្បិ ។

មិនទទួលភិក្ខា ដែលគេកន្លងអង្រែនាំមក មិនទទួលភិក្ខា ដែលគេកន្លងកំណាត់ឈើនាំមក មិនទទួលភិក្ខា របស់មនុស្សកំពុងបរិភោគពីរនាក់ មិនទទួលភិក្ខារបស់ស្ត្រីមានគភ៌ មិនទទួលភិក្ខា របស់ស្ត្រីកំពុងបំបៅកូន មិនទទួលភិក្ខា របស់ស្ត្រីដែលកំពុងស្ទាបអង្អែលបុរស មិនទទួលភិក្ខារបស់បុគ្គលដែលមានគេដឹកនាំឲ្យធ្វើ មិនទទួលភិក្ខា ក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលភិក្ខា ក្នុងទីដែលរុយកំពុងរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំ ។ អចេលកៈនោះ ទទួលភិក្ខាចំពោះតែក្នុងផ្ទះ ១ ឬញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយ ១ ពំនូតខ្លះ ទទួលភិក្ខាចំពោះតែក្នុងផ្ទះពីរ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយដុំបាយពីរពំនូតខ្លះ ទទួលភិក្ខាចំពោះតែក្នុងផ្ទះ ៧ ឬញុំាងអត្តភាពឲ្យប្រព្រឹត្តទៅចំពោះតែក្នុងដុំបាយ ៧ ពំនូតខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភាជន៍ ១ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភាជន៍ ២ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភាជន៍ ៧ ខ្លះ បរិភោគអាហាររំលង ១ ថ្ងៃខ្លះ បរិភោគអាហាររំលង ២ ថ្ងៃខ្លះ បរិភោគអាហាររំលង ៧ ថ្ងៃខ្លះ អចេលកៈនោះប្រកបនូវព្យាយាម ក្នុងភត្តភោជនដោយការផ្លាស់ប្តូរគ្នាកន្លះខែយ៉ាងនេះដូច្នេះ ។ អចេលកៈនោះ បរិភោគតែអន្លក់ស្រស់ខ្លះ បរិភោគតែស្រងែខ្លះ

និវារភក្ខោ វា ហោតិ ទទ្ទុលភក្ខោ វា ហោតិ សាតភក្ខោ វា ហោតិ(១) កណភក្ខោ វា ហោតិ អាចាមភក្ខោ វា ហោតិ បិញ្ញាកភក្ខោ វា ហោតិ តិណភក្ខោ វា ហោតិ គោមយភក្ខោ វា ហោតិ វនមូលផលាហារោ យាបេតិ បវត្តផលភោជី ។ សោ សាណានិបិ ធារេតិ មសាណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ បំសុកូលានិបិ ធារេតិ(២) តិរីដានិបិ ធារេតិ អជិនម្បិ ធារេតិ អជិនក្ខិបម្បិ ធារេតិ កុសចីរម្បិ ធារេតិ វាកចីរម្បិ ធារេតិ ផលកចីរម្បិ ធារេតិ កេសកម្ពលម្បិ ធារេតិ វាលកម្ពលម្បិ ធារេតិ ឧលូកបក្ខិកម្បិ ធារេតិ កេសមស្សុលោចកោបិ ហោតិ កេសមស្សុលោចនានុយោគមនុយុត្តោ ឧព្ភដ្ឋកោបិ ហោតិ អាសនប្បដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុដិកប្បធានមនុយុត្តោ

---

១ ឱ. ម. ទទ្ទុលភក្ខោ វា ហោតិ ហដភក្ខោ វា ហោតិ ។ ២ ឱ. ឯត្ថន្តរេ កម្ពលានិបិ ធារេតីតិ ទិស្សតិ ។

បរិភោគតែស្គួយខ្លះ បរិភោគតែបំនៀវស្បែកដែលគេចោលខ្លះ បរិភោគតែជ័រឫសាពយខ្លះ បរិភោគតែកុណ្ឌកខ្លះ បរិភោគតែបាយក្តាំងដែលគេចោលខ្លះ បរិភោគតែម្សៅខ្លះ បរិភោគតែស្មៅខ្លះ បរិភោគតែអាចម៍គោខ្លះ បរិភោគតែមើមនិងផ្លែក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះខ្លះ ។ គេប្រើសំពត់សម្បកធ្មៃខ្លះ ប្រើសំពត់ដែលគេត្បាញលាយគ្នាខ្លះ ប្រើសំពត់រុំសាកសពខ្លះ ប្រើសំពត់បង្សុកូលខ្លះ ស្លៀកពាក់សម្បកឈើខ្លះ ស្លៀកពាក់ស្បែកខ្លាខ្លះ ស្លៀកពាក់ស្បែកខ្លាទាំងក្រចកខ្លះ ស្លៀកពាក់ស្បូវក្រង់ខ្លះ ស្លៀកពាក់សំពត់សម្បកក្រចៅខ្លះ ប្រើសំពត់គេត្បាញដោយសម្បកផ្លែឈើខ្លះ ប្រើសំពត់កម្ពលដែលគេត្បាញដោយសក់មនុស្សខ្លះ ប្រើសំពត់កម្ពលដែលគេត្បាញដោយសក់កន្ទុយសេះខ្លះ ស្លៀកពាក់សំពត់ស្លាបមៀមខ្លះ ជាអ្នកដកសក់និងពុកមាត់ ប្រកបព្យាយាមក្នុងការដកសក់និងពុកមាត់ខ្លះ ជាអ្នកឈរហើយហាមឃាត់អាសនៈខ្លះ ជាអ្នកអង្គុយច្រហោង ប្រកបព្យាយាមក្នុងការអង្គុយច្រហោងខ្លះ ជាអ្នកគាន់

## ឧទុម្ពរិកសុត្តេ តបោជិគុច្ឆាវាទកថា

កណ្ដកាបស្សយិកោបិ ហោតិ កណ្ដកាបស្សយេ សេយ្យំ កប្បេតិ ផលកសេយ្យំបិ កប្បេតិ ថណ្ឌិលសេយ្យំបិ(១) កប្បេតិ ឯកបស្សយិកោបិ ហោតិ រជោជល្លធរោ អព្ភោកាសិកោបិ ហោតិ យថាសន្ថតិកោ វេកដិកោបិ ហោតិ វិកដភោជនានុយោគមនុយុត្តោ អបានកោបិ ហោតិ អបានកត្តមនុយុត្តោ សាយំតតិយកំបិ(២) ឧទកោរោហនានុយោគមនុយុត្តោ វិហរតិ ។ តំ កឹ មញ្ញសិ និគ្រោធ យទិ ឯវំ សន្តេ តបោជិគុច្ឆា បរិបុណ្ណា ហោតិ អបរិបុណ្ណាតិ(៣) ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តបោជិគុច្ឆា បរិបុណ្ណា ហោតិ នោ អបរិបុណ្ណាតិ ។ ឯវំ បរិបុណ្ណាយបិ ខោ អហំ និគ្រោធ តបោជិគុច្ឆាយ អនេកវិហិតេ ឧបក្កិលេសេ វទាមីតិ ។

---

១ ឱ. ថណ្ឌិលសេយ្យម្បិ ។ ២ ឱ. សាយតតិយកម្បិ ។ ៣ ឱ. បរិបុណ្ណា វា ហោតិ អបរិបុណ្ណា វាតិ ។

## ឧទុម្ពរិកសូត្រ ពោលអំពីតបោជិគុច្ឆាភិទជាដើម

វត្តឈរដើរជាដើមលើបន្លា សម្រេចការដេកលើបន្លាខ្លះ សម្រេចការដេកលើបន្ទះក្តារខ្លះ សម្រេចការដេកលើផែនដីទួលខ្លះ ជាអ្នកដេកផ្អៀងតែម្ខាងខ្លះ ជាអ្នកប្រឡាក់ខ្លួនដោយធូលី ឈរក្នុងទីវាល អង្គុយតែលើអាសនៈមួយ ដែលខ្លួនបានមកយ៉ាងណាខ្លះ បរិភោគតែលាមកប្រកបព្យាយាម ក្នុងការបរិភោគលាមកខ្លះ ជាអ្នកហាមឃាត់ទឹកត្រជាក់ប្រកបព្យាយាម ក្នុងការហាមឃាត់ទឹកត្រជាក់ខ្លះ ប្រកបព្យាយាមក្នុងការចុះត្រាំទឹកក្នុងមួយថ្ងៃ ៣ ដងខ្លះ ។ ម្នាលនិគ្រោធ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមាន ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិបូណ៌ហើយ ឬមិនទាន់បរិបូណ៌ទេ ។ និគ្រោធបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុយ៉ាងនេះមាន ការខ្ពើមបាបដោយសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ឈ្មោះថា បរិបូណ៌ហើយដោយពិត មិនមែនមិនបរិបូណ៌ទេ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមបាបដោយព្យាយាម ជាគ្រឿងដុតកិលេស ទុកជាបរិបូណ៌ហើយ យ៉ាងនេះ ក៏តថាគតឲ្យឈ្មោះថា នៅតែមានឧបក្កិលេសច្រើនយ៉ាង ។

[២៤] យថាកថំ បន ភន្តេ ភគវា ឃំបរិបុណ្ណាយ តបោជិគុច្ឆាយ អនេកវិហិតេ ឧបក្កិលេសេ វទតីតិ ។ ឥធ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ យំបិ(១) និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា អត្តានុក្កំសេតិ បរំ វម្ភេតិ ។ យំបិ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា អត្តានុក្កំសេតិ បរំ វម្ភេតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ

---

១ ឱ. យម្បី ហេ ។

(២៨) និគ្រោធបរិព្វាជក ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបាប ដោយព្យាយាមជាគ្រឿងដុតកិលេស បានបរិបូណ៌ប៉ុណ្ណោះដែរ ហេតុអ្វីក៏ព្រះមានព្រះភាគ នៅឲ្យឈ្មោះថា មានឧបក្កិលេសច្រើនយ៉ាង ៗ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ព្រោះមនុស្សមានតបវត្ត (វត្តសម្រាប់ព្យាយាមដុតកិលេស) ក្នុងលោកនេះ សមាទានតបវត្ត គេពេញចិត្ត ទាំងមានសេចក្ដីត្រិះរិះអស់ហើយត្រឹមតបវត្តនោះ ៗ ម្នាលនិគ្រោធ ត្រង់ដែលមនុស្សមានតបវត្ត សមាទាននូវតបវត្ត គេពេញចិត្តទាំងមានសេចក្ដីត្រិះរិះអស់ហើយ ត្រឹមតបវត្តនោះ ម្នាលនិគ្រោធ នេះឯង ជាឧបក្កិលេសរបស់មនុស្សអ្នកមានតបវត្ត ។ ម្នាលនិគ្រោធ ពាក្យខាងមុខទៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត អ្នកនោះលើកតែខ្លួនឯង បង្អាប់អ្នកដទៃ ព្រោះតបវត្តនោះ ៗ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទាននូវតបវត្ត គេលើកតែខ្លួនឯង តែងបង្អាប់អ្នកដទៃ ព្រោះតបវត្តនោះ ម្នាលនិគ្រោធ នេះក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខទៅមានទៀត

តបស្សី តបំ សមាទិយតិ សោ តេន តបសា មជ្ជតិ មុច្ឆតិ មទមាបជ្ជតិ(១) ។ យំបិ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា មជ្ជតិ មុច្ឆតិ មទមាបជ្ជតិ(២) អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន លាភសក្ការសិលោកេន អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ ។ យំបិ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន លាភសក្ការសិលោកេន អត្តមនោ ហោតិ បរិបុណ្ណសង្កប្បោ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន លាភសក្ការសិលោកេន អត្តានុក្កំសេតិ បរំ វម្ភេតិ ។

---

១-២ ឱ. ម. បមាទមាបជ្ជតិ ។

មនុស្សអ្នកមានតបវត្ត សមាទាននូវតបវត្ត គេស្រវឹង ជ្រប់ ដល់នូវសេចក្តីស្រវឹង ព្រោះតបវត្តនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលមនុស្សអ្នកមានតបវត្ត សមាទាននូវតបវត្ត គេស្រវឹង ជ្រប់ ដល់នូវសេចក្តីស្រវឹង ព្រោះតបវត្តនោះ ម្នាលនិគ្រោធ នេះក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការៈនឹងសេចក្តីសរសើរ គេពេញចិត្ត ទាំងមានសេចក្តីត្រិះរិះអស់ហើយត្រឹមលាភសក្ការៈនឹងសេចក្តីសរសើរនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទាននូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការៈនឹងសេចក្តីសរសើរ គេពេញចិត្ត ទាំងមានសេចក្តីត្រិះរិះអស់ហើយត្រឹមលាភសក្ការៈនឹងសេចក្តីសរសើរនោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការៈនឹងសេចក្តីសរសើរ គេលើកខ្លួនឯង បង្អាប់អ្នកដទៃ ព្រោះតែលាភសក្ការៈនឹងសេចក្តីសរសើរនោះ ។

យម្បិ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន លាភសក្ការសិលោកេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន លាភសក្ការសិលោកេន មជ្ជតិ មុច្ឆតិ បមាទមាបជ្ជតិ ។ យម្បិ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន លាភសក្ការសិលោកេន មជ្ជតិ មុច្ឆតិ បមាទមាបជ្ជតិ អយម្បិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ ភោជនេសុ វោទាសំ អាបជ្ជតិ ឥទំ មេ ខមតិ ឥទំ មេ ន ខមតីតិ ។ សោ យញ្ច ខ្វាស្ស[១] ន ខមតិ តំ សាបេក្ខោ បជហតិ យំ បនស្ស ខមតិ តំ គធិតោ មុច្ឆិតោ អជ្ឈោបន្នោ អនាទីនវទស្សាវី អនិស្សរណប្បញ្ញោ

---

១ ឱ. យំ ហិ ខោស្ស ។

ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទាននូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភលក្ការៈនឹងសេចក្តីសរសើរ គេក៏លើកខ្លួនឯងតែងបង្អាប់អ្នកដទៃ ព្រោះតែលាភសក្ការៈនោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត គេយកតបវត្តនោះជាគ្រឿងឲ្យកើតលាភសក្ការៈនឹងសេចក្តីសរសើរនោះ គេក៏ស្រវឹងភ្លេចខ្លួន ដល់នូវសេចក្តីវង្វេង ព្រោះតែលាភសក្ការៈនឹងសេចក្តីសរសើរនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទាននូវតបវត្ត គេយកតបវត្តនោះ ជាគ្រឿងឲ្យកើតលាភសក្ការៈនឹងសេចក្តីសរសើរ គេក៏ស្រវឹងភ្លេចខ្លួន ដល់នូវសេចក្តីវង្វេង ព្រោះតែលាភសក្ការៈនឹងសេចក្តីសរសើរនោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់មនុស្សអ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត ចែកភោជនជាពីរចំណែកថា ភោជននេះគាប់ចិត្តខ្ញុំ ភោជននេះមិនគាប់ចិត្តខ្ញុំទេ ។ តាបសដែលប្រកបដោយសេចក្តីចង់នោះ មិនគាប់ចិត្តភោជនណា រមែងលះបោលភោជននោះ ចំណែកភោជនណាគាប់ចិត្តគេ ៗ ក៏ត្រេកត្រអាលភ្លេចស្មារតី ជាប់ស្អិតនឹងភោជននោះ ជាបុគ្គលឥតឃើញទោស ឥតមានប្រាជ្ញាជាគ្រឿងរលាស់ចិត្តចេញ

បរិកុញ្ជតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ លាភសក្ការសិលោកនិកន្តិហេតុ សក្ការិស្សន្តិ មំ រាជានោ រាជមហាមត្តា ខត្តិយា ព្រាហ្មណា គហបតិកា តិត្ថិយាតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី អញ្ញតរំ សមណំ វា ព្រាហ្មណំ វា កុតោ(១) អប្បសាទេតា(២) ហោតិ កិំ បនាយំ សម្ពហុលាជីវោ សព្វំ សំភក្ខេតិ(៣) សេយ្យថីទំ មូលពីជំ ខន្ធពីជំ ផលុពីជំ អគ្គពីជំ ពីជពីជមេវ បញ្ចមំ អសនិវិចក្កំ ទន្តកូដំ សមណប្បវាទេនាតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី បស្សតិ អញ្ញតរំ សមណំ វា ព្រាហ្មណំ វា កុលេសុ សក្ករិយមានំ គរុការិយមានំ មានិយមានំ បូជិយមានំ ។

---

១ ឱ. ម. កុតោតិ នត្ថិ ។ ២ ម. អបសាទេតា ។ ៣ ឱ. ពហុលាជីវោ សព្វំ សម្ភក្ខេតិ ។

បេះតែបរិភោគ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្តសមាទាននូវតបវត្ត ដោយហេតុប្រាថ្នាលាភសក្ការៈនិងសេចក្តីសរសើរថា ពួកព្រះរាជា រាជមហាមាត្រ ក្សត្រ ព្រាហ្មណ៍ គហបតី តិរ្ថិយ នឹងធ្វើសក្ការៈចំពោះយើង ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ពោលបង្អាប់សមណព្រាហ្មណ៍ណាមួយថា បែបនេះឬសមណព្រាហ្មណ៍ ជាអ្នកមានការចិញ្ចឹមជីវិតច្រើនយ៉ាង តែងស៊ីពូជឈើសព្វសរពើ គឺពូជកើតអំពីឫស ពូជកើតអំពីដើម ពូជកើតអំពីថ្នាំង ពូជកើតអំពីចុង ពូជកើតអំពីពូជផងគ្នាជាគំរប់ ៥ នរណា ៗ ក៏ដឹងថា ញញួរគឺធ្មេញរបស់សមណៈនេះ ដូចជាកាំរន្ទះ អ្នកនេះជាសមណៈត្រឹមតែការប្តេជ្ញាថាសមណៈប៉ុណ្ណោះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ឃើញសមណព្រាហ្មណ៍ណាមួយ ដែលមានគេកំពុងធ្វើសក្ការៈ គោរព រាប់អាន បូជា ក្នុងត្រកូលទាំងឡាយ ៗ

តស្ស(១) ឯវំ ហោតិ ឥមម្ហិ នាម(២) សត្តហុលាជីវំ កុលេសុ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ មំ បន តបស្សឹ លូខាជីវឹ កុលេសុ ន សក្ករោន្តិ ន គរុករោន្តិ ន មានេន្តិ ន បូជេន្តីតិ ។ ឥតិ សោ ឥស្សាមច្ឆរិយំ កុលេសុ ឧប្បាទេតា ហោតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី អាបាថកនិសាទី ហោតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី អត្តានំ អទស្សយមានោ កុលេសុ ចរតិ ឥទំបិ មេ តបស្មឹ ឥទំបិ មេ តបស្មិន្តិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ

---

១ ឱ. ទិស្វា តស្ស ។ ២ ឥមស្មឹ នាមាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

អ្នកនោះតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា មនុស្សទាំងឡាយគេធ្វើសក្ការៈ គោរព រាប់អាន បូជាសមណៈ ដែលមានការបិញ្ចឹមជីវិតច្រើនមុខនេះ ក្នុងត្រកូលទាំងឡាយ ប្រយោជន៍អ្វី ពួកគេម្តេចក៏មិនធ្វើសក្ការៈ គោរព រាប់អាន បូជា អាត្មាអញ ដែលមានតបវត្ត ជាអ្នកមានការបិញ្ចឹមជីវិតសៅហ្មង ក្នុងត្រកូលទាំងឡាយវិញ ៗ អ្នកនោះ រមែងកើតសេចក្តីឫស្យា កំណាញ់ក្នុងត្រកូលទាំងឡាយ ដោយប្រការយ៉ាងនេះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់មនុស្សអ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត រមែងអង្គុយក្នុងទីចំភ្នែកមនុស្សមើលឃើញ(១) ម្នាលនិគ្រោធ នេះឯង ក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ដើរបង្ហាញខ្លួន ដើរទៅក្នុងត្រកូលទាំងឡាយ(២) ដោយគិតថា ការនេះជាតបវត្ត របស់អាត្មា ការនេះជាតបវត្តរបស់អាត្មា ម្នាលនិគ្រោធ នេះឯង ក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត

---

១ សំដៅយកការរំទំ ឬធ្វើកិច្ចវត្តផ្សេង ៗ បានតែក្នុងទីចំពោះមុខគេ ឲ្យគេស្ញើច ។ ២ សំដៅយកពុតត្បុតរបស់មនុស្សដែលដើរអួតអាង បើមានគេសរសើរពីកិច្ចវត្តណា ឬពីអ្នកណា ក៏លើកដាក់ខ្លួនថា ការនោះជាស្នាដៃខ្លួន ឬថាជាសិស្សខ្លួនជាដើម ។

## ឧទុម្ពរិកសុត្តេ តបោជិគុច្ឆាយ ឧបក្កិលេសកថា

តបស្សី កិញ្ចិនេវ(១) បដិច្ឆន្នំ សេវតិ សោ ខមតិ តេ ឥទន្តិ បុដ្ឋោ សមានោ អក្ខមមានំ អាហ ខមតីតិ ខមមានំ អាហ ន ខមតីតិ ។ ឥតិ សោ សម្បជានមុសា ភាសិតា ហោតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តថាគតស្ស វា តថាគតសាវកស្ស វា ធម្មំ ទេសេន្តស្ស សន្តំយេវ បរិយាយំ អនុញ្ញេយ្យំ នានុជានាតិ អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី កោធនោ ហោតិ ឧបនាហី ។ យំបិ និគ្រោធ តបស្សី កោធនោ ហោតិ ឧបនាហី អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី មក្ខី ហោតិ បឡាសី ឥស្សុកី ហោតិ មច្ឆរី សឋោ ហោតិ មាយាវី ថទ្ធោ ហោតិ អតិមានី បាបិច្ឆោ ហោតិ បាបិកានំ ឥច្ឆានំ វសង្គតោ មិច្ឆាទិដ្ឋិកោ ហោតិ អន្តគ្គាហិកាយ ទិដ្ឋិយា សមន្នាគតោ

---

១ ម. យំ កិញ្ចិទេវ ។

ឧទុម្ពរិកសូត្រ ពោលអំពីឧបក្កិលេសនៃការខ្ពើមបាបដោយព្យាយាមជាគ្រឿងដុតកិលេស

អ្នកមានតបវត្ត អាស្រ័យល្បិចបិទបាំងនីមួយ គឺបើមានគេសួរអ្នកនោះថា លោកគាប់ចិត្តការនេះឬ បើទុកជាការនោះខ្លួនមិនគាប់ចិត្តទេ ក៏និយាយថា គាប់ចិត្ត បើការនោះខ្លួនគាប់ចិត្ត ក៏និយាយថា មិនគាប់ចិត្តវិញ ។ អ្នកនោះឈ្មោះថា និយាយកុហកទាំងដឹងខ្លួន ដោយសំដីបែបនេះ ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត កាលបើព្រះតថាគត ឬសាវ័ករបស់ព្រះតថាគត កំពុងសំដែងធម៌ រមែងមិនអនុមោទនា នូវបរិយាយដែលខ្លួនគួរអនុមោទនា ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ជាអ្នកមានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុកណា ម្នាលនិគ្រោធ នេះឯងក៏ជាឧបក្កិលេស របស់អ្នកបានតបវត្តដែរ ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ជាអ្នករមិលគុណ រាយឫកស្មើ ឈ្នានីស កំណាញ់ អួតអាង មានកលមាយា រឹងត្អឹង មើលងាយគេ មានសេចក្តីប្រាថ្នាលាមក ទាំងលុះអំណាចនៃសេចក្តីប្រាថ្នាដ៏លាមក ជាមនុស្សមិច្ឆាទិដ្ឋិ ប្រកបដោយអន្តគ្គាហិកទិដ្ឋិ(១)

១ មិច្ឆាទិដ្ឋិដែលស្ទុះផល់ទីបំផុតលែងរើ គឺប្រកាន់មាំក្នុងទិដ្ឋិទាំង ១០ នោះ ណាមួយ មានប្រកាន់ថា លោកទៀង លោកមិនទៀងជាដើម ។ សារត្ថទីបនី ដីកាវិន័យ ។

សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី យំបិ ខោ និគ្រោធ តបស្សី សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី អយំបិ ខោ និគ្រោធ តបស្សិនោ ឧបក្កិលេសោ ហោតិ ។ តំ កឹ មញ្ញសិ និគ្រោធ យទិមេ តបោជិគុច្ឆា ឧបក្កិលេសា វា អនុបក្កិលេសា វាតិ ។ អទ្ធា ខោ ឥមេ ភន្តេ តបោជិគុច្ឆា ឧបក្កិលេសា នោ អនុបក្កិលេសា ឋានំ ខោ បនេតំ ភន្តេ វិជ្ជតិ យំ ឥធេកច្ចោ តបស្សី សព្វេហេវ ឥមេហិ ឧបក្កិលេសេហិ សមន្នាគតោ អស្ស កោ បន វាទោ អញ្ញតរញ្ញតរេនាតិ ។

(២៥) ឥធ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា ន អត្តមនោ ហោតិ ន បរិបុណ្ណសង្កប្បោ ។ យំបិ និគ្រោធ តបស្សី តបំ សមាទិយតិ

អ្នកប្រកាន់យកតែសេចក្តីឃើញរបស់ខ្លួន ប្រកាន់មាំ ជាបុគ្គលដែលគេមិនអាចឲ្យលះបង់បានដោយងាយ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ជាអ្នកប្រកាន់យកតែសេចក្តីឃើញរបស់ខ្លួន ប្រកាន់មាំ ជាបុគ្គលដែលគេឲ្យលះបង់បានដោយក្រ ម្នាលនិគ្រោធ នេះឯង ក៏ជាឧបក្កិលេសរបស់អ្នកមានតបវត្តដែរ ។ ម្នាលនិគ្រោធ អ្នកសំគាល់សេចក្តីនោះដូចម្តេច បើការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសទាំងនេះជាឧបក្កិលេស ឬមិនមែនជាឧបក្កិលេសទេ ។ និគ្រោធបរិព្វាជកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសទាំងនេះ ជាឧបក្កិលេសពិត ៗ មិនមែនជាអនុបក្កិលេសទេ បពិត្រព្រះអង្គដ៏ចម្រើន អ្នកមានតបវត្តពួកខ្លះក្នុងលោកនេះ ជាអ្នកប្រកបដោយឧបក្កិលេស ទាំងអស់នេះទៅហើយ ចាំបាច់ពោលទៅថ្វី ដោយឧបក្កិលេសឯទៀត ៗ ។

(២៥) ម្នាលនិគ្រោធ អ្នកមានតបវត្តក្នុងលោកនេះ សមាទាននូវតបវត្ត គេមិនមែនពេញចិត្ត ទាំងមានសេចក្តីត្រិះរិះមិនមែនអស់ហើយត្រឹមតបវត្តនោះ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត សមាទាននូវតបវត្តណា

## ឧទុម្ពរិកសុត្តេ តបោជិគុច្ឆាយ បរិសុទ្ធិកថា

សោ តេន តបសា ន អត្តមនោ ហោតិ ន
បរិបុណ្ណសង្កប្បោ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ
ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ
សមាទិយតិ សោ តេន តបសា ន អត្តានុក្កំ-
សេតិ ន បរំ វម្ភេតិ ។ បេ ។ ឯវំ សោ តស្មឹ
ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ
តបស្សី តបំ សមាទិយតិ សោ តេន តបសា ន
មជ្ជតិ ន មុច្ចតិ ន មទមាបជ្ជតិ ។ បេ ។ ឯវំ សោ
តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ
តបស្សី តបំ សមាទិយតិ សោ តេន តបសា
លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន
លាភសក្ការសិលោកេន ន អត្តមនោ ហោតិ ន
បរិបុណ្ណសង្កប្បោ ។ យម្បិ និគ្រោធ តបស្សី ។ បេ ។
ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន
ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ សោ
តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ

គេមិនមែនពេញចិត្ត ទាំងមានសេចក្តីត្រិះរិះ មិនមែនអស់ហើយត្រឹមតបវត្តនោះ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ៗ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត គេមិនលើកខ្លួនឯង មិនកំហែងអ្នកដទៃ ព្រោះតបវត្តនោះ ៗ បេ ៗ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ៗ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត គេមិនស្រវឹង មិនឈ្លក់គំនិត មិនដល់នូវសេចក្តីស្រវឹង ព្រោះតែតបវត្តនោះទេ ៗ បេ ៗ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ៗ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត គេញុំាងលាភសក្ការៈនឹងសេចក្តីសរសើរ ឲ្យកើតឡើង ព្រោះតបវត្តនោះ តែគេមិនពេញចិត្ត មិនមានសេចក្តីត្រិះរិះ អស់ហើយត្រឹមលាភសក្ការៈនឹងសេចក្តីសរសើរនោះទេ ៗ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ៗបេៗ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ៗ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត គេញុំាងលាភសក្ការៈនឹងសេចក្តីសរសើរ ឲ្យកើតឡើង គេមិន

សោ តេន លាភសក្ការសិលោកេន ន អត្តានុក្កំសេតិ ន បរំ វម្ភេតិ ។ យម្បិ និគ្រោធ តបស្សី ។ បេ ។ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ សោ តេន តបសា លាភសក្ការសិលោកំ អភិនិព្វត្តេតិ សោ តេន លាភសក្ការសិលោកេន ន មជ្ជតិ ន មុច្ឆតិ ន មទមាបជ្ជតិ ។ យម្បិ និគ្រោធ តបស្សី ។ បេ ។ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តបំ សមាទិយតិ ភោជនេសុ ន វោទានំ អាបជ្ជតិ ឥទំ មេ ខមតិ ឥទំ មេ ន ខមតីតិ ។ សោ យញ្ច ខ្វាស្ស[១] ន ខមតិ តំ អនបេក្ខោ បជហាតិ យំ បនស្ស ខមតិ តំ អគធិតោ អមុច្ឆិតោ អនជ្ឈាបន្នោ អាទីនវទស្សាវី និស្សរណបញ្ញោ បរិភុញ្ជតិ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ

១ ឱ. យំ ហិ ខោស្ស ។

លើកខ្លួន មិនបង្អាប់អ្នកដទៃ ព្រោះតែលាភសក្ការ នឹងសេចក្តីសរសើរ នោះទេ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ។ បេ ។ គេឈ្មោះ ថា បរិសុទ្ធកង់ហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខ នៅមានទៀត អ្នកមានតបវត្ត សមាទាននូវតបវត្ត គេញុំាងលាភសក្ការៈ នឹងសេចក្តីសរសើរ ឲ្យកើតឡើង ដោយតបវត្តនោះ តែគេមិនស្រវឹង មិន ឈ្លក់គំនិត មិនដល់នូវសេចក្តីស្រវឹង ព្រោះតែលាភសក្ការៈនឹងសេចក្តី សរសើរនោះទេ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ។ បេ ។ គេ ឈ្មោះថា បរិសុទ្ធកង់ហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យ ខាងមុខនៅមានទៀត អ្នកមានតបវត្ត សមាទានតបវត្ត មិនចែកភោជន ជាពីរចំណែកថា ភោជននេះគាប់ចិត្តខ្ញុំ ភោជននេះមិនគាប់ចិត្តខ្ញុំទេ ។ គេជាមនុស្សគ្មានប្រាថ្នាភោជនណា មិនគាប់ចិត្តគេ ៗ ក៏លះបង់ភោជន នោះដែរ តែថា ភោជនណាគាប់ចិត្តគេៗ មិនត្រេកត្រអាល មិនភ្លេច ស្មារតីមិនជាប់ស្អិត ជាអ្នកឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿង រលាស់ចិត្តចេញ បរិភោគភោជននោះ គេឈ្មោះថា បរិសុទ្ធកង់ ហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត

ឧទុម្ពរិកសុត្តេ តបោជិគុច្ឆាយ បរិសុទ្ធិកថា

តបស្សី តបំ សមាទិយតិ ន សោ(១) លាភសក្ការសិលោកាភិកត្តិហេតុ សក្ការិស្សន្តិ មំ រាជានោ រាជមហាមត្តា ខត្តិយា ព្រាហ្មណា គហបតិកា តិត្ថិយាតិ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី អញ្ញតរំ សមណំ វា ព្រាហ្មណំ វា ន អបសាទេតា ហោតិ កឹ បនាយំ សម្ពហុលាជីវោ សព្វសព្វំ សំភក្ខេតិ សេយ្យថីទំ មូលពីជំ ខន្ធពីជំ ផលុពីជំ អគ្គពីជំ ពីជពីជមេវ បញ្ចមំ អសនិវិចក្កំ ទន្តកូដំ សមណប្បវាទេនាតិ(២) ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី បស្សតិ អញ្ញតរំ សមណំ វា ព្រាហ្មណំ វា កុលេសុ សក្ការិយមានំ គរុការិយមានំ មានិយមានំ បូជិយមានំ ។ តស្ស ន ឯវំ ហោតិ ឥមំ ហិ នាម សម្ពហុលាជីវំ កុលេសុ សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ មំ បន តបស្សឹ លូខាជីវឹ កុលេសុ ន សក្ករោន្តិ ន គរុករោន្តិ ន មានេន្តិ ន បូជេន្តីតិ ។

---

១ ន សោ តេនាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ សមណស្ស វាទេនាតិ កត្ថចិ បោត្ថកេ ទិសតិ ។

អ្នកមានតបវត្ត គេមិនសមាទានតបវត្តហេតុតែសេចក្តីប្រាថ្នាលាភសក្ការៈ នឹងសេចក្តីសរសើរថា ពួកព្រះរាជា រាជមហាមាត្រ ក្សត្រិយ៍ ព្រាហ្មណ៍ គហបតី តិរ្ថិយ នឹងធ្វើសក្ការៈ ចំពោះអាត្មាអញ អ្នកនោះឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ៗ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត មិនបានពោលបង្អាប់សមណៈឬព្រាហ្មណ៍ណាមួយ ថា បែបនេះ ឬសមណព្រាហ្មណ៍ ជាអ្នកមានការចិញ្ចឹមជីវិតច្រើនយ៉ាង តែងស៊ីពូជសព្វសរពើ គឺពូជកើតអំពីឫស ពូជកើតអំពីដើម ពូជកើតអំពីថ្នាំង ពូជកើតអំពីចុង ពូជកើតអំពីពូជជាគំរប់ ៥ នរណា ៗ ក៏ដឹងថា ញញួរគឺធ្មេញរបស់សមណៈនេះ ដូចជាកាំរន្ទះ គេជាសមណៈត្រឹមតែការប្តេជ្ញាថា សមណៈប៉ុណ្ណោះទេ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ៗ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ឃើញគេធ្វើសក្ការៈ គោរព រាប់អាន បូជាសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងត្រកូលទាំងឡាយ ៗ គេមិនបានត្រិះរិះយ៉ាងនេះថា គួរដែរឬ ពួកមនុស្សតែងធ្វើសក្ការៈ គោរព រាប់អាន បូជាសមណៈដែលមានអាជីវៈច្រើន ក្នុងត្រកូលទាំងឡាយនេះ ចំណែកខាងអាត្មាអញ ជាអ្នកមានតបវត្ត មានអាជីវៈសៅហ្មង (ម្តេចក៏) ពួកគេមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជា ក្នុងត្រកូលទាំងឡាយវិញ ៗ

ឥតិ សោ ឥស្សាមច្ឆរិយំ កុលេសុ នុប្បាទេតា ហោតិ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី ន អាចាមកាំសាទី ហោតិ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី ន អត្តានំ ឧស្សយមានោ កុលេសុ ចរតិ ឥទំបិ មេ តបស្មឹ ឥទំបិ មេ តបស្មិន្តិ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី ន កិញ្ចិទេវ បដិច្ឆន្នំ សេវតិ សោ ខមតិ តេ ឥទន្តិ បុដ្ឋោ សមានោ អក្ខមមានំ អាហ ន ខមតីតិ ខមមានំ អាហ ខមតីតិ ។ ឥតិ សោ សម្បជានមុសា ន ភាសិតា ហោតិ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី តថាគតស្ស វា តថាគតសាវកស្ស វា ធម្មំ ទេសេន្តស្ស សន្តិយេ បរិយាយំ អនុញ្ញេយ្យំ អនុជានាតិ ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។

គេមិនឲ្យកើតសេចក្តីឫស្យា ទាំងសេចក្តីកំណាញ់ ក្នុងត្រកូលទាំងឡាយដូច្នេះឡើយ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះយ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខទៅមានទៀត អ្នកមានតបវត្ត មិនជាអ្នកអង្គុយក្នុងទីចំក្នែកមនុស្ស គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខទៅមានទៀត អ្នកមានតបវត្ត មិនដើរបង្ហាញខ្លួន ក្នុងត្រកូលទាំងឡាយថា ការនេះជាតបវត្តរបស់អាត្មាដែរ ការនេះជាតបវត្តរបស់អាត្មាដែរ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខទៅមានទៀត អ្នកមានតបវត្ត មិនអាស្រ័យការបិទបាំងនីមួយ បើមានគេសួរអ្នកនោះថា ការនេះគាប់ចិត្តលោកឬ បើការនោះមិនគាប់ចិត្តខ្លួនក៏និយាយថា មិនគាប់ចិត្ត របស់នេះគួរដល់អ្នកឬ ប្រាប់នូវរបស់ ដែលមិនគួរថា មិនគួរ បើការនោះខ្លួនគាប់ចិត្ត ក៏និយាយថា គាប់ចិត្ត ។ អ្នកនោះមិនបាននិយាយកុហកទាំងដឹងខ្លួន គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខទៅមានទៀត អ្នកមានតបវត្ត កាលតថាគតឬសាវ័ករបស់តថាគត កំពុងសំដែងធម៌ រមែងអនុមោទនានូវបរិយាយដែលគួរអនុមោទនា គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។

បុន ចបរំ និគ្រោធ តបស្សី អក្កោធនោ ហោតិ អនុបនាហី ។ យំបិ និគ្រោធ តបស្សី អក្កោធនោ ហោតិ អនុបនាហី ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ បុន ចបរំ និគ្រោធ តបស្សី អមក្ខី ហោតិ អបឡាសី អនិស្សុកី ហោតិ អមច្ឆរី អសឋោ ហោតិ អមាយាវី អថទ្ធោ ហោតិ អនតិមានី ន បាបិច្ឆោ ហោតិ ន បាបិកានំ ឥច្ឆានំ វសង្គតោ ន មិច្ឆាទិដ្ឋិកោ ហោតិ ន អន្តគ្គាហិកាយ(១) ទិដ្ឋិយា សមន្នាគតោ ន សន្ទិដ្ឋិបរាមាសី(២) ហោតិ ន អាធានគ្គាហី(៣) សុប្បដិនិស្សគ្គី ។ យំបិ និគ្រោធ តបស្សី ន សន្ទិដ្ឋិបរាមាសី ហោតិ ន អាធានគ្គាហី សុប្បដិនិស្សគ្គី ឯវំ សោ តស្មឹ ឋានេ បរិសុទ្ធោ ហោតិ ។ តំ កឹ មញ្ញសិ និគ្រោធ យទិ ឯវំ សន្តេ តបោជិគុច្ឆា

---

១ ឱ. អនន្តគ្គាហិកាយ ។ ២ ឱ. អសន្ទិដ្ឋិបរាមាសី ។ ៣ ឱ. អនាធានគ្គាហី ។

## ឧទុម្ពរិកសូត្រ ពោលអំពីសេចក្ដីបរិសុទ្ធិនៃតបោជិគុច្ឆភាព

ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ជាអ្នកមិនក្រោធ មិនចងសេចក្ដីក្រោធទុក ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ជាអ្នកមិនក្រោធ មិនចងសេចក្ដីក្រោធទុក គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះយ៉ាងនេះបាន ។ ម្នាលនិគ្រោធ ពាក្យខាងមុខនៅមានទៀត អ្នកមានតបវត្ត ជាអ្នកមិនរមិលគុណ មិនវាយឫកស្មើ មិនឈ្នា-នីស មិនកំណាញ់ មិនអួតអាង មិនមានកលមាយា មិនរឹងត្អឹង មិនមើលងាយគេ មិនមានសេចក្ដីប្រាថ្នាដ៏លាមក មិនលុះក្នុងអំណាចនៃសេចក្ដីប្រាថ្នាដ៏លាមក មិនមែនជាមិច្ឆាទិដ្ឋិ មិនប្រកបដោយអន្តគា-ហិកទិដ្ឋិ មិនប្រកាន់យកតាមតែសេចក្ដីឃើញរបស់ខ្លួន មិនប្រកាន់មាំ ជាមនុស្សដែលគេឲ្យលះបង់បានដោយងាយ ។ ម្នាលនិគ្រោធ ត្រង់ដែលអ្នកមានតបវត្ត ជាអ្នកមិនប្រកាន់យកតាមតែសេចក្ដីឃើញរបស់ខ្លួន មិនប្រកាន់មាំ ជាមនុស្សដែលគេឲ្យលះបង់បានដោយងាយ គេឈ្មោះថា បរិសុទ្ធក្នុងហេតុនោះ យ៉ាងនេះបាន ។ ព្រះមានបុណ្យត្រាស់សួរថា ម្នាលនិគ្រោធ អ្នកសំគាល់សេចក្ដីនោះដូចម្ដេច កាលបើហេតុមានមកដូច្នេះ ការខ្ពើមបាប ដោយសេចក្ដីព្យាយាម ជាគ្រឿងដុតកិលេស

បរិសុទ្ធា វា[១] ហោតិ អបរិសុទ្ធា វាតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តបោជិគុច្ឆា បរិសុទ្ធា ហោតិ នោ អបរិសុទ្ធា អគ្គប្បត្តា ច ហោតិ[២] សារប្បត្តា ចាតិ ។ ន ខោ និគ្រោធ ឯត្តាវតា តបោជិគុច្ឆា អគ្គប្បត្តា សារប្បត្តា ហោតិ[៣] អបិច ខោ បបដិកប្បត្តា ច[៤] ហោតីតិ ។

(២៦) កិត្តាវតា បន ភន្តេ តបោជិគុច្ឆា អគ្គប្បត្តា សារប្បត្តា ច ហោតិ សាធុ មេ ភន្តេ ភគវា តបោជិគុច្ឆាយ អគ្គំយេវ បាបេតុ សារំយេវ បាបេតូតិ ។ ឥធ និគ្រោធ តបស្សី ចាតុយាម-សំវរសំវុតោ ហោតិ ។ កថញ្ច និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ ។ ឥធ និគ្រោធ

១ ឱ. វាសទ្ទោ ន ទិស្សតិ ។ ២ ឱ. ម. ហោតីតិ ន ទិស្សតិ ។ ៣ ឱ. អគ្គប្បត្តា វា ហោតិ សារប្បត្តា វា ។ ៤ ឱ. បបដិកប្បត្តា ហោតិ ។

ឈ្មោះថា បរិសុទ្ធហើយ ឬមិនទាន់បរិសុទ្ធទេ ។ និគ្រោធបរិព្វាជក ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុមានមកដូច្នេះ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធហើយដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ហើយផង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ត្រឹមតែប៉ុណ្ណោះ មិនទាន់ដល់កំពូលធម៌ មិនទាន់ដល់ខ្លឹមធម៌នៅឡើយទេ គ្រាន់តែដល់ត្រឹមធម៌ ដូចជាក្រមរប៉ុណ្ណោះទេតើ ។

(២៦) និគ្រោធបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ចុះការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសត្រឹមណា ទើបឈ្មោះថា ដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ផង បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានបុណ្យសំដែងឲ្យដល់កំពូល ឲ្យដល់ខ្លឹមសារ របស់ការខ្ពើមបាបដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសតែម្តងដល់ខ្ញុំព្រះអង្គឲ្យទាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកមានតបវត្តក្នុងលោកនេះ ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាង ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាងតើដូចម្តេច ។ ម្នាលនិគ្រោធ អ្នក

តបស្សី ន បាណំ អតិបាតេតិ(១) ន បាណំ អតិបាតយតិ ន បាណំ អតិបាតយតោ សមនុញ្ញោ ហោតិ ន អទិន្នំ អាទិយតិ ន អទិន្នំ អាទិយាបេតិ ន អទិន្នំ អាទិយតោ សមនុញ្ញោ ហោតិ ន មុសា ភណតិ ន មុសា ភណាបេតិ ន មុសា ភណតោ សមនុញ្ញោ ហោតិ ន ភាវិតមាសីសតិ ន ភាវិតមាសីសាបេតិ ន ភាវិតមាសីសតោ សមនុញ្ញោ ហោតិ ។ ឯវំ(២) និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ ។ យតោ(៣) និគ្រោធ តបស្សី(៤) ចាតុយាមសំវរសំវុតោ ហោតិ អទុញ្ចស្ស ហោតិ តបស្សិតាយ ។ សោ អភិហរតិ នោ ហីនាយាវត្តតិ ។ សោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ(៥) ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ

---

១ អតិបាបេតីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. ឯវំ ខោ ។ ៣ ឱ. ម. យតោ ខោ ។ ៤ ឱ. តបស្សី ឯវំ ។ ៥ ឱ. ម. បលាលបុញ្ជំ ។

មានតបវត្តកក្នុងលោកនេះ មិនសម្លាប់សត្វ មិនប្រើអ្នកដទៃឲ្យសម្លាប់សត្វ មិនគាប់ចិត្តនឹងអ្នកសម្លាប់សត្វ មិនកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ មិនប្រើអ្នកដទៃឲ្យកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ មិនគាប់ចិត្តនឹងអ្នកកាន់យកទ្រព្យ ដែលម្ចាស់គេមិនបានឲ្យ រមែងមិននិយាយកុហក មិនប្រើអ្នកដទៃឲ្យនិយាយកុហក មិនគាប់ចិត្តនឹងអ្នកនិយាយកុហក មិនសេពភាវិតធម៌ (គឺកាមគុណ៥) មិនប្រើអ្នកដទៃឲ្យសេពនូវភាវិតធម៌ មិនគាប់ចិត្តនឹងអ្នកដែលសេពនូវភាវិតធម៌ ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាង ដោយហេតុយ៉ាងនេះ ។ ម្នាលនិគ្រោធ កាលណាអ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួមទាំង ៤ យ៉ាង ក៏រមែងមានពាក្យគេសរសើរអ្នកនោះ ព្រោះខ្លួនជាអ្នកមានតបវត្ត ។ គេខំប្រឹងបំពេញ (សីល) មិនត្រឡប់មកដើម្បីភេទថោកទាប (ភេទគ្រហស្ថ)។ គេរមែងអាស្រ័យសេនាសនៈស្ងាត់ ព្រៃ គល់ឈើ ភ្នំ ញកភ្នំ ជ្រោះភ្នំ ទីស្មសាន ដងព្រៃ ទីវាល នឹងទីដែលប្រក់បាំងដោយស្មៅ ។ បុគ្គលនោះ លុះកាលខាងក្រោយភត្ត ក៏ត្រឡប់មកពីបិណ្ឌបាតហើយ

និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ(១) សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទបទោសំ(២) បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទបទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ

---

១ ឱ. ម. បរិមុខំ ។ ២ ឱ. ព្យាបាទបទោសំ ។

អង្គុយពែនភ្នែនតម្រង់កាយឲ្យត្រង់ ប្រុងស្មារតីឲ្យមានមុខពោះ (ទៅរកកម្មដ្ឋាន) ។ គេលះអភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះព្យាបាទជាគ្រឿងប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះសត្វទាំងពួង ដោយប្រយោជន៍ ជម្រះចិត្តឲ្យស្អាតចាកព្យាបាទជាគ្រឿងប្រទូស្ត លះថីនមិទ្ធៈ មានចិត្តប្រាសចាកថីនមិទ្ធៈ មានសេចក្តីសំគាល់ក្នុងពន្លឺ មានសតិ មានសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ លះឧទ្ធច្ចកុក្កុច្ចៈ មានចិត្តមិនរវើរវាយ មានចិត្តខាងក្នុងស្ងប់រម្ងាប់ ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះវិចិកិច្ឆា មានចិត្តឆ្លងផុតចាកវិចិកិច្ឆា មិនមានសេចក្តីងឿងឆ្ងល់ ជម្រះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ក្នុងកុសលធម៌ទាំងឡាយ ។ គេលះនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេស ជាគ្រឿងធ្វើបញ្ញាឲ្យថយ

មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ ករុណាសហគតេន ចេតសា ។ មុទិតាសហគតេន ចេតសា ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ តំ កឹ មញ្ញសិ និគ្រោធ យទិ ឯវំ សន្តេ តបោជិគុច្ឆា បរិសុទ្ធា វា ហោតិ អបរិសុទ្ធា វាតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តបោជិគុច្ឆា

កំឡាំង ក៏សម្រេចសម្រាន្តឥរិយាបថ ដោយការផ្សាយចិត្តប្រកបដោយមេត្តា ទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូច្នោះ ទិសទី៣ ក៏ដូច្នោះ ទិសទី ៤ ក៏ដូច្នោះ សម្រេចសម្រាន្តឥរិយាបថ ដោយការផ្សាយចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វលោកទាំងមូល ដោយយកខ្លួនទៅប្រៀប នឹងសត្វទាំងអស់ ក្នុងទិសទាំងពួង គឺទិសខាងលើ ទិសខាងក្រោម នឹងទិសទទឹង(១)ដោយប្រការដូច្នេះ ៗ ចិត្តប្រកបដោយករុណា ៗ ចិត្តប្រកបដោយមុទិតា ៗ សម្រេចសម្រាន្តឥរិយាបថ ដោយការផ្សាយចិត្ត ប្រកបដោយឧបេក្ខា ទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូច្នោះ ទិសទី ៣ ក៏ដូច្នោះ ទិសទី ៤ ក៏ដូច្នោះ សម្រេចសម្រាន្តឥរិយាបថ ដោយការផ្សាយចិត្ត ប្រកបដោយឧបេក្ខាដ៏ធំទូលាយ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ទៅកាន់សត្វ-លោកទាំងមូល ដោយយកខ្លួនទៅប្រៀប នឹងសត្វទាំងអស់ ក្នុងទិសទាំងពួង គឺទិសខាងលើ ទិសខាងក្រោម នឹងទិសទទឹង ៗ ម្នាលនិគ្រោធ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើហេតុមានមកដូច្នេះ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធហើយ ឬមិនទាន់បរិសុទ្ធទេ ៗ និគ្រោធបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលបើដូច្នេះ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុត

---

១ សំដៅយកទិសតូច ៗ គឺទិសអគ្នេយ៍ និរតី ពាយព្យ ឦសាណ ។

បរិសុទ្ធា ហោតិ នោ អបរិសុទ្ធា អគ្គបញ្ញត្តា ច ហោតិ(១) សារបញ្ញត្តា ចាតិ ។ ន ខោ និគ្រោធ ឯត្តាវតា តបោជិគុច្ឆា អគ្គបញ្ញត្តា វា ហោតិ សារបញ្ញត្តា វា អបិច ខោ តចប្បត្តា ហោតីតិ ។

(២៧) កិត្តាវតា បន ភន្តេ តបោជិគុច្ឆា អគ្គបញ្ញត្តា ច ហោតិ សារបញ្ញត្តា ច សាធុ មេ ភន្តេ ភគវា តបោជិគុច្ឆាយ អគ្គំយេវ បាបេតុ សារំយេវ បាបេតូតិ ។ ឥធ និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ ។ កថញ្ច និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ ។ បេ ។ យតោ(២) និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ អទុញ្ចស្ស ហោតិ តបស្សិតាយ ។ សោ អភិហរតិ នោ ហីនាយាវត្តតិ ។ សោ វិវិត្តំ សេនាសនំ ភជតិ ។ បេ ។

១ ឱ. ម. ហោតីតិ ន ទិស្សតិ ។ ២ ឱ. យតោ ច ខោ ។ ម. យតោ ខោ ។

កិលេសឈ្មោះថា បរិសុទ្ធដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ផង ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ត្រឹមតែប៉ុណ្ណោះ មិនទាន់ឈ្មោះថា ដល់កំពូលធម៌ ឬដល់ខ្លឹមធម៌នៅឡើយទេ គ្រាន់តែដល់ត្រឹមសំបកធម៌ប៉ុណ្ណោះទេ ។

[២៧] និគ្រោធបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ចុះការខ្ពើមបាប ដោយព្យាយាម ជាគ្រឿងដុតកិលេសត្រឹមណា ទើបឈ្មោះថា ដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ផង បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំដែងឲ្យដល់កំពូល ឲ្យដល់ខ្លឹមសារបស់ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសតែម្តង ដល់ខ្ញុំព្រះអង្គឲ្យបាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកមានតបវត្តក្នុងលោកនេះ ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាង ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាង តើដូចម្តេច ។ បេ ។ ម្នាលនិគ្រោធ កាលណាអ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាង រមែងមានពាក្យគេសរសើរអ្នកនោះ ព្រោះខ្លួនជាអ្នកមានតបវត្ត ។ គេខំប្រឹងបំពេញសីល មិនត្រឡប់មកដើម្បីភេទថោកទាប ។ គេអាស្រ័យសេពសេនាសនៈស្ងាត់ ។ បេ ។

សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ ។ បេ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតិំ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ។ បេ ។ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ សតំបិ ជាតិយោ សហស្សំបិ ជាតិយោ សតសហស្សំបិ ជាតិយោ អនេកេបិ សំវដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុប្បរិយន្តោ

គេបានលះនីវរណធម៌ទាំង ៥ នេះ ដែលជាគ្រឿងធ្វើចិត្តឲ្យសៅហ្មង ជាគ្រឿងធ្វើប្រាជ្ញាឲ្យថយកំលាំង សម្រេចសម្រាន្តឥរិយាបថ ដោយការផ្សាយចិត្ត ប្រកបដោយមេត្តា ទៅកាន់ទិសទី ១ ។បេ។ គេរលឹកឃើញខន្ធបញ្ចក:ដែលបានអាស្រ័យនៅអំពីមុន ជាច្រើនជាតិ គឺមួយជាតិខ្លះ ពីរជាតិខ្លះ បីជាតិខ្លះ បួនជាតិខ្លះ ប្រាំជាតិខ្លះ ។បេ។ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ជាតិខ្លះ ៤០ជាតិខ្លះ ៥០ជាតិខ្លះ មួយរយជាតិខ្លះ មួយពាន់ជាតិខ្លះ ១ សែនជាតិខ្លះ ច្រើនសំវដ្តកប្ប (កប្បវិនាស) ខ្លះ ច្រើនវិវដ្តកប្ប (កប្បចំរើន) ខ្លះ ច្រើនសំវដ្តវិវដ្តកប្ប (កប្បវិនាសនិងកប្បចំរើន) ខ្លះ ថា ក្នុងកាលឯណោះ អាត្មាអញបានមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុយ៉ាងនេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ក្នុងភពនោះឯង អាត្មាអញបានមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុយ៉ាងនេះ

សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ តំ កិំ មញ្ញសិ និគ្រោធ យទិ ឯវំ សន្តេ តបោជិគុច្ឆា បរិសុទ្ធា វា ហោតិ អបរិសុទ្ធា វាតិ ។ អទ្ធា ខោ[១] ភន្តេ ឯវំ សន្តេ តបោជិគុច្ឆា បរិសុទ្ធា ហោតិ នោ អបរិសុទ្ធា អគ្គប្បត្តា ច ហោតិ សារប្បត្តា ចាតិ ។ ន ខោ និគ្រោធ ឯត្តាវតា តបោជិគុច្ឆា អគ្គប្បត្តា វា[២] ហោតិ សារប្បត្តា វា[៣] អបិច ខោ ផេគ្គុប្បត្តា ហោតីតិ ។

(២៨) កិត្តាវតា បន ភន្តេ តបោជិគុច្ឆា អគ្គប្បត្តា ច ហោតិ សារប្បត្តា ច[៤] សាធុ មេ ភន្តេ

---

១ ឱ. អទ្ធា ខោ បទំ ។ ២-៣ ឱ. ម. ច ។ ៤ ឱ. បទទ្វយំ នត្ថិ ។

អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ រមែងរលឹកឃើញខន្ធបញ្ចកៈ ដែលអាស្រ័យនៅអំពីមុន បានច្រើនជាតិ ព្រមទាំងអាការៈ(១) ព្រមទាំងឧទ្ទេសៈ(២) ដោយប្រការដូច្នេះ ៗ ម្នាលនិគ្រោធ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើដូច្នេះ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធហើយ ឬមិនទាន់បរិសុទ្ធទេ ៗ និគ្រោធបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើយ៉ាងនេះ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ផង ៗ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ត្រឹមតែប៉ុណ្ណេះ មិនទាន់ឈ្មោះថា ដល់កំពូលធម៌ ឬដល់ខ្លឹមធម៌នៅឡើយទេ បានដល់ត្រឹមតែស្រាយ របស់ធម៌ប៉ុណ្ណោះទេ ៗ

(២៨) និគ្រោធបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសត្រឹមណា ទើបឈ្មោះថា ដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ផង បពិត្រព្រះអង្គដ៏ចំរើន

---

១ អដ្ឋកថា ថា គឺរូបនឹងអាហារជាដើម ។ ២ គឺឈ្មោះនឹងគោត្រត្រកូល ។

កថញ្ច តបោជិគុច្ឆាយ អគ្គញ្ចេវ បាបេតុ សារញ្ចេវ បាបេតូតិ ។ ឥធ និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ ។ កថញ្ច និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ ។ បេ ។ យតោ ច (១) ខោ និគ្រោធ តបស្សី ចាតុយាមសំវរសំវុតោ ហោតិ អទុញ្ចស្ស ហោតិ តបស្សិតាយ ។ សោ អភិហរតិ នោ ហីនាយាវត្តតិ ។ សោ វិវិត្តំ សេនាសនំ ភជតិ ។ បេ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ មេត្តាសហគតេន ចេតសា ។ បេ ។ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ

---

១ ឱ. ចសទ្ទោ នត្ថិ ។

សូមព្រះមានព្រះភាគសំដែងឲ្យដល់កំពូល ឲ្យដល់ខ្លឹមសាររបស់ការខ្ពើម បាប ដោយសេចក្ដីព្យាយាម ជាគ្រឿងដុតកិលេសតែម្ដង ដល់ខ្ញុំព្រះអង្គឲ្យបាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកមានតបវត្ត ក្នុងលោកនេះ ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាង ។ ម្នាលនិគ្រោធ អ្នកមានតបវត្ត ជាអ្នកសង្រួមដោយការសង្រួម ៤ យ៉ាង តើដូចម្ដេច ។ បេ ។ ម្នាលនិគ្រោធ កាលណាអ្នកមានតបវត្ត ជាអ្នកសង្រួមដោយ ការសង្រួម ៤ យ៉ាង ក៏រមែងមានពាក្យគេសរសើរអ្នកនោះ ព្រោះខ្លួនជា អ្នកមានតបវត្ត ។ គេខំប្រឹងបំពេញសីល មិនត្រឡប់មកដើម្បីភេទថោក ទាប ។ គេអាស្រ័យសេពសេនាសនៈស្ងាត់ ។ បេ ។ គេលះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេស ជាគ្រឿងធ្វើប្រាជ្ញាឲ្យថយកំឡាំង មានចិត្តប្រកបដោយមេត្តា ។បេ។ សម្រេចសម្រាន្តឥរិយាបថ ដោយការ ផ្សាយចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ មិនមានប្រមាណ មិនមាន ពៀរ មិនមានព្យាបាទ ។ គេរមែងរលឹកឃើញខន្ធបញ្ចកៈ ដែលបាន អាស្រ័យនៅអំពីមុនជាច្រើនជាតិ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រមែង រលឹកឃើញនូវខន្ធបញ្ចកៈ ដែលអាស្រ័យនៅអំពីមុនជាច្រើនជាតិ ព្រម ទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ គេមានចក្ខុដូច ជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុមនុស្សសាមញ្ញ បានឃើញនូវសត្វទាំងឡាយ

ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆា-ទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិ-កម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។

ដែលកំពុងច្យុតនឹងចាប់បដិសន្ធិ ដ៏ទាបថោកនឹងឧត្តម មានទ្រង់ទ្រាយល្អនឹងអាក្រក់ ទៅកាន់សុគតិនឹងទុគ្គតិ រមែងដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយបុគ្គល ជាមិច្ឆាទិដ្ឋិ សមាទាននូវមិច្ឆាទិដ្ឋិកម្ម សត្វទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ចំណែកខាងសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ សមាទាននូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏ទៅកើតឯសុគតិលោក គឺសួគ៌ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុមនុស្សសាមញ្ញ រមែងឃើញ នូវសត្វទាំងឡាយ កំពុងច្យុតនឹងចាប់បដិសន្ធិ ដ៏ទាបថោកនឹងឧត្តម មានទ្រង់ទ្រាយល្អនឹងអាក្រក់ ទៅកាន់សុគតិនឹងទុគ្គតិ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះៗ

តំ កឹ មញ្ញសិ និគ្រោធ យទិ ឯវំ សន្តេ តបោ-ជិគុច្ឆា បរិសុទ្ធា វា ហោតិ អបរិសុទ្ធា វាតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តបោជិគុច្ឆា បរិសុទ្ធា ហោតិ នោ អបរិសុទ្ធា អគ្គប្បត្តា ច ហោតិ សារប្បត្តា ចាតិ ។ ឯត្តាវតា និគ្រោធ តបោជិគុច្ឆា អគ្គប្បត្តា ច ហោតិ សារប្បត្តា ច ។ ឥតិ(១) និគ្រោធ យំ មំ ត្វំ អវចាសិ(២) កោ នាម សោ(៣) ភគវតោ ធម្មោ យេន ភគវា សាវកេ វិនេតិ យេន ភគវតា សាវកា វិនីតា អស្សាសប្បត្តា បដិជានន្តិ អជ្ឈា-សយំ អាទិព្រហ្មចរិយន្តិ ។ ឥតិ ខោ(៤) និគ្រោធ ឋានំ ឧត្តរិតរញ្ច បណីតតរញ្ច យេនាហំ សាវកេ វិនេមិ យេន មយា សាវកា វិនីតា អស្សាសប្បត្តា បដិជានន្តិ អជ្ឈាសយំ អាទិព្រហ្មចរិយន្តិ ។ ឯវំ វុត្តេ

---

១ ឱ. ម. ឥតិ ខោ ។ ២ ឱ. អភាសិ ។ ៣ ឱ ម. សោ ភន្តេ ។ ៤ ឱ. ម. ឯត្តកេ តត្ថ ទិស្សតិ ។

ម្នាលនិគ្រោធ អ្នកសំគាល់សេចក្តីនោះដូចម្តេច កាលបើដូច្នេះ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធហើយឬមិនទាន់បរិសុទ្ធទេ ។ និគ្រោធបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើដូច្នេះ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ឈ្មោះថា បរិសុទ្ធដោយពិត មិនមែនមិនបរិសុទ្ធទេ ទាំងដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ផង ។ ម្នាលនិគ្រោធ ការខ្ពើមបាប ដោយសេចក្តីព្យាយាម ជាគ្រឿងដុតកិលេសទាំងប៉ុណ្ណោះ ទើបឈ្មោះថា ដល់កំពូលធម៌ផង ដល់ខ្លឹមធម៌ផង ។ ម្នាលនិគ្រោធ អ្នកបាននិយាយនឹងតថាគតថា ព្រះមានព្រះភាគ ទ្រង់ទូន្មានពួកសាវ័ក ដោយធម៌ណា ពួកសាវ័កដែលព្រះអង្គទ្រង់ទូន្មាន ដោយធម៌ណាហើយ ដល់នូវសេចក្តីគាប់ចិត្ត បានបំពេញអរិយមគ្គ ជាព្រហ្មចរិយធម៌ដើម ដែលឲ្យកើតនិស្ស័យដ៏ឧត្តម ធម៌របស់ព្រះមានព្រះភាគនោះ តើឈ្មោះដូចម្តេច ។ ម្នាលនិគ្រោធ តថាគតទូន្មានពួកសាវ័ក ដោយពាក្យប្រៀនប្រដៅណា ពួកសាវ័កដែលតថាគតបានទូន្មាន ដោយពាក្យប្រៀនប្រដៅណា ដល់នូវសេចក្តីត្រេកអរ បានបំពេញអរិយមគ្គ ជាព្រហ្មចរិយធម៌ដើម ដែលឲ្យកើតនិស្ស័យដ៏ឧត្តម ហេតុ (របស់ពាក្យប្រៀនប្រដៅនោះ) ឧត្តមជាង វិសេសជាង ដូច្នេះឯង ។ កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ

តេ បរិព្វាជកា ឧន្នាទិនោ ឧច្ចាសទ្ទមហាសទ្ទា អហេសុំ ឯត្ថ មយំ ន បស្សាម សាចរិយកា ឯត្ថ មយំ ន បស្សាម សាចរិយកា ន មយំ ឥតោ ភិយ្យោ ឧត្តរិតរំ បជានាមាតិ(១) ។

(២៩) យទា អញ្ញាសិ សន្ធានោ គហបតិ អញ្ញទត្ថុ ខោ ទានិមេ អញ្ញតិត្ថិយា បរិព្វាជកា ភគវតោ ភាសិតំ សុស្សូសន្តិ សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋបេន្តីតិ អថ(២) និគ្រោធំ បរិព្វាជកំ ឯតទវោច ឥតិ ខោ ភន្តេ និគ្រោធ យំ មំ ត្វំ អវចាសិ យគ្ឃេ គហបតិ ជានេយ្យាសិ កេន សមណោ គោតមោ សទ្ធឹ សល្លបតិ កេន សាកច្ឆំ សមាបជ្ជតិ កេន បញ្ញាវេយ្យត្តិយំ សមាបជ្ជតិ(៣) សុញ្ញាគារហតា សមណស្ស គោតមស្ស បញ្ញា អបរិសាវចរោ សមណោ គោតមោ នាលំ សល្លាបាយ

---

១ ឱ. ម. ឯត្ថ មយំ អនស្សាម សាចរិយកា ន មយំ ឥតោ ភិយ្យោ ឧត្តរិតរំ បជានាមាតីតិ ឋាបក្កមោ ទិស្សតិ ។ ២ ម. អថ ខោ ។ ៣ ឱ. អាបជ្ជតិ ។

បរិព្វាជកទាំងនោះ ក៏បន្លឺសំឡេងហ៊ោ សំឡេងខ្លាំងថា ពួកយើង ដែលជាអ្នករួមអាចារ្យផងគ្នា មិនដែលឃើញ ក្នុងដំណើរនេះឡើយ ពួកយើងដែលជាអ្នករួមអាចារ្យផងគ្នា មិនដែលឃើញ ក្នុងដំណើរនេះឡើយ ពួកយើងមិនធ្លាប់ដឹង ឲ្យលើសជាងពីនេះ ទៅទៀតឡើយ ។

(២៩) កាលណាសន្ធានគហបតិបានដឹងថា ឥឡូវនេះពួកបរិព្វាជកជាអន្យតិរ្ថិយទាំងនេះ កំពុងប្រុងស្តាប់ភាសិត របស់ព្រះមានព្រះភាគ ត្រាប់ត្រង់ស្រោតប្រសាទ ដំកល់ចិត្តមិនឲ្យរាយមាយ ដោយពិតដូច្នោះហើយ ទើបបាននិយាយពាក្យនេះ នឹងនិគ្រោធបរិព្វាជកថា បពិត្រនិគ្រោធ លោកបាននិយាយនឹងខ្ញុំរួចហើយថា នែគហបតិ ដូចជាយើងរិះគន់ អ្នកត្រូវដឹងថា ព្រះសមណគោតម ចរចាជាមួយនឹងអ្នកណាបាន ប្រទះសាកច្ឆាជាមួយនឹងអ្នកណាបាន ល្បងនូវភាពវាងវៃ ដោយប្រាជ្ញាជាមួយនឹងអ្នកណា (ដូចម្តេចបាន) ព្រោះប្រាជ្ញារបស់ព្រះសមណគោតម វិនាសបាត់បង់ទៅ ក្នុងផ្ទះស្ងាត់ទៅហើយ ព្រះសមណគោតម មិនហ៊ានចូលកាន់បរិស័ទទេ មិនអាចធ្វើការចរចា នឹងអ្នកដទៃបានទេ

សោ អន្តមន្តានេវ សេវតិ សេយ្យថាបិ នាម គោកាណា បរិយន្តចារិនី អន្តមន្តានេវ សេវតិ ឯវមេវំ សុញ្ញាគារហតា សមណស្ស គោតមស្ស បញ្ញា អបរិសាវចរោ សមណោ គោតមោ នាលំ សល្លាបាយ សោ អន្តមន្តានេវ សេវតិ ឥង្ឃ គហបតិ សមណោ គោតមោ ឥមំ បរិសំ អាគច្ឆេយ្យ ឯកបញ្ហេនេវ នំ សំសាទេយ្យាម(១) តុច្ឆកុម្ភីវ នំ មញ្ញេ ឱកេដេយ្យាមាតិ អថ ភោ(២) សោ កេត្ត ភគវា អរហំ សម្មាសម្ពុទ្ធោ ឥធានុប្បត្តោ អបរិសាវចរំ បន នំ ករេម គោកាណំ បរិយន្តចារិនី ករេម ឯកបញ្ហេនេវ នំ សំសាទេម(៣) តុច្ឆកុម្ភីវ នំ មញ្ញេ ករេមាតិ ។ ឯវំ វុត្តេ និគ្រោធោ បរិព្វាជកោ តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។

---

១ ម. សំហរេយ្យាម ។ ២ ឱ. ម. អយំ ភោ ។ ៣ ម. សំហរេម ។

បានជាលោក តែងអាស្រ័យសេនាសនៈ ដ៏ស្ងាត់ប៉ុណ្ណោះ ដូចមេគោខ្វាក់ភ្នែកម្ខាង តែងត្រាច់ទៅតែខាង ៗ ជុំវិញ តែងគប់រកតែទីស្ងាត់ប៉ុណ្ណោះ ដូចម្ដេចមិញ ប្រាជ្ញារបស់ព្រះសមណគោតម វិនាសបាត់បង់ទៅ ក្នុងផ្ទះស្ងាត់ទៅហើយ ព្រះសមណគោតម មិនហ៊ានចូលកាន់បរិស័ទ មិនអាចធ្វើការបរបានឹងអ្នកដទៃបានទេ បានជាលោកតែងអាស្រ័យនៅ តែក្នុងសេនាសនៈស្ងាត់ ដូច្នោះឯង នែគហបតី ល្បងមើលចុះ (ប្រសិនបើ) ព្រះសមណគោតម គប្បីមកកាន់បរិស័ទនេះ (មែន) ពួកយើងគួរសាកសួរលោក មួយប្រស្នាល្បងមើលដែរ ពួកយើងត្រូវចាប់បង្វិលព្រះសមណគោតមនោះ ឲ្យដូចគេចាប់បង្វិលឆ្នាំងទទេ (មិនខាន) បពិត្រលោកដ៏ចំរើន ស្រាប់តែព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ស្ដេចដល់មកក្នុងទីនេះ អើឥឡូវនេះដល់ហើយ ចូរលោកធ្វើព្រះអង្គ ឲ្យជាអ្នកមិនហ៊ានចូលមកកាន់បរិស័ទចុះ ចូរលោកធ្វើព្រះអង្គ ឲ្យដូចមេគោខ្វាក់ភ្នែកម្ខាង ដែលត្រាច់ទៅតែខាង ៗ ជុំវិញចុះ ចូរលោកសាកសួរព្រះអង្គ ដោយប្រស្នាចុះ ចូរលោកបង្វិលព្រះសមណគោតមនោះ ឲ្យដូចជាគេចាប់បង្វិលឆ្នាំងទទេចុះ ៗ កាលសន្ធានគហបតី និយាយយ៉ាងនេះហើយ និគ្រោធបរិព្វាជក អង្គុយនៅតែស្ងៀម អៀនខ្មាស ឱនកដាក់មុខ ជ្រប់ស្រពោន ទ័លប្រាជ្ញា ៗ

(១០) អថខោ ភគវា និគ្រោធំ បរិព្វាជកំ តុណ្ហីភូតំ មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា និគ្រោធំ បរិព្វាជកំ ឯតទវោច សច្ចំ និគ្រោធ ភាសិតា តេ ឯសា វាចាតិ ។ សច្ចំ ភន្តេ ភាសិតា មេ ឯសា វាចា យថាពាលេន យថាមូឡ្ហេន យថាអកុសលេនាតិ ។ តំ កឹ មញ្ញសិ និគ្រោធ កិន្តិ តេ សុតំ បរិព្វាជកានំ វុឌ្ឍានំ(១) មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យេ តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា ឯវំ សុ តេ ភគវន្តោ សង្គម្ម សមាគម្ម ឧន្នាទិនោ ឧច្ចាសទ្ទមហាសទ្ទា អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរឹសុ សេយ្យថីទំ រាជកថំ ចោរកថំ ។បេ។ ឥតិភវាភវកថំ ឥតិ វា សេយ្យថាបិ ត្វំ ឯតរហិ សាចរិយកោ ឧទាហុ ឯវំ សុ តេ ភគវន្តោ

១ ឱ. វុទ្ធានំ ។

(៣០) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា និគ្រោធបរិព្វាជក អង្គុយនៅស្ងៀម អៀនខ្មាស ឱនកជាក់មុខ ជ្រប់ស្រពោន ទ័លប្រាជ្ញាហើយ ក៏បានត្រាស់សួរនិគ្រោធបរិព្វាជក យ៉ាងនេះថា ម្នាលនិគ្រោធ សំដីនេះ អ្នកបាននិយាយមែនឬ ។ និគ្រោធបរិព្វាជក ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ បាននិយាយសំដីនេះ ពិតមែន តាមដែលខ្ញុំព្រះអង្គ ជាមនុស្សល្ងង់ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនិគ្រោធ អ្នកសំគាល់សេចក្តីនោះដូចម្តេច អ្នកបានឮពួកបរិព្វាជកព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងកាលកន្លងទៅហើយ ព្រះសម្មាសម្ពុទ្ធទាំងឡាយដ៏មានព្រះភាគនោះ ទ្រង់ជួបជុំសមាគម ហើយបន្លឺសំឡេងហ៊ោ សំឡេងខ្លាំង ប្រកបនូវតិរច្ឆានកថា ជាច្រើនយ៉ាង គឺនិយាយពីស្តេច និយាយពីចោរ ។ បេ ។ និយាយពីសេចក្តីចំរើន នឹងសេចក្តីសាបសូន្យ ដែលឥតប្រយោជន៍ ថា ដូច្នេះខ្លះ ដូច្នោះខ្លះ ដូចជាអ្នកដែលរួមអាចារ្យផងគ្នា ក្នុងកាលឥឡូវនេះយ៉ាងនេះដែរឬ ឬថា ព្រះមានព្រះភាគទាំងនោះ

អរញ្ញវនបត្ថានិ[១] បន្តានិ សេនាសនានិ បដិសេវន្តិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ សេយ្យថាបាហមេតរហិ ។ សុតមេតំ[២] ភន្តេ បរិព្វាជកានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យេ តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា ន ឯវំ សុ តេ[៣] ភគវន្តោ ឯវំ[៤] សង្គម្ម សមាគម្ម ឧន្នាទិនោ ឧច្ចាសទ្ទមហាសទ្ទា អនេកវិហិតំ តិរច្ឆានកថំ អនុយុត្តា វិហរន្តិ សេយ្យថីទំ រាជកថំ ចោរកថំ ។ បេ ។ ឥតិភវាភវកថំ ឥតិ វា សេយ្យថាបាហមេតរហិ សាចរិយកោ ឯវំ សុ តេ ភគវន្តោ អរញ្ញវនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហសេយ្យកានិ បដិសល្លានសារុប្បានិ សេយ្យថាបិ ភគវា ឯតរហិ ។ តស្ស ខោ[៥] និគ្រោធ វិញ្ញុស្ស សតោ មហល្លកស្ស

---

១ ឱ. អរញ្ញេ វនបត្ថានិ ។ ២ ឱ. សុតំ មេ តំ ។ ៣ ឱ. នាស្សុ តេ ។ ៤ ឱ. ម. ឯវន្តិ ន ទិស្សតិ ។ ៥ ឱ. ម. តេ ។

ឧទុម្ពរិកសូត្រ ពោលអំពីគុណលោកថានៃព្រះសម្មាសម្ពុទ្ធ

តែងអាស្រ័យសេពសេនាសនៈដ៏ស្ងាត់ ជាទីតាំងនៅក្នុងព្រៃស្រោង ជាសេនាសនៈមានសំឡេងសន្ធឹកគឹកកងតិច ប្រាសចាកសំដីអ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស គួរដល់ការលាក់ខ្លួនពួនអាត្មាបាន ដូចជាតថាគតក្នុងកាលឥឡូវនេះ យ៉ាងនេះ ៗ និគ្រោធបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮពួកបរិព្វាជកព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយគ្នា យ៉ាងនេះថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងកាលកន្លងទៅហើយ ព្រះមានព្រះភាគទាំងនោះ ជួបជុំសមាគមយ៉ាងនេះហើយ បន្លឺសំឡេងហ៊ោ សំឡេងខ្លាំង ប្រកបនូវតិរច្ឆានកថា ជាច្រើនយ៉ាង គឺនិយាយពីស្ដេច និយាយពីចោរ ៗ បេ ៗ និយាយពីសេចក្ដីចំរើន និងសេចក្ដីសាបសូន្យ ដែលឥតប្រយោជន៍ថា ដូច្នេះខ្លះ ដូច្នោះខ្លះ ដូចជាខ្ញុំព្រះអង្គ ជាអ្នករួមអាចារ្យផងគ្នា ក្នុងកាលឥឡូវនេះ យ៉ាងនេះក៏ទេ ព្រះមានព្រះភាគទាំងឡាយនោះ តែងអាស្រ័យសេពសេនាសនៈដ៏ស្ងាត់ ជាទីតាំងនៅក្នុងព្រៃស្រោង ជាសេនាសនៈមានសំឡេងសន្ធឹកគឹកកងតិច ប្រាសចាកសំដីរបស់អ្នកផង សមគួរដល់ការស្ងប់ស្ងាត់របស់មនុស្ស គួរដល់ការលាក់ខ្លួនពួនអាត្មាបាន ដូចព្រះមានព្រះភាគក្នុងកាលឥឡូវនេះ យ៉ាងនេះដែរ ។ ព្រះអង្គត្រាស់ថា ម្នាលនិគ្រោធ វិញ្ញូជនចាស់ទុំដែលជាអ្នកមានសតិនោះ

ច ឯតទហោសិ ពុទ្ធោ សោ ភគវា សម្ពោធាយ(១) ធម្មំ ទេសេតិ ទន្តោ សោ ភគវា ទមថាយ ធម្មំ ទេសេតិ សន្តោ សោ ភគវា សមថាយ ធម្មំ ទេសេតិ តិណ្ណោ សោ ភគវា តរណាយ ធម្មំ ទេសេតិ បរិនិព្វុតោ សោ ភគវា បរិនិព្វានាយ ធម្មំ ទេសេតីតិ ។

(៣៦) ឯវំ វុត្តេ និគ្រោធោ បរិព្វាជកោ ភគវន្តំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ(២) ភគវន្តំ ឯវំ អវចាសឹ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ តគ្ឃ តំ(៣) និគ្រោធ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ

១ ឱ. ពោធាយ ។ ម. សំពោធាយ ។ ២ ឱ. សោហំ ។ ៣ ម. ត្វំ ។

មិនមានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹង (ដោយព្រះអង្គឯង) ហើយទ្រង់សំដែងធម៌ ដើម្បីញុំាងបុគ្គលដទៃ ឲ្យត្រាស់ដឹង ព្រះមានព្រះភាគអង្គនោះ ទ្រង់ទូន្មានព្រះអង្គបានហើយ ទើបសំដែងធម៌ ដើម្បីទូន្មានអ្នកដទៃ ព្រះមានព្រះភាគអង្គនោះ ទ្រង់ស្ងប់ហើយ ទើបសំដែងធម៌ ដើម្បីសេចក្តីស្ងប់ដល់អ្នកដទៃ ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្លងផុតហើយ ទើបសំដែងធម៌ ដើម្បីការឆ្លងដល់អ្នកដទៃ ព្រះមានព្រះភាគអង្គនោះ ទ្រង់រំលត់កិលេសបានហើយ ទើបសំដែងធម៌ ដើម្បីសេចក្តីរំលត់កិលេសដល់អ្នកដទៃ ។

[៣១] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ និគ្រោធបរិព្វាជក បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទោសកំហុសបានគ្របសង្កត់នូវខ្ញុំព្រះអង្គ ព្រោះជាមនុស្សល្ងង់យ៉ាងណា ជាមនុស្សវង្វេងយ៉ាងណា ជាមនុស្សមិនឈ្លាសយ៉ាងណា ខ្ញុំព្រះអង្គបានពោលពាក្យទ្នាំងទ្នងយ៉ាងនេះ នឹងព្រះមានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់អត់នូវទោសតាមទោស ដល់ខ្ញុំព្រះអង្គនោះ ដើម្បីសេចក្តីសង្រួមតទៅ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលនិគ្រោធ អើក៏ ទោសកំហុស គ្របសង្កត់នូវអ្នក ព្រោះជាមនុស្សល្ងង់យ៉ាងណា ជាមនុស្សវង្វេងយ៉ាងណា

យថាអកុសលំ យំ មំ ត្វំ ឯវំ អវចាសិ យតោ ច ខោ និគ្រោធ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តំ តេ(១) មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា និគ្រោធ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ ។ អហំ បន និគ្រោធ ឯវំ វទាមិ ឯតុ វិញ្ញូ បុរិសោ អសឋោ អមាយាវី ឧជុជាតិកោ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថាបដិបជ្ជមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ សត្តវស្សានិ ។ តិដ្ឋន្តុ និគ្រោធ សត្តវស្សានិ ។ ឯតុ វិញ្ញូ បុរិសោ អសឋោ អមាយាវី ឧជុជាតិកោ អហមនុសាសាមិ

១. ម. តត្តេ ។

ជាមនុស្សមិនឈ្លាសយ៉ាងណា អ្នកបានពោលពាក្យផ្គាំផ្គងណា នឹងតថា-គតយ៉ាងនេះហើយ ម្នាលនិគ្រោធ បើអ្នកឃើញទោស តាមទោសណាហើយ ត្រឡប់ធ្វើឱ្យសមគួរ តាមធម៌វិញ តថាគតនឹងអត់ទោសនោះដល់អ្នក ម្នាលនិគ្រោធ នេះឯងជាសេចក្តីចំរើន ក្នុងវិន័យរបស់ព្រះអរិយ-បុគ្គល ព្រោះមនុស្សណា ឃើញទោសតាមទោសហើយ ត្រឡប់ធ្វើឱ្យសមគួរតាមធម៌វិញ អ្នកនោះ រមែងដល់នូវសេចក្តីសង្រួមតទៅបាន ។ ម្នាលនិគ្រោធ មួយទៀត តថាគតបានពោលយ៉ាងនេះថា បុរសអ្នកដឹងជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ក៏ចូរមកចុះ តថាគតនឹងប្រដៅ តថាគតនឹងសំដែងធម៌ បុគ្គលនោះ កាលបើប្រតិបត្តិតាមធម៌ ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រ ដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឱ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គ-ព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តទៅ (ដោយឥរិយាបថទាំង ៤) អស់៧ឆ្នាំ ។ ម្នាលនិគ្រោធ ៧ ឆ្នាំ ចូរលើកទុកចុះ ។ បុរសជាអ្នកប្រាជ្ញ ជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ចូរមកចុះ តថាគតនឹងប្រដៅ

អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ យថាបដិបជ្ជមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ ឆ វស្សានិ ។ បញ្ច វស្សានិ ។ ចត្តារិ វស្សានិ ។ តីណិ វស្សានិ ។ ទ្វេ វស្សានិ ។ ឯកំ វស្សំ ។ តិដ្ឋតុ និគ្រោធ ឯកំ វស្សំ ។ ឯតុ វិញ្ញូ បុរិសោ អសឋោ អមាយាវី ឧជុជាតិកោ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថាបដិបជ្ជមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ សត្ត មាសានិ ។ តិដ្ឋន្តុ និគ្រោធ សត្ត មាសានិ ។ ឆ មាសានិ ។ បញ្ច មាសានិ ។ ចត្តារិ មាសានិ ។ តីណិ មាសានិ ។

តថាគតនឹងសំដែងធម៌ បុគ្គលនោះកាលបើប្រតិបត្តិតាមធម៌ ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួស ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) អស់ ៦ ឆ្នាំ ។ ៥ ឆ្នាំ ។ ៤ ឆ្នាំ ។ ៣ ឆ្នាំ ។ ២ ឆ្នាំ ។ ១ ឆ្នាំ ។ ម្នាលនិគ្រោធ ១ ឆ្នាំចូរលើកទុកចុះ ។ បុរសជាអ្នកប្រាជ្ញ ជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ចូរមកចុះ តថាគតនឹងប្រដៅ តថាគតនឹងសំដែងធម៌ បុគ្គលនោះកាលបើប្រតិបត្តិតាមធម៌ ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង៤) អស់ ៧ ខែ ។ ម្នាលនិគ្រោធ ៧ ខែចូរលើកទុកចុះ ។ ៦ ខែ ។ ៥ ខែ ។ ៤ ខែ ។ ៣ ខែ ។

ទ្វេ មាសានិ ។ ឯកំ មាសំ ។ អឌ្ឍមាសំ ។ តិដ្ឋតុ និគ្រោធ អឌ្ឍមាសោ ។ ឯតុ វិញ្ញូ បុរិសោ អសឋោ អមាយាវី ឧជុជាតិកោ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថាបដិបជ្ជមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតិ សត្តាហំ ។ សិយា ខោ បន តេ និគ្រោធ ឯវមស្ស អន្តេវាសិកម្យតា(១) សមណោ គោតមោ ឯវមាហាតិ ។ ន ខោ បនេតំ និគ្រោធ ឯវំ ទដ្ឋព្វំ យោ ឯវំ តេ អាចរិយោ សោយេវ តេ(២) អាចរិយោ ហោតុ ។ សិយា ខោ បន តេ និគ្រោធ ឯវមស្ស ឧទ្ទេសា នោ ចាវេតុកាមោ សមណោ គោតមោ ឯវមាហាតិ ។ ន ខោ បនេតំ និគ្រោធ ឯវំ ទដ្ឋព្វំ យោ ឯវំ តេ(៣) ឧទ្ទេសោ

---

១ ឱ. ម. អន្តេវាសិកម្យតោ នោ ។ ២ តេតិ កត្ថចិ ពោត្ថកេ ទិស្សតិ ។ ៣ ឱ. ភេ ។

## ឧទុម្ពរិកសូត្រ ពោលអំពីអានិសង្សដ៏ឧត្តមនៃការប្រតិបត្តិក្នុងធម្មវិន័យ

២ ខែ ៗ ១ ខែ ៗ កន្លះខែ ៗ ម្នាលនិគ្រោធ កន្លះខែចូរលើកទុកចុះ ៗ បុរសជាអ្នកប្រាជ្ញ ជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាអ្នកត្រង់ ចូរមកចុះ តថាគតនឹងប្រដៅ តថាគតនឹងសំដែងធម៌ បុគ្គលនោះ កាលបើប្រតិបត្តិតាមធម៌ ដែលតថាគតប្រៀនប្រដៅហើយ ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) អស់ ៧ ថ្ងៃ ៗ ម្នាលនិគ្រោធ សមតែអ្នកមានគំនិត យ៉ាងនេះថា ព្រះសមណគោតម បានជានិយាយយ៉ាងនេះ ព្រោះចង់បានកូនសិស្ស ៗ ម្នាលនិគ្រោធ តែថា អ្នកមិនត្រូវឃើញហេតុនុ៎ះ យ៉ាងនេះឡើយ អ្នកណាជាអាចារ្យរបស់ពួកអ្នក អ្នកនោះចូរនៅជាអាចារ្យរបស់ពួកអ្នកដដែលចុះ ៗ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិតយ៉ាងនេះថា ព្រះសមណគោតមប្រាថ្នា ដើម្បីញុំាងពួកយើងឲ្យកក្រើកចាកឧទ្ទេស ទើបបានត្រាស់យ៉ាងនេះ ៗ ម្នាលនិគ្រោធ តែថា អ្នកមិនត្រូវឃើញហេតុនុ៎ះយ៉ាងនេះឡើយ ឧទ្ទេសណាជារបស់អ្នក

សោ យេវ តេ ឧទ្ទេសោ ហោតុ ។ សិយា ខោ បន តេ និគ្រោធ ឯវមស្ស អាជីវា នោ ចាវេតុកាមោ សមណោ គោតមោ ឯវមាហាតិ ។ ន ខោ បនេតំ និគ្រោធ ឯវំ ទដ្ឋព្វំ យោ ច តេ(១) អាជីវោ សោ យេវ តេ(២) អាជីវោ ហោតុ ។ សិយា ខោ បន តេ និគ្រោធ ឯវមស្ស យេ តេ(៣) ធម្មា អកុសលា អកុសលសង្ខាតា សាចរិយកានំ តេសុ បតិដ្ឋាបេតុកាមោ សមណោ គោតមោ ឯវមាហាតិ ។ ន ខោ បនេតំ និគ្រោធ ឯវំ ទដ្ឋព្វំ អកុសលា យេវ តេ ធម្មា(៤) ហោន្តុ អកុសលសង្ខាតា សាចរិយកានំ ។ សិយា ខោ បន តេ និគ្រោធ ឯវមស្ស យេ តេ ធម្មា កុសលា កុសលសង្ខាតា សាចរិយកានំ តេហិ វិវេចេតុកាមោ(៥) សមណោ គោតមោ ឯវមាហាតិ ។ ន ខោ បនេតំ និគ្រោធ ឯវំ ទដ្ឋព្វំ

---

១ ឱ. យោ ឯវ តេ ។ ២ តេ ។ ៣ ឱ. ម នោ ។ ៤ ឱ. អកុសលា ចេវ តេ តេ ធម្មា ។ ម. ... តេ ធម្មា ។ ៥ ឱ. វិវេចេតុកាមោ ។

ឧទ្ទេសនោះ ក៏នៅជាឧទ្ទេស របស់អ្នកដដែលចុះ ។ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិតយ៉ាងនេះថា ព្រះសមណគោតម ប្រាថ្នា ដើម្បីញុំាងពួកយើង ឲ្យកក្រើកចាកអាជីវៈ ទើបបានត្រាស់យ៉ាងនេះ ។ ម្នាលនិគ្រោធ អ្នកមិនត្រូវឃើញហេតុនុ៎ះ យ៉ាងនេះឡើយ អាជីវៈណា ជារបស់អ្នក អាជីវៈនោះក៏នៅជាអាជីវៈ របស់អ្នកដដែលចុះ ។ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិត យ៉ាងនេះថា ពួកធម៌ណា ជាអកុសល រាប់ចូលក្នុងអកុសលរបស់ជន ដែលរួមអាចារ្យផងគ្នា ព្រះសមណគោតម ប្រាថ្នានឹងញុំាងពួកអ្នក ឲ្យតាំងនៅ ក្នុងធម៌ទាំងនោះ ទើបបានត្រាស់យ៉ាងនេះ ។ ម្នាលនិគ្រោធ តែថា អ្នកមិនត្រូវឃើញហេតុនុ៎ះយ៉ាងនេះឡើយ ពួកធម៌ជាអកុសល រាប់ចូលក្នុងអកុសលនោះ របស់ជនរួមអាចារ្យផងគ្នា ចូរនៅជាអកុសលធម៌ដដែលចុះ ។ ម្នាលនិគ្រោធ មួយទៀត សមតែអ្នកមានគំនិត យ៉ាងនេះថា ពួកធម៌ណាជាកុសល រាប់ចូលក្នុងកុសល របស់ជនជាអ្នករួមអាចារ្យផងគ្នា ព្រះសមណគោតម ប្រាថ្នា ដើម្បីញុំាងពួកអ្នក ឲ្យឃ្លាតចាកកុសលធម៌ទាំងនោះ ទើបបាន ត្រាស់យ៉ាងនេះ ។ ម្នាលនិគ្រោធ តែថា អ្នកមិនត្រូវឃើញហេតុនុ៎ះ

កុសលាយេវ តេ ធម្មា ហោន្តុ កុសលសង្ខាតា សាចរិយកានំ ។ ឥតិ ខោហំ(១) និគ្រោធ នេវ អន្តេវាសិកម្យតា ឯវំ វទាមិ នាបិ(២) ឧទ្ទេសា ចាវេតុកាមោ ឯវំ វទាមិ នាបិ(៣) អាជីវា ចាវេតុ-កាមោ ឯវំ វទាមិ នបិ យេ តេ(៤) ធម្មា អកុសលា អកុសលសង្ខាតា សាចរិយកានំ តេសុ បតិដ្ឋាបេតុ-កាមោ ឯវំ វទាមិ នបិ យេ តេ(៥) ធម្មា កុសលា កុសលសង្ខាតា សាចរិយកានំ តេហិ វិវេចេតុកាមោ ឯវំ វទាមិ ។ សន្តិ ច ខោ និគ្រោធ អកុសលា ធម្មា អប្បហីនា សង្កិលេសិកា បោនោព្ភវិកា(៦) សទរថា(៧) ទុក្ខវិបាកា អាយតឹ ជាតិជរាមរណិយា យេសាហំ បហា-នាយ ធម្មំ ទេសេមិ ។ យថាបដិបន្នានំ វោ សង្កិលេសិ-កា ធម្មា បហីយិស្សន្តិ វោទានិយា ធម្មា អភិវឌ្ឍិស្សន្តិ

---

១ ម. ខ្វាហំ ។ ២-៣ ឱ. ម. នបិ ។ ៤-៥ ម. យេ ច វោ ។ ឱ. វោ ។
៦ ឱ. បោនោភវិកា ។ ម បោនព្ភវិកា ។ ៧ ឱ សទរា ។

យ៉ាងនេះឡើយ ពួកធម៌ជាកុសលរាប់ចូល ក្នុងកុសលនោះ របស់ពួកជនរួមអាចារ្យផងគ្នា ប្តូរទៅជាកុសលធម៌ដដែលចុះ ។ ម្នាលនិគ្រោធ តថាគតបានពោលយ៉ាងនេះ ព្រោះចង់បានអន្តេវាសិកក៏ទេ មានប្រាថ្នា ដើម្បីញុំាងពួកអ្នក ឲ្យក្រើកចាកឧទ្ទេស ទើបបានពោលយ៉ាងនេះក៏ទេ មានប្រាថ្នា ដើម្បីញុំាងពួកអ្នក ឲ្យក្រើកចាកអាជីវៈ ទើបបានពោលយ៉ាងនេះក៏ទេ ពួកធម៌ណាជាអកុសល រាប់ថាជាអកុសល របស់ពួកជនដែលរួមអាចារ្យផងគ្នា តថាគតប្រាថ្នា ដើម្បីញុំាងពួកអ្នក ឲ្យតាំងនៅក្នុងធម៌ទាំងនោះ ទើបបានពោលយ៉ាងនេះក៏ទេ ពួកធម៌ណាជាកុសល រាប់ថាជាកុសល របស់ពួកជនដែលរួមអាចារ្យផងគ្នា តថាគតប្រាថ្នា ដើម្បីញុំាងពួកអ្នក ឲ្យឃ្លាតចាកធម៌ទាំងនោះ ទើបបានពោលយ៉ាងនេះក៏ទេ ។ ម្នាលនិគ្រោធ មួយទៀត ពួកធម៌ជាអកុសល ដែលបុគ្គលលះមិនទាន់បាន ប្រព្រឹត្តទៅ ដើម្បីសេចក្តីសៅហ្មង ប្រព្រឹត្តទៅ ដើម្បីសេចក្តីកើតទៀត ប្រកបដោយសេចក្តីក្រវល់ក្រវាយ មានទុក្ខ ជាផល ជាបច្ច័យដល់សេចក្តីកើត ចាស់ ស្លាប់ ទៅខាងមុខ តថាគតសំដែងធម៌ ដើម្បីលះបង់នូវធម៌ ជាអកុសលទាំងឡាយនោះ ។ កាលបើពួកអ្នកប្រតិបត្តិសមគួរហើយ ធម៌ទាំងឡាយប្រកបដោយសេចក្តីសៅហ្មង មុខជានឹងសាបសូន្យទៅ ធម៌ទាំងឡាយជាទីតាំងនៃសេចក្តីបរិសុទ្ធិ នឹងចំរើនឡើង

បញ្ញាចារិយំ វេបុល្លត្តញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ ឯវំ វុត្តេ តេ បរិព្វាជកា តុណ្ហីភូតា មង្កុភូតា បត្តក្ខន្ធា អធោមុខា បជ្ឈាយន្តា អប្បដិភាណា និសីទឹសុ យថាតំ មារេន បរិយុដ្ឋិតចិត្តា ។

[៣២] អថខោ ភគវតោ ឯតទហោសិ សព្វេបិមេ មោឃបុរិសា ផុដ្ឋា មារេន(១) បាបិមតា យត្រ ហិ នាម ឯកស្សបិ ន ឯវំ ភវិស្សតិ ហន្ទ មយំ អញ្ញាណត្ថំបិ សមណេ គោតមេ ព្រហ្មចរិយំ ចរាម កឹ ករិស្សតិ សត្តាហោតិ ។ អថខោ ភគវា ឧទុម្ពរិកាយ បរិព្វាជការាមេ សីហនាទំ នទិត្វា វេហាសំ អព្ភុគ្គន្ត្វា គិជ្ឈកូដេ បព្វតេ បច្ចុដ្ឋាសិ ។ សន្ធានោ(២) គហបតិ តាវទេវ រាជគហំ បាវិសីតិ ។

ឧទុម្ពរិកសុត្តំ ទុតិយំ និដ្ឋិតំ(៣) ។

---

១ ខ. ម. មារេនាតិ ន ទិស្សតិ ។ ២ ម. សន្ធានោ បន ។ ៣ ខ. ឧទុម្ពរិកសីហនាទសុត្តំ ទុតិយំ ។ ម. ឧទុម្ពរិកសុត្តន្តំ ទុតិយំ ។

ពួកអ្នកពល់គ្នា មុខជានឹងធ្វើឲ្យជាក់ច្បាស់ នូវការបំពេញប្រាជ្ញា ដើម្បីមគ្គនឹងសេចក្តីផ្សាយផលនៃប្រាជ្ញា ដើម្បីដល់ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) ។ កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ពួកបរិព្វាជកទាំងនោះ ក៏អង្គុយនៅស្ងៀម អៀនខ្មាស ឱនក ដាក់មុខ ជួបស្រពោន ទល់ប្រាជ្ញា ព្រោះមារចូលជ្រែកចិត្ត ។

(៣៤) គ្រានោះឯង ព្រះមានព្រះភាគ មានសេចក្តីត្រិះរិះដូច្នេះថា មោឃបុរសទាំងអស់នេះ ត្រូវមារចិត្តបាប ចូលជ្រែកហើយ ព្រោះថា សូម្បីតែម្នាក់ មុខជាគ្មានគំនិតយ៉ាងនេះថា ណ្ហើយចុះ ពួកយើងទាំងអស់គ្នា ចូរប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះសមណគោតម ដើម្បីសេចក្តីដឹងច្បាស់ត្រឹម ៧ ថ្ងៃ ប៉ុណ្ណោះ នឹងយូរប៉ុន្មាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បន្លឺនូវសីហនាទ ក្នុងអារាមនៃបរិព្វាជក ជារបស់នៃនាងឧទុម្ពរិកាទេវី ហើយទ្រង់ហោះឡើងទៅកាន់វេហាសស្ថាន ត្រឡប់ទៅគង់លើភ្នំគិជ្ឈកូដវិញ ។ ឯសន្ធានគហបតី ក៏ចូលទៅកាន់ក្រុងរាជគ្រឹះ ក្នុងពេលនោះដែរ ។

ចប់ ឧទុម្ពរិកសូត្រ ទី ២ ។

# ចក្កវត្តិសុត្តំ (១) តតិយំ

[៣៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មគធេសុ វិហរតិ មាតុលាយំ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អត្តទីបា ភិក្ខវេ វិហរថ អត្តសរណា អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញសរណា ។ កថញ្ច បន ភិក្ខវេ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្ប-

---

១ ទ. ចក្កវត្តិសីហនាទសុត្តំ ។

# ចក្កវត្តិសូត្រទី ៣

(៣៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ (ក្នុងដងព្រៃ) ជិតមាតុលានគរ ក្នុងដែនមគធៈ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមានខ្លួន(១)ជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃ ជាទីពឹងពំនាក់ឡើយ ចូរមានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ កុំមានរបស់ដទៃ ជាទីពឹងពំនាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹងពំនាក់តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ ជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកំដៅនូវ

---

១ អដ្ឋកថា ថា លោកិយធម៌នឹងលោកុត្តរធម៌ ឈ្មោះថា ខ្លួន ។ ព្រោះហេតុនោះបាន ជាទ្រង់ពោលថែមទៀតថា ចូរមានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ កុំមានរបស់ដទៃ ជាទីពឹងពំនាក់ឡើយ ។

ជានោ សតិមា វិនេយ្យលោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ វេទនានុបស្សី ៗ ចិត្តេ ចិត្តានុបស្សី ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យលោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។ គោចរេ ភិក្ខវេ ចរថ សកេ បេត្តិកេ វិសយេ ។ គោចរេ ភិក្ខវេ ចរតំ សកេ បេត្តិកេ វិសយេ ន លច្ឆតិ មារោ ឱតារំ ន លច្ឆតិ មារោ អារម្មណំ ។ កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតិ(១) ។

---

១ ឱ. បវឌ្ឍតីតិ ។

កិលេសមានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់នូវអភិជ្ឈានឹងទោមនស្ស ក្នុងលោកបាន ។ ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី ។ ពិចារណានូវចិត្ត ក្នុងចិត្តជាប្រក្រតី ។ ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កំចាត់បង់នូវអភិជ្ឈានឹងទោមនស្ស ក្នុងលោកបាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ហៅថា ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រព្រឹត្តក្នុងគោចរជាវិស័យ ដែលមានមកអំពីបិតារបស់ខ្លួន។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយប្រព្រឹត្ត ក្នុងគោចរជាវិស័យ ដែលមានមកអំពីបិតារបស់ខ្លួន[១] មារ[២]ក៏មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុណ្យនេះ រមែងចំរើនឡើង ព្រោះហេតុសមាទាន នូវកុសលធម៌ទាំងឡាយ យ៉ាងនេះ ។

---

១ ជាដំណែលរបស់ព្រះសម្មាសម្ពុទ្ធ ជាបិតានៃពុទ្ធបរិស័ទ ។ ២ អដ្ឋកថា សំដៅយកតែទេវបុត្តមារនឹងកិលេសមារប៉ុណ្ណោះ ។

[៣៤] ភូតបុព្វំ ភិក្ខវេ រាជា ទឡ្ហនេមិ នាម អហោសិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ ។ តស្សិមានិ សត្ត រតនានិ អហេសុំ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ ។ បរោសហស្សំ ខោ បនស្ស បុត្តា អហេសុំ សូរា វីរង្គរូបា បរសេនប្បមទ្ទនា ។ សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន សមេន(១) អភិវិជិយ អជ្ឈាវសិ ។ អថខោ ភិក្ខវេ រាជា ទឡ្ហនេមិ ពហុន្នំ វស្សានំ ពហុន្នំ វស្សសតានំ ពហុន្នំ វស្សសហស្សានំ អច្ចយេន អញ្ញតរំ បុរិសំ អាមន្តេសិ យទា ត្វំ អម្ភោ បុរិស បស្សេយ្យាសិ ទិព្វំ ចក្ករតនំ ឱសក្កិតំ ឋានា ចុតំ អថ មេ អារោចេយ្យាសីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សោ បុរិសោ

១ ឱ. សមេនាតិ ន ទិស្សតិ ។

## បក្កវិសូត្រ រឿងស្តេចចក្រពត្តិព្រះនាមទឡ្ហនេមិ រ័តន៍ ៧ ប្រការ

(៧៤) ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានព្រះរាជា (ព្រះអង្គ) ទ្រង់ព្រះនាមទឡ្ហនេមិ ជាស្តេចចក្រពត្តិ ព្រះអង្គជាធម្មិក-ធម្មរាជ ជាឥស្សរៈលើផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវថិរភាព (សេចក្តីមាំមួន) ទ្រង់បរិបូណ៌ ដោយរ័តន៍ទាំង ៧ ប្រការ ។ ឯរ័តន៍ទាំង ៧ ប្រការ របស់ព្រះបាទទឡ្ហនេមិនោះគឺ ចក្ករ័តន៍ (ចក្រកែវ) ១ ហត្ថិរ័តន៍ (ដំរីកែវ) ១ អស្សរ័តន៍ (សេះកែវ) ១ មណីរ័តន៍ (កែវមណី) ១ ឥត្ថីរ័តន៍ (ស្រីកែវ) ១ គហបតីរ័តន៍ (គហបតីកែវ) ១ បរិនាយករ័តន៍ (នាយពលកែវ) ១ រួមត្រូវជា ៧ ប្រការ ។ ឯព្រះបាទទឡ្ហនេមិនោះ មានព្រះរាជបុត្រច្រើនជាងពាន់ សុទ្ធសឹងតែក្លៀវក្លា អង់អាច អាចសង្កត់សង្កិន នូវសេនារបស់ស្តេចដទៃបាន ។ ព្រះបាទទឡ្ហនេមិនោះ ទ្រង់គ្រួតត្រាគ្រប់គ្រងផែនដី ដែលមានសាគរ ជាព្រំប្រទល់នេះ ដោយធម៌ដ៏ស្មើ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ ។ ម្នាលភិក្ខុទាំងឡាយ លុះកាលកន្លងទៅបានច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ទើបព្រះបាទទឡ្ហនេមិ ទ្រង់ត្រាស់នឹងបុរសម្នាក់ថា ម្នាលបុរសដ៏ចំរើន (បើ) អ្នកឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតចាកទីតាំងកាលណា អ្នកត្រូវប្រាប់ដល់យើងក្នុងកាលនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះទទួល

រញ្ញោ ទឡ្ហនេមិស្ស[១] បច្ចស្សោសិ ។ អទ្ទសា ខោ ភិក្ខវេ សោ បុរិសោ ពហុន្នំ វស្សានំ ពហុន្នំ វស្សសតានំ ពហុន្នំ វស្សសហស្សានំ អច្ចយេន ទិព្វំ ចក្ករតនំ ឱសក្កិតំ ឋានា ចុតំ ទិស្វាន[២] យេន រាជា ទឡ្ហនេមិ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ ទឡ្ហនេមឹ ឯតទវោច យគ្ឃេ ទេវ ជានេយ្យាសិ ទិព្វន្តេ ចក្ករតនំ ឱសក្កិតំ ឋានា ចុតន្តិ ។ អថខោ ភិក្ខវេ រាជា ទឡ្ហនេមិ ជេដ្ឋបុត្តំ កុមារំ អាមន្តេត្វា ឯតទវោច ទិព្វំ កិរ មេ តាត កុមារ ចក្ករតនំ ឱសក្កិតំ ឋានា ចុតំ សុតំ ខោ បនេតំ យស្ស រញ្ញោ ចក្កវត្តិស្ស ទិព្វំ ចក្ករតនំ ឱសក្កតិ ឋានា ចវតិ ន ទានិ តេន រញ្ញា ចិរំ ជីវិតព្វំ ហោតីតិ ភុត្តា ខោ បន មេ មានុសកា កាមា សមយោ ទានិ មេ ទិព្វេ[៣] កាមេ បរិយេសិតុំ ឯហិ ត្វំ តាត កុមារ ឥមំ សមុទ្ទបរិយន្តំ បឋវឹ បដិបជ្ជ អហំ បន កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សាមីតិ ។

---

១ ឱ. ទឡ្ហនេមិកស្ស ។ ២ ឱ. ទិស្វា ។ ៣ ឱ. សមយោ ទិព្វេ ។

ស្តាប់ព្រះរាជឱង្ការនៃព្រះបាទទឡ្ហនេមិថា ព្រះករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ លុះកាលកន្លងទៅ បានច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ បុរសនោះបានឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតចាកទី ក៏ចូលទៅគាល់ព្រះបាទទឡ្ហនេមិ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះបាទទឡ្ហនេមិដូច្នេះថា សូមព្រះរាជតេជះដម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប (ដឹង) ចក្ករ័តន៍ជាទិព្វ របស់ព្រះអង្គឃ្លាតច្យុតចាកទីហើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទទឡ្ហនេមិ ទ្រង់ហៅព្រះរាជកុមារជាបុត្រច្បងមកហើយ ទ្រង់ត្រាស់ដូច្នេះថា ម្នាលកុមារមាសឪពុក ឮថា ចក្ករ័តន៍ជាទិព្វរបស់យើង ឃ្លាតច្យុតចាកទីហើយ សេចក្តីនេះ ឪពុកធ្លាប់ឮថា (បើ) ចក្ករ័តន៍ជាទិព្វរបស់ស្តេចចក្រពត្តិអង្គណា ឃ្លាតច្យុតចាកទីហើយ តពីនោះមក ស្តេចអង្គនោះ មិនរស់នៅបានយូរឡើយ ឯកាមជារបស់មនុស្ស ឪពុកបានបរិភោគ (ឆ្អែតស្កប់ស្កល់ហើយ) សម័យនេះ ជាសម័យដែលឪពុកគួរស្វែងរកកាម ជាទិព្វវិញ ម្នាលកុមារមាសឪពុក ចូរអ្នកគ្រប់គ្រងផែនដី ដែលមានសមុទ្រ ជាព្រំប្រទល់នេះចុះ ឯឪពុកនឹងកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់កាសាវពស្ត្រចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។

អថខោ ភិក្ខវេ រាជា ទឡ្ហនេមិ ជេដ្ឋបុត្តំ កុមារំ សា-
ធុកំ រជ្ជេ សមនុសាសេត្វា កេសមស្សុំ ឱហារេត្វា
កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ
បព្វជិ ។ សត្តាហំ បព្វជិតេ ខោ បន ភិក្ខវេ
រាជិសិម្ហិ ទិព្វំ ចក្ករតនំ អន្តរធាយិ ។

(៣៨) អថខោ ភិក្ខវេ អញ្ញតរោ បុរិសោ យេន
រាជា ខត្តិយោ មុទ្ធាវសិត្តោ[១] តេនុបសង្កមិ ឧបសង្ក-
មិត្វា រាជានំ ខត្តិយំ មុទ្ធាវសិត្តំ ឯតទវោច យគ្ឃេ
ទេវ ជានេយ្យាសិ ទិព្វំ ចក្ករតនំ អន្តរហិតន្តិ ។
អថខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ ទិព្វេ
ចក្ករតនេ អន្តរហិតេ អនត្តមនោ អហោសិ អនត្ត-
មនតញ្ច បដិសំវេទេសិ ។ សោ យេន[២] រាជិសិ
តេនុបសង្កមិ ឧបសង្កមិត្វា រាជិសឹ ឯតទវោច យគ្ឃេ

---

១ មុទ្ធាភិសិត្តោតិ កត្ថចិ បោត្ថកេ ទិស្សតិ ២ ឱ. យេន ប ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទទឡ្ហនេមិ ទ្រង់ឲ្យហៅព្រះរាជកុមារ ជាបុត្រច្បង ឲ្យគ្រប់គ្រងរាជសម្បត្តិ ដោយប្រពៃហើយក៏ទ្រង់ដាក់ព្រះកេសា នឹងព្រះមស្សុ ទ្រង់ស្លៀកដណ្តប់កាសាវពស្ត្រ ចេញចាកព្រះរាជាគារ ស្ដេចទៅកាន់ផ្នួស ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះរាជឥសី ទើបនឹងទ្រង់ព្រះផ្នួសបាន៧ថ្ងៃ ចក្ករ័តន៍ជាទិព្វបាត់ទៅ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ មានបុរសម្នាក់ចូលទៅគាល់ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ លុះចូលទៅដល់ក៏ក្រាបបង្គំទូលព្រះរាជា ជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប (ផ្សិត) ចក្ករ័តន៍ជាទិព្វបាត់ទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង កាលបើចក្ករ័តន៍ជាទិព្វបាត់ទៅ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ក៏តូចព្រះហឫទ័យ នឹងសោយនូវសេចក្ដីមិនសប្បាយព្រះហឫទ័យ ។ ព្រះមហាក្សត្រិយ៍អង្គនោះ ក៏ចូលទៅគាល់ព្រះរាជឥសី លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះរាជឥសីដូច្នេះថា សូមព្រះ

ទេវ ជានេយ្យាសិ ទិព្វំ ចក្ករតនំ អន្តរហិតន្តិ ។ ឯវំ វុត្តេ ភិក្ខវេ រាជិសិ រាជានំ ខត្តិយំ មុទ្ធាវសិត្តំ ឯតទវោច មា ខោ ត្វំ តាត ទិព្វេ ចក្ករតនេ អន្តរហិតេ អនត្តមនោ អហោសិ អនត្តមនតញ្ច បដិសំវេទេសិ ន ហិ តេ តាត ទិព្វំ ចក្ករតនំ បេត្តិកំ ទាយជ្ជំ ឥង្ឃ ត្វំ តាត អរិយេ ចក្កវត្តិវត្តេ វត្តាហិ ឋានំ ខោ បនេតំ វិជ្ជតិ យំ តេ អរិយេ ចក្កវត្តិវត្តេ វត្តមានេ តទហុបោសថេ បណ្ណរសេ សីសនហាតស្ស[1] ឧបោសថិកស្ស ឧបរិបាសាទ-វរគតស្ស ទិព្វំ ចក្ករតនំ បាតុភវិស្សតិ សហស្សារំ សនេមិកំ សនាភិកំ សព្វាការបរិបូរន្តិ ។ កតមំ បនេតំ ទេវ អរិយំ ចក្កវត្តិវត្តន្តិ ។ តេនហិ ត្វំ តាត ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ មានេន្តោ ធម្មំ បូជេន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ

---

១ ឱ. សីសំ នហាតស្ស ។

រាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប (ដ្បិត) ចក្ករតនៈជាទិព្វបាត់ទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រិយ៍ក្រាបបង្គំទូលយ៉ាងនេះ ព្រះរាជឥសីទ្រង់ត្រាស់នឹងព្រះរាជា ជាក្សត្រ ដែលបានមុទ្ធាភិសេកហើយដូច្នេះថា ម្នាលបា កាលបើចក្ករតនៈជាទិព្វបាត់ទៅ អ្នកកុំមានសេចក្ដីតូចចិត្ត កុំសោយនូវសេចក្ដីមិនសប្បាយចិត្តឡើយ ម្នាលបា ព្រោះថា ចក្ករតនៈជាទិព្វនេះ មិនមែនជាមត៌ក ដែលមានមកអំពីបិតាអ្នកទេ ម្នាលបា ណ្ហើយចុះ អ្នកចូរប្រព្រឹត្តចក្កពត្តិវត្ត (វត្តរបស់ស្ដេចចក្រពត្តិ) ដ៏ប្រសើរវិញចុះ កាលបើចក្កពត្តិវត្ត ដែលអ្នកប្រព្រឹត្តហើយ ចក្ករតនៈជាទិព្វ មានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ បរិបូណ៌ ដោយអាការសព្វគ្រប់ នឹងកើតប្រាកដដល់បា ដែលកក់កេសាហើយរក្សាឧបោសថ បិតនៅលើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថនោះ ហេតុនេះ រមែងមានប្រាកដ ។ ព្រះមហាក្សត្រក្រាបបង្គំទូលសួរថា បពិត្រព្រះសម្មតិទេព ចុះចក្កពត្តិវត្តដ៏ប្រសើរនុ៎ះ តើដូចម្ដេច ។ ព្រះរាជឥសីត្រាស់ថា ម្នាលបា បើដូច្នោះ ចូរអ្នកអាស្រ័យនូវធម៌តែម្យ៉ាង ហើយធ្វើសក្ការៈចំពោះធម៌ គោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាស្លាក យកធម៌ជាអធិបតី

## ចក្កវត្តិសុត្តេ ចក្កវត្តិវត្តកថា

ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហស្សុ អន្តោជនស្មឹ ពលកាយស្មឹ ខត្តិយេសុ អនុយន្តេសុ ព្រាហ្មណ-គហបតិកេសុ នេគមជានបទេសុ សមណព្រាហ្ម-ណេសុ មិគបក្ខីសុ មា ច(១) តេ តាត វិជិតេ អធម្មការោ បវត្តិត្ថ យេ ច តេ តាត វិជិតេ អធនា(២) តេសញ្ច ធនំ អនុប្បទេយ្យាសិ(៣) យេ ច តេ តាត វិជិតេ សមណព្រាហ្មណា មទប្បមាទា បដិវិរតា ខន្តិសោរច្ចេ និវិដ្ឋា ឯកមត្តានំ ទមេន្តិ ឯកមត្តានំ សមេន្តិ ឯកមត្តានំ បរិនិព្ពាបេន្តិ តេ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆេយ្យាសិ បរិបញ្ហេយ្យាសិ(៤) កឹ ភន្តេ កុសលំ កឹ ភន្តេ(៥) អកុសលំ កឹ សាវជ្ជំ កឹ អនវជ្ជំ កឹ សេវិ-តព្វំ កឹ ន សេវិតព្វំ កឹ មេ ករិយមានំ

---

១ ឱ. ម. ក ។ ២ ឱ អធនា អស្សុ ។ ៣ ម. ធនមនុប្បទេយ្យាសិ ។ ៤ ឱ. បរិបញ្ហេយ្យាសីតិ ន ទិស្សតិ ។ ម. បរិគ្គណ្ហេយ្យាសិ ។ ៥ ឱ ម ភន្តេតិ ន ទិស្សតិ ។

## ចក្កវត្តិសូត្រ ពោលអំពីចក្កវត្តិវត្ត

ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រង ប្រកបដោយធម៌ ចំពោះជនខាងក្នុង គឺបុត្រភរិយា ចំពោះពួកពល ពួកក្សត្រិយ៍ ពួកជនចុះចូល ពួកព្រាហ្មណ៍ គហបតី ពួកអ្នកនិគម អ្នកជនបទ ពួកសមណព្រាហ្មណ៍ និងពួកម្រឹគ បក្សី ម្នាលបា អ្នកកុំធ្វើអកុសលធម៌ ក្នុងដែនរបស់អ្នកឡើយ ម្នាលបា បើពួកជនណាក្នុងដែនរបស់អ្នក មិនមានទ្រព្យ អ្នកគប្បីផ្តល់ទ្រព្យដល់ជនទាំងនោះ ម្នាលបា បើពួកសមណព្រាហ្មណ៍ណា ក្នុងដែនរបស់អ្នក ជាអ្នកវៀរចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ តាំងនៅក្នុងខន្តិនិងសោរច្ចៈ តែងទូន្មានខ្លួនឯងតែម្នាក់ឯង ធ្វើខ្លួនឯងឲ្យស្ងប់រម្ងាប់តែម្នាក់ឯង ធ្វើខ្លួនឯងឲ្យរលត់ (ចាករគាទិក្កិលេស) តែម្នាក់ឯង អ្នកគប្បីចូលទៅរកសមណព្រាហ្មណ៍ ទាំងនោះសព្វៗកាល ហើយគប្បីសាកសួរ គប្បីចោទដណ្តឹងថា បពិត្រលោកដ៏ចំរើន អ្វីជាកុសល បពិត្រលោកចំរើន អ្វីជាអកុសល អ្វីជាអំពើប្រកបដោយទោស អ្វីជាអំពើមិនប្រកបដោយទោស អ្វីគួរសេព អ្វីមិនគួរសេព អំពើដូចម្តេច ដែលខ្ញុំធ្វើទៅហើយ

ទីឃរត្តំ អហិតាយ ទុក្ខាយ អស្ស កឹ វា បន មេ ករិយមានំ ទីឃរត្តំ ហិតាយ សុខាយ អស្សាតិ តេសំ សុត្វា យំ អកុសលំ តំ អភិនិវជ្ជេយ្យាសិ យំ កុសលំ តំ សមាទាយ វត្តេយ្យាសិ ឥទំ ខោ តាត តំ អរិយំ ចក្កវត្តិវត្តន្តិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ រាជិសិស្ស បដិស្សុត្វា អរិយេ ចក្កវត្តិវត្តេ វត្តតិ(១) ។ តស្ស អរិយេ ចក្កវត្តិវត្តេ វត្តមានស្ស តទហុបោសថេ បណ្ណរសេ សីសនហា-តស្ស ឧបោសថិកស្ស ឧបរិបាសាទវរគតស្ស ទិព្វំ ចក្ករតនំ បាតុរហោសិ សហស្សារំ សនេមិកំ សនា-ភិកំ សព្វាការបរិបូរំ ។ ទិស្វា(២) រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ឯតទហោសិ សុតំ ខោ បន មេតំ

---

១ ម. អរិយំ ចក្កវត្តិវត្តំ វត្តី ។ ឧ. វត្តិ ។ ២ ម. ទិស្វាន ។

មិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែង មួយទៀត អំពើដូចម្តេច ដែលខ្ញុំធ្វើទៅហើយ ជាប្រយោជន៍ ជាសុខអស់កាលយូរអង្វែង លុះអ្នកបានស្តាប់ពាក្យសមណព្រាហ្មណ៍ ទាំងនោះហើយ គប្បីវៀរនូវអំពើដែលជាអកុសល ហើយសមាទានប្រព្រឹត្តនូវអំពើ ដែលជាកុសល ម្នាលបា នេះឯង ជាចក្កពត្តិវត្តដ៏ប្រសើរនោះ ៗ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ បានទទួលស្តាប់ពាក្យព្រះរាជឥសីថា ព្រះករុណាថ្លៃវិសេស ហើយក៏ប្រព្រឹត្តចក្កពត្តិវត្តដ៏ប្រសើរ ៗ កាលដែលព្រះរាជានោះ កំពុងប្រព្រឹត្តចក្កពត្តិវត្តដ៏ប្រសើរ កក់ព្រះកេសា សមាទានឧបោសថ ហើយស្តេចទៅខាងលើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃទី ១៥ ដែលជាថ្ងៃឧបោសថនោះ ចក្ករ័តន៍ជាទិព្វមានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ បរិបូណ៌ដោយអាការសព្វគ្រប់ក៏កើតប្រាកដឡើង ៗ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកទ្រង់ទតឃើញហើយ ទ្រង់ព្រះរាជតម្រិះថា អាត្មាអញ បានឮមកដូច្នេះថា

យស្ស រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស តទហុបោសថេ បណ្ណរសេ សីសនហាតស្ស ឧបោសថិកស្ស ឧបរិបាសាទវរគតស្ស ទិព្វំ ចក្ករតនំ បាតុភវតិ សហស្សារំ សនេមិកំ សនាភិកំ សព្វាការបរិបូរំ សោ ហោតិ រាជា ចក្កវត្តីតិ អស្សំ នុ ខោ អហំ រាជា ចក្កវត្តីតិ ។

(៣៦) អថខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា វាមេន ហត្ថេន ភិង្ការំ(១) គហេត្វា ទក្ខិណេន ហត្ថេន ចក្ករតនំ អព្ភុក្កិរិ បវត្តតុ ភវំ ចក្ករតនំ អភិវិជិនាតុ ភវំ ចក្ករតនន្តិ ។ អថខោ តំ ភិក្ខវេ ចក្ករតនំ បុរត្ថិមំ ទិសំ បវត្តិ(២) ។ អន្វទេវ រាជា ចក្កវត្តិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យស្មឹ ខោ បន ភិក្ខវេ បទេសេ ចក្ករតនំ បតិដ្ឋាសិ តត្ថ រាជា ចក្កវត្តិ វាសំ ឧបគច្ឆិ(៣) សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យេ ខោ បន ភិក្ខវេ បុរត្ថិមាយ ទិសាយ បដិរាជានោ

---

១ ឱ. ម. ភិង្ការំ ។ ២ បវត្តីតិបិ បាឋោ ។ ៣ ឧបគញ្ឆីតិ វា បាឋោ ។

ចក្ករ័តន៍ជាទិព្វ មានកាំ១ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ បរិបូណ៌ ដោយអាការគ្រប់យ៉ាង កើតប្រាកដឡើង ដល់ព្រះរាជាជាក្សត្រិយ៍អង្គណា ដែលបានមុទ្ធាភិសេកហើយ កក់ព្រះកេសា សមាទានឧបោសថ ស្តេចទៅខាងលើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃទី ១៥ ដែលជាថ្ងៃឧបោសថ នោះ ព្រះរាជាអង្គនោះ ទើងជាស្តេចចក្រពត្តិ ឬហ្ន៎ ! អាត្មាអញប្រាកដជាស្តេចចក្រពត្តិហើយតើ ។

(៣៦) ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ ទ្រង់ក្រោកអំពីអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ទើបយកព្រះហស្តខាងឆ្វេង កាន់កុណ្ឌី យកព្រះហស្តខាងស្តាំ ប្រស់ព្រំចក្ករ័តន៍ ហើយអធិដ្ឋានថា សូមឲ្យចក្ករ័តន៍ដ៏ចំរើនប្រព្រឹត្តទៅ សូមឲ្យចក្ករ័តន៍ដ៏ចំរើន មានជ័យជំនះចុះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ចក្ករ័តន៍នោះក៏អណ្តែតត្រសែត ទៅកាន់ទិសខាងកើត ។ ទើបព្រះបាទចក្រពត្តិ ស្តេចទៅតាម (ចក្ករ័តន៍នោះ) ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករ័តន៍ទៅប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រពត្តិ ក៏ស្តេចចូលទៅតាំងព្រះរាជនិវេសន៍ក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងស្តេច ជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាង

តេ រាជានំ ចក្កវត្តិំ ឧបសង្កមិត្វា ឯវមាហំសុ ឯហិ ខោ មហារាជ ស្វាគតំ(១) មហារាជ សកន្តេ មហារាជ អនុសាស មហារាជាតិ ។ រាជា ចក្កវត្តិ ឯវមាហ បាណោ ន ហន្តព្វោ អទិន្នំ នាទាតព្វំ កាមេសុ មិច្ឆា ន ចរិតព្វា មុសា ន ភាសិតព្វា មជ្ជំ ន បាតព្វំ យថាភុត្តញ្ច ភុញ្ជថាតិ ។ យេ ខោ បន ភិក្ខវេ បុរត្ថិមាយ ទិសាយ បដិរាជានោ តេ រញ្ញោ ចក្កវត្តិស្ស អនុយន្តា(២) អហេសុំ ។ អថខោ តំ ភិក្ខវេ ចក្ករតនំ បុរត្ថិមំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា ទក្ខិណំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា បច្ឆិមំ ទិសំ បវត្តិ ។ អន្វទេវ រាជា ចក្កវត្តិ សទ្ធិំ ចតុរង្គិនិយា សេនាយ ។ យស្មឹ ខោ បន ភិក្ខវេ បទេសេ ចក្ករតនំ បតិដ្ឋាសិ តត្ថ រាជា ចក្កវត្តិ វាសំ ឧបគច្ឆិ សទ្ធិំ ចតុរង្គិនិយា សេនាយ ។

---

១ ម. ស្វាគតន្តេ ។ ២ ឱ. អនុយុត្តា ។

កើត ស្តេចទាំងនោះ ក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូល យ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចចូលមកចុះ បពិត្រមហារាជ ព្រះអង្គមានព្រះរាជដំណើរ មកស្រួលហើយ បពិត្រមហារាជ ដែនរបស់ខ្ញុំព្រះអង្គ ជាដែនរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិ មានព្រះបន្ទូល ( ប្រដៅ ) យ៉ាងនេះថា អ្នកទាំងឡាយមិនត្រូវសម្លាប់សត្វ មិនត្រូវលួចទ្រព្យ ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ ចូរបរិភោគតែរបស់ ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងកើត ស្តេចទាំងនោះ ក៏ទៅជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ចក្ករ័តន៍នោះក៏ចុះកាន់សមុទ្រ ក្នុងទិសខាងកើត រួចឆ្លងឡើងចុះទៅកាន់សមុទ្រ ក្នុងទិសខាងត្បូង រួចឆ្លងឡើងអណ្តែតត្រសែត ទៅកាន់ទិសខាងលិច ។ ព្រះបាទចក្រពត្តិ ក៏ស្តេចទៅតាម ( ចក្ករ័តន៍នោះ ) ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករ័តន៍ទៅប្រតិស្ឋាន ក្នុងប្រទេសណា ព្រះបាទចក្រពត្តិ ក៏ស្តេចចូលទៅកាន់ទីសម្រាក ក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។

យេ ខោ បន ភិក្ខវេ បច្ឆិមាយ ទិសាយ បដិរាជានោ តេ រាជានំ ចក្កវត្តឹ ឧបសង្កមិត្វា ឯវមាហំសុ ឯហិ ខោ មហារាជ ស្វាគតំ មហារាជ សកន្តេ មហារាជ អនុសាស មហារាជាតិ ។ រាជា ចក្កវត្តិ ឯវមាហ បាណោ ន ហន្តព្វោ អទិន្នំ នាទាតព្វំ កាមេសុ មិច្ឆា ន ចរិតព្វា មុសា ន ភាសិតព្វា មជ្ជំ ន បាតព្វំ យថា-ភុត្តញ្ច ភុញ្ជថាតិ ។ យេ ខោ បន ភិក្ខវេ បច្ឆិមាយ ទិសាយ បដិរាជានោ តេ រញ្ញោ ចក្កវត្តិស្ស អនុយន្តា អហេសុំ ។ អថ ខោ តំ ភិក្ខវេ ចក្ករតនំ បច្ឆិមំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា ឧត្តរំ ទិសំ បវត្តិ ។ អន្វទេវ រាជា ចក្កវត្តិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យស្មឹ ខោ បន ភិក្ខវេ បទេសេ ចក្ករតនំ បតិដ្ឋាសិ តត្ថ រាជា ចក្កវត្តិ វាសំ ឧបគច្ឆិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។

ម្នាលភិក្ខុទាំងឡាយ ឯស្ដេចជាសឹកសត្រូវ ទាំងឡាយណា ដែលនៅក្នុងទិសខាងលិច ស្ដេចទាំងនោះ ក៏នាំគ្នាចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្ដេចចូលមកចុះ បពិត្រមហារាជ ព្រះអង្គមានព្រះរាជដំណើរ មកស្រួលហើយ បពិត្រមហារាជ ដែនរបស់ខ្ញុំព្រះអង្គ ជាដែនរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិទ្រង់មានព្រះរាជឱង្ការ (ប្រដៅ) យ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវលួចទ្រព្យ ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ ចូរបរិភោគតែរបស់ ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯស្ដេចដែលជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងលិច ស្ដេចទាំងនោះ ក៏ទៅជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ចក្ករ័តន៍នោះក៏ចុះកាន់សមុទ្រ ក្នុងទិសខាងលិច ធ្ងងឡើងអណ្ដែតត្រសែត ទៅកាន់ទិសខាងជើង ។ ព្រះបាទចក្រពត្តិក៏ស្ដេចទៅតាម (ចក្ករ័តន៍នោះ) ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករ័តន៍ទៅប្រតិស្ឋាន ក្នុងប្រទេសណា ព្រះបាទចក្រពត្តិក៏ស្ដេចចូលទៅកាន់ទីសម្រាក ក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។

យេ ខោ បន ភិក្ខវេ ឧត្តរាយ ទិសាយ បដិរាជានោ តេ រាជានំ ចក្កវត្តិំ ឧបសង្កមិត្វា ឯវមាហំសុ ឯហិ ខោ មហារាជ ស្វាគតំ មហារាជ សកន្តេ មហារាជ អនុសាស មហារាជាតិ ។ រាជា ចក្កវត្តិ ឯវមាហ បាណោ ន ហន្តព្វោ អទិន្នំ នាទាតព្វំ កាមេសុ មិច្ឆា ន ចរិតព្វា មុសា ន ភាសិតព្វា មជ្ជំ ន បាតព្វំ យថាភុត្តញ្ច ភុញ្ជថាតិ ។ យេ ខោ បន ភិក្ខវេ ឧត្តរាយ ទិសាយ បដិរាជានោ តេ រញ្ញោ ចក្កវត្តិស្ស អនុយន្តា អហេសុំ ។ អថ ខោ តំ ភិក្ខវេ ចក្ករតនំ សមុទ្ទបរិយន្តំ បឋវឹ អភិវិជិនិត្វា តមេវ រាជធានឹ បច្ចាគន្ត្វា(១) រញ្ញោ ចក្កវត្តិស្ស អន្តេបុរទ្វារេ អត្ថករណបមុខេ អក្ខាហតំ មញ្ញេ អដ្ឋាសិ រញ្ញោ ចក្កវត្តិស្ស អន្តេបុរំ ឧបសោភយមានំ ។

---

១ បច្ចាគន្ត្វាតិបិ ជាៈបឧ ភវិតព្វំ ។

ម្នាលភិក្ខុទាំងឡាយ ឯស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងជើង ស្តេចទាំងនោះ ក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូល យ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចចូលមកចុះ បពិត្រមហារាជ ព្រះអង្គមានព្រះរាជដំណើរ មកស្រួលហើយ បពិត្រមហារាជ ផែនរបស់ខ្ញុំព្រះអង្គ ជាផែនរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិទ្រង់មានព្រះរាជឱង្ការ (ប្រដៅ) យ៉ាងនេះថា អ្នកទាំងឡាយមិនត្រូវសម្លាប់សត្វ មិនត្រូវលួចទ្រព្យ ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ ចូរបរិភោគតែរបស់ ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងជើង ស្តេចទាំងនោះ ក៏ទៅជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ចក្ករតន៍នោះ ក៏បង្ក្រាបផែនដីដែលមានសមុទ្រជាព្រំប្រទល់ ហើយត្រឡប់មកកាន់ព្រះរាជធានីនោះវិញ ឋិតនៅក្នុងរបៀងនៃសាលាវិនិច្ឆ័យ ទៀបទ្វារព្រះរាជវាំង របស់ព្រះបាទចក្រពត្តិ (នៅនឹងថ្កល់) ហាក់ដូចជាបាក់ក្តៅ បំភ្លឺព្រះរាជវាំងរបស់ព្រះបាទចក្រពត្តិ ឲ្យភ្លឺព្រោងព្រាត ។

## ចក្កវត្តិសុត្តេ ទិព្វំ ចក្ករតនំ ឋានា ចុតំ

(៣៧) ទុតិយោបិ ខោ ភិក្ខវេ រាជា ចក្កវត្តិ ។ តតិយោបិ ខោ ភិក្ខវេ រាជា ចក្កវត្តិ ។ ចតុត្ថោបិ ខោ ភិក្ខវេ រាជា ចក្កវត្តិ ។ បញ្ចមោបិ ខោ ភិក្ខវេ រាជា ចក្កវត្តិ ។ ឆដ្ឋោបិ ខោ ភិក្ខវេ រាជា ចក្កវត្តិ ។ សត្តមោបិ ខោ ភិក្ខវេ រាជា ចក្កវត្តិ ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ អច្ចយេន អញ្ញតរំ បុរិសំ អាមន្តេសិ យទា ខោ ត្វំ អម្ភោ បុរិស បស្សេយ្យាសិ ទិព្វំ ចក្ករតនំ ឱសក្កិតំ ឋានា ចុតំ អថ មេ អារោចេយ្យាសីតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សោ បុរិសោ រញ្ញោ ចក្កវត្តិស្ស បច្ចស្សោសិ ។ អទ្ទសា ខោ ភិក្ខវេ សោ បុរិសោ ពហូនំ វស្សានំ ពហូនំ វស្សសតានំ ពហូនំ វស្សសហស្សានំ អច្ចយេន ទិព្វំ ចក្ករតនំ ឱសក្កិតំ ឋានា ចុតំ ទិស្វា យេន រាជា ចក្កវត្តិ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ ចក្កវត្តឹ ឯតទវោច យគ្ឃេ ទេវ ជានេយ្យាសិ ទិព្វន្តេ ចក្ករតនំ ឱសក្កិតំ ឋានា ចុតន្តិ ។ អថខោ ភិក្ខវេ រាជា ចក្កវត្តិ ជេដ្ឋបុត្តំ កុមារំ អាមន្តេត្វា

## ចក្កវត្តិសូត្រ ចក្ករ័តន៍ជាទិព្វច្យុតបាកទី

(៣៧) ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទី ២ ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទី ៣ ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទី ៤ ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទី ៥ ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទី ៦ ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទី ៧ ក្តី លុះកន្លងកាលទៅ បានច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ត្រាស់នឹងបុរសម្នាក់ថា ម្នាលបុរសដ៏ចំរើន បើអ្នកបានឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតបាកទីកាលណា អ្នកគប្បីប្រាប់ដល់យើងក្នុងកាលនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះក៏ទទួលព្រះរាជឱង្ការព្រះបាទចក្រពត្តិថា ព្រះករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ លុះកន្លងទៅ ជាច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ បុរសនោះបានឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតបាកទី ក៏ចូលទៅគាល់ស្តេចចក្រពត្តិ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះបាទចក្រពត្តិដូច្នេះថា សូមព្រះរាជតេជះដម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប (ថ្បិត) ចក្ករ័តន៍ជាទិព្វរបស់ព្រះអង្គ ឃ្លាតច្យុតបាកទីហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទចក្រពត្តិ ទ្រង់ហៅព្រះរាជកុមារជាបុត្រច្បង

ឯតទវោច ទិព្វំ កិរ មេ តាត កុមារ ចក្ករតនំ ឱសក្កិតំ ឋានា ចុតំ សុតំ ខោ បន មេតំ យស្ស រញ្ញោ ចក្កវត្តិស្ស ទិព្វំ ចក្ករតនំ ឱសក្កតិ ឋានា ចវតិ ន ទានិ តេន រញ្ញា ចិរំ ជីវិតព្វំ ហោតីតិ ភុត្តា បន(១) មេ មានុសកា កាមា សមយោ ទានិ មេ ទិព្វេ កាមេ បរិយេសិតុំ ឯហិ ត្វំ តាត កុមារ ឥមំ សមុទ្ទបរិយន្តំ បឋវឹ បដិបជ្ជ អហំ បន កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សាមីតិ ។ អថខោ ភិក្ខវេ រាជា ចក្កវត្តិ ជេដ្ឋបុត្តំ កុមារំ សាធុកំ រជ្ជេ សមនុសាសេត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិ ។ សត្តាហំ បព្វជិតេ ខោ បន ភិក្ខវេ រាជិសិម្ហិ ទិព្វំ ចក្ករតនំ អន្តរធាយិ ។

១ ម. ភុត្តា ខោ បន ។

មកហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលកុមារមាសឪពុក ឮថា ចក្ករ័តន៍ ជាទិព្វរបស់យើង ឃ្លាតចាកទីហើយ សេចក្តីនេះ ឪពុកធ្លាប់បានឮមកថា (បើ) ចក្ករ័តន៍ជាទិព្វរបស់ស្តេចចក្រពត្តិអង្គណា ឃ្លាតច្យុតចាកទីហើយ តពីនោះមក ស្តេចអង្គនោះមិនរស់នៅបានយូរឡើយ ឯកាមជារបស់មនុស្ស ឪពុកបានបរិភោគ (ឆ្អែតស្កប់ស្កល់ហើយ) សម័យនេះ ជាសម័យដែលឪពុកគួរស្វែងរកកាម ជាទិព្វវិញ ម្នាលកុមារមាសឪពុក ចូរអ្នកគ្រប់គ្រងផែនដី ដែលមានសមុទ្រ ជាព្រំប្រទល់នេះចុះ ឯឪពុកនឹងកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់កាសាវព័ស្ត្រ ចេញចាកអគារស្ថានចូលទៅកាន់ផ្នួស ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទចក្រពត្តិទ្រង់លួងលោមព្រះរាជកុមារ ជាបុត្រច្បង ឲ្យគ្រេកអរ ក្នុងរាជសម្បត្តិដោយប្រពៃ ទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ រួចទ្រង់ស្លៀកដណ្តប់កាសាវព័ស្ត្រ ចេញចាករាជាគារស្ថាន ចូលទៅទ្រង់ព្រះផ្នួស ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះរាជឥសី ទើបនឹងទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃ ចក្ករ័តន៍ជាទិព្វ ក៏បាត់ទៅ ។

(៣៨) អថខោ ភិក្ខវេ អញ្ញតរោ បុរិសោ ។បេ។ អន្តរហិតន្តិ ។ អថខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ ទិព្វេ ចក្ករតនេ អន្តរហិតេ អនត្តមនោ អហោសិ អនត្តមនតញ្ច បដិសំវេទេសិ ។ នោ ច ខោ រាជិសឹ ឧបសង្កមិត្វា អរិយំ ចក្កវត្តិវត្តំ បុច្ឆិ ។ សោ សមតេនេវ សុទំ ជនបទំ បសាសតិ តស្ស សមតេន ជនបទំ បសាសតោ ន បុព្វេនាបរំ ជនបទា បព្វន្តិ( ) យថា តំ បុព្វកានំ រាជូនំ អរិយេ ចក្កវត្តិវត្តេ វត្តមានានំ ។ អថខោ ភិក្ខវេ អមច្ចា បារិសជ្ជា គណកមហាមត្តា អនីកដ្ឋា ទោវារិកា មន្តស្សាជីវិនោ សន្និបតិត្វា រាជានំ ខត្តិយំ មុទ្ធាវសិត្តំ ឯតទវោចុំ ន ខោ តេ ទេវ

---

១ ម. បុព្វេនាបរំ ជនបទា ន បព្វត្តិ ។ ខ. បព្វត្តិ ។

## ចក្កវត្តិសូត្រ ចក្ករ័តន៍ជាទិព្វបាត់ទៅ

(៣៨) ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង បុរសម្នាក់បានក្រាបបង្គំទូលព្រះរាជា ដែលបានមុទ្ធាភិសេកហើយ ។ បេ ។ ថា ចក្ករ័តន៍ជាទិព្វបាត់ទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង កាលបើចក្ករ័តន៍ជាទិព្វបាត់ទៅ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយក៏ទ្រង់តូចព្រះហឫទ័យ នឹងសោយនូវសេចក្តីមិនសប្បាយក្នុងព្រះហឫទ័យ តែមិនចូលទៅសួរវត្តរបស់ស្តេចចក្រពត្តិដ៏ប្រសើរ នឹងព្រះរាជឥសីឡើយ ។ បានឮថា ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយនោះ ទ្រង់ប្រៀនប្រដៅអ្នកជនបទ តាមព្រះយោបល់របស់ព្រះអង្គ កាលព្រះរាជានោះប្រៀនប្រដៅអ្នកជនបទ តាមព្រះយោបល់របស់ព្រះអង្គហើយ លុះបំណោរមកខាងក្រោយ អ្នកជនបទក៏មិនចំរើនស្មើនឹងកាលមុន ដូចកាលស្តេចទាំងឡាយជាន់ដើម ដែលប្រព្រឹត្តវត្តរបស់ស្តេចចក្រពត្តិដ៏ប្រសើរនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកអាមាត្យ ពួកបរិស័ទ ពួកហោរនឹងមហាមាត្រ ពួកហ្មដំរី ពួកអ្នករក្សាទ្វារនឹងពួកជនអ្នកចិញ្ចឹមជីវិតដោយមន្ត ក៏ប្រជុំគ្នា (ចូលទៅ) ក្រាបបង្គំទូលព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយដូច្នេះថា បពិត្រព្រះសម្មតិទេព

សកេន មតិនា ជនបទំ បសាសតោ បុព្វេនាបរំ ជនបទា បប្ផន្តិ(១) យថា តំ បុព្វកានំ រាជូនំ អរិយេ ចក្កវត្តិវត្តេ វត្តមានានំ សំវិជ្ជន្តិ ខោ តេ ទេវ វិជិតេ អមច្ចា បារិសជ្ជា គណកមហាមត្តា អនីកដ្ឋា ទោវារិកា មន្តស្សាជីវិនោ មយញ្ចេវ អញ្ញេ ច យេ មយំ អរិយំ ចក្កវត្តិវត្តំ ធារេម ឥង្ឃ ត្វំ ទេវ អម្ហេ អរិយំ ចក្កវត្តិវត្តំ បុច្ឆ តស្ស តេ មយំ អរិយំ ចក្កវត្តិវត្តំ បុដ្ឋា ព្យាករិស្សាមាតិ ។

(៣៩) អថខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ អមច្ចេ បារិសជ្ជេ គណកមហាមត្តេ អនីកដ្ឋេ ទោវារិកេ មន្តស្សាជីវិនោ សន្និបាតាបេត្វា អរិយំ ចក្កវត្តិវត្តំ បុច្ឆិ ។ តស្ស តេ អរិយំ ចក្កវត្តិវត្តំ បុដ្ឋា

---

១ ឱ. ម. បព្វន្តិ ។

បានឮថា កាលព្រះអង្គទ្រង់ប្រៀនប្រដៅអ្នកជនបទ ដោយព្រះយោបល់របស់ព្រះអង្គ លុះបំណោរមកខាងក្រោយ ពួកអ្នកជនបទមិនចំរើនស្មើនឹងកាលមុន ដូចកាលព្រះរាជាទាំងឡាយជាន់ដើម ដែលប្រព្រឹត្តចក្កវត្តិវត្តដ៏ប្រសើរនោះឡើយ បពិត្រព្រះសម្មតិទេព ពួកអាមាត្យ ពួកបរិស័ទ ពួកហោរាទីនឹងមហាមាត្រ ពួកហង្វៀ ពួកអ្នករក្សាទ្វារ នឹងពួកជនអ្នកចិញ្ចឹមជីវិតដោយមន្ត្រ ទាំងពួកខ្ញុំព្រះអង្គក្តី ពួកជនដទៃក្តី ក៏មាននៅក្នុងដែនរបស់ព្រះអង្គស្រាប់ហើយ យើងខ្ញុំទាំងឡាយ (សុទ្ធតែ) ចាំស្ទាត់ នូវចក្កវត្តិវត្តដ៏ប្រសើរ បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គសូមរំលឹក សូមព្រះអង្គទ្រង់សួរ នូវចក្កវត្តិវត្តដ៏ប្រសើរ នឹងពួកខ្ញុំព្រះអង្គចុះ ពួកខ្ញុំព្រះអង្គ បើព្រះអង្គទ្រង់ត្រាស់សួរ នូវចក្កវត្តិវត្ត ដ៏ប្រសើរហើយ មុខជានឹងព្យាករបាន ៗ

(៣៩) ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ទ្រង់ត្រាស់បង្គាប់ពួកអាមាត្យ ពួកបរិស័ទ ពួកហោរាទីនឹងមហាមាត្រ ពួកហង្វៀ ពួកអ្នករក្សាទ្វារ នឹងពួកជនអ្នកចិញ្ចឹមជីវិតដោយមន្ត្រ ឲ្យប្រជុំគ្នាហើយទ្រង់សួរ នូវចក្កវត្តិវត្តដ៏ប្រសើរ ៗ ជនទាំងនោះ ដែលព្រះរាជាអង្គនោះទ្រង់សួរ នូវចក្កវត្តិវត្តដ៏ប្រសើរហើយ

## ចក្កវត្តិសុត្តេ ៖ អធនានំ ធនានុប្បទានំ

ព្យាការំសុ ។ តេសំ សុត្វា ធម្មិកញ្ហិ(១) ខោ
រក្ខាវរណគុត្តឹ សំវិទហិ នោ ច ខោ អធនានំ
ធនមនុប្បទាសិ ។ អធនានំ ធនេ នានុប្បទិ-
យមានេ ទាឡិទ្ទិយំ(២) វេបុល្លំ អគមាសិ ។
ទាឡិទ្ទិយេ វេបុល្លំ គតេ អញ្ញតរោ បុរិសោ បរេសំ
អទិន្នំ ថេយ្យសង្ខាតំ អាទិយិ ។ តមេនំ អគ្គហេ-
សុំ គហេត្វា រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស
ទស្សេសុំ អយំ ទេវ បុរិសោ បរេសំ អទិន្នំ ថេយ្យ-
សង្ខាតំ អាទិយីតិ ។ ឯវំ វុត្តេ ភិក្ខវេ រាជា
ខត្តិយោ មុទ្ធាវសិត្តោ តំ បុរិសំ ឯតទវោច សច្ចំ
កិរ ត្វំ អម្ភោ បុរិស បរេសំ អទិន្នំ ថេយ្យ-
សង្ខាតំ អាទិយសីតិ(៣) ។ សច្ចំ ទេវាតិ ។

---

១ ឱ. ធម្មិកំ ហិ ។ ២ ឱ. ទឡ្ឡិយំ ។ ៣ ឱ. អាទិយីតិ ។

ក៏បានព្យាករថ្វាយ ។ លុះព្រះរាជា ទ្រង់ព្រះសវនាការពាក្យព្យាករណ៍ របស់ជនទាំងនោះហើយ ទើបទ្រង់ចាត់ចែងនូវការរក្សា ទប់ទល់គ្រប់គ្រង ប្រកបដោយធម៌វិញ តែទ្រង់មិនបានព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្សត់ទ្រព្យឡើយ ។ កាលបើ ព្រះរាជទ្រព្យ ដែលទ្រង់មិនបានព្រះរាជ-ទានដល់ពួកអ្នកខ្សត់ទ្រព្យ សេចក្ដីទ័លក្រ ក៏មានច្រើនឡើង ។ កាលបើសេចក្ដីទ័លក្រ មានច្រើនឡើងហើយ មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ពួករាជបុរស ចាប់បុរសនោះបាន នាំយកទៅថ្វាយព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះកាន់យកទ្រព្យ របស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួករាជបុរស ក្រាបបង្គំទូលយ៉ាងនេះ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ទ្រង់ត្រាស់សួរបុរសនោះដូច្នេះថា នែបុរស អ្នកឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិតមែនឬ ។ បុរសនោះ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។

កឹការណាតិ ។ ន ហិ ទេវ ជីវាមីតិ ។ អថខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ តស្ស បុរិសស្ស ធនមនុប្បទាសិ ឥមិនា ត្វំ អម្ភោ បុរិស ធនេន អត្តនា ច ជីវាហិ មាតាបិតរោ ច បោសេហិ បុត្តទារញ្ច បោសេហិ កម្មន្តេ(១) បយោជេហិ សមណេសុ ព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋបេហិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកន្តិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សោ បុរិសោ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស បច្ចស្សោសិ ។ អញ្ញតរោបិ ខោ ភិក្ខវេ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយិ ។ តមេនំ អគ្គហេសុំ គហេត្វា រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ទស្សេសុំ អយំ ទេវ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយីតិ ។

១ ឱ. ម. កម្មន្តេ ច ។

ព្រះរាជាទ្រង់ត្រាស់សួរថា ព្រោះហេតុអ្វី (បានជាអ្នកលួចទ្រព្យគេ) ។ បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រោះខ្ញុំព្រះអង្គមិនមាន (របស់អ្វី) នឹងចិញ្ចឹមជីវិត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់បុរសនោះ រួចទ្រង់ត្រាស់បង្គាប់ថា ម្នាលបុរសដ៏ចំរើន អ្នកចូរយកទ្រព្យនេះទៅចិញ្ចឹមជីវិតខ្លួនផង ចិញ្ចឹមមាតាបិតាផង ចិញ្ចឹមបុត្តភរិយាផង ប្រកបការងារផង ចូរតម្កល់ទក្ខិណាទាន ដែលមានផលខ្ពង់ខ្ពស់ ចំពោះសមណព្រាហ្មណ៍ទាំងឡាយ ជាទានអាចនាំសត្វឲ្យកើត ក្នុងឋានសួគ៌ មានផលជាសុខ ប្រព្រឹត្តទៅ ដើម្បីកើតក្នុងឋានសួគ៌ផងចុះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះក៏ទទួលព្រះរាជឱង្ការ នៃព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ មានបុរសម្នាក់ទៀត កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលគេហៅថា លួច ។ ពួករាជបុរសចាប់បុរសនោះបាន ក៏នាំយកទៅថ្វាយព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថាលួច ។

ឯវំ វុត្តេ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ តំ(១) បុរិសំ ឯតទវោច សច្ចំ កិរ ត្វំ អម្ភោ បុរិស បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយសីតិ ។ សច្ចំ ទេវាតិ ។ កឹការណាតិ ។ ន ហិ ទេវ ជីវាមីតិ ។ អថខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ តស្ស បុរិសស្ស ធនមនុប្បទាសិ ឥមិនា ត្វំ អម្ភោ បុរិស ធនេន អត្តនា ច ជីវាហិ មាតាបិតរោ ច បោសេហិ បុត្តទារញ្ច បោសេហិ កម្មន្តេ បយោជេហិ សមណេសុ ព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋបេហិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកន្តិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ សោ(២) បុរិសោ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស បច្ចស្សោសិ ។ អស្សោសុំ ខោ ភិក្ខវេ

---

១ ឱ. តត្ថ ន ទិស្សតិ ។ ២ ខ. ខោ សោ ភិក្ខវេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើពួករាជបុរស ក្រាបបង្គំទូល យ៉ាងនេះហើយ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ត្រាស់សួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចំរើន អ្នកឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិតមែនឬ ។ បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។ ព្រះរាជាទ្រង់ត្រាស់សួរថា ព្រោះហេតុអ្វី (បានជាអ្នកឯងលួចទ្រព្យគេ) ។ បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រោះខ្ញុំព្រះអង្គ មិនមាន (របស់អ្វី) នឹងចិញ្ចឹមជីវិត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់បុរសនោះ រួចទ្រង់ត្រាស់បង្គាប់ថា ម្នាលបុរសដ៏ចំរើន អ្នកចូរយកទ្រព្យនេះ ទៅចិញ្ចឹមជីវិតខ្លួនឯងផង ចិញ្ចឹមមាតាបិតាផង ចិញ្ចឹមបុត្រភរិយាផង ប្រកបការងារផង ចូរដំកល់ទក្ខិណាទានដែលមានផលខ្ពង់ខ្ពស់ ចំពោះសមណព្រាហ្មណ៍ទាំងឡាយ ជាទានអាចនាំសត្វឲ្យកើត ក្នុងឋានសួគ៌ មានផលជាសុខ ប្រព្រឹត្តទៅ ដើម្បីកើតក្នុងឋានសួគ៌ផងចុះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះក៏ទទួលព្រះរាជឱង្ការ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ដោយពាក្យថា ព្រះ.ករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សបានឮដំណឹងថា

មនុស្សា យេ កេចិ លោកេ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយន្តិ តេសំ រាជា អនុប្បទេតីតិ(១) ។ សុត្វាន តេសំ ឯតទហោសិ យន្នូន មយំបិ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយេយ្យាមាតិ ។

[៨០] អថខោ ភិក្ខវេ អញ្ញតរោ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយិ ។ តមេនំ អគ្គហេសុំ គហេត្វា រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ទស្សេសុំ អយំ ទេវ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយីតិ ។ ឯវំ វុត្តេ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ តំ បុរិសំ ឯតទវោច សច្ចំ កិរ ត្វំ អម្ភោ បុរិស បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយសីតិ ។ សច្ចំ ទេវាតិ ។

---

១ ឱ. ធនមនុប្បទេសីតិ ។

ព្រះរាជាទ្រង់ព្រះរាជទាន នូវព្រះរាជទ្រព្យ ដល់ពួកមនុស្ស ដែលកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យដែលហៅថា លួច ។ លុះមនុស្សទាំងនោះបានឮហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នោះ មានតែពួកយើងនាំគ្នា ទៅកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច (កុំខាន) ។

(៤០) ម្នាលភិក្ខុទាំងឡាយ លុះគ្រាជាខាងក្រោយមក មានបុរសម្នាក់កាន់យកទ្រព្យ របស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ពួករាជបុរសចាប់បុរសនោះបាន ក៏នាំយកទៅថ្វាយព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះឯង កាន់យកទ្រព្យ របស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួករាជបុរស ក្រាបបង្គំទូល យ៉ាងនេះហើយ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ត្រាស់សួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចំរើន អ្នកឯងកាន់យកទ្រព្យ របស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិតមែនឬ ។ បុរសនោះ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។

កឹការណាតិ ។ ន ហិ ទេវ ជីវាមីតិ ។ អថ ខោ ភិក្ខវេ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ឯតទហោសិ សចេ ខោ អហំ យោ យោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយិស្សតិ តស្ស តស្ស ធនមនុប្បទស្សាមិ(១) ឯវមិទំ អទិន្នាទានំ បវឌ្ឍិស្សតិ យន្នូនាហំ ឥមំ បុរិសំ សុនិសេធំ និសេធេយ្យ មូលឃច្ចំ(២) ករេយ្យំ សីសមស្ស ឆិន្ទេយ្យន្តិ ។ អថ ខោ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ បុរិសេ អាណាបេសិ តេនហិ ភណេ ឥមំ បុរិសំ ទឡ្ហាយ រជ្ជុយា បច្ឆាពាហុំ(៣) គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខមិត្វា ទក្ខិណតោ នគរស្ស សុនិសេធំ និសេធេថ មូលឃច្ចំ ករោថ សីសមស្ស ឆិន្ទថាតិ ។ ឯវំ ទេវាតិ ខោ ភិក្ខវេ តេ បុរិសា រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស បដិស្សុត្វា តំ បុរិសំ ទឡ្ហាយ រជ្ជុយា បច្ឆាពាហុំ គាឡ្ហពន្ធនំ ពន្ធិត្វា

---

១ ឱ. ធនមនុប្បទាមិ ។ ២ ឱ. មូលឃច្ចំ ។ ម. មូលឆេជ្ជំ ។ ៣ ឱ. ម. បច្ឆាពាហំ ។

ព្រះរាជាទ្រង់ត្រាស់សួរថា ព្រោះហេតុអ្វី (បានជាអ្នកឯងលួចទ្រព្យគេ) ។ បុរសនោះ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រោះខ្ញុំព្រះអង្គ មិនមាន (របស់អ្វី) នឹងចិញ្ចឹមជីវិត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ទ្រង់មានសេចក្ដីត្រិះរិះដូច្នេះថា បើអាត្មាអញនៅតែឲ្យទ្រព្យ ដល់អ្នកដែលកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច តែយ៉ាងនេះ មុខជាអទិន្នាទាននេះ នឹងរីងរឹតតែចំរើនឡើង បើដូច្នោះ គួរតែអាត្មាអញផ្ចាញ់ផ្ចាលបុរសនេះ គួរធ្វើនូវការផ្ដាច់ផ្ដិលឫសគល់ គឺកាត់ក្បាលវាចេញ ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធា-ភិសេកហើយ ទ្រង់ត្រាស់បង្គាប់ពួករាជបុរសថា នែប្រស្ដែង បើដូច្នោះ ចូរអ្នកទាំងឡាយចងស្លាបសេកបុរសនេះ ឲ្យជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងរួច (ត្រូវទូង) ស្គរដែលមានសំឡេងឮខ្លាំង នាំបណ្ដើរជុំវិញសព្វច្រក សព្វផ្លូវបំបែករួចនាំចេញទៅតាមទ្វារខាងត្បូង ហើយចូរផ្ចាញ់ផ្ចាល ធ្វើនូវការផ្ដាច់ឫសគល់ គឺកាត់ក្បាលវាចេញ ក្នុងទិសខាងត្បូងនៃក្រុងចុះ ។ ម្នាលភិក្ខុទាំងឡាយ រាជបុរសទាំងនោះ ទទួលព្រះរាជឱង្ការព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយចងស្លាបសេកបុរសនោះ ឲ្យជាប់ដោយខ្សែដ៏មាំ

ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខមិត្វា ទក្ខិណតោ នគរស្ស សុនិសេធំ និសេធេសុំ មូលឃច្ចំ អកំសុ សីសមស្ស ឆិន្ទឹសុ ។

(៨១) អស្សោសុំ ខោ ភិក្ខវេ មនុស្សា យេ កិរ ភោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយន្តិ តេ រាជា សុនិសេធំ និសេធេតិ មូលឃច្ចំ ករោតិ សីសានិ តេសំ ឆិន្ទតីតិ ។ សុត្វាន តេសំ ឯតទហោសិ យន្នូន មយំបិ តិណ្ហានិ សត្ថានិ ការាបេយ្យាម(១) តិណ្ហានិ សត្ថានិ ការាបេត្វា យេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយិស្សាម តេ សុនិសេធំ និសេធេស្សាម មូលឃច្ចំ ករិស្សាម សីសានិ នេសំ ឆិន្ទិស្សាមាតិ ។ តេ តិណ្ហានិ សត្ថានិ ការាបេសុំ តិណ្ហានិ សត្ថានិ ការាបេត្វា គាមឃាតំបិ ឧបក្កមឹសុ កាតុំ និគមឃាតំបិ ឧបក្កមឹសុ កាតុំ នគរឃាតំបិ ឧបក្កមឹសុ កាតុំ

---

១ ម. ការាបេស្សាម ។

រួចកោរក្បាលឲ្យរលីង (ទួង) ស្គរដែលមានសំឡេងខ្លាំង នាំបណ្ដើរជុំវិញសព្វច្រក សព្វផ្លូវបំបែក នាំចេញតាមទ្វារខាងត្បូង ហើយផ្ដាញ់ផ្ដាល ធ្វើនូវការផ្ដាច់ផ្ដិលឫសគល់ គឺកាត់ក្បាលបុរសនោះ ក្នុងទិសខាងត្បូងនៃក្រុង ។

(៤១) ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សបានឮដំណឹងថា ពួកជនណាកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ព្រះរាជាទ្រង់ផ្ដាញ់ផ្ដាល នូវជនទាំងនោះ ទ្រង់ធ្វើនូវការផ្ដាច់ផ្ដិលឫសគល់ គឺទ្រង់កាត់ក្បាលពួកជនទាំងនោះ ។ លុះមនុស្សទាំងនោះបានឮហើយ ក៏គិតយ៉ាងនេះថា បើដូច្នោះមានតែពួកយើងនាំគ្នាធ្វើគ្រឿងសស្ត្រាវុធដ៏មុតក្លា លុះនាំគ្នាធ្វើគ្រឿងសស្ត្រាវុធដ៏មុតក្លារួចហើយ នឹងកាន់យកទ្រព្យរបស់ពួកជនណា ដែលគេមិនបានឲ្យ ដែលហៅថា លួចហើយពួកយើងនឹងផ្ដាញ់ផ្ដាល នូវជនទាំងនោះ នឹងធ្វើនូវការផ្ដាច់ផ្ដិលនូវឫសគល់ គឺកាត់ក្បាលរបស់ជនទាំងនោះចេញ ។ មនុស្សទាំងនោះ ក៏នាំគ្នាធ្វើគ្រឿងសស្ត្រាវុធដ៏មុតក្លា លុះនាំគ្នាធ្វើគ្រឿងសស្ត្រាវុធដ៏មុតក្លារួចហើយ ក៏ព្យាយាមធ្វើ នូវការសម្លាប់អ្នកស្រុកខ្លះ ព្យាយាមធ្វើ នូវការសម្លាប់អ្នកនិគមខ្លះ ព្យាយាមធ្វើ នូវការសម្លាប់អ្នកនគរខ្លះ

### ចក្កវត្តិសុត្តេ ធនានុប្បទានំ

បន្ថទុហនម្បិ(១) ឧបក្កមឹសុ កាតុំ ។ យេសំ តេ(២) អទិន្នំ ថេយ្យសង្ខាតំ អាទិយន្តិ តេ សុនិសេធំ និសេធេន្តិ មូលឃច្ចំ ករោន្តិ សីសានិ នេសំ ឆិន្ទន្តិ ។

(៤២) ឥតិ ខោ ភិក្ខវេ អធនានំ ធនេ អននុប្បទិយមានេ ទាលិទ្ទិយំ វេបុល្លមគមាសិ ទាលិទ្ទិយេ វេបុល្លំ គតេ អទិន្នាទានំ វេបុល្លមគមាសិ អទិន្នាទានេ វេបុល្លំ គតេ សត្ថំ វេបុល្លមគមាសិ សត្ថេ វេបុល្លំ គតេ បាណាតិបាតោ វេបុល្លមគមាសិ បាណាតិបាតេ វេបុល្លំ គតេ មុសាវាទោ វេបុល្លមគមាសិ មុសាវាទេ វេបុល្លំ គតេ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ អសីតិវស្សសហស្សាយុកានំ មនុស្សានំ ចត្តារីសវស្សសហស្សាយុកា បុត្តា អហេសុំ ចត្តារីសវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ

---

១ ម. បន្ថទូសនំ បិ ។ ២ ឱ. តេ យេសំ ។

ព្យាយាមធ្វើនូវការបួនអ្នកដើរផ្លូវខ្លះ ៗ មនុស្សទាំងនោះតែងកាន់យកទ្រព្យ របស់ពួកជនណា ដែលគេមិនបានឲ្យដែលហៅថា លួច ហើយផ្ដាញ់ផ្ដាល ពួកជនទាំងនោះ ធ្វើនូវការផ្ដាច់ផ្ដិលឫសគល់ គឺកាត់ក្បាលជនទាំងនោះ ។

(៤២) ម្នាលភិក្ខុទាំងឡាយ កាលបើ ព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះ សេចក្ដីទាលក្រក៏មានច្រើនឡើង កាលបើ សេចក្ដីទាលក្រមានច្រើនឡើងហើយ អទិន្នាទានក៏មានច្រើនឡើង កាលបើ អទិន្នាទានមានច្រើនឡើងហើយ បាណាតិបាត ក៏មានច្រើនឡើង កាលបើ បាណាតិបាតមានច្រើនឡើងហើយ មុសាវាទក៏មានច្រើនឡើង កាលបើ មុសាវាទមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុរ របស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ៨ ម៉ឺនឆ្នាំ ក៏ថយមក មានអាយុត្រឹម ៤ ម៉ឺនឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកមនុស្ស ដែលមានអាយុត្រឹម ៤ ម៉ឺនឆ្នាំ (នោះ)

អញ្ញតរោ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយិ ។ តមេនំ អគ្គហេសុំ គហេត្វា រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស ទស្សេសុំ អយំ ទេវ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយីតិ ។ ឯវំ វុត្តេ ភិក្ខវេ រាជា ខត្តិយោ មុទ្ធាវសិត្តោ តំ បុរិសំ ឯតទវោច សច្ចំ កិរ ត្វំ អម្ភោ បុរិស បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយសីតិ ។ ន ហិ ទេវាតិ សម្បជានមុសា ភាសិ ។

(៨៣) ឥតិ ខោ ភិក្ខវេ អធនានំ ធនេ នានុប្បទិយមានេ ទាលិទ្ទិយំ វេបុល្លមគមាសិ ទាលិទ្ទិយេ វេបុល្លំ គតេ អទិន្នាទានំ វេបុល្លមគមាសិ អទិន្នាទានេ វេបុល្លំ គតេ សត្ថំ វេបុល្លមគមាសិ សត្ថេ វេបុល្លំ គតេ បាណាតិបាតោ វេបុល្លមគមាសិ

មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ពួករាជបុរសក៏ចាប់បុរសនោះ នាំយកទៅថ្វាយព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេក ហើយក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ម្នាលភិក្ខុទាំងឡាយ កាលបើ ពួករាជបុរសក្រាបបង្គំទូលយ៉ាងនេះហើយ ទើបព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេក ទ្រង់ត្រាស់សួរបុរសនោះ យ៉ាងនេះថា នែបុរសដ៏ចំរើន អ្នកឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិតមែនឬ ។ បុរសនោះ ក៏ពោលសម្បជានមុសាវាទថា បពិត្រព្រះសម្មតិទេព មិនមែនទេ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ កាលបើ ព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្វះទ្រព្យដូច្នេះហើយ សេចក្តីទលក្រ ក៏មានច្រើនឡើង កាលបើសេចក្តីទលក្រ មានច្រើនឡើងហើយ អទិន្នាទាន ក៏មានច្រើនឡើង កាលបើ អទិន្នាទាន មានច្រើនឡើងហើយ គ្រឿងសស្ត្រាវុធក៏មានច្រើនឡើង កាលបើ គ្រឿងសស្ត្រាវុធមានច្រើនឡើងហើយ បាណាតិបាត ក៏មានច្រើនឡើង កាលបើ

បាណាតិបាតេ វេបុល្លំ គតេ មុសាវាទោ វេបុល្លមគមាសិ មុសាវាទេ វេបុល្លំ គតេ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ(១) អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ ចត្តារីសវស្សសហស្សាយុកានំ មនុស្សានំ វីសតិវស្សសហស្សាយុកា បុត្តា អហេសុំ វីសតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ អញ្ញតរោ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយិ ។ តមេនំ អញ្ញតរោ បុរិសោ រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស អារោចេសិ ឥត្ថន្នាមោ ទេវ បុរិសោ បរេសំ អទិន្នំ ថេយ្យសង្ខាតំ អាទិយីតិ បេសុញ្ញមកាសិ ។

(៤៤) ឥតិ ខោ ភិក្ខវេ អធនានំ ធនេ នានុប្បទិយមានេ ទាលិទ្ទិយំ វេបុល្លមគមាសិ ទាលិទ្ទិយេ វេបុល្លំ គតេ ។ បេ ។ បិសុណា វាចា វេបុល្លមគមាសិ បិសុណាយ វាចាយ វេបុល្លំ គតាយ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ

១ ម. តេសន្តិ ន ទិស្សតិ ។

បាណាតិបាតមានច្រើនឡើងហើយ មុសាវាទក៏មានច្រើនឡើង កាលបើ មុសាវាទមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុរ របស់សត្វទាំងនោះ ក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ ៤ ម៉ឺនឆ្នាំ ក៏ថយមកមានអាយុត្រឹម ២ ម៉ឺនឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកមនុស្ស ដែលមានអាយុត្រឹម ២ ម៉ឺនឆ្នាំ (នោះ) មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ បុរសម្នាក់ នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូល ញុះញង់ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយថា បពិត្រព្រះសម្មតិទេព បុរសឈ្មោះនេះ កាន់យកទ្រព្យ របស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។

(៤៤) ម្នាលភិក្ខុទាំងឡាយ កាលបើ ព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់អ្នកខ្វត់ទ្រព្យដូច្នេះហើយ សេចក្តីទាលក្រក៏មានច្រើនឡើង កាលបើ សេចក្តីទាលក្រមានច្រើនឡើងហើយ ។ បេ ។ បិសុណាវាចា ក៏មានច្រើនឡើង កាលបើ បិសុណាវាចាមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុរ របស់សត្វទាំងនោះក៏ថយចុះ កាល

តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ វីសតិវស្សសហស្សាយុកានំ មនុស្សានំ ទសវស្សសហស្សាយុកា បុត្តា អហេសុំ ទសវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ ឯកច្ចេ សត្តា វណ្ណវន្តា(១) ហោន្តិ ឯកច្ចេ សត្តា ទុព្វណ្ណា តត្ថ យេ តេ សត្តា ទុព្វណ្ណា តេ វណ្ណវន្តេ សត្តេ អភិជ្ឈាយន្តា បរេសំ ទារេសុ ចារិត្តំ អាបជ្ជឹសុ ។

(៨៥) ឥតិ ខោ ភិក្ខវេ អធនានំ ធនេ ននុប្បទិយមានេ ទាលិទ្ទិយំ វេបុល្លមគមាសិ ទាលិទ្ទិយេ វេបុល្លំ គតេ អទិន្នាទានំ វេបុល្លមគមាសិ អទិន្នាទានេ វេបុល្លំ គតេ ។ សង្ខិត្តំ ។ កាមេសុ មិច្ឆាចារោ វេបុល្លមគមាសិ កាមេសុ មិច្ឆាចារេ វេបុល្លំ គតេ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ ទសវស្សសហស្សាយុកានំ មនុស្សានំ បញ្ចវស្សសហស្សាយុកា បុត្តា អហេសុំ បញ្ចវស្សសហស្សាយុកេសុ ភិក្ខវេ

១ ឱ. ម. វណ្ណវន្តោ ។

សត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ២ ម៉ឺនឆ្នាំ ក៏ថយចុះមកមានអាយុត្រឹម ១ ម៉ឺនឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកមនុស្សដែលមានអាយុ ១ ម៉ឺនឆ្នាំ (នោះ) សត្វពួកខ្លះមានពណ៌សម្បុរល្អ សត្វពួកខ្លះមានពណ៌សម្បុរអាក្រក់ បណ្តាសត្វទាំងពីរពួកនោះ សត្វណា ដែលមានពណ៌សម្បុរអាក្រក់ ក៏ស្រឡាញ់ពួកសត្វដែលមានពណ៌សម្បុរល្អ ក៏ប្រព្រឹត្តមិច្ឆាចារក្នុងភរិយារបស់ពួកជនដទៃ ៗ

[៤៩] ម្នាលភិក្ខុទាំងឡាយ កាលបើ ព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្វះទ្រព្យដូច្នេះហើយ សេចក្តីទាលក្រក៏មានច្រើនឡើង កាលបើ សេចក្តីទាលក្រ មានច្រើនឡើងហើយ អទិន្នាទាន ក៏មានច្រើនឡើង កាលបើ អទិន្នាទានមានច្រើនឡើងហើយ ៗ សេចក្តីសង្ខេប ៗ កាមេសុ មិច្ឆាចារ ក៏មានច្រើនឡើង កាលបើ កាមេសុមិច្ឆាចារ មានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះ ក៏ថយចុះ កាលសត្វទាំងនោះ ថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ ១ ម៉ឺនឆ្នាំ ក៏ថយមក មានអាយុត្រឹម ៥ ពាន់ឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ

## ចក្កវត្តិសុត្តេ ទសអកុសលកម្មបថា អាយុបរិហានិ

មនុស្សេសុ ទ្វេ ធម្មា វេបុល្លមគមឹសុ ផរុសា ច វាចា សម្ផប្បលាបោ ច ទ្វីសុ ធម្មេសុ វេបុល្លំ គតេសុ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ បញ្ចវស្សសហស្សាយុកានំ មនុស្សានំ អប្បេកច្ចេ អឌ្ឍតេយ្យវស្សសហស្សាយុកា អប្បេកច្ចេ ទ្វេវស្សសហស្សាយុកា បុត្តា អហេសុំ អឌ្ឍតេយ្យវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ អភិជ្ឈា ព្យាបាទា វេបុល្លមគមឹសុ អភិជ្ឈាព្យាបាទេសុ វេបុល្លំ គតេសុ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ អឌ្ឍតេយ្យវស្សសហស្សាយុកានំ មនុស្សានំ វស្សសហស្សាយុកា បុត្តា អហេសុំ វស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ មិច្ឆាទិដ្ឋិ វេបុល្លមគមាសិ

ធម៌ទាំងពីរប្រការគឺផរុសវាចា១ សម្ផប្បលាបៈ១ ក៏មានច្រើនឡើង ក្នុងពួកមនុស្ស ដែលមានអាយុត្រឹម៥ពាន់ឆ្នាំ កាលបើ ធម៌ទាំងពីរប្រការមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុរ របស់សត្វទាំងនោះ ក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៥ ពាន់ឆ្នាំ ពួកខ្លះក៏ថយមកមានអាយុត្រឹម ២ ពាន់ ៥ រយឆ្នាំវិញ ពួកខ្លះក៏ថយមកមានអាយុត្រឹម ២ ពាន់ឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ អភិជ្ឈានិងព្យាបាទ ក៏មានច្រើនឡើង ក្នុងពួកមនុស្សដែលមានអាយុត្រឹម ២ ពាន់៥រយឆ្នាំ កាលអភិជ្ឈានិងព្យាបាទ មានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ២ពាន់៥រយឆ្នាំ ក៏ថយមកមានអាយុត្រឹម ១ ពាន់ឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិក៏មានច្រើនឡើងក្នុងពួកមនុស្ស ដែលមានអាយុត្រឹម១ ពាន់ឆ្នាំ

មិច្ឆាទិដ្ឋិយា វេបុល្លំ គតាយ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ វីសតិវស្សសហស្សាយុកានំ មនុស្សានំ បញ្ចវស្សសតាយុកា បុត្តា អហេសុំ បញ្ចវស្សសតាយុកេសុ ភិក្ខវេ មនុស្សេសុ តយោ ធម្មា វេបុល្លមគមំសុ អធម្មរាគោ វិសមលោភោ មិច្ឆាធម្មោ តីសុ ធម្មេសុ វេបុល្លំ គតេសុ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេនបិ បរិហាយមានានំ បញ្ចវស្សសតាយុកានំ មនុស្សានំ អប្បេកច្ចេ អឌ្ឍតេយ្យវស្សសតាយុកា អប្បេកច្ចេ ទ្វេវស្សសតាយុកា បុត្តា អហេសុំ អឌ្ឍតេយ្យវស្សសតាយុកេសុ ភិក្ខវេ មនុស្សេសុ ឥមេ ធម្មា វេបុល្លមគមំសុ អមត្តេយ្យតា[1] អបេត្តេយ្យតា អសាមញ្ញតា អព្រហ្មញ្ញតា នកុលេជេដ្ឋាបចាយិតា[2] ។

---

១ ម. អមេត្តេយ្យតា ។ ២ នកុលេជេដ្ឋាបចាយិកាតិបិ ភ បាឋោ ។

កាលបើ មិច្ឆាទិដ្ឋិមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ ១ ពាន់ឆ្នាំក៏ថយមក មានអាយុត្រឹម ៥ រយឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ ប្រការគឺ អធម្មរាគៈ(១) ១ វិសមលោភៈ(២) ១ មិច្ឆាធម្មៈ(៣) ១ ក៏មានច្រើនឡើងក្នុងពួកមនុស្ស ដែលមានអាយុត្រឹម ៥ រយឆ្នាំ កាលបើធម៌ ៣ ប្រការមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ ៥ រយឆ្នាំពួកខ្លះក៏ថយមក មានអាយុត្រឹម ២ រយ ៥០ ឆ្នាំវិញ ពួកខ្លះក៏ថយមក មានអាយុត្រឹម ២ រយឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះគឺការមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែង ដល់បុគ្គលជាធំក្នុងត្រកូលក៏មានច្រើនឡើង ក្នុងពួកមនុស្ស ដែលមានអាយុត្រឹម ២ រយ ៥០ ។

---

១ អធម្មរាគ គឺ សេចក្តីត្រេកត្រអាលក្រៅគន្លងធម៌ បានដល់តម្រេកក្នុងទីមិនសមគួរ គឺតម្រេកក្នុងអាគា ម្តាយមីងខាងមាតាបិតា ម្តាយធំខាងបិតាជាដើម។ ២ សេចក្តីចង់បានខ្លាំងពេក ។ ៣ សេចក្តីប្រាថ្នាខុសគន្លងធម៌ បានដល់តម្រេករបស់បុរស ក្នុងបុរស របស់ស្ត្រី ក្នុងស្ត្រី ។

ឥតិ ខោ ភិក្ខវេ អធនានំ ធនេ អននុប្បទិយមានេ ទាឡិទ្ទិយំ វេបុល្លមគមាសិ ទាឡិទ្ទិយេ វេបុល្លំ គតេ អទិន្នាទានំ វេបុល្លមគមាសិ អទិន្នាទានេ វេបុល្លំ គតេ សត្ថំ វេបុល្លមគមាសិ សត្ថេ វេបុល្លំ គតេ បាណាតិបាតោ វេបុល្លមគមាសិ បាណាតិបាតេ វេបុល្លំ គតេ មុសាវាទោ វេបុល្លមគមាសិ មុសាវាទេ វេបុល្លំ គតេ បិសុណា វាចា វេបុល្លមគមាសិ បិសុណាយ វាចាយ វេបុល្លំ គតាយ កាមេសុ មិច្ឆាចារោ វេបុល្លមគមាសិ កាមេសុ មិច្ឆាចារេ វេបុល្លំ គតេ ទ្វេ ធម្មា វេបុល្លមគមំសុ ផរុសា ច (១) វាចា សម្ផប្បលាបោ ច ទ្វីសុ ធម្មេសុ វេបុល្លំ គតេសុ អភិជ្ឈាព្យាបាទា វេបុល្លមគមំសុ អភិជ្ឈាព្យាបាទេសុ វេបុល្លំ គតេសុ (២) មិច្ឆាទិដ្ឋិ វេបុល្លមគមាសិ មិច្ឆាទិដ្ឋិយា វេបុល្លំ គតាយ តយោ ធម្មា វេបុល្លមគមំសុ អធម្មរាគោ វិសមលោភោ មិច្ឆាធម្មោ តីសុ ធម្មេសុ

---

១ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។ ២ ឱ. អភិជ្ឈាព្យាបាទោ វេបុល្លមគមាសិ អភិជ្ឈាព្យា-បាទេ វេបុល្លំគតេ ។

ចក្កវត្តិសូត្រ  ដំណើរកើតឡើងនៃសេចក្ដីទ័លក្រជាដើម

ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រិយ៍មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះហើយ សេចក្ដីទ័លក្រក៏មានច្រើនឡើង កាលបើសេចក្ដីទ័លក្រមានច្រើនឡើងហើយ អទិន្នាទានក៏មានច្រើនឡើង កាលអទិន្នាទានមានច្រើនឡើងហើយ គ្រឿងសស្ត្រាវុធក៏មានច្រើនឡើង កាលគ្រឿងសស្ត្រាវុធមានច្រើនឡើងហើយ បាណាតិបាត ក៏មានច្រើនឡើង កាលបាណាតិបាតមានច្រើនឡើងហើយ មុសាវាទ ក៏មានច្រើនឡើង កាលមុសាវាទមានច្រើនឡើងហើយ បិសុណាវាចា ក៏មានច្រើនឡើង កាលបិសុណាវាចាមានច្រើនឡើងហើយ កាមេសុ មិច្ឆាចារ ក៏មានច្រើនឡើង កាលកាមេសុ មិច្ឆាចារមានច្រើនឡើងហើយ ធម៌ ២ ប្រការគឺផរុសវាចា ១ សម្ផប្បលាបៈ ១ ក៏មានច្រើនឡើង កាលធម៌ ២ ប្រការមានច្រើនឡើងហើយ អភិជ្ឈានឹងព្យាបាទ ក៏មានច្រើនឡើង កាលអភិជ្ឈានឹងព្យាបាទ មានច្រើនឡើងហើយ មិច្ឆាទិដ្ឋិ ក៏មានច្រើនឡើង កាលមិច្ឆាទិដ្ឋិ មានច្រើនឡើងហើយ ធម៌ ៣ ប្រការគឺ អធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ក៏មានច្រើនឡើង កាលធម៌ ៣ ប្រការ

វេបុល្លំ គតេសុ ឥមេ ធម្មា វេបុល្លមគមំសុ អមត្តេយ្យ-តា អបេត្តេយ្យតា អសាមញ្ញតា អព្រហ្មញ្ញតា នកុលេជេដ្ឋាបចាយិតា ឥមេសុ ធម្មេសុ វេបុល្លំ គតេសុ តេសំ សត្តានំ អាយុបិ បរិហាយិ វណ្ណោបិ បរិហាយិ តេសំ អាយុនាបិ បរិហាយមានានំ វណ្ណេន-បិ បរិហាយមានានំ អឌ្ឍតេយ្យវស្សសតាយុកានំ មនុស្សានំ វស្សសតាយុកា បុត្តា អហេសុំ ។

(៤៦) ភវិស្សតិ ភិក្ខវេ សោ សមយោ យំ ឥមេសំ មនុស្សានំ ទសវស្សាយុកា បុត្តា ភវិស្សន្តិ ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ បញ្ចវស្សិកា កុមារិកា អលំបតេយ្យា ភវិស្សន្តិ ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ ឥមានិ រសានិ អន្តរធាយិស្សន្តិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ លោណំ

មានច្រើនឡើងហើយ ធម៌ទាំងឡាយនេះ គឺការមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងដល់បុគ្គលជាធំ ក្នុងត្រកូលក៏មានច្រើនឡើង កាលធម៌ទាំងនេះមានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុរ របស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះ ថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ ២ រយ ៥០ ឆ្នាំ ក៏ថយមកមានអាយុត្រឹម ១ រយឆ្នាំវិញ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ (តទៅខាងមុខ) នឹងមានសម័យដែលកូនរបស់មនុស្សទាំងនេះ មានអាយុ១០ឆ្នាំ កាលបើ មនុស្សមានអាយុ ១០ ឆ្នាំ ពួកនាងកុមារិកាអាយុ៥ ឆ្នាំនឹងល្មមឲ្យមានប្តី ម្នាលភិក្ខុទាំងឡាយ កាលបើមនុស្សមានអាយុ ១០ ឆ្នាំ រស(ដ៏ប្រសើរ) ទាំងនេះគឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ អំបិល នឹងបាត់ទៅ

## ចក្កវត្តិសុត្តេ កុទ្រូសកអគ្គភោជនូបមា

ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ កុទ្រូសកោ អគ្គភោជនំ(១) ភវិស្សតិ សេយ្យថាបិ ភិក្ខវេ ឯតរហិ សាលិមំសោទនោ អគ្គភោជនំ ឯវមេវ ខោ ភិក្ខវេ ទសវស្សាយុកេសុ មនុស្សេសុ កុទ្រូសកោ អគ្គភោជនំ ភវិស្សតិ ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ ទស កុសលកម្មបថា សព្វេន សព្វំ អន្តរធាយិស្សន្តិ ទស អកុសលកម្មបថា អតិវិយ ទិប្បិស្សន្តិ(២) ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ កុសលន្តិបិ ន ភវិស្សតិ កុតោ បន កុសលស្ស ការកោ ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ យេ តេ ភវិស្សន្តិ អមត្តេយ្យា អបេត្តេយ្យា អស្សាមញ្ញា អព្រហ្មញ្ញា នកុលេជេដ្ឋាបចាយិនោ តេ បូជា(៣) ច ភវិស្សន្តិ បាសំសា ច សេយ្យថាបិ ភិក្ខវេ ឯតរហិ មត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចាយិនោ តេ បូជា ច បាសំសា ច

១ ឱ. ម. កុទ្រូសកោ អគ្គំ ភោជនានំ ។ ២ ម. អតិព្យាទិប្បិស្សន្តិ ។ ៣ បុជាតិបិ បុជ្ជាតិបិ បាឋោ ភវិតព្វំ ។

ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ១០ឆ្នាំ ស្មៅគែលលកនឹងជាភោជនដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បាយស្រូវសាលីលាយដោយសាច់ ជាភោជនដ៏ប្រសើរដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ ១០ ឆ្នាំ ស្មៅគែលលកនឹងជាភោជនដ៏ប្រសើរយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ កុសលកម្មបថទាំង ១០ នឹងសាបសូន្យទៅគ្រប់អន្លើ អកុសលកម្មបថទាំង ១០ នឹងចំរើនច្រើនឡើង ម្នាលភិក្ខុទាំងឡាយ កាលបើ ពួកមនុស្សមានអាយុ ១០ ឆ្នាំ សូម្បីពាក្យថា កុសលក៏មិនមាន បើដល់ម្ល៉ោះទៅហើយ មនុស្សអ្នកធ្វើកុសល តើនឹងមានមកពីណា ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ ជនទាំងឡាយណាជាអ្នកមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល ជនទាំងនោះនឹងជាអ្នកគួរគេបូជាផង នឹងជាអ្នកគួរគេសរសើរផង ម្នាលភិក្ខុទាំងឡាយ មនុស្សក្នុងកាលឥឡូវនេះ ដែលជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ ប្រព្រឹត្តកោតក្រែងបុគ្គល ជាច្បងក្នុងត្រកូល មនុស្សទាំងនោះ ទើបជាអ្នកគួរគេបូជាផង គួរគេសរសើរផង ដូចម្តេចមិញ

ឯវមេវ ខោ ភិក្ខវេ ទសវស្សាយុកេសុ មនុស្សេសុ យេ តេ ភវិស្សន្តិ អមត្តេយ្យា អបេត្តេយ្យា អសា-មញ្ញា អព្រហ្មញ្ញា នកុលេជេដ្ឋាបចាយិនោ តេ បូជា ច ភវិស្សន្តិ បាសំសា ច ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ ន ភវិស្សតិ មាតាតិ វា មាតុច្ឆាតិ វា បិតាតិ វា បិតុច្ឆាតិ វា(១) មាតុលា-នីតិ វា អាចរិយភរិយាតិ វា គរូនំ ទារាតិ វា សម្ភេទំ លោកោ គមិស្សតិ យថា អជេឡកា កុក្កុដា សូករា សោណា សិគាលា(២) ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ តេសំ សត្តានំ អញ្ញមញ្ញម្ហិ តិព្វោ អា-ឃាតោ បច្ចុបដ្ឋិតោ ភវិស្សតិ តិព្វោ ព្យាបាទោ តិព្វោ មនោបទោសោ តិព្វំ វធកចិត្តំ មាតុបិ បុត្តម្ហិ ។ បុត្តស្សបិ មាតរិ ។ បិតុបិ បុត្តម្ហិ ។ បុត្តស្សបិ បិតរិ ។

---

១ ឱ. ម. បិតាតិ វា បិតុច្ឆាតិ វាតិ ន ទិស្សតិ ។ ២ ឱ. កុក្កុដសូករា សោណសិគាលា ។

ម្នាលភិក្ខុទាំងឡាយ កាលដែលពួកមនុស្សមានអាយុ ១០ ឆ្នាំ ជនណា មិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងបុគ្គល ជាច្បងក្នុងត្រកូល ជនទាំងនោះ ទើបជាអ្នកគួរគេបូជាផង គួរគេសរសើរផង ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ នឹងមិនមានសេចក្តីគោរពកោតក្រែងថា (អ្នកនេះ) ជាមាតា ជាម្តាយមីងខាងមាតា ជាបិតា ជាម្តាយមីងខាងបិតា ជាម្តាយធំខាងមាតា ជាភរិយារបស់អាចារ្យ ឬថាជាប្រពន្ធរបស់គ្រូ (នៃខ្លួន) ដូច្នេះឡើយ សត្វលោកនឹងប្រឡូកប្រឡំគ្នា ដូចជាពពែ មាន់ ជ្រូក ឆ្កែ ចចក ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លា នឹងកើតប្រាកដដល់គ្នានឹងគ្នា គឺមាតានឹងបុត្ត ៗ បុត្តនឹងមាតា ៗ បិតានឹងបុត្ត ៗ បុត្តនឹងបិតា ៗ

## ចក្កវត្តិសុត្តំ តិព្វាឃាតាទិកថា

ភាតុបិ ភគិនិយា ។ ភគិនិយា ភាតរិ(១) តិព្វោ អាឃាតោ បច្ចុបដ្ឋិតោ ភវិស្សតិ តិព្វោ ព្យាបាទោ តិព្វោ មនោបទោសោ តិព្វំ វធកចិត្តំ សេយ្យថាបិ ភិក្ខវេ មាគវិកស្ស មិគំ ទិស្វា តិព្វោ អាឃាតោ បច្ចុបដ្ឋិតោ ហោតិ តិព្វោ ព្យាបាទោ តិព្វោ មនោ-បទោសោ តិព្វំ វធកចិត្តំ ឯវមេវ ខោ ភិក្ខវេ ទសវស្សាយុកេសុ មនុស្សេសុ តេសំ សត្តានំ អញ្ញមញ្ញម្ហិ តិព្វោ អាឃាតោ បច្ចុបដ្ឋិតោ ភវិស្សតិ តិព្វោ ព្យាបាទោ តិព្វោ មនោបទោសោ តិព្វំ វធកចិត្តំ មាតុបិ បុត្តម្ហិ ។ បុត្តស្សបិ មាតរិ ។ បិតុបិ បុត្តម្ហិ ។ បុត្តស្សបិ បិតរិ ។ ភាតុបិ ភគិនិ-យា(២) ។ ភគិនិយាបិ ភាតរិ តិព្វោ អាឃាតោ បច្ចុបដ្ឋិតោ ភវិស្សតិ តិព្វោ ព្យាបាទោ តិព្វោ មនោបទោសោ តិព្វំ វធកចិត្តំ ។

---

១ ឱ. ភាតុបិ ភាតរិ ។ ភាតុបិ ភគិនិយា ។ ភគិនិយាបិ ភាតរិ ។ ២ ឱ. ភាតុបិ ភាតរិ ។ ភាតុបិ ភគិនិយា ។

បងប្អូនប្រុសនឹងបងប្អូនស្រី ៗ គំនុំដ៏ក្តៀតក្តា ព្យាបាទដ៏ក្តៀតក្តា ចិត្តប្រទូស្តដ៏ក្តៀតក្តា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្តៀតក្តា របស់បងប្អូនស្រីនឹងកើតប្រាកដឡើងដល់បងប្អូនប្រុស ម្នាលភិក្ខុទាំងឡាយ គំនុំដ៏ក្តៀតក្តា ព្យាបាទដ៏ក្តៀតក្តា ចិត្តប្រទូស្តដ៏ក្តៀតក្តា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្តៀតក្តា របស់ព្រានម្រឹគកើតឡើងប្រាកដ ព្រោះឃើញម្រឹគ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ គំនុំដ៏ក្តៀតក្តា ព្យាបាទដ៏ក្តៀតក្តា ចិត្តប្រទូស្តដ៏ក្តៀតក្តា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្តៀតក្តា របស់សត្វទាំងនោះ នឹងកើតប្រាកដ ដល់គ្នានឹងគ្នា មានឧបមេយ្យដូច្នោះឯង គឺមាតានឹងបុត្ត ៗ បុត្តនឹងមាតា ៗ បិតានឹងបុត្រ ៗ បុត្តនឹងបិតា ៗ បងប្អូនប្រុសនឹងបងប្អូនស្រី ៗ គំនុំដ៏ក្តៀតក្តា ព្យាបាទដ៏ក្តៀតក្តា ចិត្តប្រទូស្តដ៏ក្តៀតក្តា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្តៀតក្តា របស់បងប្អូនស្រីនឹងកើតប្រាកដ ដល់បងប្អូនប្រុស ។

(៤៧) ទសវស្សាយុកេសុ ភិក្ខវេ មនុស្សេសុ សត្តាហំ សត្ថន្តរកប្បោ ភវិស្សតិ តេ អញ្ញមញ្ញំ មិគសញ្ញំ(១) បដិលភិស្សន្តិ តេសំ តិណ្ហានិ សត្ថានិ ហត្ថេសុ បាតុភវិស្សន្តិ តេ តិណ្ហេន សត្ថេន ឯស មិគោតិ(២) អញ្ញមញ្ញំ ជីវិតា វោរោបេស្សន្តិ ។ អថខោ តេសំ ភិក្ខវេ សត្តានំ ឯកច្ចានំ ឯវំ ភវិស្សតិ មា ច មយំ កញ្ចិ មា ច អម្ហេ កោចិ យន្នូន មយំ តិណគហនំ វា វនគហនំ វា រុក្ខគហនំ វា នទីវិទុគ្គំ វា បព្វតវិសមំ វា បវិ-សិត្វា វនមូលផលាហារា យាបេយ្យាមាតិ ។ តេ តិណគហនំ វា(៣) វនគហនំ វា(៤) រុក្ខគហនំ វា(៥) នទីវិទុគ្គំ វា(៦) បព្វតវិសមំ វា(៧) បវិសិត្វា សត្តាហំ វនមូលផលាហារា យាបេស្សន្តិ ។ តេ តស្ស សត្តាហស្ស អច្ចយេន តិណគហនា វនគហនា រុក្ខគហនា នទីវិទុគ្គា បព្វតវិសមា

---

១ ម. អញ្ញមញ្ញម្ហិ. . . . ។ ២ ឱ. ម ឯស មិគោ ឯស មិគោតិ អាមេឌិតំ ទិស្សតិ ។
៣-៤-៥-៦-៧ ឱ. វាសទ្ទោ ន ទិស្សតិ ។

(៤៧) ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ សត្ថន្តរកប្ប (លោកវិនាសទៅដោយគ្រឿងសស្ត្រាវុធ) នឹងកើតមានឡើងអស់៧ថ្ងៃ មនុស្សទាំងនោះ នឹងសំគាល់គ្នាថា ដូចជាម្រឹគ គ្រឿងសស្ត្រាវុធដ៏មុតក្តានឹងជាប់នៅក្នុងដៃ នៃមនុស្សទាំងនោះ មនុស្សទាំងនោះសំគាល់ថា នេះជាម្រឹគ ហើយក៏ផ្តាច់ជីវិតគ្នានឹងគ្នា ដោយគ្រឿងសស្ត្រាវុធដ៏មុតក្តា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បណ្តាសត្វទាំងនោះ សត្វពួកខ្លះនឹងគិតគ្នាយ៉ាងនេះថា ពួកយើងកុំសម្លាប់បុរសណាមួយឡើយ ទាំងបុរសណាមួយក៏កុំសម្លាប់ពួកយើងឡើយ បើដូច្នោះ ពួកយើងគួរចូលទៅរកស្មៅស្បាត ព្រៃស្បាត ឈើស្បាត ស្ទឹងដែលទៅមកបានដោយលំបាក ឬភ្នំដែលមិនរាបស្មើ ហើយយកមើមនឹងផ្លែក្នុងព្រៃ ជាអាហារចិញ្ចឹមជីវិត ។ សត្វទាំងនោះ នឹងចូលទៅរកស្មៅស្បាត ព្រៃស្បាត ឈើស្បាត ស្ទឹងដែលទៅមកបានដោយលំបាក ឬភ្នំដែលមិនរាបស្មើ ហើយយកមើមនឹងផ្លែក្នុងព្រៃ ជាអាហារចិញ្ចឹមជីវិតអស់៧ថ្ងៃ ។ លុះថ្ងៃ៧នោះកន្លងទៅ ទើបសត្វអម្បាលនោះចេញមក អំពីស្មៅស្បាត អំពីព្រៃស្បាត អំពីឈើស្បាត អំពីស្ទឹងដែលទៅមកបានដោយលំបាក អំពីភ្នំដែលមិន

និក្ខមិត្វា អញ្ញមញ្ញំ អាលិង្គិត្វា សភាសុ(១) តា-
យិស្សន្តិ សមស្សាសិស្សន្តិ ទិដ្ឋា ភោ សត្តា
ជីវសិ ត្វំ(២) ទិដ្ឋា ភោ សត្តា ជីវសីតិ ។
អថខោ តេសំ ភិក្ខវេ សត្តានំ ឯវំ ភវិស្សតិ
មយំ ខោ អកុសលានំ ធម្មានំ សមាទានហេតុ
ឯវរូបំ(៣) អាយតំ ញាតិក្ខយំ បត្តា យន្នូន មយំ
កុសលំ ករេយ្យាម កឹ កុសលំ ករេយ្យាម
យន្នូន មយំ បាណាតិបាតា វិរមេយ្យាម ឥទំ កុសលំ
ធម្មំ សមាទាយ វត្តេយ្យាមាតិ ។ តេ បាណាតិបាតា
វិរមិស្សន្តិ ឥទំ កុសលំ ធម្មំ សមាទាយ វត្តិស្សន្តិ
តេ កុសលានំ ធម្មានំ សមាទានហេតុ អាយុនាបិ
វឌ្ឍិស្សន្តិ វណ្ណេនបិ វឌ្ឍិស្សន្តិ តេសំ អាយុនាបិ
វឌ្ឍមានានំ វណ្ណេនបិ វឌ្ឍមានានំ ទសវស្សាយុកានំ
មនុស្សានំ វីសតិវស្សាយុកា បុត្តា ភវិស្សន្តិ ។
អថខោ តេសំ ភិក្ខវេ សត្តានំ ឯវំ ភវិស្សតិ

---

១ ឱ. ម. សភា ។ ២ ឱ. ម. ត្វន្តិ ន ទិស្សតិ ។ ៣ ឱ. ឯវរូបន្តិ ន ទិស្សតិ ។

ពបស្មើ ហើយឱបគ្នាទៅវិញទៅមក រួចហើយនិយាយពក់ទាក់ លួងលោមគ្នាក្នុងកោងទាំងឡាយដោយពាក្យថា ម្នាលអ្នកដ៏ចំរើន អ្នករស់នៅដូចពួកសត្វ ដែលយើងបានឃើញហើយ ម្នាលអ្នកដ៏ចំរើន អ្នករស់នៅដូចពួកសត្វដែលយើងបានឃើញហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សត្វអម្បាលនោះ ទឹងមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកយើងនេះឯង បានដល់នូវការអស់ទៅ នៃញាតិជាច្រើនដូច្នេះ ព្រោះហេតុតែកាន់ធម៌ជាអកុសលទាំងឡាយ បើដូច្នោះមានតែពួកយើងធ្វើកុសលវិញ តើគួរធ្វើកុសលដូចម្ដេច ណ្ហើយចុះ ពួកយើងគួរវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាននូវកុសលធម៌នេះចុះ ។ ទើបសត្វទាំងនោះនាំគ្នាវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាន នូវកុសលធម៌នេះ សត្វទាំងនោះ ក៏ចំរើនអាយុ ចំរើនពណ៌សម្បុរឡើង ព្រោះហេតុដែលបានសមាទាននូវកុសលធម៌ទាំងឡាយ កាលសត្វទាំងនោះបានចំរើនអាយុ ចម្រើនពណ៌សម្បុរហើយ កូនទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ១០ ឆ្នាំ ក៏ត្រឡប់ទៅ ជាមានអាយុ ២០ ឆ្នាំឡើងវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សត្វអម្បាលនោះ ទឹងមានសេចក្ដីត្រិះរិះ យ៉ាងនេះថា

មយំ ខោ កុសលានំ ធម្មានំ សមាទានហេតុ អាយុ-
នាបិ វឌ្ឍាម វណ្ណេនបិ វឌ្ឍាម យន្នូន មយំ ភិយ្យោ-
សោ មត្តាយ កុសលំ ករេយ្យាម កឹ កុសលំ ក-
រេយ្យាម(១) យន្នូន មយំ អទិន្នាទានា វិរមេយ្យាម កា-
មេសុ មិច្ឆាចារា វិរមេយ្យាម(២) បិសុណាយ វាចាយ
វិរមេយ្យាម ផរុសាយ វាចាយ វិរមេយ្យាម សម្ផប្បលា-
បា វិរមេយ្យាម អភិជ្ឈំ បជហេយ្យាម ព្យាបាទំ បជ-
ហេយ្យាម មិច្ឆាទិដ្ឋឹ បជហេយ្យាម តយោ ធម្មេ
បជហេយ្យាម អធម្មរាគំ វិសមលោភំ មិច្ឆាធម្មំ យន្នូន
មយំ មត្តេយ្យា អស្សាម បេត្តេយ្យា សាមញ្ញា
ព្រហ្មញ្ញា កុលេ ជេដ្ឋាបចាយិនោ ឥទំ កុសលំ
ធម្មំ សមាទាយ វត្តេយ្យាមាតិ ។ តេ មត្តេយ្យា
ភវិស្សន្តិ បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេ
ជេដ្ឋាបចាយិនោ ឥទំ កុសលំ ធម្មំ សមាទាយ
វត្តិស្សន្តិ តេសំ(៣) កុសលានំ ធម្មានំ សមាទាន-
ហេតុ អាយុនាបិ វឌ្ឍិស្សន្តិ វណ្ណេនបិ វឌ្ឍិស្សន្តិ តេសំ

---

១ ឱ. កឹ កុសលំ ករេយ្យាមាតិ ន ទិស្សតិ ។ ២ ឱ. ម. ឯត្ថន្តរេ មុសាវាទា វិរមេយ្យាមាតិ ទិស្សតិ ។ ៣ ឱ. ម. តេ ។

ពួកយើងបានចំរើនអាយុ បានចំរើនពណ៌សម្បុរឡើងវិញ ព្រោះហេតុតែបានសមាទាន នូវកុសលធម៌ទាំងឡាយ បើដូច្នោះ ពួកយើងគួរធ្វើកុសលឲ្យច្រើនក្រៃលែង ជាងនេះទៅទៀត តើគួរធ្វើកុសលអ្វី ណ្ហើយចុះ ពួកយើងគួរវៀរចាកអទិន្នាទាន គួរវៀរចាកកាមេសុមិច្ឆាចារ គួរវៀរចាកបិសុណាវាចា គួរវៀរចាកផរុសវាចា គួរវៀរចាកសម្ផប្បលាបៈ គួរលះបង់អភិជ្ឈា គួរលះបង់ព្យាបាទ គួរលះបង់មិច្ឆាទិដ្ឋិចេញ គួរលះបង់ធម៌ ៣ ប្រការ គឺ អធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ចេញ បើដូច្នោះ ពួកយើងគួរជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងបុគ្គល ជាច្បងក្នុងត្រកូល ពួកយើងគួរនាំគ្នាប្រព្រឹត្ត សមាទាន នូវកុសលធម៌ទាំងនេះចុះ ។ សត្វទាំងនោះក៏ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្ត កោតក្រែងត្រកូលរៀមច្បង ប្រព្រឹត្តសមាទាន នូវកុសលធម៌នេះ ក៏បានចំរើនអាយុ ចំរើនពណ៌សម្បុរឡើងវិញ ព្រោះហេតុដែលបានសមាទាន នូវកុសលធម៌ទាំងនោះ កាលសត្វអម្បាលនោះចំរើន

អាយុនាបិ វឌ្ឍមានានំ វណ្ណេនបិ វឌ្ឍមានានំ វីសតិវស្សាយុកានំ មនុស្សានំ ចត្តារីសវស្សាយុកា បុត្តា ភវិស្សន្តិ ។ ចត្តារីសវស្សាយុកានំ មនុស្សានំ អសីតិវស្សាយុកា បុត្តា ភវិស្សន្តិ ។ អសីតិវស្សាយុកានំ មនុស្សានំ សដ្ឋីវស្សសតាយុកា បុត្តា ភវិស្សន្តិ ។ សដ្ឋីវស្សសតាយុកានំ មនុស្សានំ វីសតិតិវស្សសតាយុកា បុត្តា ភវិស្សន្តិ ។ វីសតិតិវស្សសតាយុកានំ មនុស្សានំ ចត្តារីសចវស្សសតាយុកា(១) បុត្តា ភវិស្សន្តិ ។ ចត្តារីសចវស្សសតាយុកានំ មនុស្សានំ ទ្វេវស្សសហស្សាយុកា បុត្តា ភវិស្សន្តិ ។ ទ្វេវស្សសហស្សាយុកានំ មនុស្សានំ ចត្តារិវស្សសហស្សាយុកា បុត្តា ភវិស្សន្តិ ។ ចត្តារិវស្សសហស្សាយុកានំ មនុស្សានំ អដ្ឋវស្សសហស្សាយុកា បុត្តា ភវិស្សន្តិ ។

---

១ ឱ. វីសំតីតិវស្សសតាយុកា បុត្តា ភវិស្សន្តិ ។ វីសំតីតិវស្សសតាយុកានំ មនុស្សានំ ចត្តារីសំ ចតុវស្សសតាយុកា ។

អាយុចំរើនពណ៌សម្បុរឡើងហើយ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ២០ ឆ្នាំ ក៏មានអាយុ ៤០ ឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយ របស់ពួកមនុស្ស ដែលមានអាយុ ៤០ ឆ្នាំ ក៏មានអាយុ ៨០ ឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៨០ ឆ្នាំក៏មានអាយុ ១៦០ ឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ១៦០ ឆ្នាំ ក៏មានអាយុ ៣២០ ឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៣២០ ឆ្នាំ ក៏មានអាយុ ៦៤០ ឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៦៤០ ឆ្នាំ ក៏មានអាយុ២ពាន់ឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ២ពាន់ឆ្នាំ ក៏មានអាយុ ៤ ពាន់ឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៤ ពាន់ឆ្នាំ ក៏មានអាយុ ៨ពាន់ឆ្នាំឡើងវិញ ។

អដ្ឋវស្សសហស្សាយុកានំ មនុស្សានំ វីសតិវស្សសហស្សាយុកា បុត្តា ភវិស្សន្តិ ។ វីសតិវស្សសហស្សាយុកានំ មនុស្សានំ ចត្តាឡីសវស្សសហស្សាយុកា បុត្តា ភវិស្សន្តិ ។ ចត្តាឡីសវស្សសហស្សាយុកានំ មនុស្សានំ អសីតិវស្សសហស្សាយុកា បុត្តា ភវិស្សន្តិ ។

(៤៨) អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ បញ្ចវស្សសតិកា កុមារិកា អលំបតេយ្យា ភវិស្សន្តិ ។ អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ តយោ អាពាធា ភវិស្សន្តិ ឥច្ឆា អនសនំ ជរា ។ អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ អយំ ជម្ពុទីបោ ឥទ្ធោ ចេវ ភវិស្សតិ ផីតោ ច កុក្កុដសម្បាតិកា[១] គាមនិគមជនបទរាជធានិយោ ។ អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ អយំ ជម្ពុទីបោ អវីចិ មញ្ញេ ផុដោ[២] ភវិស្សតិ មនុស្សេហិ សេយ្យថាបិ នឡវនំ វា សរវនំ វា ។

---

១ កុក្កុដសម្បាទិកាតិបិ បាឋោ ។ ២ ម. ផុដ្ឋោ ។

កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៨ ពាន់ឆ្នាំ ក៏មានអាយុ ២ ម៉ឺនឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ២ ម៉ឺនឆ្នាំ ក៏មានអាយុ ៤ ម៉ឺនឆ្នាំឡើងវិញ ។ កូនចៅទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៤ ម៉ឺនឆ្នាំ ក៏មានអាយុ ៨ ម៉ឺនឆ្នាំ ឡើងវិញ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ ៨ ម៉ឺនឆ្នាំ ពួកនាងកុមារិកា មានអាយុ ៥០០ ឆ្នាំ ទើបល្មមឲ្យមានប្តី ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ ៨ ម៉ឺនឆ្នាំ នឹងមានអាពាធតែ ៣ យ៉ាង គឺចំណង់ក្នុងអាហារ ១ បរិភោគអាហារមិនបាន ១ សេចក្តីគ្រាំគ្រាពងកាយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលពួកមនុស្ស មានអាយុ ៨ ម៉ឺនឆ្នាំ ជម្ពូទ្វីបនេះ នឹងជាទ្វីបស្តុកស្តម្ភធំទូលាយ មានស្រុក និគម រាជធានី (តៗគ្នា) មួយរយៈមាន់ហើរធ្លាក់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ជម្ពូទ្វីបនេះនឹងពេញ ដោយពួកមនុស្ស (រកចន្លោះគ្មាន) ដូចអវីចិនរក ពុំនោះសោត ដូចព្រៃប្របុស ឬព្រៃពំងក្នុ ។

## ចក្កវត្តិសុត្តេ សង្ខរាជុប្បត្តិ

អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ អយំ ពារាណសី កេតុមតី នាម រាជធានី ភវិស្សតិ ឥទ្ធា ចេវ ផីតា ច ពហុជនា ច អាកិណ្ណមនុស្សា ច សុភិក្ខា ច ។ អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ ឥមស្មឹ ជម្ពុទីបេ ចតុរាសីតិនគរសហស្សានិ ភវិស្សន្តិ កេតុមតីរាជធានីបមុខានិ ។ អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ កេតុមតីរាជធានិយា[១] សង្ខោ នាម រាជា ឧប្បជ្ជិស្សតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ ។ តស្សិមានិ សត្ត រតនានិ ភវិស្សន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ ។ បរោសហស្សំ ខោ បនស្ស បុត្តា ភវិស្សន្តិ សូរា វីរង្គរូបា[២] បរសេនប្បមទ្ទនា ។ សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសិស្សតិ ។

---

១ ខ. កេតុមតិយា រាជធានិយា ។ ២ រង្គរូបាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ ៨ ម៉ឺនឆ្នាំ ក្រុងពារាណសីនេះ នឹងប្រែឈ្មោះជាកេតុមតីរាជធានីវិញ ជារាជធានី ស្តុកស្តម្ភ ធំទូលាយ មានជនក៏ច្រើន មានមនុស្សកុះករ នឹងមានភិក្ខាហារដ៏សម្បូណ៌ ៗ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ៨ម៉ឺនឆ្នាំ ក្នុងជម្ពូទ្វីបនេះ នឹងមាននគរ ៨ម៉ឺន៤ពាន់ មានកេតុមតីរាជធានីឯងជាប្រធាន ៗ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ៨ម៉ឺនឆ្នាំ នឹងមានព្រះរាជា(១ព្រះអង្គ)ព្រះនាមសង្ខៈទ្រង់កើតឡើង ក្នុងកេតុមតីរាជធានី ជាស្តេចចក្រពត្តិ ទ្រង់ជាធម្មិកធម្មរាជ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវថិរភាព ទ្រង់បរិបូណ៌ ដោយរ័តន៍ ៧ ប្រការ ៗ ឯរ័តន៍ទាំង ៧ ប្រការរបស់ព្រះបាទសង្ខៈនោះគឺ ចក្ករ័តន៍ ១ ហត្ថិរ័តន៍ ១ អស្សរ័តន៍ ១ មណិរ័តន៍ ១ ឥត្ថីរ័តន៍ ១ គហបតិរ័តន៍ ១ រាប់បរិនាយករ័តន៍ ១ ផង ជាគម្រប់ ៧ ៗ ឯព្រះបាទសង្ខៈនោះ នឹងមានព្រះរាជបុត្រ ច្រើនជាងពាន់ សុទ្ធសឹងក្លៀវក្លា អង់អាច សង្កត់សង្កិននូវពួកសេនា របស់ស្តេចដទៃបាន ៗ ព្រះបាទសង្ខៈនោះ ទ្រង់គ្រួតត្រាគ្រប់គ្រង នូវផែនដី ដែលមានសាគរជាទីបំផុត ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ ៗ

អសីតិវស្សសហស្សាយុកេសុ ភិក្ខវេ មនុស្សេសុ មេត្តេយ្យោ នាម ភគវា លោកេ ឧប្បជ្ជិស្សតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សេយ្យថាបាហមេតរហិ លោកេ ឧប្បន្នោ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ។ សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេស្សតិ

ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ៨ម៉ឺនឆ្នាំ ព្រះមានព្រះភាគទ្រង់ព្រះនាមមេត្តេយ្យៈ នឹងកើតឡើងក្នុងលោក ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានឹងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់ នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃកត ខាងលើហើយ ដូចជាតថាគត ដែលឆ្ងាយចាកកិលេស ត្រាស់ដឹងញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះខ្លួនឯង បរិបូណ៌ដោយវិជ្ជានឹងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តានៃទេវតា នឹងមនុស្សទាំងឡាយ ជ្រាបច្បាស់នូវចតុរារិយសច្ច មានដំណើរទៅកាន់ត្រៃកត ខាងលើហើយ ដែលកើតឡើងក្នុងលោក ក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យៈ មានព្រះភាគអង្គនោះ ទ្រង់បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ នូវព្រះនិញ្វានចំពោះព្រះអង្គ ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនឹងមនុស្ស

សេយ្យថាបាហមេតរហិ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេមិ ។ សោ ធម្មំ ទេសេស្សតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេស្សតិ សេយ្យថាបាហមេតរហិ ធម្មំ ទេសេមិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេមិ ។ សោ អនេកសហស្សំ[1]) ភិក្ខុសង្ឃំ បរិហរិស្សតិ សេយ្យថាបាហំ ឯតរហិ អនេកសតំ ភិក្ខុសង្ឃំ បរិហរាមិ ។ អថខោ ភិក្ខវេ សង្ខោ នាម រាជា យោ សោ[2]) យូបោ រញ្ញា មហាបនាទេន ការាបិតោ តំ យូបំ ឧស្សាបេត្វា អជ្ឈាវសិត្វា វិសជ្ជិត្វា[3]) សមណព្រាហ្មណកបណទ្ធិកវណិព្វកយាចកានំ ទានំ ទត្វា

---

១ ម. អនេកសតសហស្សំ ។ ២ ខ. យោនស្ស ។ ៣ ខ. ទទិត្វា វិសជ្ជេត្វា ។ ម. តំ ទត្វា វិសជ្ជិត្វា ។

ដ៏សេសឲ្យត្រាស់ដឹងផង ដូចតថាគតដែលបានត្រាស់ដឹង ហើយធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វានចំពោះខ្លួនឯង ហើយញ៉ាំងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញ៉ាំងពពួកសត្វព្រមទាំងសមណៈនឹងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេសឲ្យត្រាស់ដឹងផង ក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យៈមានព្រះភាគអង្គនោះ នឹងទ្រង់សំដែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ទាំងទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថនឹងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ដូចតថាគតដែលសំដែងធម៌ ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថនឹងព្យញ្ជនៈដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យៈមានព្រះភាគអង្គនោះ នឹងគ្រប់គ្រងនូវភិក្ខុសង្ឃច្រើនពាន់ ដូចតថាគតដែលគ្រប់គ្រងនូវភិក្ខុសង្ឃច្រើនរយ ក្នុងកាលឥឡូវនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទសង្ខៈទ្រង់ត្រាស់បង្គាប់ឲ្យលើកប្រាសាទ ដែលព្រះបាទមហាបនាទៈឲ្យកសាង ហើយទ្រង់ប្រថាប់នៅ (ក្នុងប្រាសាទនោះ) ទ្រង់លះបង់[១] (ប្រាសាទនោះ) ឲ្យជាទាន ដល់ពួកសមណព្រាហ្មណ៍ កបណៈ (មនុស្សកំព្រា) អទ្ធិកៈ (អ្នកដំណើរ) វណិព្វកៈ (អ្នកនិយាយសរសើរហើយសូម) នឹងពួកយាចក (សូម) រូប

១ អដ្ឋកថា ថា ទ្រង់អធិដ្ឋានឲ្យប្រាសាទនោះបែកខ្ទេច ហើយទ្រង់ព្រះរាជទាន ។

មេត្តេយ្យស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិ-
កេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ
អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សតិ ។
សោ ឯវំ បព្វជិតោ សមានោ ឯកោ វូបកដ្ឋោ
អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ
យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អន-
គារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ
ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧប-
សម្បជ្ជ វិហរិស្សតិ ។

(៨៩) អត្តទីបា ភិក្ខវេ វិហរថ អត្តសរណា
អនញ្ញសរណា ធម្មទីបា ធម្មសរណា អនញ្ញស-
រណា ។ កថញ្ច ភិក្ខវេ ភិក្ខុ អត្តទីបោ វិហរតិ
អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មស-
រណោ អនញ្ញសរណោ ។ ឥធ ភិក្ខវេ ភិក្ខុ

ទ្រង់ដាក់ព្រះកេសានិងព្រះមស្សុ ទ្រង់ស្លៀកដណ្តប់កាសាវព័ស្ត្រ ចេញចាកកជាគារស្ថាន បួសទៅកាន់ផ្នួស ក្នុងសំណាក់នៃព្រះមេត្តេយ្យៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ កាលព្រះបាទសង្ខៈនោះ ទ្រង់ព្រះផ្នួសយ៉ាងនេះហើយ ទ្រង់គេចចេញទៅតែមួយព្រះអង្គឯង ឥតមានសេចក្តីប្រមាទឡើយ មានសេចក្តីព្យាយាម ដាក់គ្រឿងដុតបង់នូវកិលេស មានព្រះហឫទ័យបែរឆ្ពោះ ទៅរកព្រះនិព្វាន ពួកកុលបុត្រដែលចេញចាកផ្ទះទៅបួសក្នុងភាពជាបុគ្គលមិនមានផ្ទះ ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ពុំយូរប៉ុន្មាន ក៏ព្រះសង្ខត្ថេរ បានត្រាស់ដឹងបានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចារ្យ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ក៏សម្រាកសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

(៤៩) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃ ជាទីពឹងពំនាក់ឡើយ ចូរមានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ កុំមានរបស់ដទៃ ជាទីពឹងពំនាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹងពំនាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា

កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុ-បស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អត្តទីបោ វិហរតិ អត្តសរណោ អនញ្ញសរណោ ធម្មទីបោ ធម្មសរណោ អនញ្ញសរណោ ។

(៥០) គោចរេ ភិក្ខវេ ចរថ សកេ បេត្តិកេ វិស-យេ ។ គោចរេ ភិក្ខវេ ចរន្តា សកេ បេត្តិកេ វិសយេ

នេះ ពិចារណានូវកាយ ក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកបាន ពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតបង់នូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកបាន ពិចារណានូវចិត្ត ក្នុងចិត្តជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតបង់នូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់ នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកបាន ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតបង់នូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកំចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកបាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។

(៩០) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្ត ក្នុងគោចរជាវិស័យ ដែលមានមកអំពីបិតានៃខ្លួន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយប្រព្រឹត្ត ក្នុងគោចរជាវិស័យ ដែលមានមកអំពីបិតានៃខ្លួន

អាយុនាបិ វឌ្ឍិស្សថ វណ្ណេនបិ វឌ្ឍិស្សថ សុខេនបិ វឌ្ឍិស្សថ ភោគេនបិ វឌ្ឍិស្សថ ពលេនបិ វឌ្ឍិស្សថ ។ កិញ្ច ភិក្ខវេ ភិក្ខុនោ អាយុស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិប្បធាន...ចិត្តសមាធិប្បធាន...វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ សោ ឥមេសំ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ ឥទំ ខោ ភិក្ខវេ ភិក្ខុនោ អាយុស្មឹ(១) ។ កិញ្ច ភិក្ខវេ ភិក្ខុនោ វណ្ណស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ ឥទំ ខោ ភិក្ខវេ ភិក្ខុនោ វណ្ណស្មឹ ។ កិញ្ច ភិក្ខវេ ភិក្ខុនោ សុខស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច

១ ឧ. អាយុស្មឹ វាចមិ ។

ហើយ នឹងចំរើនអាយុផង ចំរើនពណ៌សម្បុរផង ចំរើនសេចក្ដីសុខផង ចំរើនភោគៈផង ចំរើនកំឡាំងផង ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី (ជាហេតុឲ្យចំរើន) អាយុរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនឥទ្ធិបាទប្រកបដោយឆន្ទសមាធិ នឹងបធានសង្ខារ ចំរើនឥទ្ធិបាទប្រកបដោយវិរិយសមាធិ នឹងបធានសង្ខារ... ចិត្តសមាធិនឹងបធានសង្ខារ...វីមំសាសមាធិនឹងបធានសង្ខារ ភិក្ខុនោះ បើមានបំណង (នឹងរស់នៅ) គប្បីឋិតនៅអស់ ១ អាយុកប្ប ឬ ១ អាយុកប្បច្ចាយ ព្រោះហេតុដែលបានចំរើន បានធ្វើឲ្យច្រើន នូវឥទ្ធិបាទទាំង ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង (ជាហេតុឲ្យចំរើន) អាយុរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី (ជាហេតុឲ្យចំរើន) ពណ៌សម្បុររបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនឹងគោចរៈ ជាអ្នកឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង (ជាហេតុឲ្យចំរើន) សម្បុររបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី (ជាហេតុឲ្យចំរើន) សេចក្ដីសុខរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ

អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិ-
សុខំ បឋមំ ឈានំ(១) ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ
វូបសមា ។ បេ ។ ទុតិយំ ឈានំ ។ តតិយំ
ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។
ឥទំ ខោ ភិក្ខវេ ភិក្ខុនោ សុខស្មឹ ។ កិញ្ច ភិក្ខវេ
ភិក្ខុនោ ភោគស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុ មេត្តាសហគតេន
ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ
តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ
សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហ-
គតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន
អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ ករុណា-
សហគតេន ចេតសា ។ មុទិតាសហគតេន ចេតសា ។
ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា
វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ
ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ
លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន

---

១ ខ. បឋមជ្ឈានំ ។

## ចក្កវត្តិសូត្រ និយាយអំពីឈានទាំង ៤

ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្ក វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ជាអារម្មណ៍ ភិក្ខុនោះ លុះរម្ងាប់វិតក្កវិចារៈរួចហើយ ៗ ។ល។ ក៏ចូលទុតិយជ្ឈាន ៗ ចូលតតិយជ្ឈាន ៗ ចូលចតុត្ថជ្ឈាន ៗ ម្នាលភិក្ខុទាំងឡាយ នេះឯង (ជាហេតុឲ្យចំរើន) សេចក្ដីសុខរបស់ភិក្ខុ ៗ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី (ជាហេតុឲ្យចំរើន) ភោគៈរបស់ភិក្ខុ ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិស១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតមានពៀរ ឥតមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួន ឲ្យស្មើនឹងសត្វទាំងអស់ ក្នុងទិសទាំងពួង ៗ មានចិត្តប្រកបដោយករុណា ៗ មានចិត្តប្រកបដោយមុទិតា ៗ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយឧបេក្ខា ដ៏ធំទូលាយ រក

មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ ឥទំ ខោ ភិក្ខវេ ភិក្ខុនោ ភោគស្មឹ ។ កិញ្ច ភិក្ខវេ ភិក្ខុនោ ពលស្មឹ ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ(១) បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥទំ ខោ ភិក្ខវេ ភិក្ខុនោ ពលស្មឹ ។ នាហំ ភិក្ខវេ អញ្ញំ ឯកពលម្បិ សមនុបស្សាមិ ឯវំ ទុប្បសហំ យថយិទំ ភិក្ខវេ មារពលំ កុសលានំ ភិក្ខវេ ធម្មានំ សមាទានហេតុ ឯវមិទំ បុញ្ញំ បវឌ្ឍតីតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ចក្កវត្តិសុត្តំ តតិយំ(២) និដ្ឋិតំ ។

---

១ ឱ. អនាសវំ ចេតោវិមុត្តឹ ។ ២ ឱ. ចក្កវត្តិសីហនាទសុត្តំ តតិយំ ។ ម. ចក្កវត្តិសុត្តំ តតិយំ ។

ប្រមាណមិនបាន ជាចិត្តឥតមានចងពៀរ ឥតមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួន ឲ្យស្មើនឹងសត្វទាំងអស់ក្នុងទិសទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ នេះឯង (ជាហេតុឲ្យចំរើន) ភោគៈរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី (ជាហេតុឲ្យចំរើន) កំឡាំងរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានត្រាស់ដឹង បានធ្វើជាក់ច្បាស់ ដោយខ្លួនឯង នូវចេតោវិមុត្តិនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយក្នុងបច្ចុប្បន្ននេះ ហើយសម្រាកសម្រាន្ត ដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង (ជាហេតុឲ្យចំរើន) កំឡាំងរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមើល មិនឃើញកំឡាំងដទៃ សូម្បីតែកំឡាំង ១ ដែលបុគ្គលគ្របសង្កត់បានដោយកម្រ ឲ្យដូចជាកំឡាំងនៃមារនេះឡើយ ម្នាលភិក្ខុទាំងឡាយ បុណ្យនេះ តែងចំរើនឡើងយ៉ាងនេះ ព្រោះហេតុសមាទាន នូវកុសលធម៌ទាំងឡាយ ។ លុះព្រះមានព្រះភាគទ្រង់សំដែង នូវព្រះសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរកាយ បំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ចក្កវត្តិសូត្រ ទី ៣ ។

# អគ្គញ្ញសុត្តំ ចតុត្ថំ

(៥១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ ។ តេន ខោ បន សមយេន វាសេដ្ឋភារទ្វាជា ភិក្ខូសុ បរិវសន្តិ(១) ភិក្ខុភាវំ អាកង្ខមានា ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ បាសាទា ឱរោហិត្វា បាសាទបច្ឆាយាយំ(២) អព្ភោកាសេ ចង្កមតិ ។ អទ្ទសា ខោ វាសេដ្ឋោ ភគវន្តំ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតំ បាសាទា ឱរោហិត្វា បាសាទបច្ឆាយាយំ អព្ភោកាសេ ចង្កមន្តំ ទិស្វាន(៣) ភារទ្វាជំ អាមន្តេសិ អយំ អាវុសោ ភារទ្វាជ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ បាសាទា ឱរោហិត្វា បាសាទបច្ឆាយាយំ អព្ភោកាសេ ចង្កមតិ អាយាមាវុសោ ភារទ្វាជ យេន ភគវា តេនុបសង្ក-

---

១ ម. បរិវសន្តិ ។ ២ ម. បាសាទច្ឆាយាយំ ។ ៣ ខ. ទិស្វា ។

# អគ្គញ្ញសូត្រ ទី ៤

(៨១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ របស់មិគារមាតា (នាងវិសាខា) ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង វាសេដ្ឋសាមណេរ នឹងភារទ្វាជសាមណេរ[1] មានប្រាថ្នានឹងបួសជាភិក្ខុ ទើបនៅតិត្ថិយបរិវាស ក្នុងសំណាក់ភិក្ខុទាំងឡាយ ។ លំដាប់នោះឯង វេលាថ្ងៃរសៀល ព្រះមានព្រះភាគ ទ្រង់ចេញចាកទីសម្ងំ ហើយចុះអំពីប្រាសាទ ទៅចង្ក្រមក្នុងទីវាល ត្រង់ម្លប់ប្រាសាទ ។ ឯវាសេដ្ឋសាមណេរ ក៏បានឃើញព្រះមានព្រះភាគ ដែលទ្រង់ចេញចាកទីសម្ងំ ក្នុងវេលាថ្ងៃរសៀល ហើយចុះអំពីប្រាសាទ ទៅចង្ក្រមក្នុងទីវាល ត្រង់ម្លប់ប្រាសាទ លុះឃើញហើយ ក៏ប្រាប់ភារទ្វាជសាមណេរថា ម្នាលអាវុសោភារទ្វាជៈ ព្រះមានព្រះភាគនេះ ទ្រង់ចេញចាកទីសម្ងំ ក្នុងវេលាថ្ងៃរសៀល ហើយចុះអំពីប្រាសាទ កំពុងចង្ក្រមក្នុងទីវាល ត្រង់ម្លប់ប្រាសាទ ម្នាលអាវុសោភារទ្វាជៈ មក យើងនឹងចូលទៅ

---

១ អដ្ឋកថា ថា សាមណេរទាំងពីររូបនេះ កើតក្នុងត្រកូលព្រាហ្មណមហាសាល មានទ្រព្យ ៤០ កោដិដូចគ្នា ជាអ្នកបានរៀនចេះចប់ត្រៃវេទ បានស្តាប់វាសេដ្ឋសូត្រហើយក៏ដល់សរណគមន៍ លុះស្តាប់តេវិជ្ជសូត្រហើយ ក៏បួសជាសាមណេរ ដល់ពេលនេះ មានប្រាថ្នានឹងបួសជាភិក្ខុទៀត ទើបនៅតិត្ថិយបរិវាស ។

មិស្សាម អប្បេវនាម លភេយ្យាម ភគវតោ សម្មុខា(១) ធម្មិំ កថំ សវនាយាតិ ។ ឯវមាវុសោតិ ខោ ភារទ្វាជោ វាសេដ្ឋស្ស បច្ចស្សោសិ ។ អថ ខោ វាសេដ្ឋភារទ្វាជា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ភគវន្តំ ចង្កមន្តំ អនុចង្កមឹសុ ។ អថ ខោ ភគវា វាសេដ្ឋំ អាមន្តេសិ តុម្ហេ ខ្វត្ថ វាសេដ្ឋា(២) ព្រាហ្មណជច្ចា ព្រាហ្មណកុលីនា ព្រាហ្មណកុលា អគារស្មា អនគារិយំ បព្វជិតា កច្ចិ វោ វាសេដ្ឋា ព្រាហ្មណា ន អក្កោសន្តិ ន បរិភាសន្តីតិ ។ តគ្ឃ នោ ភន្តេ ព្រាហ្មណា អក្កោសន្តិ បរិភាសន្តិ អត្តរូបាយ បរិភាសាយ បរិបុណ្ណាយ នោ អបរិបុណ្ណាយាតិ ។ យថាកថំ បន វោ វាសេដ្ឋា ព្រាហ្មណា អក្កោសន្តិ បរិភាសន្តិ អត្តរូបាយ បរិភាសាយ បរិបុណ្ណាយ នោ អបរិបុណ្ណាយាតិ ។ ព្រាហ្មណា ភន្តេ ឯវមាហំសុ ព្រាហ្មណោ វ

---

១ ឱ. សន្តិកា ។ ម. សម្មុខា ។ ២ ម. វាសេដ្ឋ ។ ឯវំ សព្វត្ថាលបនបទេសុ អដ្ឋកថាយម្បិ ឯវមេវ ។

គាល់ព្រះមានព្រះភាគ ក្រែងលោយើងនឹងបានស្តាប់ធម្មីកថា ចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ។ ភារទ្វាជសាមណេរ ក៏បានទទួលស្តាប់ពាក្យវាសេដ្ឋសាមណេរ ថា អេវមាវុសោ ។ គ្រានោះឯង វាសេដ្ឋសាមណេរ នឹងភារទ្វាជសាមណេរ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏ដើរតាមព្រះមានព្រះភាគ ដែលកំពុងចង្រ្កម ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូល នឹងវាសេដ្ឋសាមណេរថា ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ អ្នកទាំងឡាយ ជាជាតិព្រាហ្មណ៍ ជាត្រកូលព្រាហ្មណ៍ បានលះបង់ត្រកូលព្រាហ្មណ៍ ចេញចាកផ្ទះចូលមកកាន់ផ្នួស ចុះពួកព្រាហ្មណ៍ដ៏ប្រសើរ មិនជេរ មិនប្រទេចអ្នកទាំងឡាយទេឬ ។ វាសេដ្ឋសាមណេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ពួកព្រាហ្មណ៍ជេរប្រទេចយើងទាំងឡាយ ដោយពាក្យប្រទេច តាមចិត្តគេពេញទី មិនមែនខ្វះកន្ទះទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ ចុះពួកព្រាហ្មណ៍ ជេរប្រទេចអ្នកទាំងឡាយ ដោយពាក្យប្រទេច តាមចិត្តគេពេញទី មិនមែនខ្វះកន្ទះទេ តើដូចម្តេច ។ វាសេដ្ឋសាមណេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើនពួកព្រាហ្មណ៍និយាយយ៉ាងនេះថា មានតែព្រាហ្មណ៍

## អគ្គញ្ញសុត្តំ ចតុវណ្ណកថា

សេដ្ឋោ វណ្ណោ ហីនា អញ្ញេ វណ្ណា(១) ព្រាហ្មណោវ សុក្កោ វណ្ណោ កណ្ហា អញ្ញេ វណ្ណា(២) ព្រាហ្មណាវ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា(៣) ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទា តេ តុម្ហេ សេដ្ឋំ វណ្ណំ ហិត្វា ហីនមត្ថ វណ្ណំ អជ្ឈុបគតា យទិទំ មុណ្ឌកេ សមណកេ ឥព្ភេ កណ្ហេ ពន្ធុ បាទាបច្ចេតិ(៤) ។ តយិទំ ន សាធុ តយិទំ នប្បតិរូបំ យំ តុម្ហេ សេដ្ឋំ វណ្ណំ ហិត្វា ហីនមត្ថ វណ្ណំ អជ្ឈុបគតា យទិទំ មុណ្ឌកេ សមណកេ ឥព្ភេ កណ្ហេ ពន្ធុ បាទាបច្ចេតិ ។ ឯវំ ខោ នោ ភន្តេ ព្រាហ្មណា អក្កោសន្តិ បរិភាសន្តិ អត្តរូបាយ បរិភាសាយ បរិបុណ្ណាយ នោ អបរិបុណ្ណាយាតិ ។ តគ្ឃ វោ វាសេដ្ឋ ព្រាហ្មណា បោរាណំ អស្សរន្តា ឯវមាហំសុ

---

១ ឱ. ហីនោ អញ្ញោ វណ្ណោ ។ ២ ឱ. កណ្ហោ អញ្ញោ វណ្ណោ ។ ៣ ឱ. ម. ព្រាហ្មណាវ ។ ៤ ម. បច្ចេ ។

ទើបជាវណ្ណៈ[១]ប្រសើរបំផុត ពួកជនឯទៀត ជាវណ្ណៈថយថោក មានតែព្រាហ្មណ៍ ទើបជាវណ្ណៈស ពួកជនឯទៀត ជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍ មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឧស្ឋព្រហ្ម កើតមកអំពីព្រហ្ម ព្រហ្មបានតាក់តែងមក ជាទាយាទ[២]របស់ព្រហ្ម ឯអ្នកទាំងឡាយនោះ លះបោលវណ្ណៈដ៏ប្រសើរចេញ ហើយត្រឡប់មកកាន់វណ្ណៈថយថោកវិញ គឺត្រឡប់ចូលទៅ ក្នុងសំណាក់សមណៈត្រងោល ជាគហបតី វណ្ណៈខ្មៅជាពួកនៃមារ កើតអំពីព្រះបាទព្រហ្ម ក៏អ្នកទាំងឡាយលះបោលវណ្ណៈដ៏ប្រសើរចេញ ហើយត្រឡប់មកកាន់វណ្ណៈថយថោកវិញ គឺត្រឡប់ចូលទៅ ក្នុងសំណាក់សមណៈត្រងោល ជាគហបតី វណ្ណៈខ្មៅជាពួកនៃមារ កើតមកអំពីព្រះបាទព្រហ្ម ដោយហេតុណា ហេតុនោះពុំប្រពៃ ពុំសមគួរឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ពួកព្រាហ្មណ៍ជេរប្រទេចយើងទាំងឡាយ ដោយពាក្យប្រទេច តាមចិត្តគេពេញទី មិនមែនខ្វះកន្ទះទេ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើកសេដ្ឋៈ នឹងភារទ្វាជៈ ពួកព្រាហ្មណ៍របស់អ្នកទាំងឡាយ មិនបានដឹងនូវការកើតឡើង នៃលោកអំពីដើមមកទេ ទើបបានជានិយាយយ៉ាងនេះថា

---

១ ពាក្យថា វណ្ណៈនេះ តាមដំណើរដើម សំដៅយកពណ៌សំបៀកបំពាក់ ជាគ្រឿងសំគាល់ជាតិ ។ ២ ញាតិអ្នកទទួលកេរ្តិ៍សំបាច់ ។

ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ព្រាហ្មណោវ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណាវ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ។ ទិស្សន្តិ ខោ បន វាសេដ្ឋ ព្រាហ្មណានំ ព្រាហ្មណិយោ ឧតុនិយោបិ គព្ភិនិយោបិ វិជាយមានាបិ បាយមានាបិ តេ ច ព្រាហ្មណា យោនិជាវ សមានា ឯវមាហំសុ ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ ។ តេ ច(១) ព្រហ្មានញ្ចេវ អព្ភាចិក្ខន្តិ មុសា ច ភាសន្តិ ពហុញ្ច អបុញ្ញំ បសវន្តិ ។

[៥២] ចត្តារោមេ វាសេដ្ឋ វណ្ណា(២) ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ។ ខត្តិយោបិ ខោ វាសេដ្ឋ ឥធេកច្ចោ បាណាតិបាតី ហោតិ

---

១ ឱ បសត្ថោ ន ទិស្សតិ ។ ២ ឱ. ម. វាសេដ្ឋ វណ្ណា ។

មានតែព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថយថោក មានតែព្រាហ្មណ៍ ទើបជាវណ្ណៈស ពួកជនឯទៀត ជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍ ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍ មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតអំពីព្រហ្ម ព្រហ្មបានតាក់តែងមក ជាទាយាទរបស់ព្រហ្ម ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ឯពួកនាងព្រាហ្មណី ដែលមានរដូវក្តី មានគភ៌ក្តី កំពុងសម្រាលកូនក្តី កំពុងបំបៅកូនក្តី សឹងប្រាកដដល់ពួកព្រាហ្មណី ឯព្រាហ្មណ៍ទាំងនោះ ក៏សុទ្ធតែកើតមកអំពីយោនី (នាងព្រាហ្មណី) តែត្រឡប់ជានិយាយយ៉ាងនេះវិញថា មានតែព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរបំផុត ។ បេ ។ ជាទាយាទរបស់ព្រហ្មដូច្នេះ ។ ឯព្រាហ្មណ៍ទាំងនោះ ឈ្មោះថា និយាយបង្អាប់ព្រហ្មផង និយាយកុហកផង រមែងទទួលនូវបាបច្រើន ។

(៨២) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ វណ្ណៈទាំងឡាយនេះមាន ៤ ពួក គឺខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ទោះខត្តិយៈពួកខ្លះ ក្នុងលោកនេះ ក៏ជាអ្នកសម្លាប់សត្វ

អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋិ(១) ។ ឥតិ ខោ វាសេដ្ឋា យេមេ ធម្មា អកុសលា អកុសលសង្ខាតា សាវជ្ជា សាវជ្ជសង្ខាតា អសេវិតព្វា អសេវិតព្វសង្ខាតា នាលមរិយា នាលមរិយសង្ខាតា កណ្ហា កណ្ហវិបាកា វិញ្ញុគរហិតា ។ ខត្តិយេបិ តេ ឥធេកច្ចេ សន្ទិស្សន្តិ ។ ព្រាហ្មណេបិ ខោ វាសេដ្ឋា ។ បេ ។ វេស្សេបិ ខោ វាសេដ្ឋា ។ បេ ។ សុទ្ទេបិ ខោ វាសេដ្ឋា ឥធេកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋិ ។ ឥតិ ខោ វាសេដ្ឋា យេមេ ធម្មា អកុសលា អកុសលសង្ខាតា ។ បេ ។ កណ្ហា កណ្ហវិបាកា វិញ្ញុគរហិតា ។ សុទ្ទេបិ តេ ឥធេកច្ចេ សន្ទិស្សន្តិ ។

---

១ ឱ. អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋិ ហោតិ ។

លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ជាអ្នកមានសេចក្ដីលោភ មានចិត្តប្រកបដោយព្យាបាទ មានសេចក្ដីយល់ខុសដែរ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណា ជាអកុសល ក៏រាប់ថា ជាអកុសល ដែលមានទោស ក៏រាប់ថា មានទោស ដែលមិនគួរសេព ក៏រាប់ថា មិនគួរសេព ដែលមិនសមគួរក្នុងអរិយការៈ ក៏រាប់ថា មិនសមគួរក្នុងអរិយការៈ ជាធម៌ខ្មៅ មានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល ។ ធម៌ទាំងឡាយនោះ តែងប្រាកដក្នុងខត្តិយៈពួកខ្លះ ក្នុងលោកនេះឯង ។ ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ ទោះព្រាហ្មណ៍ ។បេ។ ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ ទោះវេស្សៈ ។បេ។ ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ ទោះសុទ្ទៈពួកខ្លះ ក្នុងលោកនេះ ក៏ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ។ បេ ។ មានសេចក្ដីយល់ខុសដែរ ។ ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណា ជាអកុសល ក៏រាប់ថា ជាអកុសល ។ បេ ។ ជាធម៌ខ្មៅ មានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល ។ ធម៌ទាំងឡាយនោះ តែងប្រាកដក្នុងសុទ្ទៈពួកខ្លះ ក្នុងលោកនេះឯង ។

[៨៣] ខត្តិយោបិ ខោ វាសេដ្ឋ ឥធេកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ (១) អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ បិសុណាយ វាចាយ បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈាលុ អព្យាបន្នចិត្តោ សម្មាទិដ្ឋី ។ ឥតិ ខោ វាសេដ្ឋ យេមេ ធម្មា កុសលា កុសលសង្ខាតា អនវជ្ជា អនវជ្ជសង្ខាតា សេវិតព្វា សេវិតព្វសង្ខាតា អលមរិយា អលមរិយសង្ខាតា សុក្កា សុក្កវិបាកា វិញ្ញុបសត្ថា ។ ខត្តិយេបិ តេ ឥធេកច្ចេ សន្ទិស្សន្តិ ។ ព្រាហ្មណោបិ ខោ វាសេដ្ឋ ។ វេស្សោបិ ខោ វាសេដ្ឋ ។ សុទ្ទោបិ ខោ វាសេដ្ឋ ឥធេកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ អនភិជ្ឈាលុ អព្យាបន្នចិត្តោ សម្មាទិដ្ឋី ។ ឥតិ ខោ វាសេដ្ឋ យេមេ ធម្មា កុសលា កុសលសង្ខាតា អនវជ្ជា អនវជ្ជសង្ខាតា សេវិតព្វា សេវិតព្វសង្ខាតា អលមរិយា អលមរិយ-

---

១ ម. ហោតីតិ សព្វត្ថ បទេសុ ទិស្សតិ ។

(៩៣) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះខត្តិយៈពួកខ្លះក្នុងលោកនេះ ក៏ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ ជាអ្នកមិនមានសេចក្តីលោភ មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវដែរ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណាជាកុសល ក៏រាប់ថា ជាកុសល ដែលមិនមានទោស ក៏រាប់ថា មិនមានទោស ដែលគួរសេព ក៏រាប់ថា គួរសេព ដែលសមគួរក្នុងអរិយការៈ ក៏រាប់ថា សមគួរក្នុងអរិយការៈ ជាធម៌ស មានផលស ដែលវិញ្ញូជនតែងសរសើរ ។ ធម៌ទាំងឡាយនោះ តែងប្រាកដក្នុងខត្តិយៈ ពួកខ្លះ ក្នុងលោកនេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះព្រាហ្មណ៍ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះវេស្សៈ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះសុទ្ទៈពួកខ្លះ ក្នុងលោកនេះក៏ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ ជាអ្នកមិនមានសេចក្តីលោភ មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវដែរ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណាជាកុសល ក៏រាប់ថា ជាកុសល ដែលមិនមានទោស ក៏រាប់ថា មិនមានទោស ដែលគួរសេព ក៏រាប់ថា គួរសេព ដែលសមគួរក្នុងអរិយការៈ ក៏រាប់ថា សមគួរក្នុងអរិយការៈ

## អគ្គញ្ញសុត្តេ សុក្កកណ្ហធម្មកថា

សម្មតា សុក្កា សុក្កវិបាកា វិញ្ញុប្បសត្ថា ។ សុទ្ទេបិ តេ ឥធេកច្ចេ សន្ទិស្សន្តិ ។ ឥមេសុ ខោ វាសេដ្ឋ ចតូសុ វណ្ណេសុ ឯវំឧភយព្យោកិណ្ណេសុ វត្តមានេសុ កណ្ហសុក្កេសុ ធម្មេសុ វិញ្ញុគរហិតេសុ ចេវ វិញ្ញុ-បសត្ថេសុ ច យទេត្ថ ព្រាហ្មណា ឯវមាហំសុ ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ហីនា អញ្ញេ វណ្ណា ព្រាហ្មណោវ សុក្កោ វណ្ណោ កណ្ហា អញ្ញេ វណ្ណា ព្រាហ្មណាវ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ។ តន្តេសំ វិញ្ញូ នានុ-ជានន្តិ ។ តំ កិស្ស ហេតុ ។ ឥមេសំ ហិ វាសេដ្ឋ ចតុន្នំ វណ្ណានំ យោ ហោតិ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តស-

## អគ្គញ្ញសូត្រ និយាយអំពីធម៌សនឹងធម៌ខ្មៅ

ជាធម៌ស មានផលស ដែលវិញ្ញូជនតែងសរសើរ ។ ធម៌ទាំងឡាយនោះ តែងប្រាកដក្នុងសត្វៈពួកខ្លះ ក្នុងលោកនេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលបើវណ្ណៈទាំង ៤ ពួកនេះឯង ប្រព្រឹត្តប្រឡូកប្រឡំគ្នា ក្នុងធម៌ពីរពួក គឺធម៌ខ្មៅនិងធម៌ស ដែលវិញ្ញូជនតែងតិះដៀលខ្លះ សរសើរខ្លះ បើពួកព្រាហ្មណ៍ (ដែលកំពុងប្រព្រឹត្ត) ក្នុងធម៌ខ្មៅនឹងធម៌សនោះ និយាយយ៉ាងនេះថា មានតែព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថោកទាប មានតែព្រាហ្មណ៍ ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍ ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតអំពីព្រហ្ម ព្រហ្មបានតាក់តែងមក ជាទាយាទរបស់ព្រហ្មដូច្នេះ ។ វិញ្ញូជនទាំងឡាយ មិនយល់ព្រមតាម គឺមិនសរសើរនូវពាក្យ របស់ពួកព្រាហ្មណ៍ ទាំងនោះទេ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ ព្រោះថា បណ្តាវណ្ណៈទាំង ៤ ពួកនេះ វណ្ណៈណា ជាភិក្ខុឆ្ងាយចាកកិលេស អស់អាសវៈហើយ ប្រព្រឹត្តព្រហ្មចារ្យ រួចស្រេចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ មានភារៈគឺកិលេសនិងខន្ធដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់

ទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ សោ នេសំ អគ្គមក្ខាយតិ ធម្មេនេវ នោ អធម្មេន ។ ធម្មោ ហិ វាសេដ្ឋ សេដ្ឋោ ជនេតស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។ តទមិនាបេតំ វាសេដ្ឋ បរិយាយេន វេទិតព្វំ យថា ធម្មោ សេដ្ឋោ ជនេ-តស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។

(៥៤) ជានាតិ ខោ វាសេដ្ឋ រាជា បសេនទិ កោសលោ សមណោ គោតមោ អនុត្តរោ សក្យ-កុលា បព្វជិតោតិ ។ សក្យា ខោ បន វាសេដ្ឋ រញ្ញោ បសេនទិស្ស កោសលស្ស អនន្តរា អនុយុត្តា[១] ភវន្តិ ។ ករោន្តិ ខោ វាសេដ្ឋ សក្យា រញ្ញោ[២] បសេ-នទិម្ហិ កោសលេ និបច្ចការំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជ-លិកម្មំ សាមីចិកម្មំ ។ ឥតិ ខោ វាសេដ្ឋ យំ ករោន្តិ សក្យា រញ្ញោ បសេនទិម្ហិ កោសលេ និបច្ច-ការំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិ-កម្មំ ករោតិ តំ រាជា បសេនទិ កោសលោ

---

១ ឱ. បសេនទិកោសលស្ស អនុយុត្តា ។ ម. បសេនទិនោ កោសលស្ស អនន្តរា អនុយុត្តា ។ ២ ម. រញ្ញោ ។

ខ្លួនតាមលំដាប់ហើយ មានតណ្ហាជាគ្រឿងចង ក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ វណ្ណៈនោះ ប្រាកដជាបុគ្គលប្រសើរលើស ជាងវណ្ណៈទាំងនោះ ដោយធម៌ពិត មិនមែនដោយអធម៌ទេ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជន ទាំងបច្ចុប្បន្ននឹងបរលោក ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ បើដោយបរិយាយនេះឯង អ្នកគប្បីដឹងយ៉ាងនេះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជន ទាំងបច្ចុប្បន្ននឹងបរលោក ។

(៨៤) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបថា ព្រះសមណគោតម ជាបុគ្គលខ្ពង់ខ្ពស់ ចេញចាកសក្យត្រកូលមកទ្រង់ព្រះផ្នួស ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ប៉ុន្តែអម្បាលពួកសក្យៈ គង់ជាចំណុះព្រះបាទបសេនទិកោសល មិនមានចន្លោះ(១) ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជ; ពួកសក្យៈតែងធ្វើសេចក្តីគោរព ថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម នឹងសាមីចិកម្ម ចំពោះព្រះបាទបសេនទិកោសល ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ពួកសក្យៈ តែងធ្វើសេចក្តីគោរព ថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម នឹងសាមីចិកម្មណា ៗ ចំពោះព្រះបាទបសេនទិកោសល ឯព្រះបាទបសេនទិកោសល ក៏ទ្រង់ធ្វើ

១ អដ្ឋកថា ថា ចុះចូលកោតខ្លាចព្រះបាទបសេនទិកោសល ដូចជាត្រកូលរបស់ខ្លួន ។

តថាគតេ និបច្ចការំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ននុ សុជាតោ សមណោ គោតមោ ទុជ្ជាតោហមស្មិ ពលវា សមណោ គោតមោ ទុព្ពលោហមស្មិ ឱធាសាទិកោ(១) សមណោ គោតមោ ទុព្វណ្ណោហមស្មិ មហេសក្ខោ សមណោ គោតមោ អប្បេសក្ខោហមស្មីតិ អថខោ នំ ធម្មំយេវ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ មានេន្តោ ធម្មំ បូជេន្តោ ធម្មំ អបចយមានោ(២) ។ ឯវំ រាជា បសេនទិ កោសលោ តថាគតេ និបច្ចការំ ករោតិ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ។ ឥមិនា ខោ ឯវំ(៣) វាសេដ្ឋ បរិយាយេន វេទិតព្វំ យថា ធម្មោ សេដ្ឋោ ជនេតស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។

(៤៩) តុម្ហេ ខ្វត្ថ វាសេដ្ឋ នានាជច្ចា នានានាមា នានាគោត្តា នានាកុលា អគារស្មា អនគារិយំ បព្វជិតា កេ តុម្ហេតិ បុដ្ឋា សមានា សមណា សក្យបុត្តិយាម្ហាតិ(៤) បដិជានាថាតិ(៥) ។ យស្ស ខោ

---

១ ឱ. ម. បាសាទិកោ ។ ២ ឱ. អបចាយមានោ ។ ៣ ឱ. ម. ឯតំ ។ ឱ· សក្យបុត្តិយម្ហាតិ ។ ៥ ឱ. ម. បដិជានាថ ។

សេចក្តីគោរព ថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម នឹងសាមីចិកម្ម នោះ ៗ ចំពោះតថាគតដែរ ដោយទ្រង់ព្រះដំរិះថា ព្រះសមណគោតម ព្រះអង្គមានជាតិបរិសុទ្ធ អាត្មាអញជាមនុស្ស មានជាតិមិនបរិសុទ្ធ ព្រះសមណគោតមព្រះអង្គមានកំឡាំង អាត្មាអញជាមនុស្ស មានកំឡាំងថយ ព្រះសមណគោតម ព្រះអង្គមានសម្បុរជ្រះថ្លា អាត្មាអញជាមនុស្ស មានសម្បុរសៅហ្មង ព្រះសមណគោតម ព្រះអង្គមានសក្តានុភាពច្រើន អាត្មាអញជាមនុស្ស មានសក្តានុភាពតិច ដូច្នេះ តពីនោះមក ទ្រង់ក៏ធ្វើសក្ការៈចំពោះធម៌នោះ ធ្វើសេចក្តីគោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌ ដោយប្រការដូច្នេះឯង ៗ ព្រះបាទបសេនទិកោសល ទ្រង់ធ្វើសេចក្តីគោរព ថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម នឹងសាមីចិកម្ម ចំពោះតថាគតយ៉ាងនេះឯង ៗ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ បើដោយបរិយាយនេះឯង អ្នកគប្បីដឹងយ៉ាងនេះថា ធម៌ជាគុណប្រសើរបំផុត ក្នុងប្រជុំជន ទាំងបច្ចុប្បន្ន នឹងបរលោក ៗ

(៤៩) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ អ្នកទាំងឡាយមានជាតិផ្សេង ៗ គ្នា មានឈ្មោះផ្សេងៗគ្នា មានគោត្រផ្សេងៗគ្នា មានត្រកូលផ្សេង ៗ គ្នា ចេញចាកផ្ទះមកកាន់ផ្នួស បើមានគេសួរថា លោកទាំងឡាយជាអ្វី ដូច្នេះ ចូរប្រាប់ទៅគេវិញថា យើងជាសមណសក្យបុត្តិយ៍ ៗ ម្នាលវាសេដ្ឋៈ

យស្ស វាសេដ្ឋ តថាគតេ សទ្ធា និវិដ្ឋា មូលជាតា បតិដ្ឋិតា ទឡ្ហា អសំហារិយា[១] សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ តស្សេតំ កល្លំ វចនាយ ភគវតោម្ហិ បុត្តោ ឱរសោ មុខតោ ជាតោ ធម្មជោ ធម្មនិម្មិតោ ធម្មទាយាទោតិ ។ តំ កិស្ស ហេតុ ។ តថាគតស្ស ហេតំ វាសេដ្ឋ អធិវចនំ ធម្មកាយោ ឥតិបិ ព្រហ្មកាយោ ឥតិបិ ធម្មភូតោ ឥតិបិ ព្រហ្មភូតោ ឥតិបិ[២] ។

(៥៦) ហោតិ ខោ សោ វាសេដ្ឋ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន អយំ លោកោ សំវដ្ដតិ សំវដ្ដមានេ លោកេ យេភុយ្យេន សត្តា អាភស្សរសំវត្តនិកា ហោន្តិ តេ តត្ថ[៣] មនោមយា បីតិភក្ខា សយំបភា អន្តលិក្ខចរា សុភដ្ឋា-

១ ឱ. អសំហារិកា ។ ២ ឱ. ឥតិបីតិ ។ ៣ ឱ. ម. តេ តត្ថ ហោន្តិ ។

នឹងភារទ្វាជៈ បើជនណាមានសទ្ធា គឺការជឿស្ដុងចុះស៊ប់ហើយ មានឫសដុះតាំងខ្ជាប់មាំមួន ក្នុងតថាគត នោះបើសមណព្រាហ្មណ៍ ទេវតា ព្រហ្ម ឬ នរណាមួយ ក្នុងលោក ក៏មិនអាចនឹងបំបែរ ឲ្យត្រឡប់បានឡើយ ជននោះគួរនិយាយ យ៉ាងនេះថា ខ្ញុំជាបុត្រ ជាឱរស នៃព្រះមានព្រះភាគ កើតមកអំពីព្រះឱស្ឋ របស់ព្រះមានព្រះភាគ កើតមកអំពីធម៌ ធម៌តាក់តែងមក ជាទាយាទរបស់ធម៌ ៗ ព្រោះហេតុអ្វី បានជាតថាគតថាដូច្នោះ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ព្រោះពាក្យថា ធម្មកាយ ដូច្នេះក្តី ព្រហ្មកាយ ដូច្នេះក្តី ធម្មភូត ដូច្នេះក្តី ព្រហ្មភូត ដូច្នេះក្តី ជាឈ្មោះរបស់តថាគត ។

(៩៦) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ មានសម័យដែលលោកនេះត្រូវវិនាសម្ដងៗ ដោយការកន្លងកាល ជាយូរអង្វែង កាលដែលលោកកំពុងតែវិនាសទៅ មានពួកសត្វបានទៅកើត ក្នុងអាភស្សរព្រហ្ម ដោយច្រើន ពួកសត្វទាំងនោះជាអ្នកកើត ដោយឈានចិត្ត[1] មានបីតិជាអាហារ[2] មានរស្មីភ្លឺចេញឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងវិមានដ៏ល្អ

១ អដ្ឋកថា ថា ក្នុងបឋមកប្ប ពួកសត្វទាំងនោះ សូម្បីមកកើតក្នុងមនុស្សលោកនេះ ក៏គង់កើតជាឱបបាតិកកំណើត គឺកើតតាមចិត្តបាន ។ ២ សត្វទាំងនោះ មានបីតិជាអាហារ ក្នុងមនុស្សលោកនេះ ដូចព្រហ្មក្នុងព្រហ្មលោកនោះដែរ ។

## អគ្គញ្ញសុត្តេ លោកស្ស វិវដ្ដំ

យតោ ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ ។ ហោតិ ខោ សោ វាសេដ្ឋា សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន អយំ លោកោ វិវដ្ដតិ វិវដ្ដមានេ លោកេ យេភុយ្យេន សត្តា អាភស្សរកាយា ចវិត្វា ឥត្ថត្តំ អាគច្ឆន្តិ តេ ច ហោន្តិ មនោមយា បីតិភក្ខា សយំបភា អន្តលិក្ខចរា សុភដ្ឋាយិនោ ចិរំ ទីឃ-មទ្ធានំ តិដ្ឋន្តិ ។ ឯកោទកីភូតំ ខោ បន វា-សេដ្ឋា តេន សមយេន ហោតិ អន្ធការោ អន្ធការ-តិមិសា ន ចន្ទិមសុរិយា បញ្ញាយន្តិ ន នក្ខត្តានិ តារករូបានិ បញ្ញាយន្តិ ន រត្តិន្ទិវា បញ្ញាយន្តិ ន មាសឌ្ឍមាសា បញ្ញាយន្តិ ន ឧតុសំវច្ឆរា បញ្ញាយន្តិ ន ឥត្ថីបុរិសា បញ្ញាយន្តិ ។ សត្តា សត្តាត្វេវ សំខ្យំ គច្ឆន្តិ ។ អថខោ តេសំ វាសេដ្ឋា សត្តានំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន រសបថវី ឧទកស្មឹ សមតានិ(១)

---

១ ម. ម. សមតានិ ។

នៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសម័យ ដែលលោកនេះ ត្រូវចំរើនឡើងម្តង ៗ ដោយកាលកន្លង ជាយូរអង្វែងទៅ កាលដែលលោកកំពុងតែចំរើនឡើង សត្វទាំងឡាយច្យុតចាកអាភស្សរ-ព្រហ្ម មកកាន់ភាពជាមនុស្សនេះ ឯសត្វទាំងនោះ ជាអ្នកកើតដោយ ឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯង ត្រាច់ទៅក្នុង អាកាសបាន ឋិតនៅក្នុងវិមានដ៏ល្អ នៅអស់កាលយូរអង្វែង ។ ម្នាល វាសេដ្ឋៈ និងភារទ្វាជៈ សម័យនោះឯង ចក្រវាឡទាំងអស់ ក៏រលាយទៅ ជាទឹកចូលគ្នា មានងងឹតអព្ទុស្សូន្យសុង ព្រះចន្ទ្រនិងព្រះអាទិត្យ ក៏មិន ប្រាកដ នក្ខត្តឫក្សដែលមានរូប ជាផ្កាយទាំងឡាយ ក៏មិនប្រាកដ យប់ និងថ្ងៃ ក៏មិនប្រាកដ ខែមួយនិងកន្លះខែ ក៏មិនប្រាកដ រដូវនិងឆ្នាំ ក៏មិន ប្រាកដ ស្រីនិងប្រុស ក៏មិនប្រាកដ ។ សត្វទាំងឡាយក៏គ្រាន់តែរាប់ថាជា សត្វប៉ុណ្ណោះឯង ។ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ លុះកាលកន្លងទៅ ជាយូរ អង្វែងម្តង ៗ ផែនដីមានរសអណ្តែតជាសលើទឹក សម្រាប់សត្វទាំងនោះ

សេយ្យថាបិ នាម បយតត្តស្ស(១) និព្វាយមានស្ស ឧបរិ សន្តានកំ ហោតិ ឯវមេវំ(២) បាតុរហោសិ សា អហោសិ វណ្ណសម្បន្នា គន្ធសម្បន្នា រសសម្បន្នា សេយ្យថាបិ នាម សម្បន្នា(៣) វា សប្បិ សម្បន្នំ វា នវនីតំ ឯវំវណ្ណា អហោសិ សេយ្យថាបិ នាម ខុទ្ទមធុំ អនេឡកំ ឯវមស្សាទា អហោសិ ។ អថខោ វាសេដ្ឋ អញ្ញតរោ សត្តោ លោលជាតិកោ អម្ភោ កិមេវិទំ ភវិស្សតីតិ រសបថវី អង្គុលិយា សាយិ តស្ស រសបថវឹ អង្គុលិយា សាយតោ អច្ឆាទេសិ តណ្ហាបស្ស(៤) ឱក្កមិ ។ អញ្ញេបិ(៥) ខោ វាសេដ្ឋ សត្តា តស្ស សត្តស្ស ទិដ្ឋានុគតឹ អាបជ្ជមានា រសបថវឹ អង្គុលិយា សាយឹសុ ។ តេសំ រសបថវឹ អង្គុលិយា សាយតំ អច្ឆាទេសិ តណ្ហា ច តេសំ ឱក្កមិ ។ អថខោ តេ វាសេដ្ឋ

---

១ ឱ. បយសោតត្តស្ស ។ ម. បាយសោតក្កស្ស ។ ២ ម. ឯវមេវ ខោ ។
៣ ឱ. ម. សម្បន្នំ ។ ៤ តណ្ហាវស្សាតិ តណ្ហាចស្សាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។
៥ ឱ. អញ្ញតរេបិ ខោ ។

ប្រាកដ ដូចជាទឹកដោះ ក្តៅរលាយអណ្តែតដាស នៅលើទឹកដូច្នោះ ផែនដីមានរសនោះ មានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែម មានសម្បុរស ដូចទឹកដោះថ្លា ឬដូចទឹកដោះខាប់ ដែលមានរសផ្អែម ផែនដីនុ៎ះមានរសឆ្ងាញ់ពិសា ដូចទឹកឃ្មុំតូច (ឃ្មុំផ្អិត) ដែលឥតទោស (គ្មានកូនឃ្មុំ) ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះឯង មានសត្វម្នាក់ មានជាតិជាអ្នកលេះលោះគិតថា យីអើ នេះជាអ្វីអេះ ក៏យកចង្អុលដៃ (ឆ្កឹះយក) ផែនដីមានរសមកលិទ្ធមើល កាលសត្វនោះយកចង្អុលដៃ (ឆ្កឹះយក) ផែនដីមានរសមកលិទ្ធភ្លក្សមើល រសផែនដីក៏ជ្រួតជ្រាបទៅ សព្វសរសៃសម្រាប់ទទួលនូវរស ឯសេចក្តីប្រាថ្នាក្នុងរស ក៏កើតដល់សត្វនោះ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ មានពួកសត្វដទៃទៀត កាលយកតម្រាប់តាមសត្វនោះនាំគ្នាយកចង្អុលដៃ (ឆ្កឹះយក) ផែនដីមានរស មកលិទ្ធភ្លក្សមើល ។ កាលពួកសត្វទាំងនោះលិទ្ធភ្លក្សរសផែនដីនឹងចង្អុលដៃ រសផែនដីក៏ជ្រួតជ្រាបទៅ (សព្វសរសៃសម្រាប់ទទួលនូវរស) ឯសេចក្តីប្រាថ្នាក្នុងរសក៏កើតឡើងដល់ពួកសត្វទាំងនោះ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ លំដាប់នោះ

## អគ្គញ្ញសុត្តេ រសបឋវីអាទិកថា

សត្តា រសបឋវឹ ហត្ថេហិ អាលុប្បការកំ (១)
ឧបក្កមឹសុ បរិភុញ្ជិតុំ ។ យតោ ខោ វាសេដ្ឋ
សត្តា រសបឋវឹ ហត្ថេហិ អាលុប្បការកំ (២)
ឧបក្កមឹសុ បរិភុញ្ជិតុំ អថ (៣) តេសំ សត្តានំ
សយំបភា អន្តរធាយិ ។ សយំបភាយ អន្តរ-
ហិតាយ ចន្ទិមសុរិយា បាតុរហេសុំ ចន្ទិមសុរិយេសុ
បាតុភូតេសុ នក្ខត្តានិ តារករូបានិ បាតុរហេសុំ
នក្ខត្តេសុ តារករូបេសុ បាតុភូតេសុ រត្តិន្ទិវា បញ្ញា-
យឹសុ រត្តិន្ទិវេសុ បញ្ញាយមានេសុ មាសឌ្ឍមាសា
បញ្ញាយឹសុ មាសឌ្ឍមាសេសុ បញ្ញាយមានេសុ ឧតុ-
សំវច្ឆរា បញ្ញាយឹសុ ។ ឯត្តាវតា ខោ វាសេដ្ឋ
អយំ លោកោ បុន វិវដ្តោ ហោតិ ។

(៨៧) អថខោ តេ វាសេដ្ឋ សត្តា រសបឋវឹ
បរិភុញ្ជន្តា តព្ភក្ខា (៤) តទាហារា ចិរំ ទីឃមទ្ធានំ
អដ្ឋំសុ ។ យថា យថា ខោ តេ វាសេដ្ឋ សត្តា
រសបឋវឹ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃ-

---

១-២ ឱ. អាលុម្បការកំ ។ ៣ ម. អថខោ ។ ៤ ឱ. ម. តម្ភក្ខា ។

អគ្គញ្ញសូត្រ និយាយអំពីហេតុមានរសផែនដីជាដើម

ក៏សត្វទាំងនោះនាំគ្នាយកដៃកកាយផែនដី ដែលមានរសមកធ្វើជាពំនូត ហើយបរិភោគ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ កាលដែលសត្វទាំងឡាយនាំគ្នាយកដៃកកាយផែនដី ដែលមានរសមកធ្វើជាពំនូត ហើយបរិភោគ ពន្លឺដែលភ្លឺចេញឯង ( អំពីកាយ ) របស់សត្វទាំងនោះ ក៏សាបសូន្យបាត់ទៅ ។ លុះពន្លឺដែលភ្លឺចេញឯង សាបសូន្យទៅហើយ ព្រះចន្ទ្រនឹងព្រះអាទិត្យ ក៏កើតប្រាកដឡើង លុះព្រះចន្ទ្រនឹងព្រះអាទិត្យកើតប្រាកដឡើងហើយ នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយ ក៏កើតប្រាកដឡើង លុះនក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយ កើតប្រាកដឡើងហើយ យប់នឹងថ្ងៃក៏កើតប្រាកដឡើង លុះយប់នឹងថ្ងៃកើតប្រាកដឡើងហើយ ខែ ១ នឹងកន្លះខែ ក៏កើតប្រាកដឡើង លុះខែ ១ នឹងកន្លះខែកើតប្រាកដឡើងហើយ រដូវនឹងឆ្នាំក៏កើតប្រាកដឡើង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ លោកនេះ ចំរើនឡើងវិញ ដោយហេតុប៉ុណ្ណោះឯង ។

(៥៧) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រាកាលពួកសត្វទាំងនោះនាំគ្នាបរិភោគផែនដីមានរស យកផែនដីនោះជាចំណី យកផែនដីនោះជាអាហារ ហើយឋិតនៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ កាលពួកសត្វទាំងនោះ បរិភោគផែនដីមានរស យកផែនដីនោះជាចំណី យកផែនដីនោះជាអាហារ ហើយឋិតនៅអស់កាលយូរអង្វែង

មទ្ធានំ អដ្ឋំសុ តថា តថា តេសំ សត្តានំ ខរត្តញ្ចេវ កាយស្មឹ ឱក្កមិ វណ្ណវេវណ្ណតា ច បញ្ញាយិត្ថ ។ ឯកិទំ សត្តា វណ្ណវន្តោ ហោន្តិ ឯកិទំ សត្តា ទុព្វណ្ណា ។ តត្ថ យេ តេ សត្តា វណ្ណវន្តោ តេ ទុព្វណ្ណេ សត្តេ អតិមញ្ញន្តិ មយមេតេហិ វណ្ណវន្តតរា អម្ហេហេតេ ទុព្វណ្ណតរាតិ ។ តេសំ វណ្ណាតិមាន-បច្ចយា មានាតិមានជាតិកានំ រសបថវី អន្តរធាយិ ។ រសបថវិយា(១) អន្តរហិតាយ សន្និបតឹសុ សន្និបតិត្វា អនុត្ថុនឹសុ អហោ រសំ អហោ រសន្តិ ។ តទេតរហិបិ មនុស្សា កិញ្ចិទេវ សុរសំ(២) លភិត្វា ឯវមាហំសុ អហោ រសំ អហោ រសន្តិ ។ តទេវ បោរាណំ អគ្គញ្ញំ អក្ខរំ អនុស្សរន្តិ ន ត្វេវស្ស អត្ថំ អាជានន្តិ ។

---

១ ឱ. រសាយ បថវិយា ។ ២ ឱ. សាធុរសំ ។

ដោយប្រការយ៉ាងណា ៗ សេចក្តីរឹងប៉ឹង ក្នុងកាយរបស់សត្វទាំងនោះ ក៏កើតឡើង ទាំងពណ៌សម្បុរក៏ប្លែក ៗ គ្នា ប្រាកដឡើង ដោយប្រការយ៉ាងនោះ ៗ ៗ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់ ៗ បណ្តាសត្វទាំងពីរពួកនោះ ពួកសត្វណាដែលមានសម្បុរល្អ ពួកសត្វនោះតែងមើលងាយពួកសត្វ ដែលមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អលើសជាងពួកសត្វនុ៎ះ ពួកសត្វនុ៎ះមានសម្បុរអាក្រក់ ជាងពួកយើង ៗ កាលសត្វទាំងនោះ មានសេចក្តីប្រកាន់ខ្លួន នឹងការមើលងាយកើតឡើង ព្រោះបច្ច័យនៃសេចក្តីមើលងាយ នូវសម្បុរគ្នា ផែនដីដែលមានរសក៏សាបសូន្យអស់ទៅ ៗ លុះផែនដីដែលមានរសសាបសូន្យហើយ សត្វទាំងឡាយក៏មកប្រជុំគ្នា លុះមកប្រជុំគ្នាហើយ ក៏ត្អូញត្អែរថា ឱ រស (ឆ្ងាញ់របស់យើង) ឱ រស (ឆ្ងាញ់របស់យើង) ៗ ហេតុនោះ ក៏ដូចគ្នានឹងមនុស្សទាំងឡាយ ក្នុងកាលឥឡូវនេះដែរ ដែលបានវត្ថុអ្វីមួយ មានរសឆ្ងាញ់ហើយ តែងនាំគ្នាលាន់មាត់ យ៉ាងនេះថា ឱ រស (ឆ្ងាញ់របស់យើង) ឱ រស (ឆ្ងាញ់របស់យើង ) ៗ សត្វទាំងឡាយនាំគ្នានឹករកអក្ខរៈ ដែលជាច្បាប់ចាស់(១) នោះឯង ប៉ុន្តែ មិនអាចនឹងយល់សេចក្តី នៃអក្ខរៈនោះបានឡើយ ៗ

---

១ អដ្ឋកថា ថា បានដល់សំដីជាវង្ស ដែលកើតឡើងសម្រាប់លោក ៗ

## អគ្គញ្ញសុត្តេ ភូមិបប្បដកាទិកថា

[៥៨] អថខោ តេសំ វាសេដ្ឋ សត្តានំ រសបថវិយា អន្តរហិតាយ ភូមិបប្បដកោ(១) បាតុរហោសិ ។ សេយ្យថាបិ នាម អហិច្ឆត្តកោ ឯវមេវំ បាតុរហោសិ ។ សោ អហោសិ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ សេយ្យថាបិ នាម សម្បន្នំ វា(២) សប្បិ សម្បន្នំ វា នវនីតំ ឯវំវណ្ណោ អហោសិ សេយ្យថាបិ នាម ខុទ្ទមធុំ(៣) អនេឡកំ ឯវមស្សាទោ អហោសិ ។ អថខោ តេ វាសេដ្ឋ សត្តា ភូមិបប្បដកំ ឧបក្កមិំសុ បរិភុញ្ជិតុំ តេ(៤) បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋំសុ ។ យថា យថា ខោ តេ វាសេដ្ឋ សត្តា ភូមិបប្បដកំ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋំសុ តថា តថា តេសំ សត្តានំ ភិយ្យោសោ មត្តាយ ខរត្តញ្ចេវ កាយស្មឹ ឱក្កមិ វណ្ណវេវណ្ណតា ច បញ្ញាយិត្ថ ។ ឯកិទំ សត្តា វណ្ណវន្តោ ហោន្តិ ឯកិទំ សត្តា ទុព្វណ្ណា ។ តត្ថ យេ តេ សត្តា វណ្ណវន្តោ

១ ភូមិបប្បដកោតិបិ បាឋោ ។ ២ ឱ. ម. សម្បន្នំ វា ។ ៣ ឱ. ខុទ្ទំ មធុំ ។ ៤ ឱ. ម. តេ តំ ។

អគ្គញ្ញសូត្រ និយាយអំពីក្រមរផែនដីជាដើម

(៤៨) ម្នាលវាសេដ្ឋៈ ទាំងភារទ្វាជៈ លុះផែនដីមានរស របស់សត្វ ទាំងនោះ សាបសូន្យអស់ទៅហើយ ក្រមរផែនដី ក៏កើតប្រាកដឡើង ។ ក្រមរផែនដីនោះ កើតប្រាកដឡើង ដូចជាផ្សិត ។ ក្រមរផែនដីនោះ បរិបូណ៌ដោយសម្បុរ មានក្លិន (ក្រអូប) មានរស (ឆ្ងាញ់) មាន ពណ៌ដូចជាសប្បិសុទ្ធ ឬដូចជា នវនីតសុទ្ធ មានរស (ឆ្ងាញ់ពិសា) ដូចទឹកឃ្មុំតូច (ឃ្មុំផ្អិត) ដែលឥតទោស (គ្មានកូនឃ្មុំ) ម្នាលវាសេដ្ឋៈទាំង ភារទ្វាជៈ គ្រានោះឯង សត្វទាំងឡាយនោះ ក៏នាំគ្នាបរិភោគក្រមរផែនដី កាលសត្វទាំងនោះ នាំគ្នាបរិភោគក្រមរផែនដី យកក្រមរផែនដីនោះជា ចំណី យកក្រមរផែនដីនោះ ជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង។ ម្នាលវាសេដ្ឋៈទាំងភារទ្វាជៈ កាលពួកសត្វទាំងនោះ នាំគ្នាបរិភោគក្រមរ ផែនដី យកក្រមរផែនដីនោះជាចំណី យកក្រមរផែនដីនោះជាអាហារ ឋិត នៅអស់កាលជាយូរអង្វែង ដោយប្រការយ៉ាងណា ៗ សេចក្តីរឹងប៉ឹងក្នុង កាយរបស់សត្វទាំងនោះ ក៏កើតដោយក្រៃលែងលើសប្រមាណ ពណ៌ សម្បុរក៏ប្លែក ៗ គ្នាប្រាកដឡើង ដោយប្រការយ៉ាងនោះ ៗ ។ សត្វពួកខ្លះ មានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់ ។ បណ្តាសត្វទាំងពីរពួកនោះ

តេ ទុព្វណ្ណេ សត្តេ អតិមញ្ញន្តិ មយមេតេហិ វណ្ណ-វន្តតរា អម្ហេហេតេ ទុព្វណ្ណតរាតិ ។ តេសំ វណ្ណា-តិមានបច្ចយា មានាតិមានជាតិកានំ ភូមិបប្បដកោ អន្តរធាយិ ។ ភូមិបប្បដកេ អន្តរហិតេ បទាលតា(១) បាតុរហោសិ ។ សេយ្យថាបិ នាម កលម្ពុកា(២) ឯវមេវំ បាតុរហោសិ ។ សា អហោសិ វណ្ណសម្បន្នា គន្ធសម្បន្នា រសសម្បន្នា សេយ្យថាបិ នាម សម្បន្នា វា សប្បិ សម្បន្នំ វា នវនីតំ ឯវំវណ្ណា អហោសិ សេយ្យថាបិ នាម ខុទ្ទមធុំ អនេឡកំ ឯវមស្សាទោ អហោសិ ។ អថខោ តេ វាសេដ្ឋា សត្តា បទាលតំ ឧបក្កមឹសុ បរិភុញ្ជិតុំ តេ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋំសុ ។ យថា យថា ខោ តេ វាសេដ្ឋា សត្តា បទាលតំ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋំសុ តថា

---

១ ឱ. ពទាលតា ទិស្សតិ ។ ២ ឱ. ម. កលម្ពុកា ។

សត្វពួកណា មានសម្បុរល្អ សត្វពួកនោះ រមែងមើលងាយពួកសត្វដែល មានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អជាងពួកសត្វនុ៎ះ ពួកសត្វទាំងនោះ មានសម្បុរអាក្រក់ជាងពួកយើង ។ កាលសត្វទាំងឡាយនោះ មានសេចក្តីប្រកាន់ខ្លួន នឹងការមើលងាយកើតឡើង ព្រោះសេចក្តីមើលងាយ នូវសម្បុរគ្នាជាបច្ច័យ ក្រមរផែនដីក៏សាបសូន្យអស់ទៅ លុះក្រមរផែនដីសាបសូន្យទៅហើយ បទាលតា[1]ក៏កើតប្រាកដឡើង ។ បទាលតានោះ កើតប្រាកដឡើង ដូចជាវល្លិត្រកួន ។ បទាលតានោះ មានសម្បុរល្អ មានក្លិន (ក្រអូប) មានរស (ឆ្ងាញ់) វល្លិនោះមានសម្បុរដូចសប្បិសុទ្ធ ឬដូចនវនីតសុទ្ធ មានរស (ឆ្ងាញ់ពិសា) ដូចទឹកឃ្មុំតូច (ឃ្មុំផ្អិត) ដែលឥតទោស (គ្មានកូនឃ្មុំ) ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះឯង សត្វទាំងឡាយនោះ ក៏នាំគ្នាបរិភោគបទាលតា កាលពួកសត្វទាំងនោះ បរិភោគបទាលតា យកវល្លិនោះជាចំណី យកវល្លិនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ កាលសត្វទាំងនោះ បរិភោគបទាលតា យកវល្លិនោះជាចំណី យកវល្លិនោះជាអាហារ ឋិតនៅអស់កាលជាយូរអង្វែង ដោយ

១ អដ្ឋកថា ថា ជាឈ្មោះវល្លិមួយយ៉ាងមានរសផ្អែម ។

## អគ្គញ្ញសុត្តេ វណ្ណាទិកថា

តថា តេសំ សត្តានំ ភិយ្យោសោ មត្តាយ ខរត្តញ្ចេវ កាយស្មឹ ឱក្កមិ វណ្ណវេវណ្ណតា ច បញ្ញាយិត្ថ ។ ឯកិទំ សត្តា វណ្ណវន្តោ ហោន្តិ ឯកិទំ សត្តា ទុព្វណ្ណា ។ តត្ថ យេ តេ សត្តា វណ្ណវន្តោ តេ ទុព្វណ្ណេ សត្តេ អតិមញ្ញន្តិ មយមេតេហិ វណ្ណវន្តតរា អម្ហេហេតេ ទុព្វណ្ណតរាតិ ។ តេសំ វណ្ណាតិមានបច្ចយា មានាតិ-មានជាតិកានំ បទាលតា អន្តរធាយិ ។ បទាលតាយ អន្តរហិតាយ សន្និបតឹសុ សន្និបតិត្វា អនុត្ថុនឹសុ អហុ វត នោ អហាយិ វត នោ បទាលតាតិ ។ តទេតរហិ(១) មនុស្សា កេនចិទេវ(២) ទុក្ខធម្មេន ផុដ្ឋា ឯវមាហំសុ អហុ វត នោ អហាយិ វត នោតិ ។ តទេវ បោរាណំ អគ្គញ្ញំ អក្ខរំ អនុស្សរន្តិ(៣) ន ត្វេវស្ស អត្ថំ អាជានន្តិ ។

---

១ ឱ. ម. តទេតរហិ បិ ។ ២ ឱ. ម. កេនចិ ។ ៣ ឱ. អនុបតន្តិ ។

ប្រការយ៉ាងណា ៗ សេចក្តីរឹងប៉ឹងក្នុងកាយ របស់សត្វទាំងនោះ ក៏កើតឡើង ដោយក្រៃលែងលើសប្រមាណ ទាំងពណ៌សម្បុរក៏ប្លែក ៗ គ្នាប្រាកដឡើង ដោយប្រការយ៉ាងនោះ ៗ ។ សត្វពួកខ្លះ មានសម្បុរល្អ សត្វពួកខ្លះ មានសម្បុរអាក្រក់ ។ បណ្តាសត្វទាំងពីរពួកនោះ ពួកសត្វណា ដែលមានសម្បុរល្អ ពួកសត្វនោះ តែងមើលងាយពួកសត្វ ដែលមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អលើស ជាងពួកសត្វនុ៎ះ ពួកសត្វនេះ មានសម្បុរអាក្រក់ ជាងពួកយើង ។ កាលសត្វទាំងឡាយនោះ មានសេចក្តីប្រកាន់ខ្លួន នឹងការមើលងាយ កើតឡើង ព្រោះសេចក្តីមើលងាយ នូវសម្បុរគ្នាជាបច្ច័យ ឯបទាលតាក៏សាបសូន្យទៅ ។ លុះបទាលតាសាបសូន្យហើយ សត្វទាំងឡាយក៏មកប្រជុំគ្នា លុះមកប្រជុំគ្នាហើយ ក៏ត្អូញត្អែរថា ឱហ្ន៎ បទាលតារបស់យើងធ្លាប់មានហើយ ឱហ្ន៎ បទាលតារបស់យើង បាត់អស់ទៅហើយ ។ ហេតុនោះក៏ដូចគ្នានឹងមនុស្សទាំងឡាយ ក្នុងកាលឥឡូវនេះដែរ ដែលធម៌ជាទុក្ខណាមួយប៉ះពាល់ ក៏និយាយគ្នាយ៉ាងនេះថា ឱហ្ន៎ យើងធ្លាប់មាន ឱហ្ន៎ យើងសាបសូន្យអស់ហើយ ។ សត្វទាំងឡាយនាំគ្នានឹករកអក្សរ ដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តី នៃអក្សរនោះបានឡើយ ។

(៤៩) អថខោ តេសំ វាសេដ្ឋា សត្តានំ បទាលតាយ អន្តរហិតាយ អកដ្ឋបាកោ សាលិ បាតុរហោសិ អកណោ អថុសោ សុទ្ធោ(១) សុគន្ធោ តណ្ឌុលប្ផលោ ។ យន្តំ សាយំ សាយមាសាយ អាហរន្តិ បាតោ តំ ហោតិ បក្កំ បដិវិរូឡ្ហំ យន្តំ បាតោ បាតរាសាយ អាហរន្តិ សាយំ តំ ហោតិ បក្កំ បដិវិរូឡ្ហំ នាបទានំ បញ្ញាយតិ ។ អថខោ(២) វាសេដ្ឋា សត្តា អកដ្ឋបាកំ សាលឹ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋំសុ ។ យថា យថា ខោ តេ វាសេដ្ឋា សត្តា អកដ្ឋបាកំ សាលឹ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋំសុ តថា តថា តេសំ សត្តានំ ភិយ្យោសោ មត្តាយ ខរត្តញ្ចេវ កាយស្មឹ ឱក្កមិ វណ្ណវេវណ្ណតា ច បញ្ញាយិត្ថ ។ ឥត្ថិយា ច ឥត្ថិលិង្គំ បាតុរហោសិ បុរិសស្ស បុរិសលិង្គំ ។

---

១ ឱ. សុគន្ធោតិ ន ទិស្សតិ ។ ២ ឱ. អថខោ តេ ។

(៨៩) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រាកាលបទាលតា របស់សត្វទាំងនោះសាបសូន្យទៅហើយ ស្រូវសាលីកើតឯងជាស្រូវគ្មានកុណ្ឌក គ្មានអង្កាម សស្អាត មានក្លិនក្រអូប មានផ្លែចេញមក ជាអង្ករតែម្តង ក៏កើតប្រាកដឡើង ។ មនុស្សទាំងឡាយនាំយកស្រូវសាលី ត្រង់ទីណា ក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើង ទីនោះ ក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ មនុស្សទាំងឡាយនាំយកស្រូវសាលី ត្រង់ទីណាក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាចទីនោះ ក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះក៏ប្រាកដ ហាក់ដូចជាមិនបានច្រូតឡើយ ។ ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ គ្រានោះឯង សត្វទាំងឡាយក៏បរិភោគស្រូវសាលីកើតឯង យកស្រូវសាលីនោះជាចំណី យកស្រូវសាលីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈនឹងភារទ្វាជៈ កាលសត្វទាំងនោះនាំគ្នាបរិភោគស្រូវសាលីកើតឯង យកស្រូវសាលីនោះជាចំណី យកស្រូវសាលីនោះជាអាហារ ឋិតនៅអស់កាលជាយូរអង្វែង ដោយប្រការយ៉ាងណា ៗ សេចក្តីរឹងប៉ឹងក្នុងកាយ របស់សត្វទាំងនោះ ក៏កើតឡើងលើសប្រមាណ ទាំងពណ៌សម្បុរ ក៏ប្លែកៗគ្នាប្រាកដឡើង ដោយប្រការយ៉ាងនោះ ៗ ភេទស្រីក៏ប្រាកដឡើងដល់ស្រី ភេទប្រុសក៏ប្រាកដឡើងដល់ប្រុស ។

ឥត្ថី ច សុទំ អតិវេលំ បុរិសំ ឧបនិជ្ឈាយតិ បុរិសោ ច ឥត្ថឹ ។ តេសំ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តានំ សារាគោ ឧទបាទិ បរិឡាហោ កាយស្មឹ ឱក្កមិ ។ តេ បរិឡាហបច្ចយា មេថុនំ ធម្មំ បដិសេវឹសុ ។ យេ ខោ បន តេ វាសេដ្ឋ តេន សមយេន សត្តា បស្សន្តិ មេថុនំ ធម្មំ បដិសេវន្តេ អញ្ញេ បំសុំ ខិបន្តិ អញ្ញេ សេដ្ឋឹ ខិបន្តិ អញ្ញេ គោមយំ ខិបន្តិ នស្ស វសលិ[1] នស្ស វសលីតិ[2] ។ កថញ្ហិ នាម សត្តោ សត្តស្ស ឯវរូបំ ករិស្សតីតិ ។ តទេតរហិបិ មនុស្សា ឯកច្ចេសុ ជនបទេសុ វធុយា និព្វុយ្ហមានាយ[3] អញ្ញេ បំសុំ ខិបន្តិ អញ្ញេ សេដ្ឋឹ ខិបន្តិ អញ្ញេ គោមយំ ខិបន្តិ ។ តទេវ បោរាណំ អគ្គញ្ញំ អក្ខរំ អនុស្សរន្តិ ន ត្វេវស្ស អត្ថំ អាជានន្តិ ។

---

១-២ ឱ. អសុចិ ។ ៣ ឱ. វធុយា និព្វុយ្ហមានាយ ។ ម. វធុយា និគ្គុយ្ហមានាយ ។

## អគ្គញ្ញសូត្រ ការសំឡឹងមើលគ្នាទៅវិញទៅមក

បានពុទ្ធថា ស្រីសំឡឹងមើលប្រុសទាល់តែហួសវេលា បំណែកខាងប្រុស ក៏សំឡឹងមើលស្រីទាល់តែហួសវេលា ។ កាលសត្វទាំងនោះ សំឡឹងមើលគ្នាទៅវិញទៅមកទាល់តែហួសវេលា តម្រេកក៏កើតឡើង សេចក្តីក្តៅក្រហាយព្រោះតម្រេក ក៏ប្រជុំចុះក្នុងកាយ ។ សត្វទាំងនោះ ក៏នាំគ្នាសេពមេថុនធម្ម ព្រោះសេចក្តីរោលរាលជាបច្ច័យ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សម័យនោះ ពួកសត្វណាបានឃើញនូវពួកសត្វ ដែលកំពុងតែសេពមេថុនធម្ម ពួកសត្វខ្លះក៏យកអាចម៍ដីបោះទៅ សត្វខ្លះយកផេះបាចដាក់ សត្វខ្លះយកអាចម៍គោបោះទៅ និយាយថា នៃវសលិ(១) លាញទៅ នៃវសលិ លាញទៅ ហងលាញទៅ ។ ចុះហេតុដូចម្តេច បានជាសត្វហ៊ានធ្វើអំពើ ដល់សត្វយ៉ាងនេះ ។ ហេតុនោះ ក៏ដូចគ្នានឹងពួកមនុស្ស ក្នុងកាលឥឡូវនេះដែរ កាលបើស្រីក្នុងជនបទនីមួយ មានគេចាប់នាំយកទៅ ពួកខ្លះក៏យកអាចម៍ដីបោះទៅ ពួកខ្លះក៏យកផេះបាចដាក់ ពួកខ្លះក៏យកអាចម៍គោបោះទៅ ។ សត្វទាំងឡាយ នាំគ្នានឹករកអក្ខរៈដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តី នៃអក្ខរនោះបានឡើយ ។

---

១ ជាពាក្យអាសគ្រាម សម្រាប់ជេរបញ្ចោរ ។

(៦០) អធម្មសម្មតំ តំ(១) ខោ បន វាសេដ្ឋា តេន សមយេន ហោតិ តទេតរហិ ធម្មសម្មតំ ។ យេ ខោ បន តេ(២) វាសេដ្ឋា តេន សមយេន សត្តា មេថុនំ ធម្មំ បដិសេវន្តិ តេមាសំបិ ទ្វេមាសំបិ ន លភន្តិ គាមំ វា និគមំ វា បវិសិតុំ ។ យតោ ខោ វាសេដ្ឋា តេ(៣) សត្តា តស្មឹ(៤) អសទ្ធម្មេ អតិវេលំ បាតព្យតំ(៥) អាបជ្ជឹសុ អថ(៦) អគារានិ ឧបក្កមឹសុ កាតុំ តស្សេវ អសទ្ធម្មស្ស បដិច្ឆាទនត្ថំ ។ អថខោ វាសេដ្ឋា អញ្ញតរស្ស សត្តស្ស អលសជាតិកស្ស ឯតទហោសិ អម្ភោ កិមេវាហំ វិហញ្ញាមិ សាលឹ អាហរន្តោ សាយំ សាយមាសាយ បាតោ បាតរាសាយ យន្នូនាហំ សាលឹ អាហរេយ្យំ សកិទេវ សាយំ បាតរាសាយោតិ(៧) ។ អថខោ សោ វាសេដ្ឋា សត្តោ សាលឹ អាហាសិ សកិទេវ សាយំ បាតរាសាយាតិ ។ អថខោ វាសេដ្ឋា

---

១ ឱ. ម. តន្តិ ន ទិសតិ ។ ២ ឱ. ម. តេតិ ន ទិស្សតិ ។ ៣ ម. យតោ ខោ បន តេ វាសេដ្ឋ ។ ៤ ឱ. តស្មឹ សមយេ ។ ៥ ឱ. កាតព្វតំ ។ ៦ ម. អថខោ ។ ៧ ឱ. សកិទេវ សាយបាតរាសាយាតិ ។ ម. សកឹទេវ សាយបាតរាសាយាតិ ។

[៦០] ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សម័យនោះឯង អំពើមាន ការបោះអាចម៍ដីជាដើមនោះ គេសន្មតថា មិនមែនធម៌ តែអំពើនោះ ក្នុងកាលឥឡូវនេះ គេត្រូវរាប់សន្មតថា ជាធម៌វិញ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សម័យនោះ បើពួកសត្វណាសេពមេថុនធម្ម សត្វទាំងនោះ មិនបានចូលមក កាន់ស្រុកឬនិគម អស់មួយខែក៏មាន ពីរខែក៏មាន ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ កាលណាពួកសត្វទាំងនោះ ដល់នូវស៊ប់នូវភាពជាអ្នកសេព ចំពោះអសទ្ធម្មនោះហួសវេលាហើយ ក៏នាំគ្នាផ្តើមធ្វើផ្ទះ ដើម្បីបិទបាំងអសទ្ធម្មនោះឯង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះ ឯង មានសត្វ ១ នាក់ប្រកបដោយជាតិ ជាអ្នកខ្ជិលច្រអូស បាន គិតយ៉ាងនេះថា យីអើ អាត្មាអញកាលដែលនាំយកស្រូវសាលី ក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច នាំយកស្រូវសាលី ក្នុងវេលាព្រឹកសម្រាប់បរិភោគក្នុងវេលាព្រឹក ហៅពេញជាលំបាកខ្វល់ខ្វាយម្ល៉េះ ណ្ហើយចុះ អាត្មាអញគួរតែនាំយកស្រូវសាលី ក្នុងវេលាល្ងាចតែម្តង ហើយទុកបរិភោគក្នុងវេលាព្រឹកផង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះឯង សត្វនោះក៏ទៅយកស្រូវសាលី ក្នុងវេលាល្ងាចតែម្តងប៉ុណ្ណោះ សម្រាប់បរិភោគក្នុងវេលាព្រឹកផង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះឯង

## អគ្គញ្ញសុត្តំ សាលាហារនាទិកថា

អញ្ញតរោ សត្តោ យេន សោ សត្តោ តេនុបសង្កមិ ឧបសង្កមិត្វា តំ សត្តំ ឯតទវោច ឯហិ ភោ សត្ត សាលាហារំ គមិស្សាមាតិ ។ អលំ ភោ សត្ត អាហតោ មេ សាលិំ សកិំទេវ សាយំ បាតរាសាយាតិ ។ អថខោ សោ វាសេដ្ឋា សត្តោ តស្ស សត្តស្ស ទិដ្ឋានុគតឹ អាបជ្ជមានោ សាលឹ អាហាសិ សកិំទេវ ទ្វីហាយ ឯវំបិ កិរ ភោ សាធូតិ ។ អថខោ វាសេដ្ឋា អញ្ញតរោ សត្តោ យេន សោ សត្តោ តេនុបសង្កមិ ឧបសង្កមិត្វា តំ សត្តំ ឯតទវោច ឯហិ ភោ សត្ត សាលាហារំ គមិស្សាមាតិ ។ អលំ ភោ សត្ត អាហតោ មេ សាលិ សកិំទេវ សាយំ បាតរាសាយាតិ ។ អថខោ សោ វាសេដ្ឋា សត្តោ តស្ស សត្តស្ស ទិដ្ឋានុគតឹ អាបជ្ជមានោ សាលឹ អាហាសិ សកិំទេវ ចតូហាយ ឯវំ កិរ ភោ សាធូតិ ។ អថខោ វាសេដ្ឋា អញ្ញតរោ សត្តោ យេន សោ សត្តោ តេនុបសង្កមិ

## អគ្គញ្ញសូត្រ និយាយអំពីការនាំយកស្រូវសាលីជាដើម

មានសត្វម្នាក់ចូលទៅរកសត្វនោះ លុះចូលទៅដល់ហើយ បាននិយាយបបួលសត្វនោះដូច្នេះថា នែសត្វដ៏ចំរើន អ្នកចូរមក យើងនឹងទៅនាំយកស្រូវសាលីជាអាហារ ។ សត្វនោះឆ្លើយតបថា នែសត្វដ៏ចំរើន ណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលី ក្នុងវេលាល្ងាចតែម្តង ហើយទុកបរិភោគ ក្នុងវេលាព្រឹកផង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ទើបសត្វនោះ បានយកតម្រាប់តាមសត្វនោះ ក៏ទៅនាំយកស្រូវសាលីមកដោយគិតថា យីអើ ការដែលនាំយកស្រូវសាលី មកតែម្តងប៉ុណ្ណោះសម្រាប់បរិភោគ បានពីរថ្ងៃយ៉ាងនេះ ជាការស្រួលមែន ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះឯង មានសត្វម្នាក់ទៀតចូលទៅរកសត្វនោះ លុះចូលទៅដល់ហើយ បាននិយាយបបួលសត្វនោះ ដូច្នេះថា នែសត្វដ៏ចំរើន អ្នកចូរមក យើងនឹងទៅនាំយកស្រូវសាលី ជាអាហារ ។ សត្វនោះឆ្លើយតបថា នែសត្វដ៏ចំរើន ណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលី ក្នុងវេលាល្ងាចតែម្តង ហើយទុកបរិភោគវេលាព្រឹកផង ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ទើបសត្វនោះយកតម្រាប់តាមសត្វនោះ ក៏នាំយកស្រូវសាលីមកដោយគិតថា យីអើ ការដែលនាំយកស្រូវសាលី មកតែម្តងប៉ុណ្ណោះសម្រាប់បរិភោគ បានបួនថ្ងៃយ៉ាងនេះ ជាការស្រួលមែន ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះឯង មានសត្វម្នាក់ទៀត ចូលទៅរកសត្វនោះ

ឧបសង្កមិត្វា តំ សត្តំ ឯតទវោច ឯហិ ភោ សត្ត សាលាហារំ គមិស្សាមាតិ ។ អលំ ភោ សត្ត អាហដោ មេ សាលិ សកិទេវ ចតូហាយាតិ ។ អថខោ សោ វាសេដ្ឋា សត្តោ តស្ស សត្តស្ស ទិដ្ឋានុគតឹ អាបជ្ជមានោ សាលឹ អាហាសិ សកិទេវ អដ្ឋាហាយ ឯវំ កិរ ភោ សាធូតិ ។ យតោ ខោ តេ វាសេដ្ឋា សត្តា សន្និធិការកំ សាលឹ ឧបក្កមឹសុ បរិភុញ្ជិតុំ ។ អថខោ វាសេដ្ឋា កណោ តណ្ឌុលំ បរិយោនន្ធិ[១] ថុសោបិ តណ្ឌុលំ បរិយោនន្ធិ លុនំបិ នប្បដិវិរុឡ្ហំ អបទានំ បញ្ញាយិត្ថ សណ្ឌាសណ្ឌា សាលយោ[២] អដ្ឋំសុ ។

(៦១) អថខោ តេ វាសេដ្ឋា សត្តា សន្និបតឹសុ សន្និបតិត្វា អនុត្ថុនឹសុ បាបកា វត ភោ ធម្មា សត្តេសុ បាតុភូតា មយំ ហិ បុព្វេ មនោមយា អហុម្ហា បីតិភក្ខា សយំបភា អន្តលិក្ខចរា សុភដ្ឋាយិនោ

១ ឧ. ម, អថ កណោបិ តណ្ឌុលំ បរិយោនន្ធិ ។ ២ ឧ ម. សាលិយោ ។

លុះចូលទៅដល់ហើយ បាននិយាយ បបួលសត្វនោះដូច្នេះថា ម្នាល សត្វដ៏ចំរើន អ្នកចូរមក យើងនឹងទៅនាំយកស្រូវសាលី ជាអាហារ ។ សត្វនោះឆ្លើយតបថា ម្នាលសត្វដ៏ចំរើន ណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលីមកតែម្តង ហើយទុកបរិភោគបានបួនថ្ងៃ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ទើបសត្វនោះយកគំរាប់តាមសត្វនោះ ក៏នាំយកស្រូវសាលីមកដោយគិតថា យីអើ ការដែលនាំយកស្រូវសាលីមកតែម្តងប៉ុណ្ណោះ ទុកសម្រាប់បរិភោគបាន ៨ ថ្ងៃយ៉ាងនេះ ជាការស្រួលមែន ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ លុះពួកសត្វទាំងនោះ បាននាំគ្នាផ្តើមបរិភោគស្រូវសាលីដែលខ្ចីនសន្សំទុកក្នុងកាលណាហើយៗ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ កាលនោះឯង កុណ្ឌកក៏រុំព័ទ្ធអង្ករ ទាំងអង្កាមក៏រុំព័ទ្ធអង្ករ ស្ទូង្សែកខ្ទឹងដែលគេច្រូតហើយ ក៏លែងដុះឡើងវិញ ប្រាកដជាមិនពេញដូចដើម ស្រូវសាលីទាំងឡាយ ក៏ដុះមួយគុម្ពៗ (ហាក់ដូចជាគេចងជាបាច់) ។

[៦១] ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះឯង ពួកសត្វទាំងនោះមកប្រជុំគ្នា លុះមកប្រជុំគ្នាហើយ ត្អូញត្អែរថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ខុហ្ន ធម៌ដ៏លាមកទាំងឡាយ បានកើតប្រាកដក្នុងពួកសត្វហើយ ព្រោះកាលពីដើម ពួកយើងជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯង អំពីកាយ ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុង

### អគ្គញ្ញសុត្តេ សាលិវិភជនំ មរិយាទដ្ឋបនំ

ចិរំ ទីឃមទ្ធានំ អដ្ឋម្ហា តេសំ នោ អម្ហាកំ កទាចិ ករហចិ ចិរំ(១) ទីឃស្ស អទ្ធុនោ អច្ចយេន រសបថវី ឧទកស្មឹ សមតនិ(២) សា អហោសិ វណ្ណសម្បន្នា គន្ធសម្បន្នា រសសម្បន្នា តេ មយំ រសបថវី ហត្ថេហិ អាលុម្បការកំ ឧបក្កមិម្ហា បរិភុញ្ជិតុំ តេសំ នោ រសបថវី ហត្ថេហិ អាលុម្បការកំ ឧបក្កមតំ បរិភុញ្ជតំ សយំបភា អន្តរធាយិ សយំបភាយ អន្តរហិតាយ ចន្ទិមសុរិយា បាតុរហេសុំ ចន្ទិមសុរិយេសុ បាតុភូតេសុ នក្ខត្តានិ តារករូបានិ បាតុរហេសុំ នក្ខត្តេសុ តារករូបេសុ បាតុភូតេសុ រត្តិន្ទិវា បញ្ញាយឹសុ រត្តិន្ទិវេសុ បញ្ញាយមានេសុ មាសទ្ធមាសា បញ្ញាយឹសុ មាសទ្ធមាសេសុ បញ្ញាយមានេសុ ឧតុសំវច្ឆរា បញ្ញាយឹសុ តេ មយំ រសបថវី បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋម្ហា តេសំ នោ បាបកានំយេវ អកុសលានំ ធម្មានំ បាតុភាវា រសបថវី អន្តរធាយិ

១ ឱ. ម. ចិរន្តិ ន ទិស្សតិ ។ ២ ឱ. ម. សមតានិ ។

## អគ្គញ្ញសូត្រ ការបែកស្រូវសាលី ការតាំងភ្លឺស្រែ

ទីដីល្អ បានឋិតនៅអស់កាលជាយូរអង្វែង លុះកាលកន្លងជាយូរអង្វែងទៅ ផែនដីមានរស ក៏អណ្តែតជាសលើទឹក ដើម្បីពួកយើងទាំងនោះ ឯផែនដីនោះ មានសម្បុរ (ល្អ) មានក្លិន (ក្រអូប) មានរស (ផ្អែម) ពួកយើងទាំងនោះ បាននាំគ្នាយកដៃ កកាយផែនដី ដែលមានរសមកធ្វើជាពំនូតហើយបរិភោគ កាលពួកយើងទាំងនោះ នាំគ្នាយកដៃកកាយផែនដី ដែលមានរសធ្វើជាពំនូត ហើយបរិភោគ ពន្លឺដែលភ្លឺចេញឯង (អំពីកាយ) ក៏សាបសូន្យទៅ លុះពន្លឺដែលភ្លឺចេញឯង សាបសូន្យទៅហើយ ព្រះចន្ទ្រនិងព្រះអាទិត្យ ក៏កើតប្រាកដឡើង លុះព្រះចន្ទ្រនិងព្រះអាទិត្យកើតប្រាកដឡើងហើយ នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយ ក៏កើតប្រាកដឡើង លុះនក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយ កើតប្រាកដឡើងហើយ យប់និងថ្ងៃក៏កើតប្រាកដឡើង លុះយប់និងថ្ងៃកើតប្រាកដឡើងហើយ ខែ ១ និងកន្លះខែក៏កើតប្រាកដឡើង លុះខែ ១ និងកន្លះខែកើតប្រាកដឡើងហើយ រដូវនិងឆ្នាំក៏កើតប្រាកដឡើង កាលពួកយើងទាំងនោះ បរិភោគផែនដីមានរស យកផែនដីនោះជាចំណី យកផែនដីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែផែនដីមានរសសាបសូន្យទៅ ព្រោះហេតុនៃធម៌ទាំងឡាយ ជាអកុសលដ៏លាមកកើតប្រាកដ ដល់យើងទាំងឡាយនោះ លុះផែនដីមានរសសាបសូន្យ

រសបថវិយា អន្តរហិតាយ ភូមិបប្បដិកោ បាតុរហោសិ សោ អហោសិ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ តេ មយំ ភូមិបប្បដិកំ ឧបក្កមិម្ហា បរិភុញ្ជិតុំ តេ មយំ តំ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋម្ហា តេសំ នោ បាបកានំយេវ អកុសលានំ ធម្មានំ បាតុភាវា ភូមិបប្បដិកោ អន្តរធាយិ ភូមិបប្បដិកេ អន្តរហិតេ បទាលតា បាតុរហោសិ សា អហោសិ វណ្ណសម្បន្នា គន្ធសម្បន្នា រសសម្បន្នា តេ មយំ បទាលតំ ឧបក្កមិម្ហា បរិភុញ្ជិតុំ តេ មយំ តំ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋម្ហា តេសំ នោ បាបកានំយេវ អកុសលានំ ធម្មានំ បាតុភាវា បទាលតា អន្តរធាយិ បទាលតាយ អន្តរហិតាយ អកដ្ឋបាកោ សាលិ បាតុរហោសិ អកណោ អថុសោ សុទ្ធោ សុគន្ធោ តណ្ឌុលប្ផលោ យន្តំ សាយំ សាយមាសាយ អាហរាម បាតោ តំ ហោតិ បក្កំ បដិវិរុឡ្ហំ

ហើយ ក្រមរផែនដីក៏កើតប្រាកដឡើង ឯក្រមរផែនដីនោះមានសម្បុរ (ល្អ) មានក្លិន (ក្រអូប) មានរស (ផ្អែម) ពួកយើងទាំងនោះ ក៏នាំគ្នាផ្តើមបរិភោគក្រមរផែនដី កាលពួកយើងទាំងនោះ បរិភោគក្រមរផែនដីនោះ យកក្រមរផែនដីនោះជាចំណី យកក្រមរផែនដីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែក្រមរផែនដីនោះសាមសូន្យទៅ ព្រោះហេតុនៃធម៌ទាំងឡាយ ជាអកុសលដ៏លាមក កើតប្រាកដដល់យើងទាំងឡាយនោះ លុះក្រមរផែនដីសាបសូន្យហើយ បទាលតាក៏កើតប្រាកដឡើង ឯបទាលតានោះ មានសម្បុរ (ល្អ) មានក្លិន (ក្រអូប) មានរស (ផ្អែម) ពួកយើងទាំងនោះ ក៏នាំគ្នាផ្តើមបរិភោគបទាលតា កាលពួកយើងទាំងនោះបរិភោគបទាលតានោះ យកបទាលតានោះជាចំណី យកបទាលតានោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែបទាលតានោះសាបសូន្យទៅ ព្រោះហេតុនៃធម៌ទាំងឡាយ ជាអកុសលដ៏លាមក កើតប្រាកដឡើងដល់យើងទាំងឡាយនោះ បទាលតាសាបសូន្យហើយ ទើបស្រូវសាលីកើតឯង មិនមានកុណ្ឌក មិនមានអង្កាម ជាស្រូវស្អាត មានក្លិនប្រអូប មានផ្លែចេញមកជាអង្ករ ក៏កើតប្រាកដឡើង ពួកយើងនាំយកស្រូវសាលី ត្រង់ទីណាក្នុវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងទីនោះ ក៏មានស្រូវសាលីដុះទ្រុប

យន្តំ បាតោ បាតរាសាយ អាហរាម សាយន្តំ ហោតិ បក្កំ បដិវិរុឡ្ហំ នាបទានំ បញ្ញាយិត្ថ តេ មយំ អកដ្ឋបាកំ សាលឹ បរិភុញ្ជន្តា តព្ភក្ខា តទាហារា ចិរំ ទីឃមទ្ធានំ អដ្ឋម្ហា តេសន្នោ បាបកានំយេវ អកុសលានំ ធម្មានំ បាតុភាវា កណោបិ តណ្ឌុលំ បរិយោនទ្ធិ ថុសោបិ តណ្ឌុលំ បរិយោនទ្ធិ លូនំបិ នប្បដិវិរុឡ្ហំ អបទានម្បិ(១) បញ្ញាយិត្ថ សណ្ឌសណ្ឌា សាលយោ ឋិតា យន្នូន មយំ សាលឹ វិភជេយ្យាម មរិយាទំ ឋបេយ្យាមាតិ ។ អថខោ(២) តេ សត្តា សាលឹ វិភជឹសុ មរិយាទំ ឋបេសុំ ។

(៦២) អថខោ វាសេដ្ឋ អញ្ញតរោ សត្តោ លោលជាតិកោ សកំ ភាគំ បរិរក្ខន្តោ អញ្ញតរំ ភាគំ អទិន្នំ អាទិយិត្វា បរិភុញ្ជិ ។ តមេនំ អគ្គហេសុំ គហេត្វា ឯតទវោចុំ បាបកំ វត ភោ សត្ត ករោសិ យត្រ ហិ នាម សកំ ភាគំ បរិរក្ខន្តោ

១ ម. អបទានំ ។ ២ ឱ. ម. អថខោ តេ ។

ទ្រុល មានផ្លែទុំឡើងវិញ ពួកយើងនាំយកស្រូវសាលី ត្រង់ទីណាមក ក្នុងវេលាព្រឹក សម្រាប់បរិភោគ ក្នុងវេលាព្រឹក លុះវេលាល្ងាច ទីនោះក៏មានស្រូវសាលី ដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះក៏ប្រាកដហាក់ដូចជាមិនបានច្រូតឡើយ កាលពួកយើងទាំងនោះ បរិភោគស្រូវសាលីកើតឯង យកស្រូវសាលីនោះជាចំណី យកស្រូវសាលីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែកុណ្ឌករុំពទ្ធអង្ករ ទាំងអង្កាម ក៏រុំពទ្ធអង្ករ សូម្បីទីដែលច្រូត ក៏មិនដុះឡើងវិញប្រាកដពេញដូចដើម ស្រូវសាលីទាំងឡាយក៏ដុះមួយគុម្ព ៗ (ហាក់ដូចជាគេចងជាបាច់) ព្រោះហេតុនៃធម៌ទាំងឡាយ ជាអកុសលដ៏លាមក កើតប្រាកដដល់យើងទាំងឡាយនោះ បើដូច្នោះ គួរតែយើង ចែកស្រូវសាលីគ្នា គួរតែបោះព្រំខណ្ឌ ៗ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ លំដាប់នោះឯង សត្វទាំងឡាយ ក៏នាំគ្នាចែកស្រូវសាលី បោះព្រំខណ្ឌ ដោយខ្លួនៗ ៗ

(៦២) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ គ្រានោះ មានសត្វម្នាក់ជាតិជាអ្នកលេះលោះ លាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃ ដែលគេមិនបានឲ្យ មកបរិភោគ ៗ សត្វទាំងឡាយក៏បានចាប់សត្វនោះ លុះចាប់បានហើយក៏ស្តីឲ្យដូច្នេះថា ឱសត្វអើយ ឯងធ្វើអំពើអាក្រក់ណាស់ មិនគួរបើឯងលាក់សំចៃចំណែករបស់ខ្លួនទុក លួច

អញ្ញតរំ ភាគំ អទិន្នំ អាទិយិត្វា បរិភុញ្ជសិ មា ភោ (១) សត្ត បុន (២) ឯវរូបមកាសីតិ ។ ឯវំ ភោតិ ខោ វាសេដ្ឋា សោ សត្តោ តេសំ សត្តានំ បច្ចស្សោសិ ។ ទុតិយម្បិ ខោ វាសេដ្ឋា សោ សត្តោ ។ បេ ។ តតិយម្បិ ខោ វាសេដ្ឋា សោ សត្តោ សកំ ភាគំ បរិរក្ខន្តោ អញ្ញតរំ ភាគំ អទិន្នំ អាទិយិត្វា បរិភុញ្ជិ ។ តមេនំ អគ្គហេសុំ គហេត្វា ឯតទវោចុំ បាបកំ វត ភោ សត្ត ករោសិ យត្រ ហិ នាម សកំ ភាគំ បរិរក្ខន្តោ អញ្ញតរំ ភាគំ អទិន្នំ អាទិយិត្វា បរិភុញ្ជិ (៣) មា ភោ សត្ត បុនបិ ឯវរូបំ អកាសីតិ ។ អញ្ញេ បាណិនា បហរឹសុ អញ្ញេ លេឌ្ឌុនា បហរឹសុ អញ្ញេ ទណ្ឌេន បហរឹសុ ។ តទគ្គេ ខោ បន វាសេដ្ឋា អទិន្នាទានំ បញ្ញាយតិ គរហា បញ្ញាយតិ មុសាវាទោ បញ្ញាយតិ ទណ្ឌាទានំ បញ្ញាយតិ ។ អថខោ តេ វាសេដ្ឋា សត្តា សន្និបតឹសុ សន្និបតិត្វា អនុត្ថុនឹសុ

---

១ ឱ. មាស្សុ ភោ ។ ម. មាសុ ភោ ។ ២ ឱ. ម. បុនបិ ។ ៣ ឱ. ម. បរិភុញ្ជសិ ។

យកចំណែករបស់អ្នកដទៃ ដែលគេមិនបានឲ្យ មកបរិភោគសោះ នែសត្វអើយ ឯងកុំធ្វើអំពើបែបនេះទៀតឡើយ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះបានទទួលតបពាក្យ របស់ពួកសត្វទាំងនោះថា អើអ្នកដ៏ចំរើន ។ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ សត្វនោះ (លួចយកចំណែករបស់អ្នកដទៃ) ជាគំរប់ពីរដងផង ។ បេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះបានលាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃ ដែលគេមិនបានឲ្យ មកបរិភោគជាគំរប់ ៣ ដងផង ។ សត្វទាំងឡាយក៏បានចាប់សត្វនោះ លុះចាប់បានហើយក៏ស្តីឲ្យដូច្នេះថា នែសត្វអើយ ឯងធ្វើអំពើអាក្រក់ណាស់ មិនគួរបើឯងលាក់សំចៃរបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃ ដែលគេមិនបានឲ្យ មកបរិភោគសោះ នែសត្វអើយ ឯងកុំធ្វើអំពើបែបនេះទៀតឡើយ ។ ពួកសត្វខ្លះគប់ទះ (សត្វនោះ) នឹងដៃ ពួកសត្វខ្លះចោលនឹងដុំដី ពួកសត្វខ្លះវាយនឹងតម្បង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ការលួចទ្រព្យគេក៏ប្រាកដឡើង ការតិះដៀលក៏ប្រាកដឡើង ការនិយាយកុហកក៏ប្រាកដឡើង ការដាក់អាជ្ញាក៏ប្រាកដឡើង តាំងពីកាលនោះជាដើមមក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង ពួកសត្វទាំងនោះមកប្រជុំគ្នា លុះប្រជុំគ្នាហើយ ក៏ត្អូញត្អែរថា

## អគ្គញ្ញសុត្តេ ឯកសត្តសម្មតិ សាលិភាគានុប្បទានំ

បាបកា វត ភោ ធម្មា សត្តេសុ បាតុភូតា យត្រ ហិ នាម អទិន្នាទានំ បញ្ញាយិស្សតិ គរហា បញ្ញាយិស្សតិ មុសាវាទោ បញ្ញាយិស្សតិ ទណ្ឌាទានំ បញ្ញាយិស្សតិ យន្នូន មយំ ឯកំ សត្តំ សម្មន្នេយ្យាម យោ[១] នោ សម្មាខីយិតព្វំ ខីយេយ្យ សម្មាគរហិតព្វំ គរហេយ្យ សម្មាបព្វាជេតព្វំ បព្វាជេយ្យ មយំ បនស្ស សាលីនំ ភាគំ អនុប្បទស្សាមាតិ ។ អថខោ តេ វាសេដ្ឋ សត្តា យោ នេសំ សត្តោ អភិរូបតរោ ច ទស្សនីយតរោ ច បាសាទិកតរោ ច មហេសក្ខតរោ ច តំ សត្តំ ឧបសង្កមិត្វា ឯតទវោចុំ ឯហិ ភោ សត្ត សម្មាខីយិតព្វំ ខីយ[២] សម្មាគរហិតព្វំ គរហ[៣] សម្មាបព្វាជេតព្វំ បព្វាជេហិ មយំ បន តេ[៤] សាលីនំ ភាគំ អនុប្បទស្សាមាតិ ។

---

១ ឱ. សោ ។ ២ ខីយីតិបិ កត្ថចិ បោត្ថកេ ។ ៣ ឱ. គរហោ ។ ៤ ឱ. ម. តេ ។

យីអើហ្ន៎ ធម៌ដ៏លាមកទាំងឡាយ កើតប្រាកដដល់សត្វទាំងឡាយហើយ ព្រោះថា ការលួចទ្រព្យគេក៏កើតប្រាកដឡើង ការតិះដៀលក៏កើតប្រាកដឡើង ការនិយាយកុហកក៏កើតប្រាកដឡើង ការដាក់អាជ្ញាក៏កើតប្រាកដឡើង បើដូច្នោះ គួរតែពួកយើងសន្មតសត្វណាម្នាក់ ឲ្យជាអ្នកបន្ទោសសត្វ ដែលយើងគួរបន្ទោសតាមហេតុ ឲ្យតិះដៀលសត្វ ដែលយើងគួរតិះដៀលតាមហេតុ ឲ្យបណ្តេញសត្វ ដែលយើងគួរបណ្តេញតាមហេតុ ចំណែកខាងពួកយើង ត្រូវជូនចំណែកស្រូវសាលីទាំងឡាយ ឲ្យដល់សត្វនោះ ៗ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទើបពួកសត្វទាំងនោះ នាំគ្នាចូលទៅរកសត្វ ដែលជាអ្នកមានរូបល្អ គួររមិលមើល គួរជ្រះថ្លា មានសក្តិធំ(១) ជាងពួកសត្វទាំងនោះ លុះចូលទៅដល់ហើយ បាននិយាយដូច្នេះថា បពិត្រសត្វដ៏ចំរើន អ្នកចូរមកបន្ទោសសត្វ ដែលគួរបន្ទោសតាមហេតុ ចូរតិះដៀលសត្វ ដែលគួរតិះដៀលតាមហេតុ ចូរបណ្តេញសត្វ ដែលគួរបណ្តេញតាមហេតុចុះ សូមពួកយើងនឹងជូនចំណែកស្រូវសាលីទាំងឡាយដល់អ្នក ៗ

---

១ ( អដ្ឋកថា ) គឺព្រះបរមពោធិសត្វនៃយើង ។

ឯវំ ភោតិ ខោ សោ វាសេដ្ឋ សត្តោ(១) តេសំ សត្តានំ បដិស្សុត្វា សម្មាខីយិតព្វំ ខីយិ សម្មាគរហិតព្វំ គរហិ សម្មាបព្វាជេតព្វំ បព្វាជេសិ ។ តេ បនស្ស សាលីនំ ភាគំ អនុប្បទំសុ ។

(៦៣) មហាជនសម្មតោតិ ខោ វាសេដ្ឋ មហាសម្មតោត្វេវ(២) បឋមំ អក្ខរំ ឧបនិព្វត្តំ ។ ខេត្តានំ អធិបតីតិ(៣) ខោ វាសេដ្ឋ ខត្តិយោ ខត្តិយោត្វេវ ទុតិយំ អក្ខរំ ឧបនិព្វត្តំ ។ ធម្មេន បរេ រញ្ជេតីតិ(៤) ខោ វាសេដ្ឋ រាជា រាជាត្វេវ តតិយំ អក្ខរំ ឧបនិព្វត្តំ ។ ឥតិ ខោ វាសេដ្ឋ ឯវមេតស្ស ខត្តិយមណ្ឌលស្ស បោរាណេន អគ្គញ្ញេន អក្ខរេន អភិនិព្វត្តិ អហោសិ ។ តេសំយេវ សត្តានំ អនញ្ញេសំ សទិសានំយេវ នោ អសទិសានំ ធម្មេនេវ

---

១ ឱ. ម. វាសេដ្ឋ សោ សត្តោ ។ ២ ឱ. ម. មហាសម្មតោ មហាសម្មតោត្វេវ ។
៣ ឱ. បតីតិ ។ ៤ ឱ. បរេ រញ្ជេតីតិ ។

ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សត្វនោះ បានទទួលតបពាក្យរបស់សត្វទាំងនោះថា អើអ្នកដ៏ចំរើនទាំងឡាយ ហើយក៏បន្ទោសសត្វ ដែលគួរបន្ទោសតាមហេតុ តិះដៀលសត្វដែលគួរតិះដៀលតាមហេតុ បណ្តេញសត្វ ដែលគួរបណ្តេញតាមហេតុ ។ ពួកសត្វទាំងនោះ ក៏បានជូនចំណែកស្រូវសាលីទាំងឡាយដល់សត្វនោះ ។

(៦៣) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សត្វនោះ មហាជនសន្មតហើយ ព្រោះហេតុនោះឯង ទើបអក្ខរៈ(១)ជាដំបូងក៏កើតឡើងថា មហាសន្មត ដូច្នេះ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សត្វនោះជាអធិបតីនៃស្រែទាំងឡាយ ព្រោះហេតុនោះឯង ទើបអក្ខរៈទី ២ ក៏កើតឡើងថា ខត្តិយៈ ខត្តិយៈ ដូច្នេះ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សត្វនោះញ៉ាំងសត្វទាំងឡាយដទៃ ឲ្យពេញចិត្តដោយធម៌ ព្រោះហេតុនោះឯង ទើបអក្ខរៈទី ៣ ក៏កើតឡើងថា រាជា រាជា ដូច្នេះ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ហេតុដូច្នោះ អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើងដល់ខត្តិយមណ្ឌលនោះយ៉ាងនេះឯង ។ ការកើតនៃអក្ខរៈដល់ពួកសត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងតែដោយធម៌

---

១ អដ្ឋកថា ថា បាឧធិលំពាក្យសម្រាប់កំណត់ សម្រាប់ហៅឈ្មោះ សម្រាប់បញ្ញត្តិ សម្រាប់និយាយ ។

នោ អធម្មេន ។ ធម្មោ ហិ វាសេដ្ឋា សេដ្ឋោ ជនេតស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។

(៦៤) អថខោ តេសំ សត្តានំយេវ(១) ឯកច្ចានំ ឯតទហោសិ បាបកា វត ភោ ធម្មា សត្តេសុ បាតុភូតា យត្រ ហិ នាម អទិន្នាទានំ បញ្ញាយិស្សតិ គរហា បញ្ញាយិស្សតិ មុសាវាទោ បញ្ញាយិស្សតិ ទណ្ឌាទានំ បញ្ញាយិស្សតិ បព្វាជនំ បញ្ញាយិស្សតិ យន្នូន មយំ បាបកេ អកុសលេ ធម្មេ វាហេយ្យាមាតិ(២) ។ តេ បាបកេ អកុសលេ ធម្មេ វាហេសុំ ។ បាបកេ អកុសលេ ធម្មេ វាហេន្តីតិ ខោ វាសេដ្ឋា ព្រាហ្មណា ព្រាហ្មណាត្វេវ បឋមំ អក្ខរំ ឧបនិព្វត្តំ ។ តេ អរញ្ញាយតនេ បណ្ណកុដិយោ ច ករិត្វា បណ្ណកុដីសុ ឈាយន្តិ ។ វីតង្គារា វីតធូមា បន្នមុសលា សាយំ សាយមាសាយ បាតោ បាតរាសាយ គាមនិគមរាជធានិយោ ឱសរន្តិ ឃាសមេសនា(៣) ។ តេ

១ ឱ. តេសញ្ញេវ ខោ វាសេដ្ឋ សត្តានំ ។ ម. អថខោ តេសំ វាសេដ្ឋ សត្តានំយេវ ។
២ ឱ. ពាហេយ្យាមាតិ ។ ៣ ម. ឃាសមេសមានា ។

អគ្គញ្ញសូត្រ និយាយអំពីបាបធម៌មានអទិន្នាទានជាដើម

ប៉ុណ្ណោះឯង មិនមែនដោយសុខធម៌ទេ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជន ទាំងបច្ចុប្បន្ន នឹងបរលោក ។

(៦៤) គ្រានោះឯង បណ្តាសត្វទាំងឡាយនោះ សត្វពួកខ្លះបាន គិតគ្នាយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើនទាំងឡាយ ធម៌ដ៏លាមកទាំងឡាយ កើតប្រាកដ ដល់ពួកសត្វហើយ ព្រោះថា ការលួចទ្រព្យគេ ក៏ប្រាកដ ឡើង ពាក្យតិះដៀល ក៏ប្រាកដឡើង ការនិយាយកុហក ក៏ប្រាកដឡើង ការដាក់អាជ្ញា ក៏ប្រាកដឡើង ការបណ្តេញ ក៏ប្រាកដឡើង បើដូច្នោះ ពួកយើងគួរតែបន្សាត់ នូវធម៌ជាអកុសល ដ៏លាមកទាំងឡាយចេញ ។ សត្វទាំងនោះ ក៏បានបន្សាត់ នូវធម៌ជាអកុសលដ៏លាមកចេញ ។ ម្នាល វាសេដ្ឋៈ នឹងភារទ្វាជៈ សត្វទាំងឡាយនោះបន្សាត់ នូវធម៌ជាអកុសល ដ៏លាមក ព្រោះហេតុនោះឯង ទើបអក្ខរៈទី ១ ក៏កើតឡើងថា ព្រាហ្មណៈ ព្រាហ្មណៈដូច្នេះ ។ សត្វទាំងឡាយនោះ បានធ្វើជំរំស្លឹកក្នុងព្រៃរំលោង ហើយសំឡឹងអារម្មណ៍ ក្នុងជំរំប្រក់ស្លឹកទាំងឡាយ ។ ពួកសត្វទាំងនោះ មិនមានភ្លើង មិនមានផ្សែង មិនមានអង្រែ ត្រាច់ទៅកាន់ស្រុកនិគមនឹង រាជធានី ស្វែងរកអាហារក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច ស្វែងរកក្នុងវេលាព្រឹកសម្រាប់បរិភោគក្នុងវេលាព្រឹក ។ ពួកសត្វទាំងនោះ

ឃាសំ បដិលភិត្វា បុនទេវ អរញ្ញាយតនេ បណ្ណកុដីសុ ឈាយន្តិ ។ តមេនំ មនុស្សា ទិស្វា ឯវមាហំសុ ឥមេ ខោ ភោ សត្តា អរញ្ញាយតនេ បណ្ណកុដិយោ ករិត្វា បណ្ណកុដីសុ ឈាយន្តិ វីតង្គារា វីតធូមា បន្នមុសលា សាយំ សាយមាសាយ បាតោ បាតរាសាយ គាម-និគមរាជធានិយោ ឱសរន្តិ ឃាសមេសនា ។ តេ ឃាសំ បដិលភិត្វា បុនទេវ អរញ្ញាយតនេ បណ្ណ-កុដីសុ ឈាយន្តិ ។ ឈាយន្តីតិ ខោ បន វាសេដ្ឋ ឈាយិកា ឈាយិកាត្វេវ(១) ទុតិយំ អក្ខរំ ឧប-និព្វត្តំ ។ តេសំយេវ ខោ វាសេដ្ឋ សត្តានំ ឯកច្ចេ សត្តា អរញ្ញាយតនេ បណ្ណកុដីសុ ឈានំ(២) អន-ភិសម្ភុនមានា គាមសាមន្តំ និគមសាមន្តំ ឱសរិត្វា(៣) គន្ថេ ករោន្តា អាគច្ឆន្តិ ។ តមេនំ មនុស្សា ទិស្វា ឯវមាហំសុ ឥមេ ខោ បន ភោ(៤) សត្តា

---

១ ឱ. ឈាយន្តិ ។ ឈោយន្តីតិ ខោ បន វាសេដ្ឋ ឈាយកា ឈាយកាត្វេវ ។ ២ ឱ. ម. តំ ឈានំ ។ ៣ ឱ. និគមសាមន្តមោសរិត្វា ។ ៤ ឱ. ម. ខោ ភោ ។

លុះបានអាហារហើយ ក៏នៅសំឡឹងអារម្មណ៍ ក្នុងដំរំស្លឹកទាំងឡាយក្នុងព្រៃរំលោងទៀត ។ មនុស្សទាំងឡាយ លុះឃើញសត្វទាំងនោះហើយ ក៏និយាយគ្នាយ៉ាងនេះថា នែគ្នាយើងអើយ ពួកសត្វទាំងនេះឯង ធ្វើដំរំស្លឹកទាំងឡាយ ក្នុងព្រៃរំលោង ហើយនៅសំឡឹងអារម្មណ៍ ក្នុងដំរំស្លឹកទាំងឡាយ ជាសត្វមិនមានភ្លើង មិនមានផ្សែង មិនមានអង្រែ តែងត្រាច់ទៅកាន់ស្រុកនិគមនឹងរាជធានី ស្វែងរកអាហារក្នុងវេលាល្ងាចសម្រាប់បរិភោគក្នុងវេលាល្ងាច ស្វែងរកក្នុងវេលាព្រឹកសម្រាប់បរិភោគ ក្នុងវេលាព្រឹក ។ ពួកសត្វទាំងនោះ លុះបានអាហារហើយ ក៏សំឡឹងអារម្មណ៍ក្នុងដំរំស្លឹក ក្នុងព្រៃរំលោងទៀត ។ ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ ពួកសត្វទាំងនោះឯង តែងសំឡឹងអារម្មណ៍ ព្រោះហេតុនោះឯង ទើបអក្ខរៈទី ២ ក៏កើតឡើងថា ឈាយិកា ឈាយិកា (អ្នកសំឡឹងអារម្មណ៍) ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ បណ្ដាសត្វទាំងនោះឯង សត្វពួកខ្លះកាលមិនអាចនឹងសំឡឹងអារម្មណ៍ក្នុងដំរំស្លឹកទាំងឡាយ ក្នុងព្រៃរំលោងបាន ក៏ចូលទៅកាន់ស្រុកជិត និគមជិត តាក់តែងបង្រៀននូវគន្ថៈ (គឺវេទមន្ត) រួចត្រឡប់មកវិញ ។ មនុស្សទាំងឡាយ លុះបានឃើញសត្វទាំងនោះហើយនិយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើងអើយ ពួកសត្វទាំងនេះឯង មិនអាចនឹង

អរញ្ញាយតនេ បណ្ណកុដីសុ ឈានំ អនភិសម្ភុណមានា គាមសាមន្តំ និគមសាមន្តំ ឱសរិត្វា គន្ថេ ករោន្តា អច្ឆន្តិ ។ ន ទានិមេ ឈាយន្តិ ន ទានិមេ ឈាយន្តីតិ ខោ វាសេដ្ឋ អជ្ឈាយិកា អជ្ឈាយិកាត្វេវ តតិយំ អក្ខរំ ឧបនិព្វត្តំ ។ ហីនសម្មតំ ខោ បន វាសេដ្ឋ តេន សមយេន ហោតិ តទេតរហិ សេដ្ឋសម្មតំ ។ ឥតិ ខោ វាសេដ្ឋ ឯវមេតស្ស ព្រាហ្មណមណ្ឌលស្ស បោរាណេន អគ្គញ្ញេន អក្ខរេន អភិនិព្វត្តិ អហោសិ ។ តេសំយេវ សត្តានំ អនញ្ញេសំ សទិសានំយេវ នោ អសទិសានំ ធម្មេនេវ នោ អធម្មេន ។ ធម្មោ ហិ វាសេដ្ឋ សេដ្ឋោ ជនេតស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។

(៦៨) តេសំយេវ ខោ វាសេដ្ឋ សត្តានំ ឯកច្ចេ សត្តា មេថុនំ ធម្មំ សមាទាយ វិសុំ កម្មន្តេ[១] បយោជេសុំ ។ មេថុនំ ធម្មំ សមាទាយ វិសុំ

---

១ ឱ. មេថុនធម្មំ សមាទាយ វិស្សុតកម្មន្តេ ។

សំឡឹងអារម្មណ៍ក្នុងជំរំស្លឹកទាំងឡាយ ក្នុងព្រៃរំលោងបាន ក៏ចូលមកកាន់ស្រុកជិត និគមជិត តាក់តែងបង្រៀននូវគន្ថៈរូបត្រឡប់ទៅវិញ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សត្វទាំង នះ រមែងមិនសំឡឹងអារម្មណ៍ ក្នុងកាលឥឡូវនេះ សត្វទាំងនេះ រមែងមិនសំឡឹងអារម្មណ៍ ក្នុងកាលឥឡូវនេះ ព្រោះហេតុនោះឯង ទើបអក្ខរៈទី ៣ ក៏កើតឡើងថា អជ្ឈាយិកា អជ្ឈាយិកា (អ្នកមិនសំឡឹងអារម្មណ៍) ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ក្នុងសម័យនោះ ការទ្រទ្រង់នឹងការបង្រៀននូវមន្ត គេសន្មតថាជាការថោកទាបទេ តែក្នុងកាលឥឡូវនេះ ការទ្រទ្រង់នឹងការបង្រៀននូវមន្តនោះ គេសន្មតថាជាការប្រសើរវិញ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ហេតុដូច្នោះឯង អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើង ដល់ព្រាហ្មណមណ្ឌលនោះ យ៉ាងនេះ ។ ការកើតនៃអក្ខរៈដល់ពួកសត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែម្យ៉ាងប៉ុណ្ណោះឯង មិនមែនដោយខុសធម៌ទេ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជនទាំងបច្ចុប្បន្ននឹងបរលោក ។

(៦៩) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ បណ្ដាសត្វទាំងនោះឯង សត្វពួកខ្លះប្រព្រឹត្តកាន់នូវមេថុនធម្ម ហើយប្រកបការងារផ្សេងគ្នា ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ សត្វទាំងឡាយប្រព្រឹត្តកាន់នូវមេថុនធម្ម ហើយ

កម្មន្តេ បយោជេន្តីតិ ខោ វាសេដ្ឋា វេស្សា វេស្សា ត្វេវ អក្ខរំ និព្វត្តំ ។ ឥតិ ខោ វាសេដ្ឋា ឯវមេតស្ស ។ សន្និត្តំ(១) ។ ឥតិ ខោ វាសេដ្ឋា ឯវមេតស្ស សុទ្ទ-មណ្ឌលស្ស បោរាណេន អគ្គញ្ញេន អក្ខរេន អភិនិព្វត្តិ អហោសិ តេសំយេវ សត្តានំ អនញ្ញេសំ(២) សទិសានំ-យេវ នោ អសទិសានំ ធម្មេនេវ នោ អធម្មេន ។ ធម្មោ ហិ វាសេដ្ឋា សេដ្ឋោ ជនេតស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។

[៦៦] អហុ ខោ សោ វាសេដ្ឋា សមយោ យំ ខត្តិយោបិ សកំ ធម្មំ គរហមានោ អគារស្មា អនគា-រិយំ បព្វជតិ សមណោ ភវិស្សាមីតិ ។ ព្រាហ្មណោបិ វាសេដ្ឋា ។ បេ ។ វេស្សោបិ វាសេដ្ឋា ។ បេ ។ សុទ្ទោបិ ខោ(៣) សកំ ធម្មំ គរហមានោ អគារស្មា អនគារិយំ បព្វជតិ សមណោ ភវិស្សាមីតិ ។ ឥមេហិ ខោ វាសេដ្ឋា ចតូហិ មណ្ឌលេហិ សមណមណ្ឌលស្ស

១ ឱ. ម. សន្និត្តន្តិ ន ទិស្សតិ ។ ២ ឱ. ម. អនញ្ញេសំ ។ ៣ ឱ. ខោ វាសេដ្ឋ ន ទិស្សតិ ។

ប្រកបការងារផ្សេងគ្នា ព្រោះហេតុនោះឯង ទើបអក្ខរៈក៏កើតថា វេស្សៈ វេស្សៈដូច្នេះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ( ការកើតឡើងនៃអក្ខរៈ ដែលជាច្បាប់ចាស់ក៏មានឡើង ) ដល់វេស្សមណ្ឌលនុ៎ះយ៉ាងនេះ ដោយហេតុនេះឯង ។ សេចក្តីបំប្រួញ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ហេតុដូច្នោះឯង អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើងដល់សុទ្ទមណ្ឌលនុ៎ះយ៉ាងនេះឯង ការកើតឡើងនៃអក្ខរៈ ដល់ពួកសត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែប៉ុណ្ណោះឯង មិនមែនដោយខុសធម៌ទេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជន ទាំងបច្ចុប្បន្ន និងបរលោក ។

(៦៦) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសម័យ ដែលខត្តិយៈខ្លះ តិះដៀលធម៌របស់ខ្លួន ហើយចេញចាកផ្ទះចូលមកបួស ដោយបំណងថា អាត្មាអញនឹងធ្វើជាសមណៈដូច្នេះក៏មាន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រាហ្មណ៍ខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ វេស្សៈខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សុទ្ទៈខ្លះ តិះដៀលធម៌របស់ខ្លួន ចេញចាកផ្ទះចូលទៅបួសដោយបំណងថា អាត្មាអញនឹងធ្វើជាសមណៈដូច្នេះក៏មាន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ការកើតឡើងនៃសមណមណ្ឌល ក៏បានមានឡើង

អភិនិព្វត្តិ អហោសិ តេសំយេវ សត្តានំ អនញ្ញេសំ សទិសានំយេវ នោ អសទិសានំ ធម្មេនេវ នោ អធម្មេន ។ ធម្មោ ហិ វាសេដ្ឋ សេដ្ឋោ ជនេតស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។

(៦៧) ខត្តិយោបិ ខោ វាសេដ្ឋ កាយេន ទុច្ចរិតញ្ចរិត្វា វាចាយ ទុច្ចរិតញ្ចរិត្វា មនសា ទុច្ចរិតញ្ចរិត្វា មិច្ឆាទិដ្ឋិកោ មិច្ឆាទិដ្ឋិកម្មសមាទានោ[១] មិច្ឆាទិដ្ឋិកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ព្រាហ្មណោបិ ខោ វាសេដ្ឋ ។ បេ ។ វេស្សោបិ ខោ វាសេដ្ឋ ។ បេ ។ សុទ្ទោបិ ខោ វាសេដ្ឋ ។ បេ ។ សមណោបិ ខោ វាសេដ្ឋ កាយេន ទុច្ចរិតញ្ចរិត្វា វាចាយ ទុច្ចរិតញ្ចរិត្វា មនសា ទុច្ចរិតញ្ចរិត្វា មិច្ឆាទិដ្ឋិកោ មិច្ឆាទិដ្ឋិកម្មសមាទានោ មិច្ឆាទិដ្ឋិកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។

---

១ ឱ. មិច្ឆាទិដ្ឋិកម្មសមាទានោតិ ន ទិស្សតិ ។

ដោយសារមណ្ឌលទាំង ៤ នេះឯង ការកើតឡើងនៃសមណមណ្ឌលដល់សត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែប៉ុណ្ណោះឯង មិនមែនដោយខុសធម៌ទេ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជនទាំងបច្ចុប្បន្ននឹងបរលោក ។

(៦៧) ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ មានខត្តិយៈខ្លះប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្តជាមិច្ឆា-ទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ ព្រោះហេតុតែប្រកាន់ នូវកម្មជាមិច្ឆា-ទិដ្ឋិនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ។ បេ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ មានវេស្សៈខ្លះ ។ បេ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ មានសុទ្ទៈខ្លះ ។ បេ ។ ម្នាលវាសេដ្ឋៈ នឹងភារទ្វាជៈ មានសមណៈខ្លះ ប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ ព្រោះហេតុតែប្រកាន់នូវកម្មជាមិច្ឆា-ទិដ្ឋិនោះ លុះបែកធ្លាយរាយកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។

(២៨) ខត្តិយោបិ ខោ វាសេដ្ឋ កាយេន សុចរិតញ្ចរិត្វា វាចាយ សុចរិតញ្ចរិត្វា មនសា សុចរិតញ្ចរិត្វា សម្មាទិដ្ឋិកោ សម្មាទិដ្ឋិកម្មសមាទានោ សម្មាទិដ្ឋិកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ព្រាហ្មណោបិ ខោ វាសេដ្ឋ ។ បេ ។ វេស្សោបិ ខោ វាសេដ្ឋ ។ បេ ។ សុទ្ទោបិ ខោ វាសេដ្ឋ ។ បេ ។ សមណោបិ ខោ វាសេដ្ឋ កាយេន សុចរិតញ្ចរិត្វា វាចាយ សុចរិតញ្ចរិត្វា មនសា សុចរិតញ្ចរិត្វា សម្មាទិដ្ឋិកោ សម្មាទិដ្ឋិកម្មសមាទានោ សម្មាទិដ្ឋិកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។

(២៩) ខត្តិយោបិ ខោ វាសេដ្ឋ កាយេន ទ្វយការី វាចាយ ទ្វយការី មនសា ទ្វយការី វិមិស្សទិដ្ឋិកោ វិមិស្សកម្មសមាទានោ វិមិស្សកម្មសមាទានហេតុ(១) កាយស្ស ភេទា បរំ មរណា

១ ឱ. វិតិមិស្សទិដ្ឋិកោ វិតិមិស្សទិដ្ឋិកម្មសមាទានហេតុ ។

(៦៨) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានខត្តិយៈខ្លះប្រព្រឹត្តល្អដោយកាយ ប្រព្រឹត្តល្អដោយវាចា ប្រព្រឹត្តល្អដោយចិត្ត ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ ព្រោះហេតុតែប្រកាន់នូវកម្មជាសម្មាទិដ្ឋិនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ។ បេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានវេស្សៈខ្លះ ។ បេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសុទ្ទៈខ្លះ ។ បេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសមណៈខ្លះប្រព្រឹត្តល្អដោយកាយ ប្រព្រឹត្តល្អដោយវាចា ប្រព្រឹត្តល្អដោយចិត្ត ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ ព្រោះហេតុតែប្រកាន់នូវកម្មជាសម្មាទិដ្ឋិនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

(៦៩) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានខត្តិយៈខ្លះជាអ្នកធ្វើអំពើទាំងពីរ គឺជួនកាល ធ្វើអំពើអាក្រក់ ជួនកាល ធ្វើអំពើល្អដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិប្រឡំគ្នាផ្សេង ៗ ប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេង ៗ ព្រោះហេតុតែប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេង ៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តី

## អគ្គញ្ញសុត្តេ ទុច្ចរិតចរណំ សុចរិតវិបាកា

សុខទុក្ខប្បដិសំវេទី ហោតិ ។ ព្រាហ្មណោ បិ ខោ វាសេដ្ឋា កាយេន ទ្វយការី វាចាយ ទ្វយការី មនសា ទ្វយការី វិមិស្សទិដ្ឋិកោ វិមិស្សកម្មសមាទានោ វិមិស្សកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា សុខទុក្ខប្បដិសំវេទី ហោតិ ។ វេស្សោ បិ ខោ វាសេដ្ឋា កាយេន ទ្វយការី វាចាយ ទ្វយការី មនសា ទ្វយការី វិមិស្សទិដ្ឋិកោ វិមិស្សកម្មសមាទានោ វិមិស្សកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា សុខទុក្ខប្បដិសំវេទី ហោតិ ។ សុទ្ទោ បិ ខោ វាសេដ្ឋា កាយេន ទ្វយការី វាចាយ ទ្វយការី មនសា ទ្វយការី វិមិស្សទិដ្ឋិកោ វិមិស្សកម្មសមាទានោ វិមិស្សកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា សុខទុក្ខប្បដិសំវេទី ហោតិ ។ សមណោ បិ ខោ វាសេដ្ឋា កាយេន ទ្វយការី វាចាយ ទ្វយការី មនសា ទ្វយការី

ស្លាប់ ក៏បានទទួលសុខខ្លះទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ជាអ្នកធ្វើអំពើទាំងពីរ ដោយកាយ ធ្វើអំពើទាំងពីរ ដោយវាចា ធ្វើអំពើទាំងពីរ ដោយចិត្ត មានទិដ្ឋិ ប្រទាំគ្នាផ្សេង ៗ ប្រកាន់នូវកម្មដែលប្រទាំគ្នាផ្សេង ៗ ព្រោះហេតុតែប្រកាន់នូវកម្ម ដែលប្រទាំគ្នាផ្សេង ៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានវេស្សៈខ្លះ ជាអ្នកធ្វើអំពើទាំងពីរ ដោយកាយ ធ្វើអំពើទាំងពីរ ដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិប្រទាំគ្នាផ្សេង ៗ ប្រកាន់នូវកម្មដែលប្រទាំគ្នាផ្សេង ៗ ព្រោះហេតុតែប្រកាន់នូវកម្ម ដែលប្រទាំគ្នាផ្សេង ៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសុទ្ទៈខ្លះ ជាអ្នកធ្វើអំពើទាំងពីរ ដោយកាយ ធ្វើអំពើទាំងពីរ ដោយវាចា ធ្វើអំពើទាំងពីរ ដោយចិត្ត មានទិដ្ឋិប្រទាំគ្នាផ្សេង ៗ ប្រកាន់នូវកម្មដែលប្រទាំគ្នាផ្សេង ៗ ព្រោះហេតុតែប្រកាន់នូវកម្ម ដែលប្រទាំគ្នាផ្សេង ៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសមណៈខ្លះ ជាអ្នកធ្វើអំពើទាំងពីរ ដោយកាយ ធ្វើអំពើទាំងពីរ ដោយវាចា ធ្វើអំពើទាំងពីរ ដោយចិត្ត មានទិដ្ឋិ

វិមិស្សទិដ្ឋិកោ វិមិស្សកម្មសមាទានោ វិមិស្សកម្មសមាទានហេតុ កាយស្ស ភេទា បរំ មរណា សុខទុក្ខប្បដិសំវេទី ហោតិ ។

(៧០) ខត្តិយោបិ ខោ វាសេដ្ឋ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ សត្តន្នំ ពោធិបក្ខិយានំ ធម្មានំ[1] ភាវនមន្វាយ ទិដ្ឋេយេវ[2] ធម្មេ បរិនិព្វាយតិ[3] ។ ព្រាហ្មណោបិ ខោ វាសេដ្ឋ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ សត្តន្នំ ពោធិបក្ខិយានំ ធម្មានំ ភាវនមន្វាយ ទិដ្ឋេយេវ ធម្មេ បរិនិព្វាយតិ ។ វេស្សោបិ ខោ វាសេដ្ឋ កាយេន សំវុតោ វាចាយ សំវុតោ មនសា សំវុតោ សត្តន្នំ ពោធិបក្ខិយានំ ធម្មានំ ភាវនមន្វាយ ទិដ្ឋេយេវ ធម្មេ បរិនិព្វាយតិ ។ សុទ្ទោបិ ខោ វាសេដ្ឋ កាយេន[4] សំវុតោ វាចាយ សំវុតោ មនសា សំវុតោ សត្តន្នំ ពោធិបក្ខិយានំ ធម្មានំ ភាវនមន្វាយ ទិដ្ឋេយេវ ធម្មេ បរិនិព្វាយតិ ។

---

១ ម. ពោធិបក្ខិយធម្មានំ ។ ២ ឱ. ម. ទិដ្ឋេវ ។ ៣ ម. បរិនិព្វាតិ ។ ៤ ឱ. ម. សុទ្ទោបិ ខោ វាសេដ្ឋ ។ សមណោបិ ខោ វាសេដ្ឋ កាយេន ។

ប្រទុស្តគ្នាផ្សេងៗ ប្រកាន់នូវកម្មដែលប្រទុស្តគ្នាផ្សេងៗ ព្រោះហេតុតែប្រកាន់នូវកម្មដែលប្រទុស្តគ្នាផ្សេងៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។

(៧០) ម្នាលវាសេដ្ឋៈ និងទ្វារភាជៈ មានខត្តិយៈខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចំរើនពោធិបក្ខិយធម៌ ៧ កង(១) ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចំរើនពោធិបក្ខិយ-ធម៌ ៧ កង ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានវេស្សៈខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចំរើនពោធិបក្ខិយធម៌ ៧ កង ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសុទ្ទៈខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចំរើនពោធិបក្ខិយធម៌ ៧ កង ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។

---

១ ពោធិបក្ខិយធម៌ ៧ កងរាប់យកសតិប្បដ្ឋាន៤ជាកង ១ រហូតដល់អដ្ឋង្គិកមគ្គជាកងទីបំផុត ។

## អគ្គញ្ញសុត្តំ សនង្កុមារព្រហ្មគាថា

(៧១) ឥមេសំ ហិ វាសេដ្ឋា ចតុន្នំ វណ្ណានំ យោ ហោតិ ភិក្ខុ អរហំ ខីណាសវោ វុសិតវា[១] កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ សោ នេសំ អគ្គមក្ខាយតិ ធម្មេនេវ នោ អធម្មេន ។ ធម្មោ ហិ វាសេដ្ឋា សេដ្ឋោ ជនេតស្មឹ ទិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច ។ ព្រហ្មុនាបិ[២] វាសេដ្ឋា សនង្កុមារេន គាថា ភាសិតា

(៧២) ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តបដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេតិ ។

សាបិ ខោ[៣] បនេសា វាសេដ្ឋា ព្រហ្មុនា សនង្កុមារេន គាថា សុគីតា នោ ទុគ្គីតា សុភាសិតា នោ ទុព្ភាសិតា អត្ថសញ្ហិតា នោ អនត្ថសញ្ហិតា អនុមតា មយា ។

---

១ ឱ. វុសិតវាតិ ន. ទិស្សតិ ។ ២ ឱ. ព្រហ្មុនាបេសា ។ ៣ ឱ. ម. សា ហ ។

## អគ្គញ្ញសូត្រ គាថារបស់សនង្កុមារព្រហ្ម

(៧១) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ក៏បណ្តាវណ្ណៈទាំង ៤ នេះ វណ្ណៈណា ជាភិក្ខុ ជាអរហន្ត ជាខីណាស្រព ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួន ដោយលំដាប់ហើយ មានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹង ដោយប្រពៃ អ្នកនោះប្រាកដថាជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំង ៤ នោះ តាមធម៌ពិត មិនមែនមិនដោយធម៌ទេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថាធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន និងបរលោក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សូម្បីព្រហ្មឈ្មោះសនង្កុមារ ក៏បានពោលគាថាទុកថា

(៧២) ខត្តិយៈជាជាតិប្រសើរបំផុត ក្នុងប្រជុំជន ដែលជា
អ្នករឭកដល់គោត្រ អ្នកដែលបរិបូណ៌ ដោយវិជ្ជានិងចរណៈ
ប្រសើរបំផុត ក្នុងពួកទេវតានិងមនុស្ស ។

ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ឯគាថានេះឯង ព្រហ្មឈ្មោះសនង្កុមារ បានពោលពីរោះហើយ មិនមែនពោលមិនពីរោះទេ បានសំដែងល្អហើយ មិនមែនសំដែងមិនល្អទេ ជាគាថាប្រកបដោយប្រយោជន៍ មិនមែនជាមិនប្រកបដោយប្រយោជន៍ឡើយ តថាគតក៏យល់ព្រមតាមដែរ ។

អហម្បិ វាសេដ្ឋា ឯវំ វទាមិ

ខត្តិយោ សេដ្ឋោ ជនេតស្មឹ

យេ គោត្តបដិសារិនោ

វិជ្ជាចរណសម្បន្នោ

សោ[១] សេដ្ឋោ ទេវមានុសេតិ ។

ឥទមវោច ភគវា ។ អត្តមនា វាសេដ្ឋភារទ្វាជា ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

អគ្គញ្ញសុត្តំ ចតុត្ថំ[២] និដ្ឋិតំ ។

---

១ ឱ. សោតិ ន ទិស្សតិ ។ ២ ម. អគ្គញ្ញសុត្តន្តំ ចតុត្ថំ ។

ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ចំណែកខាងឥឡូវគឺបានពោលយ៉ាងនេះថា

ខត្តិយៈជាជាតិប្រសើរបំផុត ក្នុងប្រជុំជន ដែលជាអ្នករឭក

ដល់គោត្រ ដែលជាអ្នកបរិបូណ៌ដោយវិជ្ជានិងចរណៈប្រសើរ

បំផុត ក្នុងពួកទេវតានិងមនុស្ស ។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះ ចប់ហើយ ។

វាសេដ្ឋសាមណេរ និងភារទ្វាជសាមណេរ ក៏មានចិត្តត្រេកអររីករាយ

ចំពោះភាសិតរបស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

ចប់ អគ្គញ្ញសូត្រទី ៤ ។

# សម្បសាទនីយសុត្តំ បញ្ចមំ

(៧៣) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា
នាឡន្ទាយំ វិហរតិ បាវារិកម្ពវនេ ។ អថ ខោ
អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ
ឯតទវោច ឯវំ បសន្នោ អហំ ភន្តេ ភគវតិ ន
ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ
សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោ-
ភិញ្ញតរោ យទិទំ សម្ពោធិយន្តិ ។ ឧឡារា ខោ តេ
អយំ សារីបុត្ត អាសភិវាចា ភាសិតា ឯកំសោ

# សម្បសាទនីយសូត្រ ទី៥

(៧៣) ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងព្រៃស្វាយ របស់បាវារិកសេដ្ឋី[១] ទៀបក្រុងនាឡន្ទា ។ លំដាប់នោះឯង ព្រះសារីបុត្តដ៏មានអាយុ ចូលទៅគាល់ព្រះមានជោគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរស្រេចហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះមានព្រះភាគ យ៉ាងនេះថា សមណៈឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលុបជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខក៏មិនមាន ក្នុងកាលឥឡូវនេះ ក៏មិនមាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត អាសភិវាចា (វាចាដ៏អង់អាច) ដែលអ្នកបានពោលមកនេះ ខ្ពស់ពេកណាស់ អ្នកបានកាន់យកនូវសេចក្តី

---

១ អដ្ឋកថា ថា បានជាឈ្មោះថា បាវារិកសេដ្ឋី ព្រោះសេដ្ឋីនេះ ជាអ្នកលក់សំពត់ឈ្មោះបាវារៈ គឺសំពត់ដែលមានរោមញីកវែងហើយទន់ផង ។

គហិតោ សីហនាទោ នទិតោ ឯវំ បសន្នោ អហំ ភន្តេ ភគវតិ ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយន្តិ ។

(៧៤) កឹ នុ ខោ តេ(១) សារីបុត្ត យេ តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ ចេតសា ចេតោ បរិច្ច វិទិតា ឯវំសីលា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំធម្មា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំបញ្ញា តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំវិហារី តេ ភគវន្តោ អហេសុំ ឥតិបិ ឯវំវិមុត្តា តេ ភគវន្តោ អហេសុំ ឥតិបីតិ ។ នោ ហេតំ ភន្តេតិ(២) ។

---

១ កិន្នុតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ភន្តេ ។

ដាច់ស្រេច(១) ហើយ បានទាំងបន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជ្រះថ្លា ចំពោះព្រះមានព្រះភាគ យ៉ាងនេះថា សមណៈឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលុប ជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខ ក៏មិនមាន ទាំងក្នុងកាលឥឡូវនេះ ក៏មិនមាន ។

(៧៤) ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយ អ្នកបានកំណត់នូវព្រះហឫទ័យរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគទាំងអស់នោះ ដោយចិត្ត (របស់ខ្លួន) ថា ព្រះមានព្រះភាគទាំងនោះ មានសីលយ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះ មានធម៌យ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះ មានបញ្ញាយ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះ មានវិហារធម៌យ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះក្តី ដូច្នេះ ៗ ដែរឬ ។ ព្រះសារីបុត្រក្រាបបង្គំទូលថា ដំណើរនុ៎ះ មិនមែនដូច្នោះទេ ព្រះអង្គ ។

១ ចូលចិត្តស៊ប់ដោយប្រាជ្ញា មិនជឿតាមពាក្យដែលឮតាម ៗ គ្នាមក មិនជឿតាមពាក្យបរម្បរាគឺពាក្យដែលត ៗ មកតាមអាចារ្យ មិនជឿតាមពាក្យដែលឮគេថា មិនជឿដោយអាងក្បួនខុស មិនជឿតាមសេចក្តីត្រិវត្តង(?)អាការៈ មិនជឿតាមសេចក្តីចូលចិត្តដោយគំនិតដែលខ្លួនធ្លាប់យល់មិនជឿតាមហេតុដែលខ្លួនត្រិះរិះ មិនជឿតាមហេតុដែលប្រមាណយកនឹងខ្លួនឯង ។ អដ្ឋកថា ។ (មើលសេចក្តីពិស្តារក្នុងកាលាមសូត្រ របស់ព្រះមហាវិមលធម្ម ដែលបោះពុម្ពរួចហើយផងចុះ) ។

## សម្បសាទនីយសុត្តេ សារីបុត្តស្ស បុច្ឆំ

កឹ បន តេ សារីបុត្ត យេ តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ ចេតសា ចេតោ បរិច្ច វិទិតា ឯវំសីលា តេ ភគវន្តោ ភវិស្សន្តិ ឥតិបិ ឯវំធម្មា ។ ឯវំបញ្ញា ។ ឯវំវិហារី ។ ឯវំវិមុត្តា តេ ភគវន្តោ ភវិស្សន្តិ ឥតិបីតិ ។ នោ ហេតំ ភន្តេតិ(១) ។ កឹ បន តេ សារីបុត្ត អហំ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ ចេតសា ចេតោ បរិច្ច វិទិតោ ឯវំសីលោ ភគវា ឥតិបិ ឯវំធម្មោ ។ ឯវំបញ្ញោ ។ ឯវំវិហារី ។ ឯវំវិមុត្តោ ភគវា ឥតិបីតិ ។ នោ ហេតំ ភន្តេតិ ។ ឯត្ថ ហិ(២) តេ សារីបុត្ត អតីតានាគតបច្ចុប្បន្នេសុ អរហន្តេសុ សម្មាសម្ពុទ្ធេសុ ចេតោបរិយញាណំ នត្ថិ

---

១ ម. ភន្តេ ។ ២ ម. ឯត្ថ បរហិ ។

សម្បសាទនីយសូត្រ ការត្រាស់សួរចំពោះព្រះសារីបុត្រ

ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលនឹងមានក្នុងខាងមុខ អ្នកបានកំណត់នូវព្រះហឫទ័យរបស់ព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគទាំងអស់នោះ ដោយចិត្ត (របស់ខ្លួន) ថា ព្រះមានព្រះភាគទាំងនោះ នឹងមានសីលយ៉ាងនេះក្តី នឹងមានធម៌យ៉ាងនេះក្តី ដែរឬ ។ នឹងមានបញ្ញាយ៉ាងនេះ ។ នឹងមានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ នឹងមានវិមុត្តិយ៉ាងនេះ ដូច្នេះ ។ ដែរឬ ។ ព្រះសារីបុត្រក្រាបបង្គំទូលថា ដំណើរនុ៎ះ មិនមែនដូច្នោះទេ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ តថាគតដែលជាព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងកាលឥឡូវនេះ អ្នកបានកំណត់នូវចិត្តរបស់តថាគត ដោយចិត្ត (របស់ខ្លួន) ថា ព្រះមានព្រះភាគ មានសីលយ៉ាងនេះក្តី មានធម៌យ៉ាងនេះក្តី ។ មានបញ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគ មានវិមុត្តិយ៉ាងនេះ ដូច្នេះ ។ ដែរឬ ។ ព្រះសារីបុត្រក្រាបបង្គំទូលថា ដំណើរនុ៎ះ មិនមែនដូច្នោះទេ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ អ្នកមិនមានចេតោបរិយ-ញ្ញាណ គឺប្រាជ្ញាជាគ្រឿងកំណត់ដឹងនូវចិត្ត ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយនេះ ដែលជាអតីត អនាគត បច្ចុប្បន្នទេ កាលបើមិនមាន

អថ កិញ្ចរហិ តេ អយំ សារិបុត្ត ឧឡារា អាសភី វាចា ភាសិតា ឯកំសោ គហិតោ សីហនាទោ នទិតោ ឯវំ បសន្នោ អហំ ភន្តេ ភគវតិ ន ចាហុ ន ច ភវិស្សតិ ន ចេតរហិ វិជ្ជតិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយន្តិ ។ ន ខោ មេ តំ ភន្តេ[១] អតីតានាគតបច្ចុប្បន្នេសុ អរហន្តេសុ សម្មាសម្ពុទ្ធេសុ ចេតោបរិយញាណំ អត្ថិ អបិ ច មេ ធម្មន្វយោ[២] វិទិតោ សេយ្យថាបិ ភន្តេ រញ្ញោ បច្ចន្តិមំ នគរំ ទឡ្ហុទ្ទាបំ[៣] ទឡ្ហបាការតោរណំ ឯកទ្វារំ តត្រស្ស ទោវារិកោ បណ្ឌិតោ វិយត្តោ មេធាវី អញ្ញាតានំ និវារេតា ញាតានំ បវេសេតា សោ តស្ស នគរស្ស សាមន្តា អនុបរិយាយបថំ អនុក្កមមានោ[៤] ន បស្សេយ្យ បាការសន្ធិំ វា បាការវិវរំ វា អន្តមសោ វិឡារនិក្ខមនមត្តំបិ[៥]

---

១ ឱ. ន ខោ មេ ភន្តេ ។ ២ ឱ. អបិច មេ ភន្តេ ធម្មន្វយោ ។ ម. អបិច ខោ... ។ ៣ ឱ. ម. ទឡ្ហុទ្ទាបំ ។ ៤ ឱ. អនុក្កមន្តេ ។ ៥ ឱ. ពិឡាលនិស្សក្កនមត្តម្បិ ។ ម. ពិឡារនិក្ខមនមត្តំបិ ។

ញាណដូច្នេះ ហេតុអ្វីបានជាអ្នកនិយាយយ៉ាងនេះ ម្នាលសារីបុត្រ អ្នកបាននិយាយអាសភិវាចា ដែលអ្នកបានពោលមកនេះ ហួសពេកណាស់ អ្នកបានកាន់យកនូវសេចក្តីដាច់ស្រេច ហើយបានទាំងបន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគ យ៉ាងនេះថា សមណៈឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលុប ជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខ ក៏មិនមាន ក្នុងកាលឥឡូវនេះ ក៏មិនមាន ។ ព្រះសារីបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនមានចេតោបរិយញ្ញាណនេះ ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលជាអតីត អនាគត បច្ចុប្បន្នទេ ប៉ុន្តែខ្ញុំព្រះអង្គបានដឹងតាមទំនងធម៌ បពិត្រព្រះអង្គដ៏ចំរើន នគរបុង្ហែនរបស់ព្រះរាជា មានជើងបន្ទាយមាំ មានសសរក្លោងទ្វារកំពែងមាំ មានប្រកទ្វារតែមួយ អ្នករក្សាទ្វារនៃនគរនោះ ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា ហាមប្រាមនូវពួកមនុស្ស ដែលខ្លួនមិនធ្លាប់ស្គាល់ ( មិនឲ្យចូលទៅ ) បើកឲ្យតែពួកមនុស្ស ដែលខ្លួនធ្លាប់ស្គាល់ ឲ្យចូលទៅ អ្នករក្សាទ្វារនោះ កាលដើរត្រួតត្រាមើលផ្លូវកំពែងខាត់ខ្វែង ដោយជុំវិញនៃនគរនោះ ក៏មិនបានឃើញនូវទី-ត នៃកំពែង ឬចន្លោះនៃកំពែងឡើយ ដោយហោចទៅ សូម្បីគ្រាន់តែឆ្មាចេញរួច ( ក៏ពុំមាន )

តស្ស ធម្មស្ស យេ កេចិ(១) ឱឡារិកា បាណា ឥមំ នគរំ បវិសន្តិ វា និក្ខមន្តិ វា សព្វេ តេ ឥមិនា វ ទ្វារេន បវិសន្តិ វា និក្ខមន្តិ វាតិ ឯវមេវ ខោ មេ ភន្តេ ធម្មន្វយោ វិទិតោ យេ តេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិបដ្ឋានេសុ សុបតិដ្ឋិតចិត្តា សត្ត សម្ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈឹសុ យេបិ តេ ភន្តេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា សព្វេ តេ ភគវន្តោ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ ចតូសុ សតិបដ្ឋានេសុ សុបតិដ្ឋិតចិត្តា សត្ត សម្ពោជ្ឈង្គេ យថាភូតំ ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈិស្សន្តិ ភគវាបិ ភន្តេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ

---

១ ម. យេ តេ កេចិ ។

អ្នករក្សាទ្វារនោះ មានគំនិតយ៉ាងនេះថា ពួកសត្វដែលធំ ៗ ណាមួយ ចូលមកកាន់នគរនេះក្តី ចេញទៅវិញក្តី សត្វទាំងអស់នោះ រមែងចូល មកឬចេញទៅតាមទ្វារនេះប៉ុណ្ណោះ សេចក្តីនេះយ៉ាងណាមិញ បពិត្រ ព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានដឹងតាមទំនងធម៌ យ៉ាងនោះដែរ ថា ព្រះ អរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយ ព្រះអរហន្តសម្មា-សម្ពុទ្ធមានព្រះភាគទាំងនោះ ទ្រង់លះនូវនីវរណៈទាំង៥ ប្រការ ជាឧបក្កិ-លេសរបស់ចិត្ត ជាគ្រឿងធ្វើបញ្ញាឲ្យទុព្វលភាព មានព្រះហឫទ័យតាំង ខ្ជាប់ល្អ ក្នុងសតិប្បដ្ឋានទាំង ៤ បានចំរើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរ ដល់សេចក្តីពិត ក៏បានត្រាស់ដឹង នូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចំរើន ទោះបីព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលនឹង មានក្នុងអនាគតកាល ព្រះអរហន្តសម្មាសម្ពុទ្ធ មានព្រះភាគទាំងអស់នោះ ទ្រង់លះនូវនីវរណៈទាំង៥ ប្រការ ជាឧបក្កិលេសរបស់ចិត្ត ជាគ្រឿង ធ្វើបញ្ញាឲ្យទុព្វលភាព មានព្រះហឫទ័យតាំងខ្ជាប់ល្អ ក្នុងសតិប្បដ្ឋាន ទាំង ៤ បានចំរើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរដល់សេចក្តីពិត្រ នឹងបាន ត្រាស់ដឹង នូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចំរើន ទោះបីព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ក្នុងកាលឥឡូវនេះ

បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ
បញ្ញាយ ទុព្ពលីករណេ ចតូសុ សតិប្បដ្ឋានេសុ
សុប្បតិដ្ឋិតចិត្តា សត្ត សម្ពោជ្ឈង្គេ យថាភូតំ
ភាវេត្វា អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធា ។
ឥធាហំ ភន្តេ យេន ភគវា តេនុបសង្កមឹ ធម្មស្ស-
វណាយ ។ តស្ស ភន្តេ[១] ភគវា ធម្មំ ទេសេតិ
ឧត្តរុត្តរំ[២] បណីតបណីតំ កណ្ហសុក្កំ សប្បដិភា-
គំ[៣] ។ យថា យថា ភន្តេ[៤] ភគវា ធម្មំ ទេសេតិ
ឧត្តរុត្តរំ បណីតបណីតំ កណ្ហសុក្កំ សប្បដិភាគំ
តថា តថាហំ តស្មឹ ធម្មេ អភិញ្ញា ឥធេកច្ចំ
ធម្មំ ធម្មេសុ និដ្ឋមគមំ សត្ថរិ បសីទឹ សម្មា-
សម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ
សុប្បដិបន្នោ សង្ឃោតិ[៥] ។

---

១ ឱ. តស្ស មេ ភន្តេ ។ ២ ឱ. ឧត្តរុត្តរឹ ។ ៣ ឱ. ម. កណ្ហសុក្កសប្បដិភាគំ ។
៤ ឱ. ម យថា យថា មេ ភន្តេ ។ ៥ ម. សាវកសង្ឃោតិ ។

ទ្រង់លះនូវនីវរណៈទាំង ៥ ប្រការ ជាឧបក្កិលេសរបស់ចិត្ត ជាគ្រឿងធ្វើបញ្ញាឲ្យទុព្វលភាព មានព្រះហឫទ័យតាំងខ្ជាប់ល្អ ក្នុងសតិប្បដ្ឋានទាំង៤ បានចំរើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរដល់សេចក្តីពិត បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានចូលមកគាល់ព្រះមានព្រះភាគក្នុងទីនេះ ដើម្បីស្តាប់ធម៌ ។ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដ៏ប្រសើរថ្លៃថ្លា ព្រមទាំងគ្រឿងប្រៀបធៀប ទាំងចំណែកខ្មៅទាំងចំណែក-ស ដល់ខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដ៏ប្រសើរថ្លៃថ្លា ព្រមទាំងគ្រឿងប្រៀបធៀប ទាំងចំណែកខ្មៅទាំងចំណែក-ស ដោយប្រការយ៉ាងណា ៗ ខ្ញុំព្រះអង្គបានដឹងក្នុងធម៌នោះ បានចូលចិត្តធម៌ពួកខ្លះក្នុងធម៌ទាំងឡាយ ក៏ជ្រះថ្លាក្នុងព្រះសាស្តា ដោយប្រការយ៉ាងនោះៗ ថា ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងប្រពៃហើយ ព្រះធម៌ដែលព្រះមានព្រះភាគពោលទុកប្រពៃហើយ ព្រះសង្ឃលោកប្រតិបត្តិប្រពៃហើយដូច្នេះ ៗ

(៧៨) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ កុសលេសុ ធម្មេសុ តត្រិមេ កុស-លា ធម្មា សេយ្យថីទំ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥធ ភន្តេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោ-វិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯតទានុត្តរិយំ ភន្តេ កុសលេសុ ធម្មេសុ តំ ភគវា អសេសម-ភិជានាតិ តំ ភគវតោ អសេសមភិជានតោ ឧត្តរិ-អភិញ្ញេយ្យំ នត្ថិ យទភិជានំ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ អស្ស យទិទំ កុសលេសុ ធម្មេសុ ។

សម្បសាទនីយសូត្រ ពោធិបក្ខិយធម៌កិរិយាញុំាងបុគ្គលឲ្យស្គាល់ត្រូវអោយចេះ

(៧៨) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងកុសលធម៌ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង បណ្ដាធម៌ទាំងនោះ កុសលធម៌នោះតើដូចម្ដេច កុសលធម៌នោះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យច្បាស់នូវចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរក្នុងកុសលធម៌ទាំងឡាយ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវទេសនានោះឥតមានសល់ កាលព្រះមានព្រះភាគ ជ្រាបច្បាស់នូវទេសនានោះឥតមានសេសសល់ហើយ ក៏នឹងរកបុគ្គលដែលគួរដឹងច្បាស់ជាងព្រះអង្គនោះទៅទៀតគ្មាន សមណៈឬព្រាហ្មណ៍ឯទៀត កាលបើដឹង ក៏នឹងដឹងជាងព្រះមានព្រះភាគ ក្នុងកុសលធម៌ទាំងឡាយ មិនមានដែរ ។

(៧៦) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ អាយតនបណ្ណត្តីសុ ។ ឆយិមានិ ភន្តេ អជ្ឈត្តិកពាហិរានិ អាយតនានិ ចក្ខុញ្ចេវ រូបា(១) ច សោតញ្ច(២) សទ្ទា ច ឃានញ្ច(៣) គន្ធា ច ជិវ្ហា ច(៤) រសា ច កាយោ ច(៥) ផោដ្ឋព្វា ច មនោ ច(៦) ធម្មា ច ។ ឯតទានុត្តរិយំ ភន្តេ អាយតនបណ្ណត្តីសុ តំ ភគវា អសេសមភិជានាតិ តំ ភគវតោ អសេសមភិជានតោ ឧត្តរិអភិញ្ញេយ្យំ(៧) នត្ថិ យទភិជានំ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ អស្ស យទិទំ អាយតន-បណ្ណត្តីសុ ។

(៧៧) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ គព្ភាវក្កន្តីសុ ។ ចតស្សោ ឥមា ភន្តេ គព្ភាវក្កន្តិយោ ។ ឥធ បន ភន្តេ

---

១ ម. រូបានិ ។ ២ ឱ. សោតញ្ចេវ ។ ៣ ឱ. ឃានញ្ចេវ ។ ៤ ឱ. ជិវ្ហា ចេវ ។ ៥ ឱ. កាយោ ចេវ ។ ៦ ឱ. មនោ ចេវ ។ ៧ ឱ ឧត្តរឹ ។

(៧៦) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងអាយតនបណ្ណត្តិ គឺកិរិយាញ៉ាំងបុគ្គលឲ្យស្គាល់នូវអាយតនៈទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន អាយតនៈទាំងឡាយខាងក្នុង ៦ ខាងក្រៅ ៦ នេះ គឺចក្ខុ ១ រូប ១ សោតៈ ១ សទ្ទៈ ១ ឃានៈ ១ គន្ធៈ ១ ជិវ្ហា ១ រស ១ កាយ ១ ផោដ្ឋព្វៈ ១ មនោ ១ ធម្មៈ ១ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងអាយតនបណ្ណត្តិទាំងឡាយ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវទេសនានោះ ឥតមានសល់ កាលព្រះមានព្រះភាគ ជ្រាបច្បាស់នូវទេសនានោះ ឥតមានសេសសល់ហើយ នឹងរកបុគ្គលដែលគួរដឹងច្បាស់ ជាងព្រះអង្គទៅទៀតគ្មាន សមណៈឬព្រាហ្មណ៍ឯទៀត កាលបើដឹង ក៏នឹងដឹងឲ្យជាងព្រះមានព្រះភាគ ក្នុងអាយតនបណ្ណត្តិទាំងឡាយ ក៏មិនមានដែរ ។

(៧៧) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគទ្រង់សំដែងធម៌ ក្នុងដំណើរចុះកាន់គភ៌ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន ដំណើរចុះកាន់គភ៌ទាំងឡាយនេះ មាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន

## សម្បសាទនីយសុត្តេ ចតស្សោ គព្ភាវក្កន្តិយោ

ឯកច្ចោ អសម្បជានោ(១) មាតុ កុច្ឆឹ ឱក្កមតិ អសម្បជានោ មាតុ កុច្ឆិស្មឹ ឋាតិ អសម្បជានោ មាតុ កុច្ឆិម្ហា និក្ខមតិ អយំ បឋមា គព្ភាវក្កន្តិ ។ បុន ចបរំ ភន្តេ ឥធេកច្ចោ សម្បជានោ ហិ ខោ(២) មាតុ កុច្ឆឹ ឱក្កមតិ អសម្បជានោ មាតុ កុច្ឆិស្មឹ ឋាតិ អសម្បជានោ មាតុ កុច្ឆិម្ហា និក្ខមតិ អយំ ទុតិយា គព្ភាវក្កន្តិ ។ បុន ចបរំ ភន្តេ ឥធេកច្ចោ សម្បជានោ មាតុ កុច្ឆឹ ឱក្កមតិ សម្បជានោ មាតុ កុច្ឆិស្មឹ ឋាតិ អសម្បជានោ មាតុ កុច្ឆិម្ហា និក្ខមតិ អយំ តតិយា គព្ភាវក្កន្តិ ។ បុន ចបរំ ភន្តេ ឥធេកច្ចោ សម្បជានោ(៣) មាតុ កុច្ឆឹ ឱក្កមតិ សម្បជានោ មាតុ កុច្ឆិស្មឹ ឋាតិ សម្បជានោ មាតុ កុច្ឆិម្ហា និក្ខមតិ អយំ ចតុត្ថា(៤) គព្ភាវក្កន្តិ ។ ឯតទានុត្តរិយំ ភន្តេ គព្ភាវក្កន្តីសុ ។

---

១ ឱ. អសម្បជានោ បេរ ។ ២ ឱ. សម្បជានោបិ ខោ ។ ហិ ខោតិ ន ទិស្សតិ ។ ៣ ឱ. សម្បជានោ បេរ ។ ៤ ម. ចតុត្ថី ។

## សម្បសាទនីយសូត្រ ដំណើរចុះកាន់គភ៌មាន ៤ យ៉ាង

សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏មិនដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតា ក៏មិនដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏មិនដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ១ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន តែឋិតនៅក្នុងផ្ទៃមាតា ក៏លែងដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏លែងដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ២ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន លុះប្រសូតចេញចាកផ្ទៃមាតា ក៏លែងដឹងខ្លួនទៅវិញ នេះជាដំណើរចុះកាន់គភ៌ទី ៣ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតា ក៏ដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏ដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ៤ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរក្នុងដំណើរចុះកាន់គភ៌ទាំងឡាយ ។

(៧៨) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ អាទេសនវិធាសុ ។ ចតស្សោ ឥមា ភន្តេ អាទេសនវិធា ។ ឥធ ភន្តេ ឯកច្ចោ និមិត្តេន អាទិសតិ ឯវំបិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ សោ ពហុំ ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថាតិ(១) ។ អយំ បឋមា អាទេសនវិធា ។ បុន ចបរំ ភន្តេ ឥធេកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ អបិច ខោ មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ ឯវំបិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថាតិ(២) ។

---

១-២ ឱ. ម. អញ្ញថា ។

(៧៨) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខទៅមានតទៅទៀត ព្រះមានព្រះភាគទ្រង់សំដែងធម៌ ក្នុងអាទេសនវិធី គឺវិធីសម្រាប់ទាយទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន អាទេសនវិធីនេះមាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះក្នុងលោកនេះ តែងទាយតាមនិមិត្ត[១] ថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នក មានប្រការយ៉ាងនេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ទោះបីបុគ្គលនោះ ទាយច្រើនតទៅទៀត ចិត្តនោះក៏ដូច្នោះឯង មិនមែនជាយ៉ាងដទៃទេ ។ នេះចាត់ជាអាទេសនវិធីទី ១ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខទៅមានទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានទាយតាមនិមិត្តក៏ទេ គ្រាន់តែស្តាប់សំឡេងពួកមនុស្សនឹងអមនុស្ស ឬទេវតាទាំងឡាយ ហើយទើបទាយថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ទោះបីបុគ្គលនោះ ទាយច្រើនតទៅទៀត ចិត្តនោះក៏ដូច្នោះឯង មិនមែនទៅជាយ៉ាងដទៃវិញទេ ។ នេះចាត់

---

១ និមិត្តមាន ៣ ប្រការ គឺអាគតនិមិត្ត ទាយនិមិត្តដែលមកដល់ត្រូវតាមហេតុ ដែលខ្លួនធ្លាប់ចំណាំ ១ គតិនិមិត្ត ទាយនិមិត្តដែលបុគ្គលដទៃដើរជិតខ្លួន ១ ឋាននិមិត្ត ទាយនិមិត្តដែលបុគ្គលដទៃឈរជិតខ្លួន ១ ។ ដីកា ។

អយំ ទុតិយា អាទេសនវិធា ។ បុន ចបរំ ភន្តេ ឥធេកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ នាបិ(១) មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ អបិច ខោ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារសទ្ទំ សុត្វា អាទិសតិ ឯវំបិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថាតិ ។ អយំ តតិយា អាទេសនវិធា ។ បុន ចបរំ ភន្តេ ឥធេកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ នាបិ មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ នបិ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារសទ្ទំ សុត្វា អាទិសតិ អបិច ខោ វិតក្កវិចារសមាធិំ(២) សមាបន្នស្ស ចេតសា ចេតោ បរិច្ច បជានាតិ យថា ឥមស្ស ភោតោ មនោសង្ខារា បណិហិតា តថា ឥមស្ស ចិត្តស្ស

---

១ ឱ. នបិ ។ ២ ឱ. អបិ ច ខោ អវិតក្កំ អវិចារំ សមាធិំ ។ ម. អបិ ច ខោ វិតក្កវិចារសមាធិំ ។

ជាអាទេសនវិធី ទី ២ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខទៅមានទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានទាយតាមនិមិត្ត ទាំងមិនបានស្តាប់សំឡេងពួកមនុស្ស និងអមនុស្ស ឬទេវតាទាំងឡាយទេ ក៏ទាយត្រូវដែរ ប៉ុន្តែ លុះតែបានស្តាប់សំឡេង ដែលផ្សាយចេញអំពីសេចក្តីត្រិះរិះ របស់អ្នកដែលកំពុងនឹក កំពុងគិត ក៏ទាយថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ទោះបីបុគ្គលនោះ ទាយច្រើនទៅទៀត ចិត្តនោះក៏ដូច្នោះឯង មិនមែនជាយ៉ាងដទៃទេ ។ នេះចាត់ជាអាទេសនវិធី ទី ៣ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខទៅមានទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបានទាយតាមនិមិត្ត ទាំងមិនបានស្តាប់សំឡេងពួកមនុស្ស និងអមនុស្សឬទេវតាទាំងឡាយ ហើយទាយទេ និងថាបានស្តាប់សំឡេងដែលផ្សាយចេញអំពីសេចក្តីត្រិះរិះ របស់អ្នកដែលកំពុងនឹក កំពុងគិត ហើយទាយក៏ទេដែរ តែថា បុគ្គលនោះ កំណត់ដឹងនូវចិត្តរបស់អ្នកដែលចូលកាន់វិតក្កវិចារសមាធិ ដោយចិត្តរបស់ខ្លួនបានថា បុគ្គលដ៏ចំរើននេះ ដំកល់ទុកនូវមនោសង្ខារ ដោយប្រការណា ចិត្តរបស់បុគ្គលនេះ នឹង

អនន្តរា ឥមំ នាម(១) វិតក្កំ វិតក្កេស្សតីតិ ។ សោ ពហុម្បិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា-តិ ។ អយំ ភន្តេ ចតុត្ថា អាទេសនវិធា ។ ឯតទា-នុត្តរិយំ ភន្តេ អាទេសនវិធាសុ ។

(៧៩) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ ទស្សនសមាបត្តីសុ ។ ចតស្សោ ឥមា ភន្តេ ទស្សនសមាបត្តិយោ ។ ឥធ ភន្តេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋិ

---

១ ឱ. អមុំ នាម ។

ទឹកដល់វិតក្កៈឈ្មោះនេះមិនមានបន្ទោះ ទោះបីបុគ្គលនោះ ទាយច្រើនទៅទៀត ចិត្តនោះក៏ដូច្នោះឯង មិនមែនជាយ៉ាងដទៃទេ ។ បពិត្រព្រះអង្គដ៏ចំរើន នេះចាត់ជាអាទេសនវិធី ទី ៤ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងអាទេសនវិធីទាំងឡាយ ។

(៧៩) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត ព្រះមានព្រះភាគទ្រង់សំដែងធម៌ ក្នុងទស្សនសមាបត្តិ[១]ទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចំរើន ទស្សនសមាបត្តិទាំងនេះមាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន សមណៈឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងដុតកិលេស អាស្រ័យសេចក្តីព្យាយាមជាគ្រឿងដំកល់មាំ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យសេចក្តីមិនប្រមាទ អាស្រ័យសេចក្តីធ្វើទុកក្នុងចិត្តដោយប្រពៃ កាលបើចិត្តខ្ជាប់ខ្ជួនហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ ក៏ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាទជើងឡើងមក ខាងក្រោមតាំងពីចុងសក់ចុះទៅ មានស្បែករុំព័ទ្ធពីក្រៅ ដែលពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេង ៗ មាននៅក្នុងកាយនេះ គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង

១ អដ្ឋកថា ថា សំដៅយកបឋមជ្ឈានសមាបត្តិ ដែលព្រះយោគីធ្វើទុកក្នុងចិត្ត បំពោះអាការ ៣២ មានសក់ជាដើមឲ្យកើតឡើង ដោយបដិកូល ។

## សម្បសាទនីយសុត្តេ ចតស្សោ ទស្សនសមាបត្តិយោ

អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ អយំ បឋមា ទស្សនសមាបត្តិ ។ បុន ចបរំ ភន្តេ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរំ នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។ បេ ។ លសិកា មុត្តំ(១) អតិក្កម្ម ច បុរិសស្ស ឆវិមំសលោហិតំ អដ្ឋឹ បច្ចវេក្ខតិ អយំ ទុតិយា ទស្សនសមាបត្តិ ។ បុន ចបរំ ភន្តេ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរំ នានប្បការស្ស

---

១ ម. មុត្តន្តិ ទិស្សតិ ។

ខួរក្នុងឆ្អឹង ទាប បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ នេះជាទស្សនសមាបត្តិទី ១ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ។ បេ ។ កាលបើចិត្តខ្ជាប់ខ្ជួនហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងមក ខាងក្រោមតាំងពីចុងសក់ចុះទៅ មានស្បែករុំព័ទ្ធពីក្រៅ ដែលពេញដោយរបស់មិនស្អាតមានប្រការផ្សេង ៗ មាននៅក្នុងកាយនេះ គឺសក់ រោម ។ បេ ។ ទឹករំអិល ទឹកមូត្រ រហូតដល់ទៅពិចារណា នូវពណ៌សម្បុរ សាច់ ឈាម ឆ្អឹង របស់បុរស នេះជាទស្សនសមាបត្តិទី ២ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ បេ ។ កាលបើចិត្តខ្ជាប់ខ្ជួនហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាព យ៉ាងនោះ ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងមក ខាងក្រោមតាំងពីចុងសក់ចុះទៅ មានស្បែករុំព័ទ្ធពីក្រៅ ដែលពេញដោយរបស់មិនស្អាត មានប្រការផ្សេង ៗ មាននៅក្នុងកាយនេះ

អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។ បេ ។ លសិកា មុត្តំ អតិក្កម្ម ច បុរិសស្ស ឆវិមំសលោហិតំ អដ្ឋឹ បច្ចវេក្ខតិ បុរិសស្ស ច វិញ្ញាណសោតំ បជានាតិ ឧភយតោ អព្ពោច្ឆិន្នំ ឥធលោកេ បតិដ្ឋិតញ្ច បរលោកេ បតិដ្ឋិតញ្ច អយំ តតិយា ទស្សនសមាបត្តិ ។ បុន ចបរំ ភន្តេ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ ។ បេ ។ លសិកា មុត្តំ អតិក្កម្ម ច បុរិសស្ស ឆវិមំសលោហិតំ អដ្ឋឹ បច្ចវេក្ខតិ បុរិសស្ស ច វិញ្ញាណសោតំ បជានាតិ ឧភយតោ អព្ពោច្ឆិន្នំ ឥធលោកេ អប្បតិដ្ឋិតញ្ច បរលោកេ អប្បតិដ្ឋិតញ្ច អយំ ចតុត្ថា(១) ទស្សនសមាបត្តិ ។ ឯតទានុត្តរិយំ ភន្តេ ទស្សនសមាបត្តីសុ ។

---

១ ម. ចតុត្ថី ។

គឺសក់ រោម ។ បេ ។ ទឹករំអិល ទឹកមូត្រ រហូតដល់ទៅពិចារណាពណ៌សម្បុរ សាច់ ឈាម ឆ្អឹង របស់បុរស ទាំងដឹងច្បាស់នូវវិញ្ញាណសោតៈ(១)របស់បុរស ដែលមិនដាច់ចេញជាពីរចំណែក គឺតាំងនៅក្នុងលោកនេះ ១ ផ្នែក តាំងនៅក្នុងលោកខាងមុខ ១ ផ្នែក នេះជាទស្សនសមាបត្តិទី ៣ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត សមណៈព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។ បេ ។ ទឹករំអិល ទឹកមូត្រ រហូតដល់ទៅពិចារណាពណ៌សម្បុរ សាច់ ឈាម ឆ្អឹង របស់បុរស ទាំងដឹងច្បាស់នូវវិញ្ញាណសោតៈ របស់បុរស ដែលមិនដាច់ចេញ ជាពីរចំណែក គឺមិនតាំងនៅ ក្នុងលោកនេះ ១ ផ្នែក មិនតាំងនៅ ក្នុងលោកខាងមុខ ១ ផ្នែក នេះជាទស្សនសមាបត្តិទី ៤ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរក្រៃលែង ក្នុងទស្សនសមាបត្តិទាំងឡាយ ។

---

១ ដីកា ជាឈ្មោះរបស់វិញ្ញាណ តែបានជាឈ្មោះថា វិញ្ញាណសោតៈ ដូច្នេះ ព្រោះវិញ្ញាណនេះចេះតែប្រព្រឹត្តទៅមិនដាច់ដូចខ្សែទឹកហូរ គឺថាវិញ្ញាណនុ៎ះ លុះតែបានអនន្តរប្បច្ច័យ អំពីមុនហើយ ទើបឲ្យជាបច្ច័យដល់អនន្តរប្បច្ច័យ ដែលកើតខាងក្រោយទៀត ។

សម្បសាទនីយសុត្តេ សត្តបុគ្គលា

(៨០) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ បុគ្គលបណ្ណត្តីសុ (១) ។ សត្តិមេ ភន្តេ បុគ្គលា ឧភតោភាគវិមុត្តោ បញ្ញា-វិមុត្តោ កាយសក្ខិ ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ

---

១ ឱ. បុគ្គលបញ្ញត្តីសុ ។

## សម្បសាទនីយសូត្រ បុគ្គល ៧ ពួក

(៨០) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគទ្រង់សំដែងធម៌ ក្នុងបុគ្គលបញ្ញត្តិទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលទាំង ៧ ពួកនេះគឺ ឧភតោភាគវិមុត្តបុគ្គល គឺបុគ្គលដែលរួចចាកចំណែកទាំងពីរ[1] ១ បញ្ញាវិមុត្តបុគ្គល គឺបុគ្គលដែលរួចចាកអាសវៈដោយបញ្ញា[2] ១ កាយសក្ខិបុគ្គល គឺបុគ្គលដែលធ្វើឲ្យច្បាស់ នូវឈានផស្សៈ ដែលខ្លួនពាល់ត្រូវ[3] ១ ទិដ្ឋិប្បត្តបុគ្គល គឺបុគ្គលដែលដល់ នូវសេចក្តីឃើញច្បាស់[4] ១ សទ្ធាវិមុត្តបុគ្គល គឺបុគ្គលរួចចាកអាសវៈ ដោយសទ្ធា[5] ១

---

១ គឺរួចចាករូបកាយ ដោយអរូបសមាបត្តិ ១ រួចចាកនាមកាយដោយមគ្គ ១ សំដៅយកបុគ្គល ៥ ពួក គឺបុគ្គលដែលចេញចាកអរូបសមាបត្តិ ៤ អរូបសមាបត្តិមួយ ៗ ហើយពិចារណានូវសង្ខារទើបបានសម្រេចព្រះអរហត្ត ៤ ពួក អនាគាមិបុគ្គលដែលចេញចាកនិរោធ ហើយបានសម្រេចព្រះអរហត្ត ១ ពួក រួមត្រូវជា ៥ ពួក ។ ២ សំដៅយកបុគ្គល ៥ ពួក គឺ សុក្ខវិបស្សកបុគ្គល ១ ពួក បុគ្គលដែលចេញចាកឈានទាំង ៤ ហើយទើបបានសម្រេចអរហត្ត ៤ ពួក រួមត្រូវជា ៥ ពួក ។ បុគ្គលទាំងនេះ មិនបានពាល់ត្រូវវិមោក្ខ ៨ ទេ គ្រាន់តែឃើញដោយបញ្ញាប៉ុណ្ណោះ ហើយក៏អស់អាសវៈទៅ ។ ៣ បុគ្គលអ្នកបាននូវឈានផស្សៈមុនហើយទើបធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានជាខាងក្រោយ សំដៅយកបុគ្គល ៦ ពួក គឺរាប់ពីត្រឹមបុគ្គលដែលបានសម្រេចសោតាបត្តិផល រហូតដល់បុគ្គលដែលបានសម្រេចអរហត្តមគ្គ ។ ៤ សំដៅយកបុគ្គល ៦ ពួក ដូចគ្នានឹងកាយសក្ខិបុគ្គលដែរ ប៉ុន្តែបុគ្គលទាំងនេះបានដឹងច្បាស់នូវអរិយសច្ច ៤ ប្រការដោយបញ្ញារបស់ខ្លួន ។ ៥ បុគ្គលនេះបានដឹងច្បាស់នូវអរិយសច្ច ៤ ប្រការ ដូចគ្នានឹងទិដ្ឋិប្បត្តបុគ្គលដែរ ប្លែកតែសទ្ធាវិមុត្តបុគ្គលនេះ មានសេចក្តីជឿស៊ប់មិនកម្រើកក្នុងខណៈនៃមគ្គជាចំណែកខាងដើម ហើយទើបអស់កិលេស ឯទិដ្ឋិប្បត្តបុគ្គលនោះ មានបញ្ញាជាគ្រឿងកាត់កិលេសដ៏មុតក្លា ក្នុងខណៈនៃមគ្គជាចំណែកខាងដើម ។

ធម្មានុសារី សទ្ធានុសារី ។ ឯតទានុត្តរិយំ ភន្តេ បុគ្គលបណ្ណត្តីសុ (១) ។

(៨១) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ បធានេសុ ។ សត្តិមេ ភន្តេ ពោជ្ឈង្គា សតិសម្ពោជ្ឈង្គោ ធម្មវិចយសម្ពោជ្ឈង្គោ វីរិយសម្ពោជ្ឈង្គោ បីតិសម្ពោជ្ឈង្គោ បស្សទ្ធិសម្ពោជ្ឈង្គោ សមាធិសម្ពោជ្ឈង្គោ ឧបេក្ខាសម្ពោជ្ឈង្គោ ។ ឯតទានុត្តរិយំ ភន្តេ បធានេសុ ។

---

១ ឱ. បុគ្គលបញ្ញត្តីសុ ។

ធម្មានុសារីបុគ្គល គឺបុគ្គលដែលរលឹករឿយ ៗ នូវ (មគ្គដែលមានបញ្ញា[1] ជាប្រធាន) ១ សទ្ធានុសារីបុគ្គល គឺបុគ្គលដែលរលឹករឿយ ៗ នូវធម៌គឺបញ្ញាដោយសទ្ធា[2] ១ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរក្រៃលែងក្នុងបុគ្គលបញ្ញត្តិទាំងឡាយ ។

(៨១) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងបធានធម៌ គឺពោជ្ឈង្គទាំង ៧ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន ពោជ្ឈង្គនេះមាន ៧ យ៉ាងគឺ សតិសម្ពោជ្ឈង្គ ១ ធម្មវិចយ-សម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ[3] ១ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរក្រៃលែង ក្នុងបធានធម៌ទាំងឡាយ ។

---

១.២ សំដៅយកសោតាបត្តិមគ្គបុគ្គលតែមួយពួកប៉ុណ្ណោះ ។ តែសោតាបត្តិមគ្គបុគ្គលដែលផ្តងចិត្ត ដើម្បីឲ្យបានសម្រេចសោតាបត្តិផល ជាអ្នកមានបញ្ញិន្ទ្រិយដ៏ក្លៀវក្លា ដឹកនាំឲ្យចំរើននូវអរិយមគ្គដែលមានបញ្ញាជាទីតាំង ហៅថា ធម្មានុសារីបុគ្គល ។ សោតាបត្តិមគ្គបុគ្គលដែលផ្តងចិត្តដើម្បីឲ្យបានសម្រេចនូវសោតាបត្តិផល ជាអ្នកមានសទ្ធិន្ទ្រិយដ៏ក្លៀវក្លា ដឹកនាំឲ្យចំរើននូវអរិយមគ្គដែលមានសទ្ធាជាទីតាំង ហៅថា សទ្ធានុសារីបុគ្គល ។ អដ្ឋកថាព្រមទាំងដីកា ។ ៣ ចូរមើលនយលក្ខណៈ របស់ពោជ្ឈង្គទាំង ៧ នេះ ក្នុងមហាសតិប្បដ្ឋានសូត្រ ទីឃនិកាយ មហាវគ្គ ខាងដើមផងចុះ ។

(៨២) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ បដិបទាសុ ។ ចតស្សោ ឥមា ភន្តេ បដិបទា ទុក្ខា បដិបទា ទន្ធាភិញ្ញា ទុក្ខា បដិបទា ខិប្បាភិញ្ញា សុខា បដិបទា ទន្ធាភិញ្ញា សុខា បដិបទា ខិប្បាភិញ្ញាតិ តត្រ ភន្តេ យាយំ បដិបទា ទុក្ខា ទន្ធាភិញ្ញា អយំ បន ភន្តេ(១) បដិបទា ឧភយេនេវ ហីនា អក្ខាយតិ ទុក្ខត្តា ច ទន្ធត្តា ច ។ តត្រ ភន្តេ យាយំ បដិបទា ទុក្ខា ខិប្បាភិញ្ញា អយំ បន ភន្តេ(២) បដិបទា ទុក្ខត្តា ហីនា អក្ខាយតិ ។ តត្រ ភន្តេ យាយំ បដិបទា សុខា ទន្ធាភិញ្ញា អយំ បន ភន្តេ(៣) បដិបទា ទន្ធត្តា ហីនា អក្ខាយតិ ។ តត្រ ភន្តេ យាយំ បដិបទា សុខា ខិប្បាភិញ្ញា

---

១-២-៣ ឱ. ម. អយំ ភន្តេ ។

សម្បសាទនីយសូត្រ បដិបទា ៤ យ៉ាង

(៨២) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ គឺបដិបទាទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ៗ បពិត្រព្រះអង្គដ៏ចំរើន បដិបទានេះ មាន ៤ យ៉ាង គឺ ទុក្ខាបដិបទា ទន្ធាភិញ្ញា ១ ទុក្ខាបដិបទា ខិប្បាភិញ្ញា ១ សុខាបដិបទា ទន្ធាភិញ្ញា ១ សុខាបដិបទា ខិប្បាភិញ្ញា ១ បពិត្រព្រះអង្គដ៏ចំរើន បណ្ដាបដិបទាទាំង ៤ នោះ បដិបទាណា ប្រកបដោយសេចក្ដីលំបាក ត្រាស់ដឹងបានដោយយឺតយូរ បពិត្រព្រះអង្គដ៏ចំរើន បដិបទានេះឯង រមែងប្រាកដថា ថោកទាប ដោយចំណែកទាំងពីរ គឺប្រកបដោយសេចក្ដីលំបាកផង យឺតយូរផង ៗ បពិត្រព្រះអង្គដ៏ចំរើន បណ្ដាបដិបទាទាំងនោះ បដិបទាណា ប្រកបដោយសេចក្ដីលំបាក តែត្រាស់ដឹងបានដោយឆាប់ បពិត្រព្រះអង្គដ៏ចំរើន បដិបទានេះឯង រមែងប្រាកដថា ថោកទាប ព្រោះប្រកបដោយសេចក្ដីលំបាក ៗ បពិត្រព្រះអង្គដ៏ចំរើន បណ្ដាបដិបទាទាំងនោះ បដិបទាណា ប្រកបដោយសេចក្ដីងាយ តែត្រាស់ដឹងបានដោយយឺតយូរ បពិត្រព្រះអង្គដ៏ចំរើន បដិបទានេះឯង រមែងប្រាកដថា ថោកទាប ព្រោះត្រាស់ដឹងដោយយឺតយូរ ៗ បពិត្រព្រះអង្គដ៏ចំរើន បណ្ដាបដិបទាទាំងនោះ បដិបទាណា ប្រកបដោយសេចក្ដីងាយ ទាំងត្រាស់ដឹងបានដោយឆាប់

អយំ បន ភន្តេ(១) បដិបទា ឧភយេនេវ បណីតា អក្ខាយតិ សុខត្តា ច វិបុលត្តា ច ។ ឯតទានុត្តរិយំ ភន្តេ បដិបទាសុ ។

(៨៣) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ ភស្សសមាចារេ ។ ឥធ ភន្តេ ឯកច្ចោ ន ចេវ មុសាវាទុបសញ្ហិតំ វាចំ ភាសតិ ន ច វេភូតិយំ បេសុណិយំ(២) ន ច សារម្ភជំ ជយាបេក្ខោ(៣) មន្តាមន្តា ច(៤) វាចំ ភាសតិ និធានវតី កាលេន ។ ឯតទានុត្ត-រិយំ ភន្តេ ភស្សសមាចារេ ។

(៨៤) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ បុរិសសីលសមាចារេ ។ ឥធ ភន្តេ ឯកច្ចោ សច្ចោ ចស្ស សទ្ធោ ច ន ច

១ ឱ. ម. អយំ ភន្តេ ។ ២ ឱ. ន ច បេសុណិយំ ។ ៣ ម. ជយាបេក្ខា ។ ៤ ឱ. បាឋោ ន ទិស្សតិ ។

បពិត្រព្រះអង្គដ៏ចំរើន បដិបទានេះឯង រមែងប្រាកដថា ប្រសើរដោយចំណែកទាំង ២ គឺប្រកបដោយសេចក្តីងាយផង ទាំងត្រាស់ដឹងបានដោយឆាប់ផង ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនា ដ៏ប្រសើរក្នុងបដិបទាទាំងឡាយ ។

(៨៣) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងភស្សសមាចារ (កិរិយាប្រព្រឹត្តិល្អដោយវាចា) ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះក្នុងលោកនេះ មិននិយាយសំដីប្រកបដោយមុសាវាទផង មិននិយាយពាក្យញុះញង់ ដែលធ្វើគេឲ្យបែកបាក់ផ្សេងពីគ្នាផង មិននិយាយនូវពាក្យដែលកើត អំពីការប្រណាំងប្រជែងផង ជាអ្នកមិនប្រាថ្នាចង់ឈ្នះ ពិចារណាដោយបញ្ញា (ទើបពោលផង) និយាយនូវសំដី គួរឲ្យអ្នកផងយកទុក ក្នុងហឫទ័យ តាមកាលគួរផង ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងភស្សសមាចារ ។

(៨៤) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងបុរិសសីលសមាចារ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានសច្ចធម៌ផង មានសទ្ធាផង មិន

កុហកោ ន ច លបកោ ន ច នេមិត្តិកោ ន ច និប្បេសិកោ ន ច លាភេន លាភំ និជិគឹសនកោ[១] ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេសុ មត្តញ្ញូ[២] សមការី[៣] ជាគរិយានុយោគមនុយុត្តោ អតន្ទិតោ អារទ្ធវីរិយោ ឈាយី[៤] សតិមា កល្យាណបដិភាណោ គតិមា ធិតិមា មតិមា[៥] ន ច កាមេសុ គិទ្ធោ សតោ ច និបកោ ចរេ ។ ឯតទានុត្តរិយំ ភន្តេ បុរិសសីលសមាចារេ ។

(៨៥) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ អនុសាសនវិធាសុ ។ ចតស្សោ ឥមា ភន្តេ អនុសាសនវិធា ។ ជានាតិ ភន្តេ ភគវា បរំ បុគ្គលំ[៦] បច្ចត្តំ យោនិសោមនសិការា អយំ បុគ្គលោ យថានុសិដ្ឋំ តថាបដិបជ្ជមានោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ភវិស្សតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។

---

១ ឱ. និជិគឹសិតា ។ ២ ឱ. ម. ភោជនេ មត្តញ្ញូ ។ ៣ ម. សម្បជានការី ។ ៤ ឱ. ញាយី ។ ៥ ឱ. មុតិមា ។ ៦ ឱ. បរបុគ្គលំ ។

កុហកផង មិននិយាយរួសរាយ (ហួសហេតុ) ផង មិននិយាយបញ្ចិតបញ្ចៀងផង មិននិយាយគម្រាមគេផង មិននាំទៅនូវលាភ ដើម្បីលាភផង ជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជនទាំងឡាយ ប្រព្រឹត្តស្មើ ប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងភ្ញាក់រលឹក មិនខ្ជិលប្រអូស ប្រារព្ធសេចក្តីព្យាយាម មានឈាន មានសតិ មានបដិភាណដ៏ល្អ មានគតិគឺប្រាជ្ញា ជាគ្រឿងស្ទុះទៅ មានប្រាជ្ញាជាគ្រឿងទ្រទ្រង់ មានគំនិត ជាអ្នកមិនជាប់ជក់នៅ ក្នុងកាមទាំងឡាយផង មានសតិផង មានប្រាជ្ញាខ្ជាប់ខ្ជួនផង ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងបុរិសសីលសមាចារ ។

(៨៩) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងអនុសាសនវិធាទាំងឡាយ ដោយទេសនាណា ទេសនានុះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន អនុសាសនវិធានេះ មាន៤យ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុក ក្នុងព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះ កាលប្រតិបត្តិតាមគួរ ដល់ពាក្យប្រៀនប្រដៅ នឹងបានជាសោតាបន្នបុគ្គល ព្រោះអស់ទៅ នៃសំយោជនៈទាំងឡាយ ៣ ប្រការ មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងទាត់ មានកិរិយា

ជានាតិ ភន្តេ ភគវា បរំ បុគ្គលំ[១] បច្ចត្តំ យោនិ-
សោមនសិការា អយំ បុគ្គលោ យថានុសិដ្ឋំ តថា-
បដិបជ្ជមានោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគ-
ទោសមោហានំ តនុត្តា សកទាគាមី ភវិស្សតិ សកិ-
ទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតីតិ ។
ជានាតិ ភន្តេ ភគវា បរំ បុគ្គលំ[២] បច្ចត្តំ យោនិសោ-
មនសិការា អយំ បុគ្គលោ យថានុសិដ្ឋំ តថាបដិបជ្ជ-
មានោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា
ឱបបាតិកោ ភវិស្សតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ
តស្មា លោកាតិ ។ ជានាតិ ភន្តេ ភគវា បរំ បុគ្គលំ
បច្ចត្តំ យោនិសោមនសិការា អយំ បុគ្គលោ យថា-
នុសិដ្ឋំ តថាបដិបជ្ជមានោ អាសវានំ បរិក្ខយា អនា-
សវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ
អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ ។ ឯត-
ទានុត្តរិយំ ភន្តេ អនុសាសនវិធាសុ ។

---

១-២ ឱ. បរបុគ្គលំ ។

ត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុក ក្នុងព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះ កាលប្រតិបត្តិ តាមគួរដល់ពាក្យប្រៀនប្រដៅ នឹងបានជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសំយោជនៈទាំងឡាយ ៣ ប្រការ នឹងស្រាលស្តើងពាក រាគៈ ទោសៈ មោហៈ នឹងមកកាន់លោកនេះតែម្តងទៀត ទើបធ្វើនូវទីបំផុតទុក្ខបាន ១ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះ កាលប្រតិបត្តិតាមគួរដល់ពាក្យប្រៀនប្រដៅ នឹងបានជាឧបបាតិកៈ (ជាអនាគាមិបុគ្គល) ព្រោះអស់ទៅនៃសំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ប្រការ នឹងបរិនិព្វានក្នុងភពនោះ មិនត្រឡប់ពាកលោកនោះ ជាធម្មតា ១ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះ កាលប្រតិបត្តិតាមគួរដល់ពាក្យប្រៀនប្រដៅ នឹងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះ ក៏សម្រេចសម្រាន្តនៅ ដោយឥរិយាបថ ១ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងអនុសាសនវិធាទាំងឡាយ ។

(៨៦) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា
ភគវា ធម្មំ ទេសេតិ បរបុគ្គលវិមុត្តិញាណេ ។
ជានាតិ ភន្តេ ភគវា បរំ បុគ្គលំ បច្ចត្តំ យោនិ-
សោមនសិការា អយំ បុគ្គលោ តិណ្ណំ សញ្ញោ-
ជនានំ បរិក្ខយា សោតាបន្នោ ភវិស្សតិ អវិនិបាត-
ធម្មោ និយតោ សម្ពោធិបរាយនោតិ ។ ជានាតិ
ភន្តេ ភគវា បរំ បុគ្គលំ បច្ចត្តំ យោនិសោមនសិការា
អយំ បុគ្គលោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា
រាគទោសមោហានំ តនុត្តា សកទាគាមី សកិទេវ
ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សតីតិ ។
ជានាតិ ភន្តេ ភគវា បរំ បុគ្គលំ បច្ចត្តំ យោនិសោមន-
សិការា អយំ បុគ្គលោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោ-
ជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី
អនាវត្តិធម្មោ តស្មា លោកាតិ ។ ជានាតិ ភន្តេ
ភគវា បរំ បុគ្គលំ បច្ចត្តំ យោនិសោមនសិការា

## សម្បសាទនីយសូត្រ វិមុត្តិញ្ញាណរបស់បុគ្គលដទៃ

(៨៦) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងវិមុត្តិញ្ញាណ របស់បុគ្គលដទៃ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុក ក្នុងព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះ នឹងបានជាសោតាបន្នបុគ្គល ព្រោះអស់ទៅនៃសំយោជនៈទាំងឡាយ ៣ ប្រការ មានកិរិយាមិនធ្លាក់ចុះ ជាធម្មតា ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុក ក្នុងព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះជាសកទាគាមិ-បុគ្គល ព្រោះអស់ទៅនៃសំយោជនៈទាំងឡាយ ៣ ប្រការ ទាំងស្រាលស្តើងហកកពាគៈ ទោសៈ មោហៈ នឹងមកកាន់លោកនេះម្តងទៀត ទើបធ្វើនូវទីបំផុតទុក្ខបាន ១ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុក ក្នុងព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះ ជាឧបបាតិកៈ ( ជាអនាគាមិបុគ្គល ) ព្រោះអស់ទៅនៃសំយោជនៈទាំងឡាយ ជាចំណែកខាងក្រោម ៥ ប្រការ នឹងបរិនិព្វាន ក្នុងភពនោះ មិនត្រឡប់ចាកលោកនោះ ជាធម្មតា ១ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុក ក្នុង

អយំ បុគ្គលោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ ។ ឯតទានុត្តរិយំ ភន្តេ បរបុគ្គលវិមុត្តិញាណេ ។

(៨៧) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ សស្សតវាទេសុ ។ តយោមេ ភន្តេ សស្សតវាទា ។ ឥធ ភន្តេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធិំ ផុសតិ យថាសមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតិំ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តិំសំបិ ជាតិយោ ចត្តាឡីសំបិ(១) ជាតិយោ បញ្ញាសំបិ ជាតិយោ សតំបិ ជាតិំ សហស្សំបិ ជាតិំ សតសហស្សំបិ ជាតិំ(២)

---

១ ឱ. ចត្តារីសម្បិ ។ ២ ឱ. ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ ។ ម, ជាតិសតំ បិ.... ។

ព្រះហឫទ័យ ចំពោះព្រះអង្គថា បុគ្គលនេះ នឹងធ្វើឲ្យជាក់ច្បាស់នូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ ដោយឥរិយាបថ ១ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងវិមុត្តិ-ញាណរបស់បុគ្គលដទៃ ។

(៨៧) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងសស្សតវាទទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន សស្សតវាទនេះ មាន ៣ យ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ដុតកិលេស ។ បេ ។ កាលបើចិត្តតាំងនៅមាំហើយយ៉ាងណា ក៏បាននូវចេតោសមាធិមានសភាពយ៉ាងនោះ រលឹកជាតិដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើនជាតិ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ០០០ ជាតិខ្លះ ១០០.០០០ ជាតិខ្លះ

អនេកានិបិ ជាតិសតានិ អនេកានិបិ ជាតិសហស្សានិ អនេកានិបិ ជាតិសតសហស្សានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធុបបន្នោតិ(១) ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សោ ឯវមាហ អតីតំ ចាហំ(២) អទ្ធានំ ជានាមិ សំវដ្ដិ វា លោកោ វិវដ្ដិ វាតិ ។ អនាគតំ ចាហំ(៣) អទ្ធានំ ជានាមិ(៤) សំវដ្ដិស្សតិ វា លោកោ វិវដ្ដិស្សតិ វាតិ ។ សស្សតោ អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមន្តិ ។ អយំ បឋមោ សស្សតវាទោ ។

---

១ ខ ម ឥធូបបន្នោតិ ។ ២-៣ ខ. បហំ ។ ម. បាហំ ។ ៤ ខ. ន ជានាមិ សំវដ្ដិស្សតិ ។

ច្រើនជាង ១០០ ជាតិខ្លះ ច្រើនជាង ១ ០០០ ជាតិខ្លះ ច្រើនជាង ១០០ ០០០ ជាតិខ្លះ ដូច្នេះថា អាត្មាអញកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណោះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ៗ បុគ្គលនោះរមែងរលឹកនូវជាតិ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ បុគ្គលនោះនិយាយយ៉ាងនេះថា អាត្មាអញតែងដឹងនូវអតីតកាលថា លោកវិនាស ឬលោកចំរើន ដូច្នេះ ៗ អាត្មាអញតែងដឹងនូវអនាគតកាលថា លោកនឹងវិនាស ឬលោកនឹងចំរើនដូច្នេះ ៗ បុគ្គលនោះនិយាយថា ខ្លួននិងលោក ជាសភាពទៀងទាត់ ផុតពូជជារ ឋិតនៅដូចភ្នំ ឋិតនៅដូចសសរគោល ចំណែកសត្វទាំងឡាយនោះ តែងត្រាច់ទៅ អន្ទោលទៅ ច្យុតកើតមាននៅប្រាកដស្មើ ដូចសស្សតិវត្ថុ ៗ នេះជាសស្សតវាទទី ១ ៗ

បុន ចបរំ ភន្តេ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ សំវដ្ដវិវដ្ដំ ទ្វេបិ សំវដ្ដវិវដ្ដានិ តីណិបិ សំវដ្ដវិវដ្ដានិ ចត្តារិបិ សំវដ្ដវិវដ្ដានិ បញ្ចបិ សំវដ្ដវិវដ្ដានិ ទសបិ សំវដ្ដវិវដ្ដានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ។ បេ ។ ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សោ ឯវមាហ អតីតំ ខោ នាហំ(១) អទ្ធានំ ជានាមិ សំវដ្ដិ វា(២) លោកោ វិវដ្ដិ វាតិ(៣) ។

---

១ ឱ. ខោ អហំ ។ ២-៣ ឱ. បិ ។

បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខទៅមានទៀត សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ។ បេ ។ កាលបើចិត្តដំកល់មាំហើយយ៉ាងណា ក៏បាននូវចេតោសមាធិមានសភាពយ៉ាងនោះ រលឹកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ គឺរលឹកបាន ១ សំវដ្តកប្បនឹងវិវដ្តកប្ប (កប្បវិនាសនឹងកប្បចំរើន) ខ្លះ ២ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ៣ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ៤ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ៥ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ១០ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះថា អាត្មាអញ បានកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។ បេ ។ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញ លុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ។ បុគ្គលនោះ រមែងរលឹកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយបការដូច្នេះ បុគ្គលនោះ និយាយយ៉ាងនេះថា អាត្មាអញ តែងដឹងនូវអតីតកាលថា លោកវិនាស ឬលោកចំរើនដូច្នេះ ។

## សម្បសាទនីយសុត្តេ តយោ សស្សតវាទា

អនាគតញ្ច ខ្វាហំ(១) អន្តំ ជានាមិ សំវដ្ដិស្សតិ វា លោកោ វិវដ្ដិស្សតិ វាតិ ។ សស្សតោ អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមន្តិ ។ អយំ ទុតិយោ សស្សតវាទោ ។ បុន ចបរំ ភន្តេ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ទសបិ សំវដ្ដវិវដ្ដានិ វីសំបិ សំវដ្ដវិវដ្ដានិ តឹសំបិ សំវដ្ដវិវដ្ដានិ ចត្តាឡីសំបិ សំវដ្ដវិវដ្ដានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ។ បេ ។

១ ឱ អនាគតំ ច អហំ ។

បុគ្គលនោះ និយាយថា អាត្មាអញ តែងដឹងនូវអនាគតកាលថា លោកនឹងវិនាស ឬលោកនឹងចំរើនដូច្នេះ ។ បុគ្គលនោះ និយាយថា ខ្លួននឹងលោកជាសភាពទៀងទាត់ ផុតពូដផារ ឋិតនៅដូចភ្នំ ឋិតនៅដូចសសរគោល ចំណែកសត្វទាំងឡាយនោះ តែងត្រាច់ទៅ អន្ទោលទៅ ច្យុតកើត មាននៅប្រាកដស្មើ ដូចសស្សតវត្ថុ ។ នេះជាសស្សតវាទទី ២ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខនៅមានទៀត សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ។ បេ ។ កាលបើចិត្តដំកល់នៅមាំហើយយ៉ាងណា ក៏បាននូវចេតោ-សមាធិ មានសភាពយ៉ាងនោះ រលឹកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ គឺរលឹកបាន ១០ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ២០ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ៣០ សំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ៤០ សំវដ្ត-កប្បនឹងវិវដ្តកប្បខ្លះថា អាត្មាអញ បានកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញ មានឈ្មោះយ៉ាងនេះ ។ បេ ។

ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សោ ឯវមាហ អតីតំ ចាហំ(១) អទ្ធានំ ជានាមិ សំវដ្ដិបិ លោកោ វិវដ្ដិបីតិ(២) ។ អនាគតំ ចាហំ អទ្ធានំ ជានាមិ សំវដ្ដិស្សតិបិ លោកោ វិវដ្ដិស្សតិបីតិ(៣) ។ សស្សតោ អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមន្តិ ។ អយំ ភន្តេ(៤) តតិយោ សស្សតវាទោ ។ ឯតទានុត្តរិយំ ភន្តេ សស្សតវាទេសុ ។

(៨៨) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ បុព្វេនិវាសានុស្សតិញ្ញាណេ ។ ឥធ ភន្តេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា

---

១ ឱ. បហំ ។ ម. ចាហំ ។ ២ ឱ. វិវដ្ដិបិ លោកោតិ ។ ៣ ឱ. វិវដ្ដិស្សតិ បិ លោកោតិ ។ ៤ ឱ. ភន្តេតិ ន ទិស្សតិ ។

បុគ្គលនោះ រមែងរលឹកនូវជាតិ ដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុនបាន ច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ បុគ្គល នោះ និយាយយ៉ាងនេះថា អាត្មាអញតែងដឹងនូវអតីតកាលថា លោក វិនាសទៅខ្លះ ឬលោកចំរើនឡើងខ្លះដូច្នេះ ។ អាត្មាអញ តែងដឹងនូវអនាគតកាលថា លោកនឹងវិនាសទៅខ្លះ ឬលោកនឹងចំរើនឡើងខ្លះដូច្នេះ ។ បុគ្គលនោះ និយាយថា ខ្លួននឹងលោកជាសភាពទៀងទាត់ ផុតពូជធារ ឋិតនៅដូចកំពូល ឋិតនៅដូចសសរគោល ចំណែកសត្វទាំងឡាយនោះ តែងត្រាច់ទៅ តែងអន្ទោលទៅ ច្យុត កើត មាននៅប្រាកដស្មើ ដូចសស្សតិវត្ថុ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាសស្សតវាទទី ៣ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងសស្សតវាទទាំងឡាយ ។

(៨៨) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគសំដែងធម៌ ក្នុងបុព្វេនិវាសានុស្សតិញាណ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម

អាតប្បមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេ-និវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាលីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ សតំបិ ជាតឹ សហស្សំបិ ជាតឹ សត-សហស្សំបិ ជាតឹ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សន្តិ កត្ថ សត្តា[១] យេសំ ច[២] ន សក្កា គណនាយ វា សង្ខានេន វា អយំ សង្ខាតុំ[៣] អបិច យស្មឹ[៤] អត្តភាវេ អភិនិព្វត្តបុព្វោ[៥] ហោតិ យទិ វា រូបីសុ យទិ វា អរូបីសុ យទិ វា សញ្ញីសុ យទិ វា អសញ្ញីសុ យទិ វា នេវសញ្ញីនាសញ្ញីសុ

---

១ ឱ. ម. ទេវា ។ ២ ឱ. ម. ច ការោ ន ទិស្សតិ ។ ៣ ឱ. សង្ខាតោ វា អាយុំ សង្ខាតុំ ។
៤ ឱ. ម. យស្មឹ យស្មឹ ។ ៥ ឱ. អភិនិវុត្តបុព្វំ ។

ជាគ្រឿងដុតកិលេស ។បេ។ កាលបើ ចិត្តដំកល់នៅមាំហើយ យ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ រលឹកនូវជាតិដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើនជាតិ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១.០០០ ជាតិខ្លះ ១០០ ០០០ ជាតិខ្លះ រលឹកបានច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្ត-កប្បខ្លះ ច្រើនសំវដ្តកប្បនឹងវិវដ្តកប្បខ្លះ ។បេ។ បុគ្គលនោះ រមែងរលឹកនូវជាតិ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ឥតមានបុគ្គលណាមួយ អាចពប់អត្តភាពរបស់ពួកសត្វ ដែលធ្លាប់កើត ក្នុងរូបគត អរូបគត សញ្ញិគត អសញ្ញិគត នឹងនេវសញ្ញិនាសញ្ញិគត

ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ឯតទានុត្តរិយំ ភន្តេ បុព្វេនិវាសានុស្សតិញាណេ ។

(៨៩) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ សត្តានំ ចុតូបបាតញាណេ ។ ឥធ ភន្តេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ ។ បេ ។ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា

ដោយការរាប់បូកប្ចុកប់ដោយគំនិតបានឡើយ (បុគ្គលដែលបាននូវចេតោ-សមាធិនោះ) ទើបរលឹកនូវជាតិ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសបាន ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងបុព្វេ-និវាសានុស្សតិញ្ញាណ ។

(៨៩) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ក្នុងចុតូបបាតញាណ គឺញាណជាគ្រឿងដឹងនូវចុតិនឹងបដិសន្ធិ របស់សត្វទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចំរើន សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ។ បេ ។ កាលបើចិត្ត ដំកល់នៅមាំហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ ឃើញនូវសត្វទាំងឡាយដែលច្យុតនឹងចាប់បដិសន្ធិ ទាបថោកនឹងឧត្តម មានសណ្ឋានល្អនឹងអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធលើសលែងជាងចក្ខុ របស់មនុស្សសាមញ្ញ រមែងដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎សត្វទាំងនេះ ជាអ្នកប្រកបដោយកាយទុច្ចរិត

វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា(១) ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ ឯតទានុត្តរិយំ ភន្តេ សត្តានំ ចុតូបបាតញាណេ ។

(៩០) អបរំ បន ភន្តេ ឯតទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ ឥទ្ធិវិធាសុ ។ ទ្វេមា ភន្តេ

១ ឧ. ឧប្បន្នា ។

ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលនូវពួកព្រះអរិយ-បុគ្គល ប្រកាន់ខាងមិច្ឆាទិដ្ឋិ កាន់យកនូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏ទៅកើត ឯអបាយ ទុគ្គតិ វិនិបាត នរក ចំណែកខាងពួកសត្វទាំងនេះ ជាអ្នកប្រកបដោយ កាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះ ដៀលនូវពួកព្រះអរិយបុគ្គល ប្រកាន់ខាងសម្មាទិដ្ឋិ កាន់យកនូវកម្មជា សម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បុគ្គលនោះ រមែងឃើញនូវសត្វ ទាំងឡាយ ដែលច្យុតនឹងចាប់បដិសន្ធិ ទាបថោកនឹងឧត្តម មានសណ្ឋាន ល្អនឹងអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ លើសលែងជាងចក្ខុ របស់មនុស្សសាមញ្ញ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនា ដ៏ប្រសើរក្នុងចុតូបបាតញ្ញាណ របស់សត្វទាំងឡាយ ។

(៩០) បពិត្រព្រះអង្គដ៏ចំរើន ពាក្យខាងមុខ នៅមានតទៅទៀត ព្រះមានព្រះភាគ សំដែងនូវធម៌ ក្នុងឥទ្ធិវិធា (វិធីនៃឫទ្ធិ) ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គ

ឥទ្ធិវិធាយោ(១) ។ អត្ថិ ភន្តេ ឥទ្ធិ(២) សាសវា សឧបធិកា នោ អរិយាតិ វុច្ចតិ ។ អត្ថិ ភន្តេ ឥទ្ធិ(៣) អនាសវា អនុបធិកា អរិយាតិ វុច្ចតិ ។ កតមា ច ភន្តេ ឥទ្ធិ(៤) សាសវា សឧបធិកា នោ អរិយាតិ វុច្ចតិ ។ ឥធ ភន្តេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថាសមាហិតេ ចិត្តេ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បថវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ

---

១ ឱ. ឥទ្ធិយោ ។ ២-៣-៤ ឱ. ឥទ្ធិយា ។

ដ៏ចំរើន ឥទ្ធិវិធាមាន ២ យ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន ឫទ្ធិប្រកបដោយអាសវៈ[១] ប្រកបដោយឧបធិ[២] ព្រះអង្គមិនត្រាស់ហៅថា ឫទ្ធិរបស់ព្រះអរិយៈឡើយ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ឫទ្ធិមិនមានអាសវៈ មិនមានឧបធិ ទើបព្រះអង្គត្រាស់ហៅថា ឫទ្ធិរបស់ព្រះអរិយៈ ១ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះឫទ្ធិប្រកបដោយអាសវៈ ប្រកបដោយឧបធិ ដែលព្រះអង្គមិនត្រាស់ហៅថា ឫទ្ធិរបស់ព្រះអរិយៈនោះ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដំកល់មាំ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងប្រកបរឿយៗ អាស្រ័យសេចក្តីមិនប្រមាទ អាស្រ័យសេចក្តីធ្វើទុកក្នុងចិត្តដោយប្រពៃ កាលបើចិត្តដំកល់មាំហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ បាននូវឥទ្ធិវិធាច្រើនប្រការ មនុស្សតែម្នាក់ (និម្មិត) ទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ (និម្មិត) ទៅជាមនុស្សម្នាក់ក៏បាន ដើរ (ចេញពីខាងក្នុង) ទៅកាន់ទីវាល ទីខាងក្រៅក៏បាន ដើរទំលុះទៅខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំក៏បាន ឥតមានទើសទាល់ ដូចជាដើរទៅឯអាកាស មុជងើបក្នុងផែនដី ដូចជាមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹក

១ អដ្ឋកថា ថា ឫទ្ធិប្រកបដោយទោស (ប្រទូស្តអ្នកដទៃ) ។ ២ ឫទ្ធិប្រកបដោយការប្រណាំងប្រជែង (ប្រឡូងនឹងអ្នកដទៃ) ។

សេយ្យថាបិ បថវិយំ អាកាសេបិ បល្លង្កេន ចង្ក-មតិ(១) សេយ្យថាបិ បក្ខី(២) សកុណោ ។ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរាមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន សំវត្តេតិ(៣) ។ អយំ ភន្តេ ឥទ្ធិ(៤) សាសវា សឧបធិកា នោ អរិយាតិ វុច្ចតិ ។ កតមា ច ភន្តេ ឥទ្ធិ(៥) អនាសវា អនុបធិកា អរិយាតិ វុច្ចតិ ។ ឥធ ភន្តេ ភិក្ខុ សចេ អាកង្ខតិ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ

---

១ ឱ. ម. កមតិ ។ ២ ឱ. បក្ខិ ។ ៣ ឱ. ម. វសំវត្តេតិ ។ ៤-៥ ឱ. ឥទ្ធិយា ។

មិនបែកធ្លាយ ដូចជាដើរលើផែនដីក៏បាន ពែនភ្នែនចង្ក្រម ឯអាកាស ដូចសត្វបក្សីក៏បាន ។ ស្ទាបអង្អែល ចាប់ពាល់ព្រះចន្ទ្រនិងព្រះអាទិត្យនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយដៃខ្លួនឯងក៏បាន ញុំាងកាយឲ្យប្រព្រឹត្តទៅ រហូតដល់ព្រហ្មលោកក៏បាន ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាឫទ្ធិប្រកបដោយអាសវៈ ប្រកបដោយឧបធិ ដែលមិនហៅថា ឫទ្ធិរបស់ព្រះអរិយៈឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ចុះឫទ្ធិមិនមានអាសវៈ មិនមានឧបធិ ដែលហៅថា ឫទ្ធិរបស់ព្រះអរិយៈនោះ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន បើភិក្ខុក្នុងសាសនានេះ ប្រាថ្នាថា អាត្មាអញ គប្បីជាអ្នកសំគាល់ថា មិនជាបដិកូល ក្នុងរបស់ជាបដិកូល ដូច្នេះ រមែងជាអ្នកសំគាល់ថា មិនជាបដិកូល ក្នុងរបស់ជាបដិកូលនោះ បើភិក្ខុប្រាថ្នាថា អាត្មាអញ គប្បីជាអ្នកសំគាល់ថា ជាបដិកូលក្នុងរបស់មិនជាបដិកូលដូច្នេះ រមែងជាអ្នកសំគាល់ថាជាបដិកូល ក្នុងរបស់មិនជាបដិកូលនោះ បើភិក្ខុប្រាថ្នាថា អាត្មាអញ គប្បីជាអ្នកសំគាល់ថា មិនជាបដិកូលក្នុងរបស់ជាបដិកូល និងមិនជាបដិកូលដូច្នេះ រមែងជាអ្នកសំគាល់ថា មិនជាបដិកូល ក្នុងរបស់ជាបដិកូល និងមិនជាបដិកូលនោះ បើភិក្ខុ

បដិក្កូលេ ច អប្បដិក្កូលេ ច(១) បដិក្កូលសញ្ញី វិហា-
រេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ សចេ អាកង្ខតិ
បដិក្កូលញ្ច អប្បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា
ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ
ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ ។
អយំ បន ភន្តេ(២) ឥទ្ធិ អនាសវា អនុបធិកា
អរិយាតិ វុច្ចតិ ។ ឯតទានុត្តរិយំ ភន្តេ ឥទ្ធិ-
វិធាសុ ។ តំ ភគវា(៣) អសេសមភិជានាតិ តំ ភគវ-
តោ(៤) អសេសមភិជានតោ ឧត្តរិ(៥)អភិញ្ញេយ្យំ នត្ថិ
យទភិជានំ អញ្ញោ សមណោ វា ព្រាហ្មណោ វា
ភគវតា ភិយ្យោភិញ្ញតរោ នត្ថិ យទិទំ ឥទ្ធិវិធាសុ ។

(៩១) យម្បិ ភន្តេ សទ្ធេន កុលបុត្តេន បត្តព្វំ
អារទ្ធវីរិយេន ថាមវតា បុរិសត្ថាមេន បុរិសវីរិយេន

---

១ ឱ. អប្បដិក្កូលេ ច បដិក្កូលេ ច ។ ២ ឱ អយំ ភន្តេ ។ ៣ ឱ. តម្ភគវា ។
៤ ឱ. តម្ភគវតោ ។ ៥ ឱ. ឧត្តរឹ ។

ប្រាជ្ញាថា អាត្មាអញ គប្បីជាអ្នកសំគាល់ថាជាបដិកូល ក្នុងរបស់ជាបដិកូលនឹងមិនជាបដិកូល ដូច្នេះ រមែងជាអ្នកសំគាល់ថា ជាបដិកូល ក្នុងរបស់ជាបដិកូល នឹងមិនមែនជាបដិកូលនោះ បើភិក្ខុប្រាជ្ញាថា អាត្មាអញ គប្បីជាអ្នកមានសតិនឹងសម្បជញ្ញៈ វៀរនូវរបស់បដិកូលផង មិនមែនជារបស់បដិកូលផង ទាំង២យ៉ាងនោះចេញ ហើយជាអ្នកមានចិត្តព្រងើយ ដូច្នេះ រមែងជាអ្នកមានសតិនឹងសម្បជញ្ញៈ មានចិត្តនៅព្រងើយក្នុងរបស់ជាបដិកូល នឹងមិនមែនជារបស់បដិកូលនោះ ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯង ជាឫទ្ធិមិនមានអាសវៈ មិនមានឧបធិ ដែលហៅថា ជាឫទ្ធិរបស់ព្រះអរិយៈ ។ បពិត្រព្រះអង្គដ៏ចំរើន នេះជាទេសនាដ៏ប្រសើរ ក្នុងឥទ្ធិវិធាទាំងឡាយ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ នូវទេសនានោះឥតមានសេសសល់ កាលព្រះមានព្រះភាគ ជ្រាបច្បាស់នូវទេសនានោះឥតមានសល់ហើយ នឹងរកបុគ្គលដែលគួរដឹងច្បាស់ ជាងព្រះអង្គនោះទៅទៀតគ្មាន សមណៈឬព្រាហ្មណ៍ឯទៀត កាលបើដឹង ក៏នឹងដឹងជាងព្រះមានព្រះភាគ ក្នុងឥទ្ធិវិធាទាំងឡាយ មិនមានឡើយ ។

(៩១) បពិត្រព្រះអង្គដ៏ចំរើន អំពើណាដែលកុលបុត្រអ្នកមានសទ្ធា មានព្យាយាមមិនបន្ធូរបន្ថយ មានព្យាយាមខ្ជាប់ខ្ជួន គប្បីសម្រេចដោយព្យាយាមខ្ជាប់ខ្ជួនរបស់បុរស ដោយសេចក្ដីប្រឹងប្រែងរបស់បុរស ដោយ

បុរិសបរក្កមេន បុរិសធោរយ្ហេន អនុប្បត្តំ តំ ភគវតា ។ ន ច ភន្តេ ភគវា កាមេសុ កាមសុខលិកានុយោគមនុយុត្តោ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ ន ច អត្តកិលមថានុយោគមនុយុត្តោ ទុក្ខំ អនរិយំ អនត្ថសញ្ហិតំ ចតុន្នញ្ច(១) ភគវា ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី ។ សចេ មំ ភន្តេ ឯវំ បុច្ឆេយ្យ កិន្នុ ខោ អាវុសោ សារីបុត្ត អហេសុំ អតីតមទ្ធានំ អញ្ញេ សមណា វា ព្រាហ្មណា វា ភគវតា ភិយ្យោភិញ្ញតរោ(២) សម្ពោធិយន្តិ ។ ឯវំ បុដ្ឋាហំ ភន្តេ នោតិ វទេយ្យំ ។ កឹ បនាវុសោ សារីបុត្ត ភវិស្សន្តិ អនាគតមទ្ធានំ អញ្ញេ សមណា វា ព្រាហ្មណា វា ភគវតា ភិយ្យោភិញ្ញតរោ សម្ពោធិយន្តិ ។ ឯវំ បុដ្ឋាហំ ភន្តេ

១ ឱ. ចតុន្នំ ។ ២ ឱ. ម. ភិយ្យោភិញ្ញតរា ។

ការខ្វះខ្វែងរបស់បុរស ដោយកិរិយានាំទៅ នូវធុរៈរបស់បុរស អំពើនោះ ព្រះមានព្រះភាគ បានសម្រេចហើយដោយលំដាប់ ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ មិនបានប្រកបនូវកាមសុខល្លិកានុយោគ ក្នុងកាមទាំងឡាយដ៏ទាបថោក ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ផង មិនបានប្រកបនូវអត្តកិលមថានុយោគជាទុក្ខ មិនមែនជារបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ផង ព្រះមានព្រះភាគ ទ្រង់បានដូចសេចក្តីប្រាថ្នា បានដោយឥតលំបាក បានដោយធំទូលាយ នូវឈានទាំង ៤ ដ៏កន្លងបង់នូវកាមាវចរចិត្ត ជាសុខវិហារធម៌ ក្នុងបច្ចុប្បន្នផង ។ បពិត្រព្រះអង្គដ៏ចំរើន បើមានអ្នកផងសួរខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈឬព្រាហ្មណ៍ឯទៀត ដែលកន្លងហួសទៅហើយ ជាអ្នកមានញាណដ៏លើសលុបជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង មានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើមានអ្នកផងគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ។ បើគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈឬព្រាហ្មណ៍ឯទៀត ក្នុងកាលដែលមិនទាន់មានមក ជាអ្នកមានញាណដ៏លើសលុប ជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹងនឹងមានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើមានអ្នកផងគេសួរយ៉ាង

នោតិ វទេយ្យំ ។ កឹ បនាវុសោ សារីបុត្ត អត្ថេតរហិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា ភិយ្យោភិញ្ញតរោ សម្ពោធិយន្តិ ។ ឥតិ បុដ្ឋា អហំ ភន្តេ នោតិ វទេយ្យំ ។ សចេ បន មំ ភន្តេ ឯវំ បុច្ឆេយ្យ កឹ នុ ខោ អាវុសោ សារីបុត្ត អហេសុំ អតីតមទ្ធានំ អញ្ញេ សមណា វា ព្រាហ្មណា វា ភគវតា សមសមា សម្ពោធិយន្តិ ។ ឥតិ បុដ្ឋា អហំ ភន្តេ ឯវន្តិ វទេយ្យំ ។ កឹ បនាវុសោ សារីបុត្ត ភវិស្សន្តិ អនាគតមទ្ធានំ អញ្ញេ សមណា វា ព្រាហ្មណា វា ភគវតា សមសមា សម្ពោធិយន្តិ ។ ឥតិ បុដ្ឋា អហំ ភន្តេ ឯវន្តិ វទេយ្យំ ។ កឹ បនាវុសោ សារីបុត្ត អត្ថេតរហិ អញ្ញោ សមណោ វា ព្រាហ្មណោ វា ភគវតា

នេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ។ បើមានគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈឬព្រាហ្មណ៍ឯទៀត ក្នុងកាលឥឡូវនេះ ជាអ្នកមានញាណដ៏លើសលុប ជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹងមានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើមានអ្នកផងគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ។ បពិត្រព្រះអង្គដ៏ចំរើន បើមានអ្នកផងសួរខ្ញុំព្រះអង្គ យ៉ាងនេះថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈឬព្រាហ្មណ៍ឯទៀត ដែលកន្លងហួលទៅហើយ ជាអ្នកមានញាណស្មើ ៗ នឹងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹងមានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា បើយ៉ាងនោះ មានមែន ។ បើមានគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈឬព្រាហ្មណ៍ឯទៀត ដែលមិនទាន់មានមក ជាអ្នកមានញាណស្មើ ៗ នឹងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹងមានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា បើយ៉ាងនោះ មានមែន ។ បើមានគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈឬព្រាហ្មណ៍ឯទៀត ក្នុងកាលឥឡូវនេះ ជាអ្នកមានញាណ

សមសមា សម្ពោធិយន្តិ ។ ឯវំ បុដ្ឋា អហំ ភន្តេ នោតិ វទេយ្យំ ។ សចេ បន មំ ភន្តេ ឯវំ បុច្ឆេយ្យ កស្មា បនាយស្មា សារីបុត្តោ ឯកច្ចំ អព្ភនុជានាតិ ឯកច្ចំ ន អព្ភនុជានាតីតិ(១) ។ ឯវំ បុដ្ឋា អហំ ភន្តេ ឯវំ ព្យាករេយ្យំ សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា មយា សមសមា សម្ពោធិយន្តិ សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា មយា សមសមា សម្ពោធិយន្តិ សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ អដ្ឋានមេតំ អនវកាសោ យំ ឯកិស្សា លោកធាតុយា ទ្វេ អរហន្តោ សម្មាសម្ពុទ្ធា អបុព្វំ អចរិមំ ឧប្បជ្ជេយ្យុំ នេតំ ឋានំ វិជ្ជតីតិ ។

---

១ ឱ. នាព្ភនុជានាតីតិ ។

សម្បសាទនីយសូត្រ ព្រះសារីបុត្រសួរ ព្រះមានព្រះភាគទ្រង់ព្យាករ

ស្មើ ៗ នឹងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង មានដែរឬ ៗ បពិត្រព្រះអង្គដ៏ចំរើន កាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ៗ បពិត្រព្រះអង្គដ៏ចំរើន បើមានអ្នកផងសួរយ៉ាងនេះថា ព្រះសារីបុត្រមានអាយុ ព្រោះហេតុអ្វី បានជាដឹងខ្លះមិនដឹងខ្លះ ៗ បពិត្រព្រះអង្គដ៏ចំរើន កាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវព្យាករយ៉ាងនេះថា ម្នាលអ្នកមានអាយុ ពាក្យនេះអាត្មាបានស្តាប់ ចំពោះព្រះភក្ត្រ បានទទួល ចំពោះព្រះភក្ត្រព្រះមានព្រះភាគយ៉ាងនេះថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយក៏មានញាណស្មើ ៗ នឹងតថាគត ក្នុងការត្រាស់ដឹងដូច្នេះ ម្នាលអ្នកដ៏មានអាយុ ពាក្យនេះអាត្មាបានស្តាប់ ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះមានព្រះភាគ មកហើយថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ក្នុងកាលមិនទាន់មានមក នឹងមានញាណស្មើៗនឹងតថាគតក្នុងការត្រាស់ដឹងដូច្នេះ ម្នាលអ្នកដ៏មានអាយុ ពាក្យនេះ អាត្មាបានស្តាប់ចំពោះព្រះភក្ត្រ បានទទួល ចំពោះព្រះភក្ត្រព្រះមានព្រះភាគ យ៉ាងនេះថា មានព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ២ ព្រះអង្គ ត្រាស់ឡើងក្នុងលោកធាតុមួយ មិនមុនមិនក្រោយ (ជំណាលគ្នា) ដំណើរនេះ មិនមែនជាឋានៈ គឺមិនមានហេតុ ជាទំនងដូច្នោះទេ ៗ

[៩២] កិញ្ចាហំ(១) ភន្តេ ឯវំ បុដ្ឋោ ឯវំ ព្យាករមានោ វុត្តវាទី ចេវ(២) អហំ(៣) ភគវតោ ហោមិ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខាមិ ធម្មស្ស ចានុធម្មំ ព្យាករោមិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ(៤) អាគច្ឆតីតិ ។ តគ្ឃ ត្វំ សារីបុត្ត ឯវំ បុដ្ឋោ ឯវំ ព្យាករមានោ វុត្តវាទី ចេវ មេ(៥) ហោសិ ន ច មំ អភូតេន អព្ភាចិក្ខសិ ធម្មស្ស ចានុធម្មំ ព្យាករោសិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ អាគច្ឆតីតិ ។

[៩៣] ឯវំ វុត្តេ អាយស្មា ឧទាយិ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ តថាគតស្ស អប្បិច្ឆតា សន្តុដ្ឋិតា សល្លេខតា យត្រ ហិ នាម តថាគតោ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ អថ ច

១ ឱ. ម. កច្ចាហំ ។ ២ ម. ចេភ ។ ៣ ឱ. អហន្តិ ន ទិស្សតិ ។ ៤ ឱ. គារយ្ហំ ឋានំ ។ ៥ ឱ. មម ។

( ៩២ ) បពិត្រព្រះអង្គដ៏ចំរើន ចុះកាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គក៏ឆ្លើយតបទៅនឹងគេយ៉ាងនេះឈ្មោះថា និយាយទៅតាមព្រះពុទ្ធ-វចនៈរបស់ព្រះមានព្រះភាគ មិនបានពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិត ឆ្លើយនូវធម៌សមគួរតាមធម៌ ទាំងវាទានុវាទ (ការពោលតាមវាទៈ) ណាមួយ ដែលប្រកបដោយហេតុ ក៏ឈ្មោះថា មិនមកកាន់ទីដែលគួរតិះដៀលដែរឬ ។ ព្រះមានព្រះភាគត្រាស់ថា អើ សារីបុត្រ កាលបើមានអ្នកផងសួរយ៉ាងនេះ អ្នកក៏ឆ្លើយតបទៅនឹងគេយ៉ាងនេះឈ្មោះថា និយាយតាមពាក្យរបស់តថាគត មិនបាននិយាយបង្កាច់តថាគត ដោយពាក្យមិនពិត ឆ្លើយនូវធម៌សមគួរដល់ធម៌ហើយ ទាំងវាទានុវាទណាមួយ ដែលប្រកបដោយហេតុ ក៏ឈ្មោះថា មិនបានមកកាន់ទី គួរតិះដៀលឡើយ ។

( ៩៣ ) កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ទើបឧទាយីដ៏មានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះមិនដែលមានសោះ អម្បាលព្រះតថាគត មានបុទ្ធិច្រើនយ៉ាងនេះ មាន

បន នេវ អត្តានំ បាតុករិស្សតិ ឯកមេកញ្ចាបិ(១)
ឥតោ ភន្តេ ធម្មំ អញ្ញតិត្ថិយា បរិព្វាជកា អត្តនិ
សមនុបស្សេយ្យុំ តេ តាវតកេនេវ បដាកំ បរិហរេ-
យ្យុំ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ តថាគតស្ស
អប្បិច្ឆតា សន្តុដ្ឋិតា សល្លេខតា យត្រ ហិ នាម
តថាគតោ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ អថ ច
បន នេវ អត្តានំ(២) បាតុករិស្សតីតិ ។ បស្ស ខោ
ត្វំ ឧទាយិ តថាគតស្ស អប្បិច្ឆតា សន្តុដ្ឋិតា
សល្លេខតា យត្រ ហិ នាម តថាគតោ ឯវំមហិ-
ទ្ធិកោ ឯវំមហានុភាវោ អថ ច បន នេវ អត្តានំ(៣)
បាតុករិស្សតីតិ ឯកមេកញ្ចាបិ ឥតោ ឧទាយិ ធម្មំ
អញ្ញតិត្ថិយា បរិព្វាជកា អត្តនិ សមនុបស្សេយ្យុំ

---

១ ទី. ម, ឯកមេកញ្ចេបិ ។ ២-៣ ឱ. ន អត្តានំ ។ ម. នេវត្តានំ ។

អានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើព្រះអង្គឲ្យប្រាកដ(១) ព្រោះព្រះតថាគត ទ្រង់មិនមានសេចក្ដីប្រាថ្នា ទ្រង់សន្ដោស មានព្រះហឫទ័យផូរផង់ចាកកិលេស បពិត្រព្រះអង្គដ៏ចំរើន ពួកបរិព្វាជកជាអន្យតិរ្ថិយក្រៅចាកធម៌វិន័យនេះ (បើ) ពិចារណាឃើញធម៌មួយ ៗ ក្នុងខ្លួនហើយ ពួកបរិព្វាជកទាំងនោះនឹងលើកទង់ ដើរប្រកាសប្រាប់គ្នាដោយហេតុមានប្រមាណប៉ុណ្ណេះថា (រកអ្នកណាស្មើនឹងយើងបាន) បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះ មិនដែលមានសោះ អម្បាលព្រះតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើព្រះអង្គឲ្យប្រាកដ ព្រោះព្រះតថាគតទ្រង់មិនមានសេចក្ដីប្រាថ្នា ទ្រង់សន្ដោស មានព្រះហឫទ័យផូរផង់ចាកកិលេស ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយី អ្នកចូរមើលចុះ អម្បាលដូចតថាគតមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើខ្លួនឲ្យប្រាកដ ព្រោះតថាគតជាអ្នកមិនមានសេចក្ដីប្រាថ្នា ជាអ្នកសន្ដោស មានចិត្តផូរផង់ចាកកិលេស ម្នាលឧទាយី ពួកបរិព្វាជកជាអន្យតិរ្ថិយក្រៅ ចាកធម៌វិន័យនេះ បើពិចារណាឃើញធម៌មួយ ៗ ក្នុងខ្លួនហើយ

---

១ អដ្ឋកថា ថា ព្រះមានព្រះភាគមិនសំដែង នូវគុណរបស់ព្រះអង្គ គឺថា មិនអួតខ្លួន (ឲ្យអ្នកដទៃដឹងឡើយ) ។

តេ តាវតកោ ចេវ បជាតំ បរិហរេយ្យុំ បស្ស ខោ ត្វំ ឧទាយិ តថាគតស្ស អប្បិច្ឆតា សន្តុដ្ឋិតា សល្លេ-ខតា យត្រ ហិ នាម តថាគតោ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ អថ ច បន ន អត្តានំ បាតុក-រិស្សតីតិ ។ អថខោ ភគវា អាយស្មន្តំ សារីបុត្តំ អាមន្តេសិ យស្មាតិហ ត្វំ សារីបុត្ត ឥមំ ធម្មបរិ-យាយំ អភិក្ខណំ ភាសេយ្យាសិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ យេសំបិ ហិ សារីបុត្ត មោឃបុរិសានំ ភវិស្សតិ តថាគតេ កង្ខា វា វិមតិ វា តេសំបីមំ(១) ធម្មបរិយាយំ សុត្វា តថាគតេ កង្ខា វា វិមតិ វា សា បហីយិស្សតីតិ ។ ឥតិ ហិទំ អាយស្មា សារីបុត្តោ ភគវតោ សម្មុខា សម្បសាទំ បវេទេសិ ។ តស្មា ឥមស្ស វេយ្យាករណស្ស សម្បសាទនីយន្តេវ អធិវចនន្តិ ។

សម្បសាទនីយសុត្តំ បញ្ចមំ និដ្ឋិតំ(២) ។

---

១ ឱ. តេសម្បិ ឥមំ ។ ម. តេសមិមំ ។ ២ ឱ. សម្បសាទនីយសុត្តន្តំ បញ្ចមំ ។ ម. សម្បសាទនីយំ នាម សុត្តន្តំ បញ្ចមំ ។

ពួកបរិព្វាជកនោះ នឹងលើកទង់ដើរ ប្រកាសប្រាប់គ្នាដោយហេតុ មានប្រ-មាណប៉ុណ្ណោះថា (រកអ្នកណាស្មើនឹងយើងបាន) ម្នាលឧទាយី អ្នកចូរមើលចុះ អម្បាលតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើខ្លួនឲ្យប្រាកដ ព្រោះតថាគត ជាអ្នកមិនមានសេចក្តីប្រាថ្នា ជាអ្នកសន្តោស មានចិត្តផូរផង់ចាកកិលេស ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះសារីបុត្រ មានអាយុមកថា ម្នាលសារីបុត្រ ចូរអ្នកពោលធម្មបរិយាយនេះ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា រឿយៗ ចុះ ម្នាលសារីបុត្រ ព្រោះថា សេចក្តីសង្ស័យ ឬសេចក្តីងឿងឆ្ងល់ បំពោះតថាគត នឹងមានមកដល់មោឃបុរសពួកណា សេចក្តីសង្ស័យ ឬសេចក្តីងឿងឆ្ងល់របស់មោឃបុរសពួកនោះ បំពោះតថាគតនោះ នឹងសាបសូន្យ ទៅព្រោះបានស្តាប់ធម្មបរិយាយនេះ មិនខាន ។ ព្រះសារីបុត្រមានអាយុ ក៏សំដែងនូវអំណរនេះ បំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។ ព្រោះហេតុដូច្នោះ សូត្រនេះឈ្មោះថា សម្បសាទនីយសូត្រ ដោយវេយ្យាករណ៍នេះ ដូច្នេះឯង ។

ចប់ សម្បសាទនីយសូត្រ ទី ៥ ។

# បាសាទិកសុត្តំ ឆដ្ឋំ

[៩៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្យេសុ(១) វិហរតិ វេធញ្ញា នាម សក្យា តេសំ អម្ពវនេ បាសាទេ ។ តេន ខោ បន សមយេន និគណ្ឋោ នាដបុត្តោ បាវាយំ អធុនា កាលកតោ ហោតិ ។ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ទ្វេធិកជាតា ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ សហិតម្មេ អសហិតន្តេ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច អធិចិណ្ណន្តេ វិបរាវត្តំ អារោបិតោ តេ វាទោ និគ្គហិតោសិ ចរ វាទប្បមោក្ខាយ និព្វេឋេហិ វា សចេ បហោសីតិ ។ វធោយេវ ភោ(២) មញ្ញេ

១ ឱ. ម. សក្កេសុ ។ ២ ឱ. វធោយេវ ខោ ។ ម. វធោយេវោ ។

# បាសាទិកសូត្រ ទី ៦

(៩៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ នាអម្ពវ័នរបស់ពួកសក្យៈ ដែលមានឈ្មោះថា វេធញ្ញៈ (អ្នកហាត់បាញ់ធ្នូ) ក្នុងសក្កជនបទទាំងឡាយ ។ សម័យនោះឯង និគណ្ឋនាដបុត្រ ទើបតែធ្វើមរណកាលហើយថ្មី ៗ ក្នុងនគរបាវា ។ ព្រោះតែនិគណ្ឋនាដបុត្រនោះ ធ្វើមរណកាលទៅ ពួកនិគ្រន្ថកើតបែកគ្នាទៅជាពីរពួក កើតសេចក្តីប្រកួតប្រកាន់ កើតឈ្លោះប្រកែក ចាក់ដោតគ្នា ដោយលំពែងមាត់ថា អ្នកមិនចេះធម្មវិន័យនេះទេ ខ្ញុំទើបចេះធម្មវិន័យនេះ អ្នកនឹងចេះធម្មវិន័យនេះដូចម្តេចបាន អ្នកជាអ្នកប្រតិបត្តិខុសហើយ ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យរបស់ខ្ញុំ ប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នក មិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកនិយាយក្រោយ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកនិយាយមុន អ្នកបានសន្សំច្រើនតែវត្ថុដែលខុស ៗ ខ្ញុំលើកសេចក្តីខុសដាក់លើអ្នក អ្នកត្រូវខ្ញុំផ្ចាញ់ផ្ចាល់ហើយ ដើម្បីឲ្យផុតអំពីវាទៈរបស់សាស្តាដទៃ បើអ្នកអង់អាច ចូរដោះខ្លួនឲ្យរួចចុះ ។ ហាក់ដូចជាសេចក្តីស្លាប់តែម្យ៉ាង

និគណ្ឋេសុ នាដបុត្តិយេសុ អនុវត្តតិ ។ យេបិ និគណ្ឋស្ស នាដបុត្តស្ស សាវកា គិហី ឱទាតវសនា តេបិ និគណ្ឋេសុ នាដបុត្តិយេសុ និព្វិន្នរូបា វិរត្តរូបា បដិវានរូបា យថា តំ ទុរក្ខាតេ(១) ធម្មវិនយេ ទុប្បវេទិតេ អនិយ្យានិកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ភិន្នថូបេ អប្បដិសរណេ ។

(៩៨) អថខោ ចុន្ទោ សមណុទ្ទេសោ បាវាយំ វស្សំ វុត្ថោ យេន សាមគាមោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចុន្ទោ សមណុទ្ទេសោ អាយស្មន្តំ អានន្ទំ ឯតទវោច និគណ្ឋោ ភន្តេ នាដបុត្តោ បាវាយំ អធុនា កាលកតោ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ទ្វេធិកជាតា ។ បេ ។

---

១ ឱ. ទុរក្ខាតេ ។

ប្រព្រឹត្តទៅតាមពួកនិគ្រន្ថ ជាសិស្សរបស់នាដបុត្រ ។ ពួកគ្រហស្ថណា មានសម្លៀកបំពាក់ ដែលជាសាវ័ករបស់និគណ្ឋនាដបុត្រ ពួកគ្រហស្ថទាំងនោះ ជាអ្នកមានសេចក្ដីធុញទ្រាន់ ប្រាសចាកសេចក្ដីស្រឡាញ់ លែងគោរពក្នុងពួកនិគ្រន្ថ ដែលជាសិស្សរបស់នាដបុត្រ ព្រោះតែនិគណ្ឋ-នាដបុត្រ សំដែងនូវធម្មវិន័យមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម្មវិន័យដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ប្រកាសទុកហើយ ទាំងមានស្តូប គឺទីពំនាក់ បែកធ្លាយហើយ មិនមានទីពឹងឡើយ ។

(៩៨) លំដាប់នោះ សមណុទ្ទេស[១] ឈ្មោះចុន្ទ នៅចាំវស្សាក្នុងក្រុងបាវា បានចូលទៅរកព្រះអានន្ទមានអាយុ គង់នៅ នាសាមគ្រាម លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះចុន្ទសមណុទ្ទេស អង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយនឹងព្រះអានន្ទ មានអាយុ យ៉ាងនេះថា បពិត្រលោកដ៏ចំរើន និគណ្ឋ-នាដបុត្រ ទើបនឹងធ្វើមរណកាលហើយថ្មី ៗ ក្នុងក្រុងបាវា ព្រោះកាល-កិរិយានៃនិគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថបែកគ្នាទៅជាពីរពួក ។ បេ ។

---

១ អដ្ឋកថា ថា សមណុទ្ទេស ជាពាក្យហៅសាមណេរ ព្រះចុន្ទនោះលោកបានឧបសម្បទាហើយ តែគេនៅតែហៅលោកយ៉ាងនោះ ព្រោះធ្លាប់ហៅជាប់ពីសាមណេរមក ។

ភិន្នថូបេ អប្បដិសរណោតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ចុន្ទំ សមណុទ្ទេសំ ឯតទវោច អត្ថិ ខោ ឥទំ អាវុសោ ចុន្ទ កថាបាភតំ ភគវន្តំ ទស្សនាយ អាយាមាវុសោ ចុន្ទ យេន ភគវា តេនុបសង្កមិស្សាម ឧបសង្កមិត្វា ឯតមត្ថំ ភគវតោ អារោចេយ្យាមាតិ(១) ។ ឯវំ ភន្តេតិ ខោ ចុន្ទោ សមណុទ្ទេសោ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អថ ខោ អាយស្មា ច អានន្ទោ ចុន្ទោ ច សមណុទ្ទេសោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ ចុន្ទោ សមណុទ្ទេសោ ឯវមាហ និគណ្ឋោ ភន្តេ(២) នាដបុត្តោ បាវាយំ អធុនា កាលកតោ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ។ បេ ។ ភិន្នថូបេ អប្បដិសរណោតិ ។

---

១ ឱ អារោចេស្សាមាតិ ។ ២ ឱ. ភន្តេសទ្ទោ ន ទិស្សតិ ។

មានស្តូបគឺទីពំនាក់ បែកធ្លាយហើយ មិនមានទីពឹងឡើយ ។ កាលបើចុន្ទសមណុទ្ទេស និយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏និយាយនឹងចុន្ទសមណុទ្ទេស យ៉ាងនេះថា នែចុន្ទមានអាយុ ពាក្យមានមូលហេតុនេះ គួរក្រាបបង្គំទូល ដល់ព្រះមានព្រះភាគ នែចុន្ទដ៏មានអាយុ មកយើង នឹងទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ យើងត្រូវក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ចុន្ទសមណុទ្ទេស ក៏ទទួលស្តាប់ព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចំរើន យ៉ាងនោះមែនហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ នឹងចុន្ទសមណុទ្ទេស ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំនូវព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូល នូវព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ចុន្ទសមណុទ្ទេសនេះ និយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន និគណ្ឋនាដបុត្រ ទើបនឹងធ្វើមរណកាលហើយថ្មីៗ ក្នុងក្រុងបាវា ព្រោះកាលកិរិយានៃនិគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថបែកគ្នា ។ បេ ។ មានស្តូបគឺទីពំនាក់ បែកធ្លាយហើយ មិនមានទីពឹងឡើយ ។

[៩៦] ឯវញ្ចេតំ ចុន្ទ ហោតិ ទុរក្ខាតេ(១) ធម្មវិនយេ ទុប្បវេទិតេ អនិយ្យានិកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ។ ឥធ ចុន្ទ សត្ថា ច ហោតិ អសម្មាសម្ពុទ្ធោ ធម្មោ ច ទុរក្ខាតោ ទុប្បវេទិតោ អនិយ្យានិកោ អនុបសមសំវត្តនិកោ អសម្មាសម្ពុទ្ធប្បវេទិតោ សាវកោ ច តស្មឹ ធម្មេ ន ធម្មានុធម្មប្បដិបន្នោ វិហរតិ ន សាមីចិប្បដិបន្នោ ន អនុធម្មចារី វោក្កម្ម ច តម្ហា ធម្មា វត្តតិ សោ ឯវមស្ស វចនីយោ តស្ស តេ អាវុសោ លាភា តស្ស តេ សុលទ្ធំ សត្ថា ច តេ អសម្មាសម្ពុទ្ធោ ធម្មោ ច ទុរក្ខាតោ ទុប្បវេទិតោ អនិយ្យានិកោ អនុបសមសំវត្តនិកោ

១ ឱ. ទុរក្ខាតេ ។

(៩៦) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទ ការណ៍នុ៎ះ រមែងមានយ៉ាងហ្នឹងឯង ព្រោះតែបុគ្គលពោលនូវធម្មវិន័យមិនល្អ ប្រ-កាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម្មវិន័យដែលបុគ្គល មិនបានត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ប្រកាសទុកហើយ ។ ម្នាលចុន្ទ បើសាស្តាក្នុងលោកនេះ មិនមែនជាអ្នកត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ទាំងធម៌សោត ក៏សាស្តានោះសំដែងមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម្មវិន័យដែលបុគ្គល មិនបានត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ប្រកាសទុកហើយ តែសាវ័ក មិនមែនជាអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ មិនមែនជាអ្នកប្រតិបត្តិកោតក្រែង មិនមែនជាអ្នកប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ រមែងប្រព្រឹត្តគេចចេញ ចាកធម៌នោះថែមទៀត សាវ័កនោះ គួរគេសរសើរយ៉ាងនេះថា ម្នាលអាវុសោ ជាលាភរបស់អ្នកនោះហើយ អ្នកនោះឈ្មោះថា បានល្អហើយ ព្រោះសាស្តារបស់អ្នក មិនមែនជាអ្នកត្រាស់ដឹងខ្លួនឯង ដោយប្រពៃទេ ទាំងធម៌សោត ក៏សាស្តានោះ បានសំដែងមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គល

អសម្មាសម្ពុទ្ធប្បវេទិតោ តត្រ តស្មឹ ធម្មេ ន ធម្មា-
នុធម្មប្បដិបន្នោ វិហរតិ ន សាមីចិប្បដិបន្នោ ន
អនុធម្មចារី វោក្កម្ម ច តម្ហា ធម្មា វត្តតិ ។ ឥតិ
ខោ ចុន្ទ សត្ថាបិ តត្ថ គារយ្ហោ ធម្មោបិ តត្ថ គារយ្ហោ
សាវកោ ច តត្ថ ឯវំ បាសំសោ ។ យោ ខោ ចុន្ទ
ឯវរូបំ សាវកំ ឯវំ វទេយ្យ ឯតាយស្មា តថា បដិ-
បជ្ជតុ យថា តេ សត្ថារា ធម្មោ ទេសិតោ បញ្ញ-
ត្តោតិ ។ យោ ច សមាទបេតិ យញ្ច សមាទបេតិ
យោ ច សមាទបិតោ តថត្តាយ បដិបជ្ជតិ សព្វេ តេ
ពហុំ អបុញ្ញំ បសវន្តិ ។ តំ កិស្ស ហេតុ ។ ឯវញ្ហេតំ
ចុន្ទ ហោតិ ទុរក្ខាតេ ធម្មវិនយេ ទុប្បវេទិតេ អនិយ្យា-
និកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ។

មិនបានត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ប្រកាសទុកហើយ ទាំងអ្នកសោត ក៏មិនមែនជាអ្នកប្រតិបត្តិ នូវធម៌សមគួរតាមធម៌ មិនប្រតិបត្តិកោតក្រែង មិនប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ គឺប្រព្រឹត្តគេចចេញ ចាកធម៌នោះ ។ ម្នាលចុន្ទ សូម្បីសាស្តា ក៏គួរឲ្យអ្នកផងតិះដៀល ក្នុងហេតុនោះ ទាំងធម៌ក៏គួរឲ្យអ្នកផងតិះដៀល ក្នុងហេតុនោះ ដោយក្រការដូច្នេះឯង តែឯសាវ័កគួរគេសរសើរ ក្នុងហេតុនោះយ៉ាងនេះ ។ ម្នាលចុន្ទ អ្នកណាមួយនិយាយនឹងសាវ័ក មានសភាពដូច្នោះយ៉ាងនេះថា អ្នកមានអាយុចូលមក ចូរប្រតិបត្តិធម៌ ដែលសាស្តារបស់អ្នក បានសំដែងទុកហើយ បានបញ្ញត្តទុកហើយយ៉ាងនោះចុះ ។ បុគ្គលណាបបួលក្តី បបួលនូវបុគ្គលណាក្តី បុគ្គលណា ដែលគេបបួលហើយ ប្រតិបត្តិតាមដូច្នោះក្តី ពួកបុគ្គលទាំងអស់នោះ រមែងបាននូវបាបដ៏ច្រើន ។ ដំណើរនោះតើព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យដែលសាស្តាសំដែងមិនល្អហើយ ប្រកាសទុកមិនល្អហើយ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ប្រកាសទុកហើយ ។

[៩៧] ឥធ បន ចុន្ទ សត្ថា ច ហោតិ អសម្មា-
សម្ពុទ្ធោ ធម្មោ ច ទុរក្ខាតោ ទុប្បវេទិតោ អនិយ្យា-
និកោ អនុបសមសំវត្តនិកោ អសម្មាសម្ពុទ្ធប្បវេទិតោ
សាវកោ ច តស្មឹ ធម្មេ ធម្មានុធម្មប្បដិបន្នោ វិហរតិ
សាមីចិប្បដិបន្នោ អនុធម្មចារី សមាទាយ តំ ធម្មំ
វត្តតិ សោ ឯវមស្ស វចនីយោ តស្ស តេ អាវុសោ
អលាភា តស្ស តេ ទុល្លទ្ធំ សត្ថា ច តេ អសម្មា-
សម្ពុទ្ធោ ធម្មោ ច ទុរក្ខាតោ ទុប្បវេទិតោ អនិយ្យា-
និកោ អនុបសមសំវត្តនិកោ អសម្មាសម្ពុទ្ធប្បវេទិតោ
ត្វញ្ច តស្មឹ ធម្មេ ធម្មានុធម្មប្បដិបន្នោ វិហរសិ
សាមីចិប្បដិបន្នោ អនុធម្មចារី សមាទាយ តំ ធម្មំ
វត្តសីតិ ។ ឥតិ ខោ ចុន្ទ សត្ថាបិ តត្ថ គារយ្ហោ
ធម្មោបិ តត្ថ គារយ្ហោ សាវកោបិ តត្ថ ឯវំ គារយ្ហោ ។
យោ ខោ ចុន្ទ ឯវរូបំ សាវកំ ឯវំ វទេយ្យ អទ្ធាយស្មា

(៩៧) ម្នាលចុន្ទ មួយទៀត សាស្តាក្នុងលោកនេះ មិនមែនជាសម្មាសម្ពុទ្ធ ទាំងធម៌ក៏សាស្តានោះ សំដែងហើយមិនល្អ បានប្រកាសទុកហើយមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ប្រកាសទុកហើយ តែឯសាវ័កជាអ្នកប្រតិបត្តិធម៌ តាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តតាមធម៌ ក្នុងធម៌នោះ សមាទានប្រព្រឹត្តធម៌នោះ សាវ័កនោះ គួរគេនិយាយឲ្យយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាលាភរបស់អ្នកនោះទេ អ្នកនោះឈ្មោះថា បានអាក្រក់ហើយ ព្រោះតែសាស្តារបស់អ្នក មិនមែនជាអ្នកត្រាស់ដឹងឯងដោយប្រពៃទេ ទាំងធម៌សោត ក៏សាស្តានោះបានសំដែងហើយមិនល្អ បានប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ប្រកាសទុកហើយ ឯអ្នកក៏ជាអ្នកប្រតិបត្តិធម៌ តាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តតាមធម៌ ក្នុងធម៌នោះ សមាទានប្រព្រឹត្តតាមធម៌នោះ ៗ ម្នាលចុន្ទ ព្រោះហេតុនេះបានជាសាស្តា ក៏គួរគេតិះដៀលក្នុងហេតុនោះ ធម៌ក៏គួរគេតិះដៀលក្នុងហេតុនោះ សាវ័កក៏គួរគេតិះដៀលក្នុងហេតុនោះ យ៉ាងនេះ ៗ ម្នាលចុន្ទ បើអ្នកណាមួយ និយាយនឹងសាវ័កមានសភាពដូច្នោះ យ៉ាងនេះថា លោកមានអាយុ ជាអ្នកប្រតិបត្តិ

ញាយប្បដិបន្នោ ញាយំ អារាធេស្សតីតិ ។ យោ ច បសំសតិ យញ្ច បសំសតិ យោ ច បសំសិតោ(១) ភិយ្យោសោ មត្តាយ វីរិយំ អារភតិ សព្វេ តេ ពហុំ អបុញ្ញំ បសវន្តិ ។ តំ កិស្ស ហេតុ ។ ឯវំ ហេតំ ចុន្ទ ហោតិ ទុរក្ខាតេ ធម្មវិនយេ ទុប្បវេទិតេ អនិយ្យានិកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ។

(៩៨) ឥធ បន ចុន្ទ សត្ថា ច ហោតិ សម្មាសម្ពុទ្ធោ ធម្មោ ច ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ សាវកោ ច តស្មឹ ធម្មេ ន ធម្មានុធម្មប្បដិបន្នោ វិហរតិ ន សាមីចិប្បដិបន្នោ ន អនុធម្មចារី វោក្កម្ម ច តម្ហា ធម្មា វត្តតិ សោ ឯវមស្ស វចនីយោ តស្ស តេ អាវុសោ អលាភា តស្ស តេ ទុល្លទ្ធំ សត្ថា ចេ តេ សម្មាសម្ពុទ្ធោ ធម្មោ ច

១ ឱ. បសត្ថោ ។

ត្រូវហេតុហើយ មុខជាទីនាំសម្រេចហេតុមិនខាន ។ បុគ្គលណាសរសើរក្ដី សរសើរនូវបុគ្គលណាក្ដី អ្នកដែលគេសរសើរ ហើយប្រារព្ធព្យាយាមឲ្យលើសជាងប្រមាណក្ដី ពួកអ្នកទាំងអស់នោះ តែងបាននូវបាបដ៏ច្រើន ។ ដំណើរនុ៎ះ តើព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យ ដែលសាស្ដាសំដែងហើយមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គល មិនបានត្រាស់ដឹងខ្លួនឯង ប្រកាសទុកហើយ ។

(៩៨) ម្នាលចុន្ទ មួយទៀត សាស្ដាក្នុងលោកនេះ ជាអ្នកត្រាស់ដឹងឯងដោយប្រពៃផង ទាំងធម៌សោត ក៏សាស្ដានោះសំដែងទុកល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ប្រកាសទុកហើយ តែសាវ័កមិនមែនជាអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ មិនប្រតិបត្តិដោយគោរពក្រែង មិនប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ រមែងប្រព្រឹត្តគេចចេញចាកធម៌នោះថែមទៀត សាវ័កនោះ គួរគេនិយាយឲ្យយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាលាភរបស់អ្នកនោះទេ អ្នកនោះឈ្មោះថា បានអាក្រក់ហើយ ព្រោះសាស្ដារបស់អ្នក ជាសម្មាសម្ពុទ្ធស្រាប់ ទាំងធម៌ក៏សាស្ដានោះ

ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសម-
សំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ ត្វញ្ច តស្មិំ ធម្មេ
ច ធម្មានុធម្មប្បដិបន្នោ វិហរសិ ច សាមីចិប្បដិបន្នោ
ច អនុធម្មចារី រេក្កម្ម ព តម្ហា ធម្មា វត្តិស្សតិ ។
ឥតិ ខោ ចុន្ទ សត្ថាបិ តត្ថ បាសំសោ ធម្មោបិ តត្ថ
បាសំសោ សាវកោ ច តត្ថ ឯវំ គារយ្ហោ ។
យោ ខោ ចុន្ទ ឯវរូបំ សាវកំ ឯវំ វទេយ្យ
ឯតាយស្មា តថា បដិបជ្ជតុ យថា តេ សត្ថារា
ធម្មោ ទេសិតោ បញ្ញត្តោតិ ។ យោ ច សមាទ-
បេតិ យញ្ច សមាទបេតិ យោ ច សមាទបិតោ
តថត្តាយ បដិបជ្ជតិ សព្វេ តេ ពហុំ បុញ្ញំ
បសវន្តិ ។ តំ កិស្ស ហេតុ ។ ឯវំ ហេតំ ចុន្ទ
ហោតិ ស្វាក្ខាតេ ធម្មវិនយេ សុប្បវេទិតេ និយ្យា-
និកេ ឧបសមសំវត្តនិកេ សម្មាសម្ពុទ្ធប្បវេទិតេ ។

សំដែងទុកល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ ទាស់តែអ្នកមិនមែនជាអ្នកប្រតិបត្តិធម៌ សមគួរតាមធម៌ មិនប្រតិបត្តិកោតក្រែង មិនប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ ទៅជាប្រព្រឹត្តគេចចេញចាកធម៌នោះវិញ ។ ម្នាលចុន្ទ ព្រោះហេតុនេះ សាស្ដាក៏គួរគេសរសើរក្នុងហេតុនោះ ធម៌ក៏គួរគេសរសើរក្នុងហេតុនោះដោយប្រការដូច្នេះឯង ប៉ុន្តែឯសាវ័កគួរគេតិះដៀល ក្នុងហេតុនោះយ៉ាងនេះ ។ ម្នាលចុន្ទ បើអ្នកណាមួយនិយាយនឹងសាវ័ក មានសភាពដូច្នោះយ៉ាងនេះថា អ្នកដ៏មានអាយុចូលមក ចូរប្រតិបត្តិតាមធម៌ ដែលសាស្ដារបស់អ្នកសំដែងទុកហើយ បញ្ញត្តទុកហើយយ៉ាងនោះចុះ ។ បុគ្គលណាបបួលក្ដី បបួលនូវបុគ្គលណាក្ដី អ្នកដែលគេបបួលហើយ ប្រតិបត្តិតាមយ៉ាងនោះក្ដី ពួកអ្នកទាំងអស់នោះ រមែងបាននូវបុណ្យច្រើន ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យ ដែលសាស្ដាសំដែងល្អហើយ បានប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទុកហើយ ។

(៩៩) ឥធ បន ចុន្ទ សត្ថា ច ហោតិ សម្មាសម្ពុទ្ធោ ធម្មោ ច ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ សាវកោ ច តស្មឹ ធម្មេ ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី សមាទាយ តំ ធម្មំ វត្តតិ សោ ឯវមស្ស វចនីយោ តស្ស តេ អាវុសោ លាភា តស្ស តេ សុលទ្ធំ សត្ថា ច តេ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ ត្វញ្ច តស្មឹ ធម្មេ · ធម្មានុធម្មប្បដិបន្នោ វិហរសិ សាមីចិប្បដិបន្នោ អនុធម្មចារី សមាទាយ តំ ធម្មំ វត្តសីតិ ។ ឥតិ ខោ ចុន្ទ សត្ថាបិ តត្ថ បាសំសោ ។ ធម្មោបិ តត្ថ បាសំសោ សាវកោបិ តត្ថ ឯវំ បាសំសោ ។ យោ ខោ ចុន្ទ ឯវរូបំ សាវកំ ឯវំ វទេយ្យ អាយស្មា ញាយប្បដិបន្នោ ញាយំ

(៩៩) ម្នាលចុន្ទ មួយទៀត សាស្តាក្នុងលោកនេះ ក៏ជាសម្មាសម្ពុទ្ធ ទាំងធម៌ក៏សាស្តានោះសំដែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ ទាំងសាវ័កសោត ក៏ជាអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ សមាទានប្រព្រឹត្តតាមធម៌នោះ សាវ័កនោះ គួរគេនិយាយយ៉ាងនេះថា ម្នាលអាវុសោ ជាលាភល្អរបស់អ្នកនោះហើយ អ្នកនោះឈ្មោះថា បានល្អហើយ ព្រោះសាស្តារបស់អ្នកជាអ្នកឆ្ងាយចាកកិលេស ត្រាស់ដឹងឯងដោយប្រពៃ ទាំងធម៌ក៏សាស្តានោះបានសំដែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ អ្នកសោត ក៏ជាអ្នកប្រព្រឹត្តធម៌សមគួរតាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ សមាទានប្រព្រឹត្តតាមធម៌នោះ ។ ម្នាលចុន្ទ ព្រោះហេតុនេះ បានជាសាស្តាក៏គួរគេសរសើរ ក្នុងហេតុនោះ ធម៌ក៏គួរគេសរសើរ ក្នុងហេតុនោះ សាវ័កក៏គួរគេសរសើរ ក្នុងហេតុនោះយ៉ាងនេះ ។ ម្នាលចុន្ទ បើអ្នកណាមួយ និយាយនឹងសាវ័ក មានសភាពដូច្នោះ យ៉ាងនេះថា លោកមានអាយុ ជាអ្នកប្រតិបត្តិត្រូវហេតុហើយ មុខជានឹងសម្រេចហេតុ

អារាធេស្សតីតិ ។ យោ ច បសំសតិ យញ្ច បសំសតិ យោ ច បសន្នោ ភិយ្យោសោ មត្តាយ វីរិយំ អារភតិ សព្វេ តេ ពហុំ បុញ្ញំ បសវន្តិ ។ តំ កិស្ស ហេតុ ។ ឯវញ្ហេតំ ចុន្ទ ហោតិ ស្វាក្ខាតេ ធម្មវិនយេ សុប្បវេទិតេ និយ្យានិកេ ឧបសមសំវត្តនិកេ សម្មាសម្ពុទ្ធប្បវេទិតេ ។

(១០០) ឥធ ចុន្ទ សត្ថា ច លោកេ ឧទបាទិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ អវិញ្ញាបិតត្ថា ចស្ស ហោន្តិ សាវកា សទ្ធម្មេ នេសំ សត្ថុ ច នេសំ កេវលំ(១) បរិបូរំ ព្រហ្មចរិយំ អាវិកតំ ហោតិ ឧត្តានីកតំ សព្វសង្គហបទកតំ(២) សប្បាដិហីរកតំ(៣) យាវ ទេវមនុស្សេហិ សុប្បកាសិតំ អថ នេសំ សត្ថុនោ អន្តរធានំ ហោតិ ។ ឯវរូបោ ខោ ចុន្ទ សត្ថា ច(៤)

---

១ ឱ. សទ្ធម្មេ ន ច តេសំ កេវលំ ។ ម. សទ្ធម្មេ ន ច នេសំ កេវល . . . . . ។
២ សព្វសង្គហបទកតន្តិបិ បាឋោ ។ ឱ. សព្វសណង្គហបទកតំ ។ ៣ សប្បាដិហីរិកតន្តិបិ បាឋោ ។ ៤ ឱ. ម. ចការោ ន ទិស្សតិ ។

មិនខាន ។ បុគ្គលណាសរសើរក្តី សរសើរនូវបុគ្គលណាក្តី អ្នកដែលគេសរសើរហើយ ប្រារព្ធព្យាយាមយ៉ាងក្រៃលែង ជាងប្រមាណក្តី ពួកអ្នកទាំងអស់នោះ រមែងបាននូវបុណ្យច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យដែលសាស្តាសំដែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសទុកហើយ ។

(១០០) ម្នាលចុន្ទ ព្រះសាស្តាជាអរហន្តសម្មាសម្ពុទ្ធ កើតហើយក្នុងលោកនេះ ទាំងធម៌សោតក៏ព្រះសាស្តាសំដែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ តែពួកសាវ័ករបស់ព្រះសាស្តានោះ មិនទាន់យល់សេចក្តីច្បាស់ ក្នុងព្រះសទ្ធម្មឡើយ ទាំងព្រះសាស្តារបស់សាវ័កទាំងនោះ ក៏ពុំទាន់បានធ្វើឲ្យច្បាស់នូវព្រហ្មចរិយធម៌ឲ្យបរិបូណ៌ទាំងអស់ ពុំទាន់ធ្វើឲ្យងាយ ពុំទាន់ធ្វើដោយបទចង្រ្កងសព្វគ្រប់ ពុំទាន់ធ្វើឲ្យជាធម៌ល្មមដឹកនាំគ្នាបាន ដល់ពួកសាវ័កនោះ ដរាបតែពួកទេវតានឹងមនុស្សសំដែងបាន ដោយប្រពៃនៅឡើយ ហើយព្រះសាស្តារបស់សាវ័កទាំងនោះ បាត់ខ្លួនទៅ ។ ម្នាលចុន្ទ ព្រះសាស្តាមានសភាព

សាវកានំ កាលកតោ អនុតប្បោ ហោតិ ។ តំ កិស្ស ហេតុ ។ សត្ថា ហិ(១) លោកេ ឧទបាទិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ អវិញ្ញាបិតត្ថា ចម្ហា សទ្ធម្មេ ន ច នោ កេវលញ្ច(២) បរិបូរំ ព្រហ្មចរិយំ អាវិកតំ ហោតិ ឧត្តានីកតំ សព្វសង្គាហបទកតំ សប្បាដិហីរកតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ អថ នោ សត្ថុនោ អន្តរធានំ ហោតិ(៣) ។ ឯវរូបោ ខោ ចុន្ទ សត្ថា ច(៤) សាវកានំ កាលកតោ អនុតប្បោ ហោតិ ។

(១០១) ឥធ បន ចុន្ទ សត្ថា ច លោកេ ឧទបាទិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មា-

---

១ ឱ. ប នោ ។ ម. ប ។ ២ ឱ. បម្ហ សទ្ធម្មេ ន ប នោ កេវលំ ។ ម.... កេវល... ។ ៣ ឱ. ម. ហោតីតិ ។ ៤ ឱ. ម. ប កាលេ ន ទិស្សតិ ។

យ៉ាងនេះ ឈ្មោះថា ធ្វើមរណកាលឲ្យមានសេចក្តីក្តៅក្រហាយ ស្តាយក្រោយដល់ពួកសាវ័ក ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះ (ពួកសាវ័កនោះ មានសេចក្តីស្តាយក្រោយថា) ព្រះសាស្តាជាអរហន្តសម្មាសម្ពុទ្ធ បានកើតឡើងហើយក្នុងលោក ទាំងធម៌សោតក៏ព្រះសាស្តានោះ សំដែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ ប៉ុន្តែ ពួកយើងមិនទាន់យល់សេចក្តីច្បាស់ ក្នុងព្រះសទ្ធម្មឡើយ ទាំងព្រហ្មចរិយធម៌ដ៏បរិបូណ៌គ្រប់គ្រាន់ ក៏ព្រះសាស្តា មិនទាន់បានធ្វើឲ្យជាក់ច្បាស់ មិនទាន់ធ្វើឲ្យងាយ មិនទាន់បានធ្វើ ដោយបទបង្គ្រងសព្វគ្រប់ មិនទាន់បានធ្វើឲ្យជាធម៌ គួរដឹកនាំគ្នាបាន ដល់យើងទាំងឡាយ ដរាបតែពួកទេវតានិងមនុស្ស ក៏សំដែងបានដោយប្រពៃនៅឡើយ ព្រះសាស្តារបស់ពួកយើង បាត់បង់ទៅ ។ ម្នាលចុន្ទ ព្រះសាស្តាមានសភាពយ៉ាងនេះឯង ឈ្មោះថា ធ្វើមរណកាល ឲ្យមានសេចក្តីក្តៅក្រហាយ ស្តាយក្រោយដល់ពួកសាវ័ក ។

(១០១) ម្នាលចុន្ទ មួយទៀត ព្រះសាស្តាជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងក្នុងលោកនេះ ទាំងធម៌ក៏ព្រះសាស្តានោះ សំដែងល្អហើយ បានប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បី

សម្ពុទ្ធប្បវេទិតោ វិញ្ញាបិតត្ថា ចស្ស ហោន្តិ សាវកា សទ្ធម្មេ កោវិទា តេសំ បរិបូរំ ព្រហ្មចរិយំ អាវិកតំ ហោតិ ឧត្តានីកតំ សព្វសង្គហបទកតំ សប្បាដីហារិកតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ អថ នេសំ សត្ថុនោ អន្តរធានំ ហោតិ ។ ឯវរូបោ ខោ ចុន្ទ សត្ថា សាវកានំ កាលកតោ អននុតប្បោ ហោតិ ។ តំ កិស្ស ហេតុ ។ សត្ថាបិ លោកេ(១) ឧទបាទិ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំវត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ វិញ្ញាបិតត្ថា ចម្ហា សទ្ធម្មេ កោវិទា នោ បរិបូរំ ព្រហ្មចរិយំ អាវិកតំ ហោតិ ឧត្តានីកតំ សព្វសង្គហបទកតំ សប្បាដិហារិកតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ អថខោ សត្ថុនោ អន្តរធានំ ហោតិ ។

---

១ ឱ. ម. សត្ថា ច នោ លោកេ ។

សេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ បានប្រកាសទុកហើយ ទាំងពួកសាវ័ករបស់សាស្តានោះ បានយល់សេចក្តីច្បាស់ ក្នុងព្រះសទ្ធម្ម ហើយ ព្រះសាស្តាក៏បានធ្វើឲ្យជាក់ច្បាស់ នូវព្រហ្មចរិយធម៌ដ៏បរិបូណ៌ គ្រប់គ្រាន់ ធ្វើឲ្យងាយហើយ ធ្វើដោយបទចងក្រងសព្វគ្រប់ហើយ ធ្វើឲ្យជាធម៌គួរណែនាំគ្នាបានហើយ ដរាបតែពួកទេវតានឹងមនុស្ស ក៏សំដែងបានដោយប្រពៃ ទើបព្រះសាស្តារបស់សាវ័កទាំងនោះ អន្តរធានទៅ ។ ម្នាលចុន្ទ សាស្តាមានសភាពយ៉ាងនេះឯង ឈ្មោះថា ធ្វើមរណកាល មិនឲ្យមានសេចក្តីក្តៅក្រហាយស្តាយក្រោយ ដល់ពួកសាវ័ក ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា (ពួកសាវ័កទាំងនោះ មានសេចក្តីត្រេកអរយ៉ាងនេះថា) ព្រះសាស្តាជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោក ទាំងធម៌សោត ក៏ព្រះសាស្តាបានសំដែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ បានប្រកាសទុកហើយ ពួកយើងសោត ក៏បានយល់សេចក្តីច្បាស់ក្នុងព្រះសទ្ធម្មហើយ ព្រះសាស្តាបានធ្វើឲ្យច្បាស់នូវព្រហ្មចរិយធម៌ដ៏បរិបូណ៌ទាំងអស់ បានធ្វើឲ្យងាយហើយ បានធ្វើដោយបទចងក្រងសព្វគ្រប់ហើយ បានធ្វើឲ្យជាធម៌គួរណែនាំគ្នាបានហើយ ដរាបតែពួកទេវតានឹងមនុស្សក៏សំដែងបានដោយប្រពៃ ទើបព្រះសាស្តាបាត់បង់ទៅ ។

ឯវរូបោ ខោ ចុន្ទ សត្ថា សាវកានំ កាលកតោ អនានុតប្បោ ហោតីតិ(១) ។

(១០២) ឯតេហិ ចេបិ ចុន្ទ អង្គេហិ សមន្នាគតំ ព្រហ្មចរិយំ ហោតិ នោ ច ខោ សត្ថា(២) ហោតិ ថេរោ រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ ឯវន្តំ ព្រហ្មចរិយំ អបរិបូរំ ហោតិ តេនង្គេន ។ យតោ ខោ ចុន្ទ ឯតេហិ ចេបិ អង្គេហិ សមន្នាគតំ ព្រហ្មចរិយំ ហោតិ សត្ថា ច ហោតិ ថេរោ រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ ឯវន្តំ ព្រហ្មចរិយំ បរិបូរំ ហោតិ តេនង្គេន ។

(១០៣) ឯតេហិ ចេបិ ចុន្ទ អង្គេហិ សមន្នាគតំ ព្រហ្មចរិយំ ហោតិ សត្ថា ច ហោតិ ថេរោ រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ នោ ច ខ្វស្ស ថេរា ភិក្ខូ សាវកា ហោន្តិ វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា អលំ សមក្ខាតុំ សទ្ធម្មស្ស អលំ ឧប្បន្នំ បរប្បវាទំ

១ ឱ. ម. ហោតិ ។ ២ ម សត្ថា ប ។

ម្នាលចុន្ទ សាស្ដាមានសភាពយ៉ាងនេះឯង ឈ្មោះថា ធ្វើមរណកាល មិនឲ្យមានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ដល់ពួកសាវ័ក ។

(១០២) ម្នាលចុន្ទ ប្រសិនបើព្រហ្មចរិយធម៌ ប្រកបដោយអង្គទាំងនុ៎ះហើយ សាស្ដាមិនមែនជាថេរៈ ជាអ្នកដឹងរាត្រី ជាអ្នកបួសយូរ តាំងនៅជាអង្វែង ជាអ្នកចំរើនវ័យដោយលំដាប់ទេ ព្រហ្មចរិយធម៌នោះ ឈ្មោះថា មិនបរិបូណ៌ដោយអង្គនោះ យ៉ាងនេះឡើយ ។ ម្នាលចុន្ទ បើព្រហ្មចរិយ-ធម៌ប្រកបដោយអង្គទាំងនេះហើយ ទាំងសាស្ដាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអង្វែង ចំរើនវ័យដោយលំដាប់ ក្នុងកាលណាហើយ ព្រហ្មចរិយធម៌នោះ ទើបឈ្មោះថា បរិបូណ៌ដោយអង្គនោះ យ៉ាងនេះ ក្នុងកាលនោះ ។

(១០៣) ម្នាលចុន្ទ ប្រសិបើព្រហ្មចរិយធម៌ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្ដាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអង្វែង ចំរើនវ័យដោយលំដាប់ហើយ តែមិនមានពួកភិក្ខុជាសាវ័ក របស់សាស្ដានោះ ជាថេរៈ ជាអ្នកឈ្លាសវៃ ដឹកនាំ ក្សៀវក្លា បានដល់ធម៌ក្សេមចាកយោគៈ អាចនឹងប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទ ដែលកើត

សហធម្មេន(១) សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេតុំ ឯវន្តំ ព្រហ្មចរិយំ អបរិបូរំ ហោតិ តេនង្គេន ។ យតោ ច ខោ ចុន្ទ ឯតេហិ ចេបិ(២) អង្គេហិ សមន្នាគតំ ព្រហ្មចរិយំ ហោតិ សត្ថា ច ហោតិ ថេរោ រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ ថេរា ចស្ស ភិក្ខូ សាវកា ហោន្តិ វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា អលំ សមក្ខាតុំ សទ្ធម្មស្ស អលំ ឧប្បន្នំ បរប្បវាទំ សហធម្មេន(៣) សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេតុំ ឯវន្តំ ព្រហ្មចរិយំ បរិបូរំ ហោតិ តេនង្គេន ។

[១០៤] ឯតេហិ ចេបិ ចុន្ទ អង្គេហិ សមន្នាគតំ ព្រហ្មចរិយំ ហោតិ សត្ថា ច ហោតិ ថេរោ រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ ថេរា ចស្ស ភិក្ខូ សាវកា ហោន្តិ វិយត្តា វិនីតា វិសារទា ។ បេ ។ អលំ ឧប្បន្នំ បរប្បវាទំ

១ ម. សហធម្មេហិ ។ ២ ឱ. ចេវ ។ ៣ ម. សហធម្មេហិ ។

ឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយ ដោយពាក្យប្រកប ដោយធម៌ ហើយសំដែងធម៌ព្រមទាំងបាដិហារិយ៍ ព្រហ្មចរិយធម៌នោះ ឈ្មោះថា មិនបរិបូណ៌ដោយអង្គនោះយ៉ាងនេះ ។ ម្នាលចុន្ទ បើព្រហ្មចរិយធម៌ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអន្តែង បំរើនរ័យដោយលំដាប់ហើយ ទាំងពួកភិក្ខុជាសាវ័ករបស់សាស្តានោះ ក៏ជាថេរៈ ជាអ្នកឈ្លាសវៃ ដឹកនាំ ក្លៀវក្លា បានដល់ធម៌ក្សេមចាកយោគៈ អាចនឹងប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយប្រកបដោយធម៌ ហើយសំដែងធម៌ព្រមទាំងបាដិហារិយ៍ ក្នុងកាលណា ព្រហ្មចរិយធម៌នោះ ទើបឈ្មោះថា បរិបូណ៌ដោយអង្គនោះ យ៉ាងនេះ ក្នុងកាលនោះ ។

[១០៤] ម្នាលចុន្ទ ប្រសិនបើព្រហ្មចរិយធម៌ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអន្តែង បំរើនរ័យដោយលំដាប់ហើយ ទាំងពួកភិក្ខុជាសាវ័ករបស់សាស្តានោះក៏ជាថេរៈជាអ្នកឈ្លាសវៃដឹកនាំក្លៀវក្លា ។បេ។ អាចសង្កត់សង្កិននូវបរប្បវាទ

## បាសាទិកសុត្តេ សត្តមោ ថេររត្តញ្ញុតាទិកំ

សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេតុំ នោ ច ខ្វស្ស មជ្ឈិមា ភិក្ខូ សាវកា ហោន្តិ ។ មជ្ឈិមា ច ភិក្ខូ សាវកា ហោន្តិ ។ នោ ច ខ្វស្ស នវា ភិក្ខូ សាវកា ហោន្តិ ។ នវា ចស្ស ភិក្ខុនិយោ សាវិកា ហោន្តិ ។ នោ ច ខ្វស្ស ថេរា ភិក្ខុនិយោ សាវិកា ហោន្តិ ។ ថេរា ចស្ស ភិក្ខុនិយោ សាវិកា ហោន្តិ ។ នោ ច ខ្វស្ស មជ្ឈិមា ភិក្ខុនិយោ សាវិកា ហោន្តិ ។ មជ្ឈិមា ចស្ស ភិក្ខុនិយោ សាវិកា ហោន្តិ ។ នោ ច ខ្វស្ស នវា ភិក្ខុនិយោ សាវិកា ហោន្តិ ។ នវា ចស្ស ភិក្ខុនិយោ សាវិកា ហោន្តិ ។ នោ ច ខ្វស្ស ឧបាសកា សាវកា ហោន្តិ គិហី ឱទាតវសនា ព្រហ្មចារិនោ ។ ឧបាសកា ចស្ស សាវកា ហោន្តិ គិហី ឱទាតវសនា ព្រហ្មចរិនោ ។ នោ ច ខ្វស្ស ឧបាសកា សាវកា ហោន្តិ គិហី ឱទាតវសនា កាមភោគិនោ ។ ឧបាសកា ចស្ស សាវកា ហោន្តិ គិហី ឱទាតវសនា កាមភោគិនោ ។

ដែលកើតឡើងហើយ ជាពាក្យដែលខ្ជួនសង្កត់សង្កិន រៀបរយដោយធម៌ ហើយសំដែងធម៌ ព្រមទាំងបាដិហារិយ៍បាន តែពួកភិក្ខុជាន់កណ្តាល ជាសាវ័ករបស់សាស្តានោះ មិនមាន ។ បើមានតែពួកភិក្ខុជាន់កណ្តាល ជាសាវ័ក ។ តែសាស្តានោះ មិនមានពួកភិក្ខុខ្ចីជាសាវ័ក ។ សាស្តានោះ មានតែពួកភិក្ខុនីខ្ចីជាសាវិកា ។ តែសាស្តានោះ មិនមានពួកភិក្ខុនីចាស់ជាសាវិកា ។ សាស្តានោះ មានតែពួកភិក្ខុនីចាស់ ជាសាវិកា ។ តែសាស្តានោះ មិនមានពួកភិក្ខុនីជាន់កណ្តាល ជាសាវិកា ។ សាស្តានោះ មានតែពួកភិក្ខុនីជាន់កណ្តាល ជាសាវិកា ។ តែសាស្តានោះ មិនមានពួកភិក្ខុនីខ្ចី ជាសាវិកា ។ សាស្តានោះ មានតែពួកភិក្ខុនីខ្ចី ជាសាវិកា ។ តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសក មានសម្លៀកបម្ពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ជាសាវ័ក ។ បើសាស្តានោះ មានតែពួកគ្រហស្ថឧបាសក មានសម្លៀកបម្ពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ជាសាវ័ក ។ តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសក មានសម្លៀកបម្ពាក់ស ជាអ្នកបរិភោគកាម ជាសាវ័ក ។ បើសាស្តានោះ មានតែពួកគ្រហស្ថឧបាសក មានសម្លៀកបម្ពាក់ស បរិភោគកាម ជាសាវ័ក ។

នោ ច ខ្វស្ស ឧបាសិកា សាវិកា ហោន្តិ គិហិនី[១] ឱទាតវសនា ព្រហ្មចារិនិយោ ។ ឧបាសិកា ចស្ស សាវិកា ហោន្តិ គិហិនី[២] ឱទាតវសនា ព្រហ្មចារិនិយោ ។ នោ ច ខ្វស្ស ឧបាសិកា សាវិកា ហោន្តិ គិហិនី[៣] ឱទាតវសនា កាមភោគិនិយោ ។ ឧបាសិកា ចស្ស សាវិកា ហោន្តិ គិហិនី[៤] ឱទាតវសនា កាមភោគិនិយោ ។ នោ ច ខ្វស្ស ព្រហ្មចរិយំ ហោតិ ឥទ្ធញ្ចេវ[៥] ផីតញ្ច វិត្ថារិកំ ពហុជញ្ញំ[៦] បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ ព្រហ្មចរិយញ្ចស្ស[៧] ហោតិ ឥទ្ធញ្ច ផីតញ្ច វិត្ថារិកំ ពហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ ។ នោ ច ខោ លាភគ្គយសគ្គប្បត្តំ ឯវន្តំ ព្រហ្មចរិយំ អបរិបូរំ ហោតិ តេនង្គេន ។

---

១-២-៣-៤ ឱ. ម. គិហិនិយោ ។ ៥ ឱ. ឥទ្ធញ្ចេវ ហោតិ ។ ៦ ឱ. ម. ពាហុជញ្ញំ ។ ៧ ឱ. ព្រហ្មចរិយំ ចស្ស ។

តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសិកា មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ជាសាវិកា ។ បើសាស្តានោះ បានតែពួកគ្រហស្ថឧបាសិកា បានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ជាសាវិកា ។ តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសិកា មានសម្លៀកបំពាក់ស បរិភោគកាម ជាសាវិកា ។ បើសាស្តានោះ មានតែពួកគ្រហស្ថឧបាសិកា មានសម្លៀកបំពាក់ស បរិភោគកាម ជាសាវិកា ។ តែព្រហ្មចរិយធម៌របស់សាស្តានោះ មិនមាំមួនផ្សាយទូលាយទៅ ឥតមានគេចេះដឹងច្រើនក្រាស់ក្រែល ដរាបតែពួកទេវតានឹងមនុស្ស សំដែងដោយប្រពៃមិនបាន បើទុកជាព្រហ្មចារ្យរបស់សាស្តានោះ មាំមួនផ្សាយទូលាយទៅ មានគេចេះដឹងច្រើនក្រាស់ក្រែល ដរាបតែពួកទេវតានឹងមនុស្ស សំដែងបានដោយប្រពៃ តែមិនបានដល់នូវលាភដ៏ប្រសើរ នឹងយសដ៏ប្រសើរ កាលបើដូច្នេះ ព្រហ្មចារ្យនោះ ឈ្មោះថា មិនបរិបូណ៌ដោយអង្គនោះទេ ។

### បាសាទិកសុត្តេ សត្ថុនោ ថេររត្តញ្ញុតាទិកំ

យតោ ច ខោ ចុន្ទ ឯតេហិ ចេវ(១) អង្គេហិ សមន្នាគតំ ព្រហ្មចរិយំ ហោតិ សត្ថា ច ហោតិ ថេរោ រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ ថេរា ចស្ស ភិក្ខូ សាវកា ហោន្តិ វិយត្តា វិនីតា វិសារទា ។ បេ ។ សប្បាដិហារិយំ ធម្មំ ទេសេតុំ ។ មជ្ឈិមា ចស្ស ភិក្ខូ សាវកា ហោន្តិ ។ នវា ចស្ស ភិក្ខូ សាវកា ហោន្តិ ។ ថេរា ចស្ស ភិក្ខុនិយោ សាវិកា ហោន្តិ ។ មជ្ឈិមា ចស្ស ភិក្ខុនិយោ សាវិកា ហោន្តិ ។ នវា ចស្ស ភិក្ខុនិយោ សាវិកា ហោន្តិ ។ ឧបាសកា ចស្ស សាវកា ហោន្តិ គិហី ឱទាតវសនា ព្រហ្មចារិនោ ។ ឧបាសកា ចស្ស សាវកា ហោន្តិ គិហី ឱទាតវសនា កាមភោគិនោ ។ ឧបាសិកា ចស្ស សាវិកា ហោន្តិ គិហិនី(២) ឱទាតវសនា ព្រហ្មចារិនិយោ ។ ឧបាសិកា ចស្ស សាវិកា ហោន្តិ គិហិនី(៣) ឱទាតវសនា កាមភោគិនិយោ ។ ព្រហ្មចរិយញ្ចស្ស ហោតិ ឥទ្ធញ្ចេវ ផីតញ្ច វិត្ថារិកំ

---

១ ម. ចេវ ។ ២-៣ ឱ. ម. គិហិនិយោ ។

## បាសាទិកសូត្រ ភាវៈនៃសាស្តាជាថេរៈជាអ្នកដឹងរាត្រីជាដើម

ម្នាលចុន្ទ កាលណាបើព្រហ្មចារ្យ ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអង្វែង ចំរើនវ័យដោយលំដាប់ ទាំងពួកភិក្ខុជាសាវ័ក របស់ព្រះសាស្តានោះក៏ជាថេរៈ ជាអ្នកឈ្លាសវៃ អាចដឹកនាំក្លៀវក្លា ។ បេ ។ អាចសំដែងធម៌ ព្រមទាំងបាដិហារិយ៍បាន ។ សាស្តានោះ មានពួកភិក្ខុជាន់កណ្តាល ជាសាវ័កផង ។ សាស្តានោះ មានពួកភិក្ខុខ្ចីជាសាវ័កផង ។ សាស្តានោះ មានពួកភិក្ខុនីចាស់ជាសាវិកាផង ។ សាស្តានោះ មានពួកភិក្ខុនីជាន់កណ្តាលជាសាវិកាផង ។ សាស្តានោះ មានពួកភិក្ខុនីខ្ចីជាសាវិកាផង ។ សាស្តានោះ មានពួកគ្រហស្ថ ឧបាសក មានសំលៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ជាសាវ័កផង ។ សាស្តានោះ មានពួកគ្រហស្ថឧបាសក មានសំលៀកបំពាក់ស បរិភោគកាម ជាសាវ័កផង ។ សាស្តានោះ មានពួកគ្រហស្ថឧបាសិកា មានសំលៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យ ជាសាវិកាផង ។ សាស្តានោះ មានពួកគ្រហស្ថ ឧបាសិកា មានសំលៀកបំពាក់ស បរិភោគកាម ជាសាវិកាផង ។ ទាំងព្រហ្មចារ្យរបស់សាស្តានោះ ក៏មាំមួន ផ្សាយទូលាយទៅ មានគេចេះដឹង

ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកា-
សិតំ លាភគ្គយសគ្គប្បត្តញ្ច ឯវត្តំ ព្រហ្មចរិយំ បរិបូរំ
ហោតិ តេនង្គេន ។

(១០៨) អហំ ខោ បន ចុន្ទ ឯតរហិ សត្ថា
លោកេ ឧប្បន្នោ អរហំ សម្មាសម្ពុទ្ធោ ធម្មោ ច
ស្វាក្ខាតោ សុប្បវេទិតោ និយ្យានិកោ ឧបសមសំ-
វត្តនិកោ សម្មាសម្ពុទ្ធប្បវេទិតោ វិញ្ញាបិតត្ថា ច មេ
សាវកា សទ្ធម្មេ កេវលញ្ច តេសំ បរិបូរំ ព្រហ្ម-
ចរិយំ អាវិកតំ ហោតិ(១) ឧត្តានីកតំ សង្គហបទ-
កតំ សប្បាដិហិរកតំ យាវ ទេវមនុស្សេហិ សុប្ប-
កាសិតំ ។ អហំ ខោ បន ចុន្ទ ឯតរហិ សត្ថា
ថេរោ រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុ-
ប្បត្តោ ។

---

១ ឱ. ម. ហោតីតិ ន ទិស្សតិ ។

ច្រើនក្រាស់ក្រៃល ដរាបតែពួកទេវតានឹងមនុស្ស សំដែងបាន ដោយប្រពៃ ទាំងបានដល់នូវលាភដ៏ប្រសើរ នឹងយសដ៏ប្រសើរ កាលបើដូច្នេះ ព្រហ្មចារ្យនោះ ទើបឈ្មោះថា បរិបូណ៌ដោយអង្គនោះ ។

(១០៩) ម្នាលចុន្ទ កំឡុងនេះ តថាគតជាសាស្តា ជាអរហន្ត សម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោក ទាំងធម៌សោត តថាគតបាន សំដែងប្រពៃហើយ ប្រកាសទុកប្រពៃហើយ ជានិយ្យានិកធម៌ ជាធម៌ ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធប្រកាស ទុកហើយ ទាំងពួកសាវ័ក ក៏តថាគតបានពន្យល់ ឲ្យដឹងច្បាស់សេចក្តីក្នុងព្រះសទ្ធម្មហើយ ទាំងព្រហ្មចរិយធម៌ ដ៏បរិបូណ៌សព្វគ្រប់ ក៏តថាគតបាន ធ្វើឲ្យជាក់ច្បាស់ ដល់សាវ័កទាំងនោះ ធ្វើឲ្យផ្សាយឡើង ធ្វើដោយបទចង ក្រងធ្វើឲ្យជាធម៌គួរដឹកនាំគ្នាបាន ដរាបតែពួកទេវតានឹងមនុស្ស សំដែងបានដោយប្រពៃ ។ ម្នាលចុន្ទ កំឡុងនេះ តថាគត ក៏ជាសាស្តា ជាថេរៈ អ្នកដឹងរាត្រី បួសយូរ តាំងនៅអង្វែង ចំរើនវ័យ ដោយលំដាប់ហើយ ។

[១០៦] សន្តិ ខោ បន មេ ចុន្ទ ឯតរហិ ថេរា ភិក្ខូ សាវកា ហោន្តិ(១) វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា អលំ សមក្ខាតុំ សទ្ធម្មស្ស អលំ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហីតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេតុំ ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ មជ្ឈិមា ភិក្ខូ សាវកា ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ នវា ភិក្ខូ សាវកា ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ ថេរា ភិក្ខុនិយោ សាវិកា ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ មជ្ឈិមា ភិក្ខុនិយោ សាវិកា ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ នវា ភិក្ខុនិយោ សាវិកា ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ ឧបាសកា សាវកា គិហី ឱទាតវសនា ព្រហ្មចារិនោ ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ ឧបាសកា សាវកា គិហី ឱទាតវសនា កាមភោគិនោ ។ បេ ។ សន្តិ ខោ បន មេ ចុន្ទ ឯតរហិ

---

១ ឱ. ហោន្តីតិ ន ទិស្សតិ ។

(១០៦) ម្នាលចុន្ទ ក្នុងកាលឥឡូវនេះ តថាគត មានពួកភិក្ខុជាថេរៈ ជាសាវក ជាអ្នកឈ្លាសវៃដឹកនាំត្រៀវត្រា ដល់នូវធម៌ក្សេមចាកយោគៈ អាចប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយ ដោយពាក្យប្រកបដោយធម៌ ហើយសំដែងធម៌ព្រមទាំងបាដិហារិយ៍បាន ។ ម្នាលចុន្ទ ក្នុងកាលឥឡូវនេះ តថាគត មានពួកភិក្ខុជាន់កណ្ដាល ជាសាវកផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគត មានពួកភិក្ខុថ្មីជាសាវកផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគត មានពួកភិក្ខុនីចាស់ជាសាវិកាផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគត មានពួកភិក្ខុនីជាន់កណ្ដាលជាសាវិកាផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគត មានពួកភិក្ខុនីថ្មីជាសាវិកាផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគត មានពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវកផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគត មានពួកគ្រហស្ថឧបាសកមានសម្លៀកបំពាក់ស បរិភោគកាមជាសាវកផង ។បេ។ ម្នាលចុន្ទ ឥឡូវនេះ តថាគត មានពួកគ្រហស្ថ

ឧបាសិកា សាវិកា គិហិនី(១) ឱទាតវសនា កាមភោគិនិយោ ។ ឯតរហិ(២) បន មេ ចុន្ទ ព្រហ្មចរិយំ ឥទ្ធញ្ចេវ(៣) ផីតញ្ច វិត្ថារិកំ ពហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ ។

(១០៧) យាវតា ខោ ចុន្ទ ឯតរហិ សត្ថារោ លោកេ ឧប្បន្នា ។ នាហំ ចុន្ទ អញ្ញំ ឯកំ សត្ថារំបិ សមនុបស្សាមិ ឯវំលាភគ្គយសគ្គប្បត្តំ យថរិវាហំ ។ យាវតា ខោ បន មេ ចុន្ទ(៤) ឯតរហិ សង្ឃោ វា គណោ វា លោកេ ឧប្បន្នោ(៥) ។ នាហំ ចុន្ទ អញ្ញំ ឯកំ សង្ឃំបិ សមនុបស្សាមិ ឯវំលាភគ្គយសគ្គប្បត្តំ យថរិវ ចុន្ទ ភិក្ខុសង្ឃោ ។ យំ ខោ តំ ចុន្ទ សម្មា វទមានោ វទេយ្យ សព្វាការសម្បន្នំ សព្វាការបរិបូរំ អនូនំ អនធិកំ ស្វាក្ខាតំ កេវលបរិបូរំ ព្រហ្មចរិយំ សុប្បកាសិតន្តិ ។ ឥទមេវ តំ សម្មា វទមានោ វទេយ្យ

---

១ ឱ. ម. គិហិនិយោ ។ ២ ឱ. ម. ឯតរហិ ខោ ។ ៣ ឱ. ឥទ្ធញ្ច ។ ៤ ឱ. យាវតា ខោ ចុន្ទ ។ ម. យាវតា ខោ បន ចុន្ទ ។ ៥ ឱ. សង្ឃា វា គណា លោកេ ឧប្បន្នា ។

ឧបាសិកា មានសម្លៀកបំពាក់ស បរិភោគកាម ជាសាវិកា ។ ម្នាលចុន្ទ ឥឡូវនេះ ព្រហ្មចរិយធម៌របស់តថាគត ក៏មាំមួន ផ្សាយទូលាយទៅ មានគេចេះដឹងច្រើនក្រាស់ក្រែល ទាំងពួកទេវតានឹងមនុស្ស ក៏សំដែងបាន ដោយប្រពៃហើយ ។

(១០៧) ម្នាលចុន្ទ ឥឡូវនេះ ពោះជាសាស្តាទាំងឡាយកើតឡើងហើយក្នុងលោក ។ ម្នាលចុន្ទ តថាគត ជ្រើសរើសមិនឃើញសាស្តាដទៃសូម្បីម្នាក់ ដែលបានដល់នូវលាភដ៏ប្រសើរ នឹងយសដ៏ប្រសើរយ៉ាងនេះ ឲ្យដូចជាតថាគតឡើយ ។ ម្នាលចុន្ទ ឥឡូវនេះ ទោះជាសង្ឃក្តី គណៈក្តី របស់តថាគតកើតឡើង ក្នុងលោកហើយ ។ ម្នាលចុន្ទ តថាគត ជ្រើសរើសមិនឃើញសង្ឃដទៃសូម្បីមួយពួក ដែលបានដល់នូវលាភដ៏ប្រសើរ នឹងយសដ៏ប្រសើរយ៉ាងនេះ ឲ្យដូចជាភិក្ខុសង្ឃ (ក្នុងសា-សនានេះ) ឡើយ ។ ម្នាលចុន្ទ បុគ្គលកាលនិយាយពាក្យណា ឲ្យត្រូវនោះ គួរនិយាយថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាងបរិបូណ៌ហើយ ដោយអាការគ្រប់យ៉ាង មិនខ្វះមិនលើស ដែលព្រះមានព្រះភាគ ត្រាស់ទុកល្អហើយ បរិបូណ៌ទាំងអស់ បានប្រកាសទុកល្អហើយ ។ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា

សព្វាការសម្បន្នំ សព្វាការបរិបូរំ ។ បេ ។ សុប្បកាសិតន្តិ ។ ឧទ្ទកោ សុទំ ចុន្ទ រាមបុត្តោ ឯវំ វាចំ ភាសតិ បស្សំ ន[១] បស្សតីតិ កិញ្ច បស្សំ ន បស្សតីតិ ។ ខុរស្ស សាធុនិសិតស្ស តលមស្ស បស្សតិ ធារញ្ច ខុរស្ស[២] ន បស្សតិ ។ ឥទំ វុច្ចតិ ចុន្ទ បស្សំ ន បស្សតីតិ ។ តំ ខោ បនេតំ ចុន្ទ ឧទ្ទកេន រាមបុត្តេន ភាសិតំ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ ខុរមេវ សន្ធាយ ។ យញ្ចតំ[៣] ចុន្ទ សម្មា វទមានោ វទេយ្យ បស្សំ ន បស្សតីតិ ។ ឥទមេវ តំ សម្មា វទមានោ វទេយ្យ បស្សំ ន បស្សតីតិ ។ កិញ្ច បស្សំ ន បស្សតីតិ ។ ឯវំ សព្វាការសម្បន្នំ សព្វាការបរិបូរំ អនូនំ អនធិកំ ស្វាក្ខាតំ កេវលបរិបូរំ ព្រហ្មចរិយំ សុប្បកាសិតន្តិ[៤]

---

ឱ. បស្សន្តំ ។ ២ ឱ. ធារញ្ច ខោ តស្ស ។ ម. ធារញ្ច ខ្វស្ស ។ ៣ ឱ. យញ្ច តំ ។ ៤ ម. សុប្បកាសិតំ ។

ព្រហ្មចារ្យដល់ព្រមហើយដោយអាការគ្រប់យ៉ាង បរិបូណ៌ដោយអាការគ្រប់យ៉ាង ។ បេ ។ បានប្រកាសល្អហើយដូច្នេះ ។ ម្នាលចុន្ទ ឮថា ឧទ្ទករាមបុត្រ និយាយសំដីយ៉ាងនេះថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ ឃើញនូវអ្វី ឈ្មោះថា មិនឃើញ ។ បុគ្គលឃើញបានតែត្រឹមផ្ទៃនៃកាំបិតកោរ ដែលមុតល្អ តែមិនឃើញមុខកាំបិតកោរទេ ។ ម្នាលចុន្ទ នេះឯង ដែលឧទ្ទករាមបុត្រ និយាយថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ ម្នាលចុន្ទ ឯពាក្យដែលឧទ្ទករាមបុត្រ ពោលនោះ ជាពាក្យថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ ព្រោះសំដៅកាំបិតកោរតែម្យ៉ាង ។ ម្នាលចុន្ទ កាលបើបុគ្គល និយាយពាក្យណា ឲ្យត្រូវនោះ គួរនិយាយថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ បុគ្គលឃើញនូវអ្វីខ្លះ ឈ្មោះថា មិនឃើញ ។ ពាក្យថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាង បរិបូណ៌ហើយដោយអាការគ្រប់យ៉ាង មិនខ្វះមិនលើស ដែលតថាគត សំដែងទុកល្អហើយ បរិបូណ៌ទាំងអស់ បានប្រកាសទុកល្អហើយ យ៉ាងនេះ

ឥតិ ហេតំ ន បស្សតីតិ[១] ឥទមេត្ថ អបកឌ្ឍេយ្យ ។ ឯវន្តំ បរិសុទ្ធតរំ អស្សាតិ ឥតិ ហេតំ ន បស្សតីតិ[២] ឥទមេត្ថ ឧបកឌ្ឍេយ្យ ។ ឯវន្តំ បរិសុទ្ធតរំ អស្សាតិ ឥតិ ហេតំ ន បស្សតិ ។ ឥទំ វុច្ចតិ បស្សំ ន បស្សតីតិ ។ យំ ខោ តំ ចុន្ទ សម្មា វទមានោ វទេយ្យ សព្វាការសម្បន្នំ ។ បេ ។ ព្រហ្មចរិយំ សុប្ប-កាសិតន្តិ ។ ឥទមេតំ[៣] សម្មា វទមានោ វទេយ្យ សព្វាការសម្បន្នំ សព្វាការបរិបូរំ អនូនំ អនធិកំ ស្វាក្ខាតំ កេវលបរិបូរំ ព្រហ្មចរិយំ សុប្បកាសិតន្តិ ។

(១០៨) តស្មាតិហ ចុន្ទ យេ តេ[៤] មយា ធម្មា អភិញ្ញា ទេសិតា តត្ថ សព្វេហេវ សង្គម្ម សមាគម្ម អត្ថេន អត្ថំ ព្យញ្ជនេន ព្យញ្ជនំ សង្គាយិតព្វំ វិចរិ-តព្វំ[៥] យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្សេវ[៦] ពហុជនហិតាយ ពហុជនសុខាយ

---

១ ឱ. ហេតំ បស្សតិ ។ ២ ឱ. ន បស្សតិ ។ ៣ ម. ឥទមេវតំ ។ ៤ ឱ. ម. វោ ។ ៥ ឱ. ម. ន វិវទិតព្វំ ។ ៦ ឱ. ម. តទស្ស ។

បុគ្គលមិនឃើញសេចក្តីនុ៎ះ ដូច្នេះសោះ សមជាដកពាក្យនេះចេញ ក្នុងរឿងនោះ ៗ បុគ្គលនោះ ថែមទាំងមិនឃើញសេចក្តីនុ៎ះ ដូច្នេះថា ព្រហ្មចារ្យនុ៎ះ បរិសុទ្ធក្រៃលែងយ៉ាងនេះ សមជាបញ្ចូលពាក្យនេះ ក្នុងរឿងនុ៎ះ ៗ បុគ្គលនោះ ឈ្មោះថា មិនឃើញសេចក្តីនៃពាក្យថា ព្រហ្មចារ្យនោះបរិសុទ្ធក្រៃលែងដូច្នេះ យ៉ាងនេះ ៗ នេះហៅថា បុគ្គលកាលឃើញ ឈ្មោះថា មិនឃើញ ៗ ម្នាលចុន្ទ បុគ្គលកាលនិយាយពាក្យណា ឲ្យត្រូវនោះ គួរនិយាយថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាង ៗ បេ ៗ បានប្រកាសទុកល្អហើយ ៗ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាង បរិបូណ៌ហើយ ដោយអាការគ្រប់យ៉ាង មិនខ្វះមិនលើស ដែលតថាគត សំដែងទុកល្អហើយ បរិបូណ៌ទាំងអស់ ប្រកាសទុកល្អហើយដូច្នេះ ៗ

(១០៨) ម្នាលចុន្ទ ព្រោះហេតុនោះ ធម៌ទាំងឡាយណា ដែលតថាគត បានត្រាស់ដឹង សំដែងទុកល្អហើយ ក្នុងលោកនេះ គួរឲ្យអ្នកទាំងអស់រួមគំនិត មកប្រជុំរួបរួមផ្ទៀងផ្ទាត់ នូវអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ ក្នុងធម៌នោះ ដែលជាហេតុឲ្យព្រហ្មចារ្យនេះ តាំងនៅមាំឋិតថេរអស់កាលយូរ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខ

### បាសាទិកសុត្តេ អភិញ្ញាទេសិតធម្មកថា

លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេ ច តេ[1] ចុន្ទ ធម្មា មយា អភិញ្ញា ទេសិតា ។ យត្ថ សព្វេហេវ សង្គម្ម សមាគម្ម អត្ថេន អត្ថំ ព្យញ្ជនេន ព្យញ្ជនំ សង្គាយិតព្វំ វិចរិតព្វំ យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ សេយ្យថីទំ ។ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត សម្ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ ឥមេ ខោ តេ ចុន្ទ ធម្មា មយា អភិញ្ញា ទេសិតា យត្ថ សព្វេហេវ សង្គម្ម សមាគម្ម អត្ថេន អត្ថំ ព្យញ្ជនេន ព្យញ្ជនំ សង្គាយិតព្វំ វិចរិតព្វំ យថយិទំ ព្រហ្មចរិយំ អទ្ធនិយំ អស្ស ចិរដ្ឋិតិកំ តទស្ស

---

១ ម. ភោ ។

ដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតានឹងមនុស្សទាំងឡាយ ។ ម្នាលចុន្ទ ធម៌ទាំងឡាយដែលតថាគត បានសំដែងហើយដល់អ្នក ព្រោះសេចក្ដីដឹងដ៏ក្រៃលែង នោះតើដូចម្ដេច ។ ពួកអ្នកទាំងអស់គ្នាត្រូវរួមគំនិតមកប្រជុំគ្នារួបរួមផ្ទៀងផ្ទាត់ នូវអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ ក្នុងពួកធម៌ណាដែលជាហេតុឲ្យព្រហ្មចារ្យនេះ តាំងនៅបានមាំមួន ឋិតថេរអស់កាលយូរ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា នឹងមនុស្សទាំងឡាយ ។ ពួកធម៌នោះ ដូចម្ដេចខ្លះ ។ ពួកធម៌នោះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ៥ សម្ពោជ្ឈង្គ ៧ នឹងអរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលចុន្ទ ធម៌ទាំងឡាយនេះឯង ដែលតថាគត បានត្រាស់ដឹងសំដែងហើយ ដែលពួកបរិស័ទទាំងអស់ ត្រូវរួមគំនិត ប្រជុំគ្នារួបរួមផ្ទៀងផ្ទាត់ នូវអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ ដែលជាហេតុឲ្យព្រហ្មចារ្យនេះ ឋិតនៅបានមាំ តាំងនៅអស់កាលយូរ ដើម្បីជាប្រយោជន៍

ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។

(១០៩) តេសញ្ច វោ(១) ចុន្ទ សមគ្គានំ សម្មោទមានានំ អវិវទមានានំ សិក្ខិតព្វំ ។ អញ្ញតរោ សព្រហ្មចារី សង្ឃេ(២) ធម្មំ ភាសេយ្យ តត្រ ចេ តុម្ហាកំ ឯវមស្ស អយំ ខោ អាវុសោ(៣) អាយស្មា អត្ថញ្ចេវ មិច្ឆា គណ្ហាតិ ព្យញ្ជនានិ ច មិច្ឆា រោបេតីតិ ។ តស្ស នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ ។ អនភិនន្ទិត្វា អប្បដិក្កោសិត្វា សោ ឯវមស្ស វចនីយោ ឥមស្ស នុ ខោ អាវុសោ អត្ថស្ស ឥមានិ(៤) ព្យញ្ជនានិ ឯតានិ វា ព្យញ្ជនានិ កតមានិ ឱបាយិកតរានិ ឥមេសំ វា ព្យញ្ជនានំ អយំ វា អត្ថោ ឯសោ វា អត្ថោ កតមោ ឱបាយិកតរោតិ ។ សោ ចេ ឯវំ វទេយ្យ ឥមស្ស ខោ អាវុសោ

---

១ ឱ. ម. វោ ។ ២ ឱ. ម. សង្ឃេ ។ ៣ ឱ. ម. អាវុសោតិ ន ទិស្សតិ ។
៤ ឱ. ម. ឥមានិ វា ។

ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានឹងមនុស្សទាំងឡាយ ។

(១០៩) ម្នាលចុន្ទ ពួកអ្នកនោះឯង ជាអ្នកព្រមព្រៀងគ្នា ជាអ្នកមានចិត្តរីករាយ មិនទាស់ទែងគ្នា គប្បីសិក្សាចុះ ។ សង្ឃជាសព្រហ្មចារីបុគ្គលណាមួយ និយាយធម៌ ក្នុងការនិយាយធម៌នោះ បើអ្នកទាំងឡាយ មានសេចក្តីយល់យ៉ាងនេះថា ម្នាលអាវុសោ លោកដ៏មានអាយុនេះឯង កាន់យកនូវអត្ថខុស សំដែងនូវព្យញ្ជនៈក៏ខុស ។ អ្នកទាំងឡាយ មិនត្រូវត្រេកអរ មិនត្រូវហាមឃាត់គេឡើយ ។ លុះពួកអ្នកមិនត្រេកអរ មិនជំទាស់ហើយ គួរនិយាយនឹងគេ យ៉ាងនេះថា ម្នាលអាវុសោ ព្យញ្ជនៈទាំងនេះ ឬថា ព្យញ្ជនៈទាំងនុ៎ះ របស់អត្ថនេះ ពួកណាស្រួលជាង មួយទៀត អត្ថនេះ ឬក៏អត្ថនុ៎ះ របស់ព្យញ្ជនៈពួកនេះ អត្ថណាស្រួលជាង ។ ប្រសិនបើគេនិយាយ យ៉ាងនេះថា ម្នាលអាវុសោ

អញ្ញស្ស ឥមានេវ ព្យញ្ជនានិ ឱបាយិកតរានិ យានិ ចេវ[១] ឯតានិ ឥមេសំ ព្យញ្ជនានំ អយមេវ អត្ថោ ឱបាយិកតរោ យោ ចេវ[២] ឯសោតិ ។ សោ នេវ ឧស្សាទេតព្វោ ន អបសាទេតព្វោ ។ អនុស្សាទេត្វា អនបសាទេត្វា[៣] ស្វាស្ស[៤] សាធុកំ សញ្ញាបេតព្វោ តស្ស ច អត្ថស្ស តេសញ្ច ព្យញ្ជនានំ និសន្តិយា ។

[១១០] អបរោបិ ចេ ចុន្ទ សព្រហ្មចារី សង្ឃេ[៥] ធម្មំ ភាសេយ្យ តត្រ ចេ តុម្ហាកំ ឯវមស្ស អយំ ខោ អាយស្មា អត្ថញ្ហិ[៦] ខោ មិច្ឆា គណ្ហាតិ ព្យញ្ជនានិ សម្មា រោបេតីតិ ។ តស្ស នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ ។ អនភិនន្ទិត្វា អប្បដិក្កោសិត្វា សោ ឯវមស្ស វចនីយោ ឥមេសំ នុ ខោ អាវុសោ ព្យញ្ជនានំ អយំ វា អត្ថោ ឯសោ វា អត្ថោ

១. ២ ម. យោ ចេវ ។ ៣ ម. ឧស្សាទេតព្វោ ន អបសាទេតព្វោ ។ អនុស្សាទេត្វា អនបសាទេត្វា ។ ឱ. ន អប្បសាទេត្វា ។ ៤ ឱ. សោ វ ។ ៥ ឱ. ម. សង្ឃេ ។ ៦ ឱ. ម. អត្ថំ ហិ ។

ពួកព្យញ្ជនៈនេះឯង របស់អត្ថនេះ ជាព្យញ្ជនៈស្រួលជាងអត្ថនេះឯង របស់ពួកព្យញ្ជនៈនុ៎ះ ជាអត្ថស្រួលជាង ៗ ភិក្ខុមិនត្រូវលើក មិនត្រូវបន្អាប់គេឡើយ ៗ លុះមិនលើក មិនបន្អាប់គេហើយ គួរពន្យល់គេដោយស្រួលបួល ដើម្បីចាំទុកនូវអត្ថនោះ នឹងពួកព្យញ្ជនៈនោះ ៗ

(១១០) ម្នាលចុន្ទ បើសង្ឃជាសព្រហ្មចារីដទៃ និយាយធម៌ ក្នុងការនិយាយនោះ បើអ្នកទាំងឡាយ មានសេចក្តីយល់យ៉ាងនេះថា លោកដ៏មានអាយុនេះឯង កាន់យកនូវអត្ថខុស (តែ) សំដែងព្យញ្ជនៈទាំងឡាយត្រូវ ៗ អ្នកទាំងឡាយ ក៏មិនត្រូវត្រេកអរ មិនត្រូវជំទាស់គេឡើយ ៗ លុះមិនត្រេកអរ មិនជំទាស់ហើយ ត្រូវនិយាយនឹងគេយ៉ាងនេះថា ម្នាលអាវុសោ អត្ថនេះ ឬអត្ថនុ៎ះ របស់ពួកព្យញ្ជនៈទាំងនេះ

កតមោ ឱបាយិកតរោតិ ។ សោ ចេ ឯវំ វទេយ្យ ឥមេសំ នុ ខោ(១) អាវុសោ ព្យញ្ជនានំ អយមេវ អត្ថោ ឱបាយិកតរោ យោ ចេវ ឯសោតិ ។ សោ នេវ ឧស្សាទេតព្វោ ន អបសាទេតព្វោ ។ អនុស្សាទេត្វា អនបសាទេត្វា ស្វេវ សាធុកំ សញ្ញាបេតព្វោ តស្ស ច អត្ថស្ស និសន្តិយា ។

(១១១) អបរោបិ ចេ ចុន្ទ សព្រហ្មចារី សង្ឃេ(២) ធម្មំ ភាសេយ្យ តត្រ ចេ តុម្ហាកំ ឯវមស្ស អយំ ខោ អាយស្មា អត្ថំ ហិ ខោ សម្មា គណ្ហាតិ ព្យញ្ជនានិ មិច្ឆា រោបេតីតិ ។ តស្ស នេវ អភិនន្ទិតព្វំ នប្បដិក្កោសិតព្វំ ។ អនភិនន្ទិត្វា អប្បដិក្កោសិត្វា សោ ឯវមស្ស វចនីយោ ឥមស្ស នុ ខោ អាវុសោ អត្ថស្ស ឥមានេវ(៣) ព្យញ្ជនានិ ឯតានិ វា ព្យញ្ជនានិ កតមានិ ឱបាយិកតរានីតិ ។ សោ ចេ ឯវំ វទេយ្យ ឥមស្ស នុ ខ្វាវុសោ អត្ថស្ស ឥមានេវ ព្យញ្ជនានិ

---

១ ឱ. ឥមេសំ ខោ ។ ម. តេសំ ខោ ។ ២ ឱ. ម. សង្ឃេ ។ ៣ ឱ. ឥមានិ ប ។

អត្ថណាស្រួលជាង ៗ ប្រសិនបើគេនិយាយ យ៉ាងនេះថា ម្នាលអាវុសោ អត្ថនេះឯង របស់ព្យញ្ជនៈពួកនេះ ជាអត្ថស្រួលជាង ៗ អ្នកទាំងឡាយ មិនត្រូវលើក មិនត្រូវបន្អាប់គេឡើយ ៗ លុះមិនបានលើក មិនបាន បន្អាប់ហើយ គួរពន្យល់គេដោយស្រួលបួល ដើម្បីចាំទុកនូវអត្ថនោះ ៗ

(១១) ម្នាលចុន្ទ បើសង្ឃជាសព្រហ្មចារីដទៃទៀត និយាយធម៌ ក្នុងការនិយាយនោះ បើអ្នកទាំងឡាយ មានសេចក្ដីយល់ យ៉ាងនេះថា លោកមានអាយុនេះឯង កាន់យកនូវអត្ថត្រូវ(តែ)សំដែងនូវព្យញ្ជនៈខុស ៗ អ្នកទាំងឡាយមិនត្រូវត្រេកអរ មិនត្រូវជំទាស់គេឡើយ ៗ លុះមិនត្រេក-អរ មិនជំទាស់ហើយ ត្រូវនិយាយនឹងគេយ៉ាងនេះថា ម្នាលអាវុសោ ពួកព្យញ្ជនៈនេះ ឬពួកព្យញ្ជនៈនុ៎ះ របស់អត្ថនេះ ពួកណាស្រួលជាង ៗ បើគេនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពួកព្យញ្ជនៈនេះឯង របស់អត្ថនេះ

ឱបាយិកតរានិ យានិ ចេវ ឯតានីតិ ។ សោ នេវ ឧស្សាទេតព្វោ ន អប្បសាទេតព្វោ ។ អនុស្សាទេត្វា អនប្បសាទេត្វា ស្វេវ សាធុកំ សញ្ញាបេតព្វោ តេសំយេវ ព្យញ្ជនានំ និសន្តិយា ។

(១១២) អបរោបិ ចេ ចុន្ទ សព្រហ្មចារី សង្ឃេ(១) ធម្មំ ភាសេយ្យ តត្រ ចេ តុម្ហាកំ ឯវមស្ស អយំ ខោ អាយស្មា អត្ថញ្ញេវ សម្មា គណ្ហាតិ ព្យញ្ជនានិ សម្មា រោបេតីតិ ។ តស្ស សាធូតិ ភាសិតំ អភិនន្ទិតព្វំ អនុមោទិតព្វំ ។ តស្ស សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា សោ ឯវមស្ស វចនីយោ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ សវិស្សាម(២) ឯវំ អត្ថុបេតំ ព្យញ្ជនុបេតន្តិ(៣) ។

---

១ ឱ ម សង្ឃេ ។ ២ ឱ. ម. បស្សាម ។ ៣ ឱ. អត្ថូបេតំ ព្យញ្ជនូបេតន្តិ ។

ជាព្យញ្ជនៈស្រួលជាង ។ អ្នកទាំងឡាយមិនត្រូវលើក មិនត្រូវបង្អាប់គេឡើយ ។ លុះមិនលើក មិនបង្អាប់ហើយ គួរពន្យល់គេដោយស្រួលបួល ដើម្បីចាំទុកនូវពួកព្យញ្ជនៈនោះ ។

(១១២) ម្នាលចុន្ទ បើសង្ឃជាសព្រហ្មចារីដទៃទៀត និយាយធម៌ ក្នុងការនិយាយនោះ បើអ្នកទាំងឡាយ មានសេចក្តីយល់យ៉ាងនេះថា លោកដ៏មានអាយុនេះ កាន់យកនូវអត្ថ ក៏ត្រឹមត្រូវ សំដែងនូវពួកព្យញ្ជនៈ ក៏ត្រឹមត្រូវ ។ អ្នកទាំងឡាយ ត្រូវត្រេកអរ ត្រូវអនុមោទនា ចំពោះភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះ ។ លុះត្រេកអរ អនុមោទនា ចំពោះភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះហើយ ត្រូវនិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ជាលាភរបស់ពួកយើង ម្នាលអាវុសោ ពួកយើងបានស្រួលហើយ ពួកយើងរលឹកនូវលោកដ៏មានអាយុថា សព្រហ្មចារីប្រាកដដូចជាលោក ដែលជាអ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវព្យញ្ជនៈយ៉ាងនេះ ។

(១១៣) ន ចេ អហំ(១) ចុន្ទ ទិដ្ឋធម្មិកានំយេវ អាសវានំ សំវរាយ ធម្មំ ទេសេមិ ន បនាហំ ចុន្ទ សម្បរាយិកានំយេវ អាសវានំ បដិឃាតាយ ធម្មំ ទេសេមិ ទិដ្ឋធម្មិកានំ ចេវាហំ(២) ចុន្ទ អាសវានំ សំវរាយ ធម្មំ ទេសេមិ សម្បរាយិកានំ ច អាសវានំ បដិឃាតាយ ។ តស្មាតិហ ចុន្ទ យំ វោ មយា ចីវរំ អនុញ្ញាតំ អលំ វោ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរឹសបសម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបិនបដិច្ឆាទនត្ថំ ។ យោ វោ មយា បិណ្ឌបាតោ អនុញ្ញាតោ អលំ វោ សោ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា(៣) ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ

---

១ ឱ. នវំ អហំ ។ ២ ម. ទិដ្ឋធម្មិកានញ្ចាហំ ។ ៣ ឱ. វិហឹសូបរតិយា ។

(១១៣) ម្នាលចុន្ទ តថាគតមិនសំដែងធម៌ ដើម្បីកំពែងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន តែមួយយ៉ាង ដល់ពួកអ្នកទេ ម្នាលចុន្ទ តថាគតមិនសំដែងធម៌ ដើម្បីកំចាត់បង់នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខ ប៉ុណ្ណោះទេ ម្នាលចុន្ទ តថាគតសំដែងធម៌ ដើម្បីកំពែងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង ដើម្បីកំចាត់បង់នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ៗ ម្នាលចុន្ទ ព្រោះហេតុដូច្នោះ ចីវរណាដែលតថាគតបានអនុញ្ញាតហើយ ដល់អ្នកទាំងឡាយ ចីវរនោះ ក៏សមគួរដល់អ្នកទាំងឡាយ ដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកំដៅ ដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់តូច ពស់ធំ ទាំងឡាយប៉ុណ្ណោះ ទាំងដើម្បីបិទបាំងនូវអវយវៈ ជាគ្រឿងញុំាងសេចក្ដីអៀនខ្មាសឲ្យកម្រើក ប៉ុណ្ណោះឯង បិណ្ឌបាតណា ដែលតថាគតបានអនុញ្ញាតហើយ ដល់អ្នកទាំងឡាយ បិណ្ឌបាតនោះ ក៏គួរដល់អ្នកទាំងឡាយ ដើម្បីគ្រាន់តែឲ្យកាយនេះ តាំងនៅបាន ប្រព្រឹត្តទៅបាន ដើម្បីកំចាត់បង់ នូវសេចក្ដីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ ដើម្បីធ្វើទុកក្នុងចិត្តថា អាត្មាអញនឹងបំបាត់ នូវវេទនាចាស់ផង

នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ យំ ខោ មយា សេនាសនំ អនុញ្ញាតំ អលំ ខោ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ យាវទេវ ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ យោ ខោ មយា គិលានប្បច្ចយភេសជ្ជបរិក្ខារោ អនុញ្ញាតោ អលំ ខោ សោ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ។

ទាំងមិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តទៅ (នៃឥរិយាបថទាំង ៤ ក្តី) សេចក្តីមិនមានទោសក្តី ការនៅសប្បាយក្តី នឹងមានដល់អាត្មាអញ (ដោយការបរិភោគ នូវចង្ហាន់បិណ្ឌបាតនេះ) ទីសេនាសនៈណា ដែលតថាគតបានអនុញ្ញាតហើយ ដល់អ្នកទាំងឡាយ ទីសេនាសនៈនោះ សមគួរ ដល់អ្នកទាំងឡាយ ដើម្បីការពារនូវត្រជាក់ ដើម្បីការពារនូវកំដៅ ដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កំដៅថ្ងៃ នឹងពស់តូច ពស់ធំទាំងឡាយប៉ុណ្ណោះ ដើម្បីបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ អភិរម្យសម្ងំនៅ ក្នុងកម្មដ្ឋាន ប៉ុណ្ណោះឯង គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺណា ដែលតថាគតបានអនុញ្ញាតហើយ ដល់អ្នកទាំងឡាយ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺនោះ សមគួរដល់អ្នកទាំងឡាយ ដើម្បីការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេង ៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំង ជាធម្មតា ។

(១១៤) ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ សុខល្លិកានុយោគមនុយុត្តា សមណា សក្យបុត្តិយា វិហរន្តីតិ ។ ឯវំ វទមានា(១) ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា កតមោ សោ អាវុសោ សុខល្លិកានុយោគោ សុខល្លិកានុយោគាបិ ហិ ពហូ អនេកវិហិតា នានប្បការកាតិ ។ ចត្តារោមេ ចុន្ទ សុខល្លិកានុយោគា ហីនា គម្មា បោថុជ្ជនិកា អនរិយា អនត្ថសញ្ហិតា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ចុន្ទ ឯកច្ចោ ពាលោ បាណេ វធិត្វា អត្តានំ សុខេតិ បីណេតិ អយំ បឋមោ សុខល្លិកានុយោគោ ។ បុន ចបរំ ចុន្ទ

---

១ ឱ. ម. ឯវំ វាទិនោ ។

(១១៨) ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ(១) សមបីជានិយាយយ៉ាងនេះថា ពួកសមណ-សក្យបុត្តិយ៍ជាអ្នកប្រកបរឿយ ៗ ក្នុងសុខល្លិកានុយោគ (ប្រកបខ្លួនឲ្យប្រព្រឹត្តទៅក្នុងការស្រួល) ។ ម្នាលចុន្ទ កាលបើពួកបរិព្វាជក ជាអន្យ-តិរ្ថិយនិយាយយ៉ាងនេះ ត្រូវអ្នកទាំងឡាយនិយាយយ៉ាងនេះថា ម្នាលអាវុសោ សុខល្លិកានុយោគនោះ ដូចម្ដេចខ្លះ ព្រោះថា សុខល្លិកានុយោគ មានច្រើន មិនមែនតែមួយ មានប្រការផ្សេង ៗ ។ ម្នាលចុន្ទ សុខល្លិកា-នុយោគនេះ មាន ៤ ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនមែនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីរលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីដឹងក្រៃលែង មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ។ សុខល្លិកានុយោគ ៤ យ៉ាងនោះ ដូចម្ដេចខ្លះ ។ ម្នាលចុន្ទ ជនពាលខ្លះក្នុងលោកនេះ សម្លាប់សត្វទាំងឡាយ ហើយធ្វើខ្លួនឲ្យបានសុខ ឲ្យបានឆ្អែតឆ្អំ នេះឈ្មោះថា សុខល្លិកានុយោគ ទី ១ ។ ម្នាលចុន្ទ មួយទៀត

---

១ សំដៅពួកមានលទ្ធិដទៃក្រៅព្រះពុទ្ធសាសនា ។

ឥធេកច្ចោ អទិន្នំ អាទិយិត្វា អត្តានំ សុខេតិ បីណេតិ អយំ ទុតិយោ សុខល្លិកានុយោគោ ។ បុន ចបរំ ចុន្ទ ឥធេកច្ចោ មុសា ភណិត្វា អត្តានំ សុខេតិ បីណេតិ អយំ តតិយោ សុខល្លិកានុយោគោ ។ បុន ចបរំ ចុន្ទ ឥធេកច្ចោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ(១) អយំ ចតុត្ថោ សុខល្លិកានុយោគោ ។ ឥមេ ខោ ចុន្ទ ចត្តារោ សុខល្លិកានុយោគា ហីនា គម្មា បោថុជ្ជនិកា អនរិយា អនត្ថសញ្ហិតា ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា

---

១ ឱ បរិភេតិ ។

បាសាទិកសូត្រ សុខល្លិកានុយោគ ៤ យ៉ាង

ជនពាលពួកខ្លះ ក្នុងលោកនេះ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ហើយធ្វើខ្លួនឲ្យបានសុខ ឲ្យបានធាត់ធំ នេះឈ្មោះថា សុខល្លិកានុយោគ ទី ២ ។ ម្នាលចុន្ទ មួយទៀត ជនពាលពួកខ្លះ ក្នុងលោកនេះ ពោលពាក្យមុសាវាទ ហើយធ្វើខ្លួនឲ្យបានសុខ ឲ្យបានធាត់ធំ នេះឈ្មោះថា សុខល្លិកានុយោគ ទី ៣ ។ ម្នាលចុន្ទ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកឆ្អែតស្កប់ស្កល់ បំរើដោយកាមគុណទាំង ៥ នេះឈ្មោះថា សុខល្លិកានុយោគ ទី ៤ ។ ម្នាលចុន្ទ សុខល្លិកានុយោគ ៤ យ៉ាងនេះឯង ជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ មិនមែនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីរលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងក្រៃលែង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមាន យ៉ាងនេះ គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ

ឯវំ វទេយ្យុំ(១) ឥមេ ចត្តារោ សុខល្លិកានុយោគេ អនុយុត្តា សមណា សក្យបុត្តិយា វិហរន្តីតិ ។ តេ វោ មា(២) ហេវន្តិស្សុ វចនីយា ន តេ វោ(៣) សម្មា វទមានា វទេយ្យុំ ន អព្ភាចិក្ខេយ្យុំ តេ វោ(៤) អសតា អភូតេន ។

(១១៥) ចត្តារោមេ ចុន្ទ សុខល្លិកានុយោគា ឯកន្តំ និព្វិទាយ(៥) វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ កតមេ ចត្តារោ ។ ឥធ ចុន្ទ(៦) ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ(៧) ឧបសម្បជ្ជ វិហរតិ អយំ បឋមោ សុខល្លិកានុយោគោ ។ បុន ចបរំ ចុន្ទ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ(៨) ឧបសម្បជ្ជ វិហរតិ អយំ ទុតិយោ សុខល្លិកានុយោគោ ។

---

១ ឱ. អញ្ញតិត្ថិយា ឯវំ បុច្ឆេយ្យុំ ។ ២ ឱ. តេ មា ។ ៣-៤ ឱ វោ តេ ។ ៥ ឱ.ម. ឯកន្តនិព្វិទាយ ។ ៦ ឱ.ម. ឥធ ចុន្ទ ភិក្ខុ ។ ៧ ឱ. បឋមជ្ឈានំ ។ ៨ ឱ. ទុតិយជ្ឈានំ ។

សមបីជានិយាយយ៉ាងនេះថា ពួកសមណសក្យបុត្តិយ៍ ជាអ្នកប្រកបរឿយៗ នូវសុខល្លិកានុយោគទាំង ៤ នេះ ។ អ្នកទាំងឡាយត្រូវនិយាយតបទៅនឹងពួកបរិព្វាជកនោះថា ពួកលោកកុំនិយាយយ៉ាងនោះ ឯពួកបរិព្វាជកទាំងនោះ មិនមែននិយាយ ដោយត្រឹមត្រូវនឹងពួកអ្នកទេ ពួកបរិព្វាជកទាំងនោះ មិនគប្បីបង្កាច់ពួកអ្នក ដោយពាក្យមិនមែន ដោយពាក្យមិនពិតទេ ។

[១១៨] ម្នាលចុន្ទ សុខល្លិកានុយោគនេះមាន ៤ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីសេចក្តីប្រាសចាករាគៈ ដើម្បីសេចក្តីរលត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងក្រៃលែង ដើម្បីសេចក្តីត្រាស់ដឹង ដើម្បីព្រះនិព្វានដោយពិត ។ សុខល្លិកានុយោគ ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលចុន្ទ ភិក្ខុក្នុងសាសនានេះ ស្ងាត់ស្រឡះចាកកាមទាំងឡាយ ស្ងាត់ស្រឡះចាកធម៌ទាំងឡាយ ជាអកុសល ដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈវិចារៈ មានបីតិនិងសុខៈដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ (ជាអារម្មណ៍) នេះឈ្មោះថា សុខល្លិកានុយោគ ទី ១ ។ ម្នាលចុន្ទ មួយទៀត ព្រោះសេចក្តីរម្ងាប់នូវវិតក្កៈនិងវិចារៈទាំងឡាយ ។ បេ ។ ភិក្ខុដល់នូវទុតិយជ្ឈាន នេះឈ្មោះថា សុខល្លិកានុយោគទី២ ។

បុន ចបរំ ចុន្ទ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ តតិយោ សុខល្លិកានុយោគោ ។ បុន ចបរំ ចុន្ទ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ សុខល្លិកានុយោគោ ។ ឥមេ ខោ ចុន្ទ ចត្តារោ សុខល្លិកានុយោគា ឯកន្តំ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ ឥមេ ខោ ចត្តារោ(១) សុខល្លិកានុយោគេ អនុយុត្តា សមណា សក្យបុត្តិយា វិហរន្តីតិ ។ តេ វោ ឯវន្តិស្សុ(២) វចនីយា សម្មា តេ វោ(៣) វទមានា វទេយ្យុំ ន តេ វោ(៤) អព្ភាចិក្ខេយ្យុំ អសតា អភូតេន ។

---

១ ឱ. ម. ឥមេ ចត្តារោ ។ ២ ឱ. តេ ឯវន្តិស្សុ ។ ៣-៤ ឱ. វោ តេ ។

## បាសាទិកសូត្រ សុខល្លិកានុយោគ ៤ យ៉ាង

ម្នាលចុន្ទ មួយទៀត ព្រោះនឿយណាយបាតបីតិ ។ បេ ។ ភិក្ខុដល់នូវតតិយជ្ឈាន នេះឈ្មោះថា សុខល្លិកានុយោគ ទី ៣ ។ ម្នាលចុន្ទ មួយទៀត ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។ បេ ។ ភិក្ខុដល់នូវចតុត្ថជ្ឈាន នេះឈ្មោះថា សុខល្លិកានុយោគ ទី ៤ ។ ម្នាលចុន្ទ សុខល្លិកានុយោគទាំង ៤ យ៉ាងនេះឯង ទើបប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ ដើម្បីសេចក្ដីប្រាសចាករាគៈ ដើម្បីសេចក្ដីរលត់ទុក្ខ ដើម្បីសេចក្ដីរម្ងាប់ ដើម្បីសេចក្ដីដឹងក្រៃលែង ដើម្បីសេចក្ដីត្រាស់ដឹង ដើម្បីព្រះនិព្វាន ដោយចំណែកមួយ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមាន យ៉ាងនេះ គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ សមជានិយាយយ៉ាងនេះថា ពួកសមណៈជាសក្យបុត្តិយ៍ ជាអ្នកប្រកបរឿយ ៗ នូវសុខល្លិកានុយោគទាំង ៤ យ៉ាងនេះឯង ។ ពួកអ្នកទាំងឡាយ គួរនិយាយទៅ នឹងពួកបរិព្វាជកទាំងនោះថា យ៉ាងហ្នឹងហើយ ពួកគេកាលនិយាយឲ្យអ្នកទាំងឡាយ ឈ្មោះថា និយាយដោយត្រូវ ពួកគេមិនមែននិយាយបង្កាច់អ្នកទាំងឡាយ ដោយមិនមានមែន ដោយមិនពិតទេ ។

## សុត្តន្តបិដកេ ទីឃនិកាយស្ស បាដិកវគ្គោ

(១១៦) ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ ឥមេ បនាវុសោ ចត្តារោ សុខល្លិកានុយោគេ អនុយុត្តានំ វិហរតំ កតិ ផលានិ កតានិសំសា បាដិកង្ខាតិ ។ ឯវំវាទិនោ ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ឥមេ ខោ អាវុសោ ចត្តារោ សុខល្លិកានុយោគេ អនុយុត្តានំ វិហរតំ ចត្តារិ ផលានិ ចត្តារោ អានិសំសា បាដិកង្ខា ។ កតមេ ចត្តារោ ។ ឥធាវុសោ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោ ឥទំ បឋមំ ផលំ បឋមោ អានិសំសោ ។ បុន ចបរំ អាវុសោ ភិក្ខុ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ឥទំ ទុតិយំ ផលំ ទុតិយោ អានិសំសោ ។ បុន ចបរំ អាវុសោ ភិក្ខុ

(១១៦) ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ សមបីជានិយាយយ៉ាងនេះថា ម្នាលអាវុសោ ផលប៉ុន្មានយ៉ាង អានិសង្សប៉ុន្មានយ៉ាង រមែងប្រាកដដល់បុគ្គលអ្នកប្រកបរឿយ ៗ នូវសុខល្លិកានុយោគទាំង ៤ យ៉ាងនេះ ។ ម្នាលចុន្ទ ពួកបរិព្វាជក ជាអន្យតិរ្ថិយនិយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ផល ៤ យ៉ាង អានិសង្ស ៤ យ៉ាង រមែងប្រា-កដ ដល់ពួកបុគ្គលអ្នកប្រកបរឿយៗ នូវសុខល្លិកានុយោគទាំង ៤ យ៉ាងនេះឯង ។ ផលនឹងអានិសង្សទាំង ៤ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលអាវុសោ ភិក្ខុក្នុងធម្មវិន័យនេះ ជាសោតាបន្នបុគ្គល មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងទាត់ មានសេចក្តីត្រាស់ដឹង ប្រព្រឹត្តទៅខាងមុខ ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ នេះជាផលទី ១ ជាអានិ-សង្សទី ១ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ ទាំងស្រាលស្តើងរាគៈ ទោសៈ នឹងមោហៈ មកកាន់លោកនេះម្តងទៀត រមែងធ្វើនូវទីបំផុតនៃទុក្ខបាន នេះជាផលទី ២ ជាអានិសង្សទី ២ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានកំណើត

## បាសាទិកសុត្តេ ចត្តារោ សុខល្លិកានុយោគានិសំសា

បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ឥទំ តតិយំ ផលំ តតិយោ អានិសំសោ ។ បុន ចបរំ អាវុសោ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឥទំ ចតុត្ថំ ផលំ ចតុត្ថោ អានិសំសោ ។ ឥមេ ខោ អាវុសោ សុខល្លិកានុយោគេ អនុយុត្តានំ វិហរតំ ឥមានិ ចត្តារិ ផលានិ ចត្តារោ អានិសំសា បាដិកង្ខាតិ ។

ជាឧបបាតិកៈ (អនាគាមិបុគ្គល) តែងបរិនិព្វានក្នុងភពនោះ មានកិរិយាមិនត្រឡប់ចាកលោកនោះ ជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈជាបំណែកខាងក្រោម ៥ នេះជាផលទី ៣ ជាអានិសង្សទី ៣ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ(១) ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួន ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ រមែងសម្រេចសម្រាន្តនៅដោយឥរិយាបថ នេះជាផលទី ៤ ជាអានិសង្សទី ៤ ។ ម្នាលអាវុសោ ផលទាំង ៤ នេះ អានិសង្សទាំង ៤ នេះ រមែងប្រាកដដល់ពួកភិក្ខុអ្នកប្រកបរឿយ ៗ នូវសុខល្លិកានុយោគ ទាំងនេះឯង ។

---

១ ចេតោវិមុត្តិ សេចក្ដីរួចចាកកិលេសដោយអំណាចចិត្ត គឺវិមុត្តិមានសមាធិជាបទដ្ឋាន សំដៅយកវិមុត្តិរបស់ព្រះអរិយៈដែលបានសម្រេចអរូបជ្ឈានណាមួយរួចហើយ ទើបបំពេញវិបស្សនាជាក្រោយ ។ បញ្ញាវិមុត្តិ សេចក្ដីរួចដោយអំណាចបញ្ញា គឺវិមុត្តិសម្រេចដោយការបំពេញតែវិបស្សនាសុទ្ធ ឬបានត្រឹមរូបជ្ឈានណាមួយ ហើយក៏សម្រេចមគ្គផល សំដៅយកវិមុត្តិរបស់ពួកព្រះអរិយៈ បែកខាងសុក្ខវិបស្សកៈ ។ ក្នុងទីខ្លះ លោកថាជាឈ្មោះអរហត្តផលជាមួយគ្នា គឺចេតោវិមុត្តិ សំដៅដល់ការផុតចាករាគៈ បញ្ញាវិមុត្តិ ការផុតចាកអវិជ្ជា ។ ក្នុងបរមត្ថទីបនី អដ្ឋកថាអភិធម្ម បញ្ជាក់ថា សុក្ខវិបស្សកៈ ហៅបានតាំងពីព្រះស្រោតាឡើងទៅ ។ ក្នុងសូត្រនេះ មានបន្ថែមពាក្យថា មិនមានអាសវៈ បន្ទាប់នឹងចេតោវិមុត្តិ បញ្ញាវិមុត្តិផង នាំឲ្យយល់ថា វិមុត្តិទាំងពីរនេះ គង់ហៅបាន តាំងពីស្រោតាឡើងទៅដែរ ។

[១១៧] ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ អដ្ឋិតធម្មា សមណា សក្យបុត្តិយា វិហរន្តីតិ ។ ឯវំវាទិនោ ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា អត្ថិ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សាវកានំ ធម្មា ទេសិតា បញ្ញត្តា យាវជីវំ អនតិក្កមនីយា ។ សេយ្យថាបិ អាវុសោ ឥន្ទខីលោ វា អយោខីលោ វា គម្ភីរនេមោ សុនិក្ខិត្តោ[១] អចលោ អសម្បវេធី ឯវមេវ ខោ អាវុសោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សាវកានំ ធម្មា ទេសិតា បញ្ញត្តា យាវជីវំ អនតិក្កមនីយា ។ យោ សោ អាវុសោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ

---

១ ឱ. ម. សុនិខាតោ ។

[១១៧] ម្នាលចុន្ទ ហេតុជាទីតាំង រមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ពួកសមណៈជាសក្យបុត្តិយ៍ ជាបុគ្គលមានសភាពមិនឋិតថេរ ។ ម្នាលចុន្ទ ពួកបរិព្វាជកជាអន្យ-តិរ្ថិយ និយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងឡាយដែលព្រះមានព្រះភាគ ព្រះអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធ សំដែងហើយ បញ្ញត្តហើយ ដល់សាវ័កទាំងឡាយ ជាធម៌ដែលពួកសាវ័ក មិនត្រូវប្រព្រឹត្តកន្លងដរាបដល់អស់ជីវិត (នោះ) រមែងមានពិត ។ ម្នាលអាវុសោ សសរគោល ឬសសរដែក ដែលលិចទៅក្នុងដីដ៏ជ្រៅ ដែលបុគ្គលដាំហើយដោយល្អ មិនកម្រើក មិនញ័រយ៉ាងណាមិញ ម្នាលអាវុសោ ធម៌ទាំងឡាយដែលព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធ សំដែងហើយ បញ្ញត្តហើយ ដល់សាវ័កទាំងឡាយជាធម៌ដែលពួកសាវ័ក មិនត្រូវប្រព្រឹត្តកន្លង ដរាបដល់អស់ជីវិត យ៉ាងនោះឯង ។ ម្នាលអាវុសោ ភិក្ខុណា ជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយ-ធម៌ចប់ស្រេចហើយ មានកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មាន

អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោ អភព្វោ សោ នវ ឋានានិ អជ្ឈាចរិតុំ ។ អភព្វោ អាវុសោ ខីណាសវោ ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេតុំ អភព្វោ ខីណាសវោ ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ អាទិយិតុំ(១) អភព្វោ ខីណាសវោ ភិក្ខុ មេថុនំ ធម្មំ បដិសេវិតុំ អភព្វោ ខីណាសវោ ភិក្ខុ សម្បជានមុសាវាទំ ភាសិតុំ អភព្វោ ខីណាសវោ ភិក្ខុ សន្និធិការកកាមេ បរិភុញ្ជិតុំ សេយ្យថាបិ បុព្វេ អាគារិកភូតោ(២) អភព្វោ ខីណាសវោ ភិក្ខុ ឆន្ទាគតឹ គន្តុំ អភព្វោ ខីណាសវោ ភិក្ខុ ទោសាគតឹ គន្តុំ អភព្វោ ខីណាសវោ ភិក្ខុ មោហាគតឹ គន្តុំ អភព្វោ ខីណាសវោ ភិក្ខុ ភយាគតឹ គន្តុំ ។ យោ សោ អាវុសោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ

---

១ ឱ. អាទាតុំ ។ ២ ឱ. អគារិយភូតោ ។ ម. អគារិកភូតោ ។

ប្រយោជន៍ដល់ហើយ ដោយលំដាប់ មានសំយោជនៈក្នុងភពអស់រលីង ហើយ ជាអ្នកផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ ឈប់ប្រព្រឹត្តកន្លងនូវហេតុទាំងឡាយ ៩ យ៉ាង ។ ម្នាលអាវុសោ ភិក្ខុជាខីណាសវៈ ឈប់ក្លែងផ្តាច់បង់សត្វចាកជីវិត(១) ភិក្ខុជាខីណាសវៈ ឈប់កាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដែលហៅថា លួច(២) ភិក្ខុជាខីណាសវៈ ឈប់សេពនូវមេថុនធម្ម(៣) ភិក្ខុជាខីណាសវៈ ឈប់ពោលពាក្យមុសាវាទ ដោយដឹងខ្លួន(៤) ភិក្ខុជាខីណាសវៈ ឈប់បរិភោគ នូវកាមដែលជាសន្និធិការកៈ(៥)ទាំងឡាយ ដូចកាលដែលខ្លួន នៅជាគ្រហស្ថពីមុន(៦) ភិក្ខុជាខីណាសវៈ ឈប់លុះឆន្ទាគតិ(៧) ភិក្ខុជាខីណាសវៈ ឈប់លុះទោសាគតិ(៨) ភិក្ខុជាខីណាសវៈ ឈប់លុះមោហាគតិ(៩) ភិក្ខុជាខីណាសវៈ ឈប់លុះភយាគតិ(១០) ។ ម្នាលអាវុសោ ភិក្ខុណាជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ ចប់ស្រេចហើយ មានកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ដល់ហើយដោយលំដាប់

---

១ ។ល។ ១០ អដ្ឋកថា សំដៅយកការបរិភោគវត្ថុកាម គឺកាមគុណ ៥ មានរូបជាដើម និងកិលេសកាម គឺកិលេសជាហេតុឲ្យប្រាថ្នានូវរូបជាដើម ដែលខ្លួនបានធ្វើការសន្សំមករួចហើយ ។

បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ អភព្វោ ខោ(១) សោ ឥមានិ នវ ឋានានិ អជ្ឈាចរិត្តុំ(២) ។

[១១៨] ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ អតីតំ ខោ អទ្ធានំ អារព្ភ សមណោ គោតមោ អតីរកំ(៣) ញាណទស្សនំ បញ្ញាបេតិ នោ ច ខោ អនាគតំ អទ្ធានំ អារព្ភ អតីរកំ(៤) ញាណទស្សនំ បញ្ញាបេតិ តយិទំ កឹសុ តយិទំ កថំសូតិ ។ តេ ច(៥) អញ្ញតិត្ថិយា បរិព្វាជកា អញ្ញវិហិតកេន(៦) ញាណទស្សនេន អញ្ញវិហិតំ ញាណទស្សនំ(៧) បញ្ញាបេតព្វំ មញ្ញន្តិ យថយិទំ ពាលា អព្យត្តា ។ អតីតំ ខោ ចុន្ទ អទ្ធានំ អារព្ភ តថាគតស្ស សតានុសារិវិញ្ញាណំ(៨) ហោតិ សោ យាវតកំ អាកង្ខតិ តាវតកំ អនុស្សរតិ អនាគតញ្ច ខោ អទ្ធានំ អារព្ភ តថាគតស្ស ពោធិជំ ញាណំ ឧប្បជ្ជតិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

---

១ ឱ. ម. ខោសព្វោ ន វិស្សតិ ។ ២ ម. អជ្ឈាចរិតុំ ។ ៣-៤ ម. អតិរេកំ ។ ៥ ឱ. តេ នេវ ។ ៦ ឱ. អញ្ញវិហិតកេន ។ ៧ ឱ. ម. ញាណទស្សនំ ។ ៨ ឱ. សតានុសារិវិញ្ញាណំ ។

មានសញ្ញោជនៈប្រព្រឹត្តទៅ កន្លងពអស់ហើយ ជាអ្នកផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះឈប់ប្រព្រឹត្តកន្លង នូវហេតុទាំង ៩ យ៉ាង នេះឯង ។

[១៩៨] ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ព្រះសមណគោតម រមែងបញ្ញត្តញាណទស្សនៈដ៏លើសលុប ព្រោះប្រារព្ធនូវអតីតកាល ប៉ុណ្ណោះ មិនបញ្ញត្តញាណទស្សនៈដ៏លើសលុប ព្រោះប្រារព្ធនូវកាល ជាអនាគតឡើយ ការមិនបញ្ញត្តិនោះព្រោះហេតុអ្វី ការមិនបញ្ញត្តិដូច្នោះ ព្រោះហេតុដូចម្តេច ។ ឯពួកបរិព្វាជកជាអន្យតិរ្ថិយដទៃនោះ រមែងសំគាល់នូវពាក្យដែលគួរបញ្ញត្ត នូវហេតុមិនមែនជាញាណទស្សនៈ ដែលឃ្លាំងទៅកាន់ទីដទៃ ដោយញាណទស្សនៈ ដែលបែរទៅកាន់ទីដទៃ ប្រៀបដូចជាពួកជនពាលជាអ្នកមិនវាងវៃដូច្នោះឯង ។ ម្នាលចុន្ទ តថាគត រមែងមានសតានុសារិញ្ញាណ(១) ប្រារព្ធតែកាលដែលកន្លងទៅហើយ តថាគតនោះប្រាថ្នាហេតុ មានប្រមាណណា ក៏នឹកតាមនូវហេតុ មានប្រមាណប៉ុណ្ណោះបាន ឯញាណដែលកើតអំពីការត្រាស់ដឹង ប្រារព្ធកាលជាអនាគតក៏កើតឡើងដល់តថាគតថា ឥឡូវនេះ ជាតិនេះ ជាជាតិទីបំផុតហើយ ការកើតតទៅទៀត មិនមានទេ ។

១ អដ្ឋកថា ថា ញាណដែលសម្បយុត្តដោយបុព្វេនិវាសានុស្សតិ ។

## បាសាទិកសុត្តេ ព្យាកតាព្យាកតបញ្ហា

(១០៩) អតីតញ្ចេបិ(១) ចុន្ទ ហោតិ អភូតំ អតច្ឆំ អនត្ថសញ្ហិតំ ន តំ តថាគតោ ព្យាករោតិ ។ អតីតញ្ចេបិ(២) ខោ ចុន្ទ ហោតិ ភូតំ តច្ឆំ អនត្ថសញ្ហិតំ តំ បិ តថាគតោ ន ព្យាករោតិ ។ អតីតញ្ចេបិ(៣) ខោ ចុន្ទ ហោតិ ភូតំ តច្ឆំ អត្ថសញ្ហិតំ តត្រ កាលញ្ញូ តថាគតោ ហោតិ(៤) តស្ស បញ្ហស្ស វេយ្យាករណាយ ។ អនាគតញ្ចេបិ(៥) ចុន្ទ ហោតិ ។ បេ ។ បច្ចុប្បន្នំ ខោ ចេបិ ចុន្ទ ហោតិ អភូតំ អតច្ឆំ អនត្ថសញ្ហិតំ ន តំ តថាគតោ ព្យាករោតិ ។ បច្ចុប្បន្នំ ចេបិ ចុន្ទ ហោតិ ភូតំ តច្ឆំ អនត្ថសញ្ហិតំ តំបិ តថាគតោ ន ព្យាករោតិ ។ បច្ចុប្បន្នំបិ ចេ(៦) ចុន្ទ ហោតិ ភូតំ តច្ឆំ អត្ថសញ្ហិតំ តត្រ កាលញ្ញូ តថាគតោ ហោតិ តស្ស បញ្ហស្ស វេយ្យាករណាយ ។ ឥតិ ខោ ចុន្ទ អតីតានាគតបច្ចុប្បន្នេសុ ធម្មេសុ តថាគតោ កាលវាទី សច្ចវាទី(៧) ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី តស្មា តថាគតោតិ វុច្ចតិ ។

---

១ ម. អតីតំ ចេបិ ។ ២-៣ ឱ. ម. អតីតំ ចេបិ ។ ៤ ឱ. កាលញ្ញូ ហោតិ តថាគតោ ។ ៥ ម. អនាគតំ ចេបិ ។ ៦ ឱ. ម. ចេបិ ។ ៧ ឱ. ម. សច្ចវាទីតិ ន ទិស្សតិ ។

(១១៩) ម្នាលចុន្ទ បើពាក្យដែលកន្លងហើយមិនពិត មិនមែន មិនប្រកបដោយប្រយោជន៍ តថាគតមិនព្យាករពាក្យនោះទេ ។ ម្នាលចុន្ទ បើពាក្យដែលកន្លងហើយ ជាពាក្យពិតប្រាកដ ( តែ ) មិនប្រកបដោយប្រយោជន៍ តថាគតក៏មិនព្យាករពាក្យនោះដែរ ។ ម្នាលចុន្ទ ប្រសិនបើពាក្យដែលកន្លងហើយ ជាពាក្យពិតប្រាកដ ប្រកបដោយប្រយោជន៍ តថាគតជាអ្នកដឹងកាលគួរ ក្នុងពាក្យនោះ ទើបព្យាករប្រស្នានោះ ។ ម្នាលចុន្ទ បើពាក្យជាអនាគត ។ បេ ។ ម្នាលចុន្ទ បើពាក្យជាបច្ចុប្បន្ន មិនពិត មិនមែន មិនប្រកបដោយប្រយោជន៍ តថាគត រមែងមិនព្យាករពាក្យនោះទេ ។ ម្នាលចុន្ទ បើពាក្យជាបច្ចុប្បន្នដែលពិតមែន ( តែ ) មិនប្រកបដោយប្រយោជន៍ តថាគតរមែងមិនព្យាករពាក្យនោះទេ ។ ម្នាលចុន្ទ តែបើពាក្យជាបច្ចុប្បន្ន ដែលពិតមែន ប្រកបដោយប្រយោជន៍ តថាគតជាអ្នកដឹងកាលគួរ ក្នុងពាក្យនោះ ទើបព្យាករនូវប្រស្នានោះ ។ ម្នាលចុន្ទ តថាគតតែងនិយាយក្នុងកាលគួរ និយាយតែពាក្យសច្ចៈ និយាយតែពាក្យពិត និយាយតែពាក្យជាប្រយោជន៍ និយាយតែពាក្យជាធម៌ និយាយតែពាក្យជាវិន័យ ក្នុងធម៌ទាំងឡាយ ដែលជាអតីតអនាគតនិងបច្ចុប្បន្ន ព្រោះហេតុនោះ បានជាហៅថា ព្រះតថាគត ដោយប្រការ ដូច្នេះឯង ។

[១២០] យត្ថ ខោ(១) ចុន្ទ សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បត្តំ បរិយេសិតំ អនុវិចរិតំ មនសា សព្វំ តថាគតេន អភិសម្ពុទ្ធំ តស្មា តថាគតោតិ វុច្ចតិ ។ យញ្ច ចុន្ទ រត្តឹ តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ យញ្ច រត្តឹ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយតិ យំ ឯតស្មឹ អន្តរេ(២) ភាសតិ លបតិ និទ្ទិសតិ សព្វំ តថេវ ន ហោតិ(៣) នោ អញ្ញថាតិ(៤) តស្មា តថាគតោតិ វុច្ចតិ ។ យថាវាទី ចុន្ទ តថាគតោ តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី វា(៥)

---

១ ឱ. យំ ខោ ។ ២ ឱ. ម អន្តរេ ។ ៣ ឱ. ម. សព្វំ តំ តថេវ ហោតិ ។ ៤ ឱ. ម អញ្ញថា ។ ៥ ឱ. ម. វាសទ្ទោ ន ទិស្សតិ ។

(១៨០) ម្នាលចុន្ទ របស់ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ទាំងពពួកសត្វព្រមទាំងសមណៈ និងព្រាហ្មណ៍ និងមនុស្សដែលជាសម្មតិទេព បានឃើញហើយ បានឮហើយ បានលិទ្ធភ្លក្សហើយ បានដឹងច្បាស់ហើយ បានដល់ហើយ បានស្វែងរកហើយ បានជ្រើសរើសហើយដោយចិត្ត (របស់នោះ) តថាគតត្រាស់ដឹងហើយដោយប្រពៃ ហេតុដូច្នោះបានជាគេហៅថា ព្រះតថាគត ។ ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិប្រសើរ ក្នុងវេលាយប់ណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងវេលាយប់ណាផង រមែងសំដែងហៅចង្អុលបង្ហាញ នូវហេតុណា ក្នុងចន្លោះនុះ ហេតុទាំងអស់នោះ សុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះហើយ បានជាគេហៅថា ព្រះតថាគត ។ ម្នាលចុន្ទ តថាគតនិយាយយ៉ាងណា តែងធ្វើយ៉ាងនោះ ធ្វើយ៉ាងណា តែងនិយាយយ៉ាងនោះ ព្រោះតែតថាគតនិយាយយ៉ាងណា តែងធ្វើយ៉ាងនោះ ធ្វើយ៉ាងណា

តស្មា តថាគតោតិ វុច្ចតិ ។ យំ[១] សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ តថាគតោ អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី តស្មា តថាគតោតិ វុច្ចតិ ។

(១២១) ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កឹ នុ ខោ អាវុសោ ហោតិ តថាគតោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឯវំវាទិនោ ខោ[២] ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា អព្យាកតំ ខោ អាវុសោ ភគវតា ហោតិ តថាគតោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កឹ បនាវុសោ ន ហោតិ តថាគតោ បរំ មរណា ឥទមេវ សច្ចំ

---

១ ឱ. ម. យត្តិ ឥត្ថិ ។ ២ ឱ. ម. ពោសន្ទោ ឥត្ថិ ។

តែងនិយាយយ៉ាងនោះ ហេតុដូច្នោះហើយ បានជាគេហៅថា ព្រះតថា-
គត ។ តថាគតជាអ្នកលើសលុប មិនមានបុគ្គលដទៃគ្របសង្កត់បាន ជា
អ្នកបង្អុលបង្ហាញនូវហេតុដ៏ពិត ជាអ្នកផ្សាយនូវអំណាចទៅ ក្នុងលោក
ព្រមទាំងទេវលោក ព្រមទាំងមារលោក ព្រមទាំងព្រហ្មលោក ព្រមទាំង
សមណព្រាហ្មណ៍ នឹងពពួកសត្វ ព្រមទាំងមនុស្ស ជាសម្មតិទេព
ព្រោះហេតុនោះ បានជាគេហៅថា ព្រះតថាគត ។

(១២១) ម្នាលចុន្ទ ហេតុជាទីតាំង រមែងមានយ៉ាងនេះ គឺពួក
បរិព្វាជក ជាអន្យតិរិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខ
អំពីសេចក្តីស្លាប់ទៅ សត្វនឹងកើតទៀត ឬហ្ន៎ ការយល់ឃើញនេះឯង
ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេឬ ។ ម្នាល
ចុន្ទ (កាលបើ) ពួកបរិព្វាជក ជាអន្យតិរិយ និយាយយ៉ាងនេះហើយ
អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគ មិនដែល
សំដែងថា ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វគង់កើតទៀត ការយល់
នេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេដូច្នេះ
ទេ ។ ម្នាលចុន្ទ ហេតុជាទីតាំង រមែងមានយ៉ាងនេះ គឺពួកបរិព្វាជក
ជាអន្យតិរិ និយាយយ៉ាងនេះថា ម្នាលចុន្ទ ខាងមុខអំពីសេចក្តី
ស្លាប់ទៅ សត្វមិនកើតទៀតឬហ្ន៎ ការយល់ឃើញនេះឯង ជាការពិត

មោឃមញ្ញន្តិ ។ ឯវំវាទិនោ ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ឯតំបិ (១) ខោ អាវុសោ ភគវតា អព្យាកតំ ន ហោតិ តថាគតោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កឹ បនាវុសោ (២) ហោតិ ច ន ច ហោតិ (៣) តថាគតោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឯវំវាទិនោ ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា អព្យាកតំ ខោ បនេតំ អាវុសោ ភគវតា ហោតិ ច ន ច ហោតិ តថាគតោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ

---

១ ម. ឯវំបិ ។ ២ ឱ. កឹ នុ ខោ អាវុសោ ។ ៣ ឱ. ច ន ហោតិ ច ។

ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេឬ ។ ម្នាលចុន្ទ (កាលបើ) ពួកបរិព្វាជក ជាអន្យតិរ្ថិយដទៃ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពាក្យនុ៎ះឯង ព្រះមានព្រះភាគ មិនព្យាករថា ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វមិនកើតទៀត ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះទេ ។ ម្នាលចុន្ទ ហេតុជាទីតាំង រមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះ ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ឬហ្ន៎ ។ ម្នាលចុន្ទ (កាលបើ) ពួកបរិព្វាជក ជាអន្យតិរ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពាក្យនុ៎ះឯង ព្រះមានព្រះភាគ មិនព្យាករថា ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះ ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះទេ ។ ម្នាលចុន្ទ ហេតុជាទីតាំង រមែងមានយ៉ាងនេះ

យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កឹ បនាវុសោ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឯវំវាទិនោ ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ឯតំបិ ខោ អាវុសោ ភគវតា អព្យាកតំ នេវ ហោតិ ន ន ហោតិ តថាគតោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

(១២២) ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កស្មា បនេតំ អាវុសោ សមណេន គោតមេន អព្យាកតន្តិ ។ ឯវំវាទិនោ ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា ន ហេតំ អាវុសោ អត្ថសញ្ហិតំ ន ធម្មសញ្ហិតំ ន អាទិព្រហ្មចរិយកំ ន និព្វិទាយ ន វិរាគាយ

គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេម្ល៎ា ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពាក្យនុ៎ះឯង ព្រះមានព្រះភាគ មិនព្យាករថា ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះទេ ។

(១២២) ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាព្រះសមណគោតម មិនព្យាករពាក្យនុ៎ះ ។ ម្នាលចុន្ទ (កាលបើ) ពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះថា ពាក្យនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនប្រកបដោយធម៌ មិនមែនជាដើមចមនៃសាសនព្រហ្មចារ្យ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាសចាករាគៈ

ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ តស្មា តំ ភគវតា អព្យាកតន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កឹ បនាវុសោ សមណេន គោតមេន ព្យាកតន្តិ ។ ឯវំវាទិនោ ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា ឯវមស្សុ វចនីយា(១) ឥទំ ទុក្ខន្តិ ខោ អាវុសោ ភគវតា ព្យាកតំ អយំ ទុក្ខសមុទយោតិ ខោ អាវុសោ ភគវតា ព្យាកតំ អយំ ទុក្ខនិរោធោតិ ខោ អាវុសោ ភគវតា ព្យាកតំ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ ខោ អាវុសោ ភគវតា ព្យាកតន្តិ ។ ឋានំ ខោ បនេតំ ចុន្ទ វិជ្ជតិ យំ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ វទេយ្យុំ កស្មា បនេតំ អាវុសោ សមណេន គោតមេន ព្យាកតន្តិ ។ ឯវំវាទិនោ ខោ(២) ចុន្ទ អញ្ញតិត្ថិយា បរិព្វាជកា

---

១ ឱ. វចនីយោ ។ ២ ឱ. ម. ខោសទ្ទោ ន ទិស្សតិ ។

មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីរលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងក្រៃលែង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ព្រោះហេតុនោះហើយ បានជាព្រះមានព្រះភាគ មិនព្យាករពាក្យនោះឡើយ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺ ពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ចុះព្រះសមណគោតម ព្យាករដូចម្តេចទៅវិញ ។ ម្នាលចុន្ទ (កាលបើ) ពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខដូច្នេះ ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខសមុទ័យដូច្នេះ ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខនិរោធដូច្នេះ ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខនិរោធគាមិនី បដិបទាដូច្នេះ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺ ពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះហេតុអ្វី បានជាព្រះសមណគោតម ព្យាករពាក្យនុ៎ះ ។ ម្នាលចុន្ទ (កាលបើ) ពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះហើយ

ឯវមស្សុ វចនីយា ឯតញ្ហិ អាវុសោ អត្ថសញ្ហិតំ ធម្មសញ្ហិតំ[1] ឯតំ អាទិព្រហ្មចរិយកំ ឯកន្តំ និព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ តស្មា តំ ភគវតា ព្យាកតន្តិ ។

(១២៣) យេបិ តេ ចុន្ទ បុព្វន្តសហគតា ទិដ្ឋិនិស្សយា តេបិ ខោ[2] មយា ព្យាកតា យថា តេ ព្យាកាតព្វា[3] យថា ច[4] តេ ន ព្យាកាតព្វា កឹ តេ អហន្តេ អញ្ញតិត្ថិយេ តត្ថ ព្យាករិស្សាមិ[5] ។ យេបិ តេ ចុន្ទ អបរន្តសហគតា ទិដ្ឋិនិស្សយា តេបិ តេ[6] មយា ព្យាកតា យថា តេ ព្យាកាតព្វា យថា ច តេ ន ព្យាកាតព្វា

---

១ ឱ. ឯតំ ធម្មសំហិតំ ។ ២ ឱ. ម. វោ ។ ៣ ឱ. វ្យាកត្តព្វា ។ ៤ ឱ. ប ខោ ។
៥ ឱ កឹ នោ អហំ តថា វ្យាករិស្សាមិ ។ ម. កឹ វោ អហំ តេ តត្ថ ព្យាករិស្សាមិ ។
៦ ឱ. ម. វោ ។

អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះថា ពាក្យនុ៎ះជាពាក្យប្រកបដោយប្រយោជន៍ ប្រកបដោយធម៌ ពាក្យនុ៎ះជាដើមចមនៃសាសនព្រហ្មចារ្យ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ ប្រព្រឹត្តទៅ ដើម្បីសេចក្តីរំលត់ទុក្ខ ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងក្រៃលែង ប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានដោយពិត ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រង់ព្យាករពាក្យនោះ ។

(១២៣) ម្នាលចុន្ទ ទិដ្ឋិនិស្ស័យ(១)ទាំងឡាយណា ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងដើម តថាគតក៏បានសំដែងនូវទិដ្ឋិនិស្ស័យទាំងឡាយនោះ ដល់អ្នកហើយ តថាគតត្រូវសំដែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា មួយវិញទៀត តថាគតមិនត្រូវសំដែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា តថាគតនឹងសំដែងនូវទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នក បំពោះពួកអន្យតិរ្ថិយដទៃ ក្នុងហេតុនោះ ដូចម្តេចកើត ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណា ដែលប្រព្រឹត្តទៅ ក្នុងខាងមុខ តថាគតក៏បានសំដែងនូវទិដ្ឋិនិស្ស័យទាំងនោះ ដល់អ្នកហើយ តថាគតត្រូវសំដែង នូវទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា មួយវិញទៀត តថាគតមិនត្រូវសំដែងទិដ្ឋិ

---

១ ពាក្យថា ទិដ្ឋិនិស្ស័យ ទិដ្ឋិនិស្សិតក ទិដ្ឋិគតិក ក៏សំដៅយកតែតួទិដ្ឋិដូចគ្នា (អដ្ឋកថា) ។

កឹ វោ អហំ តេ ន តត្ថ(១) ព្យាករិស្សាមិ ។ ការណមេ តេ ចុន្ទ បុព្វន្តសហាគតា ទិដ្ឋិនិស្សយា យេ តេ មយា ព្យាកតា យថា តេ ព្យាកាតព្វា យថា ច តេ ន ព្យាកាតព្វា ។ សន្តិ ចុន្ទ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ បន ចុន្ទ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ អត្តា ច លោកោ ច ។ សន្ខិត្តិំ ។ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ច ។ នេវសស្សតោ ច(២) នាសស្សតោ ច(៣) អត្តា ច លោកោ ច ។ សយង្កតោ អត្តា ច លោកោ ច ។ បរង្កតោ អត្តា ច លោកោ ច ។ សយង្កតោ ច បរង្កតោ ច អត្តា ច លោកោ ច ។ អសយង្ការោ ច(៤) អបរង្ការោ ច(៥) អធិច្ចសមុប្បន្នោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សស្សតំ សុខទុក្ខំ ។

---

១ ឱ. កឹ ភោ អហំ តេ តថា ។ ម. កឹ ភោ អហំ តេ ន តត្ថ ។ ២-៣-៤-៥ ឱ. ម. បាឋោ ន ទិស្សតិ ។

និស្ស័យទាំងនោះយ៉ាងណា តថាគតនឹងមិនសំដែងទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នក ក្នុងហេតុនោះទេ ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណា ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងដើម តថាគតសំដែងនូវទិដ្ឋិនិស្ស័យទាំងឡាយនោះហើយ តថាគតត្រូវសំដែងនូវទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា មួយវិញទៀត មិនត្រូវសំដែងទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា ទិដ្ឋិនិស្ស័យទាំងនោះ តើដូចម្តេច ។ ម្នាលចុន្ទ មានសមណៈនិងព្រាហ្មណ៍មួយពួក ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខ្លួននឹងលោកជាសភាវៈទៀង ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ។ ម្នាលចុន្ទ មួយទៀត រមែងមានសមណៈនិងព្រាហ្មណ៍មួយពួក ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខ្លួននឹងលោកជាសភាវៈមិនទៀង ។ សេចក្តីសង្ខេប ។ ខ្លួននឹងលោកជាសភាវៈទៀងក៏មាន មិនទៀងក៏មាន ។ ខ្លួននឹងលោក ជាសភាវៈទៀងក៏មិនមែន មិនទៀងក៏មិនមែន ។ ខ្លួននឹងលោក គឺខ្លួនឯងធ្វើ ។ ខ្លួននឹងលោក គឺអ្នកដទៃធ្វើ ។ ខ្លួននឹងលោក គឺខ្លួនឯងធ្វើក៏មាន អ្នកដទៃធ្វើក៏មាន ។ ខ្លួននឹងលោក គឺខ្លួនឯងធ្វើក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន គឺកើតឡើងដោយឥតហេតុ ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទេ ។ សុខនឹងទុក្ខ ជាធម្មជាតទៀង ។

## ពាសាទិកសុត្ត សមណព្រាហ្មណានំ អធិប្បញ្ញត្តិ

អសស្សតំ សុខទុក្ខំ ។ សស្សតញ្ច អសស្សតញ្ច សុខទុក្ខំ ។ នេវសស្សតំ នាសស្សតំ សុខទុក្ខំ ។ សយង្កតំ សុខទុក្ខំ ។ បរង្កតំ សុខទុក្ខំ ។ សយញ្ចកតំ បរង្កតញ្ច(១) សុខទុក្ខំ ។ អសយង្ការំ អបរង្ការំ អធិច្ចសមុប្បន្នំ សុខទុក្ខំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

(១៨៤) តត្ថ(២) ចុន្ទ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ អត្ថិ នុ ខោ ឥទំ អាវុសោ វុច្ចតិ សស្សតោ អត្តា ច លោកោ ចាតិ ។ យញ្ច ខោ តេ ឯវមាហំសុ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តំ តេសំ នានុជានាមិ ។ តំ កិស្ស ហេតុ ។

---

១ ឱ. ម. សយំ កតញ្ច បរំ កតញ្ច ។ ២ ឱ. ម. តត្រ ។

សុខនឹងទុក្ខ ជាធម្មជាតមិនទៀង ។ សុខនឹងទុក្ខ ជាធម្មជាតទៀងខ្លះ មិនទៀងខ្លះ ។ សុខនឹងទុក្ខ ជាធម្មជាតទៀងក៏មិនមែន មិនទៀងក៏មិនមែន ។ សុខនឹងទុក្ខ ខ្លួនឯងធ្វើ ។ សុខនឹងទុក្ខ អ្នកដទៃធ្វើ ។ សុខនឹងទុក្ខ ខ្លួនឯងធ្វើខ្លះ អ្នកដទៃធ្វើខ្លះ ។ សុខនឹងទុក្ខ មិនមែនខ្លួនឯងធ្វើ មិនមែនអ្នកដទៃធ្វើ គឺកើតឡើងដោយឥតហេតុ ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ។

(១២៨) ម្នាលចុន្ទ បណ្ដាពួកសមណៈនឹងព្រាហ្មណ៍ទាំងនោះ ពួកសមណៈនឹងព្រាហ្មណ៍ណា ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខ្លួននឹងលោក ជាសភាវៈទៀង ការយល់ឃើញនេះឯងជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះ តថាគតក៏ចូលទៅរកពួកសមណៈនឹងព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ការយល់ឃើញថា ខ្លួននឹងលោក ជាសភាវៈទៀងនេះ អ្នកនិយាយមែនឬ ។ ពួកសមណៈនឹងព្រាហ្មណ៍ទាំងនោះ បាននិយាយនូវពាក្យណាយ៉ាងនេះថា ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ។ តថាគតក៏មិនយល់តាមពាក្យនោះរបស់ពួកសមណៈនឹងព្រាហ្មណ៍នោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

អញ្ញថាសញ្ញិនោបិ ហេត្ថ ចុន្ទ សន្តេកេ សត្តា ។ ឥមាយបិ ខោ អហំ ចុន្ទ បញ្ញត្តិយា នេវ អត្តនោ សមសមំ សមនុបស្សាមិ កុតោ ភិយ្យោ អថខោ អហមេវ តត្ថ ភិយ្យោ យទិទំ អធិបញ្ញត្តិ ។

(១២៥) តត្រ ចុន្ទ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ អត្តា ច លោកោ ច ។ សទ្ធិត្តិំ ។ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ច ។ នេវសស្សតោ ច នាសស្សតោ ច អត្តា ច លោកោ ច ។ សយង្កតោ អត្តា ច លោកោ ច ។ បរង្កតោ អត្តា ច លោកោ ច ។ សយង្កតោ ច បរង្កតោ ច អត្តា ច លោកោ ច ។ អសយង្ការោ ច អបរង្ការោ ច អធិច្ចសមុប្បន្នោ អត្តា ច លោកោ ច ។ សស្សតំ សុខទុក្ខំ ។ អសស្សតំ សុខទុក្ខំ ។ សស្សតញ្ច អសស្សតញ្ច សុខទុក្ខំ ។ នេវសស្សតំ ច(១) នាសស្សតំ ច(២) សុខទុក្ខំ ។

---

១-២ ឱ. ម. បកាកេ ន ទិស្សតិ ។

ម្នាលចុន្ទ ព្រោះថា គង់មានសត្វពួក ១ មានសេចក្តីសំគាល់ដោយឡែក ក្នុងដំណើរនេះដែរ ។ ម្នាលចុន្ទ តថាគតពិចារណាមិនឃើញបុគ្គល ស្មើដោយញាណដ៏ស្មើរបស់តថាគត ដោយបញ្ញត្តិនេះសោះ មានពីណា ក្រៃលែងជាង មានតែតថាគតហ្នឹងឯងក្រៃលែង (ជាងគេ) ក្នុងអធិបញ្ញត្តិ ទាំងនោះ ។

(១២៩) ម្នាលចុន្ទ បណ្តាពួកសមណៈ នឹងព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាង នេះថា ខ្លួននឹងលោក ជាសភាវៈមិនទៀង ។ សេចក្តីសង្ខេប ។ ខ្លួន នឹងលោក ជាសភាវៈទៀងខ្លះ មិនទៀងខ្លះ ។ ខ្លួននឹងលោក ជាសភាវៈ ទៀងក៏មិនមែន មិនទៀងក៏មិនមែន ។ ខ្លួននឹងលោក ខ្លួនឯងធ្វើ ។ ខ្លួននឹងលោក អ្នកដទៃធ្វើ ។ ខ្លួននឹងលោក ខ្លួនឯងធ្វើក៏មាន អ្នកដទៃ ធ្វើក៏មាន ។ ខ្លួននឹងលោក ខ្លួនឯងតាក់តែងក៏មិនមែន អ្នកដទៃតាក់តែង ក៏មិនមែន កើតឡើងដោយឥតហេតុ ។ សុខនឹងទុក្ខ ជាធម្មជាតទៀង ។ សុខនឹងទុក្ខ ជាធម្មជាតមិនទៀង ។ សុខនឹងទុក្ខ ជាធម្មជាតទៀងខ្លះ មិន ទៀងខ្លះ ។ សុខនឹងទុក្ខ ជាធម្មជាតទៀងក៏មិនមែន មិនទៀងក៏មិនមែន ។

សយង្កតំ សុខទុក្ខំ ។ បរង្កតំ សុខទុក្ខំ ។ សយញ្ច
កតំ បរង្កតញ្ច សុខទុក្ខំ ។ អសយង្ការំ អបរង្ការំ
អធិច្ចសមុប្បន្នំ សុខទុក្ខំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ
តត្រាហំ ឧបសង្កមិត្វា ឯវំ វទាមិ អត្ថិ នុ ខោ(១)
ឥទំ អាវុសោ វុច្ចតិ អសយង្ការំ អបរង្ការំ អធិច្ច-
សមុប្បន្នំ សុខទុក្ខន្តិ ។ យញ្ច ខោ តេ ឯវមា-
ហំសុ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តន្តេសន្នា-
នុជានាមិ(២) ។ តំ កិស្ស ហេតុ ។ អញ្ញថា-
សញ្ញិនោបិ ហេត្ថ ចុន្ទ សន្តេកេ សត្តា ។ ឥមា-
យបិ ខោ អហំ ចុន្ទ បញ្ញត្តិយា នេវ អត្តនា សម-
សមំ សមនុបស្សាមិ កុតោ ភិយ្យោ អថខោ អហមេវ

---

១ ឱ. អត្ថិ ខោ ។ ២ ឱ. ម. តំ តេសំ នានុជានាមិ ។

សុខនឹងទុក្ខ ខ្លួនឯងតាក់តែង ។ សុខនឹងទុក្ខ អ្នកដទៃតាក់តែង ។ សុខនឹងទុក្ខ ខ្លួនឯងតាក់តែងក៏មាន អ្នកដទៃតាក់តែងក៏មាន ។ សុខនឹងទុក្ខ ខ្លួនឯងតាក់តែង ក៏មិនមែន អ្នកដទៃតាក់តែង ក៏មិនមែន កើតឡើង ដោយឥតហេតុ ។ ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះ ។ តថាគតក៏ចូលទៅរកពួកបរិព្វាជកទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ការយល់ឃើញថា សុខនឹងទុក្ខមិនមែនខ្លួនឯងធ្វើ មិនមែនបុគ្គលដទៃធ្វើ កើតឡើង ដោយឥតហេតុ នេះអ្នកនិយាយមែនឬ ។ ពួកសមណៈនឹងព្រាហ្មណ៍ទាំងនោះ និយាយនូវពាក្យណា យ៉ាងនេះថា ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ។ តថាគតក៏មិនយល់តាមពាក្យនោះ របស់សមណព្រាហ្មណ៍ ទាំងនោះទេ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះថា គង់មានសត្វពួកខ្លះ មានសេចក្តីសំគាល់ដោយឡែក ក្នុងរឿងនេះដែរ ។ ម្នាលចុន្ទ តថាគតពិចារណាមិនឃើញបុគ្គលស្មើ ដោយញាណដ៏ស្មើ របស់តថាគត ក្នុងបញ្ញត្តិនេះ មានពីណាក្រៃលែងជាង មានតែតថាគតហ្នឹងឯង

តត្ថ ភិយ្យោ យទិទំ អធិបញ្ញត្តិ ។ ឥមេ ខោ តេ ចុន្ទ បុព្វន្តសហគតា ទិដ្ឋិនិស្សយា យេ តេ(១) មយា ព្យាកតា យថា តេ ព្យាកាតព្វា យថា ច តេ ន ព្យាកាតព្វា កឹ តេ អហន្តេ តត្ថ ព្យាករិស្សាមិ(២) ។

(១៦៦) កតមេ(៣) តេ ចុន្ទ អបរន្តសហគតា ទិដ្ឋិនិស្សយា យេ តេ(៤) មយា ព្យាកតា យថា តេ ព្យាកាតព្វា(៥) យថា ច តេ ន ព្យាកាតព្វា កឹ តេ អហំ តេ តត្ថ ព្យាករិស្សាមិ(៦) ។ សន្តិ ចុន្ទ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ រូបី អត្តា ហោតិ អរោគោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ សន្តិ ខោ បន(៧) ចុន្ទ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ

---

១ ឱ. វោ ។ ២ ឱ. កំ វោ អហំ តេ តត្ថ វ្យាករិស្សាមិ ។ ម... ព្យាករិស្សាមីតិ ។ ៣ ឱ. ម. កតមេ ច ។ ៤ ឱ. វោ ។ ៥ ឱ. វ្យាកត្តព្វា ។ ម. ព្យាកាតព្វា ។ ៦ ម. កំ វោ...។ ឱ. កំ តេ អហំ តេ តត្ថ ព្យាករិស្សាមីតិ ឲ ទិស្សតិ ។ ៧ ឱ. សន្តិបន ។

ក្រៅលែងជាងគេ ក្នុងអធិបញ្ញត្តិនោះ ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយ ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងដើមនេះឯង តថាគតបានសំដែងដល់អ្នកហើយ តថាគតត្រូវសំដែង នូវទិដ្ឋិនិស្ស័យទាំងឡាយនោះយ៉ាងណា មួយវិញទៀត តថាគតមិនត្រូវសំដែង នូវទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា តថាគតនឹងសំដែង នូវទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នក ក្នុងហេតុទាំងនោះ ដូចម្តេចកើត ។

(១២៦) ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងខាងមុខ តថាគតបានសំដែង នូវទិដ្ឋិនិស្ស័យទាំងនោះហើយ តថាគតត្រូវសំដែង នូវទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា តថាគតមិនត្រូវសំដែង នូវទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា ឯទិដ្ឋិនិស្ស័យទាំងនោះ តើដូចម្តេច តថាគតនឹងសំដែងនូវទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នកក្នុងហេតុនោះ ដូចម្តេចកើត ។ ម្នាលចុន្ទ មានសមណព្រាហ្មណ៍ ១ ពួកនេះ ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខាងមុខអំពីសេចក្តីស្លាប់ទៅ ខ្លួនមានរូបមិនមានរោគ ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេដូច្នេះ ។ ម្នាលចុន្ទ មានសមណព្រាហ្មណ៍ ១ ពួក ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា

## បាសាទិកសុត្តេ សមណព្រាហ្មណានំ អធិប្បញ្ញត្តិ

អរូបី អត្តា ហោតិ ។ រូបី ច អរូបី ច អត្តា ហោតិ ។ នេវរូបីនារូបី អត្តា ហោតិ ។ សញ្ញី អត្តា ហោតិ ។ អសញ្ញី អត្តា ហោតិ ។ សញ្ញី ច អសញ្ញី ច អត្តា ហោតិ ។ នេវសញ្ញីនាសញ្ញី អត្តា ហោតិ ។ អត្តា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តត្រ ចុន្ទ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ រូបី អត្តា ហោតិ អរោគោ បរំ មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ អត្ថិ ខោ ឥទំ អាវុសោ វុច្ចតិ រូបី អត្តា ហោតិ អរោគោ បរំ មរណាតិ ។ យញ្ច ខោ តេ ឯវមាហំសុ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តំ តេសំ នានុជានាមិ ។ តំ កិស្ស ហេតុ ។

## បាសាទិកសូត្រ អធិប្បញ្ញត្តិនៃសមណព្រាហ្មណ៍ទាំងឡាយ

ខ្លួនមិនមានរូប ។ ខ្លួនមានរូបក៏មាន ឥតរូបក៏មាន ។ ខ្លួនមានរូបក៏មិនមែន ឥតរូបក៏មិនមែន ។ ខ្លួនមានសញ្ញា ។ ខ្លួនមិនមានសញ្ញា ។ ខ្លួនមានសញ្ញាក៏មាន ឥតសញ្ញាក៏មាន ។ ខ្លួនមានសញ្ញាក៏មិនមែន ឥតសញ្ញាក៏មិនមែន ។ ខាងមុខអំពីសេចក្តីស្លាប់ទៅ ខ្លួនមែនដាច់សូន្យទៅ វិនាសទៅ មិនកើតទៀត ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះ ។ ម្នាលចុន្ទ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខាងមុខអំពីសេចក្តីស្លាប់ ខ្លួននៅមានរូប មិនមានរោគ ការយល់នេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះ តថាគត ក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្តីស្លាប់ ខ្លួននៅមានរូប មិនមានរោគ នេះអ្នកនិយាយមែនឬ ។ មួយទៀត ពួកសមណព្រាហ្មណ៍ទាំងនោះ បាននិយាយពាក្យណាយ៉ាងនេះថា ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ។ តថាគតមិនយល់តាមពាក្យនោះរបស់ពួកសមណព្រាហ្មណ៍នោះទេ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។

អញ្ញថា សញ្ញិនោបិ ហោន្ថ ចុន្ទ សន្តេកេ សត្តា ។ ឥមាយបិ ខោ អហំ ចុន្ទ បញ្ញត្តិយា នេវ អត្តនោ សមសមំ សមនុបស្សាមិ កុតោ ភិយ្យោ អថខោ(១) អហមេវ តត្ថ ភិយ្យោ យទិទំ អធិបញ្ញត្តិ ។

(១៨៧) តត្ថ(២) ចុន្ទ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អរូបី អត្តា ហោតិ ។ រូបី ច អរូបី ច អត្តា ហោតិ ។ នេវរូបីនារូបី អត្តា ហោតិ ។ សញ្ញី អត្តា ហោតិ ។ អសញ្ញី អត្តា ហោតិ ។ សញ្ញី ច អសញ្ញី ច អត្តា ហោតិ ។ នេវសញ្ញីនាសញ្ញី អត្តា ហោតិ ។ អត្តា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរំ មរណា ឥធមេវ សច្ចំ មោឃមញ្ញន្តិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ អត្ថិ ខោ ឥទំ អាវុសោ វុច្ចតិ អត្តា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរំ មរណាតិ ។ យញ្ច ខោ តេ ចុន្ទ

---

១. អថ ខោ បុន្ន ។ ២ ឱ. តត្រ ។

ម្នាលចុន្ទ ព្រោះថា គង់មានសត្វពួកខ្លះ មានសេចក្តីសំគាល់ដោយឡែក ក្នុងដំណើរនេះដែរ ៗ ម្នាលចុន្ទ តថាគត ពិចារណាមិនឃើញបុគ្គល ស្មើដោយញាណ ដ៏ស្មើរបស់តថាគត ក្នុងបញ្ញត្តិនេះទេ មានពីណា ក្រៃលែងជាង មានតែតថាគតហ្នឹងឯង ក្រៃលែង (ជាងគេ) ក្នុងអធិបញ្ញត្តិនោះ ៗ

(១២៧) ម្នាលចុន្ទ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់យ៉ាងនេះថា ខ្លួនមិនមានរូប ៗ ខ្លួនមានរូបក៏មាន ឥតរូបក៏មាន ៗ ខ្លួនមានរូបក៏មិនមែន ឥតរូបក៏មិនមែន ៗ ខ្លួនមានសញ្ញា ៗ ខ្លួនឥតសញ្ញា ៗ ខ្លួនមានសញ្ញាក៏មាន ឥតសញ្ញាក៏មាន ៗ ខ្លួនមានសញ្ញាក៏មិនមែន ឥតសញ្ញាក៏មិនមែន ៗ ខាងមុខអំពីសេចក្តីស្លាប់ ខ្លួនរមែងដាច់សូន្យទៅ វិនាសទៅ មិនកើតទៀត ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេ ដូច្នេះ តថាគត ក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្តីស្លាប់ ខ្លួនរមែងដាច់សូន្យទៅ វិនាសទៅ មិនកើតទៀតនេះ អ្នកនិយាយមែនឬ ៗ ម្នាលចុន្ទ ពួកសមណព្រាហ្មណ៍ទាំងនោះ

ឯវមាហំសុ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ តន្តេសំ ណានុជានាមិ ។ តំ កិស្ស ហេតុ ។ អញ្ញថាសញ្ញិនោបិ ហេត្ថ ចុន្ទ សន្តេកេ សត្តា ។ ឥមាយបិ ខោ អហំ ចុន្ទ បញ្ញត្តិយា នេវ អត្តនា សមសមំ សមនុបស្សាមិ កុតោ ភិយ្យោ អថខោ អហមេវ តត្ថ ភិយ្យោ យទិទំ អធិបញ្ញត្តិ ។ ឥមេ ខោ ចុន្ទ អបរន្តសហគតា ទិដ្ឋិនិស្សយា យេ តេ(១) មយា ព្យាកតា យថា តេ ព្យាកាតព្វា យថា ច តេ ន ព្យាកាតព្វាតិ(២) កឹ តេ អហន្តេ តត្ថ ព្យាករិស្សាមិ ។

(១២៨) ឥមេសញ្ច ចុន្ទ បុព្វន្តសហគតានំ ទិដ្ឋិនិស្សយានំ ឥមេសញ្ច អបរន្តសហគតានំ ទិដ្ឋិ-និស្សយានំ បហានាយ សមតិក្កមាយ ឯវំ មយា ចត្តារោ សតិបដ្ឋានា ទេសិតា បញ្ញត្តា ។ កតមេ ចត្តារោ ។

---

១ ឱ. វោ ។ ២ ឱ. វ្យាកត្តព្វា ។

និយាយនូវពាក្យណា យ៉ាងនេះថា ការយល់ឃើញនេះឯង ជាការពិត ពាក្យពួកមនុស្សដទៃ ជាពាក្យសោះសូន្យទទេដូច្នេះ ។ តថាគត មិនយល់តាមពាក្យរបស់ពួកគេនោះទេ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះថា មានសត្វ១ពួក តែងមានសេចក្ដីសំគាល់ ដោយឡែកក្នុងដំណើរនេះ ។ ម្នាលចុន្ទ តថាគតពិចារណាមិនឃើញបុគ្គល ស្មើដោយញាណដ៏ស្មើរបស់តថាគត ក្នុងបញ្ញត្តិនេះសោះ មានពីណាក្រៃលែងជាង មានតែតថាគតហ្នឹងឯង ក្រៃលែង (ជាងគេ) ក្នុងអធិបញ្ញត្តិនោះ ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខាងមុខនេះឯង តថាគត បានសំដែងដល់អ្នកហើយ តថាគត ត្រូវសំដែងទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា មួយវិញទៀត មិនត្រូវសំដែងទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា តថាគត នឹងសំដែងនូវទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នក ក្នុងហេតុទាំងនោះ ដូចម្ដេចកើត ។

(១២៨) ម្នាលចុន្ទ សតិប្បដ្ឋានទាំង ៤ ដែលតថាគតសំដែងហើយ បញ្ញត្តហើយយ៉ាងនេះ ដើម្បីលះបង់ ដើម្បីឈានកន្លងនូវពួកទិដ្ឋិនិស្ស័យ ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងដើមនេះផង នូវពួកទិដ្ឋិនិស្ស័យដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងមុខនេះផង ។ សតិប្បដ្ឋានទាំង៤ដូចម្ដេច ។

ឥធ ចុន្ទ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ ។ ចិត្តេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឥមេសញ្ច ចុន្ទ បុព្វន្តសហគតានំ ទិដ្ឋិនិស្សយានំ ឥមេសញ្ច អបរន្តសហគតានំ ទិដ្ឋិនិស្សយានំ បហានាយ សមតិក្កមាយ ឯវំ មយា ឥមេ ចត្តារោ សតិបដ្ឋានា ទេសិតា បញ្ញត្តា ។

(១២៩) តេន ខោ បន សមយេន អាយស្មា ឧបវានោ(១) ភគវតោ បិដ្ឋិតោ ឋិតោ ហោតិ ភគវន្តំ វីជយមានោ ។ អថខោ អាយស្មា ឧបវានោ(២) ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ

---

១-២ ឱ. ឧបវានោ ។ ម. ឧបវាណោ ។

ម្នាលចុន្ទ ភិក្ខុក្នុងធម្មវិន័យនេះ រមែងមានកិរិយាពិចារណារឿយ ៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតបង់នូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុមានកិរិយាពិចារណារឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតបង់នូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកំចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ម្នាលចុន្ទ សតិប្បដ្ឋានទាំង ៤ នេះ ដែលតថាគតសំដែងហើយ បញ្ញត្តហើយយ៉ាងនេះ ដើម្បីលះបង់ ដើម្បីឈានកន្លង នូវពួកទិដ្ឋិនិស្ស័យ ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងដើមនេះផង នូវពួកទិដ្ឋិនិស្ស័យ ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងមុខនេះផង ។

(១២៩) សម័យនោះឯង ព្រះឧបវានដ៏មានអាយុ ឈរបក់ព្រះមានព្រះភាគ អំពីខាងក្រោយព្រះមានព្រះភាគ លំដាប់នោះ ព្រះឧបវានដ៏មានអាយុ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនេះអស្ចារ្យណាស់ មិនគួរកើតបានសោះ

ភន្តេ បាសាទិកោ វតាយំ ភន្តេ ធម្មបរិយាយោ សុបាសាទិកោ[១] វតាយំ ភន្តេ ធម្មបរិយាយោ កោ-នាមាយំ ភន្តេ ធម្មបរិយាយោតិ ។ តស្មាតិហ ត្វំ ឧបវាន[២] ឥមំ ធម្មបរិយាយំ បាសាទិកោត្វេវ ធារេហីតិ[៣] ។ ឥទមវោច ភគវា ។ អត្តមនោ អាយស្មា ឧបវានោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

បាសាទិកសុត្តំ ឆដ្ឋំ[៤] និដ្ឋិតំ ។

---

១ ឱ. អតិបាសាទិកោ ។ ២ ឱ. ឧបវាន ។ ម. ឧបវាណ ។ ៣ ឱ. ម. នំ ធារេហីតិ ។ ៤ ឱ. ម. បាសាទិកសុត្តន្តំ ឆដ្ឋំ ។

បាសាទិកសូត្រ ធម្មបរិយាយគួរជាទីជ្រះថ្លា

បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះ គួរជាទីជ្រះថ្លាហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះ គួរជាទីជ្រះថ្លាល្អហ្ន៎ បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះឈ្មោះអ្វី ។ ព្រះអង្គត្រាស់ថា ម្នាលឧបវាន ហេតុដូច្នោះ អ្នកចូរចាំទុក នូវធម្មបរិយាយនេះថា ជាបាសាទិកៈដូច្នេះចុះ ។ លុះព្រះមានព្រះភាគ បានសំដែងសូត្រនេះ (ចប់) ហើយ ។ ឧបវានដ៏មានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ដោយប្រការ ដូច្នេះឯង ។

ចប់ បាសាទិកសូត្រទី ៦ ។

# សុត្តន្តបិដកេ ទីឃនិកាយស្ស

## បញ្ចមោ ភាគោ

---

## បាដិកវគ្គោ

### បាដិកសុត្តំ បឋមំ


| | | អង្ក |
|---|---|---|
| បាដិកសុត្តេ សុនក្ខត្តវត្ថុ | ភគវតោ បច្ចក្ខានកថា . . . | ៣ |
| | ឥទ្ធិបាដិហារិយកថា . . . . | ៥ |
| | អគ្គញ្ញកថា . . . . . . . | ៧ |
| | តេនត្តយគុណកថា . . . . | ៩ |
| | ភគវតោ ឧត្តរកាវិហរណកថា . . | ១១ |
| | អចេលកោរក្ខត្តិយកុក្កុរវត្តកថា . . | ១៣ |
| | អចេលកោរក្ខត្តិយកាលកិរិយាកថា . | ១៥ |
| | ឥទ្ធិបាដិហារិយកតាកតកថា . . | ១៧ |
| | សុនក្ខត្តស្ស បញ្ហា . . . . | ១៩ |
| | សុនក្ខត្តបាបកទិដ្ឋិគតកថា . . . | ២១ |
| | អចេលបាដិកបុត្តវត្ថុ . . . . | ២៣ |
| | អចេលបាដិកបុត្តការណត្តយុគ្គាហកថា | ២៥ |

# សុត្តន្តបិដក ទីឃនិកាយ

## បញ្ចមភាគ

---

## បាដិកវគ្គ

### បាដិកសូត្រ ទី ១

លេខទំព័រ


បាដិកសូត្រ រឿងសុនក្ខត្តលិច្ឆវីបុត្រ ពោលអំពីការក្រាបបង្គំលាព្រះមានព្រះភាគ ៣

ពោលអំពីឥទ្ធិប្បាដិហារិយ៍ . . . . . . . . . . . . ៤

ពោលអំពីក្បាប់ទំលាប់ . . . . . . . . . . . . ៧

ពោលអំពីគុណនៃព្រះរត្នត្រ័យ . . . . . . . . . . ៩

ពោលអំពីព្រះមានព្រះភាគគង់នៅក្នុងឧត្តរកានិគម . . . . ១១

ពោលអំពីកុក្កុរវត្តរបស់អចេលកោរក្ខត្តិយៈ . . . . . . ១៣

ពោលអំពីការធ្វើមរណកាលរបស់អចេលកោរក្ខត្តិយៈ . . . ១៤

ពោលអំពីការធ្វើនឹងមិនធ្វើឥទ្ធិប្បាដិហារិយ៍ . . . . . . ១៧

ប្រស្នារបស់សុនក្ខត្តលិច្ឆវីបុត្រ . . . . . . . . . . ១៩

ពោលអំពីទិដ្ឋិអាក្រក់របស់សុនក្ខត្តលិច្ឆវីបុត្រ, . . . . . ២១

រឿងអចេលបាដិកបុត្រ . . . . . . . . . . . ២៣

ពោលអំពីការរើសគូប្រណាំងប្រជែងរបស់អចេលបាដិកបុត្រ . ២៤

# មាតិកាបត្តានិ

| | | អង្ក |
|---|---|---|
| បាជិកសុត្តេ | ភគវតោ អទ្វយគាមិនី កថា | ២៧ |
| | អបេលបាជិកបុត្តចរិតកថា | ២៩ |
| | អបេលបាជិកបុត្តអាគមូបសង្កមនំ | ៣១ |
| | អបេលបាជិកបុត្តភយឆម្ភិតត្តលោមហំសកថា | ៣៣ |
| | បុរិសស្ស អបេលបាជិកបុត្តូបសង្កមនកថា | ៣៥ |
| | អបេលបាជិកបុត្តស្ស បរាភូតរូបកថា | ៣៧ |
| | សីហមិគរាជវរសិគាលោបម្មកថា | ៤៥ |
| | សីហមិគរាជវរសិគាលោបម្មគាថា | ៤៧ |
| | ឥទ្ធិប្បាដិហារិយកថា | ៥១ |
| | អគ្គញ្ញាទិកថា | ៥៣ |
| | មហាព្រហ្មាទិកថា | ៥៥ |
| | ខិឌ្ឌាបទោសិកា ទេវា អគ្គញ្ញបញ្ញត្តិ | ៥៩ |
| | មនោបទោសិកា នមនោបទោសិកា ទេវា | ៦៣ |
| | អធិច្ចសមុប្បន្នគ្គញ្ញបញ្ញត្តិកថា | ៦៥ |
| | សុភវិមោក្ខកថា | ៦៧ |

លេខទំព័រ

ជាតកសូត្រ ព្រះភាសារបស់ព្រះមានព្រះភាគមិនដែលមានដំណើរបែកចេញជា ២ ផ្លូវ ២៧
ពោលអំពីសេចក្ដីប្រព្រឹត្តិរបស់អវេលជាតកបុត្រ. . . . . . ២៩
ព្រះមានព្រះភាគស្ដេចចូលទៅកាន់អាវាមរបស់អវេលជាតកបុត្រ . ៣១
ពោលអំពីភ័យសេចក្ដីតក់ស្លុតព្រឺរោមរបស់អវេលជាតកបុត្រ . . ៣៣
ពោលអំពីបុរសម្នាក់ចូលទៅរកអវេលជាតកបុត្រ . . . . . ៣៥
ពោលអំពីការបរាជ័យរបស់អវេលជាតកបុត្រ . . . . . . ៣៧
ពោលអំពីសេចក្ដីប្រៀបធៀបដោយសីហមិគរាជនឹងចចកចាស់. . ៤៥
គាថាជាគ្រឿងប្រៀបធៀប ដោយសីហមិគរាជនឹងចចកចាស់ . . ៤៧
ពោលអំពីឥទ្ធិប្បាដិហារិយ៍ . . . . . . . . . . . ៥១
ពោលអំពីច្បាប់ទម្លាប់ជាដើម . . . . . . . . . . ៥៣
ពោលអំពីមហាព្រហ្មជាដើម . . . . . . . . . . ៥៥
ពួកទេវតាឈ្មោះខិឌ្ឌាបទោសិកានឹងការបញ្ញត្តិច្បាប់ទំលាប់. . . ៥៩
ពួកទេវតាឈ្មោះមនោបទោសិកានឹងមិនមែនមនោបទោសិកា . . ៦៣
ពោលអំពីការបញ្ញត្តិច្បាប់ទំលាប់ដែលកើតឡើងដោយមិនអាស្រ័យ-
ហេតុ . . . . . . . . . . . . . . . . ៦៥
ពោលអំពីសុភវិមោក្ខ . . . . . . . . . . . ៦៧

## ឧទុម្ពរិកាសុត្តំ ទុតិយំ


អង្កេ

ឧទុម្ពរិកសុត្តេ និគ្រោធបរិព្វាជកវត្ថុ . . . . . . . ៧១

តបោជិគុច្ឆាវាទកថា . . . . . . . ៧៧

តបោជិគុច្ឆាយ ឧបក្កិលេសកថា . . . ៨៣

តបោជិគុច្ឆាយ បរិសុទ្ធិកថា . . . . ៨៩

តបោជិគុច្ឆាយ អគ្គសារប្បត្តកថា . . . ៩៥

សន្ទានគហបតិនោ បដិបុច្ឆាកថា . . . ១០៥

សម្មាសម្ពុទ្ធគុណកថា . . . . . . . ១០៧

ធម្មិនយេ បដិបទាយ ឧត្តមានិសំសកថា . ១០៩


## ចក្កវត្តិសុត្តំ តតិយំ


ចក្កវត្តិសុត្តេ ទឡ្ហនេមិចក្កវត្តិវត្ថុ សត្ត រតនានិ . . . ១១៧

ទិព្វំ ចក្ករតនំ អន្តរហិតំ . . . . . ១១៩

ចក្កវត្តិវត្តកថា . . . . . . . . ១២១

ចក្ករតនានុភាវោ . . . . . . . ១២៣

ចក្ករតនានុភាវោ ធម្មានុសាសនី . . . ១២៥

## ឧទុម្ពរិកសូត្រ ទី ២

លេខទំព័រ


ឧទុម្ពរិកសូត្រ រឿងនិគ្រោធបរិព្វាជក . . . . . . . . . . . . . . , ៧១

ពោលអំពីតបោជិគុច្ឆាភិទជាដើម . . . . . . . . . . ៧៧

ពោលអំពីឧបក្កិលេសនៃការខ្ពើមបាប ដោយព្យាយាម ជាគ្រឿងដុតកិលេស . . . . . . . . . . . . . . . . . ៨៣

ពោលអំពីសេចក្តីបរិសុទ្ធនៃការខ្ពើមបាប ដោយព្យាយាម ជាគ្រឿងដុតកិលេស . . . . . . . . . . . . . . ៨៩

ពោលអំពីតបោជិគុច្ឆាដែលដល់នូវកំពូលធម៌និងខ្លឹមធម៌ . . . ៩៥

ពោលអំពីការសាកសួរនៃសន្ធានគហបតី . . . . . . . ១០៥

ពោលអំពីគុណនៃព្រះសម្មាសម្ពុទ្ធ . . . . . . . . ១០៧

ពោលអំពីអានិសង្សដ៏ឧត្តមនៃការប្រតិបត្តិក្នុងធម្មវិន័យ . . . . ១០៩


## ចក្កវត្តិសូត្រ ទី ៣


ចក្កវត្តិសូត្រ រឿងស្តេចចក្រពត្តិព្រះនាមទឡ្ហនេមិ រតនៈ ៧ប្រការ . . . . ១១៧

ចក្ករ័តន៍ជាទិព្វបាត់ទៅ . . . . . . . . . . ១១៩

ពោលអំពីចក្កវត្តិវត្ត . . . . . . . . . . . . ១២១

អានុភាពនៃចក្ករ័តន៍ . . . . . . . . . . . . ១២៣

អានុភាពនៃចក្ករ័តន៍ ការទ្រង់ប្រៀនប្រដៅដោយធម៌ . . . . ១២៥

| | | អង្កេ |
|---|---|---|
| ចក្កវត្តិសុត្តេ | ទិព្វំ ចក្ករតនំ ឋានា ចុតំ | ១២៧ |
| | ទិព្វចក្ករតនអន្តរធានំ | ១២៩ |
| | ន អធនានំ ធនានុប្បទានំ | ១៣១ |
| | ធនានុប្បទានំ ធម្មានុសាសនី | ១៣៣ |
| | អទិន្នាទានំ សីសច្ឆេទោ | ១៣៥ |
| | ធននានុប្បទានាទិ | ១៣៧ |
| | ទសអកុសលកម្មបថា អាយុបរិហានិ | ១៤១ |
| | ទាឡិទ្ទិយស្ស ឧប្បជ្ជនាទិ | ១៤៣ |
| | កុទ្រូសកអគ្គភោជនូបមា | ១៤៥ |
| | តិព្វាឃាតាទិកថា | ១៤៧ |
| | អកុសលកម្មបថវិរតិ អាយុអាទិវឌ្ឍនំ | ១៤៩ |
| | សង្ខពជុប្បត្តិ | ១៥៣ |
| | មេត្តេយ្យស្ស ភគវតោ គុណកថា | ១៥៥ |
| | អាយុអាទិវឌ្ឍនធម្មកថា | ១៥៧ |
| | ចតុជ្ឈានកថា | ១៥៩ |

លេខទំព័រ


ចក្កវត្តិសូត្រ ចក្កវត្តិជាទិព្វច្យុតចាកទី . . . . . . . . . . ១២៧

ចក្កវត្តិជាទិព្វបាត់ទៅ . . . . . . . . . . . ១២៩

ការមិនទ្រង់ព្រះរាជទានទ្រព្យដល់ពួកមនុស្សដែលឥតទ្រព្យ . . ១៣១

ការទ្រង់ព្រះរាជទានទ្រព្យ ការទ្រង់ប្រៀនប្រដៅដោយធម៌ . . ១៣៣

អទិន្នាទាន ការកាត់ក្បាល(ចោរ) . . . . . . . . . ១៣៥

ការមិនទ្រង់ព្រះរាជទានទ្រព្យជាដើម . . . . . . . . ១៣៧

អកុសលកម្មបថ ១០ ប្រការ សេចក្តីសាបសូន្យអាយុ . . . ១៤១

ដំណើរកើតឡើងនៃសេចក្តីទ័លក្រជាដើម . . . . . . . ១៤៣

សេចក្តីប្រៀបដោយស្មៅតែលលកជាភោជនដ៏ប្រសើរ . . . ១៤៥

និយាយអំពីគំនុំធំក្រៀវក្លាជាដើម . . . . . . . . . ១៤៧

សេចក្តីវៀរចាកអកុសលកម្មបថ សេចក្តីចំរើនដោយអាយុជាដើម. ១៤៨

ការកើតឡើងនៃព្រះបាទសង្ខរាជ . . . . . . . . . ១៥៣

អំពីគុណកថានៃព្រះមានព្រះភាគទ្រង់ព្រះនាមមេត្តេយ្យ . . . ១៥៥

និយាយអំពីធម៌ចំរើនអាយុជាដើម . . . . . . . . . ១៥៧

និយាយអំពីឈានទាំង ៤ . . . . . . . . . . . ១៥៩

អង្កេ

## អគ្គញ្ញសុត្តំ ចតុត្ថំ


| | | |
|---|---|---|
| អគ្គញ្ញសុត្តេ | ចតុវណ្ណកថា . . . . . . . . | ១៦៣ |
| | សុក្កកណ្ហធម្មកថា . . . . . . . | ១៦៧ |
| | នានាជាតិអាទិកថា . . . . . . . | ១៦៩ |
| | លោកស្ស វិវដ្ដនំ . . . . . . . | ១៧១ |
| | រសបឋវីអាទិកថា . . . . . . . | ១៧៣ |
| | ភូមិបប្បដិកាទិកថា . . . . . . . | ១៧៥ |
| | វណ្ណាទិកថា . . . . . . . . | ១៧៧ |
| | អញ្ញមញ្ញស្ស ឧបនិជ្ឈាបនំ . . . . . | ១៧៩ |
| | សាលាហរនាទិកថា . . . . . . | ១៨១ |
| | សាលិវិភជនំ មរិយាទដ្ឋបនំ . . . . | ១៨៣ |
| | ឯកសត្តសម្មតិ សាលិកាគានុប្បទានំ . . | ១៨៥ |
| | អទិន្នាទានាទិបាបធម្មកថា . . . . . | ១៨៩ |
| | អជ្ឈាយិកា អជ្ឈាយិកាត្វេវ តតិយក្ខរបទិព្វត្តិ . | ១៩១ |
| | ទុច្ចរិតចរណំ ទុច្ចរិតវិបាកា . . . . | ១៩៣ |

# អគ្គញ្ញសូត្រ ទី ៤

លេខទំព័រ

អគ្គញ្ញសូត្រ និយាយអំពីវណ្ណៈទាំង ៤ . . . . . . . . . . ១៦៣
និយាយអំពីធម៌សនឹងធម៌ខ្មៅ . . . . . . . . . . ១៦៧
ពោលអំពីជាតិផ្សេង ៗ ជាដើម . . . . . . . . . ១៦៩
សេចក្ដីចំរើននៃលោក . . . . . . . . . . . ១៧១
និយាយអំពីផែនដីមានរសជាដើម . . . . . . . . ១៧៣
និយាយអំពីក្រមរផែនដីជាដើម . . . . . . . . . ១៧៤
និយាយអំពីពណ៌សឡុរជាដើម . . . . . . . . ១៧៧
ការសំឡឹងមើលគ្នាទៅវិញទៅមក . . . . . . . . ១៧៩
និយាយអំពីការនាំយកស្រូវសាលីជាដើម . . . . . . ១៨១
ការចែកស្រូវសាលី ការតាំងភ្លឺស្រែ . . . . . . ១៨៣
ការសន្មតិសត្វម្នាក់ ការប្រគល់ឲ្យចំណែកស្រូវសាលី . . . . ១៨៥
និយាយអំពីបាបធម៌មានអទិន្នាទានជាដើម . . . . . . ១៨៩
ការកើតឡើងនៃអក្ខរទី ៣ ជា អជ្ឈាយិកា អជ្ឈាយិកា . . ១៩១
ការប្រព្រឹត្តិអាក្រក់ ផលនៃការប្រព្រឹត្តិអាក្រក់ . . . . . . ១៩៣

អង្ក

អគ្គញ្ញសុត្ត សុចរិតចរណំ សុចរិតវិបាកា . . . . . ១៩៥

សនង្កុមារព្រហ្មគាថា . . . . . . ១៩៧

សម្បសាទនីយសុត្តំ បញ្ចមំ

សម្បសាទនិយសុត្ត សារីបុត្តស្ស បុច្ឆំ . . . . . . ២០១

សម្បសាទនទេសនា នគរោបម្មំ . . . ២០៣

ពោធិបក្ខិយធម្មា អាយតនបណ្ណត្តិ . . . ២០៥

ចតស្សោ គព្ភាវក្កន្តិយោ . . . . . ២០៧

តតិយា អាទេសនវិធា . . . . . ២០៩

ចតស្សោ ទស្សនសមាបត្តិយោ . . . ២១១

សត្ត បុគ្គលា . . . . . . . . ២១៣

ចតុប្បដិបទា . . . . . . . . ២១៥

ចតស្សោ អនុសាសនវិធា . . . . ២១៧

បរបុគ្គលវិមុត្តិញ្ញាណំ . . . . . . ២១៩

តយោ សស្សតវាទា . . . . . . ២២១

បុព្វេនិវាសានុស្សតិញ្ញាណំ . . . . . ២២៥

លេខទំព័រ

អគ្គញ្ញសូត្រ ការប្រព្រឹត្តល្អ ផលនៃការប្រព្រឹត្តល្អ . . . . . . . ១៩៥

កាថារបស់សនង្កុមារព្រហ្ម . . . . . . . . . . ១៩៧

# សម្បសាទនីយសូត្រ ទី ៥

សម្បសាទនីយសូត្រ ការក្រាស់ស្នូរចំពោះព្រះសារីបុត្រ . . . . . . . ២០១

សម្បសាទនទេសនា សេចក្ដីឧបមាដោយនគរ . . . . ២០៣

ពោធិបក្ខិយធម៌ កិរិយាញុំាងបុគ្គលឲ្យស្គាល់នូវអាយតនៈ . . . ២ ៥

ដំណើរចុះកាន់គភ៌មាន ៤ យ៉ាង . . . . . . . . ២ ៧

អាទេសនវិធី ទី ៣ . . . . . . . . . . . ២០៩

ទស្សនសមាបត្តិ ៤ . . . . . . . . . . . ២១១

បុគ្គល ៧ ពួក . . . . . . . . . . . . . ២១៣

បធិបទា ៤ យ៉ាង . . . . . . . . . . . ២១៥

អនុសាសនវិធា ៤ យ៉ាង . . . . . . . . . ២១៧

វិមុត្តិញាណរបស់បុគ្គលដទៃ . . . . . . . . . ២១៩

សស្សតវាទ ៣ ប្រការ . . . . . . . . . . ២២១

បុព្វេនិវាសានុស្សតិញ្ញាណ . . . . . . . . . ២២៥

អង្ក

សម្បសាទនីយសុត្តេ ទ្វេមា ឥទ្ធិវិធាយោ . . . . . . ២២៧
ឥទ្ធិ សាសវា ឥទ្ធិ អនាសវា . . . ២២៩
សារីបុត្តស្ស បុច្ឆា ភគវតោ ព្យាករណំ . . ២៣១
ឧទាយិសម្បសាទបវេទនំ. . . . . ២៣៥

បាសាទិកសុត្តំ ឆដ្ឋំ

បាសាទិកសុត្តេ ភគវតោ អារោចនំ. . . . . . . ២៣៩
ទុរក្ខាតធម្មវិនយោ . . . . . . . ២៤១
សត្ថុ សម្ពោធិតា ធម្មស្ស ស្វាក្ខាតតា . . ២៤៣
សទ្ធម្ម អវិញ្ញាបិតត្ថសាវកា . . . . ២៤៧
សត្ថុនោ ថេររត្តញ្ញុតាទិកំ . . . . . ២៤៩
ថេរភិក្ខុំ វិយត្តតាទិ . . . . . . ២៥៥
កេវលបរិបូរំ ព្រហ្មចរិយំ . . . . . ២៥៧
អភិញ្ញាទេសិតធម្មកថា . . . . . . ២៥៩
សព្រហ្មចារិនោ ធម្មភាសិតំ . . . . . ២៦១
ចីវរបច្ចយាទិកានុជាននំ . . . . . . ២៦៥

លេខទំព័រ

សម្បសាទនីយសូត្រ ឥទ្ធិវិធា ២ យ៉ាង . . . . . . . . . . . . ២២៧
ឫទ្ធិប្រកបដោយអាសវៈ ឫទ្ធិមិនមានអាសវៈ . . . . . ២២៩
ព្រះសារីបុត្រសួរ ព្រះមានព្រះភាគទ្រង់ព្យាករ . . . . ២៣១
ព្រះឧទាយីសំដែងអំពីសេចក្ដីជ្រះថ្លា . . . . . . ២៣៥

# បាសាទិកសូត្រ ទី ៦

បាសាទិកសូត្រ ការក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ . . . . . ២៣៩
ធម្មវិន័យដែលសាស្ដាពោលទុកមិនល្អ . . . . . . ២៤១
កិរិយាប្រាស់ដឹងនៃព្រះសាស្ដា ភារៈនៃធម៌ដែលទ្រង់សំដែង
ទុកល្អហើយ . . . . . . . . . . . . ២៤៣
ពួកសាវ័កដែលមិនបានដឹងសេចក្ដីច្បាស់ក្នុងព្រះសទ្ធម្ម . . ២៤៧
ភារៈនៃសាស្ដាជាថេរៈជាអ្នកដឹងរាត្រីជាដើម . . . . ២៤៩
ភារៈនៃពួកភិក្ខុជាថេរៈជាអ្នកឆ្លៀវឆ្លាសជាដើម . . . . ២៥៥
ព្រហ្មចារ្យបរិបូណ៌ទាំងអស់ . . . . . . . . ២៥៧
ពោលអំពីអភិញ្ញាទេសិតធម៌ . . . . . . . . ២៥៩
ធម្មភាសិតរបស់សង្ឃជាសព្រហ្មចារី . . . . . . ២៦១
ការទ្រង់អនុញ្ញាតបច្ច័យមានចីវរបច្ច័យជាដើម . . . . ២៦៥

អង្ក

បាសាទិកសុត្តេ ចត្តារោ សុខល្លិកានុយោគា . . . . ២៦៧

ចត្តារោ សុខល្លិកានុយោគានិសំសា . . . ២៧១

នវឋានានជ្ឈាចរណំ . . . . . . ២៧៣

ព្យាកតាព្យាកតបញ្ហា . . . . . . ២៧៤

អព្យាកតបញ្ហា . . . . . . ២៧៧

បុព្វន្តសហគតាទិកា ទិដ្ឋិនិស្សយា . . . ២៨១

សមណព្រាហ្មណានំ អធិប្បញ្ញត្តិ . . . ២៨៣

ចត្តារោ សតិបដ្ឋានា . . . . . . ២៨៩

បាសាទិកោ ធម្មបរិយាយោ . . . ២៩១

លេខទំព័រ

បាសាទិកសូត្រ សុខល្លិកានុយោគ ៤ យ៉ាង . . . . . . . . . . . ២៦៧
អានិសង្សនៃសុខល្លិកានុយោគ ៤ យ៉ាង . . . . . . . . ២៧១
ការឈប់ប្រព្រឹត្តិកន្លងហេតុទាំង ៩ យ៉ាង . . . . . . . ២៧៣
ប្រស្នាដែលព្រះតថាគតទ្រង់ព្យាករនិងមិនទ្រង់ព្យាករ . . . . ២៧៤
ប្រស្នាដែលព្រះតថាគតមិនទ្រង់ព្យាករ . . . . . . . ២៧៧
ទិដ្ឋិនិស្ស័យដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើមជាដើម . . . ២៨១
អធិប្បញ្ញត្តិនៃសមណព្រាហ្មណ៍ទាំងឡាយ . . . . . . ២៨៣
សតិបដ្ឋានទាំង ៤ . . . . . . . . . . . . ២៨៥
ធម្មបរិយាយគួរជាទីជ្រះថ្លា . . . . . . . . . . ២៩១

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រជ្ជុលេខាយំ |
|---|---|---|---|
| អប នូនាហំ | អបិ នូនាហំ | ៣ | ១៣ |
| កាលកញា | កាលកញ្ញា | ១៣ | ១៩ |
| ពីរណតមកោ | ពីរណត្ថម្ភកោ | ,, | ,, |
| សារូធុចោ | សាធុរូចោ | ២១ | ១៧ |
| បនតិ | បនាតិ | ៤១ | ,, |
| បដ្ឋា | បុដ្ឋា | ៦២ | ៩ |
| នតិវេលំ | នាតិវេលំ | ៦៣ | ១៧ |
| វសោ | វុសោ | ៦៦ | ១២ |
| តុណីភូតោ | តុណ្ហីភូតោ | ១០៥ | ១៣ |
| បច្ចន្តិ( ) | បច្ចន្តិ(១) | ១២៩ | ៨ |
| ចាបកាយំ | ចាបកានំ | ១៨៤ | ៦ |
| ហី | ហិ | ១៩២ | ៨ |
| អនញ្ញាសំ | អនេញ្ញាសិ | ,, | ១៧ |
| ទុច្ចរិតរណំ | ទុច្ចរិតចរណំ | ១៩៣ | ១ |
| សុត្ចោ | សុត្តោ | ,, | ១២ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| សុខត្តន្តបិដក | សុត្តន្តបិដក | ៣០ | ១ |
| កាន់អាកម | កាន់អាកម | ៣១ | " |
| នៃបុរស | នៃបុរស | ៣៣ | ១៣ |
| នៅនៃ | នៅតែ | ៣៧ | ៩ |
| គប្យុត | ប្យុត | ៥៤ | ១៤ |
| មនោបទោស់កា | មនោបទោសិកា | ៦៤ | ២ |
| លីខ្ញុំ | លើខ្ញុំ | ៧០ | ៣ |
| តាំអាគារៈ | តាំងអាគារៈ | ១០០ | ៤ |
| ដែលខបាន | ដែលបាន | ១២៩ | ៨ |
| បគ្គល | បុគ្គល | ១៥០ | ១០ |
| ព្រាហ្មណី | ព្រាហ្មណ៍ | ១៦៤ | ៩ |
| ជាអ្នង | ជាអ្នក | ១៦៦ | ៣ |
| ឧបបាតិក | ឧបបាតិក | ១៧០ | ១៧ |
| ប្រាជក | ប្រាកដ | ១៧៦ | ៨ |
| ពួសត្វ | ពួកសត្វ | ១៧៩ | ៧ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | វត្ថុលេខាយំ |
|---|---|---|---|
| បរិជញ្ញាតិ | បរិជិញ្ញាតិ | ១៩៦ | ១៨ |
| (៧៨) | (៧៥) | ២០៥ | ២ |
| បរិជិញ្ញាយិ | បរិជិញ្ញាយី | ២១៨ | ១០ |
| ចេ | ច | ២៤៣ | ១៥ |
| អបិកេ | អបកេ | ២៦១ | ៩ |
| ចជ្ជ | ចុជ្ជ | ២៦៨ | ១៨ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ក្នវេលា | ក្នងវេលា | ១៨៤ | ១៧ |
| ដោយសុខធម៌ | ដោយខុសធម៌ | ១៨៩ | ២ |
| ផ្សង ៗ | ផ្សេង ៗ | ១៩០ | ៤ |
| វែង | វែង | ១៩៩ | ១៥ |
| ហួល | ហួស | ២៣២ | ៨ |
| បាសាទី | បាសាទិ | ២៤៣ | ១ |
| បាង | បាន | ២៤៦ | ៤ |
| ប្រសិបើ | ប្រសិនបើ | ២៤៩ | ១២ |
| បានតែ | មានតែ | ២៥២ | ៣ |
| បាំនសម្លៀក | មានសម្លៀក | " | ៤ |
| នេះហៅថា | នេះហៅថា | ២៥៨ | ៦ |
| បិណ្ឌបាទ | បិណ្ឌបាត | ២៦៥ | ៤ |
| បន្ទ | បុន្ទ | ២៦៨ | ១១ |
| ហៅបា | ហៅបាន | ២៧១ | ១៨ |

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE